# សុត្តន្តបិដក





២២

# SUTTANTA PITAKA

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# មជ្ឈិមនិកាយ មូលបណ្ណាសក
# តតិយភាគ
# ២២



ផ្សព្វផ្សាយដោយសម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្ដេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

## MAJJHIMANIKĀYA

## MŪLAPAṆṆĀSAKA

## TATIYABHĀGA

## 22

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំថ្វាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នាកត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមកក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណាក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមានឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមានការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាភិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

# ទំព័រទទេ

# សេចក្តីណែនាំក្នុងការអាន

១ ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយគំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរ: **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ ល គឺជាជើងរបស់ព្យញ្ជនៈ ម ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្ស** គឺ **តស្ស** ។

២ ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣ ចំពោះ **សន្ទឹកច្បាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## មជ្ឈិមនិកាយ មូលបណ្ណាសក

## តតិយភាគ

២២

ព. ស. ២៥០៤

# មហាយមកវគ្គោ

## បឋមំ ចូឡគោសិង្គសាលសុត្តំ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ញាតិកេ វិហរតិ គិញ្ជកាវសថេ ។ តេន ខោ បន សមយេន អាយស្មា ច អនុរុទ្ធោ អាយស្មា ច នន្ទិយោ អាយស្មា ច កិមិលោ[១] គោសិង្គសាល-វនទាយេ វិហរន្តិ ។ អថខោ ភគវា សាយណ្ហ-សមយំ បដិសល្លានា វុដ្ឋិតោ យេន គោសិង្គ-សាលវនទាយោ តេនុបសង្កមិ ។ អទ្ទសា ខោ ទាយបាលោ ភគវន្តំ ទូរតោ វ គច្ឆន្តំ ទិស្វាន ភគវន្តំ ឯតទវោច មា សមណ ឯតំ ទាយំ បាវិសិ សន្តេត្ថ តយោ កុលបុត្តា អត្តកាមរូបា វិហរន្តិ មា តេសំ អផាសុមកាសីតិ ។ អស្សោសិ ខោ អាយស្មា អនុរុទ្ធោ ទាយបាលស្ស ភគវតា សទ្ធឹ មន្តយមានស្ស សុត្វាន ទាយបាលំ ឯតទ-វោច មា អាវុសោ ទាយបាល ភគវន្តំ វារេសិ

១ កិម្ពិលោតិប្យត្តិ ។

# មហាយមកវគ្គ

## ចូឡគោសិង្គសាលសូត្រ ទី ១

[១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងព្រះពន្លាឥដ្ឋ ទៀបនាទិកគ្រាម ។ សម័យនោះឯង ព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ នៅក្នុងព្រៃឈ្មោះគោសិង្គសាលវ័ន[១] ។ គ្រានោះ ព្រះមានព្រះភាគចេញចាកទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅក្នុងព្រៃគោសិង្គ-សាលវ័ននោះ ។ អ្នករក្សាព្រៃ បានឃើញព្រះមានព្រះភាគកំពុងស្តេចទៅអំពីចម្ងាយ លុះឃើញហើយ ក៏និយាយនឹងព្រះមានព្រះភាគយ៉ាងនេះថា នែសមណៈ សូមលោកកុំចូលទៅក្នុងព្រៃនុ៎ះឡើយ ព្រោះក្នុងព្រៃនុ៎ះ មានកុលបុត្ត ៣ រូប ជាអ្នកប្រាថ្នានូវប្រយោជន៍បម្រុងខ្លួន សូមលោកកុំធ្វើ នូវសេចក្តីអផ្សុក ដល់កុលបុត្តទាំងនោះឡើយ ។ ព្រះអនុរុទ្ធមានអាយុ បានឮពាក្យអ្នករក្សាព្រៃ កំពុងជជែកនឹងព្រះមានព្រះភាគ លុះឮហើយ ក៏បាននិយាយនឹងអ្នករក្សាព្រៃយ៉ាងនេះថា ម្នាលអ្នករក្សាព្រៃដ៏មានអាយុ អ្នកកុំឃាត់ព្រះមានព្រះភាគឡើយ ព្រោះព្រះ

១ ពាក្យថា គោសិង្គសាលវ័ននេះ ជាឈ្មោះព្រៃដែលអាស្រ័យនឹងឈើធំ ១ ដើម ដុះប្រគាបចេញ មានសណ្ឋានដូចស្នែងគោ ។

សត្ថា នោ ភគវា អនុប្បត្តោតិ ។ អថខោ អាយស្មា អនុរុទ្ធោ យេនាយស្មា ច នន្ទិយោ អាយស្មា ច កិមិលោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តញ្ច នន្ទិយំ អាយស្មន្តញ្ច កិមិលំ ឯតទវោច អភិក្កមថា-យស្មន្តោ អភិក្កមថាយស្មន្តោ សត្ថា នោ ភគវា អនុប្បត្តោតិ ។ អថខោ អាយស្មា ច អនុរុទ្ធោ អាយស្មា ច នន្ទិយោ អាយស្មា ច កិមិលោ ភគវន្តំ បច្ចុគ្គន្ត្វា ឯកោ ភគវតោ បត្តចីវរំ បដិគ្គហេសិ ឯកោ អាសនំ បញ្ញាបេសិ ឯកោ បាទោទកំ ឧបដ្ឋបេសិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ និសជ្ជ[1] បាទេ បក្ខាលេសិ ។ តេបិ ខោ អា-យស្មន្តោ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។

[២] ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អនុរុទ្ធំ ភគវា ឯតទវោច កច្ចិ វោ[2] អនុរុទ្ធា ខមនីយំ កច្ចិ យាបនីយំ កច្ចិ បិណ្ឌកេន ន កិលមិត្ថាតិ[3] ។

---

១ ឱ. ម. ឯត្តន្តរេ ខោ ភគវាតិ ទិស្សតិ ។ ២ កត្ថចិ បោត្ថកេ តេតិ ទិស្សតិ ។ ៣ ឱ. កិលមថាតិ ។

មានព្រះភាគជាសាស្តាចារ្យរបស់យើង ទ្រង់ស្តេចមកដល់ហើយ ។ លំដាប់នោះ ព្រះអនុរុទ្ធមានអាយុ ក៏ចូលទៅរកព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងព្រះនន្ទិយៈមានអាយុផង ព្រះកិមិលៈមានអាយុផង យ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ ចូរលោកមកនេះ ម្នាលលោកមានអាយុទាំង-ឡាយ ចូរលោកមកនេះ ព្រះមានព្រះភាគជាបរមគ្រូនៃយើង ព្រះអង្គស្តេចមកដល់ហើយ ។ គ្រានោះ ព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ ក្រោកទទួលព្រះមានព្រះភាគមួយអង្គ ទទួលបាត្រនិងចីវរ របស់ព្រះមានព្រះភាគ មួយអង្គក្រាលអាសនៈ មួយអង្គទៀត តម្កល់ទឹកទុកសម្រាប់លាងព្រះបាទ ។ ព្រះមានព្រះភាគក៏គង់លើអាសនៈដែលភិក្ខុក្រាលថ្វាយ លុះគង់រួចក៏ទ្រង់ឲ្យលាងព្រះបាទ ។ ចំណែកព្រះថេរៈមានអាយុទាំងនោះ នាំគ្នាថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។

[២] ព្រះមានព្រះភាគ បានត្រាស់នឹងព្រះអនុរុទ្ធមានអាយុ ដែលអង្គុយក្នុងទីដ៏សមគួរហើយ យ៉ាងនេះថា ម្នាលអនុរុទ្ធទាំងឡាយ[១] អ្នកទាំងឡាយល្មមអត់ធន់បានឬទេ អ្នកទាំងឡាយល្មមប្រព្រឹត្តទៅបានស្រួលឬទេ អ្នកទាំងឡាយមិនលំបាកដោយអាហារបិណ្ឌបាតទេឬ ។

---

១ ពាក្យថា អនុរុទ្ធទាំងឡាយ ជាវោហារហៅរួបដល់ព្រះនន្ទិយៈ និងព្រះកិមិលៈផង ។

៣

មហាយមកវគ្គស្ស ចូឡគោសិង្គសាលសុត្តេ បដិសន្ថារវុត្តិ

ខមនីយំ ភគវា យាបនីយំ ភគវា ន ច មយំ ភន្តេ បិណ្ឌកេន កិលមិម្ហាតិ ។ កច្ចិ បន វោ អនុរុទ្ធា សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរថាតិ ។ តគ្ឃ មយំ ភន្តេ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរាមាតិ ។ យថាកថំ បន តុម្ហេ អនុរុទ្ធា សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរថាតិ ។

[៣] ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ លាភា វត មេ សុលទ្ធំ វត មេ យោហំ ឯវរូបេហិ សព្រហ្មចារីហិ សទ្ធឹ វិហរាមីតិ តស្ស មយ្ហំ ភន្តេ ឥមេសុ អាយស្មន្តេសុ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ

ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទាំង-ឡាយ ល្មមអត់ធន់បាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយ ល្មមប្រព្រឹត្តទៅបានស្រួល សូមទ្រង់ព្រះមេត្តាប្រោស មួយទៀត ខ្ញុំព្រះអង្គទាំងឡាយ មិនបានលំបាកដោយបិណ្ឌបាតទេ ។ ម្នាលអនុរុទ្ធទាំង-ឡាយ ចុះអ្នកទាំងឡាយព្រមព្រៀង ស្រុះស្រួល មិនទាស់ទែងគ្នា ដូចជាទឹកដោះលាយទឹក រមិលមើលគ្នាទៅវិញទៅមក ដោយចក្ខុគួរឲ្យស្រ-ឡាញ់ទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ ជាអ្នកព្រមព្រៀង ស្រុះស្រួល មិនទាស់ទែងគ្នា ដូចទឹកដោះលាយទឹក រមិលមើលគ្នាទៅវិញទៅមក ដោយចក្ខុគួរឲ្យស្រឡាញ់តែម្យ៉ាង ។ ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយ ព្រមព្រៀង ស្រុះស្រួល មិនទាស់ទែងគ្នា ដូចទឹកដោះលាយទឹក រមិលមើលគ្នាទៅវិញទៅមក ដោយចក្ខុគួរឲ្យស្រឡាញ់ដូចម្តេចខ្លះ ។

[៣] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះ ក្នុងទីនេះ យ៉ាងនេះថា អាត្មាអញពេញហៅមានលាភ អាត្មាអញពេញហៅបានស្រួល ត្រង់ដែលអាត្មាអញ នៅជាមួយនឹងពួកសព្រហ្មចារីមានសភាពយ៉ាងនេះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះបានតាំងកាយកម្មប្រកបដោយមេត្តា ទៅរកលោកមានអាយុទាំងនេះ

អាវី ចេវ រហោ ច មេត្តំ វចីកម្មំ... មេត្តំ មនោកម្មំ បច្ចុបដ្ឋិតំ អាវី ចេវ រហោ ច តស្ស មយ្ហំ ភន្តេ ឯវំ ហោតិ យន្នូនាហំ សកំ ចិត្តំ និក្ខិបិត្វា ឥមេសំយេវ អាយស្មន្តានំ ចិត្តស្ស វសេន វត្តេយ្យន្តិ សោ ខោ អហំ ភន្តេ សកំ ចិត្តំ និក្ខិបិត្វា ឥមេសំយេវ អាយស្មន្តានំ ចិត្តស្ស វសេន វត្តាមិ នានា ហិ ខោ នោ ភន្តេ កាយា ឯកញ្ច បន មញ្ញេ ចិត្តន្តិ ។ អាយស្មាបិ ខោ នន្ទិយោ ។ បេ ។ អាយស្មាបិ ខោ កិមិលោ ភគវន្តំ ឯតទវោច ឥធ មយ្ហម្បិ ខោ ភន្តេ ឯវំ ហោតិ លាភា វត មេ សុលទ្ធំ វត មេ យោហំ ឯវរូបេហិ សព្រហ្មចារីហិ សទ្ធឹ វិហរាមីតិ តស្ស មយ្ហំ ភន្តេ ឥមេសុ អាយស្មន្តេសុ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ អាវី ចេវ រហោ ច មេត្តំ វចីកម្មំ... មេត្តំ មនោកម្មំ បច្ចុបដ្ឋិតំ

ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ តាំងវចីកម្ម ប្រកបដោយមេត្តា តាំងមនោកម្ម ប្រកបដោយមេត្តា ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា បើដូច្នោះគួរតែ អាត្មាអញដាក់ចិត្ត របស់ខ្លួន ឲ្យប្រព្រឹត្តទៅតាមអំណាច នៃចិត្តរបស់លោកមានអាយុទាំងនេះឯង ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ ក៏ដាក់ចិត្តរបស់ខ្លួន ឲ្យប្រព្រឹត្តទៅតាមអំណាចនៃចិត្ត របស់លោកមានអាយុទាំងនេះឯង បពិត្រព្រះអង្គដ៏ចម្រើន តាមពិតកាយ របស់ខ្ញុំព្រះអង្គទាំងឡាយទីទៃពីគ្នាមែន ប៉ុន្តែចិត្តមានទំនងជាមួយគ្នា ។ ចំណែកនន្ទិយៈមានអាយុ ។ បេ ។ ចំណែកកិមិលៈមានអាយុ បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គក៏មានសេចក្តីត្រិះរិះ ក្នុងទីនេះ យ៉ាងនេះថា អាត្មាអញពេញជាមានលាភ អាត្មាអញពេញជាបានស្រួលហើយ ត្រង់ដែលអាត្មាអញនៅជាមួយនឹងពួកសព្រហ្មចារី មានសភាពយ៉ាងនេះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ បានតាំងកាយកម្ម ប្រកបដោយមេត្តាទៅរកលោកមានអាយុទាំងនេះ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ តាំងវចីកម្មប្រកបដោយមេត្តា... តាំងមនោកម្មប្រកបដោយ

អាវី ចេវ រហោ ច តស្ស មយ្ហំ ភន្តេ ឯវំ ហោតិ យន្នូនាហំ សកំ ចិត្តំ និក្ខិបិត្វា ឥមេសំយេវ អាយស្មន្តានំ ចិត្តស្ស វសេន វត្តេយ្យន្តិ សោ ខោ អហំ ភន្តេ សកំ ចិត្តំ និក្ខិបិត្វា ឥមេសំយេវ អា-យស្មន្តានំ ចិត្តស្ស វសេន វត្តាមិ នានា ហិ ខោ នោ ភន្តេ កាយា ឯកញ្ច បន មញ្ញេ ចិត្តន្តិ ។ ឯវំ ខោ មយំ ភន្តេ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរាមាតិ ។

[៤] សាធុ សាធុ អនុរុទ្ធា កច្ចិ បន វោ អនុរុទ្ធា អប្បមត្តា អាតាបិនោ បហិតត្តា វិហរថាតិ ។ តគ្ឃ មយំ ភន្តេ អប្បមត្តា អាតាបិនោ បហិតត្តា វិហ-រាមាតិ ។ យថាកថំ បន តុម្ហេ អនុរុទ្ធា អប្បមត្តា

មេត្តា ទាំងទីចំពោះមុខ និងទីកំបាំងមុខ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញដាក់ចិត្តរបស់ខ្លួន ឲ្យប្រព្រឹត្តទៅតាមអំណាចចិត្ត របស់លោកមានអាយុទាំងនេះឯង ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ ក៏ដាក់ចិត្តរបស់ខ្លួន ឲ្យប្រព្រឹត្តទៅតាមអំណាចនៃចិត្ត របស់លោកមានអាយុទាំងនេះឯង បពិត្រព្រះអង្គដ៏ចម្រើន តាមពិត កាយរបស់យើងខ្ញុំព្រះអង្គទីទៃពីគ្នាមែន ប៉ុន្តែចិត្តមានទំនងជាមួយគ្នា ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គ ព្រមព្រៀង ស្រុះស្រួល មិនទាស់ទែងគ្នា ដូចទឹកដោះលាយទឹក រមិលមើលគ្នាទៅវិញទៅមក ដោយចក្ខុគួរឲ្យស្រឡាញ់ យ៉ាងនេះឯង ។

[៤] ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំង-ឡាយ ចុះអ្នកទាំងឡាយមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ខ្លះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គសុទ្ធតែជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន តែមួយចំណែក ។ ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយជាអ្នកមិនប្រមាទ

អាតាបិនោ បហិតត្តា វិហរថាតិ ។ ឥធ បន[១] ភន្តេ អម្ហាកំ យោ បឋមំ គាមតោ បិណ្ឌាយ បដិក្កមតិ សោ អាសនានិ បញ្ញាបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋបេតិ អវក្ការបាតឹ ឧបដ្ឋបេតិ យោ បច្ឆា គាមតោ បិណ្ឌាយ បដិក្កមតិ សចេ ហោតិ ភុត្តាវសេសោ សចេ អាកង្ខតិ ភុញ្ជតិ នោ ចេ អាកង្ខតិ អប្បហរិតេ វា ឆឌ្ឌេតិ អប្បាណកេ វា ឧទកេ ឱបិលាបេតិ សោ អាសនានិ បដិសាមេតិ បានីយំ បរិភោជនីយំ បដិ-សាមេតិ អវក្ការបាតឹ បដិសាមេតិ ភត្តគ្គំ សម្មជ្ជតិ យោ បស្សតិ បានីយឃដំ វា បរិភោជនីយឃដំ វា វច្ចឃដំ វា រិត្តំ តុច្ឆំ សោ ឧបដ្ឋបេតិ សចស្ស ហោតិ អវិសយ្ហំ ហត្ថវិការេន ទុតិយំ អាមន្តេត្វា ហត្ថវិលង្ឃិកេន[២] ឧបដ្ឋបេម ន ត្វេវ មយំ ភន្តេ តប្បច្ចយា វាចំ ភិន្ទាម

១ ឱ. ម. បនាតិ ន ទិស្សតិ ។ ២ ឱ. ម. ហត្ថវិលង្គកេន ។

មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន យ៉ាងណាខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាយើងខ្ញុំព្រះអង្គ ក្នុងទីនេះ លោកណាត្រឡប់ពីបិណ្ឌបាតអំពីស្រុកមុនគេ លោកនោះ ក៏រៀបក្រាលអាសនៈ តម្កល់ទឹកឆាន់ និងទឹកសម្រាប់ប្រើប្រាស់ តម្កល់ទុកនូវភាជន៍សម្រាប់រំលែកបិណ្ឌបាតដែលមានច្រើន លោកណាត្រឡប់ពីបិណ្ឌបាត អំពីស្រុកក្រោយគេ បើមានភត្តដ៏សេសសល់អំពីភត្ត ដែលលោកអង្គណាបរិភោគហើយ បើចង់បរិភោគ ក៏បរិភោគទៅ បើមិនចង់បរិភោគទេ ក៏ចាក់ចោលក្នុងទីដែលប្រាសចាកតិណជាតិមានពណ៌ខៀវ ឬចាក់ចោលក្នុងទឹក ដែលប្រាសចាកសត្វ ភិក្ខុនោះទុកដាក់អាសនៈ ទុកដាក់ទឹកសម្រាប់ឆាន់ និងទឹកសម្រាប់ប្រើប្រាស់ ទុកដាក់ភាជន៍សម្រាប់ផ្ទេរបិណ្ឌបាត និងបោសសម្អាតរោងភត្ត លោកណាឃើញក្អមសម្រាប់ដាក់ទឹកឆាន់ ក្អមដាក់ទឹកប្រើប្រាស់ឬក្អមសម្រាប់ដាក់ទឹកទុកក្នុងវច្ចកុដិ មានទឹកតិច ឬទទេ ភិក្ខុនោះតែងដង (ទឹកទុក) បើភិក្ខុនោះ មិនអាចនឹងលើកភារៈនោះរួចទេ ក៏ហៅភិក្ខុជាគម្រប់ពីរមកដោយវិការៈនៃដៃ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទុកដាក់ដោយការជួយគ្នាដោយដៃ មិនបាច់បញ្ចេញវាចា ព្រោះកិច្ចការនោះជាបច្ច័យ

៧



បញ្ចាហិកំ ខោ បន មយំ ភន្តេ សព្វរត្តិកំ[1] ធម្មិយា កថាយ សន្និសីទាម ឯវំ ខោ មយំ ភន្តេ អប្បមត្តា អាតាបិនោ បហិតត្តា វិហរាមាតិ ។

[៤] សាធុ សាធុ អនុរុទ្ធា អត្ថិ បន វោ អនុរុទ្ធា ឯវំ អប្បមត្តានំ អាតាបីនំ បហិតត្តានំ វិហរតំ ឧត្តរិ[2] មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោតិ ។ កឹ ហិ នោ សិយា ភន្តេ ឥធ មយំ ភន្តេ យាវទេវ អាកង្ខាម វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរាម អយំ ខោ នោ ភន្តេ អម្ហាកំ អប្បមត្តានំ អាតាបីនំ បហិតត្តានំ វិហរតំ ឧត្តរិ មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោតិ ។ សាធុ សាធុ អនុរុទ្ធា

---

១ ឱ. សព្វរត្តិយា ។ ២ ឱ. ឧត្តរឹ ។

ឡើយ បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត យើងខ្ញុំព្រះអង្គ តែង អង្គុយប្រជុំគ្នាដោយធម្មីកថា ពេញមួយយប់ រាល់ថ្ងៃទី ៥ បពិត្រព្រះអង្គ ដ៏ចម្រើន យើងខ្ញុំព្រះអង្គ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុត កម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន យ៉ាងនេះ ។

[៥] ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ចុះផាសុវិហារធម៌ (ធម៌ ជាទីនៅសប្បាយ) ដ៏វិសេសគឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈ បាន ក្រៃលែងជាងមនុស្សធម៌ ដែលលោកទាំងឡាយ ជាអ្នកមិនប្រមាទ មានព្យាយាម មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បានត្រាស់ដឹងយ៉ាង នេះហើយ មានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះ ដែលយើងខ្ញុំព្រះអង្គបានត្រាស់ដឹងហើយ ថ្វីក៏មិនមាន បពិត្រព្រះអង្គ ដ៏ចម្រើន ព្រោះថា ក្នុងទីនេះ យើងខ្ញុំព្រះអង្គប្រាថ្នាស្ងាត់ចាកកាមទាំង- ឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ជាកំណត់ ក៏បានចូលបឋម- ជ្ឈាន ដែលប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខដែលកើតអំពី វិវេក បពិត្រព្រះអង្គដ៏ចម្រើន នេះឯង ជាផាសុវិហារធម៌ ជាធម៌វិសេសគឺ ញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈបាន ដ៏ក្រៃលែងជាងមនុស្សធម៌ ដែលយើងខ្ញុំព្រះអង្គជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បានត្រាស់ដឹងហើយ ។ ម្នាលអនុរុទ្ធ

៨



ឯតស្ស បន វោ អនុរុទ្ធា វិហារស្ស សមតិក្កមាយ ឯតស្ស វិហារស្ស បដិប្បស្សទ្ធិយា អត្ថញ្ញោ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោតិ ។ កឹ ហិ នោ សិយា ភន្តេ ឥធ មយំ ភន្តេ យាវទេវ អាកង្ខាម វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរាម ឯតស្ស ភន្តេ វិហារស្ស សមតិក្កមាយ ឯតស្ស វិហារស្ស បដិប្បស្សទ្ធិយា អយមញ្ញោ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោតិ ។ សាធុ សាធុ អនុរុទ្ធា ឯតស្ស បន វោ អនុរុទ្ធា វិហារស្ស សមតិក្កមាយ ឯតស្ស វិហារស្ស បដិប្បស្សទ្ធិយា អត្ថញ្ញោ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោតិ ។ កឹ ហិ នោ សិយា ភន្តេ

ទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះ ផាសុវិហារធម៌ ជាធម៌វិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈ ដ៏ក្រៃលែង ជាងមនុស្សធម៌ដទៃទៀត ដែលអ្នកទាំងឡាយត្រាស់ដឹងហើយ ដើម្បី កន្លងនូវផាសុវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវផាសុវិហារធម៌នុ៎ះ មានដែរ ឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះ ថ្វីក៏មិនមាន បពិត្រ ព្រះអង្គដ៏ចម្រើន ព្រោះថា ក្នុងទីនេះ យើងខ្ញុំព្រះអង្គប្រាថ្នាឲ្យស្ងប់រម្ងាប់នូវ វិតក្កៈនិងវិចារៈ ជាកំណត់ ក៏បានចូលទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុង សន្តានរបស់ខ្លួន ប្រកបដោយសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមាន វិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសមាធិ បពិត្រ ព្រះអង្គដ៏ចម្រើន នេះជាផាសុវិហារធម៌ ជាធម៌វិសេសគឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលយើងខ្ញុំ ព្រះអង្គបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវ វិហារធម៌នុ៎ះ ។ ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំង-ឡាយ ចុះ ផាសុវិហារធម៌ ជាធម៌វិសេសគឺញាណទស្សនៈ អាចធ្វើខ្លួន ឲ្យជាអរិយៈ ដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលអ្នកទាំងឡាយ បានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ មានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះ ថ្វីក៏មិនមាន

៩



ឥធ មយំ ភន្តេ យាវទេវ អាកង្ខាម បីតិយា ច វិរាគា ឧបេក្ខកា ច វិហរាម សតា ច សម្បជានា សុខញ្ច កាយេន បដិសំវេទេម យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរាម ឯតស្ស ភន្តេ វិហារស្ស សមតិក្កមាយ ឯតស្ស វិហារស្ស បដិប្បស្សទ្ធិយា អយមញ្ញោ ឧត្តរិ មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោតិ ។ សាធុ សាធុ អនុរុទ្ធា ឯតស្ស បន វោ អនុរុទ្ធា វិហារស្ស សមតិក្កមាយ ឯតស្ស វិហារស្ស បដិប្បស្សទ្ធិយា អត្ថញ្ញោ ឧត្តរិ មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោតិ ។ កឹ ហិ នោ សិយា ភន្តេ ឥធ មយំ ភន្តេ យាវទេវ អាកង្ខាម សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា

បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ក្នុងទីនេះ យើងខ្ញុំព្រះអង្គប្រាថ្នាប្រាកដ យើងខ្ញុំព្រះអង្គក៏ប្រាសចាកបីតិ មានតែឧបេក្ខានិងសតិសម្បជញ្ញៈ ទទួលនូវសេចក្តីសុខដោយកាយ បានដល់តតិយជ្ឈាន ដែលព្រះអរិយបុគ្គលទាំងឡាយ សំដែងថា បុគ្គលប្រកបដោយតតិយជ្ឈាន ជាអ្នកមានឧបេក្ខា មានសតិនៅជាសុខនោះ បពិត្រព្រះអង្គដ៏ចម្រើន នេះជាផាសុវិហារធម៌ ជាធម៌វិសេសគឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលយើងខ្ញុំព្រះអង្គបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ ។ ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះ ផាសុ-វិហារធម៌ ជាធម៌វិសេសគឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលអ្នកទាំងឡាយបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ មានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះ ថ្វីក៏មិនមាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ក្នុងទីនេះ យើងខ្ញុំព្រះអង្គប្រាថ្នាជាប្រាកដ យើងខ្ញុំព្រះអង្គបានលះសុខផង លះទុក្ខផង រំលត់នូវសោមនស្សនិងទោមនស្ស អំពីមុន

អទុក្ខមសុខំ ឧបេក្ខាសតិចារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរាម ឯតស្ស ភន្តេ វិហារស្ស សមតិក្កមាយ ឯតស្ស វិហារស្ស បដិប្បស្សទ្ធិយា អយមញ្ញោ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោតិ ។ សាធុ សាធុ អនុរុទ្ធា ឯតស្ស បន វោ អនុរុទ្ធា វិហារស្ស សមតិក្កមាយ ឯតស្ស វិហារស្ស បដិប្បស្សទ្ធិយា អត្ថញ្ញោ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោតិ ។ កឹ ហិ នោ សិយា ភន្តេ ឥធ មយំ ភន្តេ យាវទេវ អាកង្ខាម សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ[១] អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរាម ឯតស្ស ភន្តេ វិហារស្ស សមតិក្កមាយ ឯតស្ស វិហារស្ស បដិប្បស្សទ្ធិយា អយមញ្ញោ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោតិ ។

១ ឱ. ឯត្ថន្តរេ អត្ថង្គមា នានត្តសញ្ញានន្តិ ទិស្សតិ ។

ផង ក៏បានដល់ចតុត្ថជ្ឈាន ដែលមិនមានទុក្ខ មិនមានសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា បពិត្រព្រះអង្គដ៏ចម្រើន នេះជាផាសុវិហារធម៌វិសេសគឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលយើងខ្ញុំព្រះអង្គបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ ។ ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយម្នាលអនុរុទ្ធទាំងឡាយ ចុះ ផាសុវិហារធម៌ ជាធម៌វិសេសគឺញាណ-ទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈ ដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀតដែលពួកអ្នកបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ មានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះឬថីក៏មិនមាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាក្នុងទីនេះ យើងខ្ញុំព្រះអង្គប្រា-ថ្នាជាប្រាកដ យើងខ្ញុំព្រះអង្គ កន្លងនូវពួករូបសញ្ញា មិនធ្វើទុកក្នុងចិត្តនូវពួកបដិឃសញ្ញា ដោយប្រការទាំងពួង ក៏ចូលអាកាសានញ្ចាយតនជ្ឈានដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើននេះជាផាសុវិហារធម៌ ជាធម៌វិសេសគឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈ ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលយើងខ្ញុំព្រះអង្គបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ

១១

មហាយមកវគ្គស្ស ចូឡគោសិង្គសាលសុត្តេ ផាសុវិហារោ

សាធុ សាធុ អនុរុទ្ធា ឯតស្ស បន វោ អនុរុទ្ធា វិហារស្ស សមតិក្កមាយ ឯតស្ស វិហារស្ស បដិប្បស្សទ្ធិយា អត្ថញ្ញោ ឧត្តរិ មនុស្សធម្មា អល-មរិយញាណទស្សនវិសេសោ អធិគតោ ផាសុវិហា-រោតិ ។ កឹ ហិ នោ សិយា ភន្តេ ឥធ មយំ ភន្តេ យាវទេវ អាកង្ខាម សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរាម ។ បេ ។ សព្វសោ វិញ្ញាណញ្ចា-យតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយត-នំ ឧបសម្បជ្ជ វិហរាម ។ បេ ។ សព្វសោ អាកិញ្ចញ្ញា-យតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧប-សម្បជ្ជ វិហរាម ឯតស្ស ភន្តេ វិហារស្ស សមតិក្ក-មាយ ឯតស្ស វិហារស្ស បដិប្បស្សទ្ធិយា អយមញ្ញោ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោតិ ។ សាធុ សាធុ អនុរុទ្ធា

ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះផាសុវិហារធម៌ ជាធម៌វិសេសគឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈក្រៃលែង ជាងមនុស្សធម៌ដទៃទៀត ដែលពួកអ្នកបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ មានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះ ថ្វីក៏មិនមាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ក្នុងទីនេះ យើងខ្ញុំព្រះអង្គប្រាថ្នាជាប្រាកដ យើងខ្ញុំព្រះអង្គ ក៏បានកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង បានចូលវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ដូច្នេះ ។ បេ ។ កន្លងនូវវិញ្ញាណញ្ចាយតនៈ ដោយប្រការទាំងពួង ក៏បានចូលអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អ្វីតិចតួចក៏មិនមាន ដូច្នេះ ។ បេ ។ កន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន បពិត្រព្រះអង្គដ៏ចម្រើន នេះជាផាសុវិហារធម៌ ជាធម៌វិសេសគឺញាណទស្សនៈអាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែង ជាងមនុស្សធម៌ដទៃទៀត ដែលពួកយើងខ្ញុំព្រះអង្គបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់ នូវវិហារធម៌នុ៎ះ ។ ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ

ឯតស្ស បន វោ អនុរុទ្ធា វិហារស្ស សមតិក្កមាយ ឯតស្ស វិហារស្ស បដិប្បស្សទ្ធិយា អត្ថញ្ញោ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោតិ ។ កឹ ហិ នោ សិយា ភន្តេ ឥធ មយំ ភន្តេ យាវទេវ អាកង្ខាម សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរាម បញ្ញាយបស្ស[1] ទិស្វា អាសវា បរិក្ខីណា ហោន្តិ ឯតស្ស ភន្តេ វិហារស្ស សមតិក្កមាយ ឯតស្ស វិហារស្ស បដិប្បស្សទ្ធិយា អយមញ្ញោ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោ ។ ឥមស្មា ច មយំ ភន្តេ ផាសុវិហារា អញ្ញំ ផាសុវិហារំ ឧត្តរិតរំ វា បណីតតរំ វា ន សមនុបស្សាមាតិ ។ សាធុ សាធុ អនុរុទ្ធា ឯតស្មា អនុរុទ្ធា ផាសុវិហារា អញ្ញោ ផាសុវិហារោ ឧត្តរិតរោ វា បណីតតរោ វា នត្ថីតិ ។

---

១ ម. បញ្ញាយ ច នោ ។

ម្នាលអនុរុទ្ធទាំងឡាយ ចុះ ផាសុវិហារធម៌ ជាធម៌វិសេសគឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈ ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលពួកអ្នកបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ មានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះថ្វីក៏មិនមាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាក្នុងទីនេះ យើងខ្ញុំព្រះអង្គប្រាថ្នាជាប្រាកដ យើងខ្ញុំព្រះអង្គបានកន្លង នូវនេវសញ្ញានាសញ្ញាយតនជ្ឈានដោយប្រការទាំងពួង ក៏បានចូលសញ្ញាវេទយិតនិរោធ អាសវៈទាំងឡាយរបស់ពួកយើងខ្ញុំព្រះអង្គ ក៏អស់ទៅមិនសល់ ព្រោះបានឃើញច្បាស់ដោយវិបស្សនាបញ្ញា បពិត្រព្រះអង្គដ៏ចម្រើន នេះជាផាសុវិហារធម៌ ជាធម៌វិសេសគឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលពួកយើងខ្ញុំព្រះអង្គបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ ។ បពិត្រព្រះអង្គដ៏ចម្រើនមួយទៀត យើងខ្ញុំព្រះអង្គ មិនឃើញច្បាស់នូវផាសុវិហារធម៌ដទៃឲ្យលើសលុបជាង ឲ្យថ្លៃថ្លាជាងផាសុវិហារធម៌នេះទៅទៀតទេ ។ ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំងឡាយ ផាសុវិហារធម៌ដទៃដែលលើសលុបជាង ថ្លៃថ្លាជាងផាសុវិហារធម៌នុ៎ះទៅទៀត មិនមានទេ ។

[៦] អថខោ ភគវា អាយស្មន្តញ្ច អនុរុទ្ធំ អាយស្មន្តញ្ច នន្ទិយំ អាយស្មន្តញ្ច កិមិលំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ អាយស្មា ច អនុរុទ្ធោ អាយស្មា ច នន្ទិយោ អាយស្មា ច កិមិលោ ភគវន្តំ អនុសំយាយិត្វា តតោ បដិនិវត្តិត្វា អាយស្មា ច នន្ទិយោ អាយស្មា ច កិមិលោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោចុំ កិន្នុ ខោ មយំ អាយស្មតោ អនុរុទ្ធស្ស ឯវមារោចិម្ហា[១] ឥមាសញ្ច ឥមាសញ្ច វិហារសមាបត្តីនំ មយំ លាភិនោតិ យំ នោ អាយស្មា អនុរុទ្ធោ ភគវតោ សម្មុខា យាវ អាសវានំ ខយា បកាសេតីតិ[២] ។ ន ខោ មេ អាយស្មន្តោ ឯវមារោចេសុំ ឥមាសញ្ច ឥមាសញ្ច វិហារសមាបត្តីនំ មយំ លាភិនោតិ អបិច ខោ[៣] អាយស្មន្តានំ ចេតសា ចេតោ បរិច្ច វិទិតោ ឥមាសញ្ច ឥមាសញ្ច វិហារសមាបត្តីនំ ឥមេ អាយស្មន្តោ លាភិនោតិ

១ ឱ. ម. ឯវមារោចិម្ហ ។ ២ ឱ. បកាសេសីតិ ។ ៣ ឱ. ម. ខោសទ្ទោ ន ទិស្សតិ ។

[៦] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ពន្យល់ព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ នឹងព្រះកិមិលៈមានអាយុ ឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ទ្រង់ក្រោកអំពីអាសនៈស្តេចចេញទៅ ។ លំដាប់នោះឯង ព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ ក៏តាមហែព្រះមានព្រះភាគទៅ ហើយត្រឡប់មកអំពីទីនោះវិញ ព្រះនន្ទិយៈមានអាយុនិងព្រះកិមិលៈមានអាយុ បាននិយាយនឹងព្រះអនុរុទ្ធមានអាយុយ៉ាងនេះថា យើងទាំងឡាយ បានប្រាប់ព្រះអនុរុទ្ធមានអាយុយ៉ាងនេះថា យើងទាំងឡាយ បាននូវវិហារសមាបត្តិទាំងឡាយនេះផង នេះផងដូច្នេះដែរឬទេ បានជាព្រះអនុរុទ្ធមានអាយុប្រកាស (គុណ) របស់យើងដរាប អំពីការអស់ទៅនៃអាសវៈទាំងឡាយ ក្នុងទីចំពោះព្រះភក្រ្តនៃព្រះមានព្រះភាគ ។ ព្រះអនុរុទ្ធតបថា លោកដ៏មានអាយុទាំងឡាយ មិនបានប្រាប់ដល់ខ្ញុំយ៉ាងនេះទេថា យើងទាំងឡាយ ជាអ្នកបាននូវវិហារ-សមាបត្តិទាំងឡាយនេះផង នេះផង ដូច្នេះមែន ប៉ុន្តែខ្ញុំកំណត់ដឹងចិត្តលោកមានអាយុទាំងឡាយ ដោយចិត្តរបស់ខ្ញុំថា លោកមានអាយុទាំងឡាយនេះ បាននូវវិហារសមាបត្តិនេះផង នេះផងដូច្នេះ ទាំង

ទេវតាបិ មេ ឯតមត្ថំ អារោចេសុំ ឥមាសញ្ច ឥមាសញ្ច វិហារសមាបត្តីនំ ឥមេ អាយស្មន្តោ លាភិនោតិ តំ មេ[១] ភគវតា បញ្ហាភិបុដ្ឋេន ព្យា-កាតន្តិ ។

[៧] អថខោ ទីឃោ បរជនោ យក្ខោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវា-ទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ ទីឃោ បរជនោ យក្ខោ ភគវន្តំ ឯតទវោច លាភា ភន្តេ វជ្ជីនំ សុលទ្ធលាភា ភន្តេ វជ្ជីនំ បជាយ[២] យត្ថ តថាគតោ វិហរតិ អរហំ សម្មាសម្ពុទ្ធោ ឥមេ ច តយោ កុលបុត្តា អាយស្មា ច អនុរុទ្ធោ អាយស្មា ច នន្ទិយោ អាយស្មា ច កិមិលោតិ ។ ទីឃស្ស បរជនស្ស យក្ខស្ស សទ្ទំ សុត្វា ភុម្មា ទេវា សទ្ទមនុស្សាវេសុំ លាភា វត

១ ឱ. ម. តមេនំ ។ ២ ឱ. ម. សុលទ្ធលាភា វជ្ជិបជាយ ។

ពួកទេវតាសោត ក៏បានប្រាប់សេចក្ដីនុ៎ះដល់ខ្ញុំថា លោកមានអាយុទាំង-ឡាយនេះ បាននូវវិហារសមាបត្តិនេះផង នេះផងដូច្នេះ បានជាព្រះមានព្រះភាគ ទ្រង់ត្រាស់សួរបញ្ហាក់នូវបញ្ហា ខ្ញុំក៏បានព្យាករពាក្យនោះរួចហើយ ។

[៧] គ្រានោះឯង មានយក្សម្នាក់ ឈ្មោះទីឃបរជន ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចឋិតនៅក្នុងទីដ៏សមគួរ ។ ទីឃបរជនយក្ស ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធនិងកុលបុត្រទាំង ៣ រូបនេះ គឺព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ គង់នៅក្នុងប្រទេសណា បពិត្រព្រះអង្គដ៏ចម្រើន ប្រទេសនោះ ជាលាភរបស់ពួកអ្នកដែនវជ្ជី បពិត្រព្រះអង្គដ៏ចម្រើន ប្រទេសនោះជាលាភដែលប្រជាជនអ្នកដែនវជ្ជីបានល្អហើយ ។ ពួកភុម្មទេវតាបានឮសំឡេង របស់ទីឃបរជនយក្សហើយ ក៏ធ្វើសំឡេងលាន់ឮឡើងទៅថា អើហ្ន៎ ព្រះ

១៤

មហាយមកវគ្គស្ស ចូឡគោសិង្គសាលសុត្តេ អនុរុទ្ធាទិកិត្តិ

ភោ វជ្ជីនំ សុលទ្ធលាភា វត ភោ វជ្ជីនំ បជាយ[១] យត្ថ តថាគតោ វិហរតិ អរហំ សម្មាសម្ពុទ្ធោ ឥមេ ច តយោ កុលបុត្តា អាយស្មា ច អនុរុទ្ធោ អាយស្មា ច នន្ទិយោ អាយស្មា ច កិមិលោតិ ។ ភុម្មានំ ទេវានំ សទ្ទំ សុត្វា ចាតុម្មហារាជិកា ទេវា... តាវត្តឹសា ទេវា... យាមា ទេវា... តុសិតា ទេវា... និម្មានរតី ទេវា បរនិម្មិតវសវត្តី ទេវា ព្រហ្មកាយិកា ទេវា សទ្ទមនុស្សាវេសុំ លាភា វត ភោ វជ្ជីនំ សុលទ្ធលាភា វត ភោ វជ្ជីនំ បជាយ យត្ថ តថាគតោ វិហរតិ អរហំ សម្មាសម្ពុទ្ធោ ឥមេ ច តយោ កុលបុត្តា អាយស្មា ច អនុរុទ្ធោ អាយស្មា ច នន្ទិយោ អាយស្មា ច កិមិលោតិ ។

១ ឱ. សុលទ្ធលាភា វជ្ជិបជាយ ។

តថាគត អរហន្តសម្មាសម្ពុទ្ធ និងកុលបុត្រទាំង ៣ រូបនេះ គឺ ព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ គង់នៅក្នុងប្រទេសណា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ប្រទេសនោះ ជាលាភនៃអ្នកដែនវជ្ជី ម្នាលអ្នកទាំងឡាយដ៏ចម្រើន ប្រទេសនោះ ជាលាភដែលប្រជាជនអ្នកដែនវជ្ជីបានល្អហើយ ។ ពួកចាតុម្មហារាជិកទេវតា បានឮសំឡេងរបស់ពួកភុម្មទេវតាហើយ ... ពួកតាវត្តិង្សទេវតា ... ពួកយាមទេវតា ... ពួកតុសិតទេវតា ... ពួកនិម្មានរតីទេវតា ... ពួកបរនិម្មិតវសវត្តីទេវតា ... ពួកទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្ម ក៏បានធ្វើសំឡេងឲ្យលាន់ឮឡើងថា អើហ្ន៎ ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ និងកុលបុត្រទាំង ៣ រូបនេះ គឺ ព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ គង់នៅក្នុងប្រទេសណា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ប្រទេសនោះ ជាលាភរបស់ពួកអ្នកដែនវជ្ជី ម្នាលអ្នកទាំងឡាយដ៏ចម្រើន ប្រទេសនោះ ជាលាភដែលប្រជាជន អ្នកដែនវជ្ជីបានល្អហើយ ។

[៨] ឥតិហ តេន[១] ខណេន[២] តេន មុហុត្តេន យាវ ព្រហ្មលោកា សទ្ទា[៣] វិទិតា អហេសុំ ឯវមេតំ ទីឃ ឯវមេតំ ទីឃ យស្មាបិ ទីឃ កុលា ឯតេ តយោ កុលបុត្តា អគារស្មា អនគារិយំ បព្វជិតា តញ្ចេបិ កុលំ ឯតេ តយោ កុលបុត្តេ បសន្នចិត្តំ អនុស្សរេយ្យ តស្សបស្ស កុលស្ស ទីឃរត្តំ ហិតាយ សុខាយ យស្មាបិ ទីឃ កុលបរិវដ្ដា ឯតេ តយោ កុលបុត្តា អគារស្មា អនគារិយំ បព្វជិតា សោ ចេបិ កុលបរិវដ្ដោ ឯតេ តយោ កុលបុត្តេ បសន្នចិត្តោ អនុស្សរេយ្យ តស្សបស្ស កុលបរិវដ្ដស្ស ទីឃរត្តំ ហិតាយ សុខាយ យស្មាបិ ទីឃ គាមា ឯតេ តយោ កុលបុត្តា អគារស្មា អនគារិយំ បព្វជិតា សោ ចេបិ គាមោ ឯតេ តយោ កុលបុត្តេ បសន្នចិត្តោ អនុស្សរេយ្យ តស្សបស្ស គាមស្ស ទីឃរត្តំ ហិតាយ សុខាយ យស្មាបិ ទីឃ និគមា ឯតេ តយោ កុលបុត្តា អគារស្មា អនគារិយំ បព្វជិតា សោ ចេបិ និគមោ ឯតេ

---

១ ឱ. ម. ឥតិហ តេ អាយស្មន្តា តេនាតិ ទិស្សតិ ។ ២ ម. ឯត្តន្តរេ តេន លយេនាតិ ទិស្សតិ ។ ៣ ឱ. ម. សទ្ទាតិ ន ទិស្សតិ ។

[៨] ក៏ក្នុងខណៈមួយរំពេចនោះ សំឡេងឮកងរំពងរហូតទៅដល់ព្រហ្មលោក ដោយប្រការដូច្នេះថា ម្នាលទីឃៈ ដំណើរនុ៎ះយ៉ាងហ្នឹងហើយ ម្នាលទីឃៈ ដំណើរនុ៎ះយ៉ាងហ្នឹងហើយ ម្នាលទីឃៈ កុលបុត្រទាំង ៣ រូបនុ៎ះ ចេញចាកផ្ទះអំពីត្រកូលណា បួសក្នុងសាសនា បើត្រកូលនោះ មានចិត្តជ្រះថ្លា រលឹកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរលឹកនោះ នឹងនាំមកនូវប្រយោជន៍និងសេចក្ដីសុខ ដល់ត្រកូលនុ៎ះ អស់កាលយូរអង្វែង ម្នាលទីឃៈ កុលបុត្រទាំង ៣ រូបនោះ ចេញចាកផ្ទះអំពីវង្សត្រកូលណា បួសក្នុងសាសនា ប្រសិនបើវង្សត្រកូលនោះ មានចិត្តជ្រះថ្លារលឹកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរលឹកនោះ តែងនាំមកនូវប្រយោជន៍និងសេចក្ដីសុខដល់វង្សត្រកូលនោះ អស់កាលយូរអង្វែង ម្នាលទីឃៈ កុលបុត្រទាំង ៣ រូបនុ៎ះ ចេញចាកផ្ទះអំពីស្រុកណា បួសក្នុងសាសនា ប្រសិនបើអ្នកស្រុកនោះ មានចិត្តជ្រះថ្លារលឹកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរលឹកនោះ តែងនាំមកនូវប្រយោជន៍និងសេចក្ដីសុខ ដល់អ្នកស្រុកនោះ អស់កាលយូរអង្វែង ម្នាលទីឃៈ កុលបុត្រទាំង ៣ រូបនុ៎ះ ចេញចាកផ្ទះ អំពីនិគមណា បួសក្នុងសាសនា ប្រសិនបើ អ្នកនិគមនោះ

តយោ កុលបុត្តេ បសន្នចិត្តោ អនុស្សរេយ្យ តស្សបស្ស និគមស្ស ទីឃរត្តំ ហិតាយ សុខាយ យស្មាបិ ទីឃ នគរា ឯតេ តយោ កុលបុត្តា អគារស្មា អនគារិយំ បព្វជិតា តញ្ចេបិ នគរំ ឯតេ តយោ កុលបុត្តេ បសន្ន-ចិត្តំ អនុស្សរេយ្យ តស្សបស្ស នគរស្ស ទីឃរត្តំ ហិតាយ សុខាយ យស្មាបិ ទីឃ ជនបទា ឯតេ តយោ កុល-បុត្តា អគារស្មា អនគារិយំ បព្វជិតា សោ ចេបិ ជនប-ទោ ឯតេ តយោ កុលបុត្តេ បសន្នចិត្តោ អនុស្សរេយ្យ តស្សបស្ស ជនបទស្ស ទីឃរត្តំ ហិតាយ សុខាយ សព្វេ ចេបិ ទីឃ ខត្តិយា ឯតេ តយោ កុលបុត្តេ បសន្នចិត្តា អនុស្សរេយ្យុំ សព្វេសំបស្ស[១] ខត្តិយានំ ទីឃរត្តំ ហិតាយ សុខាយ សព្វេ ចេបិ ទីឃ ព្រាហ្ម-ណា ។ បេ ។ សព្វេ ចេបិ ទីឃ វេស្សា... សព្វេ ចេបិ ទីឃ សុទ្ទា ឯតេ តយោ កុលបុត្តេ បសន្នចិត្តា អនុស្ស-រេយ្យុំ សព្វេសំបស្ស សុទ្ទានំ ទីឃរត្តំ ហិតាយ សុខាយ

១ ឱ. សព្វេសានំ បស្ស ។ ម. សព្វេសានំ បាស្ស ។

មានចិត្តជ្រះថ្លារលឹកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរលឹកនោះតែងនាំមកនូវប្រយោជន៍និងសេចក្តីសុខដល់អ្នកនិគមនោះ អស់កាលយូរអង្វែង ម្នាលទីឃៈ កុលបុត្រទាំង ៣ រូបនុ៎ះ ចេញចាកផ្ទះអំពីនគរណា ប្រសិនបើ អ្នកនគរនោះ មានចិត្តជ្រះថ្លារលឹកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរលឹកនោះ តែងនាំមកនូវប្រយោជន៍និងសេចក្តីសុខ ដល់អ្នកនគរនោះ អស់កាលយូរអង្វែង ម្នាលទីឃៈ កុលបុត្រទាំង ៣ រូបនុ៎ះ ចេញចាកផ្ទះ អំពីជនបទណា បួសក្នុងសាសនា ប្រសិនបើ អ្នកជនបទនោះ មានចិត្តជ្រះថ្លារលឹកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរលឹកនោះ តែងនាំមកនូវប្រយោជន៍និងសេចក្តីសុខ ដល់អ្នកជនបទនោះ អស់កាលយូរអង្វែង ម្នាលទីឃៈ ប្រសិនបើ ពួកក្សត្រទាំងអស់មានព្រះហឫទ័យជ្រះថ្លា រលឹកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរលឹកនោះតែងនាំមកនូវប្រយោជន៍និងសេចក្តីសុខ ដល់ពួកក្សត្រទាំងអស់ អស់កាលយូរអង្វែង ម្នាលទីឃៈ ប្រសិនបើ ពួកព្រាហ្មណ៍ទាំងអស់ ។ បេ ។ ម្នាលទីឃៈ ប្រសិនបើពួកវេស្សៈទាំងអស់... ម្នាលទីឃៈ ប្រសិនបើ ពួកសុទ្ទៈទាំងអស់ មានចិត្តជ្រះថ្លា រលឹកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរលឹកនោះ តែងនាំមកនូវប្រយោជន៍និងសេចក្តីសុខ ដល់ពួកសុទ្ទៈទាំងអស់ អស់កាលយូរអង្វែង

សទេវកោ ចេបិ ទីឃ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា ឯតេ តយោ កុលបុត្តេ បសន្នចិត្តា អនុស្សរេយ្យ[១] សទេវកស្សបស្ស លោកស្ស សមារកស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ទីឃរត្តំ ហិតាយ សុខា បស្ស ទីឃ យាវញ្ចេតេ[២] តយោ កុលបុត្តា ពហុជនហិតាយ បដិបន្នា ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។ ឥទមវោច ភគវា អត្តមនោ ទីឃោ បរជនោ យក្ខោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ចូឡគោសិង្គសាលសុត្តំ បឋមំ និដ្ឋិតំ ។

---

១ ម. អនុស្សរេយ្យុំ ។ ២ ឱ. ម. យាវ ចេតេ ។

ម្នាលទីឃៈ ប្រសិនបើលោក ព្រមទាំងទេវលោក មារលោក ព្រហ្ម-លោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មានចិត្តជ្រះថ្លា រលឹកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរលឹកនោះតែងនាំមកនូវប្រយោជន៍ដល់លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដល់ពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសអស់កាលយូរអង្វែង ម្នាលទីឃៈ អ្នកចូរមើលកុលបុត្រទាំង ៣ រូបនុ៎ះប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ ដើម្បីគុណ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ជាកំណត់ ។ ព្រះមានព្រះភាគ បានត្រាស់សេចក្តីនេះចប់ហើយ ទីឃបរជនយក្សក៏ពេញចិត្ត ត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ ចូឡគោសិង្គសាលសូត្រ ទី ១ ។

# ទុតិយំ មហាគោសិង្គសាលសុត្តំ

[៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា គោសិង្គសាលវនទាយេ វិហរតិ សម្ពហុលេហិ អភិញ្ញាតេហិ អភិញ្ញាតេហិ ថេរេហិ សាវកេហិ សទ្ធឹ អាយស្មតា ច សារីបុត្តេន អាយស្មតា ច មហាមោគ្គល្លានេន អាយស្មតា ច មហាកស្សបេន អាយស្មតា ច អនុរុទ្ធេន អាយស្មតា ច រេវតេន អាយស្មតា ច អានន្ទេន អញ្ញេហិ ច អភិញ្ញាតេហិ អភិញ្ញាតេហិ ថេរេហិ សាវកេហិ សទ្ធឹ ។ អថខោ អាយស្មា មហាមោគ្គល្លានោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា មហាកស្សបោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាកស្សបំ ឯតទវោច អាយាមាវុសោ កស្សប យេនាយស្មា សារីបុត្តោ តេនុបសង្កមិស្សាម ធម្មស្សវនាយាតិ ។ ឯវមាវុសោតិ ខោ អាយស្មា មហាកស្សបោ អាយស្មតោ មហាមោគ្គល្លានស្ស បច្ចស្សោសិ ។

# មហាគោសិង្គសាលសូត្រ ទី ២

[៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃគោសិង្គសាលវ័ន ជាមួយនឹងព្រះថេរៈជាសាវ័ក សុទ្ធតែមាននាមល្បីល្បាញ ជាច្រើនអង្គ គឺព្រះសារីបុត្រមានអាយុ ១ ព្រះមោគ្គល្លានមានអាយុ ១ ព្រះមហាកស្សបមានអាយុ ១ ព្រះអនុរុទ្ធមានអាយុ ១ ព្រះរេវតមានអាយុ ១ ព្រះអានន្ទមានអាយុ ១ មួយអន្លើនឹងព្រះថេរៈ ជាសាវ័ក ដែលសុទ្ធតែមាននាមល្បីល្បាញឯទៀតផង ។ គ្រានោះឯង ព្រះមហាមោគ្គល្លានមានអាយុ ចេញចាកទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅរកព្រះមហាកស្សបមានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះមហាកស្សបមានអាយុ យ៉ាងនេះថា ម្នាលអាវុសោកស្សប យើងទាំងឡាយនឹងចូលទៅរកព្រះសារីបុត្រមានអាយុ ដើម្បីស្តាប់ធម៌ ។ ព្រះមហាកស្សបមានអាយុ ទទួលស្តាប់ព្រះមហាមោគ្គល្លាន មានអាយុ ថា ករុណា អាវុសោ ។

២០

អថខោ អាយស្មា ច មហាមោគ្គល្លានោ អាយស្មា ច មហាកស្សបោ អាយស្មា ច អនុរុទ្ធោ យេនាយស្មា សារីបុត្តោ តេនុបសង្កមឹសុ ធម្មស្សវនាយ ។ អទ្ទសា ខោ អាយស្មា អានន្ទោ អាយស្មន្តញ្ច មហាមោគ្គល្លានំ អាយស្មន្តញ្ច មហាកស្សបំ អាយស្មន្តញ្ច អនុរុទ្ធំ យេនាយស្មា សារីបុត្តោ តេនុបសង្កមន្តេ ធម្មស្សវនាយ ទិស្វាន យេនាយស្មា រេវតោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ រេវតំ ឯតទវោច ឧបសង្កមន្តា ខោ អម្ហ អាវុសោ រេវត សប្បុរិសា យេនាយស្មា សារីបុត្តោ តេន ធម្មស្សវនាយ អាយាមាវុសោ រេវត យេនាយស្មា សារីបុត្តោ តេនុបសង្កមិស្សាម ធម្មស្សវនាយាតិ ។ ឯវមាវុសោតិ ខោ អាយស្មា រេវតោ អាយស្មតោ អានន្ទស្ស បច្ចស្សោសិ ។ អថខោ អាយស្មា ច រេវតោ អាយស្មា ច អានន្ទោ យេនាយស្មា សារីបុត្តោ តេនុបសង្កមឹសុ ធម្មស្សវនាយ ។

គ្រានោះឯង ព្រះមហាមោគ្គល្លាន មានអាយុ ព្រះមហាកស្សបមានអាយុ និងព្រះអនុរុទ្ធមានអាយុ ក៏ចូលទៅរកព្រះសារីបុត្រ មានអាយុ ដើម្បីស្តាប់ធម៌ ។ ព្រះអានន្ទមានអាយុ បានឃើញព្រះមហាមោគ្គល្លាន មានអាយុ ព្រះមហាកស្សប មានអាយុ និងព្រះអនុរុទ្ធ មានអាយុ កំពុងដើរចូលទៅរកព្រះសារីបុត្រមានអាយុ ដើម្បីស្តាប់ធម៌ លុះឃើញហើយក៏ចូលទៅរកព្រះរេវតមានអាយុ លុះចូលទៅដល់ហើយក៏និយាយនឹងព្រះរេវតមានអាយុយ៉ាងនេះថា ម្នាលអាវុសោ រេវត ពួកលោកជាសប្បុរសឯណោះ កំពុងចូលទៅរកព្រះសារីបុត្រមានអាយុ ដើម្បីស្តាប់ធម៌ ម្នាលអាវុសោ រេវត មក យើងនឹងចូលទៅរកព្រះសារីបុត្រមានអាយុ ដើម្បីស្តាប់ធម៌ ។ ព្រះរេវតមានអាយុ ទទួលស្តាប់ព្រះអានន្ទមានអាយុថា ករុណា អាវុសោ ។ គ្រានោះឯង ព្រះរេវតមានអាយុ និងព្រះអានន្ទ មានអាយុ ក៏ចូលទៅរកព្រះសារីបុត្រ មានអាយុ ដើម្បីស្តាប់ធម៌ ។

[១០] អទ្ទសា ខោ អាយស្មា សារីបុត្តោ អាយស្មន្តញ្ច រេវតំ អាយស្មន្តញ្ច អានន្ទំ ទូរតោវ អាគច្ឆន្តេ ទិស្វាន អាយស្មន្តំ អានន្ទំ ឯតទវោច ឯតុ ខោ អាយស្មា អានន្ទោ ស្វាគតំ[១] អាយស្មតោ អានន្ទស្ស ភគវតោ ឧបដ្ឋាកស្ស ភគវតោ សន្តិកាវចរស្ស រមណីយំ អាវុសោ អានន្ទ គោសិង្គសាលវនំ ទោសិនា រត្តិ សព្វផាលិផុល្លា សាលា ទិព្វា មញ្ញេ គន្ធា សម្បវន្តិ កថំរូបេន អាវុសោ អានន្ទ ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។ ឥធាវុសោ សារីបុត្ត ភិក្ខុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថា សព្យញ្ជនា កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា សោ

---
១ ឱ. អានន្ទស្សាគតំ ។

[១០] ព្រះសារីបុត្រមានអាយុ បានឃើញព្រះរេវតមានអាយុ និងព្រះអានន្ទមានអាយុ កំពុងដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏និយាយនឹងព្រះអានន្ទមានអាយុ យ៉ាងនេះថា អានន្ទមានអាយុ ចូរចូលមក អានន្ទមានអាយុ ជាឧបដ្ឋាករបស់ព្រះមានព្រះភាគ ជាអ្នកដើរជិតជិតតាមព្រះមានព្រះភាគ មកល្អហើយ ម្នាលអាវុសោ អានន្ទ គោសិង្គសាលវ័ននេះ គួរឲ្យរីករាយ រាត្រីសោត ក៏ប្រាសចាកទោស[១] ដើមឈើទាំងឡាយ ក៏មានផ្ការីកស្គុសស្គាយ សព្វកន្លែង មានក្លិនក្រអូប គួរនាដូចក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោ អានន្ទ ចុះព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុ រូបណា ។ ព្រះអានន្ទតបថា ម្នាលអាវុសោ សារីបុត្រ ភិក្ខុក្នុងសាសនានេះ ជាអ្នកចេះចាំច្រើន ទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ធម៌ទាំងឡាយណា មានលំអក្នុងបទដើម មានលំអក្នុងបទកណ្តាល មានលំអក្នុងបទចុង ប្រកបដោយអត្ថព្រមទាំងព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះក៏ចេះចាំច្រើន ស្ទាត់ជំនាញ រត់មាត់ ពិចារណាដោយចិត្ត ចាក់ធ្លុះប្រពៃដោយទិដ្ឋិ ភិក្ខុនោះ

---

១ គឺមានមេឃស្រឡះ ប្រាសចាកពពក ទឹកសន្សើម អ័ព្ទ ផ្សែង ធូលីឬរាហុ ។ អដ្ឋកថា ។

ចតស្សន្នំ បរិសានំ ធម្មំ ទេសេតិ បរិមណ្ឌលេហិ បទព្យញ្ជនេហិ អនុប្បពន្ធេហិ អនុសយសមុគ្ឃាតាយ ឯវរូបេន ខោ អាវុសោ សារីបុត្ត ភិក្ខុនា គោសិង្គ-សាលវនំ សោភេយ្យាតិ ។

[១១] ឯវំ វុត្តេ អាយស្មា សារីបុត្តោ អាយស្មន្តំ រេវតំ ឯតទវោច ព្យាកតំ ខោ អាវុសោ រេវត អា-យស្មតា អានន្ទេន យថាសកំ បដិភានំ តត្ថ ទានិ មយំ អាយស្មន្តំ រេវតំ បុច្ឆាម រមណីយំ អាវុសោ រេវត គោសិង្គសាលវនំ ទោសិនា រត្តិ សព្វផាលិផុល្លា សាលា ទិព្វា មញ្ញេ គន្ធា សម្បវន្តិ កថំរូបេន អាវុសោ រេវត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។ ឥធាវុសោ សារីបុត្ត ភិក្ខុ បដិសល្លានារាមោ ហោតិ បដិសល្លានរតោ អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិ-រាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ឯវរូបេន ខោ អាវុសោ សារីបុត្ត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។

រមែងសំដែងធម៌ ដល់បរិស័ទទាំង ៤ ដោយបទនិងព្យញ្ជនៈទាំងឡាយ ជាបរិមណ្ឌលជាប់តគ្នា ដើម្បីគាស់រំលើង នូវអនុស័យ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុ រូបនេះ ។

[១១] កាលបើព្រះអានន្ទមានអាយុ និយាយយ៉ាងនេះហើយ ព្រះសារីបុត្រមានអាយុ បាននិយាយនឹងព្រះរេវតមានអាយុ យ៉ាងនេះថា ម្នាលអាវុសោរេវត អានន្ទមានអាយុ បានព្យាករនូវបដិភានជារបស់ខ្លួនហើយ ឥឡូវនេះ យើងនឹងសួររេវតមានអាយុក្នុងសេចក្តីនោះថា ម្នាលអាវុសោរេវត ព្រៃគោសិង្គសាលវ័ន គួររីករាយ រាត្រីក៏ប្រាសចាកទោស ឈើទាំងឡាយក៏មានផ្ការីកស្គុសស្គាយសព្វកន្លែង មានក្លិនក្រអូប បីដូចជាក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោរេវត ព្រៃគោសិង្គសាលវ័នរុង-រឿងដោយសារភិក្ខុ រូបណា ។ ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ មានការពួនសម្ងំជាទីរីករាយ ត្រេកអរក្នុងការពួនសម្ងំ ប្រកបរឿយ ៗ ក្នុងការស្ងប់រម្ងាប់ចិត្តដ៏ប្រព្រឹត្តទៅក្នុងខាងក្នុង មានឈានមិនសាបសូន្យ ឬមិនបានប្រាសចាកឈាន ប្រកបដោយវិបស្សនាបញ្ញា ទាំងចម្រើននូវសុញ្ញាគារធម៌ទាំងឡាយ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុ រូបនេះឯង ។

២៣

មហាយមកវគ្គស្ស  មហាគោសិង្គសាលសុត្តេ  ទិព្វចក្ខុប្បសំសា

[១២] ឯវំ វុត្តេ អាយស្មា សារីបុត្តោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច ព្យាកតំ ខោ អាវុសោ អនុរុទ្ធ អាយស្មតា រេវតេន យថាសកំ បដិភានំ តត្ថទានិ មយំ អាយស្មន្តំ អនុរុទ្ធំ បុច្ឆាម រមណីយំ អាវុសោ អនុរុទ្ធ គោសិង្គសាលវនំ ទោសិនា រត្តិ សព្វផាលិផុល្លា សាលា ទិព្វា មញ្ញេ គន្ធា សម្បវន្តិ កថំរូបេន អាវុសោ អនុរុទ្ធ ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។ ឥធាវុសោ សារីបុត្ត ភិក្ខុ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សហស្សំ លោកានំ វោលោកេតិ សេយ្យថាបិ អាវុសោ សារីបុត្ត ចក្ខុមា បុរិសោ ឧបរិប្បាសាទវរគតោ សហស្សំ នេមិមណ្ឌលានំ វោលោកេយ្យ ឯវមេវ ខោ អាវុសោ សារីបុត្ត ភិក្ខុ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សហស្សំ លោកានំ វោលោកេតិ ឯវរូបេន ខោ អាវុសោ សារីបុត្ត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។

[១២] កាលបើព្រះរេវតមានអាយុនិយាយយ៉ាងនេះហើយ ព្រះសារីបុត្រមានអាយុ បាននិយាយនឹងព្រះអនុរុទ្ធមានអាយុ យ៉ាងនេះថា ម្នាលអាវុសោអនុរុទ្ធ រេវតមានអាយុ បានព្យាករបដិភានជារបស់ខ្លួនហើយ ឥឡូវនេះយើងនឹងសួរអនុរុទ្ធមានអាយុក្នុងសេចក្តីនោះថា ម្នាលអាវុសោអនុរុទ្ធ ព្រៃគោសិង្គសាលវ័ន គួររីករាយ រាត្រីក៏ប្រាសចាកទោស ឈើទាំងឡាយក៏មានផ្ការីកស្គុសស្គាយសព្វកន្លែង មានក្លិនក្រអូបដូចជាក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោអនុរុទ្ធ ព្រៃគោសិង្គសាលវ័នរុងរឿងបាន ដោយសារភិក្ខុ រូបណា ។ ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ មើលឃើញលោកធាតុទាំងមួយពាន់ ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធកន្លងនូវចក្ខុជារបស់មនុស្ស ម្នាលអាវុសោសារីបុត្រ ដូចជាបុរសមានចក្ខុនៅលើប្រាសាទដ៏ប្រសើរ មើលឃើញលោកធាតុទាំងមួយពាន់ ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធកន្លងនូវចក្ខុរបស់មនុស្ស ក៏យ៉ាងនោះដែរ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងបានដោយសារភិក្ខុ រូបនេះឯង ។

[១៣] ឯវំ វុត្តេ អាយស្មា សារីបុត្តោ អាយស្មន្តំ មហាកស្សបំ ឯតទវោច ព្យាករោតុ ខោ អាវុសោ កស្សប អាយស្មតា អត្តនោ យថាសកំ បដិភានំ តត្ថធានិ មយំ អាយស្មន្តំ មហាកស្សបំ បុច្ឆាម រមណីយំ អាវុសោ កស្សប គោសិង្គសាលវនំ ទោសិ- នា រត្តិ សព្វផាលិផុល្លា សាលា ទិព្វា មញ្ញេ គន្ធា សម្បវន្តិ កថំរូបេន អាវុសោ កស្សប ភិក្ខុនា គោ- សិង្គសាលវនំ សោភេយ្យាតិ ។ ឥធាវុសោ សារីបុត្ត ភិក្ខុ អត្តនា ច អារញ្ញកោ ហោតិ អារញ្ញកត្តស្ស ច វណ្ណវាទី អត្តនា ច បិណ្ឌបាតិកោ ហោតិ បិណ្ឌ- បាតិកត្តស្ស ច វណ្ណវាទី អត្តនា ច បំសុកូលិកោ ហោតិ បំសុកូលិកត្តស្ស ច វណ្ណវាទី អត្តនា ច តេចីវរិកោ ហោតិ តេចីវរិកត្តស្ស ច វណ្ណវាទី អត្តនា ច អប្បិច្ឆោ ហោតិ អប្បិច្ឆតាយ ច វណ្ណវាទី អត្តនា ច សន្តុដ្ឋោ ហោតិ សន្តុដ្ឋិយា ច វណ្ណវាទី អត្តនា ច បវិវិត្តោ ហោតិ បវិវេកស្ស ច វណ្ណវាទី អត្តនា ច អសំសដ្ឋោ ហោតិ អសំសគ្គស្ស ច វណ្ណវាទី

[១៣] កាលបើព្រះអនុរុទ្ធ មានអាយុ និយាយយ៉ាងនេះហើយ ព្រះសារីបុត្រ មានអាយុ បាននិយាយនឹងព្រះមហាកស្សប មានអាយុ យ៉ាងនេះថា ម្នាលអាវុសោកស្សប អនុរុទ្ធមានអាយុ បានព្យាករនូវបដិភានរបស់ខ្លួនហើយ ឥឡូវនេះ យើងនឹងសួរមហាកស្សបមានអាយុ ក្នុងសេចក្តីនោះថា ម្នាលអាវុសោកស្សប ព្រៃគោសិង្គសាលនៃគួររីករាយ រាត្រីក៏ប្រាសចាកទោស ឈើទាំងឡាយក៏មានផ្ការីកស្គុសស្គាយ សព្វកន្លែង មានក្លិនក្រអូបបីដូចក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោកស្សប ព្រៃគោសិង្គសាលនៃរុងរឿង ដោយសារភិក្ខុ រូបណា ។ ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅក្នុងព្រៃខ្លួនឯងផង សរសើរគុណ នៃអ្នកនៅព្រៃផង ជាអ្នកប្រព្រឹត្តបិណ្ឌបាតខ្លួនឯងផង សរសើរគុណ នៃអ្នកប្រព្រឹត្តបិណ្ឌបាតផង ជាអ្នកទ្រទ្រង់សំពត់បង្សុកូលខ្លួនឯងផង សរសើរគុណ នៃអ្នកទ្រទ្រង់សំពត់បង្សុកូលផង ជាអ្នកទ្រទ្រង់តែចីវរបីខ្លួនឯងផង សរសើរគុណ នៃអ្នកទ្រទ្រង់តែចីវរបីផង ជាអ្នកឥតសេចក្តីប្រាថ្នាខ្លួនឯងផង សរសើរគុណនៃអ្នកឥតសេចក្តីប្រាថ្នាផង ជាអ្នកសន្តោសខ្លួនឯងផង សរសើរគុណនៃសេចក្តីសន្តោសផង ជាអ្នកស្ងប់ស្ងាត់ខ្លួនឯងផង សរសើរគុណនៃសេចក្តីស្ងប់ស្ងាត់ផង ជាអ្នកមិនច្រឡូកច្រឡំខ្លួនឯងផង សរសើរគុណនៃសេចក្តីមិនច្រឡូកច្រឡំផង ជាអ្នក

អត្តនា ច អារទ្ធវីរិយោ ហោតិ វីរិយារម្ភស្ស ច វណ្ណវាទី អត្តនា ច សីលសម្បន្នោ ហោតិ សីលសម្បទាយ ច វណ្ណវាទី អត្តនា ច សមាធិសម្បន្នោ ហោតិ សមាធិសម្បទាយ ច វណ្ណវាទី អត្តនា ច បញ្ញាសម្បន្នោ ហោតិ បញ្ញាសម្បទាយ ច វណ្ណវាទី អត្តនា ច វិមុត្តិសម្បន្នោ ហោតិ វិមុត្តិសម្បទាយ ច វណ្ណវាទី អត្តនា ច វិមុត្តិញាណទស្សនសម្បន្នោ ហោតិ វិមុត្តិញាណទស្សនសម្បទាយ ច វណ្ណវាទី ឯវរូបេន ខោ អាវុសោ សារីបុត្ត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។

[១៤] ឯវំ វុត្តេ អាយស្មា សារីបុត្តោ អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច ព្យាកតំ ខោ អាវុសោ មោគ្គល្លាន អាយស្មតា មហាកស្សបេន យថាសកំ បដិភានំ តត្ថទានិ មយំ អាយស្មន្តំ មហាមោគ្គល្លានំ បុច្ឆាម រមណីយំ អាវុសោ មោគ្គល្លាន

ប្រុងប្រៀបព្យាយាមខ្លួនឯងផង សរសើរសេចក្តីប្រុងប្រៀបព្យាយាមផង ជាអ្នកបរិបូណ៌ ដោយសីលខ្លួនឯងផង សរសើរការបរិបូណ៌ដោយសីលផង ជាអ្នកបរិបូណ៌ ដោយសមាធិខ្លួនឯងផង សរសើរការបរិបូណ៌ដោយសមាធិផង ជាអ្នកបរិបូណ៌ដោយបញ្ញាខ្លួនឯងផង សរសើរការបរិបូណ៌ដោយបញ្ញាផង ជាអ្នកបរិបូណ៌ដោយវិមុត្តិខ្លួនឯងផង សរសើរការបរិបូណ៌ដោយវិមុត្តិផង ជាអ្នកបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈខ្លួនឯងផង សរសើរការបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈផង ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុ រូបនេះឯង ។

[១៤] កាលបើព្រះមហាកស្សប មានអាយុ និយាយយ៉ាងនេះហើយ ព្រះសារីបុត្រ មានអាយុ និយាយនឹងព្រះមហាមោគ្គល្លាន មានអាយុ យ៉ាងនេះថា ម្នាលអាវុសោមោគ្គល្លាន មហាកស្សប មានអាយុ បានព្យាករនូវបដិភានជារបស់ខ្លួនហើយ ឥឡូវនេះ យើងនឹងសួរមហាមោគ្គល្លានមានអាយុក្នុងសេចក្តីនោះថា ម្នាលអាវុសោមោគ្គល្លាន

គោសិង្គសាលវនំ ទោសិនា រត្តិ សព្វផាលិផុល្លា សាលា ទិព្វា មញ្ញេ គន្ធា សម្បវន្តិ កថំរូបេន អាវុសោ មោគ្គល្លាន ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។ ឥធាវុសោ សារីបុត្ត ទ្វេ ភិក្ខូ អភិធម្មកថំ កថេន្តិ តេ អញ្ញមញ្ញំ បុច្ឆន្តិ អញ្ញមញ្ញស្ស បញ្ហំ បុដ្ឋា វិស្សជ្ជេន្តិ នោ ច សំសាទេន្តិ ធម្មី ច នេសំ កថា បវត្តនី ហោតិ ឯវរូបេន ខោ អាវុសោ សារីបុត្ត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។

[១៨] អថខោ អាយស្មា មហាមោគ្គល្លានោ អាយស្មន្តំ សារីបុត្តំ ឯតទវោច ព្យាកតំ ខោ អាវុសោ សារីបុត្ត អម្ហេហិ សព្វេហេវ យថាសកំ បដិភានំ តត្ថទានិ មយំ អាយស្មន្តំ សារីបុត្តំ បុច្ឆាម រមណីយំ អាវុសោ សារីបុត្ត គោសិង្គសាលវនំ ទោសិនា រត្តិ សព្វផាលិផុល្លា សាលា ទិព្វា មញ្ញេ គន្ធា សម្បវន្តិ កថំរូបេន អាវុសោ សារីបុត្ត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។ ឥធាវុសោ មោគ្គល្លាន ភិក្ខុ

ព្រៃគោសិង្គសាលវ័ន គួររីករាយ រាត្រីក៏ប្រាសចាកទោស ឈើទាំង-ឡាយក៏មានផ្ការីកស្គុសស្គាយសព្វកន្លែង មានក្លិនក្រអូបបីដូចក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោមោគ្គល្លាន ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុ រូបណា ។ ម្នាលអាវុសោសារីបុត្រ ភិក្ខុទាំងឡាយពីររូបក្នុងសាសនានេះ សំដែងនូវអភិធម្មកថា ភិក្ខុទាំងនោះ សួរគ្នានឹងគ្នាលុះសួរប្រស្នាហើយ ដោះស្រាយដល់គ្នានឹងគ្នា ក៏មិនបានរុករានគ្នាផងកថារបស់ភិក្ខុទាំងនោះ ប្រព្រឹត្តទៅប្រកបដោយធម៌ផង ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុ រូបនេះឯង ។

[១៥] គ្រានោះឯង ព្រះមហាមោគ្គល្លានមានអាយុបាននិយាយនឹងព្រះសារីបុត្រមានអាយុ យ៉ាងនេះថា ម្នាលអាវុសោសារីបុត្រ ពួកយើងទាំងអស់គ្នាបានព្យាករនូវបដិភានជារបស់ខ្លួនហើយ ឥឡូវនេះ យើងនឹងសួរនូវព្រះសារីបុត្រមានអាយុ ក្នុងសេចក្តីនោះថា ម្នាលអាវុសោសារី-បុត្រ ព្រៃគោសិង្គសាលវ័នគួររីករាយ រាត្រីក៏ប្រាសចាកទោស ឈើទាំងឡាយមានផ្ការីកស្គុសស្គាយសព្វកន្លែង មានក្លិនក្រអូបបីដូចជាក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័នរុងរឿងដោយសារភិក្ខុ រូបណា ។ ម្នាលអាវុសោមោគ្គល្លាន ភិក្ខុក្នុងសាសនានេះ

២៧



ចិត្តំ វសំ វត្តេតិ នោ ច ភិក្ខុ ចិត្តស្ស វសេន វត្តតិ សោ យាយ វិហារសមាបត្តិយា អាកង្ខតិ បុព្វណ្ហសមយំ វិហរិតុំ តាយ វិហារសមាបត្តិយា បុព្វណ្ហសមយំ វិហរតិ យាយ វិហារសមាបត្តិយា អាកង្ខតិ មជ្ឈន្តិក-សមយំ វិហរិតុំ តាយ វិហារសមាបត្តិយា មជ្ឈន្តិក-សមយំ វិហរតិ យាយ វិហារសមាបត្តិយា អាកង្ខតិ សាយណ្ហសមយំ វិហរិតុំ តាយ វិហារសមាបត្តិយា សា-យណ្ហសមយំ វិហរតិ សេយ្យថាបិ អាវុសោ មោគ្គល្លាន រញ្ញោ វា រាជមហាមត្តស្ស វា នានារត្តានំ ទុស្សានំ ទុស្សករណ្ឌកោ បូរោ អស្ស សោ យញ្ញទេវ ទុស្ស-យុគំ អាកង្ខេយ្យ បុព្វណ្ហសមយំ បារុបិតុំ តំតទេវ[១] ទុស្សយុគំ បុព្វណ្ហសមយំ បារុបេយ្យ យញ្ញទេវ ទុស្ស-យុគំ អាកង្ខេយ្យ មជ្ឈន្តិកសមយំ បារុបិតុំ តំតទេវ ទុស្សយុគំ មជ្ឈន្តិកសមយំ បារុបេយ្យ យញ្ញទេវ ទុស្សយុគំ អាកង្ខេយ្យ សាយណ្ហសមយំ បារុបិតុំ តំតទេវ ទុស្សយុគំ សាយណ្ហសមយំ បារុបេយ្យ

១ ឱ. តន្តទេវ ។

ញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅ ក្នុងអំណាចខ្លួនផង ភិក្ខុមិនបានប្រព្រឹត្តទៅ តាមអំណាចនៃចិត្តផង ភិក្ខុនោះប្រាថ្នាដើម្បីនៅ អស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់បុព្វណ្ហសម័យ ដោយវិហារសមា-បត្តិនោះបាន បើប្រាថ្នាដើម្បីនៅអស់មជ្ឈន្តិកសម័យ ដោយវិហារស-មាបត្តិណា ក៏នៅអស់មជ្ឈន្តិកសម័យ ដោយវិហារសមាបត្តិនោះបាន បើប្រាថ្នាដើម្បីនៅ អស់សាយណ្ហសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់សាយណ្ហសម័យដោយវិហារសមាបត្តិនោះបាន ម្នាលអាវុសោមោគ្គល្លាន ដូចជាហិបសំពត់ដ៏ពេញដោយសំពត់ទាំងឡាយ ជ្រលក់ហើយដោយពណ៌ផ្សេង ៗ របស់ព្រះរាជា ឬរាជមហាមាត្យ ព្រះរាជានិងមហាមាត្យនោះ ប្រាថ្នាដើម្បីទ្រទ្រង់នូវគូសំពត់ណា អស់បុព្វណ្ហសម័យ ក៏ទ្រទ្រង់នូវគូសំពត់នោះ ៗ បាន អស់បុព្វណ្ហសម័យ បើប្រាថ្នាដើម្បីទ្រទ្រង់នូវគូសំពត់ណា អស់មជ្ឈន្តិកសម័យ ក៏ទ្រទ្រង់នូវគូសំពត់នោះ ៗ បាន អស់មជ្ឈន្តិកសម័យ បើប្រាថ្នាដើម្បីទ្រទ្រង់នូវគូសំពត់ណា អស់សាយណ្ហសម័យ ក៏ទ្រទ្រង់នូវគូសំពត់នោះ ៗ បាន អស់សាយណ្ហសម័យ

ឯវមេវ ខោ អាវុសោ មោគ្គល្លាន ភិក្ខុ ចិត្តំ វសំ
វត្តេតិ នោ ច ភិក្ខុ ចិត្តស្ស វសេន វត្តតិ សោ
យាយ វិហារសមាបត្តិយា អាកង្ខតិ បុព្វណ្ហសមយំ
វិហរិតុំ តាយ វិហារសមាបត្តិយា បុព្វណ្ហសមយំ
វិហរតិ យាយ វិហារសមាបត្តិយា អាកង្ខតិ មជ្ឈន្តិក-
សមយំ វិហរិតុំ តាយ វិហារសមាបត្តិយា មជ្ឈន្តិក-
សមយំ វិហរតិ យាយ វិហារសមាបត្តិយា អា-
កង្ខតិ សាយណ្ហសមយំ វិហរិតុំ តាយ វិហារស-
មាបត្តិយា សាយណ្ហសមយំ វិហរតិ ឯវរូបេន ខោ
អាវុសោ មោគ្គល្លាន ភិក្ខុនា គោសិង្គសាលវនំ សោ-
ភេយ្យាតិ ។

[១៦] អថខោ អាយស្មា សារីបុត្តោ តេ អាយស្មន្តេ
ឯតទវោច ព្យាកតំ ខោ អាវុសោ អម្ហេហិ សព្វេហេវ
យថាសកំ បដិភានំ អាយាមាវុសោ យេន ភគវា
តេនុបសង្កមិស្សាម ឧបសង្កមិត្វា ឯតមត្ថំ ភគវតោ អា-
រោចេស្សាម យថា នោ ភគវា ព្យាករិស្សតិ តថា នំ
ធារេស្សាមាតិ ។ ឯវំ អាវុសោតិ ខោ តេ អាយស្មន្តោ

ម្នាលអាវុសោមោគ្គល្លាន ភិក្ខុញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចខ្លួនផង ភិក្ខុមិនបានប្រព្រឹត្តទៅតាមអំណាចរបស់ចិត្តផង ភិក្ខុនោះប្រាថ្នាដើម្បីនៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិនោះបាន បើប្រាថ្នាដើម្បីនៅអស់មជ្ឈន្តិកសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់មជ្ឈន្តិកសម័យ ដោយវិហារសមាបត្តិនោះបាន បើប្រាថ្នាដើម្បីនៅអស់សាយណ្ហសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់សាយណ្ហសម័យ ដោយវិហារសមាបត្តិនោះបាន ក៏យ៉ាងនោះដែរ ម្នាលអាវុសោមោគ្គល្លាន ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុ រូបនេះឯង ។

[១៦] លំដាប់នោះឯង ព្រះសារីបុត្រមានអាយុ បាននិយាយនឹងព្រះថេរៈមានអាយុទាំងនោះ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពួកយើងទាំងអស់គ្នាបានព្យាករបដិភានតាមសមគួរដល់ខ្លួនហើយ ម្នាលអាវុសោទាំងឡាយ មក យើងនឹងចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ នឹងក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ បើព្រះមានព្រះភាគនឹងព្យាករដល់យើង យ៉ាងណា យើងនឹងចាំទុក នូវសេចក្តីនោះ យ៉ាងនោះ ។ ព្រះថេរៈ មានអាយុទាំងនោះ

២៩

អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អថខោ តេ អាយស្មន្តោ យេន ភគវា តេនុបសង្កមឹសុ ឧប-សង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច ឥធ ភន្តេ អាយស្មា ច រេវតោ អាយស្មា ច អានន្ទោ យេនាហំ តេនុបសង្កមឹសុ ធម្មស្សវនាយ អន្ទសំ ខោ អហំ ភន្តេ អាយស្មន្តញ្ច រេវតំ អាយ-ស្មន្តញ្ច អានន្ទំ ទូរតោវ អាគច្ឆន្តេ ទិស្វាន អាយស្មន្តំ អានន្ទំ ឯតទវោចំ ឯតុ ខោ អាយស្មា អានន្ទោ ស្វា-គតំ អាយស្មតោ អានន្ទស្ស ភគវតោ ឧបដ្ឋាកស្ស ភគវតោ សន្តិកាវចរស្ស រមណីយំ អាវុសោ អានន្ទ គោសិង្គសាលវនំ ទោសិនា រត្តិ សព្វផាលិផុល្លា សាលា ទិព្វា មញ្ញេ គន្ធា សម្បវន្តិ កាថំរូបេន អាវុសោ អានន្ទ ភិក្ខុនា គោសិង្គសាលវនំ សោ-ភេយ្យាតិ ឯវំ វុត្តេ ភន្តេ អាយស្មា អានន្ទោ

ទទួលស្តាប់ព្រះសារីបុត្រមានអាយុ យ៉ាងនេះថា ម្នាលអាវុសោ យ៉ាង ហ្នឹងហើយ ។ គ្រានោះឯង ព្រះថេរៈមានអាយុទាំងនោះ នាំគ្នាចូល ទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបអភិវាទចំ-ពោះព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ កាលព្រះសារីបុត្រ មានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូល ចំពោះព្រះ មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ រេវត មានអាយុនិងអានន្ទមានអាយុ នាំគ្នាចូលមករកខ្ញុំព្រះអង្គ ដើម្បីស្តាប់ធម៌ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញរេវតមានអាយុ និងអានន្ទ មានអាយុ កំពុងដើរមកអំពីចម្ងាយ លុះឃើញហើយ បាននិយាយ នឹងអានន្ទ មានអាយុ យ៉ាងនេះថា អានន្ទមានអាយុចូរចូលមក អានន្ទ មានអាយុ ជាឧបដ្ឋាក របស់ព្រះមានព្រះភាគ ជាអ្នកដើរជិតដិតតាម ព្រះមានព្រះភាគ មកល្អហើយ ម្នាលអាវុសោអានន្ទ ព្រៃគោសិង្គសាលវ័ន គួររីករាយ រាត្រីក៏ប្រាសចាកទោស ឈើទាំងឡាយមានផ្ការីកស្គុសស្គាយ សព្វកន្លែង មានក្លិនក្រអូបដូចជាក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោ អានន្ទ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបណា បពិត្រព្រះ អង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយយ៉ាងនេះហើយ អានន្ទមានអាយុ

មំ ឯតទហោច ឥធាវុសោ សារីបុត្ត ភិក្ខុ ពហុស្សុតោ ហោតិ សុតធរោ ។ បេ ។ អនុសយសមុគ្ឃាតាយ ឯវរូបេ-ន ខោ អាវុសោ សារីបុត្ត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។ សាធុ សាធុ សារីបុត្ត យថាតំ អា-នន្ទោវ សម្មា ព្យាករមានោ ព្យាករេយ្យ អានន្ទោ ហិ សារីបុត្ត ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថា សព្យញ្ជនា កេវល-បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មន-សានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា សោ ចតស្សន្នំ បរិសានំ ធម្មំ ទេសេតិ បរិមណ្ឌលេហិ បទព្យញ្ជ-នេហិ អនុប្បពន្ធេហិ អនុសយសមុគ្ឃាតាយាតិ ។

[១៧] ឯវំ វុត្តេ អហំ ភន្តេ អាយស្មន្តំ រេវតំ ឯតទហោចំ ព្យាកតំ ខោ អាវុសោ រេវត អាយស្មតា អានន្ទេន យថាសកំ បដិភានំ

បាននិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ ជាអ្នកចេះចាំច្រើន ទ្រទ្រង់នូវពុទ្ធវចនៈ ។ បេ ។ ដើម្បីគាស់រំលើងអនុស័យ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័នរុងរឿងដោយសារភិក្ខុ រូបនេះឯង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្រ ត្រូវល្អហើយ អានន្ទព្យាករត្រឹមត្រូវតាមសេចក្តីពិត ម្នាលសារីបុត្រ ព្រោះថា អានន្ទជាអ្នកចេះចាំច្រើន ទ្រទ្រង់ទុកនូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ធម៌ទាំងឡាយណា មានលំអក្នុងបទដើម មានលំអក្នុងបទកណ្តាល មានលំអក្នុងបទចុង ប្រកបដោយអត្ថនិងព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ អានន្ទក៏បានចេះចាំច្រើន ស្ទាត់រត់មាត់ ពិចារណាបានដោយចិត្ត ចាក់ធ្លុះដោយទិដ្ឋិគឺបញ្ញា អានន្ទនោះ តែងសំដែងធម៌ដល់បរិស័ទទាំង ៤ ដោយបទនិងព្យញ្ជនៈទាំងឡាយ ជាបរិមណ្ឌលជាប់តគ្នាមិនដាច់ ដើម្បីគាស់រំលើងនូវអនុសយក្កិលេស ។

[១៧] បពិត្រព្រះអង្គដ៏ចម្រើន កាលបើអានន្ទមានអាយុ និយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គបាននិយាយនឹងរេវតមានអាយុ យ៉ាងនេះថា ម្នាលអាវុសោរេវត អានន្ទមានអាយុបានព្យាករនូវបដិភានដ៏សមគួរដល់

៣១

មហាយមកវគ្គស្ស មហាគោសិង្គសាលសុត្តេ បដិសល្លានារាមប្បសំសា

តត្ថ ទានិ មយំ អាយស្មន្តំ រេវតំ បុច្ឆាម រមណីយំ អាវុសោ រេវត គោសិង្គសាលវនំ ទោសិនា រត្តិ សព្វផាលិផុល្លា សាលា ទិព្វា មញ្ញេ គន្ធា សម្បវន្តិ កថំរូបេន អាវុសោ រេវត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ឯវំ វុត្តេ ភន្តេ អាយស្មា រេវតោ មំ ឯតទវោច ឥធាវុសោ សារីបុត្ត ភិក្ខុ បដិសល្លានារាមោ ហោតិ បដិសល្លានរតោ អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានំ ឯវរូបេន ខោ អាវុសោ សារីបុត្ត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។ សាធុ សាធុ សារីបុត្ត យថាតំ រេវតោ វ[១] សម្មា ព្យាករមានោ ព្យាករេយ្យ រេវតោ ហិ សារីបុត្ត បដិសល្លានារាមោ ហោតិ បដិសល្លានរតោ អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ វិបស្សនាយ សមន្នាគតោ ព្រូហេតា សុញ្ញាគារានន្តិ ។

១ ម. រេវតោ ច ។

ខ្លួនហើយ ឥឡូវនេះ យើងសូមសួរចំពោះរេវតមានអាយុ ក្នុងសេចក្តីនោះថា ម្នាលអាវុសោរេវត ព្រៃគោសិង្គសាលវ័ន គួររីករាយ រាត្រីក៏ប្រាសចាកទោស ឈើទាំងឡាយមានផ្ការីកស្គុសស្គាយសព្វកន្លែង មានក្លិនក្រអូបបីដូចជាក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោរេវត ព្រៃគោសិង្គ-សាលវ័ន រុងរឿងដោយសារភិក្ខុរូបណា បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយយ៉ាងនេះហើយ រេវតមានអាយុ ឆ្លើយតបនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ មានការពួនសម្ងំជាទីរីករាយ ត្រេកអរក្នុងការពួនសម្ងំ ប្រកបរឿយ ៗ នូវការស្ងប់ស្ងាត់ចិត្ត ប្រព្រឹត្តទៅខាងក្នុង មិនបានប្រាសចាកឈាន ប្រកបដោយវិបស្សនាបញ្ញា ជាអ្នកចម្រើននូវសុញ្ញាគារធម៌ទាំងឡាយ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបនេះឯង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសារីបុត្រ ត្រូវល្អហើយ រេវតព្យាករត្រឹមត្រូវតាមពិតមែនហើយ ម្នាលសារីបុត្រ ព្រោះថា រេវតជាអ្នកមានការពួនសម្ងំជាទីរីករាយ ត្រេកអរនឹងការពួនសម្ងំ ប្រកបរឿយ ៗ នូវការស្ងប់ស្ងាត់ចិត្តប្រព្រឹត្តទៅខាងក្នុង មិនបានប្រាសចាកឈាន ប្រកបដោយវិបស្សនាបញ្ញា ជាអ្នកចម្រើន នូវសុញ្ញាគារធម៌ទាំង-ឡាយ ។

[១៨] ឯវំ វុត្តេ អហំ ភន្តេ អាយស្មន្តំ អនុរុទ្ធំ ឯតទវោចំ ព្យាកតំ ខោ អាវុសោ អនុរុទ្ធ អាយស្មតា រេវតេន ។ បេ ។ កថំរូបេន អាវុសោ អនុរុទ្ធ ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ឯវំ វុត្តេ ភន្តេ អាយស្មា អនុរុទ្ធោ មំ ឯតទវោច ឥធាវុសោ សារីបុត្ត ភិក្ខុ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សហស្សំ លោកានំ វោលោកេតិ សេយ្យថាបិ អាវុសោ ចក្ខុមា បុរិសោ ឧបរិប្បាសាទវរគតោ សហស្សំ នេមិមណ្ឌលានំ វោលោកេយ្យ ឯវមេវ ខោ អាវុសោ សារីបុត្ត ភិក្ខុ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សហស្សំ លោកានំ វោលោកេតិ ឯវរូបេន ខោ អាវុសោ សារីបុត្ត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។ សាធុ សាធុ សារីបុត្ត យថាតំ អនុរុទ្ធោ វ សម្មា ព្យាករមានោ ព្យាករេយ្យ អនុរុទ្ធោ ហិ សារីបុត្ត ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សហស្សំ លោកានំ វោលោកេតីតិ ។

[១៨] បពិត្រព្រះអង្គដ៏ចម្រើន កាលបើរេវតមានអាយុ និយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គបាននិយាយនឹងអនុរុទ្ធមានអាយុ យ៉ាងនេះថា ម្នាលអាវុសោអនុរុទ្ធ រេវតមានអាយុបានព្យាករ ។ បេ ។ ម្នាលអាវុសោអនុរុទ្ធ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបណា បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយយ៉ាងនេះហើយ អនុរុទ្ធមានអាយុបានឆ្លើយតបនឹងខ្ញុំព្រះអង្គ យ៉ាងនេះថា ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ មើលឃើញលោកធាតុទាំងមួយពាន់ ដោយចក្ខុ បីដូចជាទិព្វដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្ស ម្នាលអាវុសោ ដូចជាបុរសមានចក្ខុ នៅខាងលើប្រាសាទដ៏ប្រសើរ ហើយក្រឡេកឃើញមណ្ឌលនៃខ្នងកង់ទាំងមួយពាន់ យ៉ាងណា ម្នាលអាវុសោសារីបុត្រ ភិក្ខុមើលឃើញលោកធាតុទាំងមួយពាន់ ដោយចក្ខុបីដូចជាទិព្វដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្ស ក៏យ៉ាងនោះដែរ ម្នាលអាវុសោសារីបុត្រ ព្រៃគោ-សិង្គសាលវ័ន រុងរឿងដោយសារភិក្ខុ រូបនេះឯង ។ ម្នាលសារីបុត្រ ត្រូវល្អហើយ អនុរុទ្ធព្យាករត្រឹមត្រូវតាមពិតមែនហើយ ម្នាលសារីបុត្រ ព្រោះថា អនុរុទ្ធមើលឃើញលោកធាតុទាំងមួយពាន់ ដោយចក្ខុបីដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្ស ។

មហាយមកវគ្គស្ស មហាគោសិង្គសាលសុត្តេ អារញ្ញកាទិប្បសំសា

[១៩] ឯវំ វុត្តេ អហំ ភន្តេ អាយស្មន្តំ មហាកស្សបំ ឯតទវោចំ ព្យាកតំ ខោ អាវុសោ កស្សប អាយស្មតា អនុរុទ្ធេន យថាសកំ បដិភានំ តត្ថ ទានិ មយំ អាយស្មន្តំ មហាកស្សបំ បុច្ឆាម ។ បេ ។ កថំរូបេន អាវុសោ កស្សប ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ឯវំ វុត្តេ ភន្តេ អាយស្មា មហាកស្សបោ មំ ឯតទវោច ឥធាវុសោ សារីបុត្ត ភិក្ខុ អត្តនា ច អារញ្ញកោ ហោតិ អារញ្ញកត្តស្ស ច វណ្ណវាទី អត្តនា ច បិណ្ឌបាតិកោ ហោតិ ។ បេ ។ បំសុកូលិកោ ហោតិ... តេចីវរិកោ ហោតិ... អប្បិច្ឆោ ហោតិ... សន្តុដ្ឋោ ហោតិ... បវិវិត្តោ ហោតិ... អសំសដ្ឋោ ហោតិ... អារទ្ធវីរិយោ ហោតិ... សីលសម្បន្នោ ហោតិ... សមាធិសម្បន្នោ ហោតិ... បញ្ញាសម្បន្នោ ហោតិ... វិមុត្តិសម្បន្នោ ហោតិ... អត្តនា ច វិមុត្តិញ្ញាណទស្សនសម្បន្នោ ហោតិ វិមុត្តិញ្ញាណទស្សនសម្បទាយ ច វណ្ណវាទី ឯវរូបេន ខោ អាវុ-

[១៩] បពិត្រព្រះអង្គដ៏ចម្រើន កាលបើអនុរុទ្ធនិយាយ យ៉ាងនេះហើយ ខ្ញុំព្រះអង្គបាននិយាយនឹងមហាកស្សបមានអាយុ យ៉ាងនេះថា ម្នាលអាវុសោកស្សប អនុរុទ្ធមានអាយុ បានព្យាករនូវបដិភាន សមគួរដល់ខ្លួនហើយ ឥឡូវនេះ យើងសូមសួរនូវមហាកស្សប មានអាយុក្នុងសេចក្ដីនោះថា ។ បេ ។ ម្នាលអាវុសោកស្សប ព្រៃគោសិង្គសាលរនៃរុងរឿង ដោយសារភិក្ខុ រូបណា បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយ យ៉ាងនេះហើយ មហាកស្សបមានអាយុ បាននិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅក្នុងព្រៃខ្លួនឯងផង សរសើរនូវគុណនៃអ្នកនៅក្នុងព្រៃផង ជាអ្នកប្រព្រឹត្តបិណ្ឌបាតខ្លួនឯងផង ។ បេ ។ ជាអ្នកទ្រទ្រង់សំពត់បង្សុកូល... ជាអ្នកប្រើប្រាស់ចំពោះតែចីវរបី... ជាអ្នកឥតសេចក្ដីប្រាថ្នា... ជាអ្នកសន្ដោស... ជាអ្នកស្ងប់ស្ងាត់... ជាអ្នកមិននៅច្រឡូកច្រឡំ... ជាអ្នកមានព្យាយាមតឹងតែងហើយ... ជាអ្នកបរិបូណ៌ដោយសីល... ជាអ្នកបរិបូណ៌ដោយសមាធិ... ជាអ្នកបរិបូណ៌ដោយបញ្ញា... ជាអ្នកបរិបូណ៌ដោយវិមុត្តិ... ជាអ្នកបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈខ្លួនឯងផង សរសើរការបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈផង ម្នាលអាវុសោ

សោ សារីបុត្ត ភិក្ខុ ជា គោសិង្គសាលវនំ សោភេយ្យា-
តិ ។ សាធុ សាធុ សារីបុត្ត យថាតំ កស្សបោ សម្មា ព្យាករមានោ ព្យាករេយ្យ កស្សបោ ហិ សារីបុត្ត អត្តនា ច អារញ្ញកោ ហោតិ អារញ្ញកត្តស្ស ច វណ្ណវាទី អត្តនា ច បិណ្ឌបាតិកោ ហោតិ បិណ្ឌ-
បាតិកត្តស្ស ច វណ្ណវាទី អត្តនា ច បំសុកូលិកោ ហោតិ បំសុកូលិកត្តស្ស ច វណ្ណវាទី អត្តនា ច តេចីវរិកោ ហោតិ តេចីវរិកត្តស្ស ច វណ្ណវាទី អត្តនា ច អប្បិច្ឆោ ហោតិ អប្បិច្ឆតាយ ច វណ្ណវាទី អត្តនា ច សន្តុដ្ឋោ ហោតិ សន្តុដ្ឋិយា ច វណ្ណវាទី អត្តនា ច បវិវិត្តោ ហោតិ បវិវេកស្ស ច វណ្ណវាទី អត្តនា ច អសំសដ្ឋោ ហោតិ អសំសគ្គស្ស ច វណ្ណវាទី អត្តនា ច អារទ្ធវិរិយោ ហោតិ វិរិយារម្ភស្ស ច វណ្ណវាទី អត្តនា ច សីលសម្បន្នោ ហោតិ សីលសម្បទាយ ច វណ្ណវាទី អត្តនា ច សមាធិសម្បន្នោ ហោតិ សមាធិសម្បទាយ ច វណ្ណវាទី អត្តនា ច បញ្ញាសម្បន្នោ ហោតិ បញ្ញា-
សម្បទាយ ច វណ្ណវាទី អត្តនា ច វិមុត្តិសម្បន្នោ

សារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុ រូបនេះឯង ។ ម្នាលសារីបុត្រ ត្រូវល្អហើយ កស្សបព្យាករត្រឹមត្រូវតាមពិតមែនហើយ ម្នាលសារីបុត្រ ព្រោះថា កស្សបជាអ្នកនៅក្នុងព្រៃខ្លួនឯងផង សរសើរគុណនៃអ្នកនៅក្នុងព្រៃផង ជាអ្នកប្រព្រឹត្តបិណ្ឌបាតខ្លួនឯងផង សរសើរគុណនៃអ្នកប្រព្រឹត្តបិណ្ឌបាតផង ជាអ្នកទ្រទ្រង់នូវសំពត់បង្សុកូលខ្លួនឯងផង សរសើរគុណនៃអ្នកទ្រទ្រង់សំពត់បង្សុកូលផង ជាអ្នកទ្រទ្រង់តែចីវរបីខ្លួនឯងផង សរសើរគុណនៃអ្នកទ្រទ្រង់ចំពោះតែចីវរបីផង ជាអ្នកឥតសេចក្តីប្រាថ្នាខ្លួនឯងផង សរសើរគុណនៃអ្នកឥតសេចក្តីប្រាថ្នាផង ជាអ្នកសន្តោសខ្លួនឯងផង សរសើរគុណនៃសេចក្តីសន្តោសផង ជាអ្នកមានសេចក្តីស្ងប់ស្ងាត់ខ្លួនឯងផង សរសើរនូវសេចក្តីស្ងប់ស្ងាត់ផង ជាអ្នកមិននៅច្រឡូកច្រឡំខ្លួនឯងផង សរសើរនូវសេចក្តីមិននៅច្រឡូកច្រឡំផង ជាអ្នកមានព្យាយាមប្រារព្ធខ្លួនឯងផង សរសើរនូវសេចក្តីប្រារព្ធព្យាយាមផង ជាអ្នកបរិបូណ៌ដោយសីលខ្លួនឯងផង សរសើរការបរិបូណ៌ដោយសីលផង ជាអ្នកបរិបូណ៌ដោយសមាធិខ្លួនឯងផង សរសើរការបរិបូណ៌ដោយសមាធិផង ជាអ្នកបរិបូណ៌ដោយបញ្ញាខ្លួនឯងផង សរសើរការបរិបូណ៌ដោយបញ្ញាផង ជាអ្នកបរិបូណ៌ដោយវិមុត្តិខ្លួនឯងផង

ហោតិ វិមុត្តិសម្បទាយ ច វណ្ណវាទី អត្តនា ច វិមុត្តិញ្ញាណទស្សនសម្បន្នោ ហោតិ វិមុត្តិញ្ញាណទស្សន-សម្បទាយ ច វណ្ណវាទីតិ ។

[២០] ឯវំ វុត្តេ អហំ ភន្តេ អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោចំ ព្យាកតំ ខោ អាវុសោ មោគ្គល្លាន អាយស្មតា ច[១] មហាកស្សបេន យថាសកំ បដិភានំ តត្ថទានិ មយំ អាយស្មន្តំ មហាមោគ្គល្លានំ បុច្ឆាម ។ បេ ។ កថំរូបេន អាវុសោ មោគ្គល្លាន ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ឯវំ វុត្តេ អាយស្មា មហា-មោគ្គល្លានោ មំ ឯតទវោច ឥធាវុសោ សារីបុត្ត ទ្វេ ភិក្ខូ អភិធម្មកថំ កថេន្តិ តេ អញ្ញមញ្ញំ បញ្ហំ បុច្ឆន្តិ អញ្ញមញ្ញស្ស បញ្ហំ បុដ្ឋា វិស្សជ្ជេន្តិ នោ ច សំសាទេន្តិ ធម្មី ច នេសំ កថា បវត្តនី ហោតិ ឯវរូបេន ខោ អាវុសោ សារីបុត្ត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។ សាធុ សាធុ

១ ម. ចសទ្ទោ ន ទិស្សតិ ។

សរសើរការបរិបូណ៌ដោយវិមុត្តិផង ជាអ្នកបរិបូណ៌ដោយវិមុត្តិញ្ញាណ-ទស្សនៈដោយខ្លួនឯងផង សរសើរការបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈផង ។

[២០] បពិត្រព្រះអង្គដ៏ចម្រើន កាលបើមហាកស្សបនិយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គបាននិយាយ នឹងមហាមោគ្គល្លានមានអាយុ យ៉ាងនេះថា ម្នាលអាវុសោមោគ្គល្លាន មហាកស្សបមានអាយុ បានព្យាករនូវបដិភាន សមគួរដល់ខ្លួនហើយ ឥឡូវនេះ យើងសូមសួរមហា-មោគ្គល្លានមានអាយុ ក្នុងសេចក្តីនោះថា ។ បេ ។ ម្នាលអាវុសោមោគ្គ-ល្លាន ព្រៃគោសិង្គសាលវ័ន រុងរឿង ដោយសារភិក្ខុរូបណា បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយយ៉ាងនេះហើយ មោគ្គល្លានមានអាយុ បាននិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអាវុសោសារី-បុត្រ ភិក្ខុពីររូបក្នុងសាសនានេះ សំដែងនូវអភិធម្មកថា ភិក្ខុទាំងនោះសួរប្រស្នានូវគ្នានឹងគ្នា លុះសួរប្រស្នាហើយ ដោះស្រាយដល់គ្នានឹងគ្នាក៏មិនបានរុករានគ្នាផង កថារបស់ភិក្ខុទាំងនោះ ប្រព្រឹត្តទៅ ប្រកបដោយធម៌ផង ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុង-រឿងដោយសារភិក្ខុ រូបនេះឯង ។ ម្នាលសារីបុត្រ ត្រូវល្អហើយ

សារីបុត្ត យថាតំ មោគ្គល្លានោ វ សម្មា ព្យាករមានោ ព្យាករេយ្យ មោគ្គល្លានោ ហិ សារីបុត្ត ធម្មកថិកោតិ ។

[២១] ឯវំ វុត្តេ អាយស្មា មហាមោគ្គល្លានោ ភគវន្តំ ឯតទវោច អថខ្វាហំ[១] ភន្តេ អាយស្មន្តំ សារីបុត្តំ ឯតទវោចំ ព្យាកតំ ខោ អាវុសោ សារីបុត្ត អម្ហេហិ សព្វេហេវ យថាសកំ បដិភានំ តត្ថ ទានិ មយំ អាយស្មន្តំ សារីបុត្តំ បុច្ឆាម រមណីយំ អាវុសោ សារីបុត្ត គោសិង្គសាលវនំ ទោសិនា រត្តិ សព្វផាលិផុល្លា សាលា ទិព្វា មញ្ញេ គន្ធា សម្បវន្តិ កថំរូបេន អាវុសោ សារីបុត្ត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ឯវំ វុត្តេ ភន្តេ អាយស្មា សារីបុត្តោ មំ ឯតទវោច ឥធាវុសោ មោគ្គល្លាន ភិក្ខុ ចិត្តំ វសំ វត្តេតិ នោ ច ភិក្ខុ ចិត្តស្ស វសេន វត្តតិ សោ យាយ វិហារសមាបត្តិយា អាកង្ខតិ បុព្វណ្ហសមយំ វិហរិតុំ

១ ម. អថវាហំ ។

មោគ្គល្លានព្យាករ ត្រឹមត្រូវតាមពិតមែនហើយ ម្នាលសារីបុត្រ ព្រោះថា មោគ្គល្លាន ជាធម្មកថិក ។

[២១] កាលបើព្រះសារីបុត្រនិយាយ យ៉ាងនេះថា ព្រះមហាមោគ្គល្លាន មានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ខ្ញុំព្រះអង្គបាននិយាយនឹងសារីបុត្រមានអាយុយ៉ាងនេះថា ម្នាលអាវុសោសារីបុត្រ យើងទាំងអស់គ្នា សុទ្ធតែបានព្យាករបដិភាន តាមសមគួរដល់ខ្លួនហើយ ឥឡូវនេះយើងសូមសួរសារីបុត្រមានអាយុ ក្នុងសេចក្តីនោះថា ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន គួររីករាយ រាត្រីសោតក៏ប្រាសចាកទោស ឈើទាំងឡាយមានផ្ការីកស្គុសស្គាយសព្វកន្លែង មានក្លិនក្រអូបបីដូចជាក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបណា បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយយ៉ាងនេះហើយ សារីបុត្រមានអាយុបាននិយាយនឹងខ្ញុំព្រះអង្គ យ៉ាងនេះថា ម្នាលអាវុសោមោគ្គល្លាន ភិក្ខុក្នុងសាសនានេះ ញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាច (ខ្លួន) ផង ភិក្ខុមិនបានប្រព្រឹត្តទៅតាមអំណាចរបស់ចិត្តផង ភិក្ខុនោះប្រាថ្នាដើម្បីនៅ អស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិណា

៣៧

មហាយមកវគ្គស្ស មហាគោសិង្គសាលសុត្តេ សមាបត្តិប្បសំសា

តាយ វិហារសមាបត្តិយា បុព្វណ្ហសមយំ វិហរតិ យាយ វិហារសមាបត្តិយា អាកង្ខតិ មជ្ឈន្តិកសមយំ វិហរិតុំ តាយ វិហារសមាបត្តិយា មជ្ឈន្តិកសមយំ វិហរតិ យាយ វិហារសមាបត្តិយា អាកង្ខតិ សាយណ្ហសមយំ វិហរិតុំ តាយ វិហារសមាបត្តិយា សាយណ្ហសមយំ វិហរតិ សេយ្យថាបិ អាវុសោ មោគ្គល្លាន រញ្ញោ វា រាជមហាមត្តស្ស វា នានារត្តានំ ទុស្សានំ ទុស្សករណ្ឌកោ បូរោ អស្ស សោ យញ្ញទេវ ទុស្សយុគំ អាកង្ខេយ្យ បុព្វណ្ហសមយំ បារុបិតុំ តំតទេវ ទុស្សយុគំ បុព្វណ្ហសមយំ បារុបេយ្យ យញ្ញទេវ ទុស្សយុគំ អាកង្ខេយ្យ មជ្ឈន្តិកសមយំ បារុបិតុំ តំតទេវ មជ្ឈន្តិកសមយំ បារុបេយ្យ យញ្ញទេវ ទុស្សយុគំ អាកង្ខេយ្យ សាយណ្ហសមយំ បារុបិតុំ តំតទេវ ទុស្សយុគំ សាយណ្ហសមយំ បារុបេយ្យ ឯវមេវ ខោ អាវុសោ មោគ្គល្លាន ភិក្ខុ ចិត្តំ វសំ វត្តេតិ នោ ច ភិក្ខុ ចិត្តស្ស វសេន វត្តតិ

ក៏នៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិនោះបាន បើប្រាថ្នាដើម្បីនៅអស់មជ្ឈន្តិកសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់មជ្ឈន្តិកសម័យ ដោយវិហារសមាបត្តិនោះបាន បើប្រាថ្នាដើម្បីនៅអស់សាយណ្ហសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់សាយណ្ហសម័យ ដោយវិហារសមាបត្តិនោះបាន ម្នាលអាវុសោមោគ្គល្លាន ដូចជាហិបសំពត់ដ៏ពេញដោយសំពត់ទាំងឡាយ ជ្រលក់ដោយពណ៌ផ្សេង ៗ របស់ព្រះរាជា ឬរាជមហាមាត្យ ព្រះរាជានិងរាជមហាមាត្យនោះ បើប្រាថ្នាដើម្បីទ្រទ្រង់នូវគូសំពត់ណា អស់បុព្វណ្ហសម័យ ក៏ទ្រទ្រង់នូវគូសំពត់នោះ ៗ អស់បុព្វណ្ហសម័យ បើប្រាថ្នាដើម្បីទ្រទ្រង់នូវគូសំពត់ណា អស់មជ្ឈន្តិកសម័យ ក៏ទ្រទ្រង់នូវគូសំពត់នោះ ៗ អស់មជ្ឈន្តិកសម័យ បើប្រាថ្នាដើម្បីទ្រទ្រង់នូវគូសំពត់ណា អស់សាយណ្ហសម័យ ក៏ទ្រទ្រង់នូវគូសំពត់នោះ ៗ អស់សាយណ្ហសម័យ ម្នាលអាវុសោមោគ្គល្លាន ភិក្ខុញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចខ្លួនផង ភិក្ខុមិនបានប្រព្រឹត្តទៅតាមអំណាចនៃ

សោ យាយ វិហារសមាបត្តិយា អាកង្ខតិ បុព្វណ្ហសមយំ វិហរិតុំ តាយ វិហារសមាបត្តិយា បុព្វណ្ហសមយំ វិហរតិ យាយ វិហារសមាបត្តិយា អាកង្ខតិ មជ្ឈន្តិកសមយំ វិហរិតុំ តាយ វិហារសមាបត្តិយា មជ្ឈន្តិកសមយំ វិហរតិ យាយ វិហារសមាបត្តិយា អាកង្ខតិ សាយណ្ហសមយំ វិហរិតុំ តាយ វិហារសមាបត្តិយា សាយណ្ហសមយំ វិហរតិ ឯវរូបេន ខោ អាវុសោ មោគ្គល្លាន ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។ សាធុ សាធុ មោគ្គល្លាន យថាតំ សារីបុត្តោវ សម្មា ព្យាករមានោ ព្យាករេយ្យ សារីបុត្តោ ហិ មោគ្គល្លាន ចិត្តំ វសំ វត្តេតិ នោ ច សារីបុត្តោ ចិត្តស្ស វសេន វត្តតិ សោ យាយ វិហារសមាបត្តិយា អាកង្ខតិ បុព្វណ្ហសមយំ វិហរិតុំ តាយ វិហារសមាបត្តិយា បុព្វណ្ហសមយំ វិហរតិ យាយ វិហារសមាបត្តិយា អាកង្ខតិ មជ្ឈន្តិកសមយំ វិហរិតុំ តាយ វិហារសមាបត្តិយា មជ្ឈន្តិកសមយំ វិហរតិ យាយ វិហារសមាបត្តិយា អាកង្ខតិ សាយណ្ហសមយំ វិហរិតុំ តាយ វិហារសមាបត្តិយា សាយណ្ហសមយំ វិហរតីតិ ។

ចិត្តផង ភិក្ខុនោះប្រាថ្នាដើម្បីនៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិនោះ បើប្រាថ្នាដើម្បីនៅអស់មជ្ឈន្តិកសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់មជ្ឈន្តិកសម័យ ដោយវិហារសមាបត្តិនោះ បើប្រាថ្នាដើម្បីនៅអស់សាយណ្ហសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់សាយណ្ហសម័យ ដោយវិហារសមាបត្តិនោះ ក៏យ៉ាងនោះដែរ ម្នាលអាវុសោមោគ្គល្លាន ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបនេះឯង ។ ម្នាលមោគ្គល្លាន ត្រូវល្អហើយ សារីបុត្រព្យាករត្រឹមត្រូវ តាមពិតមែនហើយ ម្នាលមោគ្គល្លាន ព្រោះថាសារីបុត្រ រមែងញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចខ្លួនផង សារីបុត្រមិនបានប្រព្រឹត្តទៅ តាមអំណាចនៃចិត្តផង សារីបុត្រនោះ ប្រាថ្នាដើម្បីនៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិនោះ បើប្រាថ្នាដើម្បីនៅ អស់មជ្ឈន្តិកសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់មជ្ឈន្តិកសម័យ ដោយវិហារសមាបត្តិនោះ បើប្រាថ្នានៅ អស់សាយណ្ហសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់សាយណ្ហសម័យ ដោយវិហារសមាបត្តិនោះ ។

៣៩

មហាយមកវគ្គស្ស  មហាគោសិង្គសាលសុត្តេ  អាសវក្ខយប្បសំសា

[២២] ឯវំ វុត្តេ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច កស្ស នុ ខោ ភន្តេ សុភាសិតន្តិ ។ សព្វេសំ វោ សារីបុត្ត សុភាសិតំ បរិយាយេន អបិច មម វចនំ សុណាថ យថារូបេន ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ឥធ សារីបុត្ត ភិក្ខុ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ន តាវាហំ ឥមំ បល្លង្កំ ភិន្ទិស្សាមិ យាវ មេ ន អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតីតិ ឯវរូបេន ខោ សារីបុត្ត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យាតិ ។ ឥទមវោច ភគវា អត្តមនា តេ អាយស្មន្តោ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

មហាគោសិង្គសាលសុត្តំ ទុតិយំ និដ្ឋិតំ ។

[២២] កាលបើព្រះមោគ្គល្លាន និយាយយ៉ាងនេះហើយ ព្រះសារីបុត្រមានអាយុ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន លោកណានិយាយត្រូវ ។ ព្រះអង្គត្រាស់ថា ម្នាលសារីបុត្រ បើដោយបរិយាយ អ្នកទាំងអស់គ្នាសុទ្ធតែនិយាយត្រូវហើយ ប៉ុន្តែអ្នកទាំងឡាយ ចូរស្តាប់ពាក្យរបស់តថាគត ព្រៃគោសិង្គសាលវ័នរុងរឿង ដោយសារភិក្ខុ រូបណានោះចុះ ម្នាលសារីបុត្រ ភិក្ខុក្នុងសាសនានេះ ត្រឡប់មកពីបិណ្ឌបាតវិញ ខាងក្រោយនៃភត្ត ក៏ចូលទៅអង្គុយពែនភ្នែន ដោយកាយឲ្យត្រង់ ផ្ចង់សតិឲ្យត្រង់ទៅមុខដោយគិតថា ចិត្តរបស់អាត្មាអញ មិនរួចចាកអាសវក្កិលេសទាំងឡាយ ព្រោះមិនមានសេចក្តីប្រកាន់ដរាបណា អាត្មាអញ នឹងមិនទម្លាយភ្នែននោះដរាបនោះ ដូច្នេះ ម្នាលសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុ រូបនេះឯង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សេចក្តីនេះហើយ ព្រះថេរៈ មានអាយុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ មហាគោសិង្គសាលសូត្រ ទី ២ ។

# តតិយំ មហាគោបាលសុត្តំ

[២៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សា-
វត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។
ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[២៤] ភគវា ឯតទវោច ឯកាទសហិ ភិក្ខវេ
អង្គេហិ សមន្នាគតោ គោបាលកោ អភព្វោ គោគណំ
បរិហរិតុំ ផាតិកាតុំ កតមេហិ ឯកាទសហិ ឥធ
ភិក្ខវេ គោបាលកោ ន រូបញ្ញូ ហោតិ ន លក្ខណ-
កុសលោ ហោតិ ន អាសាដិកំ សាដេតា ហោតិ ន
វណំ បដិច្ឆាទេតា ហោតិ ន ធូមំ កត្តា ហោតិ ន
តិត្ថំ ជានាតិ ន បីតំ ជានាតិ ន វីថឹ ជានាតិ ន គោ-
ចរកុសលោ ហោតិ អនវសេសទោហី ច ហោតិ

# មហាគោបាលសូត្រ ទី ៣

[២៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា នែភិក្ខុទាំងឡាយ ។ ឯភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ។

[២៤] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ប្រកបដោយអង្គទាំងឡាយ ១១ មិនគួរដើម្បីរក្សា នូវហ្វូងគោ មិនគួរដើម្បីញុំាងហ្វូងគោឲ្យចម្រើនឡើងបានឡើយ អង្គ ១១ តើដូចម្តេចខ្លះ ម្នាលភិក្ខុទាំងឡាយ គង្វាលគោ ក្នុងលោកនេះ ជាអ្នកមិនស្គាល់រូប (របស់គោ) ១ មិនឈ្លាសក្នុងលក្ខណៈ គឺភិនភាគស្លាកស្នាម ១ មិនផ្តិះពងរុយត្រង់ដំបៅគោ ១ មិនបិទដំបៅ ១ មិនបំពក់ផ្សែង ១ មិនស្គាល់កំពង់ទឹក ១ មិនដឹងថាគោបានផឹកទឹកហើយឬនៅឡើយ ១ មិនស្គាល់ផ្លូវ ១ មិនឈ្លាសក្នុងកន្លែងឃ្វាលគោ ១ រឹតទឹកដោះមិនឲ្យនៅសល់ ១

មហាយមកវគ្គស្ស មហាគោបាលសុត្តេ វណ្ណាភព្វតា

យេ តេ ឧសភា គោបិតរោ គោបរិណាយកា តេ ន អតិរេកបូជាយ បូជេតា ហោតិ ឥមេហិ ខោ ភិក្ខវេ ឯកាទសហិ អង្គេហិ សមន្នាគតោ គោចាលកោ អភព្វោ គោគណំ បរិហរិតុំ ផាតិកាតុំ ឯវមេវ ខោ ភិក្ខវេ ឯកាទសហិ អង្គេហិ សមន្នាគតោ ភិក្ខុ អភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិតុំ កតមេហិ ឯកាទសហិ ឥធ ភិក្ខវេ ភិក្ខុ ន រូបញ្ញូ ហោតិ ន លក្ខណកុសលោ ហោតិ ន អាសាដិកំ សាដេតា ហោតិ ន វណំ បដិច្ឆាទេតា ហោតិ ន ធូមំ កត្តា ហោតិ ន តិត្ថំ ជានាតិ ន បីតំ ជានាតិ ន វីថឹ ជានាតិ ន គោចរកុសលោ ហោតិ

*គោឧសភទាំងឡាយណា ជាបិតា (បា) របស់គោ ជាបរិនាយក (មេហ្វូង) របស់គោ មិនបូជានូវគោឧសភទាំងនោះ ដោយគ្រឿងបូជាដ៏ក្រៃលែង[១] ១ ម្នាលភិក្ខុទាំងឡាយ គង្វាលគោប្រកបព្រម ដោយអង្គទាំង ១១ នេះឯង មិនគួរដើម្បីរក្សានូវហ្វូងគោ មិនគួរដើម្បីញុំាំងហ្វូងគោឲ្យចម្រើនបានឡើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបព្រម ដោយអង្គទាំងឡាយ ១១ ក៏មិនគួរដើម្បីដល់នូវសេចក្តីចម្រើន លូតលាស់ ពេញទូលាយ ក្នុងធម៌វិន័យនេះ ក៏ដូច្នោះដែរ អង្គទាំង ១១ តើដូចម្តេចខ្លះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនស្គាល់រូប ១ មិនឈ្លាសក្នុងលក្ខណៈ ១ មិនគ្ចេះពង់រុយ ១ មិនបិទដំបៅ ១ មិនបំពក់ផ្សែង ១ មិនស្គាល់កំពង់ទឹក ១ មិនដឹងថាខ្លួនបានផឹកទឹកហើយ ឬនៅឡើយ ១ មិនស្គាល់ផ្លូវ ១ មិនឈ្លាសក្នុងកន្លែងគោចរ ១*

១ ត្រង់ដែលថាមិនបូជាដោយគ្រឿងបូជាដ៏ក្រៃលែងនោះ គឺគង្វាលគោដែលឈ្លាសតែងឲ្យនូវចំណីល្អ ប្រោះព្រំដោយប្រេងក្រអូបដោយម្រាមទាំង ៥ ប្រដាប់ដោយកម្រងផ្កា បំពាក់ចង្កុំមាសចង្កុំប្រាក់ត្រង់ស្នែង អុជប្រទីបបំភ្លឺក្នុងរាត្រី ចងពិតានអំពីលើត្រង់កន្លែងដែលគោដេក ។ គង្វាលគោដែលមិនឈ្លាស មិនធ្វើសក្ការៈណាមួយសោះ លុះពួកគោឧសភទាំងនោះ មិនបានគ្រឿងបូជាហើយ ក៏មិនរក្សាហ្វូងគោ មិនការពារអន្តរាយ គោនឹងវិនាស គង្វាលគោនោះមិនបានបញ្ចាគោរសនោះឡើយ ។ អដ្ឋកថា ។

អនវសេសនោហី ច ហោតិ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេ ន អតិរេកបូជាយ បូជេតា ហោតិ ។

[២៥] កថញ្ច ភិក្ខវេ ភិក្ខុ ន រូបញ្ញូ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យំ កិញ្ចិ រូបំ សព្វំ រូបំ ចត្តារិ មហាភូតានិ ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបន្តិ[១] យថាភូតំ នប្បជានាតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន រូបញ្ញូ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន លក្ខណកុសលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ កម្មលក្ខណោ ពាលោ កម្មលក្ខណោ បណ្ឌិតោតិ យថាភូតំ នប្បជានាតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន លក្ខណកុសលោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន អាសាដិកំ សាដេតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ អធិវាសេតិ ន បជហតិ ន វិនោទេតិ ន ព្យន្តីករោតិ[២] ន អនភាវង្គមេតិ ឧប្បន្នំ ព្យាបាទវិតក្កំ ។ បេ ។ ឧប្បន្នំ វិហឹសាវិតក្កំ

១ ឱ. ឧបាទាយរូបន្តីតិ ទិស្សតិ ។ ២ ឱ. ន ព្យន្តិករោតិ ។ ម. ន ព្យន្តឹ ករោតិ ។

រឹតយកទេយ្យវត្ថុមិនឲ្យនៅសល់ ១ ភិក្ខុទាំងឡាយណា ជាថេរ: ជាអ្នកដឹងនូវរាត្រី ជាអ្នកបួសយូរអង្វែង ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក មិនបានបូជានូវភិក្ខុជាថេរ:ទាំងនោះ ដោយការបូជាដ៏ក្រៃលែង ១ ។

[២៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនស្គាល់រូប តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនដឹងច្បាស់តាមពិតថា រូបឯណានីមួយ រូបទាំងអស់ (នោះ) គឺមហាភូតរូបទាំង ៤ ផង ឧបាទាយរូបដែលអាស្រ័យនឹងមហាភូតរូបទាំង ៤ ផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនស្គាល់រូប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនឈ្លាសក្នុងលក្ខណ: តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនស្គាល់ច្បាស់តាមពិតថា បុគ្គលពាលមានអំពើជាលក្ខណ: បណ្ឌិតមានអំពើជាលក្ខណ: ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនឈ្លាសក្នុងលក្ខណ: យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនបានគ្ដិះពងរុយ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងកាមវិតក្ក:ដែលកើតឡើងហើយ ឲ្យអាស្រ័យនៅ (ក្នុងសន្ដាន) មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាសទៅ មិនឲ្យសាបសូន្យទៅ ញុំាងព្យាបាទវិតក្ក:ដែលកើតឡើងហើយ ។ បេ ។ ញុំាងវិហិង្សាវិតក្ក:ដែលកើតឡើងហើយ

៤៣



។ បេ ។ ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ អធិវាសេតិ ន បជហាតិ ន វិនោទេតិ ន ព្យន្តីករោតិ ន អនភាវង្គមេតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន អាសាដិកំ សាដេតា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន វណំ បដិច្ឆាទេតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ នប្បដិបជ្ជតិ ន រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ ន សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ និមិត្តគ្គាហី ហោតិ អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ នប្បដិបជ្ជតិ ន រក្ខតិ

។ បេ ។ ញ៉ាំងអកុសលធម៌ដ៏លាមកទាំងឡាយ ដែលកើតឡើងរឿយ ៗ ឲ្យអាស្រ័យនៅ (ក្នុងសន្តាន) មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាសទៅ មិនឲ្យសាបសូន្យទៅ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនបានផ្តិះពងរុយចេញ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនបិទដំបៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញនូវរូបដោយភ្នែក ហើយកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ដ៏លាមកទាំងឡាយគឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវភិក្ខុជាអ្នកមិនសង្រួមនូវឥន្ទ្រិយគឺភ្នែកនុ៎ះ ដែលមានការមិនសង្រួម នូវឥន្ទ្រិយគឺភ្នែកណាជាហេតុ ក៏មិនបានប្រតិបត្តិ ដើម្បីសង្រួមនូវឥន្ទ្រិយគឺភ្នែកនោះ មិនរក្សានូវឥន្ទ្រិយគឺភ្នែក មិនដល់នូវការសង្រួមនូវឥន្ទ្រិយគឺភ្នែក ស្តាប់នូវសំឡេងដោយត្រចៀក... ហិតក្លិនដោយច្រមុះ... ទទួលរសដោយអណ្តាត... ពាល់ត្រូវនូវផោដ្ឋព្វារម្មណ៍ដោយកាយ... ដឹងច្បាស់នូវធម៌ដោយចិត្ត ហើយកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ អកុសល-ធម៌ដ៏លាមកទាំងឡាយគឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវភិក្ខុជាអ្នកមិនសង្រួមនូវឥន្ទ្រិយគឺចិត្តនុ៎ះ ដែលមានការមិនសង្រួមនូវឥន្ទ្រិយគឺចិត្តណាជាហេតុ ក៏មិនប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយគឺចិត្តនោះ មិនរក្សា

មនិន្ទ្រិយំ មនិន្ទ្រិយេ ន សំវរំ អាបជ្ជតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន វណំ បដិច្ឆាទេតា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន ធូមំ កត្តា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យថាសុតំ យថាបរិយត្តំ ធម្មំ ន វិត្ថារេន បរេសំ ទេសេតា ហោតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន ធូមំ កត្តា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន តិត្ថំ ជានាតិ ។ ឥធ ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា តេ កាលេន កាលំ ឧបសង្កមិត្វា ន បរិបុច្ឆតិ ន បរិបញ្ហតិ ឥទំ ភន្តេ កថំ ឥមស្ស កោ អត្ថោតិ តស្ស តេ អាយស្មន្តោ អវិវដញ្ចេវ ន វិវរន្តិ អនុត្តានីកតញ្ច ន ឧត្តានីករោន្តិ អនេកវិហិតេសុ ច កង្ខដ្ឋានីយេសុ[១] ធម្មេសុ កង្ខំ ន បដិវិនោទេន្តិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន តិត្ថំ ជានាតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន បីតំ ជានាតិ ។ ឥធ ភិក្ខវេ ភិក្ខុ តថាគតប្បវេទិតេ ធម្មវិនយេ ទេសិយមានេ ន លភតិ

---

១ ឱ. កំខាឋានីយេសុ ។ ម. កង្ខាឋានីយេសុ ។

នូវឥន្ទ្រិយគឺចិត្ត មិនដល់នូវការសង្រួមក្នុងឥន្ទ្រិយគឺចិត្ត ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុអ្នកមិនបានបិទដំបៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនបំពក់ផ្សែង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះមិនសំដែងធម៌ដែលខ្លួនបានស្តាប់មកយ៉ាងណា បានរៀនមកយ៉ាងណាដោយពិស្តារ ដល់ជនទាំងឡាយដទៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនបំពក់ផ្សែង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់កំពង់ទឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនចូលទៅរកពួកភិក្ខុដែលជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកាហើយសាកសួរ ប្រឹក្សារម្តងម្កាលដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្យញ្ជនៈនេះត្រូវរៀងដូចម្តេច សេចក្តីនៃភាសិតនេះដូចម្តេច ឯលោកដ៏មានអាយុទាំងនោះ ក៏មិនបានបើកចេញ នូវសេចក្តីកំបាំងផង មិនបានធ្វើនូវសេចក្តីដែលជ្រៅឲ្យរាក់ង៉ាយផង មិនបានបន្ទោបង់នូវសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីសង្ស័យច្រើនប្រការផង ដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់កំពង់ទឹក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនដឹងថាខ្លួនបានផឹកទឹកហើយឬនៅឡើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះកាលបើគេកំពុងសំដែងធម៌វិន័យ ដែលតថាគតប្រកាសហើយ ក៏មិនបាន

អត្ថវេទំ ន លភតិ ធម្មវេទំ ន លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន បីតំ ជានាតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន វីថឹ ជានាតិ ។ ឥធ ភិក្ខវេ ភិក្ខុ អរិយំ អដ្ឋង្គិកំ មគ្គំ យថាភូតំ នប្បជានាតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន វីថឹ ជានាតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន គោចរកុសលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចត្តារោ សតិប្បដ្ឋានេ យថាភូតំ នប្បជានាតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ន គោចរកុសលោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អនវសេសទោហី ច ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធា គហបតិកា អភិហដ្ឋុំ បវារេន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជ-បរិក្ខារេហិ តត្ថ[១] ភិក្ខុ មត្តំ ន ជានាតិ បដិគ្គ-ហណាយ ឯវំ ខោ ភិក្ខវេ ភិក្ខុ អនវសេសទោហី ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា

---
១ ឱ. ម. តត្រ ។

នូវសេចក្តីត្រេកអរក្នុងអត្ថ មិនបាននូវសេចក្តីត្រេកអរក្នុងធម៌ មិនបាននូវបាមោជ្ជៈដែលប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនដឹងថាខ្លួនបានផឹកទឹកហើយឬនៅឡើយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់ផ្លូវ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនស្គាល់ច្បាស់នូវផ្លូវប្រកបដោយអង្គ ៨ ដ៏ប្រសើរតាមសេចក្តីពិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់ផ្លូវ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនឈ្លាសក្នុងកន្លែងគោចរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបានស្គាល់ច្បាស់នូវសតិប្បដ្ឋាន ៤ តាមសេចក្តីពិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនឈ្លាសក្នុងកន្លែងគោចរ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នករីតយកទេយ្យវត្ថុមិនឲ្យនៅសល់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មានពួកគហបតីដែលមានសទ្ធា បាននាំយកចីវរបិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ មកបវារណាចំពោះភិក្ខុក្នុងសាសនានេះហើយ ភិក្ខុមិនស្គាល់ប្រមាណក្នុងការទទួលបច្ច័យទាំងនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នករីតយកទេយ្យវត្ថុមិនឲ្យនៅសល់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបូជាពួកភិក្ខុជាថេរៈ ដឹងនូវរាត្រី បួសយូរអង្វែង ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក

តេ ន អតិរេកបូជាយ បូជេតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេសុ ន មេត្តំ កាយកម្មំ បច្ចុបដ្ឋបេតិ អាវី ចេវ រហោ ច ន មេត្តំ វចីកម្មំ... ន មេត្តំ មនោកម្មំ បច្ចុបដ្ឋបេតិ អាវី ចេវ រហោ ច ឯវំ ខោ ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេ ន អតិរេកបូជាយ បូជេតា ហោតិ ឥមេហិ ខោ ភិក្ខវេ ឯកាទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិតុំ ។

[២៦] ឯកាទសហិ ភិក្ខវេ អង្គេហិ សមន្នាគតោ គោបាលកោ ភព្វោ គោគណំ បរិហរិតុំ ផាតិកាតុំ កតមេហិ ឯកាទសហិ ឥធ ភិក្ខវេ គោបាលកោ រូបញ្ញូ ហោតិ លក្ខណកុសលោ ហោតិ អាសាដិកំ សាដេតា ហោតិ វណំ បដិច្ឆាទេតា ហោតិ ធូមំ កត្តា ហោតិ តិត្ថំ ជានាតិ បីតំ ជានាតិ

ដោយការបូជាដ៏ក្រៃលែង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបានតម្កល់មេត្តាកាយកម្ម ក្នុងទីចំពោះមុខនិងទីកំបាំងមុខ មិនតម្កល់មេត្តាវចីកម្ម មិនតម្កល់មេត្តាមនោកម្ម ក្នុងទីចំពោះមុខ និងទីកំបាំងមុខ ចំពោះភិក្ខុទាំងឡាយដែលជាថេរៈ ដឹងនូវរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបានបូជាពួកភិក្ខុដែលជាថេរៈ ដឹងនូវរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក ដោយការបូជាដ៏ក្រៃលែង យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបព្រមដោយធម៌ទាំង ១១ នេះឯង មិនគួរដើម្បីដល់នូវសេចក្តីចម្រើន លូតលាស់ ពេញទូលាយ ក្នុងធម្មវិន័យនេះបានឡើយ ។

[២៦] ម្នាលភិក្ខុទាំងឡាយ គង្វាលគោប្រកបព្រមដោយអង្គទាំង ១១ ទើបគួរដើម្បីរក្សានូវហ្វូងគោ គួរដើម្បីញុំាងហ្វូងគោឲ្យចម្រើនបាន អង្គទាំង ១១ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ គង្វាលគោក្នុងលោកនេះ ជាអ្នកស្គាល់នូវរូបគោ ១ ឈ្លាសក្នុងលក្ខណៈ ១ ធ្កឹះនូវពងរុយ ១ បិទដំបៅ ១ បំពក់ផ្សែង ១ ស្គាល់កំពង់ទឹក ១ ដឹងថាគោបានផឹកទឹក

៤៧



វីថឹ ជានាតិ គោចរកុសលោ ហោតិ សាវសេសទោ-ហី ច ហោតិ យេ តេ ឧសភា គោបិតរោ គោបរិណា-យកា តេ អតិរេកបូជាយ បូជេតា ហោតិ ឥមេហិ ខោ ភិក្ខវេ ឯកាទសហិ អង្គេហិ សមន្នាគតោ គោបាលកោ ភព្វោ គោគណំ បរិហរិតុំ ផាតិកាតុំ ឯវមេវ ខោ ភិក្ខវេ ឯកាទសហិ អង្គេហិ សមន្នាគ-តោ ភិក្ខុ ភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិតុំ កតមេហិ ឯកាទសហិ ឥធ ភិក្ខវេ ភិក្ខុ រូបញ្ញូ ហោតិ លក្ខណកុសលោ ហោតិ អាសាដិកំ សាដេតា ហោតិ វណំ បដិច្ឆាទេតា ហោតិ ធូមំ កត្តា ហោតិ តិត្ថំ ជានាតិ បីតំ ជានាតិ វីថឹ ជានាតិ គោចរកុសលោ ហោតិ សាវសេសទោហី ច ហោតិ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃ-បរិណាយកា តេ អតិរេកបូជាយ បូជេតា ហោតិ ។

ហើយ ឬនៅឡើយ ១ ស្គាល់ផ្លូវ ១ ឈ្លាសក្នុងកន្លែងឃ្វាលគោ ១ រីតទឹកដោះឲ្យនៅសល់ ១ គោឧសភទាំងឡាយណា ជាបិតារបស់គោ ជាបរិនាយករបស់គោ រមែងបូជាគោឧសភទាំងនោះ ដោយគ្រឿងបូជាដ៏ក្រៃលែង ១ ម្នាលភិក្ខុទាំងឡាយ គង្វាលគោប្រកបដោយអង្គទាំង ១១ នេះ ទើបគួរដើម្បីរក្សានូវហ្វូងគោ គួរដើម្បីញ៉ាំងហ្វូងគោឲ្យចម្រើនបាន (យ៉ាងណាមិញ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបព្រមដោយអង្គទាំង ១១ ទើបគួរដល់នូវសេចក្ដីចម្រើន លូតលាស់ ពេញទូលាយ ក្នុងធម្មវិន័យនេះ យ៉ាងដូច្នោះដែរ អង្គទាំង ១១ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្គាល់រូប ១ ឈ្លាសក្នុងលក្ខណៈ ១ ផ្ចិះនូវពងរុយ ១ បិទនូវដំបៅ ១ បំពក់ផ្សែង ១ ស្គាល់នូវកំពង់ទឹក ១ ដឹងថាខ្លួនបានផឹកទឹកហើយ ឬនៅឡើយ ១ ស្គាល់ផ្លូវ ១ ឈ្លាសក្នុងកន្លែងគោចរ ១ រីតយកទេយ្យវត្ថុឲ្យនៅសល់ ១ បូជាពួកភិក្ខុដែលជាថេរៈ ដឹងនូវរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក ដោយការបូជាដ៏ក្រៃលែង ១ ។

[២៧] កថញ្ច ភិក្ខវេ ភិក្ខុ រូបញ្ញូ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យំ កិញ្ចិ រូបំ សព្វំ រូបំ ចត្តារិ មហាភូតានិ ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបន្តិ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ រូបញ្ញូ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ លក្ខណកុសលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ កម្មលក្ខណោ ពាលោ កម្មលក្ខណោ បណ្ឌិតោតិ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ លក្ខណកុសលោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អាសាដិកំ សាដេតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ឧប្បន្នំ ព្យាបាទវិតក្កំ... ឧប្បន្នំ វិហឹសាវិតក្កំ... ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវង្គមេតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ អាសាដិកំ សាដេតា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ វណំ បដិច្ឆាទេតា ហោតិ ។

[២៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកស្គាល់រូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា រូបឯណានីមួយ (រូបទាំងអស់នោះ) គឺមហាភូតរូបទាំង ៤ ផង ឧបាទាយរូបដែលអាស្រ័យនឹងមហាភូតរូបទាំង ៤ ផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកស្គាល់រូប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកឈ្លាសក្នុងលក្ខណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា បុគ្គលពាលមានអំពើជាលក្ខណៈ បណ្ឌិតមានអំពើជាលក្ខណៈ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកឈ្លាស ក្នុងលក្ខណៈ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកផ្ចិះនូវពងរុយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាំងកាមវិតក្កៈដែលកើតឡើងហើយ មិនឲ្យអាស្រ័យនៅ (ក្នុងខន្ធសន្តាន) លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យសាបសូន្យ ញុំាំងព្យាបាទវិតក្កៈ ដែលកើតឡើងហើយ... ញុំាំងវិហឹសាវិតក្កៈ ដែលកើតឡើងហើយ... ញុំាំងអកុសលធម៌ដ៏លាមកទាំងឡាយ ដែលកើតឡើងហើយរឿយ ៗ មិនឲ្យអាស្រ័យ (នៅក្នុងខន្ធសន្តាន) លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យសាបសូន្យ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកផ្ចិះនូវពងរុយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបិទនូវដំបៅ តើដូចម្តេច ។

៤៩

### មហាយមកវគ្គស្ស មហាគោបាលសុត្តេ ភិក្ខុនោ ឯកាទសង្គានិ

ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ វណំ បដិច្ឆាទេតា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ធូមំ កត្តា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតា ហោតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ធូមំ កត្តា ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែកហើយ មិនបានកាន់យកនូវនិមិត្ត មិនបានកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ ដ៏លាមកទាំងឡាយ គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវភិក្ខុជាអ្នកមិនបានសង្រួមនូវឥន្ទ្រិយគឺភ្នែកនុ៎ះ ដែលមានការមិនសង្រួមនូវឥន្ទ្រិយគឺភ្នែកណាជាហេតុ ក៏ប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយគឺភ្នែកនោះ រក្សានូវឥន្ទ្រិយគឺភ្នែក ដល់នូវការសង្រួមក្នុងឥន្ទ្រិយគឺភ្នែក ឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួលរសដោយអណ្តាត... ពាល់ត្រូវផ្សព្វដោយកាយ... ដឹងច្បាស់នូវធម៌ដោយចិត្ត ហើយមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈឡើយ ក៏អកុសលធម៌ដ៏លាមកទាំង-ឡាយ គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវភិក្ខុជាអ្នកមិនបានសង្រួមនូវឥន្ទ្រិយគឺចិត្តនុ៎ះ ដែលមានការមិនសង្រួមនូវឥន្ទ្រិយគឺចិត្តណាជាហេតុ ក៏ប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយគឺចិត្តនោះ រក្សានូវឥន្ទ្រិយគឺចិត្ត ដល់នូវការសង្រួមក្នុងឥន្ទ្រិយគឺចិត្ត ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបិទនូវដំបៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបំពក់ផ្សែង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ សំដែងធម៌ដែលខ្លួនបានស្តាប់មកយ៉ាងណា បានរៀនមកយ៉ាងណា ដោយពិស្តារ ដល់ជនទាំងឡាយដទៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបំពក់ផ្សែង យ៉ាងនេះឯង ។

កថញ្ច ភិក្ខវេ ភិក្ខុ តិត្ថំ ជានាតិ ។ ឥធ ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ថេរា ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា តេ កាលេន កាលំ ឧបសង្កមិត្វា បរិបុច្ឆតិ បរិបញ្ហតិ ឥទំ ភន្តេ កថំ ឥមស្ស កោ អត្ថោតិ តស្ស តេ អាយស្មន្តោ អវិវដញ្ចេវ វិវរន្តិ អនុត្តានីកតញ្ច ឧត្តានីករោន្តិ អនេកវិហិតេសុ ច កង្ខាដ្ឋានីយេសុ ធម្មេសុ កង្ខំ បដិវិនោទេន្តិ ឯវំ ខោ ភិក្ខវេ ភិក្ខុ តិត្ថំ ជានាតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ បីតំ ជានាតិ ។ ឥធ ភិក្ខវេ ភិក្ខុ តថាគតប្បវេទិតេ ធម្មវិនយេ ទេសិយមានេ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ ឯវំ ខោ ភិក្ខវេ ភិក្ខុ បីតំ ជានាតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ វីថឹ ជានាតិ ។ ឥធ ភិក្ខវេ ភិក្ខុ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់កំពង់ទឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ បានចូលទៅរកពួកភិក្ខុដែលជាថេរៈ ជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ហើយសាកសួរ ប្រឹក្សាម្តងម្កាល ដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្យញ្ជនៈនេះត្រូវរៀងដូចម្តេច សេចក្តីនៃភាសិតនេះដូចម្តេច លោកដ៏មានអាយុទាំងនោះក៏បើកនូវសេចក្តីដែលកំបាំងផង ធ្វើនូវសេចក្តីដែលជ្រៅឲ្យរាក់ង៉ាយផង បន្ទោបង់នូវសេចក្តីសង្ស័យ ក្នុងធម៌ទាំងឡាយជាទីតាំងនៃសេចក្តីសង្ស័យច្រើនប្រការផង ដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់កំពង់ទឹក យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងថាខ្លួនបានផឹកទឹកហើយ ឬនៅឡើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលបើគេកំពុងសំដែងធម្មវិន័យ ដែលតថាគតប្រកាសហើយ ក៏បាននូវសេចក្តីត្រេកអរក្នុងអត្ថ បាននូវសេចក្តីត្រេកអរក្នុងធម៌ បាននូវបាមោជ្ជៈ ដែលប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងថាខ្លួនបានផឹកទឹកហើយ ឬនៅឡើយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់ផ្លូវ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

## ៤១

### មហាយមកវគ្គស្ស មហាគោបាលសុត្តេ ភិក្ខុនោ ឯកាទសង្គានិ

អរិយំ អដ្ឋង្គិកំ មគ្គំ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ វីថឹ ជានាតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ គោចរកុសលោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចត្តារោ សតិប្បដ្ឋានេ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ គោចរកុសលោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សាវសេសបាយី ច ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុំ សទ្ធា គហបតិកា អភិហដ្ឋុំ បវារេន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ តត្រ ភិក្ខុ មត្តំ ជានាតិ បដិគ្គហណាយ ឯវំ ខោ ភិក្ខវេ ភិក្ខុ សាវសេសបាយី ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេ អតិរេកបូជាយ បូជេតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេសុ មេត្តំ កាយកម្មំ បច្ចុបដ្ឋបេតិ អាវី ចេវ រហោ ច មេត្តំ វចីកម្មំ បច្ចុបដ្ឋបេតិ អាវី ចេវ រហោ ច មេត្តំ មនោកម្មំ បច្ចុបដ្ឋបេតិ អាវី ចេវ រហោ ច

ស្គាល់នូវផ្លូវប្រកបដោយអង្គទាំង ៨ ជាផ្លូវដ៏ប្រសើរ តាមសេចក្តីពិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់ផ្លូវ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកឈ្លាសក្នុងកន្លែងគោចរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវសតិប្បដ្ឋានទាំង ៤ តាមសេចក្តីពិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកឈ្លាស ក្នុងកន្លែងគោចរ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នករីតយកទេយ្យវត្ថុឲ្យនៅសល់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកគហបតីដែលមានសទ្ធា បាននាំយកចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ មកបវារណា ចំពោះភិក្ខុក្នុងសាសនានេះហើយ ភិក្ខុស្គាល់ប្រមាណក្នុងការទទួលបច្ច័យទាំងនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នករីតយកទេយ្យវត្ថុឲ្យនៅសល់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបូជាចំពោះភិក្ខុដែលជាថេរៈ ដឹងនូវរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក ដោយការបូជាដ៏ក្រៃលែង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ តម្កល់មេត្តាកាយកម្ម ក្នុងទីចំពោះមុខនិងទីកំបាំងមុខ តម្កល់មេត្តាវចីកម្ម ក្នុងទីចំពោះមុខនិងទីកំបាំងមុខ តម្កល់មេត្តាមនោកម្ម ក្នុងទីចំពោះមុខនិងទីកំបាំងមុខ ចំពោះភិក្ខុទាំងឡាយ ដែលជាថេរៈ ដឹងនូវរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក

ឯវំ ខោ ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេ អតិរេក-បូជាយ បូជេតា ហោតិ ឥមេហិ ខោ ភិក្ខវេ ឯកា-ទសហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ ឥមស្មឹ ធម្មវិនយេ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិតុន្តិ ។ ឥទមវោ-ច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

មហាគោបាលសុត្តំ តតិយំ និដ្ឋិតំ ។

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបូជាពួកភិក្ខុជាថេរៈ ដឹងនូវរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក ដោយការបូជាដ៏ក្រៃលែងយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ១១ នេះឯង ទើបគួរដើម្បីដល់នូវសេចក្ដីចម្រើន លូតលាស់ ពេញទូលាយ ក្នុងធម្មវិន័យនេះបាន ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងនូវសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិត របស់ព្រះមានព្រះភាគ ។*

ចប់ មហាគោបាលសូត្រ ទី ៣ ។

# ចតុត្ថំ ចូឡគោបាលសុត្តំ

[២៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វជ្ជីសុ វិហរតិ ឧក្កាចេលាយំ[១] គង្គាយ នទិយា តីរេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[២៩] ភគវា ឯតទវោច ភូតបុព្វំ ភិក្ខវេ មាគធកោ គោបាលកោ ទុប្បញ្ញជាតិកោ វស្សានំ បច្ឆិមេ មាសេ សារទសមយេ[២] អសមវេក្ខិត្វា គង្គាយ នទិយា ឱរិមតីរំ[៣] អសមវេក្ខិត្វា បារិមតីរំ[៤] អតិត្ថេនេវ គាវោ បតារេសិ ឧត្តរន្តីរំ វិទេហានំ[៥] ។ អថខោ ភិក្ខវេ គាវោ មជ្ឈេ គង្គាយ នទិយា សោតេ អាមណ្ឌលិកំ ករិត្វា តត្ថេវ អនយព្យសនំ អាបជ្ជឹសុ តំ កិស្ស ហេតុ តថា ហិ សោ ភិក្ខវេ មាគ-

---

១ ឱក្កវេលាយន្តិប្បត្តិ ។ ន តំ ឥទដ្ឋកថាយ សមេតិ ។ ២ ឱ. ម. សរទសមយេ ។ ៣ ឱ. ឱរិមន្តីរំ ។ ម. ឱរិមំ តីរំ ។ ៤ ឱ. បារិមន្តីរំ ។ ម. បារិមំ តីរំ ។ ៥ ឱ. ម. សុវិទេហានំ ។

# ចូឡគោបាលសូត្រ ទី ៤

[២៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្បែរឆ្នេរទន្លេគង្គា ទៀបក្រុងឧក្កចេលា ក្នុងដែនវជ្ជី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា នែភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ក៏ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ។

[២៩] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយថា គង្វាលគោជាអ្នកនៅក្នុងដែនមគធៈ ជាមនុស្សអប្បឥតប្រាជ្ញា មិនបានពិចារណានូវត្រើយខាងអាយ ទាំងមិនបានពិចារណានូវត្រើយខាងនាយនៃទន្លេគង្គា ក៏នាំគោទាំងឡាយឆ្លងទៅកាន់ត្រើយខាងជើងនៃដែនវិទេហៈ ត្រង់ទីដែលមិនមែនជាកំពង់ ក្នុងសារទសម័យ នាខែជាខាងចុងនៃរដូវភ្លៀង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកគោក៏ធ្វើនូវការវិលវល់ ក្នុងកណ្តាលខ្សែទឹកទន្លេគង្គា ហើយក៏ដល់នូវសេចក្តីវិនាសបាត់បង់ក្នុងទឹកទន្លេនោះឯង សេចក្តីវិនាសបាត់បង់ទៅនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថាគង្វាលគោជា

ជកោ គោចាលកោ ទុប្បញ្ញជាតិកោ វស្សានំ បច្ឆិមេ មាសេ សារទសមយេ អសមវេក្ខិត្វា គង្គាយ នទិយា ឱរិមតីរំ អសមវេក្ខិត្វា បារិមតីរំ អតិត្ថេនេវ គាវោ បតារេសិ ឧត្តរន្តីរំ វិទេហានំ ឯវមេវ ខោ ភិក្ខវេ យេ កេចិ[១] សមណា វា ព្រាហ្មណា វា អកុសលា ឥមស្ស លោកស្ស អកុសលា បរស្ស លោកស្ស អកុសលា មារធេយ្យស្ស អកុសលា អមារធេយ្យស្ស អកុសលា មច្ចុធេយ្យស្ស អកុសលា អមច្ចុធេយ្យស្ស តេសំ យេ សោតព្វំ សទ្ទហាតព្វំ មញ្ញិស្សន្តិ តេសំ តំ ភវិស្សតិ ទីឃរត្តំ អហិតាយ ទុក្ខាយ ។

---

១ ឱ. ម. យេ ហិ កេចិ ។

អ្នកនៅក្នុងដែនមគធៈនោះ ជាមនុស្សអប្បឥតប្រាជ្ញា មិនបានពិចារណា នូវត្រើយខាងអាយ ទាំងមិនបានពិចារណា នូវត្រើយខាងនាយនៃទន្លេគង្គា ក៏នាំគោទាំងឡាយ ឲ្យឆ្លងទៅកាន់ត្រើយខាងជើងនៃដែនវិទេហៈ តាមទីដែលមិនមែនជាកំពង់ ក្នុងសារទសម័យ នាខែជាខាងចុងនៃរដូវភ្លៀង ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណានីមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី មិនឈ្លាសក្នុងលោកនេះ[១] មិនឈ្លាសក្នុងលោកខាងមុខ[២] មិនឈ្លាសក្នុងទីនៅនៃមារ[៣] មិនឈ្លាសក្នុងទីមិនមែនជាទីនៅនៃមារ[៤] មិនឈ្លាសក្នុងទីនៅនៃមច្ចុ[៥] មិនឈ្លាសក្នុងទីដែលមិនមែនជាទីនៅនៃមច្ចុ[៦] ពួកជនណាសំគាល់ នូវពាក្យរបស់សមណៈព្រាហ្មណ៍ទាំងអម្បាលនោះ ថាជាពាក្យគួរស្តាប់ គួរជឿ សេចក្តីសំគាល់របស់ជនទាំងនោះ នឹងប្រព្រឹត្តទៅ ដើម្បីមិនមែនជាប្រយោជន៍ ដើម្បីទុក្ខ អស់កាលយូរអង្វែង ។

---

១-២ មិនឈ្លាសក្នុងខន្ធ ធាតុ និងអាយតនៈ ។ ៣ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ។ ៤ លោកុត្តរធម៌ទាំង ៩ ប្រការ ។ ៥-៦ ធម៌ប្រព្រឹត្តទៅក្នុងភូមិ ៣ និងលោកុត្តរធម៌ ដូចគ្នា ។ អដ្ឋកថា ។

[៣០] ភូតបុព្វំ ភិក្ខវេ មាគធកោ គោបាលកោ សប្បញ្ញជាតិកោ វស្សានំ បច្ឆិមេ មាសេ សារទ-សមយេ សមវេក្ខិត្វា គង្គាយ នទិយា ឱរិមតីរំ សមវេក្ខិត្វា បារិមតីរំ តិត្ថេនេវ គាវោ បតារេសិ ឧត្តរន្តីរំ វិទេហានំ ។ សោ បឋមំ បតារេសិ យេ តេ ឧសភា គោបិតរោ គោបរិណាយកា តេ តិរិយំ គង្គាយ សោតំ ឆេត្វា សោត្ថិនា បារំ អគមំសុ ។ អថាបរេ បតារេសិ ពលវគាវេ ទម្មគាវេ តេបិ តិរិយំ គង្គាយ សោតំ ឆេត្វា សោត្ថិនា បារំ អគមំសុ ។ អថាបរេ បតារេសិ វច្ឆតរេ វច្ឆតរិយោ តេបិ តិរិយំ គង្គាយ សោតំ ឆេត្វា សោត្ថិនា បារំ អគមំសុ ។ អថាបរេ បតារេសិ វច្ឆកេ កិសពលកេ តេបិ តិរិយំ គង្គាយ សោតំ ឆេត្វា សោត្ថិនា បារំ អគមំសុ ។ ភូតបុព្វំ ភិក្ខវេ វច្ឆកោ តរុណកោ តាវទេវ ជាតកោ

មហាយមកវគ្គ ចូឡគោបាលសូត្រ រឿងធ្លាប់មានមកហើយ

[៣០] ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយថា គង្វាលគោនៅក្នុងដែនមគធៈ ជាមនុស្សមានប្រាជ្ញា បានពិចារណានូវត្រើយខាងអាយ ទាំងពិចារណានូវត្រើយខាងនាយនៃទន្លេគង្គា ក៏នាំគោទាំង-ឡាយឲ្យឆ្លងទៅកាន់ត្រើយខាងជើងនៃដែនវិទេហៈ តាមទីដែលជាកំពង់ក្នុងសារទសម័យ នាខែជាខាងចុងនៃរដូវភ្លៀង ។ គង្វាលគោនោះចម្លងគោឧសភដែលជាបិតារបស់គោ ជាគោបរិនាយកទៅមុន គោទាំងនោះក៏ហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ទៅដល់ត្រើយខាងនាយដោយស្រួលបួល ។ បន្ទាប់ពីនោះ គង្វាលគោ ចម្លងពួកគោដែលមានកម្លាំងនិងគោដែលគួរបង្ហាត់បានដទៃទៀត ឯគោទាំងនោះបានហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ទៅដល់ត្រើយខាងនាយដោយស្រួលបួល ។ តពីនោះគង្វាលគោ ចម្លងគោឈ្មោលស្ទាវ និងគោញីចំទង់ដទៃទៀត ឯគោទាំងនោះ ក៏ហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ទៅដល់ត្រើយខាងនាយដោយស្រួលបួល ។ លំដាប់ពីនោះ គង្វាលគោចម្លងកូនគោកំពុងបៅដោះ និងកូនគោស្គម មានកម្លាំងថយដទៃទៀត ឯកូនគោទាំងនោះ ក៏ហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ទៅដល់ត្រើយខាងនាយដោយស្រួលបួល ។ ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយថា កូនគោកំពុងបៅដោះ ជាកូនគោនៅខ្ចី ទើបកើតក្នុងថ្ងៃនោះឯង

មាតុ គោរវកោឧ វុយ្ហមានោ សោបិ តិរិយំ គង្គាយ សោតំ ឆេត្វា សោត្ថិនា ចារំ អគមាសិ តំ កិស្ស ហេតុ បណ្ឌិតត្តា[១] តថា ហិ សោ ភិក្ខវេ មាគ-ធកោ គោបាលកោ សប្បញ្ញជាតិកោ វស្សានំ បច្ឆិមេ មាសេ សារទសមយេ សមវេក្ខិត្វា គង្គាយ នទិយា ឱរិមតីរំ សមវេក្ខិត្វា បារិមតីរំ តិត្ថេនេវ គាវោ បតារេសិ ឧត្តរន្តីរំ វិទេហានំ ឯវមេវ ខោ ភិក្ខវេ យេ កេចិ សមណា វា ព្រាហ្មណា វា កុសលា ឥមស្ស លោកស្ស កុសលា បរស្ស លោកស្ស កុសលា មារធេយ្យស្ស កុសលា អមារធេយ្យស្ស កុសលា មច្ចុធេយ្យស្ស កុសលា អមច្ចុធេយ្យស្ស តេសំ យេ សោតព្វំ សទ្ទហាតព្វំ មញ្ញិស្សន្តិ តេសំ តំ ភវិស្សតិ ទីឃរត្តំ ហិតាយ សុខាយ ។

---

១ ឱ. ម. បណ្ឌិតត្តាតិ ន ទិស្សតិ ។

តែងហែលទៅតាមសំឡេងរបស់មេគោ ឯកូនគោនោះ ហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ទៅដល់ត្រើយខាងនាយដោយស្រួលបួល រឿងនោះព្រោះហេតុដូចម្តេច ព្រោះថាគង្វាលគោជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ គង្វាលគោនៅក្នុងដែនមគធ:នោះឯង ជាមនុស្សមានប្រាជ្ញា បានពិចារ-ណានូវត្រើយខាងអាយ ពិចារណានូវត្រើយខាងនាយ នៃទន្លេគង្គា ក៏នាំគោទាំងឡាយ ឲ្យឆ្លងទៅកាន់ត្រើយខាងជើង នៃដែនវិទេហ: តាមទីដែលជាកំពង់ ក្នុងសារទសម័យ នាខែជាខាងចុង នៃវស្សានរដូវ (ដូចម្តេចមិញ) ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណានីមួយ ទោះសមណ:ក្តី ព្រាហ្មណ៍ក្តី ជាអ្នកឈ្លាសក្នុងលោកនេះ ឈ្លាសក្នុងលោកខាងមុខ ឈ្លាសក្នុងទីនៅរបស់មារ ឈ្លាសក្នុងទីដែលមិនមែនជាទីនៅរបស់មារ ឈ្លាសក្នុងទីនៅរបស់មច្ចុ ឈ្លាសក្នុងទីដែលមិនមែនជាទីនៅរបស់មច្ចុ ពួកជនណាបានសំគាល់នូវពាក្យរបស់សមណ: និងព្រាហ្មណ៍ទាំងនោះ ថាជាពាក្យគួរស្តាប់គួរជឿ សេចក្តីសំគាល់របស់ជនទាំងនោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលយូរអង្វែង យ៉ាងដូច្នោះឯង ។

មហាយមកវគ្គស្ស ចូឡគោបាលសុត្តេ បញ្ច គោណោបមា

[៣១] សេយ្យថាបិ ភិក្ខវេ យេ តេ ឧសភា គោបិតរោ គោបរិណាយកា(១) តិរិយំ គង្គាយ សោតំ ឆេត្វា សោត្ថិនា ចារំ អគមំសុ ឯវមេវ ខោ ភិក្ខវេ យេ តេ ភិក្ខូ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណភវសញ្ញោជនា សម្មទញ្ញាវិមុត្តា តេបិ តិរិយំ មារស្ស សោតំ ឆេត្វា សោត្ថិនា ចារំ គតា ។ សេយ្យថាបិ ភិក្ខវេ យេ តេ ពលវគាវោ ទម្មគាវោ(២) តិរិយំ គង្គាយ សោតំ ឆេត្វា សោត្ថិនា ចារំ អគមំសុ ឯវមេវ ខោ ភិក្ខវេ យេ តេ ភិក្ខូ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្វាយិនោ អនាវត្តិធម្មា តស្មា លោកា តេបិ តិរិយំ មារស្ស សោតំ ឆេត្វា

១ ឱ. ម. ឯត្ថន្តរេ តេតិ ទិស្សតិ ។ ២ ឱ. សេយ្យថាបិ តេ ភិក្ខវេ ពលវគវា ទម្មគវា ។ ម. សេយ្យ... ពលគាវា ទម្មគាវា ។

មហាយមកវគ្គ ចូឡគោបាលសូត្រ ឧបមាដោយគោ ៥ ពួក

[៣១] ម្នាលភិក្ខុទាំងឡាយ គោឧសភទាំងឡាយណា ជាបិតារបស់គោ ជាគោបរិនាយក គោឧសភទាំងនោះ បានហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ទៅដល់ត្រើយខាងនាយដោយស្រួលបួល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា ជាអរហន្តខីណាស្រព មានព្រហ្មចារ្យនៅរួចហើយ មានសោឡសកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួនហើយ មានសំយោជនៈក្នុងភពគឺតណ្ហាអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះត្រាស់ដឹងនូវធម៌ដោយប្រពៃ ភិក្ខុទាំងនោះអាចកាត់នូវខ្សែនៃមារដោយទទឹង ហើយទៅដល់ត្រើយខាងនាយគឺព្រះនិព្វានដោយស្រួល មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ គោទាំង-ឡាយណា ដែលជាគោមានកម្លាំង ជាគោដែលគួរបង្ហាត់បាន គោទាំងនោះ បានហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ទៅដល់ត្រើយខាងនាយដោយស្រួលបួល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា មានសំយោជនៈជាចំណែកខាងក្រោមទាំង ៥ អស់ហើយ ជាឱបបាតិកៈ[១] បរិនិព្វានក្នុងលោកនោះ មានសភាពមិនបានត្រឡប់ចាកលោកនោះ ភិក្ខុទាំងនោះនឹងកាត់នូវខ្សែនៃមារដោយទទឹង

១ សំដៅយកព្រះអនាគាមិបុគ្គល ។

សោត្ថិនា បារំ គមិស្សន្តិ ។ សេយ្យថាបិ[១] ភិក្ខវេ វច្ឆតរា វច្ឆតរិយោ តិរិយំ គង្គាយ សោតំ ឆេត្វា សោត្ថិនា បារំ អគមំសុ ឯវមេវ ខោ ភិក្ខវេ យេ តេ ភិក្ខូ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនោ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សន្តិ តេបិ តិរិយំ មារស្ស សោតំ ឆេត្វា សោត្ថិនា បារំ គមិស្សន្តិ ។ សេយ្យថាបិ[២] ភិក្ខវេ វច្ឆកា កិសពលិកា[៣] តិរិយំ គង្គាយ សោតំ ឆេត្វា សោត្ថិនា បារំ អគមំសុ ឯវមេវ ខោ ភិក្ខវេ យេ តេ ភិក្ខូ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយនា តេបិ តិរិយំ មារស្ស សោតំ ឆេត្វា សោត្ថិនា បារំ អគមំសុ ។

---

១-២ ឱ. ម. សេយ្យថាបិ តេ ។ ៣. ឱ. កិសពលកា ។

ហើយដល់នូវត្រើយខាងនាយ គឺព្រះនិព្វាន ដោយស្រួលបួល មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ គោឈ្មោលស្វាវទាំងឡាយ គោញីចំទង់ទាំងឡាយ បានហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ហើយទៅដល់ត្រើយខាងនាយ ដោយស្រួលបួល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា មានសំយោជនៈ ៣ អស់ហើយ តែនៅមានរាគៈ ទោសៈ និងមោហៈ ដែលស្រាលស្តើង ជាសកទាគាមិបុគ្គល មកកាន់លោកនេះតែម្តងទៀត ហើយនឹងធ្វើនូវទីបំផុតទុក្ខ ភិក្ខុទាំងនោះនឹងកាត់នូវខ្សែនៃមារដោយទទឹង ហើយដល់ត្រើយខាងនាយ គឺព្រះនិព្វាន ដោយស្រួលបួល មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ កូនគោដែលកំពុងបៅដោះទាំងឡាយ និងកូនគោដែលស្គមមានកម្លាំងថយ បានហែលកាត់ទទឹងខ្សែទឹកទន្លេគង្គាទៅដល់ត្រើយខាងនាយ ដោយស្រួលបួល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា មានសំយោជនៈ ៣ អស់ហើយ ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយជាបុគ្គលទៀង មានធម៌ជាគ្រឿងត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ភិក្ខុទាំងនោះបានកាត់នូវខ្សែនៃមារដោយទទឹងហើយ ក៏បានដល់នូវត្រើយខាងនាយ គឺព្រះនិព្វាន ដោយស្រួលបួល មានឧបមេយ្យដូច្នោះឯង ។

៤៩

មហាយមកវគ្គស្ស ចូឡគោបាលសុត្តេ បញ្ច គោណោបមា

សេយ្យថាបិ សោ ភិក្ខវេ វច្ឆកោ តរុណកោ តាវទេវ ជាតកោ មាតុ គោរាវកេន វុយ្ហមានោ តិរិយំ គង្គាយ សោតំ ឆេត្វា សោត្ថិនា បារំ អគមាសិ ឯវមេវ ខោ ភិក្ខវេ យេ តេ ភិក្ខូ ធម្មានុសារិនោ សទ្ធានុសារិនោ តេបិ តិរិយំ មារស្ស សោតំ ឆេត្វា សោត្ថិនា បារំ គមិស្សន្តិ ។ អហំ ខោ បន ភិក្ខវេ កុសលោ ឥមស្ស លោកស្ស កុសលោ បរស្ស លោកស្ស កុសលោ មារធេយ្យស្ស កុសលោ អមារធេយ្យស្ស កុសលោ មច្ចុធេយ្យស្ស កុសលោ អមច្ចុធេយ្យស្ស ។ តស្ស មយ្ហំ ភិក្ខវេ យេ សោតព្វំ សទ្ទហាតព្វំ មញ្ញិស្សន្តិ តេសំ តំ ភវិស្សតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។

ម្នាលភិក្ខុទាំងឡាយ កូនគោកំពុងបៅដោះ ដែលជាកូនគោនៅខ្ចី ទើបតែនឹងកើតហើយក្នុងថ្ងៃនោះឯង ក៏ហែលទៅតាមសំឡេងនៃមេគោ បានហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ដល់ទៅត្រើយខាងនាយដោយស្រួលបួល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាដែលជាធម្មានុសារីបុគ្គល[១] និងសទ្ធានុសារីបុគ្គល[២] ពួកភិក្ខុទាំងនោះនឹងកាត់នូវខ្សែនៃមារ ដោយទទឹង ហើយដល់នូវត្រើយខាងនាយ គឺព្រះនិព្វាន ដោយស្រួលបួល ។ ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគតជាអ្នកឈ្លាសក្នុងលោកនេះ អ្នកឈ្លាសក្នុងលោកខាងមុខ អ្នកឈ្លាសក្នុងទីនៅនៃមារ អ្នកឈ្លាសក្នុងទីដែលមិនមែនជាទីនៅនៃមារ អ្នកឈ្លាសក្នុងទីនៅនៃមច្ចុ អ្នកឈ្លាសក្នុងទីដែលមិនមែនជាទីនៅនៃមច្ចុ ។ ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណា សំគាល់នូវពាក្យរបស់តថាគតថាជាពាក្យគួរស្តាប់គួរជឿ សេចក្តីសំគាល់របស់ជនទាំងនោះ នឹងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលយូរអង្វែង ។

---

១ បុគ្គលអ្នករលឹកតាមនូវធម៌គឺបញ្ញា តែងចម្រើននូវមគ្គមានបញ្ញាជាប្រធាន បានខាងបុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គ មានបញ្ញិន្ទ្រិយដ៏ក្លៀវក្លា ។ ២ បុគ្គលអ្នករលឹកតាមនូវសទ្ធា តែងចម្រើននូវមគ្គមានសទ្ធាជាប្រធាន បានខាងបុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គ មានសទ្ធិន្ទ្រិយដ៏ក្លៀវក្លា ។ អដ្ឋកថា ។

ឥទមវោច ភគវា ឥទំ វត្វាន[១] សុគតោ អថាបរំ ឯត-ទវោច សត្ថា

អយំ លោកោ បរលោកោ
ជានតា សុប្បកាសិតោ
យញ្ច មារេន សម្បត្តំ
អបត្តំ យញ្ច មច្ចុនា
សព្វំ លោកំ អភិញ្ញាយ
សម្ពុទ្ធេន បជានតា
វិវដំ អមតទ្វារំ
ខេមំ និព្វានបត្តិយា
ឆិន្នំ បាបិមតោ សោតំ
វិទ្ធស្តំ វិនឡីកតំ[២]
បាមុជ្ជពហុលា ហោថ
ខេមំ បត្ថេថ[៣] ភិក្ខវោតិ ។

ចូឡគោបាលសុត្តំ ចតុត្ថំ និដ្ឋិតំ ។

---

១ ឱ. វត្វា ។ ម. វត្វា ច ។ ២ ឱ. ម. វិនឡីកតំ ។ ៣ បត្តត្ថាតិបិ បាឋោ ។ ឯវរូបំ សត្ថារំ លភិត្វា តុម្ហេ បត្ថាយេវ នាមាតិ អត្ថោតិ ឥទដ្ឋកថា ។ បដ្ឋេថាតិប្បត្ថិ ។

ព្រះទ្រង់ព្រះភាគ ព្រះអង្គត្រាស់សូត្រនេះចប់ហើយ ព្រះសុគតជាសាស្តាលុះត្រាស់សូត្រនេះរួចហើយ ទើបសំដែងគាថានេះតទៅទៀតថា

លោកនេះ និងលោកខាងមុខ ដែលព្រះសម្ពុទ្ធទ្រង់ដឹង បាន
ប្រកាសហើយដោយប្រពៃ លោកណា ៗ ដែលមច្ចុមារទៅ
ដល់ក្តី ទៅមិនដល់ក្តី ព្រះសម្ពុទ្ធទ្រង់ដឹងច្បាស់ បានត្រាស់
ដឹងនូវលោកទាំងអស់នោះ ហើយបើកទ្វារនៃព្រះនិព្វានគឺ
អរិយមគ្គ ដើម្បីដល់នូវព្រះនិព្វានជាទីក្សេម បានកាត់កម្ចាត់
ខ្សែរបស់មារ ហើយធ្វើឲ្យប្រាសចាកដើមបបុសគឺមានះ ម្នាល
ភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាអ្នកច្រើនដោយសេចក្តី
រីករាយ ចូរប្រាថ្នានូវព្រះនិព្វានជាទីក្សេមចុះ ។

ចប់ ចូឡគោបាលសូត្រ ទី ៤ ។

# បញ្ចមំ ចូឡសច្ចកសុត្តំ

[៣២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន សច្ចកោ និគណ្ឋបុត្តោ វេសាលិយំ បដិវសតិ ភស្សប្បវាទិកោ បណ្ឌិតវាទោ សាធុសម្មតោ ពហុជនស្ស ។ សោ វេសាលិយំ បរិសតិ[១] ឯវំ វាចំ ភាសតិ នាហំ តំ[២] បស្សាមិ សមណំ វា ព្រាហ្មណំ វា សង្ឃឹ គណឹ គណាចរិយំ អបិច អរហន្តំ សម្មាសម្ពុទ្ធំ បដិជានមានំ យោ មយា វាទេន វាទំ សមារទ្ធោ ន សង្កម្បេយ្យ ន សម្បកម្បេយ្យ ន សម្បវេធេយ្យ យស្ស ន កច្ឆេហិ សេទា មុញ្ចេយ្យុំ ថូណាញ្ចេចាហំ[៣] អចេតនំ វាទេន វាទំ សមារភេយ្យំ សាបិ មយា វាទេន វាទំ សមារទ្ធា សង្កម្បេយ្យ សម្បកម្បេយ្យ សម្បវេធេយ្យ កោ បន វាទោ មនុស្សភូតស្សាតិ ។

---

១ ឱ. បរិសតឹ ។ ២ ឱ. ម. នាហន្តំ ។ ៣ ឱ. ថូណញ្ចេបហំ ។ ម. ថូណំ បាហំ ។

# ចូឡសច្ចកសូត្រ ទី ៥

[៣២] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលាក្នុងមហាវ័ន ទៀបក្រុងវេសាលី ។ សម័យនោះឯង និគន្ថបុត្រឈ្មោះសច្ចកៈ នៅក្នុងក្រុងវេសាលី ជាអ្នកពោលនូវតិរច្ឆានកថា ពោលថាខ្លួនជាអ្នកប្រាជ្ញ មហាជនសន្មតថា ជាអ្នកមានលទ្ធិល្អ ។ សច្ចកនិគន្ថបុត្រនោះ តែងពោលវាចា នាកណ្តាលបរិស័ទ ក្នុងក្រុងវេសាលីយ៉ាងនេះថា បុគ្គលណាដែលអាត្មាអញលើកឡើងនូវទោសដោយសំដី ហើយមិនកក្រើក មិនរំភើប មិនញាប់ញ័រ ទាំងញើសក៏មិនហូរចេញអំពីក្លៀក របស់បុគ្គលណា អាត្មាអញមិនឃើញនូវបុគ្គលនោះ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ជាអ្នកមានពួក មានគណៈជាអាចារ្យនៃគណៈ ឬពុំនោះសោត បានប្តេជ្ញាខ្លួនថាជាអរហន្តសម្មាសម្ពុទ្ធទេ ឯអាត្មាអញ បើលើកឡើងនូវទោសដោយពាក្យសំដី ចំពោះទៅលើបង្គោលដែលជារបស់គ្មានចេតនាសោះ ឯបង្គោលនោះ លុះអាត្មាអញលើកឡើងនូវទោសដោយពាក្យសំដីហើយ គប្បីកក្រើក រំភើប ញាប់ញ័រ ចាំបាច់ពោលទៅថ្វី ដល់មនុស្សជាតផងគ្នា ។

[៣៣] អថខោ អាយស្មា អស្សជិ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលិយំ បិណ្ឌាយ បាវិសិ ។ អទ្ទសា ខោ សច្ចកោ និគណ្ឋបុត្តោ វេសាលិយំ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ អាយស្មន្តំ អស្សជឹ ទូរតោវ គច្ឆន្តំ ទិស្វាន យេនាយស្មា អស្សជិ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អស្សជិនា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សច្ចកោ និគណ្ឋបុត្តោ អាយស្មន្តំ អស្សជឹ ឯតទវោច កថំ បន ភោ អស្សជិ សមណោ គោតមោ សាវកេ វិនេតិ កថំភាគា ច បន សមណស្ស គោតមស្ស សាវកេសុ អនុសាសនី ពហុលា បវត្តតីតិ ។ ឯវំ ខោ អគ្គិវេស្សន ភគវា សាវកេ វិនេតិ ឯវំភាគា ច បន ភគវតោ សាវកេសុ អនុសាសនី ពហុលា បវត្តតិ រូបំ ភិក្ខវេ អនិច្ចំ វេទនា អនិច្ចា សញ្ញា អនិច្ចា

[៣៣] លំដាប់នោះឯង ព្រះអស្សជិ មានអាយុ ស្លៀកស្បង់ ទ្រង់នូវបាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅក្នុងក្រុងវេសាលី ដើម្បីបិណ្ឌបាត ។ សច្ចកនិគន្ថបុត្រកំពុងដើរសសៀរ ៗ ទៅ ដើម្បីសម្រាកស្មងក្នុងក្រុងវេសាលី ក៏បានឃើញព្រះអស្សជិមានអាយុ កំពុងនិមន្តទៅអំពីចម្ងាយ លុះឃើញហើយ ក៏ចូលសំដៅទៅរកព្រះអស្សជិមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះអស្សជិមានអាយុ លុះបញ្ចប់ពាក្យ ដែលគួរឲ្យកើតសេចក្តីរីករាយ និងពាក្យដែលគួររលឹកហើយ ក៏ឋិតនៅក្នុងទីដ៏សមគួរ ។ លុះសច្ចក-និគន្ថបុត្រឋិតនៅ ក្នុងទីដ៏សមគួរហើយ ទើបពោលពាក្យនេះនឹងព្រះអស្សជិមានអាយុថា បពិត្រព្រះអស្សជិដ៏ចម្រើន ព្រះសមណគោតមតែងទូន្មាននូវសាវ័កទាំងឡាយ ដូចម្តេចខ្លះ មួយទៀត ពាក្យប្រៀនប្រដៅរបស់ព្រះសមណគោតមតែងប្រព្រឹត្តទៅច្រើន ក្នុងពួកសាវ័កទាំង-ឡាយ មានចំណែកដូចម្តេច ។ ព្រះអស្សជិតបថា ម្នាលអគ្គិវេស្សនៈ ព្រះមានព្រះភាគទ្រង់ទូន្មាន នូវពួកសាវ័កយ៉ាងនេះ មួយទៀត ពាក្យប្រៀនប្រដៅតែងប្រព្រឹត្តទៅច្រើន ក្នុងពួកសាវ័ក មានចំណែកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង វេទនាមិនទៀង សញ្ញាមិនទៀង

សង្ខារា អនិច្ចា វិញ្ញាណំ អនិច្ចំ រូបំ ភិក្ខវេ អនត្តា វេទនា អនត្តា សញ្ញា អនត្តា សង្ខារា អនត្តា វិញ្ញាណំ អនត្តា សព្វេ សង្ខារា អនត្តា[១] សព្វេ ធម្មា អនត្តាតិ ឯវំ ខោ អគ្គិវេស្សន ភគវា សាវកេ វិនេតិ ឯវំភាគា ច បន ភគវតោ សាវកេសុ អនុសាសនី ពហុលា បវត្តតីតិ ។ ទុស្សុតំ វត ភោ អស្សុម្ហ យេ មយំ ឯវំវាទឹ សមណំ គោតមំ អស្សុម្ហ អប្បេវ នាម[២] មយំ កទាចិ ករហចិ តេន ភោតា គោតមេន សទ្ធឹ សមាគច្ឆេយ្យាម អប្បេវ នាម សិយា កោចិទេវ កថាសល្លាបោ អប្បេវ នាម តស្មា បាបកា ទិដ្ឋិគតា វិវេចេយ្យាមាតិ ។

[៣៤] តេន ខោ បន សមយេន បញ្ចមត្តានិ លិច្ឆវិសតានិ សន្ថាគារេ សន្និបតិតានិ ហោន្តិ កេនចិទេវ ករណីយេន ។ អថ ខោ សច្ចកោ និគណ្ឋបុត្តោ យេន តេ លិច្ឆវី តេនុបសង្កមិ ឧបសង្កមិត្វា

១ ឱ. អនិច្ចា ។ ២ ឱ. ម. អប្បេវ ច នាម ។

សង្ខារទាំងឡាយមិនទៀង វិញ្ញាណមិនទៀង ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជាខ្លួន វេទនាមិនមែនជាខ្លួន សញ្ញាមិនមែនជាខ្លួន សង្ខារទាំងឡាយមិនមែនជាខ្លួន វិញ្ញាណមិនមែនជាខ្លួន សង្ខារទាំងពួងមិនមែនជាខ្លួន ធម៌ទាំងពួងមិនមែនជាខ្លួន ម្នាលអគ្គិវេស្សនៈ ព្រះមានព្រះភាគ ទ្រង់ទូន្មាននូវសាវ័កទាំងឡាយ យ៉ាងនេះឯង មួយទៀត ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ តែងប្រព្រឹត្តទៅច្រើនក្នុងពួកសាវ័ក មានចំណែកយ៉ាងនេះ ។ បពិត្រព្រះអស្សជិដ៏ចម្រើន យើងទាំងឡាយណា បានស្តាប់ព្រះសមណគោតម មានវាទៈយ៉ាងនេះ យើងទាំងឡាយនោះឈ្មោះថា បានស្តាប់នូវវាទៈដែលកម្របានស្តាប់ ធ្វើម្តេចយើងទាំងឡាយនឹងទៅជួបព្រះសមណគោតមដ៏ចម្រើននោះ បានម្តងហ្ន៎ ធ្វើម្តេចហ្ន៎ នឹងមានការចរចាអ្វីនីមួយទៅអេះ ធ្វើម្តេចយើងទាំងឡាយ នឹងដោះនូវសមណគោតម ឲ្យផុតអំពីទិដ្ឋិដ៏លាមកនោះចេញបានហ្ន៎ ។

[៣៤] សម័យនោះឯង ព្រះបាទលិច្ឆវី ចំនួន ៥០០ អង្គ កំពុងតែប្រជុំនៅក្នុងសន្ថាគារដ្ឋាន[១] ដោយមានកិច្ចការអ្វីនីមួយ ។ លំដាប់នោះ សច្ចកនិគន្ថបុត្រ ក៏ចូលទៅរកព្រះបាទលិច្ឆវីទាំងនោះ លុះចូល

១ សាលាសម្រាប់ប្រៀនប្រដៅរាជត្រកូល ។ អដ្ឋកថា ។

តេ លិច្ឆវី ឯតទវោច អភិក្កមន្តុ ភោន្តោ លិច្ឆវី អភិក្កមន្តុ ភោន្តោ លិច្ឆវី អជ្ជ មេ សមណេន គោតមេន សទ្ធឹ កថាសល្លាបោ ភវិស្សតិ សចេ មេ សមណោ គោតមោ តថា បតិដ្ឋហិស្សតិ[១] យថា ច មេ[២] ញាតញ្ញតរេន សាវកេន អស្សជិនា ធាម ភិក្ខុនា បតិដ្ឋិតំ សេយ្យថាបិ ធាម ពលវា បុរិសោ ទីឃលោមិកំ ឯឡកំ លោមេសុ គហេត្វា អាកឌ្ឍេយ្យ បរិកឌ្ឍេយ្យ សម្បរិកឌ្ឍេយ្យ ឯវមេវាហំ សមណំ គោតមំ វាទេន វាទំ អាកឌ្ឍិស្សាមិ បរិកឌ្ឍិស្សាមិ សម្បរិកឌ្ឍិស្សាមិ សេយ្យថាបិ ធាម ពលវា សោណ្ឌិកាកម្មការោ មហន្តំ សោណ្ឌិកាកិលញ្ជំ គម្ភីរេ ឧទករហទេ បក្ខិបិត្វា កណ្ណេ គហេត្វា អាកឌ្ឍេយ្យ បរិកឌ្ឍេយ្យ សម្បរិកឌ្ឍេយ្យ ឯវមេវាហំ សមណំ គោតមំ វាទេន វាទំ អាកឌ្ឍិស្សាមិ បរិកឌ្ឍិស្សាមិ សម្បរិកឌ្ឍិស្សាមិ

១ ឱ. ម. បតិដ្ឋិស្សតិ ។ ២ ឱ. យថាស្ស មេ ។

ទៅដល់ហើយ ក៏ពោលពាក្យនេះនឹងព្រះបាទលិច្ឆវីទាំងនោះថា សូមព្រះបាទលិច្ឆវីទាំងឡាយដ៏ចម្រើន អញ្ជើញទៅ សូមព្រះបាទលិច្ឆវីទាំងឡាយដ៏ចម្រើន អញ្ជើញទៅ ខ្ញុំនឹងមានការចរចាជាមួយនឹងព្រះសមណគោតមក្នុងថ្ងៃនេះ ថាបើព្រះសមណគោតម តតាំងនឹងខ្ញុំ ដូចជាភិក្ខុឈ្មោះអស្សជិ ជាសាវ័កដែលមានកេរ្តិ៍ឈ្មោះមួយដែរ បានតតាំងនឹងខ្ញុំរួចហើយ ខ្ញុំនឹងទាញមក ច្រានទៅ គ្រវាត់គ្រវែងនូវពាក្យសំដី ដោយពាក្យសំដីចំពោះព្រះសមណគោតម ដូចជាបុរសមានកម្លាំង ចាប់សត្វចៀមដែលមានរោមវែង ឲ្យដ៏រោមទាំងឡាយ ទាញមក ច្រានទៅ គ្រវាត់គ្រវែងដូច្នោះឯង ពុំនោះសោត ខ្ញុំនឹងទាញមក ច្រានទៅ គ្រវាត់គ្រវែងនូវពាក្យសំដី ដោយពាក្យសំដី ចំពោះព្រះសមណគោតមនោះ ដូចជាបុរសមានកម្លាំង ជាអ្នកធ្វើការងារក្នុងផ្ទះលក់សុរា ដាក់នូវកន្ទេលសម្រាប់ដាក់ម្សៅក្នុងផ្ទះលក់សុរា ក្នុងអន្លង់ទឹកដែលជ្រៅ ចាប់ត្រង់ជាយទាញមក ច្រានទៅ គ្រវាត់គ្រវែងដូច្នោះឯង ពុំនោះខ្ញុំនឹងផ្កាប់ចុះ ផ្ងារឡើង បោកបោះនូវពាក្យសំដីដោយពាក្យសំដី ចំពោះព្រះសមណគោតម

សេយ្យថាបិ នាម ពលវា បុរិសោ[១] សោណ្ឌិកាធុត្តោ ថាលំ[២] កណ្ណេ គហេត្វា ឱធុនេយ្យ និទ្ធុនេយ្យ និប្ផោ-ដេយ្យ[៣] ឯវមេវាហំ សមណំ គោតមំ វាទេន វាទំ ឱធុនិស្សាមិ និទ្ធុនិស្សាមិ និប្ផោដិស្សាមិ[៤] សេយ្យ-ថាបិ នាម កុញ្ជរោ សដ្ឋីហាយនោ គម្ភីរំ បោក្ខរណឹ ឱគាហេត្វា[៥] សាណធោវិកំ នាម កីឡិតជាតំ កីឡតិ ឯវមេវាហំ សមណំ គោតមំ សាណធោវិកំ មញ្ញេ កីឡិតជាតំ កីឡិស្សាមិ អភិក្កមថ ភោន្តោ លិច្ឆវី អភិក្កមថ ភោន្តោ លិច្ឆវី អជ្ជ មេ សមណេន គោតមេន សទ្ធឹ កថាសល្លាបោ ភវិស្សតីតិ ។ តត្រេ-កច្ចេ[៦] លិច្ឆវី ឯវមាហំសុ កឹ សមណោ គោតមោ សច្ចកស្ស និគណ្ឋបុត្តស្ស វាទំ អារោបេស្សតិ អថខោ សច្ចកោ និគណ្ឋបុត្តោ សមណស្ស គោតមស្ស វាទំ អារោបេស្សតីតិ ។ ឯកច្ចេ លិច្ឆវី ឯវមាហំសុ

---

១ ឱ. ម. បុរិសោតិ ន ទិស្សតិ ។ ២ ឱ. វាលំ ។ ៣ ឱ. ម. និប្ផាទេយ្យ ។ ៤ ឱ. ម. និប្ផាទេស្សាមិ ។ ៥ ឱ. ឱគាហិត្វា ។ ៦ ឱ. ម. តត្រេកច្ចេ ។

ដូចជាបុរសមានកម្លាំង ជាអ្នកលេងសុរា ចាប់ថាសត្រង់កណ្តាប់មាត់ផ្កាប់ចុះ ផ្ងារឡើង បោកបោះដូច្នោះឯង ពុំនោះសោត ខ្ញុំនឹងលេងនូវព្រះសមណគោតម ឲ្យមានទំនងដូចជាគេលេងនូវល្បែងលាងសម្បកធ្មៃ ឲ្យដូចគ្នានឹងដំរីដែលមានអាយុ ៦០ ឆ្នាំ ចុះកាន់ស្រះបោក្ខរណីដ៏ជ្រៅ ហើយលេងនូវល្បែងលាងសម្បកធ្មៃដូច្នោះឯង សូមព្រះបាទលិច្ឆវីទាំងឡាយដ៏ចម្រើនអញ្ជើញទៅ សូមព្រះបាទលិច្ឆវីទាំងឡាយដ៏ចម្រើនអញ្ជើញទៅ ខ្ញុំនឹងមានការចរចាជាមួយនឹងព្រះសមណគោតមក្នុងថ្ងៃនេះ ។ បណ្តាព្រះបាទលិច្ឆវីទាំងនោះ ព្រះបាទលិច្ឆវីពួកខ្លះ មានព្រះវាចាយ៉ាងនេះថា ព្រះសមណគោតម នឹងលើកឡើងនូវពាក្យសំដីរបស់សច្ចកនិគន្ថបុត្រ ដូចម្តេចបានមានតែសច្ចកនិគន្ថបុត្រទេ ទើបនឹងលើកឡើងនូវពាក្យសំដីរបស់ព្រះសមណគោតមវិញបាន ។ ព្រះបាទលិច្ឆវីពួកខ្លះ មានព្រះវាចាយ៉ាងនេះថា

កឹ សោ ភវមានោ សច្ចកោ និគន្ថបុត្តោ យោ[១] ភគវតោ វាទំ អារោបេស្សតិ អថខោ ភគវា សច្ចកស្ស និគន្ថបុត្តស្ស វាទំ អារោបេស្សតីតិ ។ អថខោ សច្ចកោ និគន្ថបុត្តោ បញ្ចមត្តេហិ លិច្ឆវិសតេហិ បរិវុតោ យេន មហាវនំ កូដាគារសាលា តេនុបសង្កមិ ។

[៣៨] តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ អព្ភោកាសេ ចង្កមន្តិ ។ អថខោ សច្ចកោ និគន្ថបុត្តោ យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច កហន្នុខោ ភោ ឯតរហិ សោ ភវំ គោតមោ វិហរតិ ទស្សនកាមា ហិ មយំ តំ ភវន្តំ គោតមន្តិ ។ ឯស អគ្គិវេស្សន ភគវា មហាវនំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសិន្នោតិ ។ អថខោ សច្ចកោ និគន្ថបុត្តោ មហតិយា លិច្ឆវិបរិសាយ សទ្ធឹ មហាវនំ អជ្ឈោគាហេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា

១ ឱ. យោតិ ន ទិស្សតិ ។

សច្ចកនិគន្ថបុត្រនោះ នឹងលើកឡើងនូវពាក្យសំដី របស់ព្រះមានព្រះភាគជាម្ចាស់ ដូចម្តេចបាន មានតែព្រះមានព្រះភាគជាម្ចាស់ទេ ទើបលើកឡើងនូវពាក្យសំដី របស់សច្ចកនិគន្ថបុត្របាន ។ លំដាប់នោះ សច្ចកនិ-គន្ថបុត្រ មានព្រះបាទលិច្ឆវីចំនួនប្រាំរយអង្គចោមរោម ក៏ចូលសំដៅទៅត្រង់កូដាគារសាលា នាមហាវ័ន ។

[៣៥] សម័យនោះឯង ភិក្ខុច្រើនរូបកំពុងចង្រ្កមនៅទីវាល ។ គ្រានោះ សច្ចកនិគន្ថបុត្រ ចូលទៅរកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ក៏ពោលពាក្យនេះនឹងភិក្ខុទាំងនោះថា នៃលោកទាំងឡាយដ៏ចម្រើន ឥឡូវនេះ ព្រះគោតមដ៏ចម្រើននោះ គង់នៅក្នុងទីណា យើងទាំង-ឡាយ ចង់ចួបនឹងព្រះគោតមដ៏ចម្រើននោះ ។ ភិក្ខុទាំងនោះតបថា ម្នាលអគ្គិវេស្សនៈ ព្រះមានព្រះភាគជាម្ចាស់អង្គនុ៎ះ ទ្រង់យាងចូលទៅកាន់មហាវ័ន គង់សម្រាកព្រះអង្គក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។ លំដាប់នោះសច្ចកនិគន្ថបុត្រ ក៏ចូលទៅកាន់មហាវ័ន ជាមួយនឹងព្រះបាទលិច្ឆវីជាបរិស័ទច្រើនអង្គ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ

ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ តេបិ ខោ លិច្ឆវី អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ អប្បេកច្ចេ ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ អប្បេកច្ចេ យេន ភគវា តេនញ្ជលិម្បណាមេត្វា ឯកមន្តំ និសីទឹសុ ។ អប្បេកច្ចេ ភគវតោ សន្តិកេ នាមគោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ ។ អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។

[៣៦] ឯកមន្តំ និសិន្នោ ខោ សច្ចកោ និគន្ថបុត្តោ ភគវន្តំ ឯតទវោច បុច្ឆេយ្យាហំ ភវន្តំ គោតមំ កញ្ចិទេវ ទេសំ សចេ មេ ភវំ គោតមោ ឱកាសំ ករោតិ បញ្ហស្ស វេយ្យាករណាយាតិ ។ បុច្ឆ អគ្គិវេស្សន យទាកង្ខសីតិ ។ កថំ បន[១] ភវំ គោតមោ សាវកេ វិនេតិ កថំភាគា ច បន ភោតោ គោតមស្ស សាវកេសុ អនុសាសនី ពហុលា បវត្តតីតិ ។

១ ម. កថញ្ច ។

ក៏ធ្វើសេចក្ដីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ ឯព្រះបាទលិច្ឆវីទាំងនោះ ពួកខ្លះ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ ពួកខ្លះ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ ពួកខ្លះ ក៏គង់ប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគ ក្នុងទីដ៏សមគួរ ។ ពួកខ្លះ ក៏សំដែងនាមនិងគោត្រ (របស់ខ្លួន) ឲ្យឮច្បាស់ក្នុងសំណាក់នៃព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ ពួកខ្លះ ក៏គង់នៅស្ងៀមក្នុងទីដ៏សមគួរ ។

[៣៦] សច្ចកនិគន្ថបុត្រ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹងព្រះមានព្រះភាគថា បើព្រះគោតមដ៏ចម្រើន ធ្វើនូវឱកាសដើម្បីដោះស្រាយនូវបញ្ហារបស់ខ្ញុំបាន ខ្ញុំនឹងសួរនូវហេតុនីមួយ នឹងព្រះគោតមដ៏ចម្រើន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអគ្គិវេស្សនៈ បើអ្នកត្រូវការនឹងសួរ ចូរសួរមកចុះ ។ ព្រះគោតមដ៏ចម្រើន តែងទូន្មានពួកសាវ័កដូចម្ដេចខ្លះ ពាក្យប្រៀនប្រដៅរបស់ព្រះគោតមដ៏ចម្រើន តែងប្រព្រឹត្តទៅច្រើនក្នុងពួកសាវ័ក មានចំណែកដូចម្ដេចខ្លះ ។ ម្នាល

ឯវំ ខោ អហំ អគ្គិវេស្សន សាវកេ វិនេមិ ឯវំភាគា ច បន មេ សាវកេសុ អនុសាសនី ពហុលា បវត្តតិ រូបំ ភិក្ខវេ អនិច្ចំ វេទនា អនិច្ចា សញ្ញា អនិច្ចា សង្ខារា អនិច្ចា វិញ្ញាណំ អនិច្ចំ រូបំ ភិក្ខវេ អនត្តា វេទនា អនត្តា សញ្ញា អនត្តា សង្ខារា អនត្តា វិញ្ញាណំ អនត្តា សព្វេ សង្ខារា អនត្តា សព្វេ ធម្មា អនត្តាតិ ឯវំ ខោ អហំ អគ្គិវេស្សន សាវកេ វិនេមិ ឯវំភាគា ច បន មេ សាវកេសុ អនុសាសនី ពហុលា បវត្តតីតិ ។ ឧបមា មំ ភោ គោតម បដិភាតីតិ ។ បដិភាតុ តំ អគ្គិវេស្សនាតិ ភគវា អវោច ។ សេយ្យថាបិ ភោ គោតម យេ កេចិមេ វីជគាមភូតគាមា[១] វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តិ សព្វេ តេ បឋវឹ និស្សាយ បឋវិយំ បតិដ្ឋាយ ឯវមេតេ វីជគាមភូតគាមា វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជន្តិ សេយ្យថាបិ វា បន ភោ គោតម

[១] ឱ. ម. ពីជគាមភូតគាមា ។

អគ្គិវេស្សនៈ តថាគតតែងទូន្មានពួកសាវ័កយ៉ាងនេះ ពាក្យប្រៀនប្រដៅរបស់តថាគត តែងប្រព្រឹត្តទៅច្រើនក្នុងពួកសាវ័ក មានចំណែកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង វេទនាមិនទៀង សញ្ញាមិនទៀង សង្ខារទាំងឡាយមិនទៀង វិញ្ញាណមិនទៀង ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជាខ្លួន វេទនាមិនមែនជាខ្លួន សញ្ញាមិនមែនជាខ្លួន សង្ខារទាំងឡាយមិនមែនជាខ្លួន វិញ្ញាណមិនមែនជាខ្លួន សង្ខារទាំងពួងមិនមែនជាខ្លួន ធម៌ទាំងពួង ក៏មិនមែនជាខ្លួនដែរ ម្នាលអគ្គិវេស្សនៈ តថាគតតែងទូន្មានពួកសាវ័កយ៉ាងនេះឯង ពាក្យប្រៀនប្រដៅរបស់តថាគត តែងប្រព្រឹត្តទៅច្រើនក្នុងពួកសាវ័ក មានចំណែកយ៉ាងនេះ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គសូមសំដែងពាក្យឧបមាបន្តិច ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អើអគ្គិវេស្សនៈ អ្នកឯងចូរសំដែងពាក្យឧបមាទៅចុះ ។ បពិត្រព្រះគោតមដ៏ចម្រើន ពីជគាមនិងភូតគាមទាំងឡាយណានីមួយដល់នូវការចម្រើន លូតលាស់ ធំទូលាយ ពីជគាមនិងភូតគាមទាំងអស់នោះ អាស្រ័យនូវផែនដី តាំងនៅលើផែនដី ពីជគាមនិងភូតគាមទាំងនុ៎ះ ក៏តែងតែដល់ នូវការចម្រើន លូតលាស់ ធំទូលាយយ៉ាងនេះ មានឧបមាដូចម្តេចមិញ បពិត្រព្រះគោតម ដ៏ចម្រើន មួយទៀត

មហាយមកវគ្គស្ស ចូឡសច្ចកសុត្តេ ពហុលប្បវត្តានុសាសនី

យេ កេចិមេ ពលករណីយា កម្មន្តា ករីយន្តិ សព្វេ តេ បឋវឹ និស្សាយ បឋវិយំ បតិដ្ឋាយ ឯវមេតេ ពលករណីយា កម្មន្តា ករីយន្តិ ឯវមេវ ខោ ភោ គោតម រូបត្តាយំ បុរិសបុគ្គលោ រូបេ បតិដ្ឋាយ បុញ្ញំ វា អបុញ្ញំ វា បសវតិ វេទនត្តាយំ បុរិសបុគ្គលោ វេទនាយ បតិដ្ឋាយ បុញ្ញំ វា អបុញ្ញំ វា បសវតិ សញ្ញត្តាយំ បុរិសបុគ្គលោ សញ្ញាយ បតិដ្ឋាយ បុញ្ញំ វា អបុញ្ញំ វា បសវតិ សង្ខារត្តាយំ បុរិសបុគ្គលោ សង្ខារេសុ បតិដ្ឋាយ បុញ្ញំ វា អបុញ្ញំ វា បសវតិ វិញ្ញាណត្តាយំ បុរិសបុគ្គលោ វិញ្ញាណេ បតិដ្ឋាយ បុញ្ញំ វា អបុញ្ញំ វា បសវតីតិ ។ ននុ តំ[១] អគ្គិវេស្សន ឯវំ វទេសិ រូបំ មេ អត្តា វេទនា មេ អត្តា សញ្ញា មេ អត្តា សង្ខារា មេ អត្តា វិញ្ញាណំ មេ អត្តាតិ ។ អហំ ហិ ភោ គោតម ឯវំ វទាមិ រូបំ មេ អត្តា វេទនា មេ អត្តា សញ្ញា មេ អត្តា សង្ខារា មេ អត្តា

---
១ ឱ. ម. ត្វំ ។

ការងារទាំងឡាយ ដែលគួរធ្វើដោយកម្លាំងឯណានីមួយ គេតែងធ្វើការងារទាំងអស់នោះ អាស្រ័យនូវផែនដី តាំងនៅលើផែនដី ការងារដែលគួរធ្វើដោយកម្លាំងទាំងនុ៎ះ គេតែងធ្វើយ៉ាងនេះ មានឧបមាដូចម្តេចមិញ បពិត្រព្រះគោតមដ៏ចម្រើន បុរសបុគ្គលនេះ មានរូបជាខ្លួន តាំងនៅក្នុងរូប ទទួលនូវបុណ្យឬបាប បុរសបុគ្គលនេះ មានវេទនាជាខ្លួន តាំងនៅក្នុងវេទនា ទទួលនូវបុណ្យឬបាប បុរសបុគ្គលនេះ មានសញ្ញាជាខ្លួន តាំងនៅក្នុងសញ្ញា ទទួលនូវបុណ្យឬបាប បុរសបុគ្គលនេះ មានសង្ខារជាខ្លួន តាំងនៅក្នុងសង្ខារទាំងឡាយ ទទួលនូវបុណ្យឬបាប បុរសបុគ្គលនេះមានវិញ្ញាណជាខ្លួន តាំងនៅក្នុងវិញ្ញាណ ទទួលនូវបុណ្យឬបាប មានឧបមេយ្យដូច្នោះឯង ។ ម្នាលអគ្គិវេស្សនៈ អ្នកពោលពាក្យយ៉ាងនេះថា រូបជាខ្លួនរបស់អញ វេទនាជាខ្លួនរបស់អញ សញ្ញាជាខ្លួនរបស់អញ សង្ខារទាំងឡាយជាខ្លួនរបស់អញ វិញ្ញាណជាខ្លួនរបស់អញ ដូច្នេះឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំឯងពោលយ៉ាងនេះថា រូបជាខ្លួនរបស់អញ វេទនាជាខ្លួនរបស់អញ សញ្ញាជាខ្លួនរបស់អញ សង្ខារទាំងឡាយជាខ្លួនរបស់អញ

វិញ្ញាណំ មេ អត្តាតិ អយញ្ច មហតី ជនតាតិ ។ កឹ ហិ តេ អគ្គិវេស្សន មហតី ជនតា ករិស្សតិ ឥង្ឃ ត្វំ អគ្គិវេស្សន សកំយេវ វាទំ និព្វេឋេហីតិ ។ អហំ ហិ ភោ គោតម ឯវំ វទាមិ រូបំ មេ អត្តា វេទនា មេ អត្តា សញ្ញា មេ អត្តា សង្ខារា មេ អត្តា វិញ្ញាណំ មេ អត្តាតិ ។

[៣៧] តេនហិ អគ្គិវេស្សន តញ្ញេវេត្ថ[១] បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ[២] ព្យាករេយ្យាសិ តំ កឹ មញ្ញសិ អគ្គិវេស្សន វត្តេយ្យ រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស សកស្មឹ វិជិតេ វសោ ឃាតេតាយំ វា ឃាតេតុំ ជាបេតាយំ វា ជាបេតុំ បព្វាជេតាយំ វា បព្វាជេតុំ សេយ្យថាបិ រញ្ញោ បសេនទិស្ស កោសលស្ស សេយ្យថាបិ វា បន រញ្ញោ មាគធស្ស អជាតសត្តុស្ស វេទេហិបុត្តស្សាតិ ។ វត្តេយ្យ ភោ គោតម រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស សកស្មឹ វិជិតេ វសោ ឃាតេតាយំ វា ឃាតេតុំ

១ ឱ. តំយេវេត្ថ ។ ២ ម. តំ ។

វិញ្ញាណជាខ្លួនរបស់អញ ទាំងប្រជុំជនជាច្រើននេះ គេក៏ថាដូច្នេះដែរ ។ នែអគ្គិវេស្សនៈ ឯប្រជុំជនជាច្រើនរបស់អ្នក នឹងធ្វើជាសំអាងម្តេចបាន ម្នាលអគ្គិវេស្សនៈ អញ្ជើញ អ្នកដោះស្រាយតែពាក្យសំដីរបស់ខ្លួនចុះ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំនៅតែពោលយ៉ាងនេះថា រូបជាខ្លួនរបស់អញ វេទនាជាខ្លួនរបស់អញ សញ្ញាជាខ្លួនរបស់អញ សង្ខារទាំងឡាយជាខ្លួនរបស់អញ វិញ្ញាណជាខ្លួនរបស់អញ ។

[៣៧] ម្នាលអគ្គិវេស្សនៈ បើដូច្នោះ តថាគតនឹងត្រឡប់សួរទៅអ្នកក្នុងប្រស្នានេះវិញ ប្រស្នាគាប់ចិត្តអ្នកយ៉ាងណា អ្នកត្រូវដោះស្រាយនូវប្រស្នានោះ យ៉ាងនោះចុះ នែអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះដូចម្តេច ព្រះរាជាជាខត្តិយៈ ដែលបានមុទ្ធាភិសេកហើយ ដូចយ៉ាងព្រះរាជាបសេនទិកោសល ពុំនោះសោត ដូចព្រះរាជាអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈ ក្នុងដែនមគធៈ មានអំណាចក្នុងដែនជារបស់ខ្លួន គប្បីប្រព្រឹត្ត ដើម្បីសម្លាប់នូវបុគ្គលដែលគួរសម្លាប់ ដើម្បីរឹបជាន់នូវបុគ្គលដែលគួររឹបជាន់ ឬដើម្បីនិរទេសនូវបុគ្គលដែលគួរនិរទេស បានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះរាជាជាខត្តិយៈ ដែលបានមុទ្ធាភិសេកហើយ ដូចយ៉ាងព្រះរាជាបសេនទិកោសល ពុំនោះសោត ដូចជាព្រះរាជាអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈ ក្នុងដែនមគធៈ មានអំណាចក្នុងដែនជារបស់ខ្លួន គប្បីប្រព្រឹត្ត ដើម្បីសម្លាប់នូវបុគ្គល ដែលគួរសម្លាប់

ឈាបេតាយំ វា ឈាបេតុំ បព្វាជេតាយំ វា បព្វាជេតុំ សេយ្យថាបិ រញ្ញោ បសេនទិស្ស កោសលស្ស សេយ្យថាបិ វា បន រញ្ញោ មាគធស្ស អជាតសត្តុស្ស វេទេហិបុត្តស្ស ឥមេសម្បិ[១] ហិ ភោ គោតម សង្ឃានំ គណានំ សេយ្យថីទំ វជ្ជីនំ មល្លានំ វត្តតិ សកស្មឹ វិជិតេ វសោ ឃាតេតាយំ វា ឃាតេតុំ ឈាបេតាយំ វា ឈាបេតុំ បព្វាជេតាយំ វា បព្វាជេតុំ កឹ បន រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស សេយ្យថាបិ រញ្ញោ បសេនទិស្ស កោសលស្ស សេយ្យថាបិ វា បន រញ្ញោ មាគធស្ស អជាតសត្តុស្ស វេទេហិបុត្តស្ស វត្តេយ្យ ភោ គោតម វត្តិតុញ្ចមរហតីតិ[២] ។ តំ កឹ មញ្ញសិ អគ្គិវេស្សន យំ ត្វំ ឯវំ វទេសិ រូបំ មេ អត្តាតិ វត្តតិ តេ តស្មឹ រូបេ វសោ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ អហោសីតិ ។ ឯវំ វុត្តេ សច្ចកោ និគណ្ឋបុត្តោ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ភគវា សច្ចកំ និគណ្ឋបុត្តំ ឯតទវោច តំ កឹ មញ្ញសិ អគ្គិវេស្សន យំ ត្វំ ឯវំ វទេសិ

---

១ ម. ឥមេសំបិ ។ ២ ម. វត្តិតុំ ច មរហតីតិ ។

ដើម្បីរឹបជាន់នូវបុគ្គលដែលគួររឹបជាន់ ឬដើម្បីនិរទេសនូវបុគ្គលដែលគួរនិរទេសបាន បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថា សូម្បីក្សត្រិយ៍ទាំងអម្បាលនេះ ជាពួក ជាគណៈ ដូចពួកក្សត្រិយ៍ដែលនៅក្នុងដែនវជ្ជី និងពួកក្សត្រិយ៍ដែលនៅក្នុងដែនមល្ល: មានអំណាចក្នុងដែនជារបស់ខ្លួន តែងប្រព្រឹត្តដើម្បីសម្លាប់នូវបុគ្គលដែលគួរសម្លាប់ ដើម្បីរឹបជាន់នូវបុគ្គលដែលគួររឹបជាន់ ឬដើម្បីនិរទេសនូវបុគ្គលដែលគួរនិរទេសបាន នឹងបាច់ពោលថ្វីដល់ទៅអំណាចរបស់ព្រះរាជាជាខត្តិយៈ ដែលបានមុទ្ធាភិសេកហើយ ដូចយ៉ាងព្រះរាជាបសេនទិកោសល ពុំនោះសោតដូចព្រះរាជាអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ បពិត្រព្រះគោតមដ៏ចម្រើន អំណាចគប្បីប្រព្រឹត្តទៅ ទាំងគួរនឹងប្រព្រឹត្តទៅ ។ នែអគ្គិវេស្សនៈ អ្នកសំគាល់ នូវហេតុនោះដូចម្តេច អ្នកពោលនូវរូបណាយ៉ាងនេះថា រូបជាខ្លួនរបស់អញ អំណាចរបស់អ្នក ប្រព្រឹត្តទៅក្នុងរូបនោះថា រូបរបស់អញ ចូរយ៉ាងនេះទៅ រូបរបស់អញ ចូរកុំមានយ៉ាងនេះឡើយ បានឬទេ ។ កាលបើព្រះសាស្តា ទ្រង់ត្រាស់យ៉ាងនេះហើយ សច្ចកនិគន្ថបុត្រ ក៏នៅស្ងៀម ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះនឹងសច្ចកនិគន្ថបុត្រ ជាគម្រប់ពីរដងថា នែអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះ ថាដូចម្តេច អ្នកពោល នូវរូបណា យ៉ាងនេះថា

រូបំ មេ អត្តាតិ វត្តតិ តេ តស្មឹ រូបេ វសោ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ ។ ឯវំ វុត្តេ ទុតិយម្បិ ខោ សច្ចកោ និគណ្ឋបុត្តោ តុណ្ហី អហោសិ ។ អថខោ ភគវា សច្ចកំ និគណ្ឋបុត្តំ ឯតទវោច ព្យាករោហិទានិ អគ្គិវេស្សន នទានិ តេ តុណ្ហីភាវស្ស កាលោ យោ ខោ[១] អគ្គិវេស្សន តថាគតេន យាវតតិយំ សហធម្មិកំ បញ្ហំ បុដ្ឋោ ន ព្យាករោតិ ឯត្ថេវស្ស សត្តធា មុទ្ធា ផលិស្សតីតិ[២] ។ តេន ខោ បន សមយេន វជិរបាណី យក្ខោ អយសំ វជិរំ អាទាយ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ សច្ចកស្ស និគណ្ឋបុត្តស្ស ឧបរិវេហាយំ ឋិតោ[៣] ហោតិ សចាយំ សច្ចកោ និគណ្ឋបុត្តោ ភគវតា យាវតតិយំ សហធម្មិកំ បញ្ហំ បុដ្ឋោ ន ព្យាករោតិ[៤] ឯត្ថេវស្ស សត្តធា មុទ្ធំ ផាលេស្សាមីតិ ។ តំ ខោ បន វជិរបាណឹ យក្ខំ ភគវា ចេវ បស្សតិ សច្ចកោ ច និគណ្ឋបុត្តោ ។ អថខោ សច្ចកោ និគណ្ឋបុត្តោ ភីតោ សំវិគ្គោ

---

១ ឱ. ម. យោ កោចិ ។ ២ ឱ. ម. ផលតីតិ ។ ៣ ឱ. ម. ឧបរិវេហាសំ ឋិតោ ។ ៤ ឱ. ម. ន ព្យាករិស្សតិ ។

រូបជាខ្លួនរបស់អញ អំណាចរបស់អ្នក ប្រព្រឹត្តទៅក្នុងរូបនោះថា រូបរបស់អញចូរយ៉ាងនេះទៅ រូបរបស់អញកុំយ៉ាងនេះឡើយ បានឬទេ ។ កាលព្រះសាស្តាទ្រង់ត្រាស់យ៉ាងនេះហើយ សច្ចកនិគន្ថបុត្រក៏នៅស្ងៀមជាគម្រប់ពីរដង ។ លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះ នឹងសច្ចកនិគន្ថបុត្រថា នែអគ្គិវេស្សនៈ អ្នកចូរដោះស្រាយនូវបញ្ហាក្នុងកាលឥឡូវនេះទៅ កាលឥឡូវនេះមិនមែនជាកាលអ្នកស្ងៀមទេ នែអគ្គិវេស្សនៈ អ្នកណាមួយ ដែលតថាគតសួរនូវបញ្ហាប្រកបដោយធម៌ ជាគម្រប់ ៣ ដង ហើយ នៅតែមិនដោះស្រាយ ក្បាលរបស់អ្នកនោះ នឹងបែកជា ៧ ភាគ ក្នុងទីនុ៎ះពុំខាន ។ សម័យនោះឯង មានយក្សម្នាក់ឈ្មោះវជិរ-បាណី[១] កាន់ដែកដូចជាកែវវជិរ ដែលឆេះប្រាលរន្ទាលភ្លឺសន្ធោសន្ធៅ មកសណ្ឋិតនៅឰដ៏អាកាស ជាខាងលើនៃសច្ចកនិគន្ថបុត្រ ពោលពាក្យដូច្នេះថា បើសច្ចកនិគន្ថបុត្រនេះ ដែលព្រះមានព្រះភាគទ្រង់សួរបញ្ហាប្រកបដោយធម៌ ជាគម្រប់ ៣ ដងហើយ នៅតែមិនដោះស្រាយ អញនឹងបំបែកក្បាលរបស់សច្ចកនិគន្ថបុត្រនោះ ជា ៧ ភាគ ក្នុងទីនេះឯង ។ ព្រះមានព្រះភាគនិងសច្ចកនិគន្ថបុត្រ ក៏បានឃើញយក្សឈ្មោះវជិរបាណីនោះប្រាកដ ។ គ្រានោះឯង សច្ចកនិគន្ថបុត្រ ភ័យ តក់ស្លុត រន្ធត់

---

១ ព្រះឥន្ទ ។

៧៣

## មហាយមកវគ្គស្ស ចូឡសច្ចកសុត្តេ តិលក្ខណព្យាករណំ

លោមហដ្ឋជាតោ ភគវន្តំយេវ តាណំ គវេសី ភគវន្តំយេវ លេណំ គវេសី ភគវន្តំយេវ សរណំ គវេសី ភគវន្តំ ឯតទវោច បុច្ឆតុ មំ ភវំ គោតមោ ព្យាករិស្សាមីតិ ។

[៣៨] តំ កឹ មញ្ញសិ អគ្គិវេស្សន យំ ត្វំ ឯវំ វទេសិ រូបំ មេ អត្តាតិ វត្តតិ តេ តស្មឹ រូបេ វសោ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ ។ នោ ហិទំ ភោ គោតម ។ មនសិករោហិ អគ្គិវេស្សន មនសិករិត្វា ខោ អគ្គិវេស្សន ព្យាករោហិ ន ខោ តេ សន្ធីយតិ បុរិមេន វា បច្ឆិមំ បច្ឆិមេន វា បុរិមំ តំ កឹ មញ្ញសិ អគ្គិវេស្សន យំ ត្វំ ឯវំ វទេសិ វេទនា មេ អត្តាតិ វត្តតិ តេ តាយ វេទនាយ វសោ ឯវំ មេ វេទនា ហោតុ ឯវំ មេ វេទនា មា អហោសីតិ ។ នោ ហិទំ ភោ គោតម ។ មនសិករោហិ អគ្គិវេស្សន មនសិករិត្វា ខោ អគ្គិវេស្សន

ព្រឹព្រួចរោម ក៏អាងព្រះមានព្រះភាគជាទីពឹង អាងព្រះមានព្រះភាគជាទីពួន អាងព្រះមានព្រះភាគជាទីកម្ចាត់បង់នូវភ័យ ក្រាបទូលសេចក្តីនេះ ចំពោះព្រះមានព្រះភាគថា សូមព្រះគោតមដ៏ចម្រើន សួរនូវបញ្ហានឹងខ្ញុំព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងដោះស្រាយឥឡូវនេះ ។

[៣៨] ម្នាលអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះថាដូចម្តេច អ្នកពោលនូវរូបណាយ៉ាងនេះថា រូបជាខ្លួនរបស់អញ អំណាចរបស់អ្នកប្រព្រឹត្តទៅក្នុងរូបនោះថា រូបរបស់អញចូរយ៉ាងនេះចុះ រូបរបស់អញចូរកុំយ៉ាងនេះឡើយ បានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីនេះមិនបានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកចូរធ្វើទុកក្នុងចិត្តចុះ នែអគ្គិវេស្សនៈ លុះអ្នកធ្វើទុកក្នុងចិត្តរួចហើយ ចូរដោះស្រាយខ្លួនឯងចុះ ព្រោះពាក្យខាងចុងរបស់អ្នកមិនជាប់តគ្នានឹងពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក មិនជាប់តគ្នានឹងពាក្យខាងចុង នែអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះថាដូចម្តេច អ្នកពោលនូវវេទនាណាយ៉ាងនេះថា វេទនាជាខ្លួនរបស់អញ អំណាចរបស់អ្នក ប្រព្រឹត្តទៅក្នុងវេទនានោះថា វេទនារបស់អញចូរយ៉ាងនេះទៅ វេទនារបស់អញ ចូរកុំយ៉ាងនេះឡើយ បានឬ ។ បពិត្រព្រះគោតម ដ៏ចម្រើន សេចក្តីនេះ មិនបានទេ ។ ម្នាលអគ្គិ-វេស្សនៈ អ្នកចូរធ្វើទុកក្នុងចិត្តចុះ នែអគ្គិវេស្សនៈ លុះអ្នកធ្វើទុកក្នុងចិត្ត

ព្យាករេហិ ន ខោ តេ សន្ធីយតិ បុរិមេន វា បច្ឆិមំ បច្ឆិមេន វា បុរិមំ តំ កឹ មញ្ញសិ អគ្គិវេស្សន យំ ត្វំ ឯវំ វទេសិ សញ្ញា មេ អត្តាតិ វត្តតិ តេ តាយ សញ្ញាយ វសោ ឯវំ មេ សញ្ញា ហោតុ ឯវំ មេ សញ្ញា មា អហោសីតិ ។ នោ ហិទំ ភោ គោតម ។ មនសិករោហិ អគ្គិវេស្សន មនសិករិត្វា ខោ អគ្គិវេស្សន ព្យាករេហិ ន ខោ តេ សន្ធីយតិ បុរិមេន វា បច្ឆិមំ បច្ឆិមេន វា បុរិមំ តំ កឹ មញ្ញសិ អគ្គិវេស្សន យំ ត្វំ ឯវំ វទេសិ សង្ខារា មេ អត្តាតិ វត្តតិ តេ តេសុ សង្ខារេសុ វសោ ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហេសុន្តិ ។ នោ ហិទំ ភោ គោតម ។ មនសិករោហិ អគ្គិវេស្សន មនសិករិត្វា ខោ

រួចហើយ ចូរដោះស្រាយចុះ ព្រោះពាក្យខាងចុងរបស់អ្នកមិនជាប់តគ្នានឹងពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក ក៏មិនជាប់តគ្នានឹងពាក្យខាងចុងដែរ នែអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះថាដូចម្តេច អ្នកពោលនូវសញ្ញាណា យ៉ាងនេះថា សញ្ញាជាខ្លួនរបស់អញ អំណាចរបស់អ្នកប្រព្រឹត្តទៅក្នុងសញ្ញានោះថា សញ្ញារបស់អញ ចូរយ៉ាងនេះ សញ្ញារបស់អញចូរកុំយ៉ាងនេះឡើយ បានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនបានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកចូរធ្វើទុកក្នុងចិត្តចុះ នែអគ្គិវេស្សនៈ លុះអ្នកធ្វើទុកក្នុងចិត្តរួចហើយ ចូរដោះស្រាយចុះ ព្រោះពាក្យខាងចុងរបស់អ្នក មិនជាប់តគ្នានឹងពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក ក៏មិនជាប់តគ្នានឹងពាក្យខាងចុងដែរ នែអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះ ថាដូចម្តេច អ្នកពោលនូវសង្ខារណាយ៉ាងនេះថា សង្ខារទាំងឡាយជាខ្លួនរបស់អញ អំណាចរបស់អ្នក ប្រព្រឹត្តទៅក្នុងសង្ខារទាំងនោះថា សង្ខារទាំងឡាយរបស់អញ ចូរយ៉ាងនេះទៅ សង្ខារទាំងឡាយរបស់អញ ចូរកុំយ៉ាងនេះឡើយ បានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនបានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកចូរធ្វើទុកក្នុងចិត្តចុះ នែអគ្គិវេស្សនៈ លុះអ្នកធ្វើទុកក្នុងចិត្តរួចហើយ ចូរដោះស្រាយចុះ

៧៤



អគ្គិវេស្សន ព្យាករោហិ ន ខោ តេ សន្ធីយតិ បុរិមេន វា បច្ឆិមំ បច្ឆិមេន វា បុរិមំ តំ កឹ មញ្ញសិ អគ្គិវេស្សន យំ ត្វំ ឯវំ វទេសិ វិញ្ញាណំ មេ អត្តាតិ វត្តតិ តេ តស្មឹ វិញ្ញាណេ វសោ ឯវំ មេ វិញ្ញាណំ ហោតុ មេ វិញ្ញាណំ មា អហោសីតិ ។ នោ ហិទំ ភោ គោតម ។ មនសិករោហិ អគ្គិវេស្សន មនសិករិត្វា ខោ អគ្គិវេស្សន ព្យាករោហិ ន ខោ តេ សន្ធីយតិ បុរិមេន វា បច្ឆិមំ បច្ឆិមេន វា បុរិមំ តំ កឹ មញ្ញសិ អគ្គិវេស្សន រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភោ គោតម ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភោ គោតម ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភោ គោតម ។ តំ កឹ មញ្ញសិ អគ្គិវេស្សន វេទនា... សញ្ញា...

ព្រោះពាក្យខាងចុងរបស់អ្នក មិនជាប់តគ្នានឹងពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក ក៏មិនជាប់តគ្នានឹងពាក្យខាងចុងដែរ នែអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះ ថាដូចម្តេច អ្នកពោលនូវវិញ្ញាណណាយ៉ាងនេះថា វិញ្ញាណជាខ្លួនរបស់អញ អំណាចរបស់អ្នក ប្រព្រឹត្តទៅក្នុងវិញ្ញាណនោះថា វិញ្ញាណរបស់អញ ចូរយ៉ាងនេះទៅ វិញ្ញាណរបស់អញ ចូរកុំយ៉ាងនេះឡើយ បានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនបានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកចូរធ្វើទុកក្នុងចិត្តចុះ នែអគ្គិវេស្សនៈ លុះអ្នកធ្វើទុកក្នុងចិត្តរួចហើយ ចូរដោះស្រាយចុះ ព្រោះពាក្យខាងចុងរបស់អ្នក មិនជាប់តគ្នានឹងពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក ក៏មិនជាប់តគ្នានឹងពាក្យខាងចុងដែរ នែអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះ ថាដូចម្តេច រូបទៀងឬមិនទៀង ។ បពិត្រព្រះគោតមដ៏ចម្រើន រូបមិនទៀងទេ ។ របស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះគោតមដ៏ចម្រើន របស់នោះជាទុក្ខ ។ ចុះរបស់ណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនគួរឃើញយ៉ាងនុ៎ះទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះថាដូចម្តេច វេទនា... សញ្ញា...

សង្ខារា... វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភោ គោតម ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភោ គោតម ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភោ គោតម ។ តំ កឹ មញ្ញសិ អគ្គិវេស្សន យោ នុ ខោ ទុក្ខំ អល្លីនោ ទុក្ខំ ឧបគតោ ទុក្ខំ អជ្ឈោសិតោ ទុក្ខំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ អបិ នុ ខោ សោ សាមំ វា ទុក្ខំ បរិជានេយ្យ ទុក្ខំ វា បរិក្ខេបេត្វា វិហរេយ្យាតិ ។ កិញ្ហិ សិយា ភោ គោតម នោ ហិទំ ភោ គោតមាតិ ។ តំ កឹ មញ្ញសិ អគ្គិវេស្សន ននុ ត្វំ ឯវំ សន្តេ ទុក្ខំ អល្លីនោ ទុក្ខំ ឧបគតោ ទុក្ខំ អជ្ឈោសិតោ ទុក្ខំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សសីតិ ។ កិញ្ហិ នោ សិយា ភោ គោតម ឯវមេតំ ភោ គោតមាតិ ។

សង្ខារទាំងឡាយ... វិញ្ញាណទៀង ឬមិនទៀង ។ បពិត្រព្រះគោតមដ៏ចម្រើន វិញ្ញាណមិនទៀងទេ ។ ចុះរបស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះគោតមដ៏ចម្រើន របស់នោះជាទុក្ខ ។ ចុះរបស់ណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនគួរឃើញយ៉ាងនុ៎ះទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះថាដូចម្តេច បុគ្គលណាស្អិតជាប់នឹងសេចក្តីទុក្ខ ប្រកបនឹងសេចក្តីទុក្ខ លិចចុះទៅក្នុងសេចក្តីទុក្ខ ឃើញនូវសេចក្តីទុក្ខថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះហើយ បុគ្គលនោះគប្បីកំណត់ដឹងនូវសេចក្តីទុក្ខដោយខ្លួនឯងបាន ឬថាគប្បីធ្វើសេចក្តីទុក្ខឲ្យអស់ទៅបាន តើមានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន នឹងមានដូចម្តេចបាន បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនមានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះថា ដូចម្តេច កាលបើមានហេតុយ៉ាងនេះ ក្រែងអ្នកជាបុគ្គលជាប់ស្អិតនឹងសេចក្តីទុក្ខ ប្រកបនឹងសេចក្តីទុក្ខ លិចចុះទៅក្នុងសេចក្តីទុក្ខហើយ ឃើញសេចក្តីទុក្ខថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះមែនឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ថ្វីក៏មិនមានដូច្នោះ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនុ៎ះយ៉ាងនេះឯង ។

៧៧

មហាយមកវគ្គស្ស  ចូឡសច្ចកសុត្តេ  សារត្ថិកូបមា

[៣៩] សេយ្យថាបិ អគ្គិវេស្សន បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនំ ចរមានោ តិណ្ហំ កុឋារឹ[១] អាទាយ វនំ បវិសេយ្យ សោ តត្ថ បស្សេយ្យ មហន្តំ កទលិក្ខន្ធំ ឧជុំ នវំ អកុក្កុជជាតំ[២] តមេនំ មូលេ ឆិន្ទេយ្យ មូលេ ឆេត្វា អគ្គេ ឆិន្ទេយ្យ អគ្គេ ឆេត្វា បត្តវដ្ដឹ វិនិព្ភុជេយ្យ សោ តត្ថ បត្តវដ្ដឹ វិនិព្ភុជន្តោ ផេគ្គុំបិ នាធិគច្ឆេយ្យ កុតោ សារំ ឯវមេវ ខោ ត្វំ អគ្គិវេស្សន មយា សកស្មឹ វាទេ សមនុយុញ្ជិយមានោ សមនុភាសិយមានោ សមនុគ្គាហិយមានោ រិត្តោ តុច្ឆោ អបរទ្ធោ ភាសិតា ខោ បន តេ ឯសា អគ្គិវេស្សន វេសាលិយំ បរិសតិ វាចា នាហន្តំ បស្សាមិ សមណំ វា ព្រាហ្មណំ វា សង្ឃឹ គណឹ គណាចរិយំ អបិច អរហន្តំ សម្មាសម្ពុទ្ធំ បដិជានមានំ យោ មយា វាទេន វាទំ សមារទ្ធោ សង្កម្បេយ្យ ន សម្បកម្បេយ្យ ន សម្បវេធេយ្យ យស្ស ន កច្ឆេហិ សេទា មុញ្ចេយ្យុំ ថូណាញ្ចាហំ អចេតនំ វាទេន វាទំ សមារភេយ្យំ

១ កុឋារិន្តិបិ ។ ២ ឱ. ម. អកុក្កុកជាតំ ។

មហាយមកវគ្គ ចូឡសច្ចកសូត្រ ឧបមាដោយអ្នកត្រូវការខ្លឹមឈើ

[៣៩] ម្នាលអគ្គិវេស្សនៈ ដូចជាបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រេចទៅស្វែងរកខ្លឹមឈើ ក៏កាន់យកនូវដឹងដ៏មុតចូលទៅកាន់ព្រៃ បុរសនោះឃើញដើមចេកធំ ក្នុងព្រៃនោះ មានដើមត្រង់ សាច់ខ្ចី មិនទាន់កើតមានស្នូលស្នង ហើយកាត់នូវដើមចេកនោះត្រង់គល់ លុះកាត់គល់រួចហើយ ក៏កាត់ចុង លុះកាត់ចុងរួចហើយ បកស្រទបចេញ កាលដែលបុរសនោះបកស្រទបចេញ ក៏មិនគប្បីបាន សូម្បីនូវស្រាយ ក្នុងដើមចេកនោះឡើយ នឹងបានខ្លឹមមកពីណា សេចក្តីនេះមានឧបមាយ៉ាងណាមិញ នែអគ្គិវេស្សនៈ អ្នកដែលតថាគតជជីកសួរដេញដោល ក៏ទៅជាមនុស្សសោះសូន្យទទេឥតខ្លឹមសារ ចាលចាញ់ក្នុងវាទៈរបស់ខ្លួន មានឧបមេយ្យដូចដើមចេកដូច្នោះឯង នែអគ្គិវេស្សនៈ មួយទៀត វាចានេះ អ្នកបានពោលហើយ នាកណ្តាលបរិស័ទ ក្រុងវេសាលីថា បុគ្គលណាដែលអាត្មាលើកឡើងនូវទោស ដោយពាក្យសំដីហើយ មិនកក្រើក មិនរំភើប មិនញាប់ញ័រ ទាំងញើសក៏មិនហូរចេញអំពីក្លៀករបស់បុគ្គលណា អាត្មាមិនបានឃើញនូវបុគ្គលនោះ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ដែលមានពួកមានគណៈ ជាអាចារ្យនៃគណៈ ឬក៏បានប្តេជ្ញាខ្លួនថាជាអរហន្តសម្មាសម្ពុទ្ធទេ ឯអាត្មា បើគប្បីលើកឡើងនូវទោសដោយពាក្យសំដីចំពោះទៅលើបង្គោល ដែលជារបស់គ្មានចេតនាសោះ

សាបិ មយា វាទេន វាទំ សមារទ្ធា សង្កម្បេយ្យ សម្បកម្បេយ្យ សម្បវេធេយ្យ កោ បន វាទោ មនុស្សភូតស្សាតិ តុយ្ហំ ខោ បន អគ្គិវេស្សន អប្បេកច្ចានិ សេទផុសិតានិ នលាដមុត្តានិ[១] ឧត្តរាសង្គំ វិនិភិន្ទិត្វា ភូមិយំ បតិដ្ឋិតានិ មយ្ហំ ខោ បន អគ្គិវេស្សន នត្ថិ ឯតរហិ កាយស្មឹ សេទោតិ ។ ឥតិ ភគវា តស្មឹ បរិសតិ សុវណ្ណវណ្ណំ កាយំ វិវរិ ។ ឯវំ វុត្តេ សច្ចកោ និគណ្ឋបុត្តោ តុណ្ហីភូតោ មង្កុភូតោ បត្តក្ខន្ធោ អធោមុខោ បជ្ឈាយន្តោ អប្បដិភាណោ និសីទិ ។

[៤០] អថខោ ទុម្មុខោ លិច្ឆវិបុត្តោ សច្ចកំ និគណ្ឋបុត្តំ តុណ្ហីភូតំ មង្កុភូតំ បត្តក្ខន្ធំ អធោមុខំ បជ្ឈាយន្តំ អប្បដិភាណំ វិទិត្វា ភគវន្តំ ឯតទវោច

---

១ ឱ. ម. នលាដា មុត្តានិ ។

បង្គោលនោះ លុះអាត្មាលើកឡើងនូវទោស ដោយពាក្យសំដីហើយ ក៏គប្បីកក្រើក រំភើប ញាប់ញ័រមិនខាន និយាយទៅថ្វីដល់មនុស្សជាតផងគ្នា ម្នាលអគ្គិវេស្សនៈ ចំណែកអ្នកមានតំណក់ញើសខ្វះ ហូរចេញអំពីថ្ងាសទំលុះសំពត់បង់ក ហើយធ្លាក់ទៅដក់លើផែនដីហើយ នៃអគ្គិវេស្សនៈ ឯតថាគត ឥឡូវនេះ ឥតមានញើសក្នុងកាយទេ ។ ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទ្រង់បើក នូវព្រះកាយ[១] ដែលមានសម្បុរដូចជាពណ៌នៃមាស ក្នុងបរិស័ទនោះ ។ កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សច្ចកនិគន្ថបុត្ត ក៏អង្គុយស្ងៀម អៀនអន់ ដាក់កសំយុង មុខចុះក្រោម ជ្រប់ស្រងូត មិនក្លៀវក្លា ។

[៤០] គ្រានោះឯង លិច្ឆវិបុត្រឈ្មោះទុម្មុខៈ ដឹងច្បាស់ថា សច្ចកនិគន្ថបុត្ត ស្ងៀម អៀនអន់ ដាក់កសំយុង មុខចុះក្រោម ជ្រប់ស្រងូត មិនក្លៀវក្លា ហើយក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះ

---

១ ព្រះអង្គបើកកាយនោះ មិនមែនបើកកាយទាំងអស់ទេ ព្រោះទំនៀមព្រះពុទ្ធគ្រប់ព្រះអង្គ តែងពាក់ក្តុំបិទសរីរៈហើយសំដែងធម៌ក្នុងប្រជុំបរិសទ្យ ។ ក្នុងកាលនោះព្រះមានព្រះភាគទ្រង់ចាប់យកចីវរ ត្រង់បំពង់ព្រះសូរងខាងមុខទម្លាក់ចុះ ប្រមាណប៉ុន ៤ ធ្នាប់ ។

មហាយមកវគ្គស្ស ចូឡសច្ចកសុត្តេ ទុម្មុខស្ស ឧបមាវចនំ

ឧបមា មំ ភគវា បដិភាតីតិ ។ បដិភាតុ តំ ទុម្មុខាតិ ភគវា អវោច ។ សេយ្យថាបិ ភន្តេ គាមស្ស វា និគមស្ស វា អវិទូរេ បោក្ខរណី តត្រស្ស កក្កដកោ អថខោ ភន្តេ សម្ពហុលា កុមារកា វា កុមារិកា វា តម្ហា គាមា វា និគមា វា និក្ខមិត្វា យេន សា បោក្ខរណី តេនុបសង្កមេយ្យុំ ឧបសង្កមិត្វា តំ បោក្ខរ-ណឹ ឱគាហេត្វា តំ កក្កដកំ ឧទកា ឧទ្ធរិត្វា ថលេ បតិដ្ឋាបេយ្យុំ យញ្ញទេវ ហិ សោ ភន្តេ កក្កដកោ អឡំ អភិនិន្នាមេយ្យ តំ តទេវ តេ កុមារកា វា កុមារិកា វា កដ្ឋេន វា កឋលេន វា សញ្ឆិន្ទេយ្យុំ សម្ភញ្ជេយ្យុំ សម្ប-លិភញ្ជេយ្យុំ ឯវញ្ហិ សោ ភន្តេ កក្កដកោ សព្វេហិ អឡេហិ សញ្ឆិន្នេហិ សម្ភគ្គេហិ សម្បលិភគ្គេហិ អ-ភព្វោ តំ បោក្ខរណឹ បុន ឱតរិតុំ សេយ្យថាបិ បុព្វេ ឯវមេវ ខោ ភន្តេ យានិ សច្ចកស្ស និគណ្ឋបុត្តស្ស វិសូ-កាយិតានិ វិសេវិតានិ វិប្ផន្ទិតានិ កានិចិ កានិចិ តានិ ភគវតា សញ្ឆិន្នានិ សម្ភគ្គានិ សម្បលិភគ្គានិ អភព្វោ ចទានិ ភន្តេ សច្ចកោ និគណ្ឋបុត្តោ បុន ភគវន្តំ

មានព្រះភាគ ខ្ញុំព្រះអង្គសូមសំដែងពាក្យឧបមាបន្តិច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលទុម្មុខៈ ចូរអ្នកសំដែងពាក្យឧបមានោះទៅមើល ។ បពិត្រព្រះអង្គដ៏ចម្រើន ដូចជាស្រះបោក្ខរណីនៅជិតស្រុកឬនិគម មានក្តាមនៅក្នុងស្រះបោក្ខរណីនោះ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ក្មេងប្រុសឬក្មេងស្រីទាំងឡាយជាច្រើន ចេញអំពីស្រុកឬនិគមនោះ ចូលទៅកាន់ស្រះបោក្ខរណី លុះចូលទៅដល់ហើយ ក៏ចុះទៅកាន់ស្រះបោក្ខរណីនោះ ហើយចាប់ក្តាមនោះស្រង់អំពីទឹក មកដាក់នៅលើគោក បពិត្រព្រះអង្គដ៏ចម្រើន ក្តាមនោះហាចេញនូវដង្កៀបណា ៗ ក្មេងប្រុសឬក្មេងស្រីទាំងនោះ ក៏កាច់បំបាក់បំបែកនូវដង្កៀបនោះ ៗ ដោយកំណាត់ឈើក្តី ដោយអំបែងក្តី បពិត្រព្រះអង្គដ៏ចម្រើន កាលបើយ៉ាងនេះហើយ ក្តាមនោះដែលមានដង្កៀបទាំងអស់ គេកាច់បំបាក់បំបែកអស់ហើយ មិនគួរដើម្បីនឹងចុះទៅកាន់ស្រះបោក្ខរណីនោះទៀតបានដូចកាលមុនទេ មានឧបមាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីចម្រូងចម្រាសគឺទិដ្ឋិ ពុតត្បុតគឺទិដ្ឋិ និងសេចក្តីញាប់ញ័រគឺទិដ្ឋិណានីមួយ របស់សច្ចកនិគន្ថបុត្រ ក៏សេចក្តីចម្រូងចម្រាសជាដើមនោះ ព្រះមានព្រះភាគទ្រង់កាច់បំបាក់បំបែកហើយ បពិត្រព្រះអង្គដ៏ចម្រើន កាលឥឡូវនេះ សច្ចកនិគន្ថបុត្រមិនគួរនឹងមានសេចក្តីប្រាថ្នាថា នឹងលើកឡើងនូវវាទៈ ចូលទៅរកព្រះមានព្រះភាគទៀតទេ

ឧបសង្កមិតុំ យទិទំ វាទាធិប្បាយោតិ ។ ឯវំ វុត្តេ សច្ចកោ និគណ្ឋបុត្តោ ទុម្មុខំ លិច្ឆវិបុត្តំ ឯតទវោច អាគមេហិ ត្វំ ទុម្មុខ អាគមេហិ ត្វំ ទុម្មុខ មុខរោសិ ត្វំ ទុម្មុខ[១] ន មយំ តយា សទ្ធឹ មន្តេម ឥធ មយំ ភោតា គោតមេន សទ្ធឹ មន្តេម តិដ្ឋតេសា ភោ គោតម អម្ហាកញ្ចេវ អញ្ញេសញ្ច បុថុសមណ-ព្រាហ្មណានំ វាចាវិលាបំ វិលបិតំ មញ្ញតិ ។

[៤១] កិត្តាវតា ច នុ ខោ ភោតោ គោត-មស្ស សាវកោ សាសនករោ ហោតិ ឱវាទប្បតិ-ករោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុ សាសនេ វិហរតីតិ ។ ឥធ អគ្គិវេស្សន មម សាវកោ យំ កិញ្ចិ រូបំ អតីតា-នាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ

១ ឱ. ម. មុខរោសិ ត្វំ ទុម្មុខាតិ ន ទិស្សតិ ។

មានឧបមេយ្យដូច្នោះឯង ។ កាលបើទុម្មុខលិច្ឆវិបុត្ត និយាយយ៉ាងនេះហើយ សច្ចកនិគន្ថបុត្រក៏ពោលពាក្យនេះទៅនឹងទុម្មុខលិច្ឆវិបុត្តថា នែទុម្មុខៈ អ្នកចូរឈប់សិន នែទុម្មុខៈ អ្នកចូរឈប់សិន នែទុម្មុខៈ អ្នកជាបុគ្គលមានមាត់រឹង យើងមិនមែនប្រឹក្សា ជាមួយនឹងអ្នកទេ ក្នុងទីនេះ យើងនឹងប្រឹក្សាជាមួយព្រះគោតមដ៏ចម្រើនថា បពិត្រព្រះគោតមដ៏ចម្រើន វាចានេះ ជាវាចារបស់យើងទាំងឡាយផង របស់សមណព្រាហ្មណ៍ដ៏ច្រើនដទៃផង ចូរស្ទេះទុកចុះ ការបញ្ចេញនូវវាចានេះ ក៏ហាក់ដូចជាគ្រាន់តែនិយាយទៅទេ ។

[៤១] សច្ចកនិគន្ថបុត្រ ក្រាបបង្គំទូលសួរថា សាវ័ករបស់ព្រះគោតមដ៏ចម្រើន ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ប្រព្រឹត្តតាមដំបូន្មាន ប្រព្រឹត្តកន្លងសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ហើយ ដល់នូវសេចក្តីក្លៀវក្លា មិនជឿអ្នកដទៃ ក្នុងសាសនានៃព្រះសាស្តា ដោយហេតុមានប៉ុន្មានយ៉ាង ។ ម្នាលអគ្គិវេស្សនៈ រូបណានីមួយ ជាអតីត អនាគត និងបច្ចុប្បន្ន ជារូបខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី មួយទៀត រូបណានៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី រូបទាំងអស់នោះ បានឈ្មោះថារូប សាវ័ករបស់តថាគតក្នុងសាសនា

បស្សតិ ។ យា កាចិ វេទនា ។ បេ ។ យា កាចិ សញ្ញា... យេ កេចិ សង្ខារា... យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ ឯត្តាវតា ខោ អគ្គិវេស្សន មម សាវកោ សាសនករោ ហោតិ ឱវាទប្បតិករោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្ប-ច្ចយោ សត្ថុ សាសនេ វិហរតីតិ ។

នេះ តែងឃើញនូវរូបនុ៎ះតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វេទនាណានីមួយ ។ បេ ។ សញ្ញាណានីមួយ... សង្ខារទាំងឡាយណានីមួយ... វិញ្ញាណណានីមួយ ជាអតីត អនាគត និងបច្ចុប្បន្ន ជាវិញ្ញាណ ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី មួយទៀត វិញ្ញាណណា ដែលមាននៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះ បានឈ្មោះថាវិញ្ញាណ សាវ័ករបស់តថាគតតែងឃើញនូវវិញ្ញាណនុ៎ះ តាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ នែអគ្គិវេស្សនៈ សាវ័ករបស់តថាគត ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ប្រព្រឹត្តតាមដំបូន្មាន ប្រព្រឹត្តកន្លងសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ហើយ ដល់នូវសេចក្តីក្លៀវក្លា មិនជឿបុគ្គលដទៃក្នុងសាសនានៃព្រះសាស្តា ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

[៤២] កិត្តាវតា បន ភោ គោតម ភិក្ខុ អរហំ ហោតិ ខីណាសវោ វុសិតវា កតករណីយោ ឱហិត-ភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្ម-ទញ្ញាវិមុត្តោតិ ។ ឥធ អគ្គិវេស្សន ភិក្ខុ យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិ-កំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិ-កេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អនុ-ចាទាវិមុត្តោ ហោតិ ។ យា កាចិ វេទនា... យា កាចិ សញ្ញា... យេ កេចិ សង្ខារា... យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ

[៤២] សច្ចកនិគន្ថបុត្រក្រាបទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន ភិក្ខុដែលឈ្មោះថាអរហន្តខីណាស្រព មានព្រហ្មចារ្យនៅរួចហើយ មានសោឡសកិច្ចធ្វើរួចហើយ មានគ្រឿងធ្ងន់ដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានសំយោជនៈ ក្នុងភពអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ ដោយហេតុមានប្រមាណប៉ុន្មាន ។ ម្នាលអគ្គិវេស្សនៈ រូបណានីមួយ ជាអតីត អនាគត និងបច្ចុប្បន្ន ជារូបខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី មួយទៀត រូបណាមាននៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី រូបទាំងអស់នោះ បានឈ្មោះថារូប ភិក្ខុក្នុងសាសនានេះ មានចិត្តផុតស្រឡះហើយ ដោយមិនមានសេចក្តីប្រកាន់មាំ ព្រោះឃើញនូវរូបនុ៎ះតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វេទនាណានីមួយ... សញ្ញាណានីមួយ... សង្ខារទាំងឡាយណានីមួយ... វិញ្ញាណណានីមួយ ជាអតីត អនាគត និងបច្ចុប្បន្ន ជាវិញ្ញាណខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី មួយទៀត វិញ្ញាណណា

៨៣



ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អនុបាទាវិមុត្តោ ហោតិ ។ ឯត្តាវតា ខោ អគ្គិវេស្សន ភិក្ខុ អរហំ ហោតិ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញាវិមុត្តោ[១] ។ ឯវំ វិមុត្តោ[២] ខោ អគ្គិវេស្សន ភិក្ខុ តីហានុត្តរិយេហិ[៣] សមន្នាគតោ ហោតិ ទស្សនានុត្តរិយេន បដិបទានុត្តរិយេន វិមុត្តានុត្តរិយេន ។ ឯវំ វិមុត្តចិត្តោ អគ្គិវេស្សន ភិក្ខុ តថាគតញ្ញេវ សក្ការោតិ គរុការោតិ មានេតិ បូជេតិ

---

១ ឱ. ម. វិមុត្តោតិ ។ ២ ឱ. ម. វិមុត្តចិត្តោ ។ ៣ ឱ. ម. តីហិ អនុត្តរិយេហិ ។

មាននៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះ បានឈ្មោះថាវិញ្ញាណ ភិក្ខុមានចិត្តផុតស្រឡះហើយ ដោយមិនមានសេចក្តីប្រកាន់មាំ ព្រោះឃើញនូវវិញ្ញាណនុ៎ះ តាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ ម្នាលអគ្គិវេស្សនៈ ភិក្ខុដែលឈ្មោះថាអរហន្តខីណាស្រព មានព្រហ្មចារ្យនៅរួចហើយ មានសោឡសកិច្ចធ្វើរួចហើយ មានគ្រឿងទម្ងន់ដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានសំយោជនៈក្នុងភពអស់ហើយ ព្រោះបានត្រាស់ដឹង ដោយប្រពៃដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។ ម្នាលអគ្គិវេស្សនៈ លុះភិក្ខុនោះ មានចិត្តផុតស្រឡះយ៉ាងនេះហើយ តែងប្រកបដោយអនុត្តរិយៈទាំង ៣ គឺ ទស្សនានុត្តរិយៈ ១[១] បដិបទានុត្តរិយៈ ១[២] វិមុត្តានុត្តរិយៈ ១[៣] ។ ម្នាលអគ្គិវេស្សនៈ ភិក្ខុមានចិត្តផុតស្រឡះយ៉ាងនេះហើយ តែងធ្វើសក្ការៈ គោរព រាប់អាន បូជានូវតថាគតដោយគិតថា

---

១ បានដល់បញ្ញាជាលោកិយៈនិងលោកុត្តរៈ ។ ២ បានដល់បដិបទាជាលោកិយៈនិងលោកុត្តរៈ ។ ៣ បានដល់វិមុត្តិជាលោកុត្តរៈ ។ ម្យ៉ាងទៀត បើសង្គ្រោះយកលោកុត្តរសុទ្ធគឺ ទស្សនានុត្តរិយៈ បានដល់អរហត្តមគ្គ សម្មាទិដ្ឋិ ។ បដិបទានុត្តរិយៈ បានដល់អង្គមគ្គដ៏សេសមានសម្មាសង្កប្បៈជាដើម ។ វិមុត្តានុត្តរិយៈ បានដល់មគ្គ ផល វិមុត្តិ ។ អ្នកប្រាជ្ញគប្បីដឹងថា ការឃើញផ្លូវព្រះនិព្វានរបស់ព្រះខីណាស្រព ហៅថា ទស្សនានុត្តរិយៈ ។ អង្គមគ្គទាំង ៨ ហៅថា បដិបទានុត្តរិយៈ ។ មគ្គ ផល ហៅថា វិមុត្តានុត្តរិយៈ ។ អដ្ឋកថា ។

ពុទ្ធោ សោ ភគវា ពោធាយ ធម្មំ ទេសេតិ ទន្តោ សោ ភគវា ទមថាយ ធម្មំ ទេសេតិ សន្តោ សោ ភគវា សមថាយ ធម្មំ ទេសេតិ តិណ្ណោ សោ ភគវា តរណាយ ធម្មំ ទេសេតិ បរិនិព្វុតោ សោ ភគវា បរិនិព្វាណាយ ធម្មំ ទេសេតីតិ ។

[៤៣] ឯវំ វុត្តេ សច្ចកោ និគន្ថបុត្តោ ភគវន្តំ ឯតទវោច មយមេវ ភោ គោតម ធំសី មយំ បគព្ភា យេ មយំ ភវន្តំ គោតមំ វាទេន វាទំ អាសាទេតព្វំ អមញ្ញិម្ហ សិយា ហិ ភោ គោតម ហត្ថឹ បភិន្នំ អាសជ្ជ បុរិសស្ស សោត្ថិភាវោ ន ត្វេវ ភវន្តំ គោតមំ អាសជ្ជ សិយា បុរិសស្ស សោត្ថិភាវោ សិយា ហិ ភោ គោតម បជ្ជលិតំ[១] អគ្គិក្ខន្ធំ អាសជ្ជ បុរិសស្ស សោត្ថិភាវោ

១ ឱ. ជលន្តំ ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹងនូវសច្ចធម៌ទាំង ៤ ហើយ ទ្រង់សំដែងធម៌ ដើម្បីញ៉ាំងពួកជនដទៃឲ្យត្រាស់ដឹងផង ព្រះមានព្រះភាគអង្គនោះ ព្រះអង្គទូន្មាននូវឥន្ទ្រិយហើយ ទ្រង់សំដែងធម៌ ដើម្បីញ៉ាំងសត្វឲ្យទូន្មាននូវឥន្ទ្រិយ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គបានរម្ងាប់បង់នូវកិលេសហើយ ទ្រង់សំដែងធម៌ ដើម្បីញ៉ាំងសត្វឲ្យរម្ងាប់បង់នូវកិលេស ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្លង (នូវអន្លង់ទាំង ៤) ហើយ ទ្រង់សំដែងធម៌ ដើម្បីញ៉ាំងសត្វឲ្យឆ្លងនូវអន្លង់ទាំង ៤ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គរំលត់នូវកិលេសហើយ ទ្រង់សំដែងធម៌ ដើម្បីញ៉ាំងសត្វឲ្យរំលត់កិលេស ។

[៤៣] កាលដែលព្រះមានព្រះភាគ ទ្រង់សំដែងយ៉ាងនេះហើយ សច្ចកនិគន្ថបុត្រ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកកម្ចាត់បង់នូវគុណ ខ្ញុំព្រះអង្គជាអ្នកឃ្នើសឃ្នងដោយវាចា ព្រោះហេតុថាខ្ញុំព្រះអង្គបានសំគាល់នូវព្រះគោតមដ៏ចម្រើន ថាជាបុគ្គលគួរសង្កត់សង្កិន នូវវាទៈដោយវាទៈបាន បពិត្រព្រះគោតមដ៏ចម្រើន សេចក្ដីចម្រើនគួរមានដល់បុរស ព្រោះបានសង្កត់សង្កិននូវដំរីចុះប្រេង សេចក្ដីចម្រើនមិនគួរមានដល់បុរស ព្រោះសង្កត់សង្កិននូវព្រះគោតមដ៏ចម្រើនទេ បពិត្រព្រះគោតមដ៏ចម្រើន សេចក្ដីចម្រើនគួរមានដល់បុរស ព្រោះបានសង្កត់សង្កិន ឬលត់នូវគំនរភ្លើងដែលកំពុងឆេះ

ន ត្វេវ ភវន្តំ គោតមំ អាសជ្ជ សិយា បុរិសស្ស សោត្ថិភាវោ សិយា ហិ ភោ គោតម អាសីវិសំ ឃោរវិសំ អាសជ្ជ បុរិសស្ស សោត្ថិភាវោ ន ត្វេវ ភវន្តំ គោតមំ អាសជ្ជ សិយា បុរិសស្ស សោត្ថិភាវោ មយមេវ ភោ គោតម ធំសី មយំ បគព្ភា យេ មយំ ភវន្តំ គោតមំ វាទេន វាទំ អាសាទេតព្វំ អមញ្ញិម្ហ អធិវាសេតុ[១] មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សច្ចកោ និគណ្ឋបុត្តោ ភគវតោ អធិវាសនំ វិទិត្វា តេ លិច្ឆវី អាមន្តេសិ សុណន្តុ មេ ភោន្តោ លិច្ឆវី សមណោ គោតមោ និមន្តិតោ ស្វាតនាយ[២] សទ្ធឹ ភិក្ខុសង្ឃេន យេន មេ អភិហរេយ្យាថ យមស្ស បដិរូបំ មញ្ញេយ្យាថាតិ ។

---

១ ឱ. ម. ឯត្ថន្តរេ ចសទ្ទោ ទិស្សតិ ។ ២ ឱ. ស្វាតនាយ ភត្តំ ។

សេចក្តីចម្រើនមិនគួរមានដល់បុរស ព្រោះបានសង្កត់សង្កិននូវព្រះគោតមដ៏ចម្រើនទេ បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីចម្រើន គួរមានដល់បុរស ព្រោះបានសង្កត់សង្កិននូវអាសិរពិស ដែលមានពិសដ៏ពន្លឹក សេចក្តីចម្រើនមិនគួរមានដល់បុរស ព្រោះបានសង្កត់សង្កិននូវព្រះគោតមដ៏ចម្រើនទេ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកកម្ចាត់បង់នូវគុណ ខ្ញុំព្រះអង្គជាអ្នកឃ្នើសឃ្នងដោយវាចា ព្រោះហេតុថាខ្ញុំព្រះអង្គបានសំគាល់នូវព្រះគោតមដ៏ចម្រើន ថាជាបុគ្គលគួរសង្កត់សង្កិននូវវាទៈ ដោយវាទៈបាន សូមព្រះគោតមដ៏ចម្រើនទទួលភត្តរបស់ខ្ញុំ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ជាមួយនឹងភិក្ខុសង្ឃ ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ លំដាប់នោះ សច្ចកនិគន្ថបុត្រ បានដឹងច្បាស់នូវកិរិយាទទួលនិមន្ត របស់ព្រះមានព្រះភាគហើយ ក៏និយាយនឹងព្រះបាទលិច្ឆវីទាំងនោះថា ព្រះបាទលិច្ឆវីទាំងឡាយដ៏ចម្រើន ចូរស្តាប់ពាក្យរបស់អាត្មា ព្រះសមណគោតមអាត្មានិមន្តហើយ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ជាមួយនឹងភិក្ខុសង្ឃ បពិត្រទាំងឡាយ គួរយកវត្ថុណាមកឲ្យអាត្មា មួយទៀត វត្ថុណាដែលជារបស់សមគួរ ដល់ព្រះសមណគោតមនោះ បពិត្រទាំងឡាយ គួរដឹងវត្ថុនោះ ៗ ។

អថខោ តេ លិច្ឆវី តស្សា រត្តិយា អច្ចយេន សច្ចកស្ស និគណ្ឋបុត្តស្ស បញ្ចមត្តានិ ថាលិបាកសតានិ ភត្តាភិហារំ អភិហរឹសុ ។ អថខោ សច្ចកោ និគណ្ឋបុត្តោ សកេ អារាមេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។

[៤៤] អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន សច្ចកស្ស និគណ្ឋបុត្តស្ស អារាមោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ សច្ចកោ និគណ្ឋបុត្តោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ សច្ចកោ និគណ្ឋបុត្តោ ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ អញ្ញតរំ នីចាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សច្ចកោ និគណ្ឋបុត្តោ ភគវន្តំ ឯតទវោច យមិទំ ភោ គោតម ទានេ បុញ្ញញ្ច បុញ្ញម្ហិ ច តំ ទាយកានំ សុខាយេវ ហោតូតិ ។

លុះកន្លងរាត្រីនោះទៅហើយ ទើបព្រះបាទលិច្ឆវីទាំងនោះ ក៏នាំនូវភត្តាភិហារប្រមាណ ៥០០ សម្រាប់ដល់សច្ចកនិគន្ថបុត្រ ។ លំដាប់នោះ សច្ចកនិគន្ថបុត្របានតាក់តែងនូវខាទនីយៈនិងភោជនីយៈដ៏ឧត្តម ក្នុងអារាមរបស់ខ្លួនហើយ ចាត់បម្រើឲ្យទៅក្រាបទូលភត្តកាល ដល់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន កាលគួរហើយ ភត្តក៏សម្រេចហើយ ។

[៤៤] លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់ដោយបាត្រចីវរក្នុងបុព្វណ្ហសម័យ ហើយស្ដេចចូលទៅកាន់អារាមរបស់សច្ចកនិគន្ថបុត្រ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយជាមួយនឹងភិក្ខុសង្ឃ ។ គ្រានោះឯង សច្ចកនិគន្ថបុត្រក៏អង្គាសព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយៈ និងភោជនីយាហារដ៏ឧត្តម ដោយដៃរបស់ខ្លួន ត្រាតែភិក្ខុសង្ឃហាមឃាត់ ។ គ្រានោះ សច្ចកនិគន្ថបុត្រកំណត់ដឹងថា ព្រះមានព្រះភាគទ្រង់ឆាន់រួចហើយ ដាក់ព្រះហស្តចុះចាកបាត្រហើយ ក៏កាន់យកនូវអាសនៈ ទាបមួយ អង្គុយក្នុងទីដ៏សមគួរ ។ លុះសច្ចកនិគន្ថបុត្រអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន បុណ្យណាដែលមានក្នុងទាននេះផង បុណ្យដទៃអំពីទាននេះផង ក៏បុណ្យនោះឯង ចូរប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់ទាយកទាំងឡាយ ។

## ៨៧

មហាយមកវគ្គស្ស ចូឡសច្ចកសុត្តេ សុត្តបរិយោសានំ

យំ ខោ អគ្គិវេស្សន តាទិសំ ជត្វិណោយ្យំ អាគម្ម អវីតរាគំ អវីតទោសំ អវីតមោហំ តំ ជាយកាដំ ភវិស្សតិ យំ ខោ អគ្គិវេស្សន មាទិសំ ជត្វិណោយ្យំ អាគម្ម វីតរាគំ វីតទោសំ វីតមោហំ តំ តុយ្ហំ ភវិស្សតីតិ ។

ចូឡសច្ចកសុត្តំ បញ្ចមំ និដ្ឋិតំ ។

មហាយមកវគ្គ ចូឡសច្ចកសូត្រ ទីបំផុតនៃសូត្រ

ព្រះសម្ពុទ្ធបរមគ្រូ ទ្រង់មានព្រះពុទ្ធដីកាថា ម្នាលអគ្គិវេស្សនៈ បុណ្យណាមួយ ដែលអាស្រ័យនូវទក្ខិណេយ្យបុគ្គលប្រាកដដូចអ្នក ដែលជាបុគ្គលមិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ បុណ្យនោះនឹងកើតមានដល់ទាយកទាំងឡាយ នៃអគ្គិវេស្សនៈ មួយទៀត បុណ្យណា ដែលអាស្រ័យនូវទក្ខិណេយ្យ-បុគ្គលប្រាកដដូចជាតថាគត ជាបុគ្គលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈហើយ បុណ្យនោះនឹងកើតមានដល់អ្នក ។

ចប់ ចូឡសច្ចកសូត្រ ទី ៥ ។

# ឆដ្ឋំ មហាសច្ចកសុត្តំ

[៤៥] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន ភគវា បុព្វណ្ហសមយំ សុនិវត្ថោ ហោតិ បត្តចីវរមាទាយ វេសាលិយំ បិណ្ឌាយ បវិសិតុកាមោ ។ អថខោ សច្ចកោ និគណ្ឋបុត្តោ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ យេន មហាវនំ កូដាគារសាលា តេនុបសង្កមិ ។ អទ្ទសា ខោ អាយស្មា អានន្ទោ សច្ចកំ និគណ្ឋបុត្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន ភគវន្តំ ឯតទវោច អយំ ភន្តេ សច្ចកោ និគណ្ឋបុត្តោ អាគច្ឆតិ ភស្សប្បវាទិកោ បណ្ឌិតវាទោ សាធុសម្មតោ ពហុជនស្ស ឯសោ ខោ ភន្តេ អវណ្ណកាមោ ពុទ្ធស្ស អវណ្ណកាមោ ធម្មស្ស អវណ្ណកាមោ សង្ឃស្ស សាធុ ភន្តេ ភគវា មុហុត្តំ និសីទតុ អនុកម្បំ ឧបាទាយាតិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ ។ អថខោ សច្ចកោ និគណ្ឋបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា

# មហាសច្ចកសូត្រ ទី ៦

[៤៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ទៀបក្រុងវេសាលី ។ សម័យនោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ដោយល្អ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចពុទ្ធដំណើរចូលទៅក្នុងក្រុងវេសាលី ដើម្បីបិណ្ឌបាត ។ គ្រានោះ សច្ចកនិគន្ថបុត្រ កំពុងចង្រ្កម កំពុងត្រាច់ទៅដោយលំដាប់ ៗ ដើម្បីសម្រាកស្មង ហើយចូលទៅកាន់កូដាគារសាលា នាមហាវ័ននោះ ។ ព្រះអានន្ទ មានអាយុ បានឃើញសច្ចកនិគន្ថ-បុត្រ កំពុងតែដើរមកអំពីចម្ងាយ លុះបានឃើញហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សច្ចកនិគន្ថបុត្រនេះ ជាអ្នកពោលតិរច្ឆានកថា ជាអ្នកពោលថាខ្លួនជាអ្នកប្រាជ្ញ ជនច្រើននាក់សន្មតគាត់ថាជាអ្នកត្រឹមត្រូវ ឥឡូវនេះកំពុងដើរមក បពិត្រព្រះអង្គដ៏ចម្រើន សច្ចកនិគន្ថបុត្រនេះ ជាអ្នកប្រាថ្នារកទោសព្រះពុទ្ធ ប្រាថ្នារកទោសព្រះធម៌ ប្រាថ្នារកទោសព្រះសង្ឃ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់គង់មួយរំពេច អាស្រ័យសេចក្តីអនុគ្រោះ ។ ព្រះមានព្រះភាគទ្រង់គង់លើអាសនៈ ដែលគេតាក់តែងហើយ ។ គ្រានោះ សច្ចកនិគន្ថបុត្រ ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ

ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារា-
ណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

[៤៦] ឯកមន្តំ និសិន្នោ ខោ សច្ចកោ និ-
គណ្ឋបុត្តោ ភគវន្តំ ឯតទវោច សន្តិ ភោ គោតម
ឯកេ សមណព្រាហ្មណា កាយភាវនានុយោគមនុ-
យុត្តា វិហរន្តិ នោ ចិត្តភាវនំ ។ ផុសន្តិ ហិ[១] ភោ
គោតម សារីរិកំ ទុក្ខំ វេទនំ[២] ។ ភូតបុព្វំ ភោ
គោតម សារីរិកាយ ទុក្ខាយ វេទនាយ ផុដ្ឋស្ស
សតោ ឩរុក្ខម្ភោបិ នាម ភវិស្សតិ ហទយម្បិ
នាម ផលិស្សតិ ឧណ្ហម្បិ លោហិតំ មុខតោ ឧគ្គ-
មិស្សតិ ឧម្មាទម្បិ បាបុណិស្សន្តិ[៣] ចិត្តក្ខេបំ ។
តស្ស ខោ ឯតំ ភោ គោតម កាយន្វយំ ចិត្តំ
ហោតិ កាយស្ស វសេន វត្តតិ តំ កិស្ស ហេតុ
អភាវិតត្តា ចិត្តស្ស ។ សន្តិ បន ភោ គោតម
ឯកេ សមណព្រាហ្មណា ចិត្តភាវនានុយោគមនុយុត្តា

១ ម. ហិ តេ ។ ២ ឱ. ម. ទុក្ខំ វេទនំ ។ ៣ ឱ. ម. បាបុណិស្សតិ ។

ក៏ធ្វើសេចក្ដីរីករាយ មួយអន្លើដោយព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។

[៤៦] លុះសច្ចកនិគន្ថបុត្រ អង្គុយនៅក្នុងទីសមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន មានសមណព្រាហ្មណ៍ពួកមួយ ខ្វល់ខ្វាយក្នុងការប្រកបរឿយ ៗ នូវការភាវនា[១] (វិបស្សនា) មិនបានខ្វល់ខ្វាយក្នុងការប្រកបរឿយ ៗ នូវចិត្តភាវនា[២] (សមថៈ) ឡើយ ។ បពិត្រព្រះគោតមដ៏ចម្រើន សមណព្រាហ្មណ៍ទាំងនោះតែងបាននូវទុក្ខវេទនា ដែលកើតឡើងក្នុងសរីរៈ ។ បពិត្រព្រះគោតមដ៏ចម្រើន រឿងរ៉ាវធ្លាប់មានមកថា បុគ្គលដែលមានទុក្ខវេទនាកើតឡើងក្នុងសរីរៈពាល់ត្រូវហើយ នឹងត្រឡប់ទៅជាមនុស្សរឹងភ្លៅក៏មាន បេះដូងនឹងបែកធ្លាយក៏មាន ឈាមក្ដៅនឹងក្អួតចេញអំពីមាត់ក៏មាន សមណព្រាហ្មណ៍ទាំងនោះ នឹងដល់នូវកិរិយាឆ្កួតរាយមាយចិត្តក៏មាន ។ បពិត្រព្រះគោតមដ៏ចម្រើន ចិត្តនុ៎ះ របស់បុគ្គលនោះឯង រមែងប្រព្រឹត្តទៅតាមកាយ តែងប្រព្រឹត្តទៅដោយអំណាចនៃកាយ សេចក្ដីនោះព្រោះហេតុដូចម្ដេច ព្រោះថាបុគ្គលនោះមិនបានអប់រំចិត្ត ។ បពិត្រព្រះគោតមដ៏ចម្រើន មួយទៀត មានសមណព្រាហ្មណ៍ពួកមួយ បានខ្វល់ខ្វាយក្នុងការប្រកប

១ ការអប់រំកាយ ។ ២ ការអប់រំចិត្ត ។

វិហរន្តិ នោ កាយភាវនំ ។ ផុសន្តិ ហិ ភោ គោតម ចេតសិកំ ទុក្ខំ វេទនំ ។ ភូតបុព្វំ ភោ គោតម ចេតសិកាយ ទុក្ខាយ វេទនាយ ផុដ្ឋស្ស សតោ ឩរុក្ខម្ភោបិ នាម ភវិស្សតិ ហទយម្បិ នាម ផលិស្សតិ ឧណ្ហម្បិ លោហិតំ មុខតោ ឧគ្គមិស្សតិ ឧម្មាទម្បិ បាបុណិស្សន្តិ ចិត្តក្ខេបំ ។ តស្ស ខោ ឯសោ ភោ គោតម ចិត្តន្វយោ កាយោ ហោតិ ចិត្តស្ស វសេន វត្តតិ តំ កិស្ស ហេតុ អភាវិតត្តា កាយស្ស ។ តស្ស មយ្ហំ ភោ គោតម ឯវំ ហោតិ អទ្ធា ភោតោ គោតមស្ស សាវកា ចិត្តភាវនានុយោគមនុយុត្តា វិហរន្តិ នោ កាយភាវនន្តិ ។

[៤៧] កិន្តិ បន តេ អគ្គិវេស្សន កាយភាវនា សុតាតិ ។ សេយ្យថីទំ នន្ទោ វច្ឆោ កិសោ សង្កិច្ចោ មក្ខលិ គោសាលោ ឯតេ ហិ ភោ គោតម អចេលកា មុត្តាចារា ហត្ថាវលេខនា ន ឯហិភទន្តិកា

រឿយ ៗ នូវចិត្តភាវនា មិនបានខ្វល់ខ្វាយក្នុងការប្រកបរឿយ ៗ នូវកាយ-ភាវនាឡើយ ។ បពិត្រព្រះគោតមដ៏ចម្រើន ក៏សមណព្រាហ្មណ៍ទាំងនោះ តែងបាននូវទុក្ខវេទនា ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ បពិត្រព្រះគោតមដ៏ចម្រើន រឿងរ៉ាវធ្លាប់មានមកថា បុគ្គលដែលមានទុក្ខវេទនាប្រព្រឹត្តទៅក្នុងចិត្តពាល់ត្រូវហើយ នឹងត្រឡប់ទៅជាមនុស្សរឹងក្ដៅក៏មាន បេះដូងនឹងបែកធ្លាយក៏មាន ឈាមក្ដៅនឹងក្អួតចេញអំពីមាត់ក៏មាន សមណព្រាហ្មណ៍ទាំងនោះ នឹងដល់នូវកិរិយាឆ្កួតវាយមាយចិត្តក៏មាន ។ បពិត្រព្រះគោតមដ៏ចម្រើន កាយនុ៎ះ របស់បុគ្គលនោះឯង រមែងប្រព្រឹត្តទៅតាមចិត្ត តែងប្រព្រឹត្តទៅដោយអំណាចនៃចិត្ត សេចក្ដីនោះព្រោះហេតុដូចម្ដេច ព្រោះថាបុគ្គលនោះមិនបានអប់រំកាយ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គគិតយ៉ាងនេះថា សាវ័កទាំងឡាយ របស់ព្រះគោតមដ៏ចម្រើន តែងខ្វល់ខ្វាយក្នុងការប្រកបរឿយ ៗ នូវចិត្តភាវនា តែមិនបានខ្វល់ខ្វាយក្នុងការប្រកបរឿយ ៗ នូវកាយភាវនាឡើយ ។

[៤៧] ម្នាលអគ្គិវេស្សនៈ ចុះកាយភាវនា អ្នកបានឮមកដូចម្ដេច ។ សច្ចកនិគន្ថបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន អចេលក៍ទាំងនេះ គឺ នន្ទវច្ឆៈ ១ កិសសង្កិច្ចៈ ១ មក្ខលិគោសាល ១ ជាអ្នកប្រព្រឹត្តលះបង់មារយាទល្អ ស៊ីលិទ្ធដៃ គេហៅថា អ្នកដ៏ចម្រើនចូរមក

៩១



ន តិដ្ឋភជន្តិកា ន អភិហដំ ន ឧទ្ទិស្ស កតំ ន និមន្តនំ សាទិយន្តិ តេ ន កុម្ភិមុខា បដិគ្គណ្ហន្តិ ន កលោបិមុខា បដិគ្គណ្ហន្តិ ន ឯឡកមន្តរំ ន ទណ្ឌមន្តរំ ន មុសលមន្តរំ ន ទ្វិន្នំ ភុញ្ជមានានំ ន គព្ភិនិយា ន បាយមានាយ ន បុរិសន្តរគតាយ ន សង្កិត្តីសុ ន យត្ថ សា ឧបដ្ឋិតោ ហោតិ ន យត្ថ មក្ខិកា សណ្ឌ-សណ្ឌចារិនី ន មច្ឆំ ន មំសំ ន សុរំ ន មេរយំ ន ថុសោទកំ បិវន្តិ តេ ឯកាគារិកា វា ហោន្តិ ឯកាលោបិកា ទ្វាគារិកា វា ហោន្តិ ទ្វាលោបិកា ។ បេ ។ សត្តាគារិកា វា ហោន្តិ សត្តាលោបិកា

ក៏មិនព្រមមក គេឃាត់ថា អ្នកដ៏ចម្រើនឈប់សិន ក៏មិនព្រមឈប់ មិនត្រេកអរនឹងចង្ហាន់ដែលគេនាំមកមុន មិនត្រេកអរនឹងចង្ហាន់ដែលគេនាំមកចំពោះខ្លួន មិនត្រេកអរនឹងកិច្ចនិមន្ត អចេលក៍ទាំងនុ៎ះមិនទទួលចង្ហាន់ដែលគេនាំចេញអំពីមាត់ឆ្នាំងហើយឲ្យ មិនទទួលចង្ហាន់ដែលគេនាំចេញអំពីមាត់កញ្ជើហើយឲ្យ មិនទទួលចង្ហាន់ដែលគេដើរកន្លងធរណីហើយនាំមកឲ្យ មិនទទួលចង្ហាន់ដែលគេដើរកន្លងកំណាត់ឈើ ហើយនាំមកឲ្យ មិនទទួលចង្ហាន់ដែលគេដើរកន្លងអង្រែហើយនាំមកឲ្យ មិនទទួលចង្ហាន់អំពីដៃមនុស្សពីរនាក់កំពុងបរិភោគ មិនទទួលចង្ហាន់អំពីដៃស្រីមានគភ៌ មិនទទួលចង្ហាន់អំពីដៃស្រីដែលកំពុងបំបៅកូន មិនទទួលចង្ហាន់អំពីដៃស្រីដែលកំពុងកាន់បុរសដទៃ មិនទទួលចង្ហាន់ ក្នុងកន្លែងដែលរៃវត្ថុបានមក[១] មិនទទួលចង្ហាន់ក្នុងកន្លែងដែលមានឆ្កែនៅចាំ មិនទទួលចង្ហាន់ត្រង់កន្លែងដែលមានរុយរោមទាំងហ្វូង មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកថ្នាំត្រាំ មួយទៀត អចេលក៍ទាំងនោះទទួលចង្ហាន់ចំពោះតែក្នុងផ្ទះមួយ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបាយតែមួយដុំខ្លះ ទទួលចង្ហាន់ចំពោះតែក្នុងផ្ទះពីរ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបាយតែពីរដុំខ្លះ ។ បេ ។ ទទួលចង្ហាន់ចំពោះតែក្នុងផ្ទះ ៧

១ ពួកសាវ័ករបស់អចេលក៍តែងនាំគ្នារៃយកវត្ថុមានអង្ករជាដើម អំពីទីនោះ ៗ មកចម្អិនបាយដើម្បីប្រគេនដល់ពួកអចេលក៍ក្នុងសម័យមានបាយក្រ អចេលក៍ដែលប្រព្រឹត្តវត្តឧក្រិដ្ឋមិនទទួលយកចង្ហាន់នោះឡើយ ។ អដ្ឋកថា ។

ឯកិស្សាបិ ទត្តិយា យាបេន្តិ ទ្វីហិបិ ទត្តីហិ យាបេន្តិ ។ បេ ។ សត្តហិបិ ទត្តីហិ យាបេន្តិ ឯកាហិកម្បិ អាហារំ អាហារេន្តិ ទ្វីហិកម្បិ អាហារំ អាហារេន្តិ ។ បេ ។ សត្តាហិកម្បិ អាហារំ អាហារេន្តិ ឥតិ ឯវរូបំ អឌ្ឍមាសិកម្បិ បរិយាយភត្តភោជនានុយោគមនុយុត្តា វិហរន្តីតិ ។ កឹ បន តេ អគ្គិវេស្សន តាវតកេនេវ យាបេន្តីតិ ។ នោ ហិទំ ភោ គោតម អប្បេកទា ភោ គោតម ឧឡារានិ ឧឡារានិ ខាទនីយានិ ខាទន្តិ ឧឡារានិ ឧឡារានិ ភោជនានិ ភុញ្ជន្តិ ឧឡារានិ ឧឡារានិ សាយនីយានិ សាយន្តិ ឧឡារានិ ឧឡារានិ បានានិ បិវន្តិ តេ ឥមំ កាយំ ពលំ គាហេន្តិ នាម ព្រូហេន្តិ នាម មេទេន្តិ នាមាតិ ។ យំ ខោ តេ អគ្គិវេស្សន បុរិមំ បហាយ បច្ឆា ឧបចិនន្តិ ឯវំ ឥមស្ស កាយស្ស អាចយាបចយោ ហោតិ ។

ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបាយ ៧ ដុំខ្លះ ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចង្ហាន់ ក្នុងភាជន៍តូចមួយខ្លះ ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចង្ហាន់ ក្នុងភាជន៍តូចពីរខ្លះ ។ បេ ។ ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចង្ហាន់ ក្នុងភាជន៍តូច ៧ ខ្លះ ស៊ីអាហារខានមួយថ្ងៃខ្លះ ស៊ីអាហារខានពីរថ្ងៃខ្លះ ។ បេ ។ ស៊ីអាហារខាន ៧ ថ្ងៃខ្លះ តែងខ្វល់ខ្វាយក្នុងការប្រកបរឿយ ៗ នូវការបរិភោគបាយផ្លាស់ប្តូរថ្ងៃអស់កន្លះខែមានសភាពយ៉ាងនេះដូច្នេះខ្លះ ។ នែអគ្គិវេស្សនៈ អចេលក៍ ទាំងនោះតែងញុំាំងអត្តភាពឲ្យប្រព្រឹត្ត ដោយហេតុមានប្រមាណតែប៉ុណ្ណោះឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនមែនមានតែប៉ុណ្ណោះទេ បពិត្រព្រះគោតមដ៏ចម្រើន អចេលក៍ទាំងនោះ ចួនកាលទំពាស៊ីនូវខាទនីយៈទាំងឡាយដ៏ឧត្តមក្រៃលែង បរិភោគនូវភោជនទាំងឡាយ ដ៏ឧត្តមក្រៃលែងត្រេបជញ្ជាបនូវសាយនីយៈទាំងឡាយ ដ៏ឧត្តមក្រៃលែង ផឹកនូវទឹកទាំងឡាយដ៏ឧត្តមក្រៃលែង អចេលក៍ ទាំងនោះ ឈ្មោះថា ញុំាំងកាយនេះឲ្យកាន់យកនូវកម្លាំង ឲ្យចម្រើន ឲ្យធាត់ធំ ។ ម្នាលអគ្គិវេស្សនៈ ត្រង់ដែលអចេលក៍ ទាំងនោះ លះបង់នូវអំពើកម្រក្នុងកាលមុន ហើយសន្សំនូវវត្ថុ មានខាទនីយៈជាដើម ក្នុងកាលជាខាងក្រោយ កាលបើធ្វើយ៉ាងនេះ ការចម្រើននិងការមិនចម្រើនរបស់កាយនេះ តែងតែមាន ។

[៤៨] កិន្តិ បន តេ អគ្គិវេស្សន ចិត្តភាវនា សុតាតិ ។ ចិត្តភាវនាយ សច្ចកោ និគណ្ឋបុត្តោ ភគវតា បុដ្ឋោ សមានោ ន សម្បាយាសិ ។ អថ ខោ ភគវា សច្ចកំ និគណ្ឋបុត្តំ ឯតទវោច យាបិ ខោ តេ ឯសា អគ្គិវេស្សន បុរិមា កាយភាវនា ភាសិតា សាបិ អរិយស្ស វិនយេ នោ ធម្មិកា កាយភាវនា កាយភាវនម្បិ[១] ខោ ត្វំ អគ្គិវេស្សន ន អញ្ញាសិ កុតោ បន ត្វំ ចិត្តភាវនំ ជានិស្សសិ អបិច អគ្គិវេស្សន យថា អភាវិតកាយោ ច ហោតិ អភាវិតចិត្តោ ច ភាវិតកាយោ ច ហោតិ[២] ភាវិតចិត្តោ ច តំ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ សច្ចកោ និគណ្ឋបុត្តោ ភគវតោ បច្ចស្សោសិ ។

---

១ ឱ. ម. កាយភាវនំ ហិ ។ ២ ឱ. ហោតីតិ ន ទិស្សតិ ។

មហាយមកវគ្គ មហាសច្ចកសូត្រ ពោលអំពីចិត្តភាវនា

[៤៨] ម្នាលអគ្គិវេស្សនៈ ចុះចំណែកខាងចិត្តភាវនា អ្នកបានឮមកដូចម្ដេច ។ សច្ចកនិគន្ថបុត្រ កាលព្រះមានព្រះភាគទ្រង់សួរហើយក្នុងចិត្តភាវនា ក៏មិនអាចនឹងដោះស្រាយបាន ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះនឹងសច្ចកនិគន្ថបុត្រថា នែអគ្គិវេស្សនៈ កាយ-ភាវនាណា ដែលអ្នកបានអប់រំហើយ ក្នុងកាលមុន កាយភាវនានោះមិនប្រកបដោយធម៌ ក្នុងអរិយវិន័យទេ ម្នាលអគ្គិវេស្សនៈ អ្នកមិនអាចដឹងសូម្បីនូវកាយភាវនា តើនឹងអាចដឹងនូវចិត្តភាវនាដូចម្ដេចបាន ម្នាលអគ្គិវេស្សនៈ ក៏ឯបុគ្គលមិនបានអប់រំកាយផង មិនបានអប់រំចិត្តផង បុគ្គលបានអប់រំកាយផង បានអប់រំចិត្តផង ដោយប្រការណា អ្នកចូរស្ដាប់នូវប្រការនោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែងឥឡូវនេះ ។ សច្ចកនិគន្ថបុត្ត ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[៤៩] ភគវា ឯតទវោច កាចញ្ច អគ្គិវេស្សន អភាវិតកាយោ ច ហោតិ អភាវិតចិត្តោ ច ។ ឥធ អគ្គិវេស្សន អស្សុតវតោ បុថុជ្ជនស្ស ឧប្បជ្ជតិ សុខា វេទនា សោ សុខាយ វេទនាយ ផុដ្ឋោ សមានោ សុខសារាគី ច ហោតិ សុខសារាគិតំ ច អាបជ្ជតិ តស្ស សា សុខា វេទនា និរុជ្ឈតិ សុខាយ វេទនាយ និរោធា ឧប្បជ្ជតិ ទុក្ខា វេទនា សោ ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ តស្ស ខោ ឯសា អគ្គិវេស្សន ឧប្បន្នាបិ សុខា វេទនា ចិត្តំ បរិយាទាយ តិដ្ឋតិ អភាវិតត្តា កាយស្ស ឧប្បន្នាបិ ទុក្ខា វេទនា ចិត្តំ បរិយាទាយ តិដ្ឋតិ អភាវិតត្តា ចិត្តស្ស យស្ស កស្សចិ អគ្គិវេស្សន ឯវំ ឧភតោបក្ខំ ឧប្បន្នាបិ សុខា វេទនា ចិត្តំ បរិយាទាយ តិដ្ឋតិ អភាវិតត្តា កាយស្ស ឧប្បន្នាបិ ទុក្ខា វេទនា

[៤៩] ព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកាថា នែអគ្គិវេស្សនៈ បុគ្គលដែលមិនបានអប់រំកាយផង មិនបានអប់រំចិត្តផង តើដូចម្តេច ។ នែអគ្គិវេស្សនៈ សុខវេទនា តែងកើតឡើង ដល់បុគ្គលជាបុថុជ្ជន ដែលមិនចេះដឹង ក្នុងលោកនេះ បុគ្គលជាបុថុជ្ជននោះ លុះសុខវេទនា ពាល់ត្រូវហើយ ក៏មានតម្រេកខ្វាំងក្នុងសេចក្តីសុខផង តែងដល់នូវ តម្រេកខ្វាំងដោយសេចក្តីសុខផង បើសុខវេទនានោះ របស់បុគ្គល ជាបុថុជ្ជននោះ រលត់ទៅ ទុក្ខវេទនា ក៏កើតឡើង ព្រោះរលត់ទៅ នៃសុខវេទនា បុគ្គលជាបុថុជ្ជននោះ លុះទុក្ខវេទនាពាល់ត្រូវហើយ តែងសោកសៅ លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់ នូវសេចក្តីវង្វេង នែអគ្គិវេស្សនៈ សុខវេទនានេះរបស់បុគ្គលជាបុថុជ្ជន នោះ ដែលកើតឡើងហើយ តែងគ្របសង្កត់ចិត្ត ព្រោះមិនបានអប់រំ កាយផង ទុក្ខវេទនាដែលកើតឡើងហើយ តែងគ្របសង្កត់ចិត្ត ព្រោះ មិនបានអប់រំចិត្តផង នែអគ្គិវេស្សនៈ សុខវេទនា របស់បុគ្គលណា នីមួយដែលកើតឡើងហើយ ដោយចំណែកទាំងពីរយ៉ាងនេះ តែងគ្រប សង្កត់ចិត្ត ព្រោះមិនបានអប់រំកាយផង ទុក្ខវេទនាដែលកើតឡើងហើយ

មហាយមកវគ្គស្ស មហាសច្ចកសុត្តេ កាយចិត្តស្ស ភាវិតត្តំ

ចិត្តំ បរិយាទាយ តិដ្ឋតិ អភាវិតត្តា ចិត្តស្ស ឯវំ ខោ អគ្គិវេស្សន អភាវិតកាយោ ច ហោតិ អភាវិតចិត្តោ ច ។ កថញ្ច អគ្គិវេស្សន ភាវិតកាយោ ច ហោតិ ភាវិតចិត្តោ ច ។ ឥធ អគ្គិវេស្សន សុតវតោ អរិយសាវកស្ស ឧប្បជ្ជតិ សុខា វេទនា សោ សុខាយ វេទនាយ ផុដ្ឋោ សមានោ ន[១] សុខសារាគី[២] ហោតិ ន សុខសារាគិតំ[៣] អាបជ្ជតិ តស្ស សា សុខា វេទនា និរុជ្ឈតិ សុខាយ វេទនាយ និរោធា ឧប្បជ្ជតិ ទុក្ខា វេទនា សោ ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ តស្ស ខោ ឯវំ សា[៤] អគ្គិវេស្សន ឧប្បន្នាបិ សុខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ភាវិតត្តា កាយស្ស ឧប្បន្នាបិ ទុក្ខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ភាវិតត្តា ចិត្តស្ស

១ ឱ. នោ ។ ២ ម. សុខសារាគី ច ។ ៣ ម. សុខសារាគិតញ្ច ។ ៤ ឱ. ម. ខោ ឯសា ។

តែងគ្របសង្កត់ចិត្ត ព្រោះមិនបានអប់រំចិត្តផង នែអគ្គិវេស្សនៈ បុគ្គលមិនបានអប់រំកាយផង មិនបានអប់រំចិត្តផង យ៉ាងនេះឯង ។ នែអគ្គិ-វេស្សនៈ បុគ្គលដែលបានអប់រំកាយផង បានអប់រំចិត្តផង តើដូចម្តេច ។ នែអគ្គិវេស្សនៈ សុខវេទនាតែងកើតឡើង ដល់បុគ្គលជាអរិយសាវ័ក ជាអ្នកចេះដឹងក្នុងលោកនេះ បុគ្គលជាអរិយសាវ័កនោះ លុះសុខវេទនាពាល់ត្រូវហើយ ក៏មិនមានតម្រេកខ្លាំងក្នុងសេចក្តីសុខ មិនដល់នូវតម្រេកខ្លាំង ដោយសេចក្តីសុខឡើយ សុខវេទនានោះ របស់អរិយសាវ័កនោះរលត់ទៅ ទុក្ខវេទនាក៏កើតឡើង ព្រោះរលត់ទៅនៃសុខវេទនា អរិយសាវ័កនោះ លុះទុក្ខវេទនាពាល់ត្រូវហើយ ក៏មិនសោកសៅ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងឡើយ នែអគ្គិវេស្សនៈ សុខវេទនានោះរបស់អរិយសាវ័កនោះ ដែលកើតឡើងហើយ មិនគ្របសង្កត់ចិត្ត ព្រោះបានអប់រំកាយផង ទុក្ខវេ-ទនាដែលកើតឡើងហើយ មិនគ្របសង្កត់ចិត្ត ព្រោះបានអប់រំចិត្តផង

យស្ស កស្សចិ អគ្គិវេស្សន[១] ឧភតោបក្ខំ ឧប្បន្នាបិ សុខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ភាវិតត្តា កាយស្ស ឧប្បន្នាបិ ទុក្ខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ភាវិតត្តា ចិត្តស្ស ឯវំ ខោ អគ្គិវេស្សន ភាវិតកាយោ ច ហោតិ ភាវិតចិត្តោ ចាតិ ។ ឯវំ បសន្នោ អហំ ភោតោ គោតមស្ស កថំ ហិ គោតមោ ភាវិតកាយោ ច ហោតិ[២] ភាវិតចិត្តោ ចាតិ ។

[៤០] អទ្ធា ខោ តេ អយំ អគ្គិវេស្សន អាសជ្ជ ឧបនីយវាចា ភាសិតា អបិច តេ អហំ ព្យាករិស្សាមិ យតោ ខោ អហំ អគ្គិវេស្សន កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតោ តំ វត មេ ឧប្បន្នា វា សុខា វេទនា ចិត្តំ បរិយាទាយ ឋស្សតិ ឧប្បន្នា វា ទុក្ខា វេទនា

១ ឱ. អគ្គិវេស្សន ឯវំ ។ ២ ឱ. ហោតីតិ ន ទិស្សតិ ។

យ៉ាងនេះឯង នែអគ្គិវេស្សនៈ សុខវេទនារបស់បុគ្គលណាមួយ ដែលកើតឡើងហើយ ដោយចំណែកទាំងពីរ មិនបានគ្របសង្កត់ចិត្ត ព្រោះបានអប់រំកាយផង ទុក្ខវេទនាដែលកើតឡើងហើយ ក៏មិនបានគ្របសង្កត់ចិត្ត ព្រោះបានអប់រំចិត្តផង នែអគ្គិវេស្សនៈ បុគ្គលដែលបានអប់រំកាយផង បានអប់រំចិត្តផង យ៉ាងនេះឯង ។ សច្ចកនិគន្ថបុត្រក្រាបទូលថា ខ្ញុំព្រះអង្គជ្រះថ្លាចំពោះព្រះគោតមដ៏ចម្រើនយ៉ាងនេះ ព្រោះថា ព្រះគោតមដ៏ចម្រើន បានអប់រំកាយផង បានអប់រំចិត្តផង ។

[៥០] នែអគ្គិវេស្សនៈ វាចាដែលអ្នកពោលហើយនេះ ជាវាចាតន្ទូវគុណ បង្អោនទៅរកគុណ ពិតណាស់ហើយ ប៉ុន្តែតថាគតនឹងដោះស្រាយប្រាប់អ្នក នែអគ្គិវេស្សនៈ កាលដែលតថាគតកោរសក់និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយ ចេញចាកផ្ទះ ហើយចូលមកកាន់ផ្នួស សុខវេទនាដែលកើតឡើងហើយ នឹងគ្របសង្កត់ចិត្ត របស់តថាគតនោះក្តី ទុក្ខវេទនាដែលកើតឡើងហើយ

ចិត្តំ បរិយាទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតីតិ ។ នហ[១] នូន ភោតោ គោតមស្ស ឧប្បជ្ជតិ តថារូបា សុខា វេទនា យថារូបា ឧប្បន្នា សុខា វេទនា ចិត្តំ បរិយាទាយ តិដ្ឋេយ្យ នហ នូន ភោតោ គោតមស្ស ឧប្បជ្ជតិ តថារូបា ទុក្ខា វេទនា យថារូបា ឧប្បន្នា ទុក្ខា វេទនា ចិត្តំ បរិយាទាយ តិដ្ឋេយ្យាតិ ។

[៨១] កិញ្ហិ នោ សិយា អគ្គិវេស្សន ឥធ មេ អគ្គិវេស្សន បុព្វេ វ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ សម្ពាធោ ឃរាវាសោ រជោបថោ អព្ភោកាសោ បព្វជ្ជា នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ ខោ អហំ អគ្គិវេស្សន អបរេន សមយេន ទហរោ វ សមានោ

១ ម. ន ហិ ។

នឹងគ្របសង្កត់ចិត្តក្តី ហេតុនេះមិនមានឡើយ ។ សច្ចកនិគន្ថបុត្រទូលសួរដូច្នេះថា សុខវេទនាមានសភាពយ៉ាងណា ដែលកើតឡើងហើយគប្បីគ្របសង្កត់ចិត្ត ក្រែងសុខវេទនាមានសភាពដូច្នោះ មិនធ្លាប់កើតឡើងដល់ព្រះគោតមដ៏ចម្រើនទេដឹង ទុក្ខវេទនាមានសភាពយ៉ាងណាដែលកើតឡើងហើយ គប្បីគ្របសង្កត់ចិត្ត ក្រែងទុក្ខវេទនាមានសភាពដូច្នោះមិនធ្លាប់កើតឡើង ដល់ព្រះគោតមដ៏ចម្រើនទេដឹង ។

[៥១] នៃអគ្គិវេស្សនៈ ហេតុនោះថ្វីក៏មិនមាន នៃអគ្គិវេស្សនៈ ក្នុងកាលមុនអំពីការត្រាស់ដឹង តថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ នៅក្នុងទីឯណោះ មានសេចក្ដីត្រិះរិះដូច្នេះថា ការនៅគ្រប់គ្រងផ្ទះ ជាគ្រឿងចង្អៀតចង្អល់ ជាផ្លូវប្រកបដោយធូលី ឯបព្វជ្ជា ជាទីឱកាសទំនេរ បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះមិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌ បរិសុទ្ធដោយចំណែកមួយ ដូចស័ង្ខដែលបុគ្គលខាត់ហើយទេ បើដូច្នោះមានតែអាត្មាអញកោរសក់និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្ដប់សំពត់កាសាយៈទាំងឡាយ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ នៃអគ្គិវេស្សនៈ សម័យជាខាងក្រោយ កាលដែលតថាគតនៅជាកំលោះ

សុសុកាឡកេសោ ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា អកាមកានំ មាតាបិតូនំ អស្សុ-មុខានំ រោទន្តានំ កេសមស្សុំ ឱហារេត្វា កាសា-យានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិំ ។ សោ បព្វជិតោ សមានោ កឹកុសលគវេសី អនុត្តរំ សន្តិវរបទំ បរិយេសមានោ យេន អាឡារោ កាលាមោ តេនុបសង្កមឹ ឧបសង្កមិត្វា អាឡារំ កា-លាមំ ឯតទវោចំ ឥច្ឆាមហំ អាវុសោ កាលាម ឥមស្មឹ ធម្មវិនយេ ព្រហ្មចរិយំ ចរិតុន្តិ ។ ឯវំ វុត្តេ អគ្គិវេស្សន អាឡារោ កាលាមោ មំ ឯត-ទវោច វិហរតាយស្មា តាទិសោ អយំ ធម្មោ យត្ថ វិញ្ញូ បុរិសោ នចិរស្សេវ សកំ អាចរិយកំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ សោ ខោ អហំ អគ្គិវេស្សន នចិរស្សេវ ខិប្បមេវ តំ ធម្មំ បរិយាបុណឹ ។ សោ ខោ អហំ អគ្គិ-វេស្សន តាវតកេនេវ ឱដ្ឋបហតមត្តេន លបិតលា-បនមត្តេន ញាណវាទញ្ច វទាមិ ថេរវាទញ្ច បជានាមិ

មានសក់ខ្មៅស្រិលប្រកបដោយវ័យដ៏ចម្រើន គឺបឋមវ័យ កាលដែលមាតានិងបិតាទាំងឡាយមិនត្រូវការឲ្យចេញទៅបួស មានព្រះភក្ត្រទទឹកដោយព្រះអស្សុទ្រទ្រង់ព្រះកន្សែង ក៏នៅតែកោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយ ចេញចាកផ្ទះ ចូលមកកាន់ផ្នួស ។ លុះតថាគតបួសរួចហើយ ក៏ស្វែងរកកឹកុសល ស្វែងរកសន្តិវរបទគឺព្រះនិព្វាន ជាគ្រឿងរម្ងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេសដ៏ប្រសើរ ហើយចូលទៅរកអាឡារតាបស កាលាមគោត្រ លុះចូលទៅដល់ហើយ បាននិយាយដូច្នេះនឹងអាឡារតាបស កាលាមគោត្រថា ម្នាលអាវុសោកាលាមៈ ខ្ញុំប្រាថ្នានឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងធម្មវិន័យនេះ ។ ម្នាលអគ្គិវេស្សនៈ កាលតថាគតបាននិយាយយ៉ាងនេះហើយ ទើបអាឡារកាលាមតាបសពោលដូច្នេះវិញនឹងតថាគតថា អ្នកមានអាយុចូរនៅចុះ នេះធម៌ដែលប្រាកដដូចជាអ្នកត្រូវការនោះ ជាធម៌ដែលវិញ្ញូបុរសធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង នូវលទ្ធិនៃអាចារ្យជារបស់ខ្លួន ហើយសម្រេចសម្រាន្តនៅ ដោយកាលមិនយូរប៉ុន្មាន ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះក៏រៀនធម៌នោះចាំមួយរំពេច មិនយឺតយូរឡើយ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះពោលនូវញាណវាទ[១]ផង ដឹងច្បាស់នូវថេរវាទ[២]ផង ដោយហេតុគ្រាន់តែបើកបបូរមាត់ ទាំងគ្រាន់តែចរចានូវពាក្យទៅមកប៉ុណ្ណោះឯង

---

១ គឺពាក្យថា អញដឹងច្បាស់ ។ ២ ពាក្យមាំមួន ។

៩៩



បស្សាមីតិ ច បដិជានាមិ អហញ្ចេវ អញ្ញេ ច ។ តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ ន ខោ អាឡារោ កាលាមោ ឥមំ ធម្មំ កេវលំ សទ្ធា-មត្តកេន សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេតិ អទ្ធា អាឡារោ កាលាមោ ឥមំ ធម្មំ ជានំ បស្សំ វិហរតីតិ ។ អថខោ អហំ[(១)] អគ្គិវេស្សន យេន អាឡារោ កាលាមោ តេនុបសង្កមឹ ឧបសង្កមិត្វា អាឡារំ កាលាមំ ឯតទវោចំ កិត្តាវតា នោ អាវុសោ កាលាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ ។ ឯវំ វុត្តេ អគ្គិវេស្សន អាឡារោ កាលាមោ អាកិញ្ចញ្ញាយតនំ បវេទេសិ ។ តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ សទ្ធា មយ្ហំ-បត្ថិ សទ្ធា ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ វីរិយំ មយ្ហំបត្ថិ វីរិយំ ន ខោ អាឡា-រស្សេវ កាលាមស្ស អត្ថិ សតិ មយ្ហំបត្ថិ សតិ

---
១ ម. អថខ្វាហំ ។

មួយទៀត តថាគតប្តេជ្ញាថាឃើញ មិនមែនតែតថាគតប៉ុណ្ណោះឡើយ សូម្បីពួកជនដទៃគង់និយាយយ៉ាងនេះដែរ ។ នែអគ្គិវេស្សនៈ តថាគតគិតដូច្នេះថា អាឡារកាលាមតាបសមិនបានប្រកាសថា អាត្មាអញធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងនូវធម៌នេះ ដោយត្រឹមតែសទ្ធាប៉ុណ្ណោះ ហើយសម្រេចសម្រាន្តនៅដូច្នេះឡើយ តាមពិត អាឡារ-កាលាមតាបស គ្រាន់តែជាអ្នកយល់ឃើញ នូវធម៌នេះប៉ុណ្ណោះទេឬ ។ ម្នាលអគ្គិវេស្សនៈ លំដាប់នោះឯង តថាគតបានចូលទៅរកអាឡារកាលាម-តាបស លុះចូលទៅដល់ហើយ បានពោលពាក្យដូច្នេះនឹងអាឡារកាលាម-តាបសថា អាវុសោកាលាមៈ លោកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងចំពោះធម៌នេះ ហើយអាចសំដែងដល់ត្រឹមណា ។ នែអគ្គិវេស្សនៈ លុះតថាគតបានពោលយ៉ាងនេះហើយ អាឡារកាលាមតាបសក៏សំដែងនូវអាកិញ្ចញ្ញាយតនៈ ។ នែអគ្គិវេស្សនៈ តថាគតគិតដូច្នេះថា អាឡារកាលាមតាបសមិនមានសទ្ធាទេ អាត្មាអញទើបមានសទ្ធា អាឡារកាលាមតាបសមិនមានវីរិយៈទេ អាត្មាអញទើបមានវីរិយៈ អាឡារកាលាមតាបសមិនមានសតិទេ អាត្មាអញទើបមានសតិ

ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ សមាធិ មយ្ហំបត្ថិ សមាធិ ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ បញ្ញា មយ្ហំបត្ថិ បញ្ញា យន្នូនាហំ យំ ធម្មំ អាឡារោ កាលាមោ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេតិ តស្ស ធម្មស្ស សច្ឆិកិរិយាយ បទហេយ្យន្តិ ។ សោ ខោ អហំ អគ្គិវេស្សន នចិរស្សេវ ខិប្បមេវ តំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសឹ ។ អថ-ខ្វាហំ អគ្គិវេស្សន យេន អាឡារោ កាលាមោ តេនុបសង្កមឹ ឧបសង្កមិត្វា អាឡារំ កាលាមំ ឯតទវោចំ ឯត្តាវតា នោ អាវុសោ កាលាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេ-សីតិ ។ ឯត្តាវតា ខោ អហំ អាវុសោ ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមីតិ ។

អាឡារកាលាមតាបស មិនមានសមាធិទេ អាត្មាអញទើបមានសមាធិ អាឡារកាលាមតាបស មិនមានបញ្ញាទេ អាត្មាអញទើបមានបញ្ញា បើដូច្នោះអាឡារកាលាមតាបសប្រកាសថា អាត្មាអញបានត្រាស់ដឹងដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងនូវធម៌ណា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ តថាគត គប្បីតម្កល់ព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ។ នៃអគ្គិវេស្សន: តថាគតនោះបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងនូវធម៌នោះមួយរំពេច មិនយឺតយូរឡើយ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ នៃអគ្គិវេស្សន: លំដាប់នោះឯង តថាគតបានចូលទៅរកអាឡារកាលាមតាបស លុះចូលទៅដល់ហើយបាននិយាយពាក្យនេះនឹងអាឡារកាលាមតាបសថា អាវុសោកាលាម: លោកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង នូវធម៌នេះ ហើយអាចប្រកាសបានដោយហេតុមានប្រមាណប៉ុណ្ណោះទេឬ ។ អាឡារកាលាមតាបសតបថា នៃអ្នកមានអាយុ យើងបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌នេះ ហើយអាចប្រកាសបានដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

អហម្បិ ខោ អាវុសោ ឯត្តាវតា ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ ។ លាភា នោ អាវុសោ សុលទ្ធំ នោ អាវុសោ យេ មយំ អាយស្មន្តំ តាទិសំ ព្រហ្មចារឹ បស្សាម ឥតិ យាហំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមិ តំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរសិ យំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរសិ តមហំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមិ ឥតិ យាហំ ធម្មំ ជានាមិ តំ ត្វំ ធម្មំ ជានាសិ យំ ត្វំ ធម្មំ ជានាសិ តមហំ ធម្មំ ជានាមិ ឥតិ យាទិសោ អហំ តាទិសោ តុវំ

តថាគតពោលថា ម្នាលអ្នកមានអាយុ យើងបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌នេះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ដោយហេតុមានប្រមាណប៉ុណ្ណោះដែរ ។ អាឡារកាលាមតាបសតបថា នែអ្នកមានអាយុ យើងពេញហៅថាជាមនុស្សមានលាភ នែអ្នកមានអាយុ អត្តភាពជាមនុស្សពេញ ហៅថាយើងបានដោយល្អ ព្រោះថាយើងបានឃើញនូវព្រហ្មចារីបុគ្គល មានអាយុប្រាកដដូចជាអ្នក យើងបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងនូវធម៌ណា ហើយអាចប្រកាសបាន លោកក៏បានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវធម៌នោះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ លោកបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវធម៌ណា ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ យើងក៏បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវធម៌នោះ ហើយអាចប្រកាសបាន យើងដឹងនូវធម៌ណា លោកក៏ដឹង នូវធម៌នោះដែរ លោកដឹងនូវធម៌ណា យើងក៏ដឹងនូវធម៌នោះដែរ យើងជាមនុស្សយ៉ាងណា លោកក៏ជាមនុស្សយ៉ាងនោះដែរ

យាទិសោ តុវំ តាទិសោ អហំ ឯហិទានិ អាវុសោ ឧភោ វសន្តា ឥមំ គណំ បរិហរាមាតិ ។ ឥតិ ខោ អគ្គិវេស្សន អាឡារោ កាលាមោ អាចរិយោ មេ សមានោ អន្តេវាសឹ មំ សមានំ អត្តនោ សមសមំ ឋបេសិ ឧឡារាយ ច មំ បូជាយ បូជេសិ ។ តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ នាយំ ធម្មោ និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ យាវទេវ អាកិញ្ចញ្ញាយតនូបបត្តិយាតិ ។ សោ ខោ អហំ អគ្គិវេស្សន តំ ធម្មំ អនលង្ករិត្វា តស្មា ធម្មា និព្វិជ្ជ អបក្កមឹ ។

[៤២] សោ ខោ អហំ អគ្គិវេស្សន កឹកុសលគវេសី អនុត្តរំ សន្តិវរបទំ បរិយេសមានោ យេន ឧទ្ទកោ រាមបុត្តោ តេនុបសង្កមឹ ឧបសង្កមិត្វា

លោកជាមនុស្សយ៉ាងណា យើងក៏ជាមនុស្សយ៉ាងនោះដែរ នែអ្នកមានអាយុ អ្នកចូរមកក្នុងកាលឥឡូវនេះ យើងទាំងពីររូបនៅរក្សាគណៈនេះ ។ នែអគ្គិវេស្សនៈ អាឡារកាលាមតាបស ជាអាចារ្យរបស់តថាគត តែគាត់តាំងតថាគតដែលជាសិស្ស ឲ្យត្រឹមស្មើនឹងខ្លួនគាត់ ទាំងបូជាតថាគតដោយការបូជាដ៏ក្រៃលែង ដោយហេតុយ៉ាងនេះឯង ។ នែអគ្គិវេស្សនៈ តថាគតក៏មានសេចក្តីត្រិះរិះដូច្នេះថា ធម៌នេះមិនប្រព្រឹត្តទៅដើម្បីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីរំលត់នូវរាគាទិកិលេស មិនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ ប្រព្រឹត្តទៅបាន ត្រឹមតែកើតក្នុងអាកិញ្ចញ្ញាយតនភព[១] ប៉ុណ្ណោះឯង ។ នែអគ្គិវេស្សនៈ តថាគតនោះ មិនពេញចិត្តនឹងធម៌នោះ ហើយនឿយណាយចាកធម៌នោះ ក៏ដើរចៀសចេញទៅ ។

[៤២] នែអគ្គិវេស្សនៈ តថាគតស្វែងរកនូវកឹកុសល ស្វែងរកសន្តិវរបទគឺព្រះនិព្វាន ជាគ្រឿងរម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេសដ៏ប្រសើរ ហើយចូលទៅរកឧទ្ទករាមបុត្រតាបស លុះចូលទៅដល់ហើយ

១ គ្រាន់តែនាំឲ្យទៅកើតក្នុងអាកិញ្ចញ្ញាយតនព្រហ្ម មានអាយុ ៦០ ពាន់កប្បប៉ុណ្ណោះ មិនប្រព្រឹត្តទៅដល់ទីខ្ពស់គឺអរហត្តផលបានឡើយ ហើយនៅមិនទាន់រួចចាកជរានិងមរណៈទេ នៅជាប់ក្នុងអន្ទាក់របស់មច្ចុមារនៅឡើយ ។ អដ្ឋកថា បាសរាសិសូត្រ ។

១០៣

មហាយមកវគ្គស្ស មហាសច្ចកសុត្តេ ឧទ្ទកូបសង្កមនំ

ឧទ្ទកំ រាមបុត្តំ ឯតទវោចំ ឥច្ឆាមហំ អាវុសោ រាម ឥមស្មឹ ធម្មវិនយេ ព្រហ្មចរិយំ ចរិតុន្តិ ។ ឯវំ វុត្តេ អគ្គិវេស្សន ឧទ្ទកោ រាមបុត្តោ មំ ឯតទវោច វិហរតាយស្មា តាទិសោ អយំ ធម្មោ យត្ថ វិញ្ញូ បុរិសោ នចិរស្សេវ សកំ អាចរិយកំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ សោ ខោ អហំ អគ្គិវេស្សន នចិរស្សេវ ខិប្បមេវ តំ ធម្មំ បរិយាបុណឹ ។ សោ ខោ អហំ អគ្គិវេស្សន តាវតកេនេវ ឱដ្ឋប្បហតមត្តេន លបិតលាបនមត្តេន ញាណវាទញ្ច វទាមិ ថេរវាទញ្ច ជានាមិ បស្សាមីតិ ច បដិជានាមិ អហញ្ចេវ អញ្ញេ ច ។ តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ ន ខោ រាមោ ឥមំ ធម្មំ កេវលំ សទ្ធាមត្តកេន សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេតិ អទ្ធា រាមោ ឥមំ ធម្មំ ជានំ បស្សំ វិហរតីតិ ។

បាននិយាយពាក្យនេះ នឹងឧទ្ទករាមបុត្តថា អាវុសោរាមៈ យើងប្រាថ្នាដើម្បីប្រព្រឹត្តនូវព្រហ្មចរិយធម៌ ក្នុងធម្មវិន័យនេះ ។ នែអគ្គិវេស្សនៈ កាលបើតថាគត ពោលយ៉ាងនេះហើយ ឧទ្ទករាមបុត្ត ក៏និយាយពាក្យនេះនឹងតថាគតថា អ្នកដ៏មានអាយុ ចូរនៅចុះ នេះធម៌ដែលប្រាកដដូចជាអ្នកត្រូវការនោះ ជាធម៌ដែលវិញ្ញូបុរស គួរធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង នូវលទ្ធិនៃអាចារ្យ ជារបស់ខ្លួន ហើយសម្រេចសម្រាន្តនៅ ដោយមិនយូរប៉ុន្មាន ។ នែអគ្គិវេស្សនៈ តថាគតក៏បានរៀនចប់ធម៌នោះ ចាំមួយរំពេច មិនយឺតយូរឡើយ ។ នែអគ្គិ-វេស្សនៈ តថាគតនោះពោលនូវញាណវាទផង ដឹងនូវថេរវាទផង ដោយហេតុគ្រាន់តែបើកបបូរមាត់ ទាំងគ្រាន់តែចរចានូវពាក្យទៅមក ប៉ុណ្ណោះឯង មួយវិញទៀត តថាគតប្តេជ្ញាថាឃើញ មិនមែនតែតថាគតប៉ុណ្ណោះឡើយ សូម្បីពួកជនដទៃគង់និយាយយ៉ាងនេះដែរ ។ ម្នាលអគ្គិ-វេស្សនៈ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា រាមបុត្តមិនបានប្រកាសថាអាត្មាអញធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង នូវធម៌នេះដោយត្រឹមតែសទ្ធាប៉ុណ្ណោះ ហើយសម្រេចសម្រាន្តនៅ ដូច្នេះឡើយតាមពិត រាមបុត្តគ្រាន់តែជាអ្នកយល់ឃើញ នូវធម៌នេះប៉ុណ្ណោះទេឬ ។

អថខ្វាហំ អគ្គិវេស្សន យេន ឧទ្ទកោ រាមបុត្តោ តេនុបសង្កមឹ ឧបសង្កមិត្វា ឧទ្ទកំ រាមបុត្តំ ឯតទវោចំ កិត្តាវតា នោ អាវុសោ រាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ ។ ឯវំ វុត្តេ អគ្គិវេស្សន ឧទ្ទកោ រាមបុត្តោ នេវសញ្ញានាសញ្ញាយតនំ បវេទេសិ ។ តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ ន ខោ រាមស្សេវ អហោសិ សទ្ធា មយ្ហំបត្ថិ សទ្ធា ន ខោ រាមស្សេវ អហោសិ វីរិយំ មយ្ហំបត្ថិ វីរិយំ ន ខោ រាមស្សេវ អហោសិ សតិ មយ្ហំបត្ថិ សតិ ន ខោ រាមស្សេវ អហោសិ សមាធិ មយ្ហំបត្ថិ សមាធិ ន ខោ រាមស្សេវ អហោសិ បញ្ញា មយ្ហំបត្ថិ បញ្ញា យន្នូនាហំ យំ ធម្មំ រាមោ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហារាមីតិ បវេទេតិ តស្ស ធម្មស្ស សច្ឆិកិរិយាយ បទហេយ្យន្តិ ។ សោ ខោ អហំ អគ្គិវេស្សន នចិរស្សេវ ខិប្បមេវ តំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា

នៃអគ្គិវេស្សនៈ លំដាប់នោះឯង តថាគតក៏ចូលទៅរកឧទ្ទករាមបុត្ត លុះចូលទៅដល់ហើយ ក៏ពោលពាក្យនេះនឹងឧទ្ទករាមបុត្តថា អាវុសោរាមៈ លោកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង នូវធម៌នេះ ហើយអាចប្រកាសបាន ដោយហេតុមានប៉ុន្មានទៅ ។ នៃអគ្គិវេស្សនៈ លុះតថាគតពោលពាក្យយ៉ាងនេះហើយ ឧទ្ទករាមបុត្តក៏ប្រកាសនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ។ នៃអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា រាមបុត្តមិនមានសទ្ធាទេ ឯអាត្មាអញទើបមានសទ្ធា រាមបុត្តមិនមានវីរិយៈទេ អាត្មាអញទើបមានវីរិយៈ រាមបុត្តមិនមានសតិទេ អាត្មាអញទើបមានសតិ រាមបុត្តមិនមានសមាធិទេ អាត្មាអញទើបមានសមាធិ រាមបុត្តមិនមានបញ្ញាទេ អាត្មាអញទើបមានបញ្ញា បើដូច្នោះ រាមបុត្តប្រកាសនូវធម៌ណាថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ អាត្មាអញគប្បីតាំងព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ។ នៃអគ្គិវេស្សនៈ តថាគតនោះ ក៏បានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង នូវធម៌នោះ មួយរំពេច មិនយឺតយូរឡើយ ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។

ឧបសម្បជ្ជ វិហាសិ ។ អជ ទ្វាហំ អត្តិវេស្សន យេន ឧទ្ទកោ រាមបុត្តោ តេនុបសង្កមឹ ឧបសង្ក-មិត្វា ឧទ្ទកំ រាមបុត្តំ ឯតទវោចំ កិត្តាវតា នោ អាវុសោ រាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ ។ ឯត្តាវតា ខោ អហំ អាវុសោ[១] ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមីតិ ។ អហម្បិ ខោ អាវុសោ ឯត្តាវតា ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ ។ លាភា នោ អាវុសោ សុលទ្ធំ នោ អាវុសោ យេ មយំ អាយស្មន្តំ តាទិសំ ព្រហ្មចារឹ បស្សាម ឥតិ យំ ធម្មំ រាមោ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសិ តំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរសិ យំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា

១ ម. ឯត្តាវតា ខោ អាវុសោ រាមោ ។

នៃអគ្គិវេស្សនៈ លំដាប់នោះឯង តថាគតក៏ចូលទៅរកឧទ្ទករាមបុត្ត លុះចូលទៅដល់ហើយ ក៏ពោលពាក្យនេះ នឹងឧទ្ទករាមបុត្តថា អាវុសោរាមៈ លោកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវធម៌នេះ ហើយអាចប្រកាសបានដោយហេតុមានប៉ុន្មានទៅ ។ ឧទ្ទករាមបុត្តតបថា នៃអ្នកមានអាយុ យើងបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌នេះ ហើយអាចប្រកាសបាន ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។ តថាគតពោលថា នៃអ្នកមានអាយុ យើងបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌នេះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ដោយហេតុមានប្រមាណប៉ុណ្ណេះដែរ ។ ឧទ្ទករាមបុត្តនិយាយថា ម្នាលអ្នកមានអាយុ យើងហៅពេញថាជាមនុស្សមានលាភ នៃអ្នកមានអាយុ អត្តភាពជាមនុស្ស ឈ្មោះថា យើងបានដោយល្អ ព្រោះថា យើងបានឃើញនូវព្រហ្មចារីបុគ្គលមានអាយុប្រាកដដូចជាអ្នក រាមបុត្តបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌ណា ហើយអាចប្រកាសបាន អ្នកក៏បានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវធម៌នោះ ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ អ្នកបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង នូវធម៌ណា

ឧបសម្បជ្ជ វិហរសិ តំ ធម្មំ រាមោ សយំ អភិញ្ញា សច្ឆិ-កត្វា ឧបសម្បជ្ជ បវេទេសិ ឥតិ យំ ធម្មំ រាមោ អញ្ញាសិ តំ ត្វំ ធម្មំ បជានាសិ យំ ធម្មំ ជានាសិ តំ ធម្មំ រាមោ អញ្ញាសិ ឥតិ យាទិសោ រាមោ អហោសិ តាទិ-សោ តុវំ យាទិសោ តុវំ តាទិសោ រាមោ អហោសិ ឯហិ ទានិ អាវុសោ ឧភោ វសន្តា ឥមំ គណំ បរិ-ហរាមាតិ ។ ឥតិ ខោ អគ្គិវេស្សន ឧទ្ទកោ រាម-បុត្តោ សព្រហ្មចារី មេ សមានោ អាចរិយដ្ឋានេ មំ ឋបេសិ ឧឡារាយ ច មំ បូជាយ បូជេសិ ។ តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ នាយំ ធម្មោ និព្វិទា-យ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ យាវទេវ នេវសញ្ញានាសញ្ញាយតនូបបត្តិយាតិ ។ សោ ខោ អហំ អគ្គិវេស្សន តំ ធម្មំ អនលង្ករិត្វា តស្មា ធម្មា និព្វិជ្ជ អបក្កមឹ ។

ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ រាមបុត្តក៏បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង នូវធម៌នោះ ហើយអាចប្រកាសបាន រាមបុត្តបានដឹងនូវធម៌ណា អ្នកក៏បានដឹង នូវធម៌នោះដែរ អ្នកបានដឹងនូវធម៌ណា រាមបុត្តក៏បានដឹងនូវធម៌នោះដែរ រាមបុត្តជាមនុស្សយ៉ាងណា អ្នកក៏ជាមនុស្សយ៉ាងនោះដែរ អ្នកជាមនុស្សយ៉ាងណា រាមបុត្តក៏ជាមនុស្សយ៉ាងនោះដែរ នែអ្នកមានអាយុ ឥឡូវនេះ អ្នកចូរមក យើងទាំងពីរនាក់ នឹងនៅរក្សាគណៈនេះ ។ នែអគ្គិវេស្សនៈ ឧទ្ទករាមបុត្ត ជាសព្រហ្មចារីបុគ្គលរបស់តថាគត តាំងតថាគតក្នុងនាទីជាអាចារ្យ ទាំងបូជាតថាគតដោយគ្រឿងបូជាដ៏ក្រៃលែង ដោយប្រការដូច្នោះឯង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះ ដូច្នេះថា ធម៌នេះមិនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយចាករាគាទិក្កិលេស មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីរំលត់នូវកងទុក្ខ មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានទេ ប្រព្រឹត្តទៅបាន ត្រឹមតែកើតក្នុងនេវសញ្ញានាសញ្ញាយតនភពប៉ុណ្ណោះ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះមិនពេញចិត្តនឹងធម៌នោះ ក៏នឿយណាយចាកធម៌នោះ ហើយចៀសចេញទៅ ។

[៨៣] សោ ខោ អហំ អគ្គិវេស្សន កឹកុសល-គវេសី អនុត្តរំ សន្តិវរបទំ បរិយេសមានោ មគធេសុ អនុបុព្វេន ចារិកញ្ចរមានោ យេន ឧរុវេលា សេនា-និគមោ តទវសរឹ ។ តត្ថទ្ទសំ រមណីយំ ភូមិភាគំ បាសាទិកញ្ច វនសណ្ឌំ នទិញ្ច សន្ទន្តឹ សេតកំ សុបតិត្ថំ រមណីយំ សមន្តា គោចរគ្គាមំ ។ តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ រមណីយោ វត ភោ ភូមិភាគោ បាសាទិកោ ច វនសណ្ឌោ នទី ច សន្ទតិ សេតកា សុបតិត្ថា រមណីយា សមន្តា គោចរគ្គាមោ ។ អលមិទំ កុលបុត្តស្ស បធានិកស្ស បធានាយាតិ ។ សោ ខោ អហំ អគ្គិវេស្សន តត្ថេវ និសីទឹ អលមិទំ បធានាយាតិ ។

[៨៤] អបិស្សុ មំ អគ្គិវេស្សន តិស្សោ ឧប-មា បដិភំសុ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។ សេយ្យថាបិ អគ្គិវេស្សន អល្លំ កដ្ឋំ សស្នេហំ

មហាយមកវគ្គ មហាសច្ចកសូត្រ ឧបមាទាំង ៣ ឧបមាទី ១

[៥៣] នែអគ្គិវេស្សនៈ កាលដែលតថាគតស្វែងរកកឹកុសល ស្វែងរកសន្តិវរបទគឺព្រះនិព្វាន ជាគ្រឿងរម្ងាប់បង់ នូវភ្លើងទុក្ខ ភ្លើងកិលេសដ៏ប្រសើរ ហើយក៏ត្រាច់ទៅកាន់ចារិក តាមលំដាប់ក្នុងដែនមគធៈ បានដល់សេនានិគម ក្នុងឧរុវេលាប្រទេស ។ តថាគតបានឃើញនូវភូមិភាគគួរជាទីសប្បាយក្នុងសេនានិគមនោះផង នូវដងព្រៃជាទីជ្រះថ្លាផង នូវស្ទឹងដែលមានទឹកហូរមានទឹកថ្លា មានកំពង់ដ៏ល្អជាទីសប្បាយផង នូវស្រុកជាទីគោចរជិតល្មមផង ។ នែអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា ឱហ្ន៎ ភូមិភាគគួរជាទីសប្បាយផង ដងព្រៃជាទីជ្រះថ្លាផង ស្ទឹងមានទឹកថ្លាមានកំពង់ដ៏ល្អជាទីសប្បាយតែងហូរទៅផង ស្រុកជាទីគោចរក៏ជិតល្មមផង ។ កន្លែងនេះជាកន្លែងគួរដើម្បីប្រព្រឹត្តព្យាយាមនៃកុលបុត្តជាអ្នកមានព្យាយាម ។ នែអគ្គិវេស្សនៈ តថាគតនោះ ក៏អង្គុយនៅក្នុងទីនោះដោយគិតថា ទីនេះគួរដើម្បីការប្រព្រឹត្តព្យាយាម ។

[៥៤] នែអគ្គិវេស្សនៈ សេចក្តីឧបមាទាំង ៣ មិនជាអស្ចារ្យណាស់ណា តថាគតមិនធ្លាប់បានឮមកក្នុងកាលមុនទេ ស្រាប់តែប្រាកដដល់តថាគត ។ នែអគ្គិវេស្សនៈ ដូចជាកំណាត់ឈើស្រស់នៅមានជ័រ

ឧទកេ និក្ខិត្តំ ។ អថ បុរិសោ អាគច្ឆេយ្យ ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេស្សាមិ តេជោ បាតុករិស្សាមីតិ ។ តំ កឹ មញ្ញសិ អគ្គិវេស្សន អបិ នុ សោ បុរិសោ អមុំ អល្លំ កដ្ឋំ សស្នេហំ ឧទកេ និក្ខិត្តំ ឧត្តរារណឹ អាទាយ អភិមត្ថេន្តោ អគ្គឹ អភិនិព្វត្តេយ្យ តេជោ បាតុករេយ្យាតិ ។ នោ ហិទំ ភោ គោតម តំ កិស្ស ហេតុ អទុញ្ហិ[១] ភោ គោតម អល្លំ កដ្ឋំ សស្នេហំ តញ្ច បន ឧទកេ និក្ខិត្តំ យាវទេវ ច បន សោ បុរិសោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ឯវមេវ ខោ អគ្គិវេស្សន យេ ហិ កេចិ សមណា វា ព្រាហ្មណា វា កាយេន ចេវ កាមេហិ អវូបកដ្ឋា វិហរន្តិ យោ ច នេសំ កាមេសុ កាមច្ឆន្ទោ កាមស្នេហោ កាមមុច្ឆា កាមបិបាសា កាមបរិឡាហោ សោ ច អជ្ឈត្តំ ន សុប្បហីនោ ហោតិ ន សុប្បដិប្បស្សទ្ធោ ។ ឱបក្កមិកា ចេបិ តេ ភោន្តោ សមណព្រាហ្មណា

---

១ ឱ. អទុំ ហិ ។ ម. អមុំ ហិ ។

ដែលត្រាំនៅក្នុងទឹក ។ លំដាប់នោះ មានបុរសម្នាក់កាន់យកឈើពំនួត ភ្លើងខាងលើ (កូនពំនួត) ដើរមកដោយគិតថា អាត្មាអញនឹងពួតភ្លើងឲ្យ កើតឡើង អាត្មាអញនឹងធ្វើភ្លើងឲ្យឆេះឡើង ។ ម្នាលអគ្គិវេស្សនៈ អ្នក សំគាល់ហេតុនោះដូចម្តេច បុរសនោះកាន់យកឈើពំនួតភ្លើងខាងលើមក ពួតនឹងឈើស្រស់នៅមានជ័រ ដែលត្រាំនៅក្នុងទឹកឯណោះ ហើយគប្បីធ្វើ ភ្លើងឲ្យកើតឡើង គប្បីធ្វើភ្លើងឲ្យឆេះឡើងបានដែរឬ ។ បពិត្រព្រះគោតម ដ៏ចម្រើន អំពើនេះមិនបានទេ សេចក្តីនោះព្រោះហេតុអ្វី បពិត្រព្រះគោតម ដ៏ចម្រើន ព្រោះថាកំណាត់ឈើស្រស់ឯណោះនៅមានជ័រ ថែមទាំងកំណាត់ ឈើនោះត្រាំនៅក្នុងទឹកទៅទៀត បុរសនោះបានតែត្រឹមចំណែកនៃសេច-ក្តីលំបាក សេចក្តីចង្អៀតចង្អល់ឥតប្រយោជន៍ មានឧបមាដូចម្តេចមិញ នៃអគ្គិវេស្សនៈ ពួកជនណានីមួយ ទោះបីជាសមណៈក្តី ព្រាហ្មណ៍ ក្តី មានកាយមិនបានចៀសចេញ ចាកវត្ថុកាមទាំងឡាយ សមណ-ព្រាហ្មណ៍ទាំងនោះ មិនបានលះបង់ មិនបានរម្ងាប់ នូវសេចក្តីប្រាថ្នា ក្នុងកិលេសកាម សេចក្តីស្រឡាញ់ក្នុងកិលេសកាម សេចក្តីជ្រុលជ្រប់ក្នុង កិលេសកាម សេចក្តីស្រេកឃ្លានក្នុងកិលេសកាម សេចក្តីក្តៅក្រហាយ ក្នុងកិលេសកាមឲ្យដ៏ខាងក្នុងផង ។ បើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើន

ទុក្ខា តិប្បា[១] ខរា[២] កដុកា វេទនា វេទិយន្តិ អភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ យេបិ តេ ភោន្តោ សមណ-ព្រាហ្មណា ឱបក្កមិកា ទុក្ខា តិប្បា ខរា កដុកា វេទនា វេទិយន្តិ អភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ អយំ ខោ មំ អគ្គិវេស្សន បឋមា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុត-បុព្វា ។

[៥៤] អបរាបិ ខោ មំ អគ្គិវេស្សន ទុតិយា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។ សេយ្យថាបិ អគ្គិវេស្សន អល្លំ កដ្ឋំ សស្នេហំ អារកា ឧទកា ថលេ និក្ខិត្តំ ។ អថ បុរិសោ អាគច្ឆេយ្យ ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេស្សាមិ តេជោ ចាតុករិស្សាមីតិ ។ តំ កឹ មញ្ញសិ អគ្គិវេស្សន

១ ម. តិព្វា ។ ២ ឱ. ខរាតិ ន ទិស្សតិ ។

ទាំងនោះ ទទួលទុក្ខវេទនា ក្លៀវក្លា រឹងរូស ក្រហល់ក្រហាយ ដែលកើតអំពីព្យាយាម ក៏គង់សមណព្រាហ្មណ៍ទាំងនោះ មិនគួរ ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរឡើយ ។ បើទុកជាសមណព្រាហ្មណ៍ទាំងនោះ មិនបានទទួលទុក្ខវេទនា ក្លៀវក្លា រឹងរូស ក្រហល់ក្រហាយ ដែលកើតអំពីព្យាយាម ក៏គង់សមណព្រាហ្មណ៍ទាំងនោះ មិនគួរ ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរដែរ មានឧបមេយ្យដូច្នោះឯង ។ ម្នាលអគ្គិវេស្សនៈ សេចក្តីឧបមាជាដំបូងនេះឯង មិនជាអស្ចារ្យណាស់ណា តថាគតមិនធ្លាប់បានឮមកក្នុងកាលមុនទេ ក៏ស្រាប់តែប្រាកដដល់តថាគត ។

[៤៥] នែអគ្គិវេស្សនៈ សេចក្តីឧបមាជាគម្រប់ ២ ដទៃទៀត មិនជាទីអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានឮមកក្នុងកាលមុន ក៏ស្រាប់តែប្រាកដដល់តថាគត ។ ម្នាលអគ្គិវេស្សនៈ កំណាត់ឈើស្រស់នៅមានជ័រដែលដាក់នៅលើគោក ឆ្ងាយអំពីទឹក ។ លំដាប់នោះ មានបុរសម្នាក់កាន់យកនូវឈើពំនួតភ្លើងខាងលើដើរមក ដោយគិតថា អាត្មាអញនឹងធ្វើភ្លើងឲ្យកើតឡើង នឹងធ្វើភ្លើងឲ្យឆេះឡើង ។ នែអគ្គិវេស្សនៈ អ្នកសំគាល់នូវ

១១០



អបិ នុ សោ បុរិសោ អមុំ អល្លំ កដ្ឋំ សស្នេហំ អារកា ឧទកា ថលេ និក្ខិត្តំ ឧត្តរារណឹ អាទាយ អភិមត្ថេន្តោ អគ្គឹ អភិនិព្វត្តេយ្យ តេជោ ចាតុករេយ្យាតិ ។ នោ ហិទំ ភោ គោតម តំ កិស្ស ហេតុ អទុញ្ហិ ភោ គោតម អល្លំ កដ្ឋំ សស្នេហំ កិញ្ចាបិ អារកា ឧទកា ថលេ និក្ខិត្តំ យាវទេវ ច បន សោ បុរិសោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ឯវមេវ ខោ អគ្គិវេស្សន យេ ហិ កេចិ សមណា វា ព្រាហ្មណា វា កាយេន ចេវ កាមេហិ វូបកដ្ឋា វិហរន្តិ យោ ច នេសំ កាមេសុ កាមច្ឆន្ទោ កាមស្នេហោ កាមមុច្ឆា កាមបិចាសា កាមបរិឡាហោ សោ ច អជ្ឈត្តំ ន សុប្បហីនោ ហោតិ ន សុប្បដិប្បស្សទ្ធោ ។ ឱបក្កមិកា ចេបិ តេ ភោន្តោ សមណព្រាហ្មណា ទុក្ខា តិប្បា ខរា កដុកា វេទនា វេទិយន្តិ អភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ នោ ចេបិ តេ ភោន្តោ សមណព្រាហ្មណា

ហេតុនោះដូចម្តេច បុរសនោះកាន់នូវឈើពំនួតភ្លើងខាងលើ មកពួតនឹងកំណាត់ឈើស្រស់នៅមានជ័រ ដែលដាក់នៅលើគោក ឆ្ងាយអំពីទឹកឯណោះ ហើយគប្បីធ្វើភ្លើងឲ្យកើតឡើង គប្បីធ្វើភ្លើងឲ្យឆេះឡើងបានដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន អំពើនេះមិនបានទេ ព្រោះហេតុអ្វី បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថាកំណាត់ឈើស្រស់ឯណោះ ពិតជាដាក់នៅលើគោក ឆ្ងាយអំពីទឹកមែន តែថានៅស្រស់មានជ័រ ឯបុរសនោះ គ្រាន់តែជាអ្នកមានចំណែកនៃសេចក្តីលំបាក និងសេចក្តីចង្អៀតចង្អល់ប៉ុណ្ណោះឯង មានឧបមាដូចម្តេចមិញ នៃអគ្គិវេស្សនៈ ជនទាំងឡាយណានីមួយ ទោះជាសមណៈក្តី ព្រាហ្មណ៍ក្តី មានកាយចៀសចេញចាកវត្ថុកាមទាំងឡាយពិតមែនហើយ តែថាសមណព្រាហ្មណ៍ទាំងនោះមិនបានលះបង់ មិនបានរម្ងាប់នូវសេចក្តីប្រាថ្នាក្នុងកិលេសកាម សេចក្តីស្រឡាញ់ក្នុងកិលេសកាម សេចក្តីជ្រុលជ្រប់ក្នុងកិលេសកាម សេចក្តីស្រេកឃ្លានក្នុងកិលេសកាម សេចក្តីក្តៅក្រហាយក្នុងកិលេសកាមឲ្យដ៏ខាងក្នុង ។ បើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ សោយនូវទុក្ខវេទនាក្លៀវក្លា រឹងរូស ក្រហល់ក្រហាយ ដែលកើតអំពីព្យាយាម ក៏គង់សមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរឡើយ ។ បើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ

ឱបក្កមិកា ទុក្ខា តិប្បា ខរា កដុកា វេទនា វេទិយន្តិ អភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ អយំ ខោ មំ អគ្គិវេស្សន ទុតិយា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។

[៥៦] អបរាបិ ខោ មំ អគ្គិវេស្សន តតិយា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។ សេយ្យថាបិ អគ្គិវេស្សន សុក្ខំ កដ្ឋំ កោឡាបំ អារកា ឧទកា ថលេ និក្ខិត្តំ ។ អថ បុរិសោ អាគច្ឆេយ្យ ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេស្សាមិ តេជោ បាតុករិស្សាមីតិ ។ តំ កឹ មញ្ញសិ អគ្គិវេស្សន អបិ នុ ខោ[១] សោ បុរិសោ អមុំ សុក្ខំ កដ្ឋំ កោឡាបំ អារកា ឧទកា ថលេ និក្ខិត្តំ ឧត្តរារណឹ អាទាយ អភិមន្ថេន្តោ អគ្គឹ អភិនិព្វត្តេយ្យ តេជោ បាតុករេយ្យាតិ ។ ឯវំ ភោ ភោតម តំ កិស្ស ហេតុ អទុញ្ហិ ភោ ភោតម សុក្ខំ កដ្ឋំ កោឡាបំ តញ្ច បន អារកា

១ ឱ. ម. ខោសទ្ទោ នត្ថិ ។

មិនបានសោយនូវទុក្ខវេទនា ក្លៀវក្លា រឹងរូស ក្រហល់ក្រហាយ ដែលកើតអំពីព្យាយាមទេ ក៏គង់សមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរដែរ មានឧបមេយ្យដូច្នោះឯង នែអគ្គិវេស្សនៈ សេចក្តីឧបមាទី ២ នេះឯង មិនជាអស្ចារ្យណាស់ណា តថាគតមិនធ្លាប់បានឮមកក្នុងកាលមុន ក៏ស្រាប់តែប្រាកដដល់តថាគត ។

[៩៦] នែអគ្គិវេស្សនៈ សេចក្តីឧបមាទី ៣ ដទៃទៀត មិនជាទីអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់ឮមកក្នុងកាលមុន ក៏ស្រាប់តែប្រាកដដល់តថាគត ។ នែអគ្គិវេស្សនៈ កំណាត់ឈើស្ងួត ជាឈើសោះ ដែលដាក់នៅលើគោក ឆ្ងាយអំពីទឹក ។ លំដាប់នោះ មានបុរសម្នាក់កាន់នូវឈើពំនួតភ្លើងខាងលើ ដើរមកដោយគិតថា អាត្មាអញនឹងធ្វើភ្លើងឲ្យកើតឡើង អាត្មាអញនឹងធ្វើភ្លើងឲ្យឆេះឡើង ។ នែអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះដូចម្តេច បុរសនោះ កាន់នូវឈើពំនួតភ្លើងខាងលើ មកពួតនឹងកំណាត់ឈើស្ងួត ជាឈើសោះ ដែលដាក់នៅលើគោក ឆ្ងាយអំពីទឹកឯណោះ ហើយគប្បីធ្វើភ្លើងឲ្យកើតឡើង គប្បីធ្វើភ្លើងឲ្យឆេះឡើងបានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន គប្បីធ្វើភ្លើងឲ្យឆេះឡើងបាន ព្រោះហេតុអ្វី បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថាកំណាត់ឈើស្ងួតឯណោះជាឈើសោះស្រាប់ ហើយថែមទាំងកំណាត់ឈើនោះនៅលើគោក ឆ្ងាយ

ឧទកា ថលេ និក្ខិត្តន្តិ ឯវមេវ ខោ អគ្គិវេស្សន យេ ហិ កេចិ សមណា វា ព្រាហ្មណា វា កាយេន ចេវ កាមេហិ វូបកដ្ឋា វិហរន្តិ យោ ច នេសំ កាមេសុ កាមច្ឆន្ទោ កាមស្នេហោ កាមមុច្ឆា កាមបិបាសា កាមបរិឡាហោ សោ ច អជ្ឈត្តំ សុប្បហីនោ ហោតិ សុប្បដិប្បស្សទ្ធោ ។ ឱបក្កមិកា ចេបិ តេ ភោន្តោ សមណព្រាហ្មណា ទុក្ខា តិប្បា ខរា កដុកា វេទនា វេទិយន្តិ ភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ នោ ចេបិ តេ ភោន្តោ សមណព្រាហ្មណា ឱបក្កមិកា ទុក្ខា តិប្បា ខរា កដុកា វេទនា វេទិយន្តិ ភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ អយំ ខោ មំ អគ្គិវេស្សន តតិយា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។ ឥមា ខោ មំ អគ្គិវេស្សន តិស្សោ ឧបមាយោ[១] បដិភំសុ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។

១ ឱ. ម. ឧបមា ។

១១២



អំពីទឹកទៅទៀត មានឧបមាយ៉ាងណាមិញ នៃអគ្គិវេស្សនៈ ពួកជនណានីមួយ ទោះបីជាសមណៈក្តី ព្រាហ្មណ៍ក្តី មានកាយចៀសចេញចាកវត្ថុកាមទាំងឡាយផង សមណព្រាហ្មណ៍ទាំងនោះ បានលះបង់ បានរម្ងាប់សេចក្តីប្រាថ្នាក្នុងកិលេសកាម សេចក្តីស្រឡាញ់ក្នុងកិលេសកាម សេចក្តីជ្រុលជ្រប់ក្នុងកិលេសកាម សេចក្តីស្រេកឃ្លានក្នុងកិលេសកាម សេចក្តីក្តៅក្រហាយក្នុងកិលេសកាមឰដ៏ខាងក្នុងផង ។ បើទុកជាសមណ-ព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ទទួលទុក្ខវេទនា ក្តៅក្តា រឹងរូស ក្រហល់ក្រហាយ ដែលកើតអំពីព្យាយាម ក៏គង់សមណព្រាហ្មណ៍ទាំងនោះគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរបាន ។ បើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ មិនទទួលទុក្ខវេទនា ក្តៅក្តា រឹងរូស ក្រហល់ក្រហាយ ដែលកើតអំពីព្យាយាមទេ ក៏គង់សមណព្រាហ្មណ៍ទាំងនោះ គួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរបានដែរ មានឧបមេយ្យយ៉ាងនោះឯង នៃអគ្គិវេស្សនៈ សេចក្តីឧបមាទី ៣ នេះឯង មិនជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានឮមកក្នុងកាលមុន ក៏ស្រាប់តែប្រាកដដល់តថាគត ។ នៃអគ្គិវេស្សនៈ សេចក្តីឧបមាទាំង ៣ នេះឯង មិនជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានឮមកក្នុងកាលមុនទេ ក៏ស្រាប់តែប្រាកដដល់តថាគត ។

[៨៧] តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ យន្នូនាហំ ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហេយ្យំ អភិនិប្បីឡេយ្យំ អភិសន្តាបេយ្យន្តិ ។ សោ ខោ អហំ អគ្គិវេស្សន ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហាមិ អភិនិប្បីឡេមិ អភិសន្តាបេមិ តស្ស មយ្ហំ អគ្គិវេស្សន ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហតោ អភិនិប្បីឡយតោ អភិសន្តាបយតោ កច្ឆេហិ សេទា មុច្ចន្តិ ។ សេយ្យថាបិ អគ្គិវេស្សន ពលវា បុរិសោ ទុព្វលតរំ បុរិសំ សីសេ វា គហេត្វា ខន្ធេ វា គហេត្វា អភិនិគ្គណ្ហេយ្យ អភិនិប្បីឡេយ្យ អភិសន្តាបេយ្យ ឯវមេវ ខោ មេ អគ្គិវេស្សន ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហតោ អភិនិប្បីឡយតោ អភិសន្តាបយតោ កច្ឆេហិ សេទា មុច្ចន្តិ ។ អារទ្ធំ ខោ បន មេ អគ្គិវេស្សន វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ

[៩៧] នែអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ មានតែអាត្មាអញខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយ ទល់ពិតាន (ក្រអូមមាត់) ដោយអណ្តាត សង្កត់គាបផ្ទប់នូវចិត្តដោយចិត្ត ។ នែអគ្គិវេស្សនៈ តថាគតនោះក៏ខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយ ទល់ពិតានដោយអណ្តាត សង្កត់គាបផ្ទប់នូវចិត្តដោយចិត្ត នែអគ្គិវេស្សនៈ កាលដែលតថាគតនោះ ខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយ ទល់ពិ-តានដោយអណ្តាត សង្កត់គាបផ្ទប់នូវចិត្តដោយចិត្ត ញើសក៏ហូរចេញអំពីក្លៀកទាំងសងខាង ។ នែអគ្គិវេស្សនៈ ដូចបុរសដែលមានកម្លាំង ចាប់បុរសដែលមានកម្លាំងថយជាងខ្លួន ត្រង់ក្បាលផង ចាប់ត្រង់កផង គប្បីសង្កត់គាបផ្ទប់ មានឧបមាយ៉ាងណាមិញ នែអគ្គិវេស្សនៈ កាលដែលតថាគតខាំសង្កត់ធ្មេញ ដោយធ្មេញទាំងឡាយ ទល់ពិតានដោយអណ្តាត សង្កត់គាបផ្ទប់នូវចិត្តដោយចិត្ត ញើសក៏ហូរចេញអំពីក្លៀកទាំងសងខាង មានឧបមេយ្យយ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគត តឹងតែងណាស់ មិនធូរថយ សតិក៏តម្កល់ខ្ជាប់

អប្បម្មុដ្ឋា(១) សារទ្ធោ ច បន មេ កាយោ ហោតិ
អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិ-
តុន្នស្ស សតោ ។ ឯវរូបាបិ ខោ មេ អគ្គិវេស្សន
ឧប្បន្នា ទុក្ខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ។

[៤៨] តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ
យន្នូនាហំ អប្បាណកំយេវ(២) ឈានំ ឈាយេយ្យន្តិ ។
សោ ខោ អហំ អគ្គិវេស្សន មុខតោ ច នាសតោ ច
អស្សាសប្បស្សាសេ ឧបរុន្ធឹ ។ តស្ស មយ្ហំ អគ្គិវេស្សន
មុខតោ ច នាសតោ ច អស្សាសប្បស្សាសេសុ
ឧបរុទ្ធេសុ កណ្ណសោតេហិ វាតានំ និក្ខន្តានំ អធិ-
មត្តោ សទ្ទោ ហោតិ ។ សេយ្យថាបិ នាម កម្មា-
រគគ្គរិយា ធមមានាយ អធិមត្តោ សទ្ទោ ហោតិ
ឯវមេវ ខោ មេ អគ្គិវេស្សន មុខតោ ច នាសតោ ច
អស្សាសប្បស្សាសេសុ ឧបរុទ្ធេសុ កណ្ណសោតេហិ
វាតានំ និក្ខន្តានំ អធិមត្តោ សទ្ទោ ហោតិ ។

១ ឱ. អសម្មុដ្ឋា ។ ម. អសំមុដ្ឋា ។ ២ ឱ. អប្បាណកំ ។

មិនមានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគតដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ដោយសារសេចក្តីព្យាយាមដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

[៤៨] នែអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះមានតែអាត្មាអញពិចារណានូវអប្បាណកជ្ឈាន គឺឈានដែលគ្មានដង្ហើមចេញចូល ។ នែអគ្គិវេស្សនៈ តថាគតក៏បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង ។ នែអគ្គិវេស្សនៈ លុះតថាគត បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង សំឡេងរបស់ខ្យល់ ដែលចេញមកអំពីរន្ធត្រចៀកទាំងសងខាង ក៏ឮខ្លាំងក្រៃពេក ។ សំឡេងស្នប់របស់ជាងមាស ដែលកំពុងសប់លាន់ឮខ្លាំងយ៉ាងណាមិញ ម្នាលអគ្គិវេស្សនៈ លុះតថាគតបិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង សំឡេងរបស់ខ្យល់ដែលចេញអំពីរន្ធត្រចៀក ទាំងសងខាង ក៏លាន់ឮខ្លាំង យ៉ាងនោះឯង ។

អារទ្ធំ ខោ បន មេ អគ្គិវេស្សន វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។ ឯវរូបាបិ ខោ មេ អគ្គិវេស្សន ឧប្បន្នា ទុក្ខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ។

[៤៩] តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ យន្នូនាហំ អប្បាណកំយេវ ឈានំ ឈាយេយ្យន្តិ ។ សោ ខោ អហំ អគ្គិវេស្សន មុខតោ ច នាសតោ ច កណ្ណតោ ច អស្សាសប្បស្សាសេ ឧបរុន្ធឹ ។ តស្ស មយ្ហំ អគ្គិវេស្សន មុខតោ ច នាសតោ ច កណ្ណតោ ច អស្សាសប្បស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា វាតា មុទ្ធានំ ឱហនន្តិ[១] ។ សេយ្យថាបិ អគ្គិវេស្សន ពលវា បុរិសោ តិណ្ហេន សិខរេន មុទ្ធានំ អភិមត្ថេយ្យ ឯវមេវ ខោ មេ អគ្គិវេស្សន

១ ឱ. ឧហនន្តិ ។ ម. ឧហនន្តិ ។

នៃអគ្គិវេស្សនៈ សេចក្ដីព្យាយាមរបស់តថាគត តឹងតែងណាស់ មិនបន្ធូរបន្ថយ ទាំងសតិក៏តម្កល់ខ្ជាប់ មិនបានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគត ដែលត្រូវព្យាយាមចាក់ដោតហើយ ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ដោយសារសេចក្ដីព្យាយាមដ៏លំបាកនោះឯង ។ នៃអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះកើតឡើងដល់តថាគត ក៏មិនគ្របសង្កត់ចិត្តរបស់តថាគតបានឡើយ ។

[៥៩] នៃអគ្គិវេស្សនៈ តថាគតនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ ពិចារណានូវអប្បាណកជ្ឈាន ។ នៃអគ្គិវេស្សនៈ តថាគតក៏បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ នៃអគ្គិវេស្សនៈ លុះតថា-គត បិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែង ក៏ចាក់ដោតនូវក្បាល ។ នៃអគ្គិវេស្សនៈ បុរសមានកម្លាំង ចាក់ធ្លៀលនូវក្បាលដោយចុងដែកស្រួចដ៏មុត យ៉ាងណាមិញ នៃអគ្គិវេស្សនៈ លុះតថាគត

មុខតោ ច ជាសតោ ច កណ្ណតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា វាតា មុទ្ធានំ ឱហនន្តិ ។ អារទ្ធំ ខោ បន មេ អគ្គិវេស្សន វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។ ឯវរូបាបិ ខោ មេ អគ្គិវេស្សន ឧប្បន្នា ទុក្ខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ។

[៦០] តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ យន្នូនាហំ អប្បាណកំយេវ ឈានំ ឈាយេយ្យន្តិ ។ សោ ខោ អហំ អគ្គិវេស្សន មុខតោ ច ជាសតោ ច កណ្ណតោ ច អស្សាសបស្សាសេ ឧបរុន្ធឹ ។ តស្ស មយ្ហំ អគ្គិវេស្សន មុខតោ ច ជាសតោ ច កណ្ណតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា សីសេ សីសវេទនា ហោន្តិ ។ សេយ្យថាបិ អគ្គិវេស្សន ពលវា បុរិសោ

*បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែង ក៏ចាក់ដោតនូវក្បាល យ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគត តឹង តែងណាស់ មិនធូរថយឡើយ សតិក៏តម្កល់ខ្ជាប់ មិនបានវង្វេងភ្លេច ឡើយ តែចំណែកខាងកាយរបស់តថាគត ដែលត្រូវព្យាយាមចាក់ ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ដោយសារ សេចក្តីព្យាយាមដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុកណាជាទុក្ខ-វេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវ ចិត្តរបស់តថាគតបានឡើយ ។*

[៦០] *នែអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះ ថា បើដូច្នោះ គួរតែអាត្មាអញពិចារណានូវអប្បាណកជ្ឈាន តែ ម្យ៉ាង ។ នែអគ្គិវេស្សនៈ តថាគតក៏បិទខ្យល់ដង្ហើមចេញ និងខ្យល់ ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ នែអគ្គិ-វេស្សនៈ លុះតថាគតនោះបិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពី មាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ សីសវេទនា*[១] *ដ៏ខ្លាំង ក្រៃលែងក៏កើតប្រាកដក្នុងក្បាល ។ នែអគ្គិវេស្សនៈ បុរសមានកម្លាំង*

---

១ ជំងឺក្បាលដ៏មានកម្លាំង កើតអំពីកងខ្យល់ដែលមិនបានចេញអំពីទ្វារណាមួយសោះ នោះឯង ។ អដ្ឋកថា ។

ទឡ្ហេន វរត្តក្ខន្ធេន(១) សីសេ សីសវេឋនំ ទទេយ្យ ឯវមេវ ខោ មេ អគ្គិវេស្សន មុខតោ ច នាសតោ ច កណ្ណតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា សីសេ សីសវេទនា ហោន្តិ ។ អារទ្ធំ ខោ បន មេ អគ្គិវេស្សន វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។ ឯវរូបាបិ ខោ មេ អគ្គិវេស្សន ឧប្បន្នា ទុក្ខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ។

[៦១] តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ យន្នូនាហំ អប្បាណកំយេវ ឈានំ ឈាយេយ្យន្តិ ។ សោ ខោ អហំ អគ្គិវេស្សន មុខតោ ច នាសតោ ច កណ្ណតោ ច អស្សាសបស្សាសេ ឧបរុន្ធឹ ។ តស្ស មយ្ហំ អគ្គិវេស្សន មុខតោ ច នាសតោ ច កណ្ណតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ

១ ឱ. ម. ទឡ្ហេន វរត្តក្ខណ្ឌេន ។

រុំក្បាលដោយកំណាត់ព្រ័ត្រដ៏មាំ យ៉ាងណាមិញ នៃអគ្គិវេស្សនៈ លុះតថាគតបិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ សីសវេទនាដ៏ខ្លាំងក្រៃលែង ក៏កើតប្រាកដក្នុងក្បាល ក៏យ៉ាងនោះឯង ។ នៃអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគត តឹងតែងណាស់ មិនធូរថយឡើយ ទាំងសតិក៏តម្កល់ខ្ជាប់ មិនបានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគត ដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ដោយសារសេចក្តីព្យាយាមដ៏លំបាកនោះឯង ។ នៃអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏គ្របសង្កត់ចិត្តរបស់តថាគតមិនបានឡើយ ។

[៦១] នៃអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ ពិចារណានូវអប្បាណកជ្ឈាន ។ នៃអគ្គិវេស្សនៈ តថាគតនោះក៏បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ នៃអគ្គិវេស្សនៈ លុះតថាគតនោះបិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង

អធិមត្តា វាតា កុច្ឆឹ បរិកន្តន្តិ ។ សេយ្យថាបិ អគ្គិវេស្សន ទក្ខោ គោឃាតកោ វា គោឃាតកន្តេ-វាសី វា តិណ្ហេន គោវិកន្តនេន កុច្ឆឹ បរិកន្តេយ្យ ឯវមេវ ខោ មេ អគ្គិវេស្សន មុខតោ ច នាសតោ ច កណ្ណតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិ-មត្តា វាតា កុច្ឆឹ បរិកន្តន្តិ ។ អារទ្ធំ ខោ បន មេ អគ្គិវេស្សន វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។ ឯវរូបាបិ ខោ មេ អគ្គិវេស្សន ឧប្បន្នា ទុក្ខា វេទនា ចិត្តំ ន បរិ-យាទាយ តិដ្ឋតិ ។

[៦២] តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ យន្នូនាហំ អប្បាណកំយេវ ឈានំ ឈាយេយ្យន្តិ ។

អំពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែង ក៏សៀតធ្លុលផ្ទៃ ។ នែអគ្គិវេស្សនៈ បុរសអ្នកសម្លាប់គោ ឬកូនសិស្សនៃបុរសអ្នកសម្លាប់គោដ៏ឈ្លាសវៃ គប្បីអារនូវផ្ទៃដោយកាំបិតសម្រាប់អារគោដ៏មុត យ៉ាងណាមិញ នែអគ្គិវេស្សនៈ លុះតថាគតបិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែង ក៏សៀតធ្លុលនូវផ្ទៃ យ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគត តឹងតែងណាស់ មិនធូរថយឡើយ ទាំងសតិក៏តម្កល់ខ្ជាប់ មិនបានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគត ដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ដោយសារសេចក្តីព្យាយាមដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនបានគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

[៦៥] ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញពិចារណានូវអប្បាណកជ្ឈាន ។

សោ ខោ អហំ អគ្គិវេស្សន មុខតោ ច នាសតោ ច កណ្ណតោ ច អស្សាសបស្សាសេ ឧបរុន្ធឹ ។ តស្ស មយ្ហំ អគ្គិវេស្សន មុខតោ ច នាសតោ ច កណ្ណតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តោ កាយស្មឹ ឌាហោ ហោតិ ។ សេយ្យថាបិ អគ្គិវេស្សន ទ្វេ ពលវន្តោ បុរិសា ទុព្វលតរំ បុរិសំ នានាពាហាសុ គហេត្វា អង្គារកាសុយា សន្តាបេយ្យុំ សម្បរិតាបេយ្យុំ ឯវមេវ ខោ អគ្គិវេស្សន មុខតោ ច នាសតោ ច កណ្ណតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តោ កាយស្មឹ ឌាហោ ហោតិ ។ អារទ្ធំ ខោ បន មេ អគ្គិវេស្សន វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។ ឯវរូបាបិ ខោ មេ អគ្គិវេស្សន ឧប្បន្នា ទុក្ខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ។ អបិស្សុ មំ អគ្គិវេស្សន ទេវតា ទិស្វា ឯវមាហំសុ

ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង ក៏បិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ ម្នាលអគ្គិវេស្សនៈ លុះតថាគតនោះបិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ សេចក្តីក្តៅក្រហាយដ៏ខ្លាំងក្រៃលែង ក៏កើតឡើងក្នុងកាយ ។ ម្នាលអគ្គិវេស្សនៈ បុរសមានកម្លាំង ពីរនាក់ ចាប់នូវបុរសមានកម្លាំងថយជាងខ្លួន ត្រង់ដៃទាំងសងខាង ផ្តើរកម្តៅលើរណ្តៅរងើកភ្លើង យ៉ាងណាមិញ ម្នាលអគ្គិវេស្សនៈ លុះតថាគតបិទខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ សេចក្តីក្តៅក្រហាយដ៏ខ្លាំងក្រៃលែង ក៏កើតឡើងក្នុងកាយ យ៉ាងនោះឯង ។ ម្នាលអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគត តឹងតែងណាស់ មិនធូរថយឡើយ ទាំងសតិក៏តម្កល់ខ្ជាប់ខ្ជួន មិនបានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគតដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ដោយសារសេចក្តីព្យាយាមដ៏លំបាកនោះឯង ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនា មានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនបានគ្របសង្កត់ នូវចិត្តរបស់តថាគតឡើយ ។ ម្នាលអគ្គិវេស្សនៈ មានពួកទេវតាបានឃើញតថាគត ដូច្នោះហើយ និយាយយ៉ាងនេះថា

កាលកតោ សមណោ គោតមោតិ ។ ឯកច្ចា ទេវតា ឯវមាហំសុ ន កាលកតោ សមណោ គោតមោ អបិច កាលំ ករោតីតិ ។ ឯកច្ចា ទេវតា ឯវមាហំសុ ន កាលកតោ សមណោ គោតមោ នបិ កាលំ ករោតិ អរហំ សមណោ គោតមោ វិហារោ ត្វេវ សោ អរហតោ ឯវរូបោ ហោតីតិ ។

[៦៣] តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ យន្នូនាហំ សព្វសោ អាហារុបច្ឆេទាយ បដិបជ្ជេយ្យន្តិ ។ អថខោ មំ អគ្គិវេស្សន ទេវតា ឧបសង្កមិត្វា ឯតទវោចុំ មា ខោ ត្វំ មារិស សព្វសោ អាហារុបច្ឆេទាយ បដិបជ្ជិ សចេ ខោ ត្វំ មារិស សព្វសោ អាហារុបច្ឆេ-ទាយ បដិបជ្ជិស្សសិ តស្ស តេ មយំ ទិព្វំ ឱជំ លោមកូបេហិ អជ្ឈោហារិស្សាម តាយ ត្វំ យាបេស្ស-សីតិ ។ តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ អ-ហញ្ចេវ ខោ បន សព្វសោ ជទ្ធុកំ[១] បដិជានេយ្យំ

១ ឱ. អជទ្ធុកន្តិ ទិស្សតិ ។

ព្រះសមណគោតមធ្វើមរណកាលហើយ ។ ទេវតាពួកខ្លះនិយាយយ៉ាងនេះថា ព្រះសមណគោតមមិនទាន់ធ្វើមរណកាលនៅឡើយទេ តែគង់នឹងធ្វើមរណកាលពុំខាន ។ ទេវតាពួកខ្លះនិយាយយ៉ាងនេះថា ព្រះសមណ-គោតម មិនបានធ្វើមរណកាលទៅហើយទេ ទាំងនឹងមិនធ្វើមរណកាលឡើយ ព្រះសមណគោតម ជាអរហន្ត ទ្រង់គង់ព្រះជន្មាយុដោយពិតការគង់ព្រះជន្មាយុរបស់ព្រះអរហន្តនោះ មានសភាពយ៉ាងនេះ ។

[៦៣] ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអាត្មាអញប្រតិបត្តិ ដើម្បីផ្តាច់បង់នូវអាហារ ដោយប្រការទាំងពួង ។ ម្នាលអគ្គិវេស្សនៈ លំដាប់នោះឯង ពួកទេវតាចូលទៅរកតថាគត ហើយនិយាយដូច្នេះថា បពិត្រព្រះអង្គអ្នកនិទុក្ខ ព្រះអង្គកុំប្រតិបត្តិដើម្បីផ្តាច់បង់នូវអាហារ ដោយប្រការទាំងពួងឡើយ បពិត្រព្រះអង្គអ្នកនិទុក្ខ បើព្រះអង្គនឹងប្រតិបត្តិដើម្បីផ្តាច់បង់នូវអាហារ ដោយប្រការទាំងពួងតទៅ យើងទាំងឡាយនឹងញ៉ាំងឱជាទិព្វ ឲ្យជ្រួតជ្រាបទៅតាមរណ្តៅរោមទាំងឡាយរបស់ព្រះអង្គ ៗ នឹងរស់នៅដោយឱជាទិព្វនោះបាន ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើអាត្មាអញនឹងប្តេជ្ញាថាខ្លួនជាអ្នកគ្មានភោជន ដោយប្រការទាំងពួងផង

ឥមា ច មេ ទេវតា ទិព្វំ ឱជំ លោមកូបេហិ អជ្ឈោហារេយ្យុំ តាយ ចាហំ យាបេយ្យំ តំ មម អស្ស មុសាតិ ។ សោ ខោ អហំ អគ្គិវេស្សន តា ទេវតា បច្ចាចិក្ខាមិ អលន្តិ វទាមិ ។

[៦៤] តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ យន្នូនាហំ ថោកំ ថោកំ អាហារំ អាហារេយ្យំ បសតំ បសតំ យទិ វា មុគ្គយូសំ យទិ វា កុលត្ថ-យូសំ យទិ វា កឡាយយូសំ យទិ វា ហរេណុ-កយូសន្តិ ។ សោ ខោ អហំ អគ្គិវេស្សន ថោកំ ថោកំ អាហារំ អាហារេសឹ បសតំ បសតំ យទិ វា មុគ្គយូសំ យទិ វា កុលត្ថយូសំ យទិ វា កឡា-យយូសំ យទិ វា ហរេណុកយូសំ ។ តស្ស មយ្ហំ អគ្គិវេស្សន ថោកំ ថោកំ អាហារំ អាហារយតោ បសតំ បសតំ យទិ វា មុគ្គយូសំ យទិ វា កុលត្ថ-យូសំ យទិ វា កឡាយយូសំ យទិ វា ហរេណុកយូសំ

ទេវតាទាំងឡាយនេះ នឹងញ៉ាំងឱជាទិព្វឲ្យជ្រួតជ្រាបចូលទៅតាមរណ្តៅរោមទាំងឡាយរបស់អាត្មាអញផង អាត្មាអញនឹងរស់នៅដោយឱជាទិព្វនោះផង អំពើនោះជាអំពើកុហករបស់អាត្មាអញ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង ក៏និយាយឃាត់ទេវតាទាំងនោះវិញ តថាគតប្រាប់ថា កុំឡើយ ដូច្នេះ ។

[៦៤] ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ មានតែអាត្មាអញ បរិភោគនូវអាហារបន្តិច ៗ ទោះបីគ្រាប់សណ្តែកបាយក្តី គ្រាប់ពពាយជ្រុំងក្តី គ្រាប់សណ្តែកកង់ក្តី គ្រាប់សណ្តែកទ្រើងក្តី ត្រឹមតែមួយទូកដៃ ៗ ។ ម្នាលអគ្គិវេស្សនៈ តថាគតក៏បានបរិភោគ នូវអាហារបន្តិច ៗ ទោះបីគ្រាប់សណ្តែកបាយក្តី គ្រាប់ពពាយជ្រុំងក្តី គ្រាប់សណ្តែកកង់ក្តី គ្រាប់សណ្តែកទ្រើងក្តី ត្រឹមតែមួយទូកដៃ ៗ ។ ម្នាលអគ្គិវេស្សនៈ កាលដែលតថាគតនោះ បរិភោគអាហារបន្តិច ៗ ទោះបីគ្រាប់សណ្តែកបាយក្តី គ្រាប់ពពាយជ្រុំងក្តី គ្រាប់សណ្តែកកង់ក្តី គ្រាប់សណ្តែកទ្រើងក្តី ត្រឹមតែមួយទូកដៃ ៗ

អធិមត្តកសិមានំ បត្តោ មេ[១] កាយោ ហោតិ ។ សេយ្យថាបិ នាម អសីតិកបព្វានិ វា កាឡបព្វានិ វា[២] ឯវមេវស្សុ[៣] មេ អង្គបច្ចង្គានិ ភវន្តិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម ឱដ្ឋបទំ ឯវមេវស្សុ មេ អានិសទំ ហោតិ តាយេវប្បាហារតា-យ ។ សេយ្យថាបិ នាម វដ្ដនាវឡី ឯវមេវស្សុ មេ បិដ្ឋិកណ្ដកោ ឧណ្ណតាវណតោ ហោតិ តាយេ-វប្បាហារតាយ ។ សេយ្យថាបិ នាម ជរសាលាយ គោបាណសិយោ ឱលុគ្គវិលុគ្គា ភវន្តិ ឯវមេវស្សុ មេ ផាសុឡិយោ ឱលុគ្គវិលុគ្គា ភវន្តិ តាយេវប្បាហារតា-យ ។ សេយ្យថាបិ នាម គម្ភីរេ ឧទបានេ ឧទកតារកា គម្ភីរគតា ឱក្ខាយិកា ទិស្សន្តិ ឯវមេវស្សុ មេ អក្ខិ-កូបេ[៤] អក្ខិតារកា គម្ភីរគតា ឱក្ខាយិកា ទិស្សន្តិ

---

១ ឱ. ម. មេតិ ន ទិស្សតិ ។ ២ ឱ. កាលាបព្វានិ វា ។ ៣ ម. ឯវមេវាស្សុ ។ ៤ ឱ. ម. អក្ខិកូបេសុ ។

កាយរបស់តថាគតក៏ដល់នូវអាការស្គាំងស្គមក្រៃលែង ។ អវយវៈ តូចធំ របស់តថាគត ដូចជាថ្នាំងនៃវល្លិ ឈ្មោះអសីតិកៈ ឬដូចជាថ្នាំងនៃវល្លិ ប្រេង ព្រោះមានអាហារតិចនោះឯង ។ គគូថរបស់តថាគត ដូចជា ស្នាមជើងនៃសត្វឱដ្ឋ ព្រោះមានអាហារតិចនោះឯង ។ ឆ្អឹងខ្នងរបស់ តថាគត រដិបរដុប ដូចជាលំពង់ឈើ ដែលវល្លិព័ទ្ធវេញ ព្រោះមាន អាហារតិចនោះឯង ។ របៀបនៃឆ្អឹងជំនីរទាំងឡាយ របស់តថាគត ក៏ រគីមរគាម ដូចជាបង្កង់នៃសាលាចាស់ ដ៏រគីមរគាម ព្រោះមាន អាហារតិចនោះឯង ។ ប្រស្រីភ្នែកក្នុងរណ្ដៅភ្នែករបស់តថាគត ក៏ជ្រៅ ខ្វង់ចុះទៅ ដូចក្រពេញទឹក ក្នុងអណ្ដូងទឹកជ្រៅ ដ៏ជ្រៅខ្វង់ចុះទៅ

តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម តិត្តិកាលាពុ[១] អាមកច្ឆិន្នោ វាតាតបេន សំផុសិតោ[២] ហោតិ សម្មិលាតោ ឯវមេវស្សុ មេ សីសេ[៣] សីសច្ឆវី សំផុសិតា ហោតិ សម្មិលាតា តាយេវប្បាហារតាយ ។ សោ ខោ អហំ អគ្គិវេស្សន ឧទរច្ឆវឹ បរិមសិស្សាមីតិ បិដ្ឋិកណ្ដកំយេវ បរិគ្គណ្ហាមិ បិដ្ឋិកណ្ដកំ បរិមសិស្សាមីតិ ឧទរច្ឆវឹយេវ បរិគ្គណ្ហាមិ យាវស្សុ មេ អគ្គិវេស្សន ឧទរច្ឆវី បិដ្ឋិកណ្ដកំ អល្លីនា ហោតិ តាយេវប្បាហារតាយ ។ សោ ខោ អហំ អគ្គិវេស្សន វច្ចំ វា មុត្តំ វា ករិស្សាមីតិ តត្ថេវ អវកុជ្ជោ បបតាមិ តាយេវប្បាហារតាយ ។ សោ ខោ អហំ អគ្គិវេស្សន ឥមមេវ កាយំ អស្សាសេន្តោ បាណិនា គត្តានិ អនុមជ្ជាមិ តស្ស មយ្ហំ អគ្គិវេស្សន បាណិនា គត្តានិ អនោមជ្ជតោ បូតិមូលានិ លោមានិ កាយស្មា បបតន្តិ តាយេវប្បាហារតាយ ។ អបិស្សុ មំ អគ្គិវេស្សន មនុស្សា ទិស្វា

១ ឱ. ម. តិត្តកាលាពុ ។ ២ ឱ. ម. សំបុដិតោ ។ ៣ ឱ. ម. សីសេតិ ន ទិស្សតិ ។

ព្រោះមានអាហារតិចនោះឯង ។ ស្បែកក្បាល ឰដ៏ក្បាលរបស់តថាគត ដែលអាហារតិចនោះពាល់ត្រូវហើយ ក៏ស្វិតជ្រីវ ដូចជាផ្លែននោងព្រៃ ដែលគេកាត់អំពីខ្ចី លុះខ្យល់និងកម្តៅថ្ងៃពាល់ត្រូវហើយ ក៏ស្វិតជ្រីវ ដូច្នោះឯង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯងគិតថា អាត្មាអញនឹងស្ទាបស្បែកពោះ ក៏ចាប់ត្រូវលើឆ្អឹងខ្នងទៅវិញ គិតថាអាត្មាអញនឹងស្ទាបឆ្អឹងខ្នង ក៏ចាប់ត្រូវលើស្បែកពោះទៅវិញ ម្នាលអគ្គិវេស្សនៈ ព្រោះថាស្បែកពោះរបស់តថាគតជាប់នឹងឆ្អឹងខ្នង ព្រោះមានអាហារតិចនោះឯង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯងគិតថា អាត្មាអញនឹងបន្ទោបង់នូវវច្ចៈ ឬទឹកមូត្រ ក៏ដួលផ្កាប់ក្នុងទីនោះ ព្រោះមានអាហារតិចនោះឯង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯងធ្វើកាយនេះឲ្យស្រួលបួល ជុសខ្លួនប្រាណដោយដៃ ម្នាលអគ្គិវេស្សនៈ កាលបើតថាគតនោះជុសខ្លួនប្រាណដោយដៃ រោមទាំងឡាយមានគល់ស្អុយក៏ធ្លាក់ចុះអំពីកាយ ព្រោះមានអាហារតិចនោះឯង ។ ម្នាលអគ្គិវេស្សនៈ មនុស្សទាំងឡាយបានឃើញតថាគត

ឯវមាហំសុ កាឡោ សមណោ គោតមោតិ ។ ឯកច្ចេ មនុស្សា ឯវមាហំសុ ន កាឡោ សមណោ គោតមោ សាមោ សមណោ គោតមោតិ ។ ឯកច្ចេ មនុស្សា ឯវមាហំសុ ន កាឡោ សមណោ គោតមោ នបិ សាមោ មង្គុរច្ឆវី សមណោ គោតមោតិ ។ យាវស្សុ មេ អគ្គិវេស្សន តាវ បរិសុទ្ធោ ឆវិវណ្ណោ បរិយោ-ទាតោ ឧបហតោ ហោតិ តាយេវប្បាហារតាយ ។

[៦៤] តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ យេ ខោ កេចិ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា ឱបក្កមិកា ទុក្ខា តិប្បា ខរា កដុកា វេទនា វេទយឹសុ ឯតាវបរមំ នយិតោ ភិយ្យោ ។ យេ កេចិ[១] អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា ឱបក្កមិ-កា ទុក្ខា តិប្បា ខរា កដុកា វេទនា វេទិយិស្សន្តិ ឯតាវបរមំ នយិតោ ភិយ្យោ ។ យេ កេចិ[២] ឯតរហិ សមណា វា ព្រាហ្មណា វា ឱបក្កមិកា ទុក្ខា តិប្បា ខរា កដុកា វេទនា វេទិយន្តិ ឯតាវបរមំ

១-២ ឱ. ម. យេបិ ហិ កេចិ ។

ហើយពោលពាក្យយ៉ាងនេះថា ព្រះសមណគោតម មានសម្បុរខ្មៅ ។ មនុស្សពួកខ្លះនិយាយយ៉ាងនេះថា ព្រះសមណគោតមមិនខ្មៅទេ ព្រះសមណគោតមសម្បុរសណ្តែកបាយ ។ មនុស្សពួកខ្លះនិយាយយ៉ាងនេះថា ព្រះសមណគោតមមិនមែនសម្បុរខ្មៅទេ មិនមែនសម្បុរសណ្តែតបាយទេ ព្រះសមណគោតមមានសម្បុរស្បែកប្រផេះ ។ ម្នាលអគ្គិវេស្សនៈ សម្បុរស្បែក របស់តថាគត បរិសុទ្ធ ផូរផង់ដល់ម៉្លោះ ក៏ត្រឡប់ជាអាប់អន់ ព្រោះមានអាហារតិចនោះឯង ។

[៦៥] ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា ជនទាំងឡាយណានីមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងអតីតកាល បានសោយនូវទុក្ខវេទនា ដ៏ក្លៀវក្លា រឹងរូស ផ្សាខ្លោច ដែលកើតអំពីព្យាយាម មានកំណត់តែត្រឹមប៉ុណ្ណេះ មិនលើសលុបជាងនេះទៅទៀតទេ ។ ជនទាំងឡាយណានីមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងអនាគតកាល នឹងរងនូវទុក្ខវេទនា ដ៏ក្លៀវក្លា រឹងរូស ផ្សាខ្លោច ដែលកើតអំពីព្យាយាម មានកំណត់តែត្រឹមប៉ុណ្ណេះ មិនលើសលុបជាងនេះទៅទៀតទេ ។ ជនទាំងឡាយណានីមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងកាលឥឡូវនេះ តែងរងទុក្ខវេទនា ដ៏ក្លៀវក្លា រឹងរូស ផ្សាខ្លោច ដែលកើតអំពីព្យាយាម មានកំណត់តែត្រឹមប៉ុណ្ណេះ

នយិតោ ភិយ្យោ ។ ន ខោ បនាហំ ឥមាយ កដុ-កាយ ទុក្ករកិរិយាយ អធិគច្ឆាមិ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ ។ សិយា នុ ខោ អញ្ញោ មគ្គោ ពោធាយាតិ ។ តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ អភិជានាមិ ខោ បនាហំ បិតុ សក្កស្ស កម្មន្តេ សីតាយ ជម្ពុច្ឆាយាយ[១] និសិន្នោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតា សិយា នុ ខោ ឯសោ មគ្គោ ពោធាយាតិ ។ តស្ស មយ្ហំ អគ្គិវេស្សន សតានុសារីវិញ្ញាណំ អហោសិ ឯសេវ[២] មគ្គោ ពោធាយាតិ ។ តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ កិន្នុ ខោ អហំ តស្ស សុខស្ស ភាយាមិ យន្តំ សុខំ អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហីតិ ។ តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ ន ខោ អហំ តស្ស សុខស្ស ភាយាមិ យន្តំ សុខំ អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហីតិ ។

១ ជម្ពូឆាយាយាតិបិ ។ ២ ឱ. ឯសោ វ ។

មិនមានលើសលុបជាងនេះទៅទៀតទេ ។ ចំណែកខាងអាត្មាអញ មិនទាន់បានត្រាស់ដឹងនូវគុណវិសេសគឺញាណទស្សនៈដ៏ឧត្តម ដែលអាចកម្ចាត់បង់នូវកិលេសដ៏ក្រៃលែងជាងមនុស្សធម៌ ដោយទុក្ករកិរិយា ដ៏ផ្សាខ្លោចនេះ នៅឡើយ ។ ផ្លូវដទៃប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង គប្បីមានដែរឬហ្ន៎ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា កាលដែលអាត្មាអញអង្គុយនៅក្រោមម្លប់នៃដើមព្រីងដ៏ត្រជាក់ ក្នុងកិច្ចការរបស់សក្យរាជជាបិតា ក៏ធ្លាប់បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះ ហើយសម្រេចសម្រាន្តនៅ ឱហ្ន៎ នុ៎ះឯង ជាផ្លូវនៃការត្រាស់ដឹងហើយ ទេដឹង ។ ម្នាលអគ្គិវេស្សនៈ វិញ្ញាណជាគ្រឿងរលឹកតាមនូវស្មារតី ក៏កើតឡើងដល់តថាគតនោះថា ផ្លូវនុ៎ះឯងហើយ ជាផ្លូវនៃការត្រាស់ដឹង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីសុខណា ក្រៅចាកកាមទាំងឡាយ ក្រៅចាកអកុសលធម៌ទាំងឡាយ អាត្មាអញខ្លាចសេចក្តីសុខនោះ ឬហ្ន៎ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីសុខណា ក្រៅចាកកាមទាំងឡាយ ក្រៅចាកអកុសលធម៌ទាំងឡាយ អាត្មាអញ មិនខ្លាចសេចក្តីសុខនោះទេ ។

[៦៦] តស្ស មយ្ហំ អគ្គិវេស្សន ឯតទហោសិ ន ខោ តំ សុករំ សុខំ អធិគន្តុំ(១) អតិមត្តកសិមានំ បត្តកាយេន យន្នូនាហំ ឱឡារិកំ អាហារំ អាហារេយ្យំ ឱទនំ កុម្មាសន្តិ ។ សោ ខោ អហំ អគ្គិវេស្សន ឱឡារិកំ អាហារំ អាហារេសិំ ឱទនំ កុម្មាសំ ។ តេន ខោ បន សមយេន អគ្គិវេស្សន(២) បញ្ច ភិក្ខូ បច្ចុបដ្ឋិតា ហោន្តិ យន្នោ(៣) សមណោ គោតមោ ធម្មំ អធិគមិស្សតិ តន្នោ(៤) អារោចេស្សតីតិ ។ យតោ ខោ អហំ អគ្គិវេស្សន ឱឡារិកំ អាហារំ អាហារេសិំ ឱទនំ កុម្មាសំ អថ មេ តេ បញ្ច ភិក្ខូ និព្វិជ្ជ បក្កមឹសុ ពាហុល្លិកោ សមណោ គោតមោ បធានវិព្ភន្តោ អាវដ្តោ(៥) ពាហុល្លាយាតិ ។

[៦៧] សោ ខោ អហំ អគ្គិវេស្សន ឱឡារិកំ អាហារំ អាហារេត្វា ពលំ គាហេត្វា វិវិច្ចេវ កាមេហិ

---

១ ឱ. ម. អធិគន្តុំ ឯវំ ។ ២ ឱ. តេន ខោ បន មំ អគ្គិវេស្សន សមយេន ។ ៣ ម. តេន... មេ... ។ ម. យំ ខោ ។ ៤ ម. តំ ខោ នោ ។ ៥ ឱ. អាវត្តោ ។

[៦៦] ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា បុគ្គលមានកាយដល់នូវអាការស្គាំងស្គមក្រៃលែងយ៉ាងនេះ មិនងាយបាននូវសេចក្តីសុខនោះទេ បើដូច្នោះគួរតែអាត្មាអញ បរិភោគនូវអាហារដ៏គ្រោតគ្រាតគឺបាយនិងនំវិញ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯងក៏បរិភោគនូវអាហារដ៏គ្រោតគ្រាត គឺបាយនិងនំ ។ ម្នាលអគ្គិវេស្សនៈ សម័យនោះឯង ភិក្ខុទាំង ៥ រូប តាមមកបម្រើតថាគត ដោយគិតថា ព្រះសមណគោតមរបស់យើង នឹងបានត្រាស់ដឹងនូវធម៌ណា លោកនឹងប្រាប់នូវធម៌នោះ ដល់យើងទាំងឡាយ ។ ម្នាលអគ្គិវេស្សនៈ ព្រោះហេតុតែតថាគតបរិភោគនូវអាហារដ៏គ្រោតគ្រាត គឺបាយនិងនំ ក្នុងកាលណា ភិក្ខុទាំងប្រាំរូបនោះ លះបង់ រត់ចោលតថាគត ក្នុងកាលនោះ ដោយគិតថា ព្រះសមណគោតមប្រកបដោយល្មោភច្រើន ដោះចោលព្យាយាម ត្រឡប់ទៅដើម្បីសេចក្តីល្មោភច្រើន ។

[៦៧] ម្នាលអគ្គិវេស្សនៈ លុះតថាគតនោះឯង បរិភោគនូវអាហារដ៏គ្រោតគ្រាតហើយ ក៏មានកម្លាំង បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់

១២៧



វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហាសឹ ។ ឯវរូបាបិ ខោ មេ អគ្គិវេស្សន ឧប្បន្នា សុខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ។ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ... តតិយំ ឈានំ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហាសឹ ។ ឯវរូបាបិ ខោ មេ អគ្គិវេស្សន ឧប្បន្នា សុខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញ្ញាណាយ ចិត្តំ អភិនិន្នាមេសឹ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ សេយ្យថីទំ

ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខដែលកើតអំពីសេចក្ដីស្ងាត់នោះ ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់ចិត្តរបស់តថាគតបានឡើយ ។ លុះតថាគតរម្ងាប់វិតក្កៈនិងវិចារៈហើយ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្ដាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លាគឺសទ្ធា ជាសភាពនៃចិត្តដ៏ខ្ពស់ឯក ឥតមានវិតក្កៈនិងវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសមាធិគឺបឋមជ្ឈាន... ក៏បានដល់នូវតតិយជ្ឈាន... បានដល់នូវចតុត្ថជ្ឈាន ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់ចិត្តរបស់តថាគតបានឡើយ ។ កាលដែលចិត្តរបស់តថាគតខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានទីទួលពោលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ (ដោយអំណាចឈានទាំង ៤) ដោយប្រការដូច្នេះហើយ តថាគតបង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ តថាគតនោះរលឹកឃើញនូវបុព្វេនិវាសច្រើនប្រការ

ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ អយំ ខោ មេ អគ្គិវេស្សន រត្តិយា បឋមេ យាមេ បឋមា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។ ឯវរូបាបិ ខោ មេ អគ្គិវេស្សន ឧប្បន្នា សុខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ។

[៦៨] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោ-ទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញាណាយ ចិត្តំ អភិនិន្នាមេសឹ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្ត-មានុសកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ

គឺរលឹកឃើញជាតិ ១ ខ្លះ ជាតិ ២ ខ្លះ ។ បេ ។ រលឹកឃើញនូវបុព្វេនិវាស ច្រើនប្រការ ព្រមទាំងអាការគឺរូបនិងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះនិងគោត្រកូលជាដើម ដោយប្រការដូច្នេះ ។ ម្នាលអគ្គិវេស្សនៈ វិជ្ជាទី ១ នេះឯង តថាគតបានហើយក្នុងបឋមយាមនៃរាត្រី អវិជ្ជាខ្ចាត់បាត់ ទៅហើយ វិជ្ជាក៏កើតឡើង សេចក្តីងងឹតខ្ចាត់បាត់ទៅហើយ ពន្លឺក៏ កើតឡើងដល់តថាគត ដូចបុគ្គលដែលមិនប្រមាទ មានព្យាយាមញុាំង កិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដែលបាននូវវិជ្ជាទី ១ នោះដែរ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

[៦៨] កាលបើចិត្តរបស់តថាគតខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិន មានទីទួលពោលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្ត ទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ ដោយប្រការដូច្នេះហើយ តថាគតក៏បង្អោនចិត្តទៅ ដើម្បីសត្តចុតូបបា-តញ្ញាណ ។ តថាគតនោះ មានចក្ខុដូចជាទិព្វដ៏ស្អាត កន្លងហួសចក្ខុ របស់មនុស្សធម្មតា ក៏បានឃើញនូវពួកសត្វដែលច្យុត ដែលកើតឡើង

ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាមិ ។ បេ ។ អយំ ខោ មេ អគ្គិវេស្សន រត្តិយា មជ្ឈិមេ យាមេ ទុតិយា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។ ឯវរូបាបិ ខោ មេ អគ្គិវេស្សន ឧប្បន្នា សុខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ។

[៦៩] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញាណាយ ចិត្តំ អភិនិន្នាមេសឹ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខសមុទយោតិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ ឥមេ អាសវាតិ យថាភូតំ អព្ភញ្ញាសឹ

ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានរូបល្អខ្លះ រូបអាក្រក់ខ្លះ មានគតិល្អខ្លះ គតិអាក្រក់ខ្លះ មួយវិញទៀត តថាគតដឹងច្បាស់ នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្ម ។ បេ ។ ម្នាលអគ្គិវេស្សនៈ វិជ្ជាទី ២ នេះឯងតថាគតបានហើយក្នុងមជ្ឈិមយាមនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅហើយ វិជ្ជាក៏កើតឡើង សេចក្ដីងងឹតខ្ចាត់បាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគតដូចបុគ្គលដែលមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឲ្យក្ដៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដែលបាននូវវិជ្ជាទី ២ ដូច្នោះដែរ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

[៦៩] កាលបើចិត្តរបស់តថាគតខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួលពោលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ តថាគតក៏បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ ។ តថាគតនោះបានដឹងច្បាស់តាមពិតថា នេះជាទុក្ខ បានដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ បានដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ បានដឹងច្បាស់តាមពិតថា នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ បានដឹងច្បាស់តាមពិតថា នេះជាអាសវៈ បានដឹងច្បាស់

អយំ អាសវសមុទយោតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវនិរោធោតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ ។ តស្ស មេ ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចិត្ថ ភវាសវាបិ ចិត្តំ វិមុច្ចិត្ថ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចិត្ថ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសឹ ។ អយំ ខោ មេ អគ្គិវេស្សន រត្តិយា បច្ឆិមេ យាមេ តតិយា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។ ឯវរូបាបិ ខោ មេ អគ្គិវេស្សន ឧប្បន្នា សុខា វេទនា ចិត្តំ ន បរិយាទាយ តិដ្ឋតិ ។

[៧០] អភិជានាមិ ខោ បនាហំ អគ្គិវេស្សន អនេកសតាយ បរិសាយ ធម្មំ ទេសេតា ។ អបិស្សុ មំ ឯកមេកោ ឯវំ មញ្ញតិ មមេវារព្ភ សមណោ គោតមោ ធម្មំ ទេសេតីតិ ។ ន ខោ បនេតំ អគ្គិវេស្សន

តាមពិតថា នេះជាធម៌នាំឲ្យកើតអាសវៈ បានដឹងច្បាស់តាមពិតថា នេះជាទីរលត់អាសវៈ បានដឹងច្បាស់តាមពិតថា នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់អាសវៈ ។ កាលបើតថាគតនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តរបស់តថាគតរួចចាកកាមាសវៈផង ចិត្តរបស់តថាគតរួចចាកភវាសវៈផង ចិត្តរបស់តថាគត រួចចាកអវិជ្ជាសវៈផង ។ បេ ។ តថាគតដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ម្នាលអគ្គិវេស្សនៈ វិជ្ជាទី ៣ នេះឯង តថាគតបានហើយក្នុងបច្ឆិមយាមនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅហើយ វិជ្ជាក៏កើតឡើង សេចក្តីងងឹតខ្ចាត់បាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគតដូចបុគ្គលដែលមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដែលបាននូវវិជ្ជាទី ៣ ដូច្នោះដែរ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

[៧០] ម្នាលអគ្គិវេស្សនៈ តថាគតធ្លាប់ជាអ្នកសំដែងធម៌ដល់បរិស័ទច្រើនរយ ។ ជនម្នាក់ ៗ សំគាល់តថាគតយ៉ាងនេះថា ព្រះសមណគោតម សំដែងធម៌ចំពោះអញតែម្នាក់ឯង ។ ម្នាលអគ្គិវេស្សនៈ ចំណែក

១៣១



ឯវំ ធម្មំ យាវទេវ វិញ្ញាបនត្ថាយ តថាគតោ សម្មទេវ តេសំ ធម្មំ ទេសេតីតិ ។ សោ ខោ អហំ អគ្គិវេស្សន តស្សាយេវ កថាយ បរិយោសានេ តស្មឹយេវ បុរិមស្មឹ សមាធិនិមិត្តេ អជ្ឈត្តមេវ ចិត្តំ សណ្ឋបេមិ សន្និសីទាមិ សមាទហាមិ ឯកោទឹ ករោមិ[១] យេន សុទំ និច្ចកប្បំ វិហរាមីតិ ។ ឱកប្បនីយមេតំ ភោតោ គោតមស្ស យថាតំ អរហតោ សម្មាសម្ពុទ្ធស្ស អភិជានាតិ ខោ[២] បន ភវំ គោតមោ ទិវា សុបិតាតិ ។ អភិជានាមហំ អគ្គិវេស្សន គិម្ហានំ បច្ឆិមេ មាសេ បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តោ ចតុគ្គុណំ សង្ឃាដឹ បញ្ញាបេត្វា ទក្ខិណេន បស្សេន សតោ សម្បជានោ និទ្ទំ ឱក្កមិតាតិ ។ ឯតំ ខោ ភោ គោតម ឯកេ សមណព្រាហ្មណា[៣] សម្មោហវិហារស្មឹ វទន្តីតិ ។ ន ខោ អគ្គិវេស្សន ឯត្តាវតា សម្មូឡ្ហោ វា ហោតិ អសម្មូឡ្ហោ វា អបិច អគ្គិវេស្សន យថា សម្មូឡ្ហោ វា

១ ឱ. ម. សន្និសាទេមិ ឯកោទឹ ករោមិ សមាទហាមីតិ ទិស្សន្តិ ។ ២ ឱ. ខោសទ្ទោ នត្ថិ ។ ៣ ម. សមណា វា ព្រាហ្មណា វា ។

អ្នកកុំគប្បីយល់ឃើញយ៉ាងនេះថា ព្រះតថាគតសំដែងធម៌ ដល់ជនទាំង-ឡាយនោះ ដោយប្រពៃ ដើម្បីប្រយោជន៍ឲ្យគ្រាន់តែចេះដឹងប៉ុណ្ណោះដូច្នេះឡើយ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង តែងនៅអស់កាលជានិច្ច ដោយផលសមាធិណា កាលបើចប់គាថានោះហើយ តថាគតក៏តម្រង់ ទប់ទល់ តម្កល់ចិត្តខាងក្នុង ធ្វើឲ្យជាចិត្តមានអារម្មណ៍តែមួយ ក្នុងសមាធិនិមិត្តដែលមានហើយ អំពីមុននោះឯង ដោយផលសមាធិនោះ ។ សច្ចកនិគន្ថបុត្រពោលថា ពាក្យរបស់ព្រះគោតមដ៏ចម្រើន ដែលជាអរហន្តសម្មាសម្ពុទ្ធនេះ ជាពាក្យគួរជឿពិតហើយ ចុះព្រះគោតមដ៏ចម្រើន ធ្លាប់ផ្ទំលក់ក្នុងវេលាថ្ងៃឬទេ ។ ម្នាលអគ្គិវេស្សនៈ តថាគតត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាបច្ឆាភត្ត ហើយក្រាលនូវសង្ឃាដីមានជាន់ ៤ ហើយធ្លាប់សិងដោយចំហៀងខាងស្តាំ មានសតិនិងសម្បជញ្ញៈចុះស៊ប់កាន់កិរិយាលក់ ក្នុងខែជាទីបំផុត នៃគិម្ហរដូវ ។ បពិត្រព្រះគោតមដ៏ចម្រើន សមណព្រាហ្មណ៍ពួកខ្លះ ពោលនូវកិរិយាដេកលក់នេះឯង ថាជាធម៌ជាគ្រឿងនៅ ប្រកបដោយសេចក្តីវង្វេង ។ ម្នាលអគ្គិវេស្សនៈ បុគ្គលវង្វេងក្តី មិនវង្វេងក្តី មិនមានដោយហេតុប៉ុណ្ណោះឡើយ ម្នាលអគ្គិវេស្សនៈ មួយយ៉ាងទៀត បុគ្គលវង្វេងក្តី

ហោតិ អសម្មូឡ្ហោ វា តំ សុណាហិ សាធុកំ មនសិ-
ករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ សច្ចកោ
និគណ្ឋបុត្តោ ភគវតោ បច្ចស្សោសិ ។

[៧១] ភគវា ឯតទវោច កថញ្ច អគ្គិវេស្សន
សម្មូឡ្ហោ ហោតិ យស្ស កស្សចិ អគ្គិវេស្សន យេ
អាសវា សង្កិលេសិកា បោនោព្ភវិកា សទរា
ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា អប្បហីនា
តមហំ សម្មូឡ្ហោតិ វទាមិ អាសវានំ ហិ អគ្គិវេស្សន
អប្បហានា សម្មូឡ្ហោ ហោតិ យស្ស កស្សចិ អគ្គិ-
វេស្សន យេ អាសវា សង្កិលេសិកា បោនោព្ភវិកា
សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា
បហីនា តមហំ អសម្មូឡ្ហោតិ វទាមិ អាសវានំ
ហិ អគ្គិវេស្សន បហានា អសម្មូឡ្ហោ ហោតិ ។
តថាគតស្ស ខោ អគ្គិវេស្សន យេ អាសវា

មិនវង្វេងក្តី ដោយហេតុណា អ្នកចូរស្តាប់ នូវហេតុនោះចុះ ចូរយកចិត្តទុកដាក់ឲ្យស្រួលបួលចុះ តថាគតនឹងសំដែងឲ្យស្តាប់ ។ សច្ចកនិគន្ថបុត្រ ក៏ទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគដូច្នេះថា ព្រះករុណា ព្រះអង្គ ។

[៧១] ព្រះមានព្រះភាគ ទ្រង់សំដែងដូច្នេះថា ម្នាលអគ្គិវេស្សនៈ បុគ្គលវង្វេងតើដូចម្តេច ម្នាលអគ្គិវេស្សនៈ អាសវៈទាំងឡាយណាជាធម៌ដ៏សៅហ្មង នាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានវិបាកជាទុក្ខ ប្រកបដោយជាតិនិងជរាមរណៈតទៅ បុគ្គលណានីមួយមិនបានលះចោលចេញហើយ តថាគតហៅបុគ្គលនោះ ថាជាអ្នកវង្វេង ម្នាលអគ្គិវេស្សនៈ ព្រោះថាបុគ្គលដែលឈ្មោះថាវង្វេងព្រោះហេតុតែមិនបានលះបង់ចោលនូវអាសវៈទាំងឡាយ ម្នាលអគ្គិវេស្សនៈ អាសវៈទាំងឡាយណា ជាធម៌ដ៏សៅហ្មង នាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានវិបាកជាទុក្ខ ប្រកបដោយជាតិនិងជរាមរណៈតទៅ បុគ្គលណានីមួយ បានលះបង់ចេញហើយ តថាគតហៅបុគ្គលនោះ ថាជាអ្នកមិនវង្វេង ម្នាលអគ្គិវេស្សនៈ ព្រោះថាបុគ្គលដែលឈ្មោះថា មិនវង្វេង ព្រោះបានលះបង់នូវអាសវៈទាំងឡាយចេញស្រឡះហើយ ។ ម្នាលអគ្គិវេស្សនៈ អាសវៈទាំងឡាយណា

សង្កិលេសិកា ចោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ សេយ្យថាបិ នាម អគ្គិវេស្សន តាលោ មត្ថកច្ឆិន្នោ អភព្វោ បុន វិរូឡ្ហិយា ឯវមេវ ខោ អគ្គិវេស្សន តថាគតស្ស យេ អាសវា សង្កិលេសិកា ចោនោ-ព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជ-រាមរណីយា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មាតិ ។

[៧២] ឯវំ វុត្តេ សច្ចកោ និគណ្ឋបុត្តោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម

ជាធម៌ដ៏សៅហ្មង នាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានវិបាកជាទុក្ខ ប្រកបដោយជាតិនិងជរាមរណៈតទៅ តថាគតបានលះបង់ស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ[១] ដូចជាទីនៅរបស់ដើមត្នោត ធ្វើមិនឲ្យបម្រើនតទៅទៀត មានសភាពមិនកើតឡើងតទៅ ។ ម្នាលអគ្គិវេស្សនៈ ដើមត្នោតកំបុតកមិនគួរលូតលាស់ដុះឡើងវិញបាន យ៉ាងណាមិញ ម្នាលអគ្គិវេស្សនៈ អាសវៈទាំងឡាយណា ជាធម៌ដ៏សៅហ្មង នាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានវិបាកជាទុក្ខ ប្រកបដោយជាតិនិងជរាមរណៈតទៅ តថាគតបានលះបង់ចេញស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅរបស់ដើមត្នោត បានធ្វើមិនឲ្យបម្រើនតទៅទៀត មានសភាពមិនកើតឡើងតទៅ យ៉ាងនេះឯង ។

[៧២] កាលដែលព្រះមានព្រះភាគ ទ្រង់ប្រកាសយ៉ាងនេះហើយ សច្ចកនិគន្ថបុត្រ ក៏និយាយដូច្នេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចំឡែកណាស់

---

១ ទីនៅក្នុងទីនេះសំដៅយកចិត្តសន្តាន គឺព្រះតថាគតធ្វើអាសវៈឲ្យអស់ទៅ នៅសល់តែចិត្តសន្តាន ប្រៀបដូចជាដើមត្នោតគេគាស់រំលើងចោលចេញ នៅសល់តែកន្លែងនោះ ហៅថាទីនៅរបស់ដើមត្នោត ។ អដ្ឋកថា ។

យាវញ្ចិទំ ភោតោ គោតមស្ស ឯវំ អាសជ្ជ អាសជ្ជ វុច្ចមានស្ស ឧបនីតេហិ វចនបថេហិ សមុទាចរិយមានស្ស ឆវិវណ្ណោ ចេវ បរិយោទាយតិ មុខវណ្ណោ ច វិប្បសីទតិ យថាតំ អរហតោ សម្មាសម្ពុទ្ធស្ស អភិជានាមហំ ភោ គោតម បូរណំ កស្សបំ វាទេន វាទំ សមារភិតា សោបិ មយា វាទេន វាទំ សមារទ្ធោ អញ្ញេនញ្ញំ បដិចរិ ពហិទ្ធា កថំ អបនាមេសិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាត្វាកាសិ ភោតោ បន គោតមស្ស ឯវំ អាសជ្ជ អាសជ្ជ វុច្ចមានស្ស ឧបនីតេហិ វចនបថេហិ សមុទាចរិយមានស្ស ឆវិវណ្ណោ ចេវ បរិយោទាយតិ មុខវណ្ណោ ច វិប្បសីទតិ យថាតំ អរហតោ សម្មាសម្ពុទ្ធស្ស អភិជានាមហំ ភោ គោតម មក្ខលឹ គោសាលំ... អជិតំ កេសកម្ពលំ... បកុធំ កច្ចាយនំ... សញ្ជយំ វេលដ្ឋបុត្តំ... និគន្ថំ នាដបុត្តំ វាទេន វាទំ សមារភិតា សោបិ មយា វាទេន វាទំ សមារទ្ធោ

(ព្រោះ) ព្រះគោតមដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គពោលសង្កត់សង្កិន និយាយដោយគន្ទងពាក្យជ្រៀតបៀតផ្សេង ៗ យ៉ាងនេះ ក៏នៅតែមានព្រះឆវិវណ្ណផូរផង់ ទាំងសម្បុរព្រះភក្ត្រទៀតក៏ថ្លាស្រស់បស់ ព្រោះថាព្រះអង្គសមជាព្រះអរហន្តសម្មាសម្ពុទ្ធពិត បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គធ្លាប់លើកឡើងនូវទោសដោយពាក្យចំពោះបូរណកស្សប ឯបូរណកស្សបនោះ លុះខ្ញុំព្រះអង្គលើកឡើងនូវទោសដោយពាក្យហើយ ក៏បិទបាំងនូវពាក្យដទៃដោយពាក្យដទៃ ហើយច្រានពាក្យចោលទៅខាងក្រៅហើយធ្វើនូវសេចក្ដីក្រោធផង ទោសៈផង សេចក្ដីមិនត្រេកអរផង ឲ្យប្រាកដឡើង ចំណែកព្រះគោតមដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គពោលសង្កត់សង្កិននិយាយដោយគន្ទងពាក្យជ្រៀតបៀតផ្សេង ៗ យ៉ាងនេះ ក៏នៅតែមានព្រះឆវិវណ្ណផូរផង់ ទាំងសម្បុរព្រះភក្ត្រទៀត ក៏ថ្លាស្រស់បស់ ព្រោះថា ព្រះអង្គសមជាព្រះអរហន្តសម្មាសម្ពុទ្ធពិត បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គធ្លាប់លើកឡើងនូវទោស ដោយពាក្យចំពោះមក្ខលិ-គោសាល... ចំពោះអជិតកេសកម្ពល... ចំពោះបកុធកច្ចាយនៈ... ចំពោះសញ្ជយវេលដ្ឋបុត្ត... លើកឡើងនូវទោសដោយពាក្យចំពោះនិគន្ថនាដ-បុត្ត ឯនិគន្ថនាដបុត្រនោះ លុះខ្ញុំព្រះអង្គលើកឡើងនូវទោសដោយពាក្យ

១៣៤



អញ្ញេនញ្ញំ បដិចរិ ពហិទ្ធា កថំ អបនាមេសិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាត្វាកាសិ ភោតោ បន គោតមស្ស ឯវំ អាសជ្ជ អាសជ្ជ វុច្ចមានស្ស ឧបនីតេហិ វចនបថេហិ សមុទាចរិយ-មានស្ស ឆវិវណ្ណោ ចេវ បរិយោទាយតិ មុខវណ្ណោ ច វិប្បសីទតិ យថាតំ អរហតោ សម្មាសម្ពុទ្ធស្ស ហន្ទ ចទានិ មយំ ភោ គោតម គច្ឆាម ពហុកិច្ចា ពហុករណីយាតិ ។ យស្សទានិ ត្វំ អគ្គិវេស្សន កាលំ មញ្ញសីតិ ។ អថខោ សច្ចកោ និគន្ថបុត្តោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយា-សនា បក្កាមីតិ ។

មហាសច្ចកសុត្តំ ឆដ្ឋំ និដ្ឋិតំ ។

ហើយ ក៏បិទបាំងនូវពាក្យដទៃដោយពាក្យដទៃ ហើយប្រាទពាក្យចោលខាងក្រៅ ហើយធ្វើនូវសេចក្ដីក្រោធផង ទោសៈផង សេចក្ដីមិនត្រេកអរផងឲ្យប្រាកដឡើង ចំណែកព្រះគោតមដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គពោលសង្កត់សង្កិននិយាយដោយគន្លងពាក្យជ្រៀតបៀតផ្សេង ៗ យ៉ាងនេះហើយ ក៏នៅតែមានព្រះឆវីវណ្ណផូរផង់ ទាំងសម្បុរព្រះភក្ត្រទៀតក៏ថ្លាស្រស់បស់ ព្រោះព្រះអង្គសមជាព្រះអរហន្តសម្មាសម្ពុទ្ធពិត ប៉ុណ្ណឹងចុះព្រះគោតមដ៏ចម្រើន ឥឡូវនេះខ្ញុំព្រះអង្គសូមលាទៅ ព្រោះមានកិច្ចច្រើនមានការងារច្រើន ។ ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាថា ម្នាលអគ្គិវេស្សនៈ ឥឡូវនេះ អ្នកសំគាល់នូវកាលដែលគួរនឹងត្រឡប់ទៅវិញចុះ ។ លំដាប់នោះ សច្ចកនិគន្ថបុត្រត្រេកអរ រីករាយហើយចំពោះភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកចាកទីអង្គុយ ចៀសចេញទៅ ។

ចប់ មហាសច្ចកសូត្រ ទី ៦ ។

# សត្តមំ ចូឡតណ្ហាសង្ខយសុត្តំ

[៧៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុ ចាសាទេ ។ អថខោ សក្កោ ទេវានមិន្ទោ យេន ភគវា តេនុប-សង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ បិតោ ខោ សក្កោ ទេវានមិន្ទោ ភគវន្តំ ឯតទវោច កិត្តាវតា នុ ខោ ភន្តេ ភិក្ខុ សង្ខិត្តេន តណ្ហាសង្ខយវិមុត្តោ ហោតិ អច្ចន្តនិដ្ឋោ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានន្តិ ។

[៧៤] ឥធ ទេវានមិន្ទ ភិក្ខុនោ សុតំ ហោតិ សព្វេ ធម្មា នាលំ អភិនិវេសាយាតិ ឯវញ្ចេ តំ ទេវាន-មិន្ទ ភិក្ខុនោ សុតំ ហោតិ សព្វេ ធម្មា នាលំ អភិនិវេសាយាតិ សោ សព្វំ ធម្មំ អភិជានាតិ

# ចូឡតណ្ហាសង្ខយសូត្រ ទី ៧

[៧៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងប្រាសាទរបស់មិគារមាតា នាវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ គ្រានោះឯង សក្កទេវរាជជាធំជាងពួកទេវតា ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចឋិតនៅក្នុងទីដ៏សមគួរ ។ លុះសក្កទេវរាជ ជាធំជាងពួកទេវតា ឋិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាអ្នកមានចិត្តបង្អោនទៅក្នុងព្រះនិព្វានជាទីក្ស័យទៅនៃតណ្ហា ជាអ្នកមានសេចក្តីចូលចិត្តទៀង មានសេចក្តីក្សេមក្សាន្តចាកយោគៈទៀង ជាអ្នកប្រព្រឹត្តដ៏ប្រសើរទៀង មានទីបំផុតទៀងទាត់ ជាបុគ្គលប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ដោយសង្ខេប តើមានប៉ុន្មាន ។

[៧៤] ព្រះអង្គត្រាស់ថា បពិត្រទេវានមិន្ទៈ ភិក្ខុក្នុងសាសនានេះ បានស្តាប់ពាក្យថា បុគ្គលមិនគួរប្រកាន់នូវធម៌ទាំងពួង[១] (ដោយអំណាចតណ្ហានិងទិដ្ឋិ) បពិត្រទេវានមិន្ទៈ លុះភិក្ខុបានស្តាប់ពាក្យនុ៎ះថា បុគ្គលមិនគួរប្រកាន់នូវធម៌ទាំងពួងយ៉ាងនេះហើយ ភិក្ខុនោះរមែងដឹងច្បាស់ នូវធម៌

---

១ ធមិទាំងពួងក្នុងទីនេះ បានដល់ខន្ធ ៥ អាយតនៈ ១២ និងធាតុ ១៨ ។ អដ្ឋកថា ។

មហាយមកវគ្គស្ស ចូឡតណ្ហាសង្ខយសុត្តេ សង្ខិត្តេន វិមុត្តិកថា

សព្វំ ធម្មំ អភិញ្ញាយ សព្វំ ធម្មំ បរិជានាតិ
សព្វំ ធម្មំ បរិញ្ញាយ យំ កិញ្ចិ វេទនំ វេទេតិ
សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សោ
តាសុ វេទនាសុ អនិច្ចានុបស្សី វិហរតិ វិរាគានុបស្សី
វិហរតិ និរោធានុបស្សី វិហរតិ បដិនិស្សគ្គានុបស្សី
វិហរតិ សោ តាសុ វេទនាសុ អនិច្ចានុបស្សី វិហរន្តោ
វិរាគានុបស្សី វិហរន្តោ និរោធានុបស្សី វិហរន្តោ
បដិនិស្សគ្គានុបស្សី វិហរន្តោ ន កិញ្ចិ លោកេ
ឧបាទិយតិ អនុបាទិយំ ន បរិតស្សតិ អបរិតស្សំ
បច្ចត្តញ្ញេវ បរិនិព្វាយតិ ខីណា ជាតិ វុសិតំ ព្រហ្មច-
រិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ
ឯត្តាវតា ខោ ទេវានមិន្ទ ភិក្ខុ សង្ខិត្តេន តណ្ហាសង្ខ-
យវិមុត្តោ ហោតិ អច្ចន្តនិដ្ឋោ អច្ចន្តយោគក្ខេមី អច្ចន្ត-
ព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានន្តិ ។

ទាំងពួង លុះដឹងច្បាស់នូវធម៌ទាំងពួងហើយ រមែងកំណត់ដឹងនូវធម៌ទាំងពួង លុះកំណត់ដឹងនូវធម៌ទាំងពួងហើយ រមែងសោយនូវវេទនាណាមួយ ជាសុខឬជាទុក្ខ ឬមិនទុក្ខមិនសុខ ភិក្ខុនោះជាអ្នកពិចារណាឃើញថាមិនទៀង ពិចារណាឃើញថាជាទីប្រាសចាកតម្រេក ពិចារ-ណាឃើញថាជាគ្រឿងរំលត់ ពិចារណាឃើញថាគួរលះបង់ ក្នុងវេទនាទាំងឡាយនោះ កាលបើភិក្ខុនោះ ពិចារណាឃើញថាមិនទៀង ពិចារ-ណាឃើញថាជាទីប្រាសចាកតម្រេក ពិចារណាឃើញថាជាគ្រឿងរំលត់ ពិចារណាឃើញថាគួរលះបង់ ក្នុងវេទនាទាំងឡាយនោះហើយ ក៏មិនបានប្រកាន់នូវធម្មជាតអ្វីតិចតួចក្នុងលោកឡើយ កាលបើមិនប្រកាន់ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុត ក៏រំលត់កិលេសដោយខ្លួនឯងបាន ទើបដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានអប់រំហើយ កិច្ចដែលត្រូវធ្វើ អាត្មាអញក៏បានធ្វើហើយ កិច្ចដទៃក្រៅអំពីកិច្ចនេះ មិនមានឡើយ បពិត្រទេវានមិន្ទៈ ភិក្ខុជាអ្នកបង្អោនចិត្តទៅក្នុងព្រះនិព្វាន ជាទីក្ស័យទៅនៃតណ្ហា ជាអ្នកមានសេចក្តីចូលចិត្តទៀង មានសេចក្តីក្សេមក្សាន្តចាកយោគៈទៀង ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរទៀង មានទីបំផុតទៀងទាត់ ជាបុគ្គលប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ដោយសង្ខេប មានប្រមាណប៉ុណ្ណោះឯង ។

អថខោ សក្កោ ទេវានមិន្ទោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ។

[៧៥] តេន ខោ បន សមយេន អាយស្មា មហាមោគ្គល្លានោ ភគវតោ អវិទូរេ និសិន្នោ ហោតិ ។ អថខោ អាយស្មតោ មហាមោគ្គល្លានស្ស ឯតទហោសិ កិន្នុ ខោ សោ យក្ខោ ភគវតោ ភាសិតំ អភិសមេច្ច អនុមោទតិ[១] ឧទាហុ នោតិ យន្នូនាហំ តំ យក្ខំ ជានេយ្យំ យទិ វា សោ យក្ខោ ភគវតោ ភាសិតំ អភិសមេច្ច អនុមោទតិ យទិ វា នោតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ បុព្វារាមេ មិគារមាតុ បាសាទេ អន្តរហិតោ ទេវេសុ តាវតឹសេសុ បាតុរហោសិ ។ តេន ខោ បន សមយេន សក្កោ ទេវានមិន្ទោ

១ ឱ. ម. អនុមោទិ ។

លំដាប់នោះ សក្កទេវរាជជាធំជាងពួកទេវតាត្រៃត្រឹង្ស អនុមោទនានូវភាសិតរបស់ព្រះមានព្រះភាគ ហើយក្រាបបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ រួចស្រាប់តែបាត់ចាកទីនោះមួយរំពេច ។

[៧៥] ចួនជាសម័យនោះឯង ព្រះមហាមោគ្គល្លានមានអាយុគង់នៅ ក្នុងទីជិតព្រះមានព្រះភាគ ។ ទើបព្រះមហាមោគ្គល្លាន មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ទេវតានោះបានដឹងនូវភាសិតរបស់ព្រះមានព្រះភាគ ហើយអនុមោទនា ឬមិនបានដឹងទេ ហើយអនុមោទនា ទោះបីទេវតានោះដឹងនូវភាសិតរបស់ព្រះមានព្រះភាគ ហើយបានអនុមោ-ទនាក្តី មិនបានដឹងហើយ អនុមោទនាក្តី គួរតែអាត្មាអញស្គាល់ទេវតានោះ ។ គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ ក៏បាត់អំពីវត្តបុព្វារាម ជាមិគារមាតុប្រាសាទ មួយរំពេច ហើយក៏ទៅប្រាកដនៅនាឋានតាវត្តិង្សទេវលោក ដូចបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញដូច្នោះឯង ។ សម័យនោះឯង ព្រះឥន្ទ្រាធិរាជ

ឯកបុណ្ឌរីកេ ឧយ្យានេ ទិព្វេហិ បញ្ចហិ តុរិយសតេហិ សមប្បិតោ សមង្គីភូតោ បរិចារេតិ ។ អទ្ទសា ខោ សក្កោ ទេវានមិន្ទោ អាយស្មន្តំ មហាមោគ្គល្លានំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន តានិ ទិព្វានិ បញ្ច តុរិយសតានិ បដិបណាមេត្វា យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច ឯហិ ខោ មារិស មោគ្គល្លាន ស្វាគតំ មោគ្គល្លាន ចិរស្សំ ខោ មារិស មោគ្គល្លាន ឥមំ បរិយាយមកាសិ យទិទំ ឥធាគមនាយ និសីទ មារិស មោគ្គល្លាន ឥទមាសនំ បញ្ញត្តន្តិ ។ និសីទិ ខោ អាយស្មា មហាមោគ្គល្លានោ បញ្ញត្តេ អាសនេ ។ សក្កោបិ ខោ ទេវានមិន្ទោ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។

[៧៦] ឯកមន្តំ និសិន្នំ ខោ សក្កំ ទេវានមិន្ទំ អាយស្មា មហាមោគ្គល្លានោ ឯតទវោច យថាកថំ បន តេ កោសិយ ភគវា សង្ខិត្តេន តណ្ហាសង្ខយវិមុត្តឹ

កំពុងតែក្រសាលសប្បាយរីករាយស្កប់ស្កល់ ដោយតូរ្យតន្ត្រីជាទិព្វ ទាំង ប្រាំរយក្នុងឱទ្យានឈ្មោះឯកបុណ្ឌរីកៈ ។ ព្រះឥន្ទ្រាធិរាជបានឃើញព្រះ មហាមោគ្គល្លានមានអាយុនិមន្តមកពីចម្ងាយលិម ៗ លុះឃើញហើយក៏ បញ្ឈប់នូវតូរ្យតន្ត្រីជាទិព្វទាំងប្រាំរយនោះ ហើយចូលទៅរកព្រះមហា-មោគ្គល្លានមានអាយុ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹង ព្រះមហាមោគ្គល្លានមានអាយុថា បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ សូម និមន្តមក បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ លោកម្ចាស់និមន្តមកនេះ ជា ការស្រួលហើយ បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ លោកម្ចាស់ខានធ្វើបរិ-យាយដើម្បីនិមន្តមកក្នុងទីនេះ ជាយូរហើយ បពិត្រព្រះមោគ្គល្លានអ្នក និទ៌ុក្ខ សូមលោកម្ចាស់និមន្តគង់ចុះ អាសនៈនេះហើយខ្ញុំព្រះករុណា ក្រាលទុកប្រគេន ។ ព្រះមហាមោគ្គល្លានមានអាយុ ក៏គង់លើអាសនៈ ដែលព្រះឥន្ទ្រាធិរាជក្រាលប្រគេន ។ ចំណែកព្រះឥន្ទ្រាធិរាជ ក៏ កាន់យកអាសនៈទាបមួយ គង់ក្នុងទីដ៏សមគួរ ។

[៧៦] លុះព្រះឥន្ទ្រាធិរាជគង់ក្នុងទីដ៏សមគួរហើយ ព្រះមហា-មោគ្គល្លានមានអាយុ បានសួរសេចក្ដីនេះថា បពិត្រកោសិយៈ ព្រះ មានព្រះភាគ បានត្រាស់សំដែងនូវកិរិយាបង្អោនចិត្តទៅកាន់ព្រះនិព្វាន ជាទីអស់ទៅនៃតណ្ហា ដោយសេចក្ដីសង្ខេបចំពោះមហារាជ ដូចម្ដេចខ្វះ

អកាសិ សាធុ មយម្បិ ឯតិស្សា កថាយ ភាគិនោ អស្សាម សវនាយាតិ ។ មយំ ខោ មារិស មោគ្គល្លាន ពហុកិច្ចា ពហុករណីយា អប្បេវ នាម សកេន ករណីយេន អបិច ទេវានំយេវ[១] តាវត្តឹសានំ ករណីយេន អបិច មារិស មោគ្គល្លាន សុស្សុតំយេវ[២] ហោតិ សុគហិតំ សុមនសិកតំ សុបធារិតំ យន្នោ ខោ[៣] ខិប្បមេវ អន្តរធាយតិ ភូតបុព្វំ មារិស មោគ្គល្លាន ទេវាសុរសង្គាមោ សមូបព្យុឡ្ហោ អហោសិ តស្មឹ ខោ បន មារិស មោគ្គល្លាន សង្គាមេ ទេវា ជិនឹសុ អសុរា បរាជិនឹសុ សោ ខោ អហំ មារិស មោគ្គល្លាន ទេវាសុរសង្គាមំ[៤] អភិវិជិនិត្វា វិជិតសង្គាមោ តតោ បដិនិវត្តិត្វា វេជយន្តំ នាម បាសាទំ មាបេសឹ វេជយន្តស្ស ខោ បន មារិស មោគ្គល្លាន បាសាទស្ស ឯកសតំ និយ្យូហំ ឯកមេកស្មឹ[៥] និយ្យូហេ សត្ត សត្ត កូដាគារសតានិ ឯកមេកស្មឹ កូដាគារេ

---

១ ម. ទេវានំ ចេវ ។ ២ ម. សុស្សុតំ ចេវ ។ ៣ ម. យំ នោ ។ ៤ ឱ. ម. តំ សង្គាមំ ។ ៥ ម. ឯកេកស្មឹ ។

សូមព្រះរាជានុញ្ញាតចុះ ដ្បិតអាត្មាភាពជាអ្នកមានចំណែកដើម្បីស្តាប់ធម្មកថានេះផង ។ សក្កទេវរាជមានព្រះរាជឱង្ការតបថា បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ ធ្វើដូចម្តេចខ្ញុំព្រះករុណាជាអ្នកមានកិច្ចច្រើន មានការងារត្រូវធ្វើច្រើន ដោយការងារដែលត្រូវធ្វើផ្ទាល់ខ្លួនផង ដោយការងារដែលត្រូវធ្វើចំពោះពួកទេវតា ក្នុងជាន់តាវត្តិង្សផង បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ ឯពាក្យដែលខ្ញុំព្រះករុណាបានស្តាប់ត្រាប់ត្រង់ ធ្វើទុកក្នុងចិត្ត ចាំទុកស្រួលបួលហើយ ពាក្យនោះក៏បាត់ទៅមួយរំពេច បពិត្រព្រះមោគ្គល្លាន អ្នកនិទ៌ុក្ខ ពីព្រេងនាយមក មានសង្គ្រាមទេវតានឹងអសុរលើកជាក្បួនទ័ព បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ ប៉ុន្តែក្នុងសង្គ្រាមនោះ ពួកទេវតាមានជ័យជំនះ ឯពួកអសុរក៏បរាជ័យ បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ លុះខ្ញុំព្រះករុណានោះ បានឈ្នះសង្គ្រាមទេវតានឹងអសុរហើយត្រឡប់មកអំពីទីនោះវិញ ក៏និម្មិតប្រាសាទឈ្មោះវេជយន្ត បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ ប្រាសាទវេជយន្ត (នោះ) មានដំបូលមួយរយក្នុងដំបូលមួយ ៗ មានផ្ទះកំពូលប្រាំពីររយ ៗ ក្នុងផ្ទះកំពូលមួយ ៗ

សត្ត សត្ត អច្ឆរាយោ ឯកមេកិស្សា អច្ឆរាយ សត្ត សត្ត បរិចារិកាយោ ឥច្ឆេយ្យាសិ នោ ត្វំ មារិស មោគ្គល្លាន វេជយន្តស្ស បាសាទស្ស រាមណេយ្យកំ ទដ្ឋុន្តិ ។ អធិវាសេសិ ខោ អាយស្មា មហាមោគ្គល្លានោ តុណ្ហីភាវេន ។

[៧៧] អថខោ សក្កោ ច ទេវានមិន្ទោ វេស្សវណោ ច មហារាជា អាយស្មន្តំ មហាមោគ្គល្លានំ បុរក្ខត្វា យេន វេជយន្តោ បាសាទោ តេនុបសង្កមឹសុ ។ អទ្ទសាសុំ[១] ខោ សក្កស្ស ទេវានមិន្ទស្ស បរិចារិកាយោ អាយស្មន្តំ មហាមោគ្គល្លានំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន ឱត្តប្បមានា ហិរិយមានា សកំ សកំ ឱវរកំ បវិសឹសុ ។ សេយ្យថាបិ នាម សុណិសា សសុរំ ទិស្វា ឱត្តប្បតិ ហិរិយតិ ឯវមេវ[២] សក្កស្ស ទេវានមិន្ទស្ស បរិចារិកាយោ អាយស្មន្តំ មហាមោគ្គល្លានំ ទិស្វា

១ ម. អទ្ទសំសុ ។ ២ ឱ. ឯវមេវំ ។

មានស្រីអប្សរប្រាំពីរ ៗ នាក់ ក្នុងស្រីអប្សរម្នាក់ ៗ មានស្រីបម្រើប្រាំពីរ ៗ នាក់ បពិត្រព្រះមហាមោគ្គល្លានអ្នកនិទ៌ុក្ខ លោកម្ចាស់ចង់ឃើញកន្ទែងដែលគួររីករាយរបស់វេជយន្តប្រាសាទដែរឬទេ ។ ព្រះមហាមោគ្គល្លានមានអាយុទទួលនិមន្ត ដោយតុណ្ហីភាព ។

[៧៧] គ្រានោះ ព្រះឥន្ទ្រាធិរាជនិងវេស្សវណមហារាជឲ្យព្រះមហា-មោគ្គល្លានមានអាយុនិមន្តមុខ ហើយនាំចូលទៅរកវេជយន្តប្រាសាទ ។ ពួកស្រីបម្រើ របស់ព្រះឥន្ទ្រាធិរាជ បានឃើញព្រះមហាមោគ្គល្លានមានអាយុ កំពុងនិមន្តមកអំពីចម្ងាយ លុះឃើញហើយក៏មានសេចក្ដីខ្មាចនិងអៀនខ្មាសនាំគ្នាចូលទៅកាន់បន្ទប់រៀងខ្លួន ។ ដូចជាកូនប្រសាស្រីបានឃើញឪពុកក្មេក ហើយមានសេចក្ដីខ្មាចនិងអៀនខ្មាស យ៉ាងណា ពួកស្រីបម្រើរបស់ព្រះឥន្ទ្រាធិរាជ បានឃើញព្រះមហាមោគ្គល្លានមានអាយុ

ឱតប្បមានា ហិរិយមានា សកំ សកំ ឱរកំ បវិសឹសុ ។ អថខោ សក្កោ ច ទេវានមិន្ទោ វេស្សវណោ ច មហារាជា អាយស្មន្តំ មហាមោគ្គល្លានំ វេជយន្តេ បាសាទេ អនុចង្កមាបេន្តិ អនុចរាបេន្តិ[១] ឥទម្បិ មារិស មោគ្គល្លាន បស្ស វេជយន្តស្ស បាសាទស្ស រាមណេយ្យកំ ឥទម្បិ មារិស មោគ្គល្លាន បស្ស វេជយន្តស្ស បាសាទស្ស រាមណេយ្យកន្តិ ។ សោភតិទំ អាយស្មតោ កោសិយស្ស យថាតំ បុព្វេ កតបុញ្ញស្ស មនុស្សាបិ កិញ្ចិទេវ រាមណេយ្យកំ ទិស្វា[២] ឯវមាហំសុ សោភតិ វត ភោ ទេវានំ តាវតឹសានន្តិ តយិទំ អាយស្មតោ កោសិយស្ស សោភតិ យថាតំ បុព្វេ កតបុញ្ញស្សាតិ ។ អថខោ អាយស្មតោ មហាមោគ្គល្លានស្ស ឯតទហោសិ អតិពាឡ្ហំ ខោ អយំ យក្ខោ បមត្តោ វិហរតិ យន្នូនាហំ ឥមំ យក្ខំ សំវេជេយ្យន្តិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ

---

១ ឱ. ម. អនុវិចរាបេន្តិ ។ ២ ឱ. ម. ទិដ្ឋា ។

ក៏មានសេចក្តីខ្លាចនិងអៀនខ្មាស នាំគ្នាចូលបន្ទប់រៀងខ្លួន យ៉ាងនោះដែរ ។ គ្រានោះ ព្រះឥន្ទ្រាធិរាជនិងវេស្សវណមហារាជ និមន្តព្រះមហាមោគ្គ-ល្លានមានអាយុត្រាច់ជុំវិញ ចូលទៅក្នុងវេជយន្តប្រាសាទ ហើយទូលថា បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ សូមលោកម្ចាស់ទតមើលកន្លែងដែលគួររីករាយរបស់វេជយន្តប្រាសាទនេះផង បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ សូមលោកម្ចាស់ទតមើលកន្លែងដែលគួររីករាយ របស់វេជយន្តប្រាសាទនេះផង ។ ព្រះថេរៈ ឆ្លើយថា ទីរបស់កោសិយៈ មានអាយុ ដែលបានធ្វើបុណ្យទុកក្នុងកាលមុននេះល្អមែន សូម្បីពួកមនុស្សបានឃើញទីណាមួយដែលជាទីគួររីករាយ ក៏តែងនាំគ្នានិយាយថា អើហ្ន៎ ទីនេះល្អដូចជាប្រា-សាទរបស់ពួកទេវតា ក្នុងជាន់តាវត្តិង្សដែរ ឯលំនៅរបស់កោសិយៈមានអាយុ ដែលមានបុណ្យធ្វើទុកក្នុងកាលមុននេះ ល្អដោយពិតហើយ ។ គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ទេវតានេះជាបុគ្គលប្រមាទខ្លាំងមែន បើដូច្នោះគួរតែអាត្មាអញធ្វើទេវតានេះឲ្យសង្វេគ ។ ទើបព្រះមហាមោគ្គល្លានមានអាយុ សំដែងឥទ្ធិប្ញទ្ធិ

តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខារេសិ យថា វេជយន្តំ បាសាទំ បាទង្គុដ្ឋកេន សង្កម្បេសិ សម្បកម្បេសិ សម្បវេធេសិ ។ អថខោ សក្កោ ច ទេវានមិន្ទោ វេស្សវណោ ច មហារាជា ទេវា ច តាវត្តឹសា អច្ឆរិយព្ភុតចិត្តជាតា អហេសុំ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សមណស្ស មហិទ្ធិកតា មហានុភាវតា យត្រ ហិ នាម ទិព្វភវនំ បាទង្គុដ្ឋកេន សង្កម្បេស្សតិ សម្បកម្បេស្សតិ សម្បវេធេស្សតីតិ ។

[៧៨] អថខោ អាយស្មា មហាមោគ្គល្លានោ សក្កំ ទេវានមិន្ទំ សំវិគ្គំ លោមហដ្ឋជាតំ វិទិត្វា សក្កំ ទេវានមិន្ទំ ឯតទវោច យថាកថំ បន[១] កោសិយ ភគវា សង្ខិត្តេន តណ្ហាសង្ខយវិមុត្តឹ អភាសិ សាធុ មយម្បិ ឯតិស្សា កថាយ ភាគិនោ អស្សាម សវនាយាតិ ។ ឥធាហំ មារិស មោគ្គល្លាន យេន ភគវា តេនុបសង្កមឹ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសឹ ឯកមន្តំ ឋិតោ ខោ អហំ មារិស មោគ្គល្លាន ភគវន្តំ ឯតទវោចំ កិត្តាវតា នុ ខោ ភន្តេ ភិក្ខុ

១ ឱ. បន តេ ។ ម. បន ខោ ។

ញ៉ាំងវេជយន្តប្រាសាទឲ្យកម្រើក រំភើប ញាប់ញ័រ ដោយចុងមេជើង តាមសមគួរដល់ឫទ្ធិ ។ គ្រានោះ ព្រះឥន្ទ្រាធិរាជ និងវេស្សវណមហារាជ និងពួកទេវតាក្នុងជាន់តាវត្តិង្ស កើតសេចក្តីអស្ចារ្យក្នុងចិត្តថា អើហ្ន៎ អស្ចារ្យណាស់ អើហ្ន៎ ចំឡែកណាស់ ត្រង់ការណ៍ដែលភាពនៃសមណៈ មានឫទ្ធិច្រើន មានអានុភាពច្រើន (ប៉ុណ្ណេះ) មិនសមបើញ៉ាំងទិព្វវិមាន ឲ្យកម្រើក រំភើប ញាប់ញ័រ ដោយចុងមេជើងបាន ។

[៧៨] គ្រានោះ ព្រះមហាមោគ្គល្លាន មានអាយុ ដឹងថាព្រះឥន្ទ្រាធិរាជ មានសេចក្តីតក់ស្លុត កើតសេចក្តីព្រឺរោមហើយ ក៏មានថេរវាចាទៅរកព្រះឥន្ទ្រាធិរាជថា បពិត្រកោសិយៈ ព្រះមានព្រះភាគបាន ត្រាស់នូវកិរិយាបង្អោនចិត្តទៅក្នុងព្រះនិព្វានជាទីអស់ទៅនៃតណ្ហា ដោយសេចក្តីបំប្រួញ (ចំពោះ) មហារាជដូចម្តេចខ្លះ សូមព្រះរាជានុញ្ញាត ដ្បិតអាត្មាភាពជាអ្នកមានចំណែកដើម្បីស្តាប់ធម្មកថានេះផង ។ សក្កទេវរាជ ឆ្លើយតបថា បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ កាលនោះខ្ញុំព្រះករុណាបាន ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំចំពោះព្រះមានព្រះភាគ រួចឋិតនៅក្នុងទីដ៏សមគួរ បពិត្រព្រះមោគ្គល្លាន អ្នកនិទ៌ុក្ខ លុះខ្ញុំព្រះករុណាឋិតនៅ ក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុអ្នក

សង្ខិត្តេន តណ្ហាសង្ខយវិមុត្តោ ហោតិ អច្ចន្តនិដ្ឋោ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានន្តិ ឯវំ វុត្តេ មារិស មោគ្គល្លាន ភគវា មំ ឯតទវោច ឥធ ទេវានមិន្ទ ភិក្ខុនោ សុតំ ហោតិ សព្វេ ធម្មា នាលំ អភិនិវេសាយាតិ ឯវញ្ចេ តំ ទេវានមិន្ទ ភិក្ខុនោ សុតំ ហោតិ សព្វេ ធម្មា នាលំ អភិនិវេសាយាតិ សោ សព្វំ ធម្មំ អភិជានាតិ សព្វំ ធម្មំ អភិញ្ញាយ សព្វំ ធម្មំ បរិជានាតិ សព្វំ ធម្មំ បរិញ្ញាយ យំ កញ្ចិ វេទនំ វេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សោ តាសុ វេទនាសុ អនិច្ចានុបស្សី វិហរតិ វិរាគានុបស្សី វិហរតិ និរោធានុបស្សី វិហរតិ បដិនិស្សគ្គានុបស្សី វិហរតិ សោ តាសុ វេទនាសុ អនិច្ចានុបស្សី វិហរន្តោ វិរាគានុបស្សី វិហរន្តោ និរោ-ធានុបស្សី វិហរន្តោ បដិនិស្សគ្គានុបស្សី វិហរន្តោ

បង្អោនចិត្តទៅកាន់ព្រះនិព្វានជាទីក្ស័យនៃតណ្ហា ជាអ្នកមានសេចក្តីចូលចិត្តទៀង ជាអ្នកមានសេចក្តីក្សេមក្សាន្តចាកយោគៈទៀង ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរទៀង មានទីបំផុតទៀងទាត់ ជាបុគ្គលប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ដោយសង្ខេប តើមានប៉ុន្មានយ៉ាង បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ កាលបើខ្ញុំព្រះករុណាសួរយ៉ាងនេះហើយ ព្រះមានព្រះភាគមានព្រះបន្ទូលមកនឹងខ្ញុំព្រះករុណា យ៉ាងនេះថា បពិត្រព្រះអង្គជាធំជាងពួកទេវតា ភិក្ខុក្នុងសាសនានេះ បានស្តាប់ពាក្យថា ភិក្ខុមិនគួរនឹងប្រកាន់នូវធម៌គឺបញ្ចក្ខន្ធទាំងអស់ឡើយ បពិត្រព្រះអង្គជាធំជាងពួកទេវតា ភិក្ខុបានស្តាប់ពាក្យនុ៎ះថា ភិក្ខុមិនគួរនឹងប្រកាន់នូវធម៌ទាំងពួងយ៉ាងនេះហើយ ភិក្ខុនោះរមែងដឹងច្បាស់នូវធម៌ទាំងពួង លុះដឹងច្បាស់នូវធម៌ទាំងពួងហើយ រមែងកំណត់ដឹងធម៌ទាំងពួងបាន លុះកំណត់ដឹងនូវធម៌ទាំងពួងហើយ រមែងសោយនូវវេទនាណាមួយ ជាសុខឬជាទុក្ខឬមិនទុក្ខមិនសុខ ភិក្ខុនោះជាអ្នកពិចារណាឃើញថាមិនទៀង ពិចារណាឃើញថាជាទីប្រាសចាកតម្រេក ពិចារណាឃើញថាជាគ្រឿងរំលត់ ពិចារណាឃើញថាគួរលះបង់ក្នុងវេទនាទាំងឡាយនោះ កាលបើភិក្ខុនោះពិចារណាឃើញថាមិនទៀង ពិចារណាឃើញថាជាទីប្រាសចាកតម្រេក ពិចារណាឃើញថាជាទីរំលត់ ពិចារណាឃើញថាគួរលះបង់ក្នុងវេទនាទាំងឡាយ

ន កិញ្ចិ លោកេ ឧបាទិយតិ អនុបាទិយំ ន បរិតស្សតិ អបរិតស្សំ បច្ចត្តញ្ញេវ បរិនិព្វាយតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ឯត្តាវតា ខោ ទេវានមិន្ទ ភិក្ខុ សង្ខិត្តេន តណ្ហាសង្ខយវិមុត្តោ ហោតិ អច្ចន្ត-និដ្ឋោ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្ត-បរិយោសានោ សេដ្ឋោ ទេវមនុស្សានន្តិ ឯវំ ខោ មេ មារិស មោគ្គល្លាន ភគវា សង្ខិត្តេន តណ្ហាសង្ខយ-វិមុត្តឹ អភាសីតិ ។ អថខោ អាយស្មា មហាមោគ្គល្លា-នោ សក្កស្ស ទេវានមិន្ទស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ទេវេសុ តាវតឹសេសុ អន្តរហិតោ បុព្វារាមេ មិគារមាតុ បាសាទេ បាតុរហោសិ ។ អថខោ សក្កស្ស ទេវានមិន្ទស្ស បរិចារិកាយោ អចិរបក្កន្តេ

នោះហើយ ក៏មិនប្រកាន់ធម្មជាតអ្វីតិចតួចក្នុងលោកឡើយ កាលបើមិនប្រកាន់ ក៏មិនតក់ស្លុត កាលបើមិនតក់ស្លុត ទើបរំលត់កិលេសដោយខ្លួនឯងបាន ទាំងដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានអប់រំហើយ កិច្ចដែលត្រូវធ្វើ អាត្មាអញក៏បានធ្វើហើយ កិច្ចដទៃក្រៅអំពីកិច្ចនេះមិនមានឡើយ បពិត្រព្រះអង្គដ៏ជាធំជាងពួកទេវតា ភិក្ខុជាអ្នកបង្អោនចិត្តទៅក្នុងព្រះនិព្វានជាទីក្ស័យទៅនៃតណ្ហា ជាអ្នកមានសេចក្តីចូលចិត្តទៀង ជាអ្នកមានសេចក្តីក្សេមក្សាន្តចាកយោគៈទៀង ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរទៀង មានទីបំផុតទៀងទាត់ ជាបុគ្គលប្រសើរជាងពួកទេវតានិងមនុស្ស ដោយសង្ខេបមានប្រមាណប៉ុណ្ណោះឯង បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគបានត្រាស់សំដែង នូវកិរិយាបង្អោនចិត្តទៅ ក្នុងព្រះនិព្វាន ជាទីក្ស័យទៅនៃតណ្ហា ដោយសេចក្តីសង្ខេប ចំពោះខ្ញុំព្រះករុណា ដូចពណ៌នាមកនេះ ។ គ្រានោះព្រះមហាមោគ្គល្លានមានអាយុ ត្រេកអរ អនុមោទនា ចំពោះភាសិតរបស់ព្រះឥន្ទ្រាធិរាជ ហើយក៏ស្រាប់តែបាត់ចាកតាវត្តិង្សទេវលោក មកប្រាកដក្នុងមិគារមាតុប្រាសាទនាវត្តបុព្វារាម មួយរំពេច ដូចជាបុរសដែលមានកម្លាំងលាដៃបត់ចូល ឬបត់ដៃដែលលាចេញ ដូច្នោះឯង ។

អាយស្មន្តេ មហាមោគ្គល្លានេ សក្កំ ទេវានមិន្ទំ ឯតទវោចុំ ឯសោ នុ ខោ[១] តេ មារិស សោ ភគវា សត្ថាតិ ។ ន ខោ មេ មារិសា សោ ភគវា សត្ថា សព្រហ្មចារី មេ ឯសោ អាយស្មា មហាមោគ្គល្លានោ-តិ ។ លាភា តេ មារិស សុលទ្ធំ តេ មារិស យស្ស តេ សព្រហ្មចារី ឯវំ មហិទ្ធិកោ ឯវំ មហា-នុភាវោ អហោ នូន តេ សោ ភគវា សត្ថាតិ ។

[៧៩] អថខោ អាយស្មា មហាមោគ្គល្លានោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវា-ទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាមោគ្គល្លានោ ភគវន្តំ ឯតទវោច

---

១ ឱ. ម. ខោសទ្ទោ ន ទិស្សតិ ។

កាលដែលព្រះមហាមោគ្គល្លានមានអាយុ ចៀសចេញទៅមិនយូរប៉ុន្មាន ពួកស្រីបម្រើរបស់ព្រះឥន្ទ្រាធិរាជ បានក្រាបទូលសួរចំពោះព្រះឥន្ទ្រាធិរាជ ដូច្នេះថា បពិត្រព្រះអង្គអ្នកនិទុក្ខ លោកនុ៎ះហើយឬ ជាព្រះមានព្រះភាគ ជាគ្រូរបស់ព្រះអង្គនោះ ។ សក្កទេវរាជឆ្លើយតបថា ម្នាលនាងអ្នកនិទុក្ខទាំងឡាយ លោកនោះមិនមែនជាព្រះមានព្រះភាគ ជាគ្រូរបស់យើងទេ លោកនោះគ្រាន់តែជាសព្រហ្មចារី (អ្នកប្រព្រឹត្តធម៌ដូចគ្នា) នឹងយើង លោកនុ៎ះហើយ ដែលឈ្មោះព្រះមហាមោគ្គល្លានមានអាយុ ។ ពួកស្រីបម្រើក្រាបទូលថា បពិត្រព្រះអង្គអ្នកនិទុក្ខ ព្រះអង្គពេញជាមានលាភហើយ បពិត្រព្រះអង្គ អ្នកនិទុក្ខ ព្រះអង្គពេញជាបានល្អហើយ ត្រង់ដែលព្រះអង្គបានសព្រហ្មចារីបុគ្គលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ឱហ្ន៎ លោកនោះទុកដូចជាព្រះមានព្រះភាគ ជាគ្រូរបស់ព្រះអង្គដោយពិតណាស់ ។

[៧៩] គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគ រួចគង់ក្នុងទីសមគួរ ។ លុះព្រះមហាមោគ្គល្លានមានអាយុ គង់ក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលសួរព្រះមាន

១៤៧



អភិជានាតិ នោ ភន្តេ ភគវា អាហុនញ្ញេវ[១] អញ្ញតរស្ស មហេសក្ខស្ស យក្ខស្ស សង្ខិត្តេន តណ្ហាសង្ខយវិមុត្តឹ ភាសិតាតិ[២] ។ អភិជានាមហំ មោគ្គល្លាន ឥធ សក្កោ ទេវានមិន្ទោ យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ឯកមន្តំ ឋិតោ ខោ មោគ្គល្លាន សក្កោ ទេវានមិន្ទោ មំ ឯតទវោច កិត្តាវតា នុ ខោ ភន្តេ ភិក្ខុ សង្ខិត្តេន តណ្ហាសង្ខយវិមុត្តោ ហោតិ អច្ចន្តនិដ្ឋោ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានន្តិ ឯវំ វុត្តេ អហំ មោគ្គល្លាន សក្កំ ទេវានមិន្ទំ ឯតទវោចំ ឥធ ទេវានមិន្ទ ភិក្ខុនោ សុតំ ហោតិ សព្វេ ធម្មា នាលំ អភិនិវេសាយាតិ ឯវញ្ចេ តំ ទេវានមិន្ទ ភិក្ខុនោ សុតំ ហោតិ សព្វេ ធម្មា នាលំ អភិនិវេសាយាតិ សោ សព្វំ ធម្មំ អភិជានាតិ សព្វំ ធម្មំ អភិញ្ញាយ

១ ឱ. អាហុតញ្ញេវ អញ្ញតរស្ស ។ ម. អាហុ អញ្ញតរញ្ញតរស្ស ។ ២ ឱ. ម. អភាសិត្ថាតិ ។

ព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគធ្លាប់បានសំដែងនូវកិរិយាបង្អោនចិត្តទៅក្នុងព្រះនិព្វាន ជាទីអស់ទៅនៃតណ្ហា ដោយសង្ខេប ជាគ្រឿងតម្វាយដល់ទេវតា ដែលមានស័ក្តិធំមួយរូបឬទេ ។ ព្រះអង្គត្រាស់ថា ម្នាលមោគ្គល្លាន តថាគតធ្លាប់សំដែង ដ្បិត សក្កទេវរាជចូលមករកតថាគត ក្នុងទីនេះ លុះចូលមកដល់ហើយ ក៏ក្រាបថ្វាយបង្គំតថាគត រួចឋិតនៅក្នុងទីដ៏សមគួរ ម្នាលមោគ្គល្លាន លុះសក្កទេវរាជឋិតនៅ ក្នុងទីដ៏សមគួរហើយ បានសួរសេចក្តីនេះ នឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាអ្នកមានចិត្តបង្អោនទៅក្នុងព្រះនិព្វាន ជាទីក្សយ័នៃតណ្ហា ជាអ្នកមានសេចក្តីចូលចិត្តទៀត មានសេចក្តីក្សេមក្សាន្តចាកយោគៈទៀត ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរទៀត មានទីបំផុតទៀតទាត់ ជាបុគ្គលប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ដោយសង្ខេប តើមានប៉ុន្មាន ម្នាលមោគ្គល្លាន កាលបើសក្កទេវរាជសួរយ៉ាងនេះហើយ តថាគតក៏ឆ្លើយតបទៅនឹងសក្កទេវរាជដូច្នេះថា បពិត្រព្រះអង្គជាធំជាងទេវតាទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានស្តាប់ពាក្យថា បុគ្គលមិនគួរនឹងប្រកាន់នូវធម៌ទាំងពួង បពិត្រព្រះអង្គជាធំជាងពួកទេវតា លុះភិក្ខុបានស្តាប់ពាក្យនុ៎ះថា បុគ្គលមិនគួរប្រកាន់នូវធម៌ទាំងពួងយ៉ាងនេះហើយ ភិក្ខុនោះរមែងដឹងច្បាស់នូវធម៌ទាំងពួង លុះដឹងច្បាស់នូវធម៌ទាំងពួង

សព្វំ ធម្មំ បរិជានាតិ សព្វំ ធម្មំ បរិញ្ញាយ យំ កញ្ចិ វេទនំ វេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សោ តាសុ វេទនាសុ អនិច្ចានុបស្សី វិហរតិ វិរាគានុបស្សី វិហរតិ និរោធានុបស្សី វិហរតិ បដិនិស្សគ្គានុបស្សី វិហរតិ សោ តាសុ វេទនាសុ អនិច្ចានុបស្សី វិហរន្តោ វិរាគានុបស្សី វិហរន្តោ និរោធានុបស្សី វិហរន្តោ បដិនិស្សគ្គានុបស្សី វិហរន្តោ ន កិញ្ចិ លោកេ ឧបាទិយតិ អនុបាទិយំ ន បរិតស្សតិ អបរិតស្សំ បច្ចត្តញ្ញេវ បរិនិព្វាយតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ឯត្តាវតា ខោ ទេវានមិន្ទ ភិក្ខុ សង្ខិត្តេន តណ្ហាសង្ខយវិមុត្តោ ហោតិ អច្ចន្តនិដ្ឋោ អច្ចន្តយោគក្ខេមី

ហើយ ក៏កំណត់ដឹងនូវធម៌ទាំងពួង លុះកំណត់ដឹងនូវធម៌ទាំងពួងហើយ រមែងសោយនូវវេទនាណាមួយ ជាសុខឬជាទុក្ខ ឬមិនទុក្ខមិនសុខ ភិក្ខុនោះពិចារណាឃើញថា មិនទៀង ពិចារណាឃើញថាជាទីប្រាសចាកតម្រេក ពិចារណាឃើញថាជាទីគួររំលត់ ពិចារណាឃើញថាគួរលះបង់ ក្នុងវេទនាទាំងឡាយនោះ កាលបើភិក្ខុនោះពិចារណាឃើញថាមិនទៀង ពិចារណាឃើញថាជាទីប្រាសចាកតម្រេក ពិចារណាឃើញថាគួររំលត់ ពិចារណាឃើញថាគួរលះបង់ក្នុងវេទនាទាំងឡាយនោះហើយ ក៏មិនប្រកាន់ធម្មជាតអ្វីតិចតួច ក្នុងលោកឡើយ កាលបើមិនប្រកាន់ ក៏រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុត ក៏រមែងរំលត់កិលេសដោយខ្លួនឯងបាន ទើបដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានអប់រំហើយ កិច្ចដែលត្រូវធ្វើ អាត្មាអញក៏បានធ្វើហើយ កិច្ចដទៃក្រៅអំពីកិច្ចនេះមិនមានឡើយ បពិត្រព្រះអង្គជាធំជាងពួកទេវតា ភិក្ខុជាអ្នកបង្អោនចិត្តទៅក្នុងព្រះនិព្វាន ជាទីក្ស័យទៅនៃតណ្ហា ជាអ្នកមានសេចក្ដីចូលចិត្តទៀង មានសេចក្ដីក្សេមក្សាន្តចាកយោគៈទៀង

១៤៩

មហាយមកវគ្គស្ស ចូឡតណ្ហាសង្ខយសុត្តេ វិមុត្តិកថា

អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានន្តិ ឯវំ ខោ អហំ មោគ្គល្លាន អភិជានាមិ សក្កស្ស ទេវានមិន្ទស្ស សង្ខិត្តេន តណ្ហាសង្ខយវិមុត្តឹ ភាសិតាតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា មហាមោគ្គល្លានោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ចូឡតណ្ហាសង្ខយសុត្តំ សត្តមំ និដ្ឋិតំ ។

ជាអ្នកប្រព្រឹត្តធម៌ ដ៏ប្រសើរទៀត មានទីបំផុតទៀតទាត់ ជាបុគ្គលប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ដោយសង្ខេប មានប្រមាណប៉ុណ្ណោះឯង ម្នាលមោគ្គល្លាន តថាគត ធ្លាប់សំដែងនូវកិរិយាបង្អោនចិត្តទៅក្នុងព្រះនិព្វាន ជាទីក្សយទៅនៃតណ្ហា ដោយសង្ខេប ចំពោះសក្កទេវរាជដូចបានពណ៌នាមកនេះឯង ។ លុះព្រះមានព្រះភាគ បានត្រាស់ភាសិតនេះចប់ហើយ ព្រះមហាមោគ្គល្លាន មានអាយុ មានសេចក្តីពេញចិត្តត្រេកអរហើយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ ចូឡតណ្ហាសង្ខយសូត្រ ទី ៧ ។

# អដ្ឋមំ មហាតណ្ហាសង្ខយសុត្តំ

[៨០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សាតិស្ស នាម ភិក្ខុនោ កេវដ្ដបុត្តស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា តទេវិទំ វិញ្ញាណំ សន្ធាវតិ សំសរតិ អនញ្ញន្តិ ។ អស្សោសុំ ខោ សម្ពហុលា ភិក្ខូ សាតិស្ស នាម[១] ភិក្ខុនោ កេវដ្ដបុត្តស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា តទេវិទំ វិញ្ញាណំ សន្ធាវតិ សំសរតិ អនញ្ញន្តិ ។

---

១ ឱ. ម. សាតិស្ស កិរ នាម ។

# មហាតណ្ហាសង្ខយសូត្រ ទី ៨

[៨០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់សម្រេចសម្រាន្តព្រះឥរិយាបថ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុឈ្មោះសាតិ ជាកូននៃព្រានសំណាញ់ មានទិដ្ឋិអាក្រក់[១] កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ[២] យ៉ាងណា អាត្មាអញក៏បានដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយយ៉ាងនោះដែរ ។ ពួកភិក្ខុជាច្រើនរូបបានឮដំណឹងថា សាតិភិក្ខុកេវដ្តបុត្តមានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា អាត្មាអញក៏បានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយ យ៉ាងនោះដែរ ។

---

១ ទិដ្ឋិអាក្រក់នេះ ក្នុងអដ្ឋកថាលោកសំដៅ សស្សតទិដ្ឋិ ដែលយល់ថាសត្វទៀង លោកទៀង ។ ២ ក្នុងអដ្ឋកថា លោកអធិប្បាយថា ភិក្ខុនោះត្រិះរិះថា រូប វេទនា សញ្ញា សង្ខារ ទាំង ៤ នេះ រលត់ទៅក្នុងភពទាំងពួង ឯវិញ្ញាណនេះជាធម្មជាតស្ទុះទៅ អន្ទោលទៅអំពីលោកនេះ ទៅកាន់លោកខាងមុខ មកកាន់លោកនេះវិញដដែល ហេតុនេះវិញ្ញាណឃើញថានៅតែកើតឡើងតាមធម្មតា គឺមិនរលត់ទៅទេ ។

១៨១



អថខោ តេ ភិក្ខូ យេន សាតិ ភិក្ខុ កេវដ្ដបុត្តោ តេនុបសង្កមឹសុ ឧបសង្កមិត្វា សាតឹ ភិក្ខុំ កេវដ្ដបុត្តំ ឯតទវោចុំ សច្ចំ កិរ តេ អាវុសោ សាតិ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា តទេវិទំ វិញ្ញាណំ សន្ធាវតិ សំសរតិ អនញ្ញន្តិ ។ ឯវំ ព្យា ខោ អហំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា តទេវិទំ វិញ្ញាណំ សន្ធាវតិ សំសរតិ អនញ្ញន្តិ ។ អថខោ តេ ភិក្ខូ សាតឹ ភិក្ខុំ កេវដ្ដបុត្តំ ឯតស្មា បាបកា ទិដ្ឋិគតា វិវេចេតុកាមា សមនុយុញ្ជន្តិ សមនុគ្គាហន្តិ សមនុភាសន្តិ មា ឯវមាវុសោ សាតិ អវច មា ភគវន្តំ អព្ភាចិក្ខ[១] ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ សាតិ បដិច្ចសមុប្បន្នំ វិញ្ញាណំ វុត្តំ ភគវតា អញ្ញត្រ បច្ចយា នត្ថិ វិញ្ញាណស្ស សម្ភវោតិ ។

១ ឱ. ម. អព្ភាចិក្ខិ ។

ទើបភិក្ខុទាំងនោះ ចូលទៅរកសាតិភិក្ខុកេវដ្តបុត្ត លុះចូលទៅដល់ហើយ បានសួរសាតិភិក្ខុកេវដ្តបុត្តដូច្នេះថា ម្នាលអាវុសោសាតិ បានឮថាអ្នកមានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅ មិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា អាត្មាអញក៏បានដឹងច្បាស់ នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះមែនឬ ។ សាតិភិក្ខុកេវដ្តបុត្តឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ វិញ្ញាណរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃ យ៉ាងណា ខ្ញុំក៏បានដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសំដែងហើយ យ៉ាងនោះដែរ ដូច្នេះមែន ។ គ្រានោះ ភិក្ខុទាំងនោះមានបំណងនឹងដោះសាតិភិក្ខុកេវដ្តបុត្តឲ្យរួចចាកទិដ្ឋិអាក្រក់នុ៎ះ ទើបនិយាយពន្យល់ ដាស់តឿន ក្រើនរំលឹកថា ម្នាលអាវុសោសាតិ អ្នកកុំនិយាយយ៉ាងនេះឡើយ អ្នកកុំនិយាយបង្កាច់ព្រះមានព្រះភាគ ព្រោះថា ការដែលពោលបង្កាច់ព្រះមានព្រះភាគមិនប្រពៃទេ ដ្បិតព្រះមានព្រះភាគព្រះអង្គមិនមានបន្ទូលយ៉ាងនេះឡើយ ម្នាលអាវុសោសាតិ ព្រះមានព្រះភាគសំដែងហើយដោយអនេកបរិយាយថា វិញ្ញាណកើតឡើងព្រោះអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យហើយ ការកើតឡើងនៃវិញ្ញាណក៏មិនមាន ។

ឯវម្បិ ខោ សាតិ ភិក្ខុ កេវដ្ដបុត្តោ តេហិ ភិក្ខូហិ សមនុយុញ្ជិយមានោ សមនុគ្គាហិយមានោ សមនុភាសិយមានោ តទេវ បាបកំ ទិដ្ឋិគតំ ថាមសា បរាមស្ស អភិនិវិស្ស វោហរតិ ឯវំ ព្យា ខោ អហំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា តទេវិទំ វិញ្ញាណំ សន្ធាវតិ សំសរតិ អនញ្ញន្តិ ។

[៨១] យតោ ខោ តេ ភិក្ខូ នាសក្ខឹសុ សាតឹ ភិក្ខុំ កេវដ្ដបុត្តំ ឯតស្មា បាបកា ទិដ្ឋិគតា វិវេចេតុំ អថ តេ ភិក្ខូ យេន[១] ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ សាតិស្ស នាម ភន្តេ ភិក្ខុនោ កេវដ្ដបុត្តស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា តទេវិទំ វិញ្ញាណំ សន្ធាវតិ សំសរតិ អនញ្ញន្តិ[២]

---

១ ឱ. អថ យេន ។ ម. អថខោ តេ ភិក្ខូ យេន ។ ២ ឱ. ម. ឯត្តន្តរេ អស្សុម្ហ ខោ មយំ ភន្តេ សាតិស្ស កិរ នាម ភិក្ខុនោ កេវដ្ដបុត្តស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា អនញ្ញន្តីតិ ទិស្សតិ ។

សាតិភិក្ខុកេវដ្ដបុត្តកាលបើពួកភិក្ខុទាំងនោះ និយាយពន្យល់ ដាស់តឿន ក្រើនរំលឹក យ៉ាងនេះហើយ ក៏នៅតែចូលចិត្តប្រកាន់ទិដ្ឋិអាក្រក់នោះដដែល ហើយនិយាយប្រកែកតាមកម្លាំងដូច្នេះថា ម្នាលអាវុសោទាំង-ឡាយ វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា ខ្ញុំក៏បានដឹងនូវធម៌ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះឯង ។

[៨១] កាលដែលភិក្ខុទាំងនោះ មិនអាចនឹងដោះសាតិភិក្ខុកេវដ្ដ-បុត្ត ឲ្យរួចចាកទិដ្ឋិអាក្រក់នុ៎ះបានហើយ ទើបភិក្ខុទាំងអម្បាលនោះ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំ នូវព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សាតិភិក្ខុកេវដ្ដបុត្ត មានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា អាត្មាអញក៏បានដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសំដែងហើយ ក៏យ៉ាងនោះដែរ

អថខោ មយំ ភន្តេ យេន សាតិ ភិក្ខុ កេវដ្ដ-
បុត្តោ តេនុបសង្កមិម្ហ ឧបសង្កមិត្វា សាតឹ ភិក្ខុំ
កេវដ្ដបុត្តំ ឯតទវោចុម្ហ សច្ចំ កិរ តេ អាវុសោ
សាតិ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ
ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា តទេវិទំ
វិញ្ញាណំ សន្ធាវតិ សំសរតិ អនញ្ញន្តិ ឯវំ វុត្តេ
ភន្តេ សាតិ ភិក្ខុ កេវដ្ដបុត្តោ អម្ហេ ឯតទវោច
ឯវំ ព្យា ខោ អហំ អាវុសោ ភគវតា ធម្មំ ទេសិតំ
អាជានាមិ យថា តទេវិទំ វិញ្ញាណំ សន្ធាវតិ សំសរតិ
អនញ្ញន្តិ អថខោ មយំ ភន្តេ សាតឹ ភិក្ខុំ កេ-
វដ្ដបុត្តំ ឯតស្មា បាបកា ទិដ្ឋិគតា វិវេចេតុកាមា
សមនុយុញ្ជិម្ហ សមនុគ្គាហិម្ហ សមនុភាសិម្ហ មា
ឯវំ អាវុសោ សាតិ អវច មា ភគវន្តំ អព្ភាចិក្ខ
ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា
ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ សាតិ

បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះយើងខ្ញុំព្រះអង្គបាននាំគ្នាចូលទៅរកសាតិ-ភិក្ខុកេវដ្តបុត្ត លុះចូលទៅដល់ហើយ បានសួរសាតិភិក្ខុកេវដ្តបុត្តដូច្នេះថា ម្នាលអាវុសោសាតិ បានឮថា អ្នកមានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា អាត្មាអញក៏បានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយក៏យ៉ាងនោះ ដូច្នេះ ពិតមែនឬ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលយើងខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ សាតិភិក្ខុកេវដ្តបុត្តក៏បាននិយាយតបមកនឹងយើងខ្ញុំព្រះអង្គដូច្នេះថា ម្នាលអាវុសោទាំងឡាយ វិញ្ញាណនេះ រមែងស្ទុះទៅ អន្ទោលទៅ មិនក្លាយទៅជាអ្វីដទៃឡើយយ៉ាងណា ខ្ញុំក៏បានដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសំដែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះមែន បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះយើងខ្ញុំព្រះអង្គមានចំណង់នឹងដោះសាតិភិក្ខុកេវដ្តបុត្ត ឲ្យរួចចាកទិដ្ឋិអាក្រក់នោះ ទើបនាំគ្នានិយាយពន្យល់ដាស់តឿនក្រើនរំលឹកថា ម្នាលអាវុសោសាតិ អ្នកកុំនិយាយយ៉ាងនេះឡើយ អ្នកកុំនិយាយបង្កាច់ព្រះមានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះមានព្រះភាគមិនប្រពៃទេ ដ្បិតព្រះមានព្រះភាគទ្រង់មិនមានព្រះបន្ទូលយ៉ាងនេះឡើយ ម្នាលអាវុសោសាតិ

បដិច្ចសមុប្បន្នំ វិញ្ញាណំ វុត្តំ ភគវតា អញ្ញត្រ បច្ចយា នត្ថិ វិញ្ញាណស្ស សម្ភវោតិ ឯវម្បិ ខោ ភន្តេ សាតិ ភិក្ខុ កេវដ្ដបុត្តោ អម្ហេហិ សមនុយុញ្ជិយមានោ សមនុគ្គាហិយមានោ សមនុភាសិយមានោ តទេវ បាបកំ ទិដ្ឋិគតំ ថាមសា បរាមស្ស អភិនិវិស្ស វោហរតិ ឯវំ ព្យា ខោ អហំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា តទេវិទំ វិញ្ញាណំ សន្ធាវតិ សំសរតិ អនញ្ញន្តិ យតោ ខោ មយំ ភន្តេ នាសក្ខិម្ហា សាតឹ ភិក្ខុំ កេវដ្ដបុត្តំ ឯតស្មា បាបកា ទិដ្ឋិគតា វិវេចេតុំ អថ មយំ ឯតមត្ថំ ភគវតោ អារោចេមាតិ ។

[៨២] អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន សាតឹ ភិក្ខុំ កេវដ្ដបុត្តំ អាមន្តេហិ សត្ថា តំ អាវុសោ សាតិ អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា យេន សាតិ ភិក្ខុ កេវដ្ដបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា សាតឹ ភិក្ខុំ កេវដ្ដបុត្តំ ឯតទវោច

ព្រះមានព្រះភាគទ្រង់សំដែងហើយ ដោយអនេកបរិយាយថា វិញ្ញាណកើតឡើង ព្រោះអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យហើយ ការកើតឡើងនៃវិញ្ញាណក៏មិនមាន បពិត្រព្រះអង្គដ៏ចម្រើន សាតិភិក្ខុកេវដ្តបុត្តនោះ កាលបើយើងខ្ញុំព្រះអង្គបាននិយាយពន្យល់ដាស់តឿនក្រើនរំលឹកយ៉ាងនេះហើយ ក៏នៅតែចូលចិត្តប្រកាន់ទិដ្ឋិអាក្រក់នោះដដែល ហើយនិយាយប្រកែកតាមកម្លាំងថា ម្នាលអាវុសោទាំងឡាយ វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា ខ្ញុំបានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយ ក៏យ៉ាងនោះដែរដូច្នេះមែន បពិត្រព្រះអង្គដ៏ចម្រើន កាលដែលយើងខ្ញុំព្រះអង្គមិនអាចនឹងដោះសាតិភិក្ខុកេវដ្តបុត្ត ឲ្យរួចចាកទិដ្ឋិអាក្រក់នេះបានហើយ ទើបយើងខ្ញុំព្រះអង្គយកសេចក្តីនេះ មកក្រាបបង្គំទូលព្រះមានព្រះភាគ ។

[៨២] គ្រានោះ ព្រះមានព្រះភាគ ត្រាស់ហៅនូវភិក្ខុ ១ រូបមកថា ម្នាលភិក្ខុ ចូរអ្នកមកអាយ ចូរអ្នកទៅហៅនូវសាតិភិក្ខុកេវដ្តបុត្តតាមពាក្យនៃតថាគតថា ម្នាលអាវុសោសាតិ ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ករុណា ព្រះអង្គ ដូច្នេះហើយ ក៏ចូលទៅរកសាតិភិក្ខុកេវដ្តបុត្តលុះចូលទៅដល់ហើយ បាននិយាយទៅនឹងសាតិភិក្ខុកេវដ្តបុត្តដូច្នេះថា

សត្ថា តំ អាវុសោ សាតិ អាមន្តេតីតិ ។ ឯវមាវុសោតិ ខោ សាតិ ភិក្ខុ កេវដ្ដបុត្តោ តស្ស ភិក្ខុនោ បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ សាតឹ ភិក្ខុំ[១] កេវដ្ដបុត្តំ ភគវា ឯតទវោច សច្ចំ កិរ តេ សាតិ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា តទេវិទំ វិញ្ញាណំ សន្ធាវតិ សំសរតិ អនញ្ញន្តិ ។ ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា តទេវិទំ វិញ្ញាណំ សន្ធាវតិ សំសរតិ អនញ្ញន្តិ ។ កតមន្តំ[២] សាតិ វិញ្ញាណន្តិ ។ យ្វាយំ ភន្តេ វទោ វេទេយ្យោ តត្រ តត្រ កល្យាណបាបកានំ កម្មានំ វិបាកំ បដិសំវេទេតីតិ ។

---

១ ម. ភិក្ខុន្តិ ន ទិស្សតិ ។ ២ ម. យំ កតមន្តំ ។

ម្នាលអាវុសោសាតិ ព្រះសាស្តាត្រាស់ហៅលោក ។ សាតិភិក្ខុកេវដ្តបុត្ត ទទួលពាក្យភិក្ខុនោះថា ករុណា អាវុសោ ដូច្នេះហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីដ៏សមគួរ ។ កាលបើសាតិភិក្ខុកេវដ្តបុត្តអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលសាតិ បានឮថាអ្នកមានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា ខ្ញុំបានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះមែនឬ ។ សាតិភិក្ខុកេវដ្តបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជារបស់ដទៃឡើយ យ៉ាងណា ខ្ញុំព្រះអង្គបានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសំដែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះមែន ។ ព្រះអង្គត្រាស់សួរថា ម្នាលសាតិ វិញ្ញាណនោះតើដូចម្តេច ។ សាតិភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន សភាវៈណា ដែលនិយាយបាន អាចទទួលអារម្មណ៍បាន បុគ្គលរមែងសោយវិបាកនៃកម្មទាំងឡាយល្អនិងអាក្រក់ព្រោះសភាវៈនោះ សភាវៈនោះ (ហៅថាវិញ្ញាណ) ។

កស្ស នុ ខោ នាម ត្វំ មោឃបុរិស មយា ឯវំ ធម្មំ ទេសិតំ អាជានាសិ ននុ មយា មោឃបុរិស អនេកបរិយាយេន បដិច្ចសមុប្បន្នំ វិញ្ញាណំ វុត្តំ អញ្ញត្រ បច្ចយា នត្ថិ វិញ្ញាណស្ស សម្ភវោតិ អថ ច បន ត្វំ មោឃបុរិស អត្តនា ទុគ្គហិតេន អម្ហេ ចេវ អព្ភាចិក្ខសិ អត្តានញ្ច ខណសិ ពហុញ្ច អបុញ្ញំ បសវសិ តញ្ហិ តេ មោឃបុរិស ភវិស្សតិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។

[៨៣] អថខោ ភគវា ភិក្ខូ អាមន្តេសិ តំ កឹ មញ្ញថ ភិក្ខវេ អបិនាយំ សាតិ ភិក្ខុ កេវដ្ដបុត្តោ ឧស្មីកតោបិ ឥមស្មឹ ធម្មវិនយេតិ ។ កិញ្ហិ សិយា ភន្តេ នោ ហេតំ ភន្តេតិ ។ ឯវំ វុត្តេ សាតិ ភិក្ខុ កេវដ្ដបុត្តោ តុណ្ហីភូតោ មង្កុភូតោ បត្តក្ខន្ធោ អធោមុខោ បជ្ឈាយន្តោ អប្បដិភាណោ និសីទិ ។

ព្រះអង្គត្រាស់ថា ម្នាលមោឃបុរស អ្នកដឹងច្បាស់នូវធម៌ដែលតថាគតសំដែងហើយ យ៉ាងណា អំពីសំណាក់បុគ្គលណា ម្នាលមោឃបុរស ក្រែងតថាគត បានសំដែងហើយ ដោយអនេកបរិយាយថា វិញ្ញាណកើតឡើងព្រោះអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យហើយ ការកើតឡើងនៃវិញ្ញាណក៏មិនមានដូច្នោះទេឬ ម្នាលមោឃបុរស ហេតុដូចម្តេច ក៏បានជាអ្នក ពោលបង្កាច់តថាគត ដោយគំនិតដែលខ្លួនប្រកាន់ខុសវិញ អ្នកឈ្មោះថាគាស់រំលើងនូវខ្លួនផង ឈ្មោះថាសោយនូវអកុសលដ៏ច្រើនផង ម្នាលមោឃបុរស ព្រោះថា គំនិតដែលប្រកាន់ខុសរបស់អ្នកនោះនឹងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលយូរអង្វែង ។

[៨៣] គ្រានោះឯង ព្រះមានព្រះភាគត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះថាដូចម្តេច សាតិភិក្ខុកេវដ្តបុត្តនេះ ឈ្មោះថាធ្វើឲ្យកក់ក្តៅក្នុងធម្មវិន័យនោះបានឬទេ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធ្វើដូចម្តេចនឹងបាន បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះមិនមែនដូច្នោះទេ ។ កាលដែលពួកភិក្ខុនិយាយយ៉ាងនេះហើយ សាតិភិក្ខុកេវដ្តបុត្តក៏នៅស្ងៀម អៀនខ្មាសឱនកចុះ សំយុងមុខចុះ អង្គុយសញ្ជប់សញ្ជឹង មិនមានប្រាជ្ញា ។

មហាយមកវគ្គស្ស  មហាតណ្ហាសង្ខយសុត្តេ  តំទិដ្ឋិបដិបុច្ឆា

អថខោ ភគវា សាតឹ ភិក្ខុំ កេវដ្ដបុត្តំ តុណ្ហីភូតំ មង្កុភូតំ បត្តក្ខន្ធំ អធោមុខំ បជ្ឈាយន្តំ អប្បដិភាណំ វិទិត្វា សាតឹ ភិក្ខុំ កេវដ្ដបុត្តំ ឯតទវោច បញ្ញាយិស្សសិ ខោ ត្វំ មោឃបុរិស ឯតេន សកេន បាបកេន ទិដ្ឋិគតេន ឥធាហំ ភិក្ខូ បដិបុច្ឆិស្សាមីតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ តុម្ហេបិ មេ ភិក្ខវេ ឯវំ ធម្មំ ទេសិតំ អាជានាថ យថាយំ សាតិ ភិក្ខុ កេវដ្ដបុត្តោ អត្តនា ទុគ្គហិតេន អម្ហេ ចេវ អព្ភាចិក្ខតិ អត្តានញ្ច ខនតិ ពហុញ្ច អបុញ្ញំ បសវតីតិ ។ នោ ហេតំ ភន្តេ អនេកបរិយាយេន ហិ នោ ភន្តេ បដិច្ចសមុប្បន្នំ វិញ្ញាណំ វុត្តំ ភគវតា អញ្ញត្រ បច្ចយា នត្ថិ វិញ្ញាណស្ស សម្ភវោតិ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសាតិភិក្ខុកេវដ្តបុត្ត នៅស្ងៀម អៀនខ្មាស ឱនកចុះ សំយុងមុខចុះ អង្គុយសញ្ជប់សញ្ជឹង មិនមានប្រាជ្ញាហើយ ទើបត្រាស់សួរសាតិភិក្ខុកេវដ្តបុត្តថា ម្នាលមោឃបុរស អ្នកប្រាកដជានៅតែប្រកាន់ខ្ជាប់ដោយទិដ្ឋិអាក្រក់របស់ខ្លួននេះតែម្យ៉ាងឬ តថាគតនឹងអាលសាកសួរពួកភិក្ខុដែលនៅក្នុងទីនេះ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ សាតិភិក្ខុកេវដ្តបុត្តនេះ ពោលបង្កាច់តថាគត ដោយគំនិតដែលខ្លួនប្រកាន់ខុសផង ឈ្មោះថាគាស់រំលើងនូវខ្លួនផង ឈ្មោះថាទទួលនូវអកុសលដ៏ច្រើនផង យ៉ាងណា ចំណែកអ្នកទាំងឡាយ នឹងយល់ច្បាស់នូវធម៌ដែលតថាគតសំដែងហើយ យ៉ាងនោះដែរឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គមិនបានយល់ដូច្នោះទេ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាព្រះមានព្រះភាគ បានសំដែងប្រោសយើងខ្ញុំព្រះអង្គដោយអនេកបរិយាយថា វិញ្ញាណកើតឡើង ព្រោះអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យហើយ ការកើតឡើងនៃវិញ្ញាណ ក៏មិនមាន ។

សាធុ ភិក្ខវេ សាធុ ខោ មេ តុម្ហេ ភិក្ខវេ ឯវំ ធម្មំ ទេសិតំ អាជានាថ អនេកបរិយាយេន ហិ ភិក្ខវេ បដិច្ចសមុប្បន្នំ វិញ្ញាណំ វុត្តំ មយា អញ្ញត្រ បច្ចយា នត្ថិ វិញ្ញាណស្ស សម្ភវោតិ អថ ច បនា-យំ សាតិ ភិក្ខុ កេវដ្ដបុត្តោ អត្តនា ទុគ្គហិតេន អម្ហេ ចេវ អព្ភាចិក្ខតិ អត្តានញ្ច ខនតិ ពហុញ្ច អបុញ្ញំ បសវតិ តញ្ហិ តស្ស មោឃបុរិសស្ស ភវិស្សតិ ទីឃរត្តំ អហិតាយ ទុក្ខាយ ។

[៨៤] យញ្ញទេវ ភិក្ខវេ បច្ចយំ បដិច្ច ឧប្បជ្ជតិ វិញ្ញាណំ តេន តេនេវ សង្ខ្យំ[១] គច្ឆតិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ វិញ្ញាណំ ចក្ខុវិញ្ញាណន្តេ្វវ សង្ខ្យំ គច្ឆតិ សោតញ្ច បដិច្ច សទ្ទេ ច ឧប្បជ្ជតិ វិញ្ញាណំ សោតវិញ្ញាណន្តេ្វវ សង្ខ្យំ គច្ឆតិ ឃានញ្ច បដិច្ច គន្ធេ ច ឧប្បជ្ជតិ វិញ្ញាណំ ឃានវិញ្ញាណន្តេ្វវ សង្ខ្យំ គច្ឆតិ

១ ឱ. សង្ខន្តិ ទិស្សតិ ឯវំ សព្វត្ថ ។

ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យអ្នកទាំងឡាយនោះត្រូវពិតហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ច្បាស់នូវធម៌ ដែលតថាគតសំដែងហើយយ៉ាងនេះ ជាការប្រពៃពិត ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគតបានសំដែងហើយ ដោយអនេកបរិយាយថា វិញ្ញាណកើតឡើង ព្រោះអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យហើយ ការកើតឡើងនៃវិញ្ញាណក៏មិនមាន បើដូច្នោះសាតិភិក្ខុកេវដ្តបុត្តនេះ ពិតជាពោលបង្កាច់តថាគតដោយគំនិតដែលខ្លួនប្រកាន់ខុសផង ឈ្មោះថាគាស់រំលើងនូវខ្លួនផង ឈ្មោះថាទទួល នូវអកុសលដ៏ច្រើនផង ព្រោះថាការប្រកាន់ខុសរបស់មោឃបុរសនោះ នឹងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលយូរអង្វែង ។

[៨៤] ម្នាលភិក្ខុទាំងឡាយ វិញ្ញាណកើតឡើងព្រោះអាស្រ័យបច្ច័យណា ៗ ក៏ដល់នូវកិរិយារាប់តាមបច្ច័យនោះ ៗ ដូចវិញ្ញាណកើតឡើងព្រោះអាស្រ័យភ្នែកនិងរូប ដល់នូវកិរិយារាប់ថាចក្ខុវិញ្ញាណ (ការដឹងដោយសារភ្នែក) វិញ្ញាណកើតឡើង ព្រោះអាស្រ័យត្រចៀកនិងសំឡេង ដល់នូវកិរិយារាប់ថាសោតវិញ្ញាណ (ការដឹងដោយសារត្រចៀក) វិញ្ញាណកើតឡើង ព្រោះអាស្រ័យច្រមុះនិងក្លិន ដល់នូវកិរិយារាប់ថាឃានវិញ្ញាណ

១៤៩



ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ វិញ្ញាណំ ជិវ្ហាវិញ្ញាណន្ត្វេវ សង្ខ្យំ គច្ឆតិ កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ឧប្បជ្ជតិ វិញ្ញាណំ កាយវិញ្ញាណន្ត្វេវ សង្ខ្យំ គច្ឆតិ មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ វិញ្ញាណំ មនោវិញ្ញាណន្ត្វេវ សង្ខ្យំ គច្ឆតិ ។ សេយ្យថាបិ ភិក្ខវេ យញ្ញទេវ បដិច្ច អគ្គិ ជលតិ តេន តេនេវ សង្ខ្យំ គច្ឆតិ កដ្ឋញ្ច បដិច្ច អគ្គិ ជលតិ កដ្ឋគ្គិត្វេវ សង្ខ្យំ គច្ឆតិ សកលិកញ្ច បដិច្ច អគ្គិ ជលតិ សកលិកគ្គិត្វេវ សង្ខ្យំ គច្ឆតិ តិណញ្ច បដិច្ច អគ្គិ ជលតិ តិណគ្គិត្វេវ សង្ខ្យំ គច្ឆតិ គោមយញ្ច បដិច្ច អគ្គិ ជលតិ គោមយគ្គិត្វេវ សង្ខ្យំ គច្ឆតិ ថុសញ្ច បដិច្ច អគ្គិ ជលតិ ថុសគ្គិត្វេវ សង្ខ្យំ គច្ឆតិ សង្ការញ្ច បដិច្ច អគ្គិ ជលតិ សង្ការគ្គិត្វេវ សង្ខ្យំ គច្ឆតិ ឯវមេវ ខោ ភិក្ខវេ យញ្ញទេវ បច្ចយំ បដិច្ច ឧប្បជ្ជតិ វិញ្ញាណំ

(ការដឹងដោយសារច្រមុះ) វិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាត និងរស ដល់នូវកិរិយារាប់ថា ជិវ្ហាវិញ្ញាណ (ការដឹងដោយសារអណ្តាត) វិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយនិងរបស់ដែលប៉ះនឹងកាយ ដល់នូវកិរិយារាប់ថា កាយវិញ្ញាណ (ការដឹងដោយសារកាយ) វិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ដល់នូវកិរិយារាប់ថា មនោ-វិញ្ញាណ (ការដឹងដោយសារចិត្ត) ។ ម្នាលភិក្ខុទាំងឡាយ ដូចជាភ្លើងឆេះ អាស្រ័យនឹងវត្ថុណា ៗ ក៏ដល់នូវកិរិយារាប់ តាមវត្ថុនោះ ៗ ដូចជាភ្លើងឆេះ ព្រោះអាស្រ័យឧស ដល់នូវកិរិយារាប់ថា ភ្លើងឧស ភ្លើងឆេះព្រោះអាស្រ័យប្រឆេះឬប៉ុយ ដល់នូវកិរិយារាប់ថា ភ្លើងប៉ុយ ភ្លើងឆេះព្រោះអាស្រ័យស្មៅ ដល់នូវកិរិយារាប់ថា ភ្លើងស្មៅ ភ្លើងឆេះព្រោះអាស្រ័យអាចម៍គោ ដល់នូវកិរិយារាប់ថា ភ្លើងអាចម៍គោ ភ្លើងឆេះព្រោះអាស្រ័យអង្កាម ដល់នូវកិរិយារាប់ថា ភ្លើងអង្កាម ភ្លើងឆេះព្រោះអាស្រ័យសម្រាម ដល់នូវកិរិយារាប់ថា ភ្លើងសម្រាម យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណកើតឡើង ព្រោះអាស្រ័យនឹងបច្ច័យណា ៗ

តេន តេនេវ សង្ខ្យំ គច្ឆតិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ វិញ្ញាណំ ចក្ខុវិញ្ញាណន្តេ្វវ សង្ខ្យំ គច្ឆតិ សោតញ្ច បដិច្ច សទ្ទេ ច ឧប្បជ្ជតិ វិញ្ញាណំ សោត-វិញ្ញាណន្តេ្វវ សង្ខ្យំ គច្ឆតិ ឃានញ្ច បដិច្ច គន្ធេ ច ឧប្បជ្ជតិ វិញ្ញាណំ ឃានវិញ្ញាណន្តេ្វវ សង្ខ្យំ គច្ឆតិ ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ វិញ្ញាណំ ជិវ្ហាវិញ្ញា-ណន្តេ្វវ សង្ខ្យំ គច្ឆតិ កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ឧប្បជ្ជតិ វិញ្ញាណំ កាយវិញ្ញាណន្តេ្វវ សង្ខ្យំ គច្ឆតិ មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ វិញ្ញាណំ មនោ-វិញ្ញាណន្តេ្វវ សង្ខ្យំ គច្ឆតិ ។

[៨៤] ភូតមិទំ ភិក្ខវេ បស្សថាតិ ។ ឯវំ ភន្តេ ។ តទាហារសម្ភវន្តិ ភិក្ខវេ បស្សថាតិ ។ ឯវំ ភន្តេ ។ តទាហារនិរោធា យំ ភូតំ តំ និរោធធម្មន្តិ ភិក្ខវេ បស្សថាតិ ។ ឯវំ ភន្តេ ។ ភូតមិទំ នោស្សូតិ ភិក្ខវេ កង្ខាតោ ឧប្បជ្ជតិ វិចិកិច្ឆាតិ ។ ឯវំ ភន្តេ ។

ក៏ដល់នូវកិរិយារាប់តាមបច្ច័យនោះ ។ ដូចជាវិញ្ញាណកើតឡើងព្រោះអាស្រ័យភ្នែកនិងរូប ដល់នូវកិរិយារាប់ថាចក្ខុវិញ្ញាណ វិញ្ញាណកើតឡើងព្រោះអាស្រ័យត្រចៀកនិងសំឡេង ដល់នូវកិរិយារាប់ថាសោតវិញ្ញាណ វិញ្ញាណកើតឡើងព្រោះអាស្រ័យច្រមុះនិងក្លិន ដល់នូវកិរិយារាប់ថាឃានវិញ្ញាណ វិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាតនិងរស ដល់នូវកិរិយារាប់ថាជិវ្ហាវិញ្ញាណ វិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយនិងរបស់ដែលប៉ះដោយកាយ ដល់នូវកិរិយារាប់ថាកាយវិញ្ញាណ វិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ដល់នូវកិរិយារាប់ថាមនោវិញ្ញាណ យ៉ាងនោះដែរ ។

[៨៥] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញនូវខន្ធបញ្ចកៈនេះដែលកើតឡើងហើយឬទេ ។ ពួកភិក្ខុក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញថា ខន្ធបញ្ចកៈនោះកើតឡើងព្រោះតែអាហារដូច្នោះឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញថា ខន្ធបញ្ចកៈនោះដែលកើតឡើងហើយរមែងរលត់ទៅវិញជាធម្មតា ព្រោះរលត់អាហារនោះដែរឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ វិចិកិច្ឆាតែងកើតឡើងព្រោះសេចក្តីសង្ស័យថា ខន្ធបញ្ចកៈនេះកើតហើយឬមិនកើតទេ ដូច្នេះដែរឬទេ ។ ព្រះករុណាព្រះអង្គ ។

១៦១



តទាហារសម្ភវំ នោ ស្សុតិ ភិក្ខវេ កង្ខាតោ ឧប្បជ្ជតិ វិចិកិច្ឆាតិ ។ ឯវំ ភន្តេ ។ ភន្តេ តទាហារនិរោធា យំ ភូតំ តំ និរោធធម្មំ នោ ស្សុតិ ភិក្ខវេ កង្ខាតោ ឧប្បជ្ជតិ វិចិកិច្ឆាតិ ។ ឯវំ ភន្តេ ។ ភូតមិទន្តិ ភិក្ខវេ យថាភូតំ សម្មប្បញ្ញាយ បស្សតោ យា វិចិកិច្ឆា សា បហីយតីតិ ។ ឯវំ ភន្តេ ។ តទាហារសម្ភវន្តិ ភិក្ខវេ យថាភូតំ សម្មប្បញ្ញាយ បស្សតោ យា វិចិកិច្ឆា សា បហីយតីតិ ។ ឯវំ ភន្តេ ។ តទាហារនិរោធា យំ ភូតំ តំ និរោធធម្មន្តិ ភិក្ខវេ យថាភូតំ សម្មប្បញ្ញាយ បស្សតោ យា វិចិកិច្ឆា សា បហីយតីតិ ។ ឯវំ ភន្តេ ។ ភូតមិទន្តិ ភិក្ខវេ ឥតិបិ វោ ឯត្ថ និព្វិចិកិច្ឆាតិ[១] ។ ឯវំ ភន្តេ ។ តទាហារសម្ភវន្តិ ភិក្ខវេ

---

១ ឱ. និវិចិកិច្ឆាតិ ។

ម្នាលភិក្ខុទាំងឡាយ វិចិកិច្ឆាកើតឡើង ព្រោះសេចក្តីសង្ស័យថា ខន្ធ-បញ្ចកៈតែងកើតឡើងព្រោះអាហារនោះ ឬមិនមែនទេ ដូច្នេះដែរឬ ។ ព្រះករុណាព្រះអង្គ ។ វិចិកិច្ឆាកើតឡើង ព្រោះសេចក្តីសង្ស័យថា ខន្ធ-បញ្ចកៈដែលកើតហើយ រលត់ទៅវិញជាធម្មតា ព្រោះតែរលត់អាហារនោះ ឬមិនមែន ដូច្នេះឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលឃើញច្បាស់ ដោយបញ្ញាដ៏ប្រពៃតាមពិតថា ខន្ធបញ្ចកៈនេះកើតហើយដូច្នេះ បុគ្គលនោះឈ្មោះថាលះបង់វិចិកិច្ឆាបានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃតាមពិតថា ខន្ធបញ្ចកៈកើតឡើង ព្រោះអាហារនោះដូច្នេះ បុគ្គលនោះឈ្មោះថាលះបង់វិចិកិច្ឆាបានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃតាមពិតថា ខន្ធបញ្ចកៈដែលកើតហើយ រមែងរលត់ទៅវិញជាធម្មតា ព្រោះរលត់អាហារនោះដូច្នេះ បុគ្គលនោះឈ្មោះថាលះបង់វិចិកិច្ឆាបានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មិនមានវិចិកិច្ឆា ក្នុងខន្ធបញ្ចកៈនុ៎ះថា ខន្ធបញ្ចកៈនេះកើតហើយ ដូច្នេះឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ

ឥតិបិ ខោ ឯតំ និព្ពិចិកិច្ឆាតិ ។ ឯវំ ភន្តេ ។ តទាហារនិរោធា យំ ភូតំ តំ និរោធធម្មន្តិ ភិក្ខវេ ឥតិបិ ខោ ឯតំ និព្ពិចិកិច្ឆាតិ ។ ឯវំ ភន្តេ ។ ភូតមិទន្តិ ភិក្ខវេ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋន្តិ ។ ឯវំ ភន្តេ ។ តទាហារសម្ភវន្តិ ភិក្ខវេ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋន្តិ ។ ឯវំ ភន្តេ ។ តទាហារនិរោធា យំ ភូតំ តំ និរោធធម្មន្តិ ភិក្ខវេ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋន្តិ ។ ឯវំ ភន្តេ ។ ឥមញ្ច តុម្ហេ ភិក្ខវេ ទិដ្ឋឹ ឯវំ បរិសុទ្ធំ ឯវំ បរិយោទាតំ អល្លីយេថ កេឡាយេថ ធនាយេថ មមាយេថ អបិ នុ តុម្ហេ ភិក្ខវេ

អ្នកទាំងឡាយមិនមានវិចិកិច្ឆាក្នុងខន្ធបញ្ចកៈនោះថា ខន្ធបញ្ចកៈនោះកើតឡើងព្រោះអាហារដូច្នេះឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនមានវិចិកិច្ឆាក្នុងខន្ធបញ្ចកៈនុ៎ះថា ខន្ធបញ្ចកៈដែលកើតឡើងរមែងរលត់ទៅវិញជាធម្មតា ព្រោះរលត់អាហារនោះ ដូច្នេះឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ត្រូវដោយបញ្ញាដ៏ប្រពៃ តាមសេចក្ដីពិតថា ខន្ធបញ្ចកៈនេះកើតហើយ ដូច្នេះឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ឃើញត្រូវដោយបញ្ញាដ៏ល្អតាមពិតថា ខន្ធបញ្ចកៈកើតឡើង ព្រោះអាហារដូច្នេះឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ឃើញត្រូវដោយប្រាជ្ញាដ៏ប្រពៃតាមសេចក្ដីពិតថា ខន្ធបញ្ចកៈដែលកើតហើយ រមែងរលត់ទៅវិញជាធម្មតា ព្រោះរលត់អាហារនោះដូច្នេះឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយជាប់ចំពាក់ រីករាយ ក្ដួចកាន់ រាប់អានទិដ្ឋិ[១]នេះថា បរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ដោយតណ្ហានិងទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ ចុះអ្នក

---

១ ទិដ្ឋិក្នុងទីនេះ សំដៅយកវិបស្សនាសម្មាទិដ្ឋិ ។

កុល្លូបមំ ធម្មំ ទេសិតំ អាជានេយ្យាថ និត្ថរណត្ថាយ នោ គហណត្ថាយាតិ ។ នោ ហេតំ ភន្តេ ។ ឥមញ្ចេ តុម្ហេ ភិក្ខវេ ទិដ្ឋឹ ឯវំ បរិសុទ្ធំ ឯវំ បរិយោទាតំ ន អល្លីយេថ ន កេឡាយេថ ន ធនាយេថ ន មមាយេថ អបិ នុ មេ[១] តុម្ហេ ភិក្ខវេ កុល្លូបមំ ធម្មំ ទេសិតំ អាជានេយ្យាថ និត្ថរណត្ថាយ នោ គហណត្ថាយាតិ ។ ឯវំ ភន្តេ ។

[៨៦] ចត្តារោមេ ភិក្ខវេ អាហារា ភូតានំ វា សត្តានំ ឋិតិយា សម្ភវេសីនំ វា សត្តានំ អនុគ្គហាយ ។ កតមេ ចត្តារោ ។ កពឡិង្ការោ[២] អាហារោ ឱឡារិកោ វា សុខុមោ

១ ឱ. ម. មេតិ ន ទិស្សតិ ។ ២ ឱ. កពឡិង្ការោ ។ ម. កពឡីការោ ។

ទាំងឡាយយល់ច្បាស់ នូវធម៌មានឧបមាដូចជាផែ ដែលតថាគតសំដែង ហើយដើម្បីប្រយោជន៍នឹងឆ្លងចេញ (ចាកឱឃៈទាំង ៤) មិនមែនដើម្បីប្រយោជន៍នឹងប្រកាន់ (ខន្ធបញ្ចកៈ) ខ្វះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយមិនជាប់ចំពាក់ មិនរីករាយ មិនក្តួចកាន់ មិនរាប់អានទិដ្ឋិនេះថា បរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ដោយអំណាចតណ្ហានិងទិដ្ឋិទេ ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយយល់ច្បាស់នូវធម៌មានឧបមាដូចជាផែ ដែលតថាគតសំដែង ហើយដើម្បីនឹងឆ្លងចេញ (ចាកឱឃៈទាំង ៤) មិនមែនប្រយោជន៍នឹងប្រកាន់ (ខន្ធបញ្ចកៈ) ខ្វះឬទេ ។ ព្រះករុណា ព្រះអង្គ ។

[៨៦] ម្នាលភិក្ខុទាំងឡាយ អាហារដែលប្រព្រឹត្តទៅ ដើម្បីតាំងនៅមាំ របស់ពួកសត្វដែលកើតហើយផង ប្រព្រឹត្តទៅ ដើម្បីអនុគ្រោះដល់សត្វដែលកំពុងកើតផង នេះមាន ៤ ប្រការ ។ អាហារទាំង ៤ ប្រការតើដូចម្តេច ។ គឺ កវឡិង្ការាហារដែលគ្រោតគ្រាតឬល្អិតជាទី ១

រា ផស្សោ ទុតិយោ មនោសញ្ចេតនា តតិយា វិញ្ញាណំ ចតុត្ថំ ។ ឥមេ ច ភិក្ខវេ ចត្តារោ អាហារា កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវា ឥមេ ចត្តារោ អាហារា តណ្ហានិទានា តណ្ហាសមុទយា តណ្ហាជាតិកា តណ្ហាបភវា ។ តណ្ហា ចាយំ ភិក្ខវេ កឹនិទានា

ផស្សាហារជាទី ២ មនោសញ្ចេតនាហារជាទី ៣ វិញ្ញាណាហារជាទី ៤[១] ម្នាលភិក្ខុទាំងឡាយ ចុះអាហារទាំង ៤ នេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ អាហារទាំង ៤ នេះ មានតណ្ហាជាហេតុ មានតណ្ហានាំឲ្យកើត មានតណ្ហាជាកំណើត មានតណ្ហាជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏តណ្ហានេះមានអ្វីជាហេតុ

---

១ កវឡិង្ការាហារ ទី ១ ដែលចាត់ជា ២ គឺជាគ្រោតគ្រាតនិងល្អិតនោះ ដោយសេចក្តីប្រៀបធៀបគ្នាដូចសត្វក្រពើលេបថ្ម បើប្រៀបនឹងអាហារសត្វក្ងោកដែលស៊ីពស់និងស្កានោះ អាហារក្រពើជាអាហារ គ្រោតគ្រាត អាហារសត្វក្ងោកជាអាហារល្អិត ។ បេ ។ អាហារពួកទេវតាជាន់បរនិម្មិតវសវត្តី ជាអាហារសុខុមល្អិតជាងអាហាររបស់ពួកទេវតាជាន់និម្មានរតី ៗ ជាអាហារគ្រោតគ្រាត ។ អាហារសុខុមមានរសជាតិជាងអាហារគ្រោតគ្រាត ។ កវឡិង្ការាហារនេះ ប្រមូលមកនូវឱជារស ៨ ប្រការ គឺ បឋវី អាបោ តេជោ វាយោ វណ្ណោ គន្ធោ រសោ ឱជា ។ ផស្សាហារ ទី ២ បានដល់វេទនាទាំង ៣ ដែលកើតអំពីការប៉ះពាល់សម្ផស្ស ៦ យ៉ាង ។ មនោសញ្ចេតនាហារ ទី ៣ នោះ លោកសំដៅយកចេតនាកម្មទាំង ៣ ប្រការ ដែលអាចប្រមូលមកនូវបដិសន្ធិក្នុងត្រៃភព ។ វិញ្ញាណាហារ ទី ៤ នោះ បានដល់ចិត្តណាមួយ ដែលនាំមកនូវរូបក្នុងខណៈបដិសន្ធិក្នុងត្រៃភពនោះ ។ អាហារទាំង ៤ នេះបើចង់ដឹងសេចក្តីពិស្តារ ចូរមើលក្នុងគម្ពីរបបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ មូលបណ្ណាសកៈ ត្រង់សម្មាទិដ្ឋិសុត្តវណ្ណនា ។

កឹសមុទយា កឹជាតិកា កឹបភវា ។ តណ្ហា វេទនានិទានា វេទនាសមុទយា វេទនាជាតិកា វេទនាបភវា ។ វេទនា ចាយំ ភិក្ខវេ កឹនិទានា កឹសមុទយា កឹជាតិកា កឹបភវា ។ វេទនា ផស្សនិទានា ផស្សសមុទយា ផស្សជាតិកា ផស្ស-ប្បភវា ។ ផស្សោ ចាយំ ភិក្ខវេ កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោ ។ ផស្សោ សឡាយតននិទានោ សឡាយតនសមុទយោ សឡា-យតនជាតិកោ សឡាយតនប្បភវោ ។ សឡាយ-តនញ្ចិទំ ភិក្ខវេ កឹនិទានំ កឹសមុទយំ កឹជាតិកំ កឹបភវំ ។ សឡាយតនំ នាមរូបនិទានំ នាមរូបស-មុទយំ នាមរូបជាតិកំ នាមរូបប្បភវំ ។ នាមរូបញ្ចិទំ ភិក្ខវេ កឹនិទានំ កឹសមុទយំ កឹជាតិកំ កឹបភវំ ។ នាមរូបំ វិញ្ញាណនិទានំ វិញ្ញាណសមុទយំ វិញ្ញាណ-ជាតិកំ វិញ្ញាណប្បភវំ ។ វិញ្ញាណញ្ចិទំ ភិក្ខវេ កឹនិទានំ កឹសមុទយំ កឹជាតិកំ កឹបភវំ ។ វិញ្ញាណំ សង្ខារនិទានំ សង្ខារសមុទយំ សង្ខារជាតិកំ

មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ តណ្ហាមានវេទនាជាហេតុ មានវេទនានាំឲ្យកើត មានវេទនាជាកំណើត មានវេទនាជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏វេទនានេះមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ វេទនាមានផស្សៈជាហេតុ មានផស្សៈនាំឲ្យកើត មានផស្សៈជាកំណើត មានផស្សៈជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏ផស្សៈនេះមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ ផស្សៈមានសឡាយតនៈជាហេតុ មានសឡាយតនៈនាំឲ្យកើត មានសឡាយតនៈជាកំណើត មានសឡាយតនៈជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏សឡាយតនៈនេះមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ សឡាយតនៈមាននាមរូបជាហេតុ មាននាមរូបនាំឲ្យកើត មាននាមរូបជាកំណើត មាននាមរូបជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏នាមរូបនេះមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ នាមរូបមានវិញ្ញាណជាហេតុ មានវិញ្ញាណនាំឲ្យកើត មានវិញ្ញាណជាកំណើត មានវិញ្ញាណជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏វិញ្ញាណនេះមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ វិញ្ញាណមានសង្ខារជាហេតុ មានសង្ខារនាំឲ្យកើត មានសង្ខារជាកំណើត

សង្ខារប្បភវំ ។ សង្ខារា ចិមេ ភិក្ខវេ កិំនិទានា កិំសមុទយា កិំជាតិកា កិំបភវា ។ សង្ខារា អវិជ្ជានិទានា អវិជ្ជាសមុទយា អវិជ្ជាជាតិកា អវិជ្ជា-បភវា ។ ឥតិ ខោ ភិក្ខវេ អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេ-តស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[៨៧] ជាតិប្បច្ចយា ជរាមរណន្តិ ឥតិ ខោ បនេតំ វុត្តំ ជាតិប្បច្ចយា នុ ខោ ភិក្ខវេ ជរាមរណំ

មានសង្ខារជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏សង្ខារទាំងឡាយនេះមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ សង្ខារទាំងឡាយ មានអវិជ្ជាជាហេតុ មានអវិជ្ជានាំឲ្យកើត មានអវិជ្ជាជាកំណើត មានអវិជ្ជាជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយ-តនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ សេចក្តីចាស់ស្លាប់ (កើតមាន) ព្រោះជាតិជាបច្ច័យ ការសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងការចង្អៀតចង្អល់ទាំងឡាយ ក៏កើតមានព្រមឯកិរិយាកើតឡើងនៃកងទុក្ខទាំងអស់នេះរមែងមានយ៉ាងនេះដូច្នេះឯង[១] ។

[៨៧] ពាក្យថា ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យដូច្នេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះជរាមរណៈ

---

១ មើលសព្វនិងនយលក្ខណៈ ក្នុងវិនយបិដក ខ្សែ ៦ ត្រង់បឋមពោធិកាលចុះ ។

១៦៧



នោ វា កថំ វា ឯត្ថ ហោតីតិ ។ ជាតិប្បច្ចយា ភន្តេ ជរាមរណំ ឯវំ នោ ឯត្ថ ហោតិ[១] ជាតិប្បច្ចយា ជរាមរណន្តិ ។ ភវប្បច្ចយា ជាតីតិ ឥតិ ខោ បនេតំ វុត្តំ ភវប្បច្ចយា នុ ខោ ភិក្ខវេ ជាតិ នោ វា កថំ វា ឯត្ថ ហោតីតិ ។ ភវប្បច្ចយា ភន្តេ ជាតិ ឯវំ នោ ឯត្ថ ហោតិ ភវប្បច្ចយា ជាតីតិ ។ ឧបាទានប្បច្ចយា ភវោតិ ឥតិ ខោ បនេតំ វុត្តំ ឧបាទានប្បច្ចយា នុ ខោ ភិក្ខវេ ភវោ នោ វា កថំ វា ឯត្ថ ហោតីតិ ។ ឧបាទានប្បច្ចយា ភន្តេ ភវោ ឯវំ នោ ឯត្ថ ហោតិ ឧបាទានប្បច្ចយា ភវោតិ ។

១ ម. ហោតីតីតិ ទិស្សតិ ឯវំ សព្វត្ថ ។

កើតមាន ព្រោះជាតិជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនោះទេ ឬដោយប្រការដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្ដីយល់ឃើញក្នុងខន្ធ-បញ្ចកៈនុ៎ះយ៉ាងនេះថា ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យដែរ ។ ពាក្យថា ជាតិកើតមាន ព្រោះភពជាបច្ច័យ ដូច្នេះនេះ តថាគតបានសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះជាតិកើតមាន ព្រោះភពជាបច្ច័យមិនមានក្នុងខន្ធបញ្ចកៈនោះទេ ឬដោយប្រការដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន ជាតិកើតមាន ព្រោះភពជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្ដីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា ជាតិកើតមានព្រោះភពជាបច្ច័យដែរ ។ ពាក្យថា ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះភពកើតមាន ព្រោះឧបាទានជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនោះទេ ឬដោយប្រការដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន ភពកើតមាន ព្រោះឧបាទានជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្ដីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា ភពកើតមានព្រោះឧបាទានជាបច្ច័យដែរ ។

តណ្ហាបច្ចយា ឧបាទានន្តិ ឥតិ ខោ បនេតំ វុត្តំ តណ្ហាបច្ចយា នុ ខោ ភិក្ខវេ ឧបាទានំ នោ វា កថំ វា ឯត្ថ ហោតីតិ ។ តណ្ហាបច្ចយា ភន្តេ ឧបាទានំ ឯវំ នោ ឯត្ថ ហោតិ តណ្ហាបច្ចយា ឧបាទានន្តិ ។ វេទនាបច្ចយា តណ្ហាតិ ឥតិ ខោ បនេតំ វុត្តំ វេទនាបច្ចយា នុ ខោ ភិក្ខវេ តណ្ហា នោ វា កថំ វា ឯត្ថ ហោតីតិ ។ វេទនាបច្ចយា ភន្តេ តណ្ហា ឯវំ នោ ឯត្ថ ហោតិ វេទនាបច្ចយា តណ្ហាតិ ។ ផស្សប្បច្ចយា វេទនាតិ ឥតិ ខោ បនេតំ វុត្តំ ផស្សប្បច្ចយា នុ ខោ ភិក្ខវេ វេទនា នោ វា កថំ វា ឯត្ថ ហោតីតិ ។ ផស្សប្បច្ចយា ភន្តេ វេទនា ឯវំ នោ ឯត្ថ ហោតិ ផស្សប្បច្ចយា វេទនាតិ ។

ពាក្យថា ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យដូច្នេះនេះ តថាគតបាន សំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនោះ យ៉ាងនេះថា ឧបាទានកើតមាន ព្រោះតណ្ហា ជាបច្ច័យដែរ ។ ពាក្យថា តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យដែរ ។ ពាក្យថា វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះវេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន វេទនាកើតមានព្រោះផស្សៈ ជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យដែរ ។

សឡាយតនប្បច្ចយា ផស្សោតិ ឥតិ ខោ បនេតំ វុត្តំ សឡាយតនប្បច្ចយា នុ ខោ ភិក្ខវេ ផស្សោ នោ វា កថំ វា ឯត្ថ ហោតីតិ ។ សឡាយតនប្បច្ចយា ភន្តេ ផស្សោ ឯវំ នោ ឯត្ថ ហោតិ សឡាយត-នប្បច្ចយា ផស្សោតិ ។ នាមរូបប្បច្ចយា សឡាយ-តនន្តិ ឥតិ ខោ បនេតំ វុត្តំ នាមរូបប្បច្ចយា នុ ខោ ភិក្ខវេ សឡាយតនំ នោ វា កថំ វា ឯត្ថ ហោតីតិ ។ នាមរូបប្បច្ចយា ភន្តេ សឡាយតនំ ឯវំ នោ ឯត្ថ ហោតិ នាមរូបប្បច្ចយា សឡាយត-នន្តិ ។ វិញ្ញាណប្បច្ចយា នាមរូបន្តិ ឥតិ ខោ បនេតំ វុត្តំ វិញ្ញាណប្បច្ចយា នុ ខោ ភិក្ខវេ នាមរូបំ

ពាក្យថា ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ ដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា ផស្សៈកើតមានព្រោះសឡាយតនៈជាបច្ច័យដែរ ។ ពាក្យថា សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យដែរ ។ ពាក្យថា នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដូច្នេះនេះ តថាគតបានសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះនាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ

នោ វា កថំ វា ឯត្ថ ហោតីតិ ។ វិញ្ញាណប្បច្ចយា ភន្តេ នាមរូបំ ឯវំ នោ ឯត្ថ ហោតិ វិញ្ញាណប្បច្ចយា នាមរូបន្តិ ។ សង្ខារប្បច្ចយា វិញ្ញាណន្តិ ឥតិ ខោ បនេតំ វុត្តំ សង្ខារប្បច្ចយា នុ ខោ ភិក្ខវេ វិញ្ញាណំ នោ វា កថំ វា ឯត្ថ ហោតីតិ ។ សង្ខារប្បច្ចយា ភន្តេ វិញ្ញាណំ ឯវំ នោ ឯត្ថ ហោតិ សង្ខារប្បច្ចយា វិញ្ញាណន្តិ ។ អវិជ្ជាបច្ចយា សង្ខារាតិ ឥតិ ខោ បនេតំ វុត្តំ អវិជ្ជាបច្ចយា នុ ខោ ភិក្ខវេ សង្ខារា នោ វា កថំ វា ឯត្ថ ហោតីតិ ។ អវិជ្ជាបច្ចយា ភន្តេ សង្ខារា ឯវំ នោ ឯត្ថ ហោតិ អវិជ្ជា-បច្ចយា សង្ខារាតិ ។

មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យដែរ ។ ពាក្យថា វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ ដូច្នេះនេះ តថាគតបានសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះវិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យដែរ ។ ពាក្យថា សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យដូច្នេះមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យដែរ ។

មហាយមកវគ្គស្ស មហាតណ្ហាសង្ខយសុត្តេ សមុទយនយោ

[៨៨] សាធុ ភិក្ខវេ ឥតិ ខោ ភិក្ខវេ តុម្ហេបិ ឯវំ វទេថ អហម្បិ ឯវំ វទាមិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ យទិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ

[៨៨] ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យនុ៎ះត្រូវល្អណាស់ហើយ ម្នាលភិក្ខុទាំងឡាយ ពួកអ្នកក៏និយាយយ៉ាងនេះ តថាគតក៏និយាយយ៉ាងនេះដូច្នេះដែរ កាលបើបច្ច័យ មានអវិជ្ជាជាដើមនេះកើតហើយ ផលមានសង្ខារជាដើមនេះក៏កើតឡើង ផលមានសង្ខារជាដើមនេះកើតឡើង ព្រោះកើតឡើងនៃបច្ច័យមានអវិជ្ជាជាដើមនេះ ដ្បិតថា សង្ខារទាំងឡាយកើតមាន ព្រោះតែអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ សេចក្តីចាស់ ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ទាំងឡាយក៏កើតមាន ព្រោះជាតិជាបច្ច័យ កិរិយាកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះដូច្នេះឯង ។ មួយទៀត សេចក្តីរលត់នៃសង្ខារ ព្រោះតែវិនាសនិងរលត់មិនសល់នៃអវិជ្ជា

សង្ខារនិរោធា វិញ្ញាណនិរោធោ វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ សឡាយតននិរោធា ផស្សនិរោធោ ផស្សនិរោធា វេទនានិរោធោ វេទនានិរោធា តណ្ហានិរោធោ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។

[៨៩] ជាតិនិរោធា ជរាមរណនិរោធោតិ ឥតិ ខោ បនេតំ វុត្តំ ជាតិនិរោធា នុ ខោ ភិក្ខវេ ជរាមរណនិរោធោ នោ វា កថំ វា ឯត្ថ ហោតីតិ ។ ជាតិនិរោធា ភន្តេ ជរាមរណនិរោធោ ឯវំ នោ ឯត្ថ ហោតិ ជាតិនិរោធា ជរាមរណនិរោធោតិ ។ ភវនិរោធា ជាតិនិរោធោតិ ឥតិ ខោ បនេតំ វុត្តំ

សេចក្តីរលត់នៃវិញ្ញាណ ព្រោះរលត់សង្ខារ សេចក្តីរលត់នៃនាមរូប ព្រោះរលត់វិញ្ញាណ សេចក្តីរលត់នៃសឡាយតនៈ ព្រោះរលត់នាមរូប សេចក្តីរលត់នៃផស្សៈ ព្រោះរលត់សឡាយតនៈ សេចក្តីរលត់នៃវេទនា ព្រោះរលត់ផស្សៈ សេចក្តីរលត់នៃតណ្ហា ព្រោះរលត់វេទនា សេចក្តីរលត់នៃឧបាទាន ព្រោះរលត់តណ្ហា សេចក្តីរលត់នៃភព ព្រោះរលត់ឧបាទាន សេចក្តីរលត់នៃជាតិ ព្រោះរលត់ភព សេចក្តីចាស់ ស្លាប់ (រលត់) ព្រោះរលត់ជាតិ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ក៏សឹងតែរលត់ទៅ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះដូច្នេះឯង[១] ។

[៨៩] ពាក្យថា សេចក្តីរលត់នៃជរាមរណៈ ព្រោះរលត់ជាតិដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់ជរាមរណៈ ព្រោះរលត់ជាតិ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់នៃជរាមរណៈ ព្រោះរលត់ជាតិមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះ យ៉ាងនេះថា សេចក្តីរលត់នៃជរាមរណៈ ព្រោះរលត់ជាតិ ។ ពាក្យថា សេចក្តីរលត់នៃជាតិ ព្រោះរលត់ភព ដូច្នេះនេះ តថាគតសំដែងហើយមែន

១ មើលសព្វនិងនយលក្ខណៈ ក្នុងវិនយបិដកខ្សែ ៦ ត្រង់បឋមពោធិកាលចុះ ។

ភវនិរោធា នុ ខោ ភិក្ខវេ ជាតិនិរោធោ នោ វា កថំ វា ឯត្ថ ហោតីតិ ។ ភវនិរោធា ភន្តេ ជាតិនិរោធោ ឯវំ នោ ឯត្ថ ហោតិ ភវនិរោធា ជាតិនិរោធោតិ ។ ឧបាទាននិរោធា ភវនិរោធោតិ ឥតិ ខោ បនេតំ វុត្តំ ឧបាទាននិរោធា នុ ខោ ភិក្ខវេ ភវនិរោធោ នោ វា កថំ វា ឯត្ថ ហោតីតិ ។ ឧបាទាននិរោធា ភន្តេ ភវនិរោធោ ឯវំ នោ ឯត្ថ ហោតិ ឧបាទាននិរោធា ភវ-និរោធោតិ ។ តណ្ហានិរោធា ឧបាទាននិរោធោតិ ឥតិ ខោ បនេតំ វុត្តំ តណ្ហានិរោធា នុ ខោ ភិក្ខវេ ឧបាទាននិរោធោ នោ វា កថំ វា ឯត្ថ ហោតី-តិ ។ តណ្ហានិរោធា ភន្តេ ឧបាទាននិរោធោ ឯវំ នោ ឯត្ថ ហោតិ តណ្ហានិរោធា ឧបាទាននិរោ-ធោតិ ។ វេទនានិរោធា តណ្ហានិរោធោតិ ឥតិ ខោ បនេតំ វុត្តំ វេទនានិរោធា នុ ខោ ភិក្ខវេ

ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់នៃជាតិព្រោះរលត់ភព មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់នៃជាតិ ព្រោះរលត់ភពមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់នៃជាតិ ព្រោះរលត់ភពដែរ ។ ពាក្យថា សេចក្តីរលត់នៃភព ព្រោះរលត់ឧបាទាន ដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់ភព ព្រោះរលត់ឧបាទានមិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់ភព ព្រោះរលត់ឧបាទានមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់ភព ព្រោះរលត់ឧបាទានដែរ ។ ពាក្យថា សេចក្តីរលត់ឧបាទាន ព្រោះរលត់តណ្ហា ដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់ឧបាទាន ព្រោះរលត់តណ្ហាមិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់ឧបាទាន ព្រោះរលត់តណ្ហាមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់ឧបាទាន ព្រោះរលត់តណ្ហាដែរ ។ ពាក្យថា សេចក្តីរលត់តណ្ហា ព្រោះរលត់វេទនាដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ

តណ្ហានិរោធោ នោ វា កថំ ឯត្ថ ហោតីតិ ។ វេទនានិរោធា ភន្តេ តណ្ហានិរោធោ ឯវំ នោ ឯត្ថ ហោតិ វេទនានិរោធា តណ្ហានិរោធោតិ ។ ផស្ស-និរោធា វេទនានិរោធោតិ ឥតិ ខោ បនេតំ វុត្តំ ផស្ស-និរោធា នុ ខោ ភិក្ខវេ វេទនានិរោធោ នោ វា កថំ វា ឯត្ថ ហោតីតិ ។ ផស្សនិរោធា ភន្តេ វេទនា-និរោធោ ឯវំ នោ ឯត្ថ ហោតិ ផស្សនិរោធា វេទនា-និរោធោតិ ។ សឡាយតននិរោធា ផស្សនិរោធោតិ ឥតិ ខោ បនេតំ វុត្តំ សឡាយតននិរោធា នុ ខោ ភិក្ខវេ ផស្សនិរោធោ នោ វា កថំ វា ឯត្ថ ហោតីតិ ។ សឡាយតននិរោធា ភន្តេ ផស្សនិរោធោ ឯវំ នោ ឯត្ថ ហោតិ សឡា-យតននិរោធា ផស្សនិរោធោតិ ។ នាមរូបនិរោធា សឡាយតននិរោធោតិ ឥតិ ខោ បនេតំ វុត្តំ

ចុះសេចក្តីរលត់តណ្ហា ព្រោះរលត់វេទនា មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់តណ្ហា ព្រោះរលត់វេទនា ដូច្នេះមែន ទាំងយើងខ្ញុំព្រះអង្គ ក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់តណ្ហា ព្រោះរលត់វេទនាដែរ ។ ពាក្យថា សេចក្តីរលត់វេទនា ព្រោះរលត់ផស្សៈ ដូច្នេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់វេទនា ព្រោះរលត់ផស្សៈមិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់វេទនា ព្រោះរលត់ផស្សៈមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់វេទនា ព្រោះរលត់ផស្សៈដែរ ។ ពាក្យថា សេចក្តីរលត់ផស្សៈ ព្រោះរលត់សឡាយតនៈ ដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់ផស្សៈ ព្រោះរលត់សឡាយតនៈ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់ផស្សៈ ព្រោះរលត់សឡាយតនៈមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់ផស្សៈព្រោះរលត់សឡាយតនៈដែរ ។ ពាក្យថា សេចក្តីរលត់សឡាយតនៈ ព្រោះរលត់នាមរូប ដូច្នេះនេះ តថាគតសំដែងហើយមែន

១៧៤

នាមរូបនិរោធា នុ ខោ ភិក្ខវេ សឡាយតននិរោធោ នោ វា កថំ វា ឯត្ថ ហោតីតិ ។ នាមរូបនិរោធា ភន្តេ សឡាយតននិរោធោ ឯវំ នោ ឯត្ថ ហោតិ នាមរូបនិរោធា សឡាយតននិរោធោតិ ។ វិញ្ញាណនិរោធា នាមរូបនិរោធោតិ ឥតិ ខោ បនេតំ វុត្តំ វិញ្ញាណនិរោធា នុ ខោ ភិក្ខវេ នាមរូបនិរោធោ នោ វា កថំ វា ឯត្ថ ហោតីតិ ។ វិញ្ញាណនិរោធា ភន្តេ នាមរូបនិរោធោ ឯវំ នោ ឯត្ថ ហោតិ វិញ្ញាណនិរោធា នាមរូបនិរោធោតិ ។ សង្ខារនិរោធា វិញ្ញាណនិរោធោតិ ឥតិ ខោ បនេតំ វុត្តំ សង្ខារនិរោធា នុ ខោ ភិក្ខវេ វិញ្ញាណនិរោធោ នោ វា កថំ វា ឯត្ថ ហោតីតិ ។ សង្ខារនិរោធា ភន្តេ វិញ្ញាណនិរោធោ ឯវំ នោ ឯត្ថ ហោតិ សង្ខារនិរោធា វិញ្ញាណនិរោធោតិ ។ អវិជ្ជានិរោធា សង្ខារនិរោធោតិ ឥតិ ខោ បនេតំ

ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់សឡាយតនៈ ព្រោះរលត់នាមរូប មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់សឡាយតនៈ ព្រោះរលត់នាមរូបមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់សឡាយតនៈ ព្រោះរលត់នាមរូបដែរ ។ ពាក្យថា សេចក្តីរលត់នាម-រូប ព្រោះរលត់វិញ្ញាណ ដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់នាមរូប ព្រោះរលត់វិញ្ញាណ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់នាមរូប ព្រោះរលត់វិញ្ញាណមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់នាមរូប ព្រោះរលត់វិញ្ញាណដែរ ។ ពាក្យថា សេចក្តីរលត់វិញ្ញាណ ព្រោះរលត់សង្ខារ ដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់វិញ្ញាណ ព្រោះរលត់សង្ខារ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់វិញ្ញាណ ព្រោះរលត់សង្ខារមែន ទាំងយើងខ្ញុំព្រះអង្គ ក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់វិញ្ញាណ ព្រោះរលត់សង្ខារដែរ ។ ពាក្យថា សេចក្តីរលត់សង្ខារ ព្រោះរលត់អវិជ្ជា ដូច្នេះនេះ

វុត្តំ អវិជ្ជានិរោធា នុ ខោ ភិក្ខវេ សង្ខារនិរោធោ នោ វា កថំ វា ឯត្ថ ហោតីតិ ។ អវិជ្ជានិរោធា ភន្តេ សង្ខារនិរោធោ ឯវំ នោ ឯត្ថ ហោតិ អវិជ្ជានិរោធា សង្ខារនិរោធោតិ ។

[៩០] សាធុ ភិក្ខវេ ឥតិ ខោ ភិក្ខវេ តុម្ហេបិ ឯវំ វទេថ អហម្បិ ឯវំ វទាមិ ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ យទិទំ អវិជ្ជានិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ សឡាយតននិរោធា ផស្សនិរោធោ ផស្សនិរោធា វេទនានិរោធោ វេទនានិរោធា តណ្ហានិរោធោ

តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់សង្ខារ ព្រោះរលត់អវិជ្ជាមិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់សង្ខារ ព្រោះរលត់អវិជ្ជាមែន ទាំងយើងខ្ញុំព្រះអង្គ ក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់សង្ខារ ព្រោះរលត់អវិជ្ជាដែរ ។

[៩០] ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យដែលអ្នកទាំងឡាយនិយាយនុ៎ះត្រូវល្អណាស់ហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយក៏និយាយយ៉ាងនេះ តថាគតក៏និយាយយ៉ាងនេះដូច្នេះដែរ កាលបើបច្ច័យមានអវិជ្ជាជាដើមនេះមិនមានហើយ ផលមានសង្ខារជាដើមនេះក៏មិនមាន ផលមានសង្ខារជាដើមនេះតែងរលត់ទៅមិនសល់ ព្រោះរលត់នៃបច្ច័យមានអវិជ្ជាជាដើមនេះ ដ្បិតថាសេចក្តីរលត់នៃសង្ខារ ព្រោះរលត់អវិជ្ជា សេចក្តីរលត់នៃវិញ្ញាណ ព្រោះរលត់សង្ខារ សេចក្តីរលត់នៃនាមរូប ព្រោះរលត់នៃវិញ្ញាណ សេចក្តីរលត់នៃសឡាយតនៈ ព្រោះរលត់នាមរូប សេចក្តីរលត់នៃផស្សៈ ព្រោះរលត់សឡាយតនៈ សេចក្តីរលត់នៃវេទនា ព្រោះរលត់ផស្សៈ សេចក្តីរលត់នៃតណ្ហា ព្រោះរលត់វេទនា

១៧៧



តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។

[៩១] អបិ នុ តុម្ហេ ភិក្ខវេ ឯវំ ជានន្តា ឯវំ បស្សន្តា បុព្វន្តំ វា បដិធាវេយ្យាថ អហោសុម្ហា(១) នុ ខោ មយំ អតីតមទ្ធានំ ន នុ ខោ អហោសុម្ហា អតីតមទ្ធានំ កឹ នុ ខោ អហោសុម្ហា អតីតមទ្ធានំ កថំ នុ ខោ អហោសុម្ហា អតីតមទ្ធានំ កឹ ហុត្វា កឹ អហោសុម្ហា នុ ខោ មយំ អតីតមទ្ធានន្តិ ។ នោ ហេតំ ភន្តេ ។ អបិ នុ តុម្ហេ ភិក្ខវេ ឯវំ ជានន្តា ឯវំ បស្សន្តា អបរន្តំ វា បដិធាវេយ្យាថ(២) ភវិស្សាម នុ ខោ មយំ អនាគតមទ្ធានំ ន នុ ខោ ភវិស្សាម អនាគតមទ្ធានំ កឹ នុ ខោ ភវិស្សាម

១ ឱ. ម. អហេសុម្ហ ។ ២ ឱ. អាភាវេយ្យាថ ។

សេចក្ដីរលត់នៃឧបាទាន ព្រោះរលត់តណ្ហា សេចក្ដីរលត់ភព ព្រោះរលត់ឧបាទាន សេចក្ដីរលត់ជាតិ ព្រោះរលត់ភព សេចក្ដីចាស់ស្លាប់ (រលត់) ព្រោះរលត់ជាតិ ការយំសោក ការខ្សឹកខ្សួល ការលំបាកកាយ ការលំបាកចិត្ត និងសេចក្ដីចង្អៀតចង្អល់ទាំងឡាយ ក៏សឹងតែរលត់ទៅមិនសល់ សេចក្ដីរលត់នៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះឯង ។

[៩១] ម្នាលភិក្ខុទាំងឡាយ ចុះកាលបើអ្នកទាំងឡាយ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ នឹងស្រាវជ្រាវនូវខន្ធ ធាតុ អាយតនៈ ជាចំណែកខាងដើមគឺអតីតកាលថា ក្នុងកាលកន្លងទៅហើយ យើងធ្លាប់បានកើតឬហ្ន៎ ឬក្នុងកាលកន្លងទៅហើយ យើងមិនធ្លាប់កើតទេ ក្នុងកាលកន្លងទៅហើយ យើងបានកើតជាជាតិអ្វីហ្ន៎ ក្នុងកាលកន្លងទៅហើយ យើងបានកើតជាមនុស្សមានទ្រង់ទ្រាយដូចម្ដេច ក្នុងកាលកន្លងទៅហើយ យើងកើតជាជាតិអ្វី បានជាអ្វី ដូច្នេះបានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះយើងខ្ញុំព្រះអង្គស្រាវជ្រាវរកមិនឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះកាលបើអ្នកទាំងឡាយ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ នឹងស្រាវជ្រាវរកខន្ធ ធាតុ អាយតនៈ ជាចំណែកខាងមុខគឺអនាគតកាលថា ក្នុងកាលជាអនាគត យើងនឹងកើតឬហ្ន៎ ក្នុងកាលជាអនាគត យើងមិនកើតទៀតទេ ក្នុងកាលជាអនាគត យើងនឹងកើត

១៧៨



អនាគតមទ្ធានំ កថំ នុ ខោ ភវិស្សាម អនាគតមទ្ធានំ កឹ ហុត្វា កឹ ភវិស្សាម នុ ខោ មយំ អនាគតមទ្ធានន្តិ ។ នោ ហេតំ ភន្តេ ។ អបិ នុ តុម្ហេ ភិក្ខវេ ឯវំ ជានន្តា ឯវំ បស្សន្តា ឯតរហិ វា បច្ចុប្បន្នមទ្ធានំ អារព្ភ អជ្ឈត្តំ កថំកថិត្ថ អហំ នុ[១] ខោស្មិ នោ នុ ខោស្មិ កិន្នុ ខោស្មិ កថំ នុ ខោស្មិ អយំ នុ ខោ សត្តោ កុតោ អាគតោ សោ កុហិង្គាមី ភវិស្សតីតិ ។ នោ ហេតំ ភន្តេ ។ អបិ នុ តុម្ហេ ភិក្ខវេ ឯវំ ជានន្តា ឯវំ បស្សន្តា ឯវំ វទេយ្យាថ សត្ថា នោ គរុ សត្ថុគារវេន[២] មយំ ឯវំ វទេយ្យាមាតិ[៣] ។ នោ ហេតំ ភន្តេ ។ អបិ នុ តុម្ហេ ភិក្ខវេ ឯវំ ជានន្តា ឯវំ បស្សន្តា ឯវំ វទេយ្យាថ សមណោ ឯវមាហ សមណា ច ន ច មយំ ឯវំ វទេមាតិ ។

---

១ ឱ. បច្ចុប្បន្នមទ្ធានំ អជ្ឈត្តំ កថំកថី អស្សថ អហន្នុ ។ ម. បច្ចុប្បន្នំ អទ្ធានមជ្ឈត្តំ កថំកថី អស្ស អហំ នុ ។ ២ ឱ. ម. គារវេន ច ។ ៣ ឱ. មយំ វទេមាតិ ។ ម. មយំ ឯវំ វទេមាតិ ។

ជាអ្វីហ្ន៎ ក្នុងកាលជាអនាគត យើងនឹងកើតជាមនុស្សមានទ្រង់ទ្រាយដូចម្ដេចហ្ន៎ ក្នុងកាលជាអនាគត យើងនឹងកើតជាជាតិអ្វី បានជាអ្វីដូច្នេះបានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះយើងខ្ញុំព្រះអង្គស្រាវជ្រាវរកមិនឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះបើអ្នកទាំងឡាយដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ គប្បីសង្ស័យ ចំពោះខន្ធ ធាតុ អាយតនៈជាចំណែកខាងក្នុង ប្រារព្ធនូវកាលជាបច្ចុប្បន្នក្នុងកាលឥឡូវនេះថា អាត្មាអញកើតទៀតឬមិនកើតទេ អាត្មាអញកើតជាជាតិអ្វីហ្ន៎ អាត្មាអញកើតជាមនុស្សមានទ្រង់ទ្រាយដូចម្ដេច សត្វនេះមកអំពីទីណា សត្វនោះនឹងទៅកើតក្នុងទីណាវិញ ដូច្នេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះយើងខ្ញុំព្រះអង្គមិនបានសង្ស័យដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ គប្បីនិយាយយ៉ាងនេះថា ព្រះសាស្ដាជាគ្រូយើង យើងត្រូវនិយាយយ៉ាងនេះដោយសេចក្ដីគោរព ចំពោះព្រះសាស្ដាដូច្នេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះយើងខ្ញុំព្រះអង្គមិនដែលនិយាយទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ គប្បីនិយាយយ៉ាងនេះថា សមណៈគឺព្រះពុទ្ធនិយាយយ៉ាងនេះ ចំណែកយើងទាំងឡាយជាសមណៈដែរ មិនត្រូវនិយាយយ៉ាងនេះ ដូច្នេះដែរឬទេ ។

១៧៩

មហាយមកវគ្គស្ស  មហាតណ្ហាសង្ខយសុត្តេ  ធម្មគុណកថា

នោ ហេតំ ភន្តេ ។ អបិ នុ តុម្ហេ ភិក្ខវេ ឯវំ ជានន្តា ឯវំ បស្សន្តា អញ្ញំ សត្ថារំ ឧទ្ទិសេយ្យា-ថាតិ ។ នោ ហេតំ ភន្តេ ។ អបិ នុ តុម្ហេ ភិក្ខវេ ឯវំ ជានន្តា ឯវំ បស្សន្តា យានិ តានិ បុថុស្សមណ-ព្រាហ្មណានំ វត្តកោតូហលមង្គលានិ តានិ សារតោ បច្ចាគច្ឆេយ្យាថាតិ ។ នោ ហេតំ ភន្តេ ។ ននុ ភិក្ខវេ យទេវ តុម្ហាកំ សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តទេវ តុម្ហេ វទេយ្យាថាតិ ។ ឯវំ ភន្តេ ។ សាធុ ភិក្ខវេ ឧបនីតា ខោ មេ តុម្ហេ ភិក្ខវេ ឥមិនា សន្ទិដ្ឋិកេន ធម្មេន អកាលិកេន ឯហិបស្សិកេន ឱបនយិកេន បច្ចត្តំ វេទិ-តព្វេន វិញ្ញូហិ សន្ទិដ្ឋិកោ អយំ ភិក្ខវេ ធម្មោ

បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនោះយើងខ្ញុំព្រះអង្គមិនដែលនិយាយទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ គប្បីឧទ្ទិសចំពោះសាស្តាឯទៀតដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គមិនបានឧទ្ទិសទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ គប្បីប្រកាន់នូវវត្តសមាទាន សេចក្តីភ្ញាក់ផ្អើលដោយទិដ្ឋិ និងទិដ្ឋមង្គល សុតមង្គល មុតមង្គល ជារបស់ពួកតិត្ថិយសមណៈនិងព្រាហ្មណសមណៈជាច្រើនដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គមិនបានប្រកាន់ទេ ។ ម្នាលភិក្ខុទាំងឡាយ ហេតុណាមួយ ដែលអ្នកទាំងឡាយស្គាល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯង អ្នកទាំងឡាយគប្បីនិយាយហេតុនោះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គនិយាយដែរ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យដែលអ្នកទាំងឡាយនិយាយនោះត្រូវល្អណាស់ហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយដែលតថាគតនាំចូលទៅ (កាន់ព្រះនិព្វាន) ដោយធម៌ដែលគួរឃើញច្បាស់ខ្លួនឯង ជាធម៌មិនរង់ចាំកាល ជាធម៌មានអាការដូចជាហៅបុគ្គលមកចង្អុលប្រាប់ ជាធម៌ដែលព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនទាំង-ឡាយគប្បីដឹងច្បាស់ក្នុងចិត្តរបស់ខ្លួន ម្នាលភិក្ខុទាំងឡាយ ធម៌នេះជាធម៌

អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[៩២] តិណ្ណំ ខោ បន ភិក្ខវេ សន្និបាតា គព្ភស្សាវក្កន្តិ ហោតិ ។ ឥធ មាតាបិតរោ ច សន្និបតិតា ហោន្តិ មាតា ច ន ឧតុនី ហោតិ គន្ធព្វោ ច ន បច្ចុបដ្ឋិតោ ហោតិ នេវ តាវ គព្ភស្សាវក្កន្តិ ហោតិ ។ ឥធ មាតាបិតរោ ច សន្និបតិតា ហោន្តិ មាតា ច ឧតុនី ហោតិ គន្ធព្វោ ច ន បច្ចុបដ្ឋិតោ ហោតិ នេវ តាវ គព្ភស្សាវក្កន្តិ ហោតិ ។ យតោ ច ខោ ភិក្ខវេ មាតាបិតរោ ច សន្និបតិតា ហោន្តិ មាតា ច ឧតុនី ហោតិ គន្ធព្វោ ច បច្ចុបដ្ឋិតោ ហោតិ ឯវំ តិណ្ណំ សន្និបាតិតា គព្ភស្សាវក្កន្តិ ហោតិ ។ តមេនំ ភិក្ខវេ មាតា នវ វា ទស វា មាសេ គព្ភំ កុច្ឆិនា បរិហរតិ

គួរឃើញច្បាស់ខ្លួនឯង ជាធម៌មិនរង់ចាំកាល ជាធម៌មានអាការដូចជាហៅបុគ្គលមកប្រាប់ ជាធម៌ដែលព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនទាំងឡាយគប្បីដឹងច្បាស់ក្នុងចិត្តរបស់ខ្លួន ហេតុដូច្នោះបានជា តថាគតពោលសំដៅត្រង់ហេតុ ដែលអ្នកទាំងឡាយដឹងច្បាស់ ដោយខ្លួនឯងនោះ ។

[៩២] ម្នាលភិក្ខុទាំងឡាយ កិរិយាចុះចាប់បដិសន្ធិ របស់សត្វដែលកើតក្នុងផ្ទៃ ព្រោះប្រជុំហេតុ ៣ ប្រការ ។ ក្នុងសត្វលោកនេះ មាតាបិតាមកប្រជុំគ្នាហើយ តែមាតាជាស្រីមិនមានរដូវផង សត្វដែលគួរកើតក្នុងផ្ទៃនោះ ក៏មិនមានប្រាកដក្នុងឱកាសនោះផង កិរិយាចុះចាប់បដិសន្ធិរបស់សត្វដែលកើតក្នុងផ្ទៃក៏មិនទាន់មាននៅឡើយ ។ ក្នុងសត្វ-លោកនេះ មាតាបិតាមកប្រជុំគ្នាហើយផង មាតាជាស្រីមានរដូវផង តែសត្វដែលគួរកើតក៏មិនមានប្រាកដក្នុងឱកាសនោះ កិរិយាចុះចាប់បដិសន្ធិរបស់សត្វដែលកើតក្នុងផ្ទៃ ក៏មិនទាន់មាននៅឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ លុះតែកាលណាមាតាបិតាមកប្រជុំគ្នាផង មាតាជាស្រីមានរដូវផង សត្វដែលគួរកើតក៏មានប្រាកដក្នុងឱកាសនោះផង លុះប្រជុំហេតុទាំង ៣ ប្រការនេះឯង ទើបសត្វចុះចាប់បដិសន្ធិក្នុងផ្ទៃនៃមាតាបាន ។ ម្នាលភិក្ខុទាំងឡាយ មាតាពគភ៌នោះដោយផ្ទៃ អស់ខែ ៩ ឬខែ ១០

មហតា សំសយេន គរុភារំ[១] តមេនំ ភិក្ខវេ មាតា នវន្នំ វា ទសន្នំ វា មាសានំ អច្ចយេន វិជាយតិ មហតា សំសយេន គរុភារំ តមេនំ ជាតំ សមានំ សកេន លោហិតេន បោសេតិ ។

[៩៣] លោហិតញ្ហេតំ ភិក្ខវេ អរិយស្ស វិនយេ យទិទំ មាតុ ថញ្ញំ ។ ស ខោ សោ ភិក្ខវេ កុមារោ វុឌ្ឍិមន្វាយ ឥន្ទ្រិយានំ បរិបាកមន្វាយ យានិ តានិ កុមារកានំ កីឡាបនកានិ តេហិ កីឡតិ សេយ្យថីទំ វង្កំ[២] ឃដិកំ មោក្ខចិកំ ចិង្គុលិកំ[៣] បត្តាឡ្ហកំ រថកំ ធនុកំ ។ ស ខោ សោ ភិក្ខវេ កុមារោ វុឌ្ឍិមន្វាយ ឥន្ទ្រិយានំ បរិបាកមន្វាយ បញ្ចហិ កាមគុណេហិ សមប្បិ-តោ សមង្គីភូតោ បរិចារេតិ ចក្ខុវិញ្ញេយ្យេហិ រូបេហិ ឥដ្ឋេហិ កន្តេហិ មនាបេហិ បិយរូបេហិ

១ ឱ. គរុម្ភារំ ។ ២ ឱ. ម. វង្កកំ ។ ៣ ឱ. ម. ចិង្គុលកំ ។

ដោយសេចក្ដីសង្ស័យ (ក្នុងជីវិត[១]) ជាច្រើន ម្នាលភិក្ខុទាំងឡាយ លុះកន្លងខែ ៩ ឬខែ ១០ ទៅ មាតាក៏ប្រសូតគភ៌នោះ ដូចជាភារៈធ្ងន់ ដោយសេចក្ដីសង្ស័យជាច្រើន កាលបើគភ៌ដូចជាភារៈធ្ងន់នោះប្រសូតរួចហើយ ក៏ចិញ្ចឹមដោយឈាម (គឺទឹកដោះ) របស់ខ្លួន ។

[៩៣] ម្នាលភិក្ខុទាំងឡាយ ទឹកដោះរបស់មាតាណា ដែលតថាគតពោលហើយ ក្នុងអរិយវិន័យ ទឹកដោះនុ៎ះគឺឈាមហ្នឹងឯង ។ ម្នាលភិក្ខុទាំងឡាយ កុមារនោះឯងអាស្រ័យនូវការចម្រើនធំឡើង អាស្រ័យនូវកិរិយាចាស់នៃឥន្ទ្រិយទាំងឡាយ (គឺចាស់ខែឆ្នាំ) ក៏លេងនូវល្បែងទាំងឡាយជាមួយនឹងពួកកុមារ គឺលេងកូននង្គ័ល ហ៊ឹង ដាំដូង កង្ហាររាល់ដីខ្សាច់ កូនរទេះ កូនធ្នូ ។ ម្នាលភិក្ខុទាំងឡាយ កុមារនោះឯងអាស្រ័យនូវសេចក្ដីចម្រើនធំឡើង អាស្រ័យនូវកិរិយាចាស់នៃឥន្ទ្រិយទាំងឡាយ ហើយក៏ឆ្អែត ស្កប់ស្កល់ រីករាយសប្បាយ ត្រេកត្រអាលដោយកាមគុណទាំង ៥ គឺរូបដែលគប្បីស្គាល់ដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់

១ គឺសង្ស័យ (ក្នុងពេលប្រសូតកូន) ថា អាត្មាអញមានរោគ ឬកូនអាត្មាអញមានរោគ ។ អដ្ឋកថា ។

កាមូបសញ្ហិតេហិ រជនីយេហិ បេមនីយេហិ[១] សោតវិញ្ញេយ្យេហិ សទ្ទេហិ... ឃានវិញ្ញេយ្យេហិ គន្ធេហិ... ជិវ្ហាវិញ្ញេយ្យេហិ រសេហិ... កាយវិញ្ញេយ្យេហិ ផោដ្ឋព្វេហិ ឥដ្ឋេហិ កន្តេហិ មនាបេហិ បិយរូបេហិ កាមូបសញ្ហិតេហិ រជនីយេហិ បេមនីយេហិ ។ សោ ចក្ខុនា រូបំ ទិស្វា បិយរូបេ រូបេ សារជ្ជតិ អប្បិយរូបេ រូបេ ព្យាបជ្ជតិ អនុបដ្ឋិតកាយស្សតិ ច វិហរតិ បរិត្តចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ សោ ឯវំ អនុរោធវិរោធំ សមាបន្នោ យង្កិញ្ចិ វេទនំ វេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា ។ សោ តំ វេទនំ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ ។ តស្ស តំ វេទនំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ ឧប្បជ្ជតិ នន្ទិ[២] យា វេទនាសុ នន្ទិ តទុបាទានំ តស្ស ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ

---

១ ឱ. ម. បេមនីយេហីតិ ន ទិស្សតិ ។ ឱ. ម. នន្ទី ។

ប្រកបដោយកាម គួរឲ្យកើតតម្រេក និងគួរឲ្យស្រឡាញ់ សំឡេងដែលគប្បីដឹងដោយត្រចៀក... ក្លិនដែលគប្បីដឹងដោយច្រមុះ... រសដែលគប្បីដឹងដោយអណ្តាត... ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរឲ្យកើតតម្រេក និងគួរឲ្យស្រឡាញ់ ។ កុមារនោះឃើញរូបដោយភ្នែក ក៏កើតតម្រេកក្នុងរូបដែលគួរស្រឡាញ់ កើតបដិបក្ខក្នុងរូបដែលគួរស្អប់ មានសតិក្នុងកាយមិនបានតាំងមាំ មានចិត្តរំកើប (ចិត្តជាអកុសល) ផង ធម៌ទាំងឡាយជាអកុសលដ៏លាមករបស់កុមារនោះ រមែងរលត់ទៅមិនសល់ក្នុងផលសមាបត្តិណា ក៏មិនបានដឹងច្បាស់ នូវផលសមា-បត្តិគឺចេតោវិមុត្តិ បញ្ញាវិមុត្តិនោះ តាមសេចក្តីពិតផង ។ កុមារនោះដល់ព្រមដោយតម្រេក និងសេចក្តីក្រេវក្រោធយ៉ាងនេះហើយ រមែងសោយនូវវេទនាណាមួយ ជាសុខឬទុក្ខ ឬមិនទុក្ខមិនសុខ ។ កុមារនោះតែងត្រេកអរ និយាយសរសើរ ប្រកាន់វេទនានោះ (ដោយអំណាចតណ្ហា) ។ កាលបើកុមារនោះ ត្រេកអរ និយាយសរសើរ ប្រកាន់វេទនានោះហើយក៏កើតទៅជាតម្រេក កាលបើតម្រេកក្នុងវេទនាទាំងឡាយមានហើយ ឧបាទានក៏កើតឡើងដល់កុមារនោះ ព្រោះតម្រេកនោះ ភពកើតមានព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ

១៨៣



ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុ-បាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខ-ក្ខន្ធស្ស សមុទយោ ហោតិ ។ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា.... មនសា ធម្មំ វិញ្ញាយ បិយរូបេ ធម្មេ សារជ្ជតិ អប្បិយរូបេ ធម្មេ ព្យាបជ្ជតិ អនុបដ្ឋិតកាយស្សតិ ច វិហរតិ បរិត្តចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញា-វិមុត្តឹ យថាភូតំ នប្បជានាតិ យត្ថស្ស តេ បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ សោ ឯវំ អនុរោធវិរោធំ សមាបន្នោ យំ កញ្ចិ វេទនំ វេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា ។ សោ តំ វេទនំ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ ។ តស្ស តំ វេទនំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ ឧប្បជ្ជតិ នន្ទិ យា វេទនាសុ នន្ទិ តទុបាទានំ តស្ស ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ

សេចក្តីចាស់ស្លាប់ កើតមាន ព្រោះជាតិជាបច្ច័យ ការសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ក៏កើតមានព្រម កិរិយាកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានដោយហេតុយ៉ាងនេះឯង ។ កុមារនោះ ឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួលរសដោយអណ្តាត... ពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ ក៏កើតតម្រេកក្នុងធម្មារម្មណ៍ដែលគួរស្រឡាញ់ កើតបដិឃៈក្នុងធម្មារម្មណ៍ដែលគួរស្អប់ផង សតិក្នុងកាយមិនតាំងខ្ជាប់ មានចិត្តជាអកុសលផង ធម៌ទាំងឡាយជាអកុសលដ៏លាមក របស់កុមារនោះ រមែងរលត់ទៅមិនសល់ ក្នុងផលសមាបត្តិណា ក៏មិនបានដឹងច្បាស់នូវផលសមាបត្តិគឺចេតោវិមុត្តិ បញ្ញាវិមុត្តិនេះ តាមសេចក្តីពិតផង ។ កុមារនោះដល់ព្រមដោយតម្រេកនិងសេចក្តីក្រេវក្រោធយ៉ាងនេះហើយ រមែងទទួលនូវវេទនាណាមួយ ជាសុខឬជាទុក្ខ ឬមិនទុក្ខមិនសុខ ។ កុមារនោះតែងត្រេកអរនិយាយសរសើរប្រកាន់វេទនានោះ ។ កាលកុមារនោះត្រេកអរនិយាយសរសើរ ប្រកាន់វេទនានោះហើយ តម្រេកក៏កើតឡើង កាលបើតម្រេកក្នុងវេទនាទាំងឡាយ មានហើយ ឧបាទានក៏កើតឡើងដល់កុមារនោះព្រោះតម្រេកនោះ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ

ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោម-
នស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស
ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

[៩៤] ឥធ ភិក្ខវេ តថាគតោ លោកេ ឧប្បជ្ជតិ
អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ
លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវម-
នុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ
សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ
សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ
សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ

ជាតិកើតមាន ព្រោះភពជាបច្ច័យ សេចក្តីចាស់ ស្លាប់ (កើតមាន) ព្រោះជាតិជាបច្ច័យ ការសោក ការខ្សឹកខ្សួល ការលំបាកកាយ ការលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏កើតព្រម កិរិយាកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានដោយប្រការដូច្នេះឯង ។

[៩២] ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ មានដំណើរល្អទៅកាន់ព្រះនិព្វាន ជ្រាបច្បាស់នូវត្រៃលោក ជាបុគ្គលប្រសើរបំផុត ជាសារថីទូន្មាននូវបុរស ជាគ្រូនៃពួកទេវតានិងមនុស្ស ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ចធម៌ លែងត្រឡប់មកកាន់ត្រៃភពហើយ ព្រះអង្គកើតឡើងក្នុងលោកនេះ ទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាចំពោះព្រះអង្គ នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយប្រកាស ព្រះអង្គសំដែងធម៌មានលំអបទដើម មានលំអបទកណ្តាល

បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលប-
រិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ ។ តំ ធម្មំ
សុណាតិ គហបតិ វា គហបតិបុត្តោ វា អញ្ញតរស្មឹ
វា កុលេ បច្ឆា ជាតោ ។ សោ តំ ធម្មំ សុត្វា
តថាគតេ សទ្ធំ បដិលភតិ ។ សោ តេន សទ្ធា-
បដិលាភេន សមន្នាគតោ ឥតិ បដិសញ្ចិក្ខតិ សម្ពាធោ
ឃរាវាសោ រជាបថោ អព្ភោកាសោ បព្វជ្ជា នយិទំ
សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្ត-
បរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ
កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆា-
ទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ អប-
រេន សមយេន អប្បំ វា ភោគក្ខន្ធំ បហាយ មហន្តំ
វា ភោគក្ខន្ធំ បហាយ អប្បំ វា ញាតិបរិវដ្ដំ បហា-
យ មហន្តំ វា ញាតិបរិវដ្ដំ បហាយ កេសមស្សុំ
ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា
អនគារិយំ បព្វជតិ ។

និងបទចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថនិងព្យញ្ជនៈ ដ៏បរិសុទ្ធបរិបូណ៌គ្រប់ទាំងអស់ ។ គហបតីក្តី កូនរបស់គហបតីក្តី មហាជនដែលកើតខាងក្រោយ ក្នុងត្រកូលណាមួយក្តី រមែងស្តាប់ធម៌នោះ ។ លុះគហបតីជាដើមនោះ ស្តាប់ធម៌នោះហើយ ក៏បាននូវសទ្ធា (សេចក្តីជឿ) ក្នុងតថាគត ។ លុះគហបតីជាដើមនោះ ប្រកបដោយការបាននូវសទ្ធានោះហើយ ក៏ពិចារណាដូច្នេះថា ឃរាវាសចង្អៀតចង្អល់ណាស់ ជាផ្លូវហូរមកនៃធូលីគឺកិលេស ឯបព្វជ្ជាមានពេលឱកាសច្រើន កាលបើអាត្មាអញ នៅគ្រប់គ្រងផ្ទះនេះមិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌ដោយចំណែកមួយ ឲ្យបរិសុទ្ធដោយចំណែកមួយ ឲ្យស្អាតដូចជាស័ង្ខដែលគេខាត់បានឡើយ បើដូច្នោះ មានតែអាត្មាអញ កោរសក់ពុកមាត់ពុកចង្កា ស្លៀកសំពត់កាសាយៈចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ លុះចំណេរមកខាងក្រោយ គហបតីជាដើមនោះ លះបង់នូវគំនរភោគសម្ប័ទតិចក្តី លះបង់នូវគំនរភោគសម្ប័ទច្រើនក្តី លះបង់នូវញាតិវង្សតិចក្តី លះបង់នូវញាតិវង្សច្រើនក្តី ហើយកោរសក់ពុកមាត់ពុកចង្កា ស្លៀកសំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។

[៩៤] សោ ឯវំ បព្វជិតោ សមានោ ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ បាណាតិបាតំ បហាយ បា-ណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិ-តសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ ។ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ ទិន្នាទាយី ទិន្នបាដិកង្ខី អថេនេន សុចិភូ-តេន អត្តនា វិហរតិ ។ អព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ អារាចារី វិរតោ មេថុនា គាមធម្មា ។ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស ។ បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ឥតោ សុត្វា ន អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ ភិន្នានំ វា សន្ធាតា

[៩៥] កាលគហបតីជាដើមនោះ បួសយ៉ាងនេះហើយ ក៏បរិបូណ៌ដោយសិក្ខានិងសាជីវៈ សម្រាប់ភិក្ខុទាំងឡាយ លះបង់នូវបាណាតិបាត ជាអ្នកវៀរស្រឡះចាកបាណាតិបាត មានអាជ្ញាដាក់ចុះ មានសស្ត្រាវុធដាក់ចុះ ជាអ្នកមានសេចក្ដីខ្មាស មានសេចក្ដីអាណិតអាសូរ អនុគ្រោះដោយប្រយោជន៍ចំពោះពួកសត្វដែលមានជីវិតទាំងអស់ ។ ជាអ្នកលះបង់នូវអទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន កាន់យកតែវត្ថុដែលគេឲ្យ ប្រាថ្នាតែរបស់ដែលគេឲ្យ មិនជាចោរ ជាអ្នកមានខ្លួនស្អាត ។ ជាអ្នកលះបង់នូវអព្រហ្មចរិយៈ (ធម៌មិនប្រសើរ) ប្រព្រឹត្តតែធម៌ដ៏ប្រសើរ វៀរឆ្ងាយ វៀរស្រឡះ ចាកមេថុនដែលជាធម៌របស់អ្នកស្រុក ។ ជាអ្នកលះបង់នូវមុសាវាទ វៀរស្រឡះចាកមុសាវាទ ជាអ្នកពោលពាក្យពិត តនូវពាក្យពិត ពោលតែពាក្យទៀងទាត់ និងពាក្យដែលគួរឲ្យជឿ ជាអ្នកមិនពោលបំភ្លាត់សត្វលោក ។ ជាអ្នកលះបង់នូវបិសុណវាចា វៀរស្រឡះចាកបិសុណវាចា គឺឮពាក្យអំពីសំណាក់ជននេះ ហើយមិនប្រាប់ជនឯណោះ ដើម្បីបំបែកជនទាំងពីរនេះឡើយ ឬឮពាក្យអំពីសំណាក់ជនឯណោះហើយ មិនប្រាប់ដល់ជននេះ ដើម្បីបំបែកពួកជនឯណោះឡើយ ជាអ្នកសង្រួបសង្រួមពួកជនដែលបែកគ្នាហើយផង

សហិតានំ វា អនុប្បទាតា សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតា ហោតិ ។ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា នេលា កណ្ណសុខា បេម-នីយា ហទយង្គមា បោរី ពហុជនកន្តា ពហុជន-មនាបា តថារូបឹ វាចំ ភាសិតា ហោតិ ។ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធានវតឹ វាចំ ភាសិតា ហោតិ កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ ។ វីជ[១]គាមភូតគាមសមារម្ភា បដិវិរតោ ហោតិ ។ ឯកភត្តិកោ ហោតិ រត្តូបរតោ វិរតោ

១ ឱ. ម. សោ ពីជ ។

ជាអ្នកបន្ថែមកម្លាំងឲ្យពួកជនដែលព្រមព្រៀងគ្នាស្រាប់ហើយផង ជាអ្នកត្រេកអរក្នុងសេចក្តីព្រមព្រៀង ពេញចិត្តក្នុងសេចក្តីព្រមព្រៀង រីករាយក្នុងសេចក្តីព្រមព្រៀង ពោលតែវាចាដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀង ។ ជាអ្នកលះបង់ នូវផរុសវាចា វៀរស្រឡះចាកផរុសវាចា បើវាចាណា ឥតទោស សុខដល់ត្រចៀក គួរឲ្យស្រឡាញ់ គួរឲ្យតម្កល់ទុកក្នុងហឫទ័យ ជាវាចាអ្នកក្រុង ជាទីត្រេកអរដល់ជនច្រើន ជាទីពេញចិត្តដល់ជនច្រើន ជាអ្នកពោលតែវាចាមានសភាពដូច្នោះ ។ ជាអ្នកលះបង់នូវសម្ផប្បលាបៈ វៀរស្រឡះចាកសម្ផប្បលាបៈ ជាអ្នកនិយាយតាមកាលគួរ និយាយពាក្យមែន និយាយពាក្យមានប្រយោជន៍ និយាយធម៌ និយាយវិន័យ និយាយវាចា ដែលគួរឲ្យអ្នកផងយកទុកក្នុងហឫទ័យ ជាពាក្យប្រកបដោយទីអាងតាមកាល ជាវាចាមានទីបំផុតនិងប្រកបដោយប្រយោជន៍ ។ ជាអ្នកវៀរស្រឡះចាកកិរិយាផ្តិលផ្តាច់នូវពីជគាមនិងភូតគាម ។ ជាអ្នកបរិភោគភត្តតែ ១ ពេល ជាអ្នកវៀរចាកការ

វិកាលភោជនា ។ នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ ហោតិ ។ មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ ហោតិ ។ ឧច្ចាសយនមហាសយនា បដិវិរតោ ហោតិ ។ ជាតរូបរជតប្បដិគ្គហណា បដិវិរតោ ហោតិ ។ អាមកធញ្ញប្បដិគ្គហណា បដិវិរតោ ហោតិ ។ អាមកមំសប្បដិគ្គហណា បដិវិរតោ ហោតិ ។ ឥត្ថីកុមារិកប្បដិគ្គហណា បដិវិរតោ ហោតិ ។ ទាសីទាសប្បដិគ្គហណា បដិវិរតោ ហោតិ ។ ខេត្តវត្ថុប្បដិគ្គហណា បដិវិរតោ ហោតិ ។ អជេឡកប្បដិគ្គហណា បដិវិរតោ ហោតិ ។ កុក្កុដសូករប្បដិគ្គហណា បដិវិរតោ ហោតិ ។ ហត្ថិគវាស្សវឡវប្បដិគ្គហណា បដិវិរតោ ហោតិ ។ ទូតេយ្យបហីណគមនានុយោគា បដិវិរតោ ហោតិ ។ កយវិក្កយា បដិវិរតោ ហោតិ ។ តុលាកូដកំសកូដមានកូដា បដិវិរតោ ហោតិ ។

បរិភោគក្នុងវេលាយប់ វៀរស្រឡះចាកកិរិយាបរិភោគក្នុងវេលាវិកាល ។ ជាអ្នកវៀរស្រឡះចាកការរាំច្រៀងប្រគំទាំងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ ។ ជាអ្នកវៀរស្រឡះ ចាកហេតុជាទីតាំងនៃកិរិយាទ្រទ្រង់ ប្រដាប់តាក់តែង ស្អិតស្អាង (រាងកាយ) ដោយផ្កាកម្រងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេង ៗ ។ ជាអ្នកវៀរស្រឡះចាកអាសនៈខ្ពស់និងអាសនៈដ៏ប្រសើរ ។ ជាអ្នកវៀរស្រឡះ ចាកកិរិយាទទួលនូវប្រាក់និងមាស ជាអ្នកវៀរស្រឡះចាកកិរិយាទទួលនូវធញ្ញជាតិឆៅ ។ ជាអ្នកវៀរស្រឡះ ចាកកិរិយាទទួលនូវសាច់ឆៅ ។ ជាអ្នកវៀរស្រឡះចាកកិរិយាទទួលនូវស្រីនិងក្មេងស្រី ។ ជាអ្នកវៀរស្រឡះ ចាកកិរិយាទទួលនូវខ្ញុំស្រីនិងខ្ញុំប្រុស ។ ជាអ្នកវៀរស្រឡះចាកកិរិយាទទួលនូវស្រែនិងចម្ការ ។ ជាអ្នកវៀរស្រឡះចាកកិរិយាទទួលនូវពពែនិងចៀម ។ ជាអ្នកវៀរស្រឡះ ចាកកិរិយាទទួលនូវមាន់និងជ្រូក ។ ជាអ្នកវៀរស្រឡះចាកកិរិយាទទួលនូវដំរី គោ សេះនិងលា ។ ជាអ្នកវៀរស្រឡះចាកកិរិយាប្រកបក្នុងកិច្ចជាទូតនាំដំណឹងទៅមក ។ ជាអ្នកវៀរស្រឡះចាកការលក់ដូរ ។ ជាអ្នកវៀរស្រឡះ ចាកការបំបាត់ដោយជញ្ជីង ទាំងបន្ទំភាជន៍ដែលមិនមែនមាសថាជាមាស និងបំបាត់ដោយរង្វាស់និងរង្វាល់ ។

ឧក្កោដនវញ្ចននិកតិសាវិយោគា បដិវិរតោ ហោតិ ។ ឆេទនវធពន្ធនវិបរាមោសអាលោបសហសាការា បដិវិរតោ ហោតិ ។ សោ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌបាតេន យេន យេនេវ បក្កមតិ សមាទាយេវ បក្កមតិ ។ សេយ្យថាបិ នាម បក្ខី សកុណោ យេន យេនេវ ឌេតិ សបត្តភារោ វ ឌេតិ ឯវមេវ ភិក្ខុ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌបាតេន យេន យេនេវ បក្កមតិ សមាទាយេវ បក្កមតិ ។ សោ ឥមិនា អរិយេន សីលក្ខន្ធេន សមន្នាគតោ អជ្ឈត្តំ អនវជ្ជសុខំ បដិសំវេទេតិ ។ សោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ ។ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។

ជាអ្នកវៀរស្រឡះចាកកិរិយាបង្កាច់ បោកប្រាស និងប្រកបក្នុងការបន្ទំដោយរបស់ក្លែង ។ ជាអ្នកវៀរស្រឡះចាកកិរិយាកាត់នូវអវយវៈ សម្លាប់ចាប់ចង ធ្វើឲ្យវង្វេងផ្លូវ ប្លន់ធំកំហែងយកទ្រព្យ ។ ភិក្ខុនោះជាអ្នកសន្តោសដោយចីវរជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ បើដើរចេញទៅទីណា ៗ ក៏កាន់យក (បរិក្ខារទាំងអស់) ដើរចេញទៅ ។ ដូចជាសត្វស្លាប ដែលហើរទៅទីណា ៗ ក៏ហើរទៅល្មមតែកម្លាំងស្លាបវា យ៉ាងណាមិញ ភិក្ខុជាអ្នកសន្តោសដោយចីវរ ជាគ្រឿងរក្សាកាយដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ បើដើរចេញទៅទីណា ៗ ក៏កាន់យក (បរិក្ខារទាំងអស់) ដើរទៅដូច្នោះដែរ ។ ភិក្ខុនោះប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះ ហើយទទួលចំពោះនូវសុខដែលមិនប្រកបដោយទោសក្នុងសន្តាន ។ ភិក្ខុនោះឃើញរូបដោយភ្នែកហើយ ក៏មិនក្តោបកាន់នូវនិមិត្តមិនក្តោបកាន់នូវអនុព្យញ្ជនៈឡើយ (មួយទៀត) ធម៌ទាំងឡាយជាអកុសលដ៏លាមក គឺអភិជ្ឈានិងទោមនស្ស រមែងជាប់តាមនូវភិក្ខុ ព្រោះហេតុមិនសង្រួមឥន្ទ្រិយគឺចក្ខុណា ភិក្ខុនោះក៏ប្រតិបត្តិ ដើម្បីសង្រួមឥន្ទ្រិយគឺចក្ខុនោះ រក្សានូវឥន្ទ្រិយគឺចក្ខុ ដល់នូវសេចក្តីសង្រួមក្នុងឥន្ទ្រិយគឺចក្ខុ ។

សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោ ឥមិនា អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ អជ្ឈត្តំ អព្យាសេកសុខំ បដិសំវេទេតិ ។ សោ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ

ភិក្ខុនោះឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួលរសដោយអណ្តាត... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ហើយក៏មិនក្តួចកាន់នូវនិមិត្ត មិនក្តួចកាន់ នូវអនុព្យញ្ជនៈឡើយ (មួយទៀត) ធម៌ទាំងឡាយជាអកុសលដ៏លាមក គឺអភិជ្ឈានិងទោមនស្ស រមែងជាប់តាមនូវភិក្ខុ ព្រោះហេតុមិនសង្រួមឥន្ទ្រិយគឺចិត្តណា ភិក្ខុនោះប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយគឺចិត្តនោះ រក្សានូវឥន្ទ្រិយគឺចិត្ត ដល់នូវសេចក្តីសង្រួមក្នុងឥន្ទ្រិយគឺចិត្ត ។ ភិក្ខុនោះប្រកបដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះ ក៏ទទួលចំពោះនូវសេចក្តីសុខ ដែលមិនច្រឡំដោយកិលេសក្នុងសន្តាន ។ ភិក្ខុនោះធ្វើនូវសេចក្តីដឹងខ្លួនក្នុងការឈានទៅមុខ និងការឈានថយក្រោយ ជាអ្នកធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាក្រឡេកមើលទៅមុខនិងក្រឡេកមើលមកខាងក្រោយ ជាអ្នកធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាបត់អវយវៈនិងលាតនូវអវយវៈ ជាអ្នកធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាទ្រទ្រង់សង្ឃាដីបាត្រចីវរ ជាអ្នកធ្វើសេចក្តីដឹងខ្លួនក្នុងការស៊ី ផឹក ទំពា ទទួលរស

ឧច្ចារប្បស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។

[៩៦] សោ ឥមិនា ច អរិយេន សីលក្ខន្ធេន សមន្នាគតោ ឥមិនា ច អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ ឥមិនា ច អរិយេន សតិសម្បជញ្ញេន សមន្នាគតោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ អភិជ្ឈំ លោកេ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ ។ ព្យាបាទបទោសំ បហាយ អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យាបាទបទោសា ចិត្តំ បរិសោធេតិ ។ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ

ជាអ្នកធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងកិរិយាបន្ទោបង់ឧច្ចារៈនិងបស្សាវៈ ជាអ្នកធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងកិរិយាដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើងវិញ និយាយ ស្ងៀម ។

[៩៦] ភិក្ខុនោះប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះផង ប្រកបដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះផង ប្រកបដោយសតិនិងសម្បជញ្ញៈដ៏ប្រសើរនេះផង ហើយចូលចិត្តសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ញកឬប្រកភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល និងគំនរចំបើង ។ ភិក្ខុនោះត្រឡប់មក អំពីបិណ្ឌបាតវិញ វេលាក្រោយភត្ត ក៏អង្គុយពែនភ្នែនតម្រង់កាយឲ្យត្រង់ តាំងស្មារតីឆ្ពោះមុខទៅរកកម្មដ្ឋាន ។ ភិក្ខុនោះលះបង់នូវអភិជ្ឈាក្នុងលោកចេញ មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តចាកអភិជ្ឈា ។ លះបង់នូវព្យាបាទ និងសេចក្ដីប្រទូស្តចេញ មានចិត្តមិនព្យាបាទ អនុគ្រោះដោយប្រយោជន៍ ចំពោះពួកសត្វមានជីវិតទាំងអស់ ជម្រះចិត្តចាកព្យាបាទ និងសេចក្ដីប្រទូស្ត ។ លះបង់នូវថីនមិទ្ធៈចេញ ជាអ្នកប្រាសចាកថីនមិទ្ធៈ បាននូវអាលោកសញ្ញាគឺសេចក្ដីភ្លឺស្វាង មានសតិ

សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ។ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ ។ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុសលេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។

[៩៧] សោ ឥមេ បញ្ច នីវរណេ បហាយ ចេត-សោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ តតិយំ ឈានំ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

និងសម្បជញ្ញៈ ជម្រះចិត្តចាកថីនមិទ្ធៈ ។ លះបង់នូវឧទ្ធច្ចកុក្កុច្ចៈចេញ ជាអ្នកមានចិត្តមិនរាយមាយ មានចិត្តស្ងប់រម្ងាប់ក្នុងសន្ដាន ជម្រះចិត្តចាកឧទ្ធច្ចកុក្កុច្ចៈ ។ លះបង់នូវវិចិកិច្ឆា ជាអ្នកឆ្លងចាកសេចក្ដីសង្ស័យ មិនងឿងឆ្ងល់ក្នុងធម៌ទាំងឡាយជាកុសល ជម្រះចិត្តចាកវិចិកិច្ឆា ។

[៩៧] ភិក្ខុនោះលុះលះបង់នូវនីវរណធម៌ទាំង ៥ ប្រការនោះ ដែលជាឧបក្កិលេសរបស់ចិត្ត ដែលជាធម្មជាតធ្វើបញ្ញាឲ្យថយកម្លាំង ហើយស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយក៏ចូលកាន់បឋមជ្ឈាន ដែលមានវិតក្កៈ វិចារៈ មានបីតិនិងសុខៈដែលកើតមកអំពីវិវេក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈបាន ក៏ចូលកាន់ទុតិយជ្ឈាន ជាទីផូរផង់ ប្រព្រឹត្តទៅខាងក្នុង ញុំាងសមាធិចិត្តឲ្យកើត ឥតមានវិតក្កៈនិងវិចារៈទេ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ ។ បេ ។ ចូលកាន់តតិយជ្ឈាន... ចូលកាន់ចតុត្ថជ្ឈាន សម្រេចសម្រាន្តឥរិយាបថ ។

[៩៨] សោ ចក្ខុនា រូបំ ទិស្វា បិយរូបេ រូបេ ន សារជ្ជតិ អប្បិយរូបេ រូបេ ន ព្យាបជ្ជតិ ឧបដ្ឋិតកាយស្សតិ ច វិហរតិ អប្បមាណចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តេ បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ សោ ឯវំ អនុរោធវិរោធវិប្បហីនោ យំ កិញ្ចិ វេទនំ វេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា ។ សោ តំ វេទនំ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ[១] តិដ្ឋតិ តស្ស តំ វេទនំ អនភិនន្ទតោ អនភិវទតោ ន អជ្ឈោសាយ[២] តិដ្ឋតោ យា វេទនាសុ នន្ទិ សា និរុជ្ឈតិ ។ តស្ស នន្ទិនិរោធា ឧបាទាន-និរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិ-និរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោ-មនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា...

១ ឱ. ម. នាជ្ឈោសាយ ។ ២ ឱ. ម. អនជ្ឈោសាយ ។

[៩៨] ភិក្ខុនោះឃើញរូបដោយភ្នែក ហើយមិនត្រេកអរនឹងរូបដែលគួរស្រឡាញ់ មិនមានបដិឃៈចំពោះរូបដែលមិនគួរស្រឡាញ់ ជាអ្នកមានសតិក្នុងកាយតម្កល់នៅខ្ជាប់ផង មានចិត្តប្រកបដោយគុណប្រមាណពុំបានផង ធម៌ទាំងឡាយជាអកុសលដ៏លាមកនោះ របស់ភិក្ខុនោះរមែងរលត់ទៅមិនសល់ក្នុងចេតោវិមុត្តិ បញ្ញាវិមុត្តិណា លោកក៏បានដឹងច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិនោះតាមសេចក្ដីពិតផង ។ ភិក្ខុនោះលុះលះបង់នូវតម្រេកនិងសេចក្ដីក្រេវក្រោធ យ៉ាងនេះហើយ រមែងទទួលវេទនាណាមួយ ជាសុខឬជាទុក្ខ ឬមិនទុក្ខមិនសុខ ។ ភិក្ខុនោះមិនត្រេកអរ មិននិយាយសរសើរ មិនប្រកាន់វេទនានោះឡើយ ។ កាលបើភិក្ខុនោះមិនត្រេកអរ មិននិយាយសរសើរ មិនប្រកាន់វេទនានោះទេ សេចក្ដីត្រេកអរក្នុងវេទនាទាំងឡាយ ក៏នឹងរលត់ទៅមិនសល់ ។ ភិក្ខុនោះបានរលត់ឧបាទាន ព្រោះរលត់តម្រេក បានរលត់ភព ព្រោះរលត់ឧបាទាន បានរលត់ជាតិ ព្រោះរលត់ភព សេចក្ដីចាស់ ស្លាប់ (រលត់) ព្រោះរលត់ជាតិ ការសោក ការខ្សឹកខ្សួល ការលំបាកកាយ ការលំបាកចិត្ត និងសេចក្ដីចង្អៀតចង្អល់ ក៏សឹងតែរលត់ទៅមិនសល់ សេចក្ដីរលត់កងទុក្ខទាំងអស់នេះ រមែងមានដោយប្រការដូច្នេះឯង ។ ភិក្ខុនោះឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួលរសដោយអណ្ដាត... ពាល់

កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ បិយរូបេ ធម្មេ ន សារជ្ជតិ អប្បិយរូបេ ធម្មេ ន ព្យាបជ្ជតិ ឧបដ្ឋិតកាយស្សតិ ច វិហរតិ អប្បមា-ណចេតសោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថា-ភូតំ បជានាតិ យត្ថស្ស តេ បាបកា អកុសលា ធម្មា អបរិសេសា និរុជ្ឈន្តិ ។ សោ ឯវំ អនុរោធវិ-រោធវិប្បហីនោ យំ កញ្ចិ វេទនំ វេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា ។ សោ តំ វេទនំ នាភិ-នន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ ។ តស្ស តំ វេទនំ អនភិនន្ទតោ អនភិវទតោ ន អជ្ឈោសាយ តិដ្ឋ-តោ យា វេទនាសុ នន្ទិ សា និរុជ្ឈតិ ។ តស្ស នន្ទិនិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវ-និរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា

ត្រូវផោដ្ឋព្វៈដោយកាយ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ ក៏មិនត្រេកអរនឹងធម្មារម្មណ៍ ដែលមានសភាពគួរស្រឡាញ់ មិនមានបដិឃៈចំពោះធម្មារម្មណ៍ ដែលមានសភាពមិនគួរស្រឡាញ់ ជាអ្នកមានសតិក្នុងកាយតម្កល់នៅខ្ជាប់ផង មានចិត្តប្រកបដោយគុណប្រមាណពុំបានផង ធម៌ទាំងឡាយជាអកុសលដ៏លាមករបស់ភិក្ខុនោះ រមែងរលត់ទៅមិនសល់ ក្នុងចេតោវិមុត្តិ បញ្ញាវិមុត្តិណា ភិក្ខុនោះក៏បានដឹងច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិនោះ តាមសេចក្ដីពិតផង ។ ភិក្ខុនោះលះបង់នូវតម្រេកនិងសេចក្ដីក្រេវក្រោធយ៉ាងនេះហើយ រមែងទទួលវេទនាណាមួយជាសុខឬជាទុក្ខឬមិនទុក្ខមិនសុខ ។ ភិក្ខុនោះមិនត្រេកអរ មិននិយាយសរសើរ មិនប្រកាន់វេទនានោះឡើយ ។ កាលបើភិក្ខុនោះមិនត្រេកអរ មិននិយាយសរសើរ មិនប្រកាន់វេទនានោះហើយ សេចក្ដីត្រេកអរក្នុងវេទនាទាំងឡាយ ក៏នឹងរលត់ទៅមិនសល់ ។ ភិក្ខុនោះបានរលត់ឧបាទាន ព្រោះរលត់តម្រេក បានរលត់ភព ព្រោះរលត់ឧបាទាន បានរលត់ជាតិ ព្រោះរលត់ភព សេចក្ដីចាស់ ស្លាប់ (រលត់) ព្រោះរលត់ជាតិ ការសោក ការខ្សឹកខ្សួល ការលំបាកកាយ ការលំបាកចិត្តនិងការចង្អៀត

និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ ឥមំ ខោ មេ តុម្ហេ ភិក្ខវេ សង្ខិត្តេន តណ្ហាសង្ខយវិមុត្តឹ ធារេថ សាតឹ បន ភិក្ខុំ កេវដ្ដបុត្តំ មហាតណ្ហាជាលសង្ឃាដប្បដិមុក្កន្តិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

មហាតណ្ហាសង្ខយសុត្តំ អដ្ឋមំ និដ្ឋិតំ ។

ចង្អុលទាំងឡាយ ក៏រលត់ទៅមិនសល់ សេចក្តីរលត់កងទុក្ខទាំងអស់នេះ រមែងមានដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុក នូវឧបាយជាគ្រឿងបង្អោនចិត្តទៅ ក្នុងព្រះនិព្វានជាទីក្ស័យនៃ តណ្ហានេះ ដោយសង្ខេបរបស់តថាគតនេះចុះ ហើយចូរចាំទុកនូវសាតិភិក្ខុ-កេវដ្តបុត្តនេះថា ជាអ្នកចំពាក់ក្នុងសំណាញ់ ដ៏ចង្អៀតចង្អុលគឺតណ្ហាធំ នេះដូច្នេះឯង ។ លុះព្រះមានព្រះភាគ បានត្រាស់ភាសិតនេះចប់ហើយ ភិក្ខុទាំងនោះក៏មានសេចក្តីពេញចិត្ត ត្រេកអរហើយចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ មហាតណ្ហាសង្ខយសូត្រ ទី ៨ ។

# នវមំ មហាអស្សបុរសុត្តំ

[៩៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា អង្គេ-
សុ វិហរតិ អស្សបុរំ នាម អង្គានំ និគមោ ។ តត្រ ខោ
ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ
ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សមណា
សមណាតិ វោ ភិក្ខវេ ជនោ សញ្ជានាតិ តុម្ហេ ច
បន កេ តុម្ហេតិ បុដ្ឋា សមានា សមណម្ហាតិ បដិ-
ជានាថ តេសំ វោ ភិក្ខវេ ឯវំសមញ្ញានំ សតំ ឯវំ-
បដិញ្ញានំ សតំ យេ ធម្មា សមណករណា ច ព្រាហ្ម-
ណករណា ច តេ ធម្មេ សមាទាយ វត្តិស្សាម ឯ-
វន្នោ អយំ អម្ហាកំ សមញ្ញា ច សច្ចា[១] ភវិស្សតិ
បដិញ្ញា ច ភូតា យេសញ្ច មយំ ចីវរបិណ្ឌបាត-
សេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេ[២] បរិភុញ្ជាម

១ ម. អវញ្ឈា ។ ២ ឱ. ម. ចីវរ... បរិក្ខារំ ។

# មហាអស្សបុរសូត្រ ទី ៩

[៩៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងនិគមរបស់អ្នកដែនអង្គៈ ឈ្មោះអស្សបុរៈ ទៀបដែនអង្គៈ ។ ក្នុងកាលនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទូលតបព្រះពុទ្ធដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកផងតែងស្គាល់ច្បាស់នូវអ្នកទាំងឡាយ ថាជាសមណៈ ៗ ដូច្នេះ ឯអ្នកទាំងឡាយបើមានអ្នកផងសួរថា លោកទាំងឡាយជាអ្វី ក៏ចូរប្តេជ្ញាថា យើងទាំងឡាយជាសមណៈ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយនោះមានឈ្មោះយ៉ាងនេះ ប្តេជ្ញាយ៉ាងនេះហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរសិក្សាយ៉ាងនេះថា ធម៌ទាំងឡាយណា ដែលធ្វើឲ្យជាសមណៈផង ធ្វើឲ្យជាព្រាហ្មណ៍ផង ពួកយើងនឹងសមាទានប្រព្រឹត្តធម៌ទាំងនោះ ឈ្មោះរបស់ពួកយើងនេះ ក៏នឹងពិតយ៉ាងនេះ ទាំងការប្តេជ្ញាក៏ប្រាកដយ៉ាងនេះ មួយវិញទៀត យើងទាំងឡាយបរិភោគនូវចីវរបិណ្ឌបាតសេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ របស់ជនទាំងឡាយណា

តេសន្តេ កាកា អម្ហេសុ មហប្ផលា ភវិស្សន្តិ មហានិសំសា អម្ហាកញ្ចេវាយំ[១] បព្ពជ្ជា អវញ្ឈា ភវិស្សតិ សផលា សឧទ្រយាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ[២] ។

[១០០] កតមេ ច ភិក្ខវេ ធម្មា សមណការណា ច ព្រាហ្មណការណា ច ។ ហិរោត្តប្បេន សមន្នាគតា ភវិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ សិយា ខោ បន ភិក្ខវេ តុម្ហាកំ ឯវមស្ស ហិរោត្តប្បេនម្ហ សមន្នាគតា អលមេត្តាវតា កតមេត្តាវតា អនុប្បត្តោ នោ សាមញ្ញត្ថោ នត្ថិ កិញ្ចិ ឧត្តរឹ ករណីយន្តិ តាវតកេនេវ ច[៣] តុដ្ឋឹ អាបជ្ជេយ្យាថ អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ មា វោ សាមញ្ញត្ថិកានំ សតំ សាមញ្ញត្ថោ បរិហាយិ សតិ ឧត្តរឹ ករណីយេ ។

---

១ ម. អម្ហាកញ្ចេវាយំ យំ ។ ២ ឱ. ម. សិក្ខិតព្វំ ។ ឥតិសទ្ទោ នត្ថិ ។ ៣ ឱ. ម. ចសទ្ទោ ន ទិស្សតិ ។

សក្ការៈទាំងឡាយនេះ ដែលជនទាំងនោះ (បូជា) ដល់យើងទាំងឡាយ នឹងទៅជាសក្ការៈមានផលច្រើន មានអានិសង្សច្រើន ឯបព្វជ្ជារបស់ពួកយើងមិនមែនជាឥតអំពើទេ នឹងមានផល មានសេចក្ដីចម្រើន ។

[១០០] ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ដែលធ្វើឲ្យជាសមណៈទាំងធ្វើឲ្យជាព្រាហ្មណ៍ ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយគប្បីសិក្សា យ៉ាងនេះថា ពួកយើងនឹងជាអ្នកប្រកបដោយហិរិនិងឱត្តប្បៈ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយមានសេចក្ដីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិនិងឱត្តប្បៈហើយ កិច្ចដែលពួកយើងធ្វើហើយក៏ល្មមត្រឹមប៉ុណ្ណោះ ប្រយោជន៍របស់សមណៈ[១] យើងទាំងឡាយ ក៏បានដល់ហើយត្រឹមប៉ុណ្ណោះ កិច្ចដែលត្រូវធ្វើតទៅទៀតតិចតួច មិនមានទេ លុះគិតដូច្នេះហើយ អ្នកទាំងឡាយគប្បីដល់នូវសេចក្ដីត្រេកអរដោយហេតុប៉ុណ្ណោះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយត្រូវការនូវភាពជាសមណៈ កុំលះបង់ប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

---

១ ប្រយោជន៍របស់សមណៈក្នុងទីនេះ សំដៅយកមគ្គនិងផល ។ អដ្ឋកថា ។

[១០១] កិញ្ច ភិក្ខវេ ឧត្តរឹ ករណីយំ ។ បរិ-
សុទ្ធោ នោ កាយសមាចារោ ភវិស្សតិ ឧត្តានោ វិវដោ
ន ច ឆិទ្ទវា សំវុតោ ច តាយ ច បន បរិសុទ្ធកា-
យសមាចារតាយ នេវត្តានុក្កំសិស្សាម ន បរំ វម្ភិស្សា-
មាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ សិយា ខោ បន
ភិក្ខវេ តុម្ហាកំ ឯវមស្ស ហិរោត្តប្បេនម្ហ សមន្នាគតា
បរិសុទ្ធោ នោ កាយសមាចារោ អលមេត្តាវតា កត-
មេត្តាវតា អនុប្បត្តោ នោ សាមញ្ញត្ថោ នត្ថិ នោ កិញ្ចិ
ឧត្តរឹ ករណីយន្តិ តាវតកេនេវ ច តុដ្ឋឹ អាបជ្ជេយ្យាថ
អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ មា
វោ សាមញ្ញត្ថិកានំ សតំ សាមញ្ញត្ថោ បរិហាយិ ស-
តិ ឧត្តរឹ ករណីយេ ។

[១០១] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀតដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា កាយសមាចារៈរបស់ពួកយើងនឹងបរិសុទ្ធខ្ពង់ខ្ពស់ មិនរយីករយាក មិនធ្លុះធ្លាយ សង្រួមល្អ ប៉ុន្តែពួកយើងនឹងកុំលើកតម្កើងខ្លួនឯង កុំបន្តុះបង្អាប់អ្នកដទៃ ព្រោះកាយសមាចារៈបរិសុទ្ធនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ពួកយើងជាអ្នកប្រកបដោយហិរិនិងឱត្តប្បៈ កាយសមាចារៈរបស់ពួកយើងបរិសុទ្ធហើយ កិច្ចដែលពួកយើងត្រូវធ្វើ ក៏ល្មមត្រឹមប៉ុណ្ណេះហើយ ទាំងប្រយោជន៍របស់សមណៈយើងទាំងឡាយក៏បានដល់ហើយ ដោយហេតុត្រឹមប៉ុណ្ណេះ កិច្ចបន្តិចបន្តួចដែលត្រូវធ្វើតទៅទៀតរបស់ពួកយើង មិនមានឡើយ លុះគិតដូច្នេះហើយ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីត្រេកអរ ដោយហេតុប៉ុណ្ណេះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយត្រូវការដោយភាពជាសមណៈហើយ ត្រូវកុំលះបង់នូវប្រយោជន៍ ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[១០២] កិញ្ច ភិក្ខវេ ឧត្តរឹ ករណីយំ ។ បរិសុទ្ធោ នោ វចីសមាចារោ ភវិស្សតិ ឧត្តានោ វិវដ្ដោ ន ច ឆិទ្ទវា សំវុតោ ច តាយ ច បន បរិសុទ្ធវចីសមាចារតាយ នេវត្តានុក្កំសិស្សាម ន បរំ វម្ភិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ សិយា ខោ បន ភិក្ខវេ តុម្ហាកំ ឯវមស្ស ហិរោត្តប្បេនម្ហា សមន្នាគតា បរិសុទ្ធោ នោ កាយសមាចារោ បរិសុទ្ធោ វចីសមាចារោ អលមេត្តាវតា កតមេត្តាវតា អនុប្បត្តោ នោ សាមញ្ញត្ថោ នត្ថិ នោ កិញ្ចិ ឧត្តរឹ ករណីយន្តិ តាវតកេនេវ ច តុដ្ឋឹ អាបជ្ជេយ្យាថ អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ មា វោ សាមញ្ញត្ថិកានំ សតំ សាមញ្ញត្ថោ បរិហាយិ សតិ ឧត្តរឹ ករណីយេ ។

[១០២] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា វចីសមាចារៈរបស់ពួកយើងនឹងបរិសុទ្ធខ្ពង់ខ្ពស់ មិនពាយមាយ មិនធ្លុះធ្លាយ សង្រួមល្អ ប៉ុន្តែពួកយើងកុំលើកតម្កើងខ្លួនឯង កុំបន្តុះបង្អាប់អ្នកដទៃព្រោះវចីសមាចារៈបរិសុទ្ធនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយមានសេចក្ដីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិនិងឱត្តប្បៈ កាយសមាចារៈរបស់ពួកយើងបរិសុទ្ធហើយ ទាំងវចីសមាចារៈក៏បរិសុទ្ធ កិច្ចដែលត្រូវធ្វើក៏ល្មមត្រឹមប៉ុណ្ណោះហើយ ប្រយោជន៍របស់សមណៈ ពួកយើងក៏បានដល់ហើយ កិច្ចបន្តិចបន្តួចត្រូវធ្វើតទៅទៀតរបស់ពួកយើងមិនមានឡើយ ដូច្នេះហើយ អ្នកទាំងឡាយគប្បីដល់នូវសេចក្ដីត្រេកអរដោយហេតុប៉ុណ្ណោះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយត្រូវការដោយភាពជាសមណៈហើយ កុំលះបង់នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[១០៣] កិញ្ច ភិក្ខវេ ឧត្តរឹ ករណីយំ ។ បរិសុទ្ធោ នោ មនោសមាចារោ ភវិស្សតិ ឧត្តានោ វិវដោ ន ច ឆិទ្ទវា សំវុតោ ច តាយ ច បន បរិសុទ្ធមនោសមាចារតាយ នេវត្តានុក្កំសិស្សាម ន បរំ វម្ភិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ សិយា ខោ បន ភិក្ខវេ តុម្ហាកំ ឯវមស្ស ហិរោត្តប្បេ-នម្ហ សមន្នាគតា បរិសុទ្ធោ នោ កាយសមាចារោ បរិសុទ្ធោ វចីសមាចារោ បរិសុទ្ធោ មនោសមាចារោ អលមេត្តាវតា កតមេត្តាវតា អនុប្បត្តោ នោ សា-មញ្ញត្ថោ នត្ថិ នោ កិញ្ចិ ឧត្តរឹ ករណីយន្តិ តាវតកេ-នេវ ច តុដ្ឋឹ អាបជ្ជេយ្យាថ អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ មា វោ សាមញ្ញត្ថិកានំ សតំ សាមញ្ញត្ថោ បរិហាយិ សតិ ឧត្តរឹ ករណីយេ ។

[១០៣] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា មនោ-សមាចារៈរបស់ពួកយើងនឹងបរិសុទ្ធខ្ពង់ខ្ពស់ មិនរាយមាយ មិនធ្លុះធ្លាយ សង្រួមល្អ ប៉ុន្តែពួកយើង កុំលើកតម្កើងខ្លួនឯង កុំបន្តុះបង្អាប់អ្នកដទៃ ព្រោះមនោសមាចារៈបរិសុទ្ធនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិនិងឱត្តប្បៈ កាយសមាចារៈរបស់ពួកយើងបរិសុទ្ធហើយ វចី-សមាចារៈបរិសុទ្ធហើយ មនោសមាចារៈបរិសុទ្ធហើយ កិច្ចដែលត្រូវធ្វើក៏ល្មមដោយហេតុត្រឹមប៉ុណ្ណេះហើយ ប្រយោជន៍របស់សមណៈ ពួកយើងក៏បានដល់ហើយដោយហេតុត្រឹមប៉ុណ្ណេះ កិច្ចបន្តិចបន្តួចត្រូវធ្វើតទៅទៀត របស់ពួកយើង មិនមានឡើយ ដូច្នេះហើយ អ្នកទាំង-ឡាយគប្បីដល់នូវសេចក្តីត្រេកអរ ដោយហេតុប៉ុណ្ណេះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយត្រូវការដោយភាពជាសមណៈហើយ កុំលះបង់នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[១០៤] កិញ្ច ភិក្ខវេ ឧត្តរឹ ករណីយំ ។ បរិសុទ្ធោ នោ អាជីវោ ភវិស្សតិ ឧត្តានោ វិវដោ ន ច ឆិទ្ទវា សំវុតោ ច តាយ ច បន បរិសុទ្ធាជីវតាយ នេវត្តានុក្កំសិស្សាម ន បរំ វម្ភិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ សិយា ខោ បន ភិក្ខវេ តុម្ហាកំ ឯវមស្ស ហិរោត្តប្បេនម្ហ សមន្នាគតា បរិសុទ្ធោ នោ កាយសមាចារោ បរិសុទ្ធោ វចីសមាចារោ បរិសុទ្ធោ មនោសមាចារោ បរិសុទ្ធោ អាជីវោ អលមេត្តាវតា កតមេត្តាវតា អនុប្បត្តោ នោ សាមញ្ញត្ថោ នត្ថិ នោ កិញ្ចិ ឧត្តរឹ ករណីយន្តិ តាវតកេនេវ ច តុដ្ឋឹ អាបជ្ជេយ្យាថ អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ មា វោ សាមញ្ញត្ថិកានំ សតំ សាមញ្ញត្ថោ បរិហាយិ សតិ ឧត្តរឹ ករណីយេ ។

មហាយមកវគ្គ មហាអស្សបុរសូត្រ បណ្តាធម៌ទាំង ១០ ធម៌ទី ៥

[១០៤] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា អាជីវៈរបស់ពួកយើងនឹងបរិសុទ្ធស្អាត មិនរាយមាយ មិនជុះធ្លាយ សង្រួមល្អ ប៉ុន្តែពួកយើងកុំលើកតម្កើងខ្លួនឯង កុំបន្តុះបង្អាប់អ្នកដទៃ ព្រោះអាជីវៈបរិសុទ្ធនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិនិងឱត្តប្បៈ កាយសមាចារៈរបស់ពួកយើងបរិសុទ្ធហើយ វចីសមាចារៈបរិសុទ្ធហើយ មនោសមាចារៈបរិសុទ្ធហើយ អាជីវៈបរិសុទ្ធហើយ កិច្ចដែលត្រូវធ្វើក៏ល្មមដោយហេតុត្រឹមប៉ុណ្ណោះហើយ ប្រយោជន៍របស់សមណៈ ពួកយើងក៏បានដល់ហើយ ដោយហេតុត្រឹមប៉ុណ្ណោះ កិច្ចបន្តិចបន្តួចត្រូវធ្វើតទៅទៀត របស់ពួកយើងមិនមានឡើយ ដូច្នេះហើយ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីត្រេកអរ ដោយហេតុមានប្រមាណប៉ុណ្ណោះ ពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយត្រូវការដោយភាពជាសមណៈហើយ អ្នកកុំលះបង់នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[១០៤] កិញ្ច ភិក្ខវេ ឧត្តរឹ ករណីយំ ។ ឥន្ទ្រិយេសុ គុត្តទ្វារា ភវិស្សាម ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជិស្សាម រក្ខិស្សាម ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជិស្សាម ។ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជិស្សាម រក្ខិស្សាម មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ សិយា ខោ បន ភិក្ខវេ តុម្ហាកំ ឯវមស្ស ហិរោត្តប្បេនម្ហ សមន្នាគតា បរិសុទ្ធោ នោ កាយសមាចារោ បរិសុទ្ធោ វចីសមាចារោ

[១០៥] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា ពួកយើងនឹងមានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ គឺបើ ឃើញរូបដោយចក្ខុក៏មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមកគឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវបុគ្គលព្រោះហេតុមិនសង្រួមឥន្ទ្រិយ គឺចក្ខុណា ពួកយើងនឹងប្រតិបត្តិ ដើម្បីសង្រួមនូវឥន្ទ្រិយគឺចក្ខុនោះ រក្សានូវឥន្ទ្រិយគឺចក្ខុ ដល់នូវកិរិយាសង្រួមក្នុងឥន្ទ្រិយគឺចក្ខុ ។ ឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួលរសដោយអណ្តាត... ពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ ក៏មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមកគឺអភិជ្ឈានិងទោមនស្ស រមែងជាប់តាមនូវបុគ្គលព្រោះហេតុមិនសង្រួមឥន្ទ្រិយគឺចិត្តណា ពួកយើងនឹងប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយគឺចិត្តនោះ រក្សានូវឥន្ទ្រិយគឺចិត្ត ដល់នូវកិរិយាសង្រួមក្នុងឥន្ទ្រិយគឺចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិនិងឱត្តប្បៈ កាយសមាចារៈរបស់ពួកយើងបរិសុទ្ធហើយ វចីសមាចារៈ

បរិសុទ្ធោ មនោសមាចារោ បរិសុទ្ធោ អាជីវោ ឥន្ទ្រិយេសុ គុត្តទ្វារា អលមេត្តាវតា កតមេត្តាវតា អនុប្បត្តោ នោ សាមញ្ញត្ថោ នត្ថិ នោ កិញ្ចិ ឧត្តរឹ ករណីយន្តិ តាវតកោនេវ ច តុដ្ឋឹ អាបជ្ជេយ្យាថ អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ មា វោ សាមញ្ញត្ថិកានំ សតំ សាមញ្ញត្ថោ បរិហាយិ សតិ ឧត្តរឹ ករណីយេ ។

[១០៦] កិញ្ច ភិក្ខវេ ឧត្តរឹ ករណីយំ ។ ភោជនេ មត្តញ្ញូ ភវិស្សាម បដិសង្ខា យោនិសោ អាហារំ អាហារិស្សាម នេវ ទវាយ ន មទាយ

បរិសុទ្ធហើយ មនោសមាចារៈបរិសុទ្ធហើយ អាជីវៈបរិសុទ្ធហើយ យើងមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយហើយ កិច្ចដែលត្រូវធ្វើល្មមដោយហេតុត្រឹមប៉ុណ្ណេះហើយ ប្រយោជន៍របស់សមណៈ ពួកយើងក៏បានដល់ដោយហេតុត្រឹមប៉ុណ្ណេះហើយ កិច្ចបន្តិចបន្តួចត្រូវធ្វើតទៅទៀត របស់ពួកយើង មិនមានឡើយ ដូច្នេះហើយ អ្នកទាំងឡាយគប្បីដល់នូវសេចក្ដីត្រេកអរដោយហេតុប៉ុណ្ណេះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយកាលបើអ្នកទាំងឡាយ ត្រូវការដោយភាពជាសមណៈហើយ អ្នកទាំង-ឡាយកុំលះបង់ នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[១០៦] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា ពួកយើងនឹងជាអ្នកដឹងប្រមាណក្នុងភោជន ពិចារណាដោយឧបាយនៃប្រាជ្ញាហើយទើបបរិភោគនូវអាហារ នឹងបរិភោគដើម្បីលេង (ដូចក្មេងអ្នកស្រុក) ក៏ទេ ដើម្បីនឹងឲ្យកើតបុរិសមានះស្រវឹង (ដូចអ្នកប្រដាល់) ក៏ទេ

ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កា-
យស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្ម-
ចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាម
នវញ្ច វេទនំ ន ឧប្បាទេស្សាម យាត្រា ច មេ
ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ឯវញ្ហិ
វោ ភិក្ខវេ សិក្ខិតព្វំ ។ សិយា ខោ បន ភិក្ខវេ
តុម្ហាកំ ឯវមស្ស ហិរោត្តប្បេនម្ហ សមន្នាគតា បរិ-
សុទ្ធោ នោ កាយសមាចារោ បរិសុទ្ធោ វចីសមា-
ចារោ បរិសុទ្ធោ មនោសមាចារោ បរិសុទ្ធោ អាជីវោ
ឥន្ទ្រិយេសុម្ហ គុត្តទ្វារា ភោជនេ មត្តញ្ញុនោ អល-
មេត្តាវតា កតមេត្តាវតា អនុប្បត្តោ នោ សាម-
ញ្ញត្ថោ នត្ថិ នោ កិញ្ចិ ឧត្តរឹ ករណីយន្តិ

ដើម្បីនឹងប្រដាប់តាក់តែងរាងកាយ (ដូចស្ត្រីក្នុងបូរី) ក៏ទេ ដើម្បីនឹងធ្វើឲ្យផូរផង់សម្បុរ (ដូចអ្នកលេងរបាំ) ក៏ទេ បរិភោគគ្រាន់តែដើម្បីតាំងនៅនៃកាយនេះ ដើម្បីញុំាងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចរិយៈ ពួកយើងនឹងបំបាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង នឹងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឲ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស គឺមិនប្រអូសកាយមិនប្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយ ដោយឥរិយាបថទាំង ៤ ក្តី នឹងមានដល់ពួកយើង (ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ) ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិនិងឱត្តប្បៈ កាយសមាចារៈរបស់ពួកយើងបរិសុទ្ធហើយ វចីសមាចារៈបរិសុទ្ធហើយ មនោសមាចារៈបរិសុទ្ធហើយ អាជីវៈបរិសុទ្ធហើយ ពួកយើងមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយហើយ ជាអ្នកដឹងប្រមាណក្នុងភោជន កិច្ចដែលត្រូវធ្វើល្មមដោយហេតុត្រឹមប៉ុណ្ណោះហើយ ប្រយោជន៍របស់សមណៈ ពួកយើងក៏បានដល់ ដោយហេតុត្រឹមប៉ុណ្ណោះហើយ កិច្ចបន្តិចបន្តួច ត្រូវធ្វើតទៅទៀតរបស់ពួកយើង មិនមានឡើយ ដូច្នេះហើយ អ្នកទាំងឡាយគប្បី

តាវតកេនេវ ច តុដ្ឋឹ អាបជ្ជេយ្យាថ អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ មា វោ សាមញ្ញត្ថិកានំ សតំ សាមញ្ញត្ថោ បរិហាយិ សតិ ឧត្តរឹ ករណីយេ ។

[១០៧] កិញ្ច ភិក្ខវេ ឧត្តរឹ ករណីយំ ។ ជាគរិយមនុយុត្តា ភវិស្សាម ទិវសំ ចង្កមេន និសជ្ជា-យ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេស្សាម រត្តិយា បឋមំ យាមំ ចង្កមេន និសជ្ជាយ អាវរ-ណីយេហិ ធម្មេហិ ចិត្តំ បរិសោធេស្សាម រត្តិយា មជ្ឈិមំ យាមំ ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេស្សាម បាទេ បាទំ អច្ចាធាយ សតោ សម្បជានោ[១] ឧដ្ឋានសញ្ញំ មនសិករិត្វា រត្តិយា បច្ឆិមំ យាមំ បច្ចុដ្ឋាយ ចង្កមេន និសជ្ជាយ អាវ-រណីយេហិ ធម្មេហិ ចិត្តំ បរិសោធេស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ សិយា ខោ បន ភិក្ខវេ តុម្ហាកំ ឯវមស្ស ហិរោត្តប្បេនម្ហ សមន្នាគតា បរិ-សុទ្ធោ នោ កាយសមាចារោ បរិសុទ្ធោ វចីសមាចារោ

ដល់នូវសេចក្ដីត្រេកអរ ដោយហេតុប៉ុណ្ណោះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំង-ឡាយ កាលបើអ្នកទាំងឡាយ ត្រូវការដោយភាពជាសមណៈហើយ អ្នកទាំងឡាយកុំលះបង់នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[១០៧] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា ពួកយើងនឹងជាអ្នកប្រកបរឿយ ៗ ក្នុងការភ្ញាក់រលឹក នឹងជម្រះចិត្តចាកពួកធម៌ដែលជាគ្រឿងរារាំង ដោយការចង្រ្កមឬអង្គុយក្នុងវេលាថ្ងៃ នឹងជម្រះចិត្តចាកពួកធម៌ដែលជាគ្រឿងរារាំង ដោយការចង្រ្កមឬអង្គុយអស់បឋមយាមនៃរាត្រី នឹងសម្រេចសីហសេយ្យាសដោយបង្អៀងខាងស្ដាំអស់មជ្ឈិម-យាមនៃរាត្រី នឹងតម្រួតជើងឆ្វេងលើជើងស្ដាំ មានសតិនិងសម្បជញ្ញៈ ធ្វើទុកក្នុងចិត្តនូវឧដ្ឋានសញ្ញា (គឺចំណាំពេលក្រោក) រួចក្រោកឡើងក្នុងមច្ឆិមយាមនៃរាត្រី ជម្រះចិត្តចាកពួកធម៌ដែលជាគ្រឿងរារាំងដោយការចង្រ្កមឬអង្គុយ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយមានសេចក្ដីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិនិងឱត្តប្បៈ កាយសមាចារៈ របស់យើងបរិសុទ្ធហើយ វចីសមាចារៈបរិសុទ្ធហើយ

បរិសុទ្ធោ មនោសមាចារោ បរិសុទ្ធោ អាជីវោ ឥន្ទ្រិយេសុម្ហ គុត្តទ្វារា ភោជនេ មត្តញ្ញុនោ ជាគរិយំ អនុយុត្តា អលមេត្តាវតា កតមេត្តាវតា អនុប្បត្តោ នោ សាមញ្ញត្ថោ នត្ថិ នោ កិញ្ចិ ឧត្តរឹ ករណីយន្តិ តាវតកេនេវ ច តុដ្ឋឹ អាបជ្ជេយ្យាថ អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ មា វោ សាមញ្ញត្ថិកានំ សតំ សាមញ្ញត្ថោ បរិហាយិ សតិ ឧត្តរឹ ករណីយេ ។

[១០៨] កិញ្ច ភិក្ខវេ ឧត្តរឹ ករណីយំ ។ សតិសម្បជញ្ញេន សមន្នាគតា ភវិស្សាម អភិក្កន្តេ បដិក្កន្តេ សម្បជានការី អាលោកិតេ វិលោកិតេ សម្បជានការី សម្មិញ្ជិតេ បសារិតេ សម្បជានការី សង្ឃាដិបត្តចីវរធារណេ សម្បជានការី

មនោសមាចារៈបរិសុទ្ធហើយ អាជីវៈបរិសុទ្ធហើយ ពួកយើងជាអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយហើយ ពួកយើងជាអ្នកដឹងប្រមាណក្នុងភោជន ជាអ្នកប្រកបរឿយ ៗ ក្នុងកិរិយាភ្ញាក់រលឹក កិច្ចដែលត្រូវធ្វើល្មមដោយហេតុត្រឹមប៉ុណ្ណោះហើយ ប្រយោជន៍របស់សមណៈ ពួកយើងក៏បានដល់ ដោយហេតុត្រឹមប៉ុណ្ណោះហើយ កិច្ចបន្តិចបន្តួចត្រូវធ្វើតទៅទៀតរបស់ពួកយើង មិនមានឡើយ ដូច្នេះហើយ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីត្រេកអរដោយហេតុប៉ុណ្ណោះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគត ប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយ ត្រូវការដោយភាពជាសមណៈហើយ អ្នកទាំងឡាយកុំលះបង់ នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[១០៨] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា ពួកយើងនឹងជាអ្នកប្រកបដោយសតិនិងសម្បជញ្ញៈ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាឈានទៅមុខនិងឈានថយក្រោយ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាក្រឡេកមើលទៅមុខនិងក្រឡេកមើលមកក្រោយ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងការបត់អវយវៈនិងលាតអវយវៈ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាទ្រទ្រង់សង្ឃាដី

## ២០៧

### មហាយមកវគ្គស្ស មហាអស្សបុរសុត្តេ នវមធម្មោ

អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ឧច្ចារប្បស្សាវកម្មេ សម្បជានការី គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការីតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ សិយា ខោ បន ភិក្ខវេ តុម្ហាកំ ឯវមស្ស ហិរោត្តប្បេនម្ហ សមន្នាគតា បរិសុទ្ធោ នោ កាយសមាចារោ បរិសុទ្ធោ វចីសមាចារោ បរិសុទ្ធោ មនោសមាចារោ បរិសុទ្ធោ អាជីវោ ឥន្ទ្រិយេសុម្ហ គុត្តទ្វារា ភោជនេ មត្តញ្ញុនោ ជាគរិយំ អនុយុត្តា សតិសម្បជញ្ញេន សមន្នាគតា អលមេត្តាវតា កតមេត្តាវតា អនុប្បត្តោ នោ សាមញ្ញត្ថោ នត្ថិ នោ កិញ្ចិ ឧត្តរឹ ករណីយន្តិ តាវតកេនេវ ច តុដ្ឋឹ អាបជ្ជេយ្យាថ អារោចយាមិ វោ ភិក្ខវេ បដិវេទយាមិ វោ ភិក្ខវេ មា វោ សាមញ្ញត្ថិកានំ សតំ សាមញ្ញត្ថោ បរិហាយិ សតិ ឧត្តរឹ ករណីយេ ។

បាត្រ ចីវរ ធ្វើនូវសេចក្ដីដឹងខ្លួនក្នុងកិរិយាឆាន់ ផឹក ទំពា ទទួលរស ធ្វើនូវសេចក្ដីដឹងខ្លួនក្នុងកិរិយាបន្ទោបង់នូវឧច្ចារៈនិងបស្សាវៈ ធ្វើនូវសេចក្ដីដឹងខ្លួនក្នុងកិរិយាដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយស្ដី នៅស្ងៀម ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយមានសេចក្ដីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិនិងឱត្តប្បៈ កាយ-សមាចាររបស់ពួកយើងបរិសុទ្ធហើយ វចីសមាចារបរិសុទ្ធហើយ មនោ-សមាចារបរិសុទ្ធហើយ អាជីវៈបរិសុទ្ធហើយ ពួកយើងជាអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយហើយ ជាអ្នកដឹងនូវប្រមាណក្នុងភោជន ជាអ្នកប្រកបរឿយ ៗ ក្នុងការភ្ញាក់រលឹក ប្រកបដោយសតិនិងសម្បជញ្ញៈ កិច្ចដែលត្រូវធ្វើល្មមដោយហេតុត្រឹមប៉ុណ្ណេះ ទាំងប្រយោជន៍របស់សម-ណៈ ពួកយើងក៏បានដល់ដោយហេតុត្រឹមប៉ុណ្ណេះហើយ កិច្ចបន្តិចបន្តួចត្រូវធ្វើតទៅទៀត របស់ពួកយើង មិនមានឡើយ ដូច្នេះហើយ អ្នកទាំងឡាយគប្បីដល់ នូវសេចក្ដីត្រេកអរ ដោយហេតុប៉ុណ្ណេះ ពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយត្រូវការដោយភាពជាសមណៈហើយ អ្នកទាំងឡាយកុំលះបង់នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[១០៩] កិញ្ច ភិក្ខវេ ឧត្តរឹ ករណីយំ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ អភិជ្ឈំ[១] លោកេ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ ។ ព្យាបាទប្បទោសំ បហាយ អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យា-បាទប្បទោសា ចិត្តំ បរិសោធេតិ ។ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ សម្ប-ជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ។ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ ។ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុសលេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។

---

១ អភិជ្ឈា ។

[១០៩] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀតដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ អាស្រ័យនូវសេនាសនៈស្ងាត់ គឺព្រៃ ទីជិតដើមឈើ ភ្នំ ច្រក ប្អញក គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង ។ ភិក្ខុនោះត្រឡប់មកពីបិណ្ឌបាតវិញ វេលាខាងក្រោយកត្ត ក៏អង្គុយពែនភ្នែនតាំងកាយឲ្យត្រង់ តម្កល់សតិឲ្យបែរមុខឆ្ពោះ (ទៅរកព្រះកម្មដ្ឋាន) ។ ភិក្ខុនោះលះបង់នូវអភិជ្ឈាក្នុងលោក ជាអ្នកមានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តចាកអភិជ្ឈា ។ លះបង់នូវព្យាបាទនិងសេចក្តីប្រទូស្ត មានចិត្តមិនព្យាបាទ ជាអ្នកអនុគ្រោះដោយប្រយោជន៍ចំពោះពួកសត្វមានជីវិតទាំងពួង ជម្រះចិត្តចាកព្យាបាទនិងសេចក្តីប្រទូស្ត ។ លះបង់នូវថីនមិទ្ធៈ គឺមានថីនមិទ្ធៈទៅប្រាសហើយ មានអាលោកសញ្ញា (គឺជាអ្នកមានសេចក្តីសំគាល់នូវពន្លឺ) មានសតិនិងសម្បជញ្ញៈ ជម្រះចិត្តចាកថីនមិទ្ធៈ ។ លះបង់នូវឧទ្ធច្ចកុក្កុច្ចៈ គឺមិនមានចិត្តរាយមាយ មានចិត្តស្ងប់រម្ងាប់ក្នុងសន្តាន ជម្រះចិត្តចាកឧទ្ធច្ចកុក្កុច្ចៈ ។ លះបង់នូវវិចិកិច្ឆា គឺមានវិចិកិច្ឆាឆ្លងផុតហើយ មិនបានសង្ស័យក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តចាកវិចិកិច្ឆា ។

[១១០] សេយ្យថាបិ ភិក្ខវេ បុរិសោ ឥណំ អាទាយ កម្មន្តេ បយោជេយ្យ តស្ស តេ កម្មន្តា សម្បជ្ជេយ្យុំ[១] ។ សោ យានិ ច ចោរាណានិ ឥណមូលានិ តានិ ច ព្យន្តីករេយ្យ សិយា ចស្ស ឧត្តរឹ អវសិដ្ឋំ ទារភរណាយ ។ តស្ស ឯវមស្ស អហំ ខោ បុព្វេ ឥណំ អាទាយ កម្មន្តេ បយោជេសឹ តស្ស មេ តេ កម្មន្តា សម្បជ្ជឹសុ សោហំ យានិ ច ចោរាណានិ ឥណមូលានិ តានិ ច ព្យន្តីអកាសឹ អត្ថិ ច បន មេ[២] ឧត្តរឹ អវសិដ្ឋំ ទារភរណាយាតិ ។ សោ តតោនិទានំ លភេថ បាមុជ្ជំ អធិគច្ឆេយ្យ សោមនស្សំ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ អាពាធិកោ អស្ស ទុក្ខិតោ ពាឡ្ហគិលានោ[៣] ភត្តញ្ចស្ស ន ឆាទេយ្យ ន ចស្ស កាយេ ពលមត្តា ។ សោ អបរេន សមយេន តម្ហា អាពាធា មុច្ចេយ្យ ភត្តញ្ចស្ស ឆាទេយ្យ សិយា ចស្ស កាយេ ពលមត្តា ។ តស្ស ឯវមស្ស អហំ ខោ បុព្វេ

១ ឱ. សមិជ្ឈេយ្យុំ ។ ២ ឱ. ម. ច មេ ។ ៣ ពាឡ្ហគិលានោតិបិ សំយោគិកោ ។

មហាយមកវគ្គ មហាអស្សបុរសូត្រ សេចក្តីប្រៀប ៥ យ៉ាង

[១១០] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសខ្ចីបំណុលគេយកមកប្រកបការងារ ការងារទាំងនោះរបស់បុរសនោះក៏សម្រេច ។ បុរសនោះ ដោះថ្លៃបំណុលចាស់រួចស្រេចហើយ ក៏សល់ទ្រព្យចំណេញទុកបម្រុងចិញ្ចឹមប្រពន្ធ (កូន) តទៅ ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលមុនអាត្មាអញខ្ចីបំណុលគេយកមកប្រកបការងារ ការងារទាំងនោះរបស់អាត្មាអញនោះក៏បានសម្រេចហើយ អាត្មាអញនោះដោះថ្លៃបំណុលចាស់រួចស្រេចហើយ អាត្មាអញ ក៏សល់ទ្រព្យបំណុលទុកបម្រុងចិញ្ចឹមប្រពន្ធ (កូន) តទៅ ។ បុរសនោះគប្បីបាននូវសេចក្តីរីករាយដល់នូវសេចក្តីសោមនស្ស ព្រោះរួចចាកបំណុលនោះជាហេតុ (យ៉ាងណាមិញ) ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសមានអាពាធ ដល់នូវទុក្ខឈឺខ្លាំងមិនឃ្លានបាយ មិនមានកម្លាំងក្នុងកាយ ។ ក្នុងសម័យខាងក្រោយតមក បុរសនោះក៏ស្បើយចាកអាពាធនោះឃ្លានបាយ មានកម្លាំងកាយឡើងវិញ ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលមុនអាត្មា

អាពាធិកោ អហោសិ ទុក្ខិតោ ពាឡ្ហគិលានោ ភត្តញ្ច មេ ន ឆាទេសិ ន ច មេ អាសិ កាយេ ពលមត្តា សោម្ហិ ឯតរហិ តម្ហា អាពាធា មុត្តោ ភត្តញ្ច មេ ឆាទេសិ[១] អត្ថិ ច មេ កាយេ ពលមត្តាតិ ។ សោ តតោនិទានំ លភេថ បាមុជ្ជំ អធិគច្ឆេយ្យ សោមនស្សំ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ ពន្ធនាគារេ ពទ្ធោ[២] អស្ស ។ សោ អបរេន សមយេន តម្ហា ពន្ធនា មុច្ចេយ្យ សោ-ត្ថិនា អភយេន[៣] ន ចស្ស កិញ្ចិ ភោគានំ វយោ ។ តស្ស ឯវមស្ស អហំ ខោ បុព្វេ ពន្ធនាគារេ ពទ្ធោ អហោសិំ សោម្ហិ ឯតរហិ តម្ហា ពន្ធនា មុត្តោ សោត្ថិនា អភយេន នត្ថិ ច មេ កិញ្ចិ ភោគានំ វយោតិ ។ សោ តតោនិទានំ លភេថ បាមុជ្ជំ អធិគច្ឆេយ្យ សោមនស្សំ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ ទាសោ អស្ស អនត្តាធីនោ បរាធីនោ ន យេនកាមង្គមោ ។ សោ អបរេន សមយេន តម្ហា ទាសព្យា មុច្ចេយ្យ អត្តាធីនោ អបរាធីនោ

១ ឱ. ម. ឆាទេតិ ។ ២ ឱ. ពទ្ធោ ។ ៣ ឱ. អព្យយេន ។

អញមានអាពាធ ដល់នូវសេចក្តីទុក្ខ ឈឺខ្លាំង មិនឃ្លានបាយ មិនមានកម្លាំងកាយសោះ ឥឡូវនេះអាត្មាអញនោះស្បើយចាកអាពាធនោះឃ្លានបាយមានកម្លាំងកាយឡើងវិញហើយ ។ បុរសនោះបាននូវសេចក្តីរីករាយ ដល់នូវសោមនស្ស ព្រោះស្បើយចាកអាពាធនោះជាហេតុ (យ៉ាងណាមិញ) ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសជាប់ក្នុងផ្ទះឃុំខាំង ។ ក្នុងសម័យខាងក្រោយតមក បុរសនោះ ក៏រួចអំពីផ្ទះឃុំខាំងដោយសួស្តី ឥតមានភ័យ ទាំងសេចក្តីវិនាស ដាច់ខាតភោគៈតិចតួច របស់បុរសនោះក៏មិនមានឡើយ ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលមុនអាត្មាអញជាប់ក្នុងផ្ទះឃុំខាំង ឥឡូវនេះ អាត្មាអញរួចពីផ្ទះឃុំខាំងដោយសួស្តី ឥតមានភ័យ ទាំងសេចក្តីវិនាស ដាច់ខាតភោគៈតិចតួចរបស់អាត្មាអញមិនមានឡើយ ។ បុរសនោះបាននូវសេចក្តីរីករាយ ដល់នូវសេចក្តីសោមនស្ស ព្រោះរួចអំពីផ្ទះឃុំខាំងនោះជាហេតុ (យ៉ាងណាមិញ) ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសខ្ញុំគេ មិនមានអំណាច គឺធ្វើអ្វីមិនបានតាមគាប់ចិត្តរបស់ខ្លួន អាស្រ័យនៅក្នុងអំណាចរបស់ជនដទៃ គឺប្រព្រឹត្តទៅតាមសេចក្តីពេញចិត្តរបស់ជនដទៃ ចង់ទៅទីណាមិនបានតាមទំនើងចិត្តឡើយ ។ ក្នុងសម័យខាងក្រោយមក បុរសនោះរួចចាកភាពជាខ្ញុំគេនោះ មានអំណាចដោយខ្លួនឯង មិនអាស្រ័យនៅ ក្នុងអំណាចរបស់ជនដទៃ

២១១



ភុជិស្សោ យេនកាមង្គមោ ។ តស្ស ឯវមស្ស អហំ ខោ បុព្វេ ទាសោ អហោសឹ អនត្តាធីនោ បរាធីនោ ន យេនកាមង្គមោ សោម្ហិ ឯតរហិ តម្ហា ទាសព្យា មុត្តោ អត្តាធីនោ អបរាធីនោ ភុជិស្សោ យេនកាមង្គមោតិ ។ សោ តតោនិទានំ លភេថ ចាមុជ្ជំ អធិគច្ឆេយ្យ សោមនស្សំ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ សធនោ សភោគោ កន្តារទ្ធានមគ្គំ បដិបជ្ជេយ្យ ។ សោ អបរេន សមយេន តម្ហា កន្តារា និត្ថរេយ្យ សោត្ថិនា អភយេន ន ចស្ស កិញ្ចិ ភោគានំ វយោ ។ តស្ស ឯវមស្ស អហំ ខោ បុព្វេ សធនោ សភោគោ កន្តារទ្ធានមគ្គំ បដិបជ្ជឹ សោម្ហិ ឯតរហិ តម្ហា កន្តារា និត្តិណ្ណោ សោត្ថិនា អភយេន

ទៅជាអ្នកជា ចង់ទៅទីណាតាមទំនើងចិត្តរបស់ខ្លួនបាន ។ បុរសនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុន អាត្មាអញជាខ្ញុំគេ មិនមាន អំណាចដោយខ្លួនឯង អាស្រ័យនៅក្នុងអំណាចរបស់ជនដទៃ ចង់ទៅ ទីណាមិនបានតាមទំនើងចិត្តរបស់ខ្លួនឡើយ ឥឡូវនេះ អាត្មាអញនោះ រួចចាកភាពជាខ្ញុំគេនោះហើយ មានអំណាចដោយខ្លួនឯង មិនអាស្រ័យ នៅក្នុងអំណាចរបស់ជនដទៃ បានជាអ្នកជា ចង់ទៅទីណាតាមទំនើងចិត្ត របស់ខ្លួនបាន ។ បុរសនោះ បាននូវសេចក្តីរីករាយ ដល់នូវសេចក្តី សោមនស្ស ព្រោះរួចចាកភាពជាខ្ញុំគេនោះជាហេតុ (យ៉ាងណាមិញ) ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសមានទ្រព្យ មានភោគសម្ប័ទ ដើរទៅ កាន់ផ្លូវឆ្ងាយដាច់ស្រយាល ។ សម័យខាងក្រោយតមក បុរសនោះឆ្លង ផុតអំពីផ្លូវឆ្ងាយដាច់ស្រយាលនោះដោយសួស្តី ឥតមានភ័យ ទាំងសេចក្តី វិនាស ដាច់ខាតភោគសម្ប័ទតិចតួច របស់បុរសនោះក៏មិនមានឡើយ ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុនអាត្មាអញមានទ្រព្យ មានភោគសម្ប័ទ ដើរទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាល ឥឡូវនេះ អាត្មា អញឆ្លងផុតអំពីផ្លូវឆ្ងាយដាច់ស្រយាលនោះ ដោយសួស្តី ឥតមានភ័យ

នត្ថិ ច មេ កិញ្ចិ ភោគានំ វយោតិ ។ សោ តតោនិទានំ លភេថ បាមុជ្ជំ អធិគច្ឆេយ្យ សោមនស្សំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ យថា ឥណំ យថា រោគំ យថា ពន្ធនាគារំ យថា ទាសព្យំ យថា កន្តារទ្ធានមគ្គំ ឥមេ បញ្ច នីវរណេ អប្បហីនេ អត្តនិ សមនុបស្សតិ ។ សេយ្យថាបិ ភិក្ខវេ យថា អានណញ្ញំ(១) យថា អារោគ្យំ យថា ពន្ធនា មោក្ខំ យថា ភុជិស្សំ យថា ខេមន្តភូមិ(២) ឯវមេវ ខោ ភិក្ខុ ឥមេ បញ្ច នីវរណេ បហីនេ អត្តនិ សមនុបស្សតិ ។

[១១១] សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលករណេ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ វិវេកជេន បីតិសុខេន អភិសន្នេតិ បរិសន្នេតិ(៣) បរិបូរេតិ បរិប្ផរតិ

១ ឱ. ម. អានណ្យំ ។ ២ ឱ. ម. ខេមន្តភូមឹ ។ ៣ ឱ. អភិសន្ទេតិ បរិសន្ទេតីតិ ទិស្សតិ ។

ហើយ ទាំងការដាច់ខាតភោគសម្ប័ទតិចតួច របស់អាត្មាអញក៏មិនមានឡើយ ។ បុរសនោះបាននូវសេចក្ដីរីករាយ ដល់នូវសេចក្ដីសោមនស្ស ព្រោះដល់នូវទីក្សេមក្សាន្តនោះជាហេតុ (យ៉ាងណាមិញ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវនីវរណៈទាំង ៥ ប្រការនោះ មាននៅក្នុងខ្លួន ដែលខ្លួនមិនទាន់លះបង់ហើយថា ទុកដូចជាបំណុល ដូចជារោគ ដូចជាផ្ទះឃុំខាំង ដូចភាពជាខ្ញុំគេ ដូចជាផ្លូវឆ្ងាយដាច់ស្រយាល យ៉ាងនោះ ៗ ដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញនូវនីវរណៈទាំង ៥ ប្រការនេះ មាននៅក្នុងខ្លួន ដែលលះបង់បានហើយថា ទុកដូចជាភាពនៃបុរសដែលរួចចាកបំណុល ដូចជាបុរសមិនមានរោគ ដូចជាបុរសរួចអំពីផ្ទះឃុំខាំង ដូចជាបុរសរួចជាអ្នកជា ដូចជាបុរសដល់នូវទីក្សេមក្សាន្ត យ៉ាងនោះ ៗ ដែរ ។

[១១១] ភិក្ខុនោះលះបង់នូវនីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេសរបស់ចិត្ត ជាធម្មជាតធ្វើបញ្ញាឲ្យមានកម្លាំងថយ ក៏ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន មានវិតក្កៈវិចារៈ និងបីតិសុខៈដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ជាអារម្មណ៍ ។ ភិក្ខុនោះញ៉ាំងករជកាយនេះឯង ឲ្យជោក ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់

នាស្ស កិញ្ចិ សព្វាវតោ កាយស្ស វិវេកជេន បីតិសុខេន អប្ផុដំ ហោតិ ។ សេយ្យថាបិ ភិក្ខវេ ទក្ខោ ន្ហាបកោ វា ន្ហាបកន្តេវាសី វា កំសថាលេ ន្ហានីយចុណ្ណានិ អាកិរិត្វា ឧទកេន បរិប្ផោសកំ បរិប្ផោសកំ សន្នេយ្យ សាយំ(១) ន្ហានីយបិណ្ឌិ សិនេហានុគតា សិនេហបរេតា(២) សន្តរពាហិរា ។ ផុដ្ឋា(៣) សិនេហេន ន ច បគ្ឃរណី ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ វិវេកជេន បីតិសុខេន អភិសន្នេតិ បរិសន្នេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស វិវេកជេន បីតិសុខេន អប្ផុដំ ហោតិ ។

[១១២] បុន ចបរំ ភិក្ខវេ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ សមាធិជេន បីតិសុខេន អភិសន្នេតិ បរិសន្នេតិ បរិបូរេតិ បរិប្ផរតិ

---

១ ឱ. សាស្ស ។ ២ ឱ. ម. ស្នេហានុគ្គតា ស្នេហបរេតា ។ ៣ ឱ. ម. ផុដា ។

ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថា មិនផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់នោះគ្មាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជានហាបកជន[១] ឬកូនសិស្សរបស់នហាបកជនដែលជាអ្នកឈ្លាស ពោយពាយនូវលំអិតសម្រាប់ងូតក្នុងផ្តិលសំរិទ្ធិ ហើយស្រោចស្រប់ច្របល់ដោយទឹក ឯដុំលំអិតសម្រាប់ងូតនោះក៏រលាយទៅដោយទឹក ជ្រួតជ្រាបទៅក្នុងទឹក ច្រឡូកច្រឡំទៅដោយទឹក ទាំងខាងក្នុងខាងក្រៅ មិនបានខ្ចាត់ខ្ចាយពីគ្នាឡើយ ដូចម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុញុំាងករជកាយនេះឯងឲ្យជោក ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់នោះគ្មាន ដូច្នោះឯង ។

[១១២] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុបានរម្ងាប់វិតក្កៈវិចារៈរួចហើយ ក៏បានដល់ទុតិយជ្ឈាន ជាទីជ្រះថ្លាក្នុងសន្តាន មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈវិចារៈទេ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិប៉ុណ្ណោះ ។ ភិក្ខុនោះញុំាងករជកាយនេះឯង ឲ្យជោក ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយបីតិនិងសុខៈដែលកើតអំពី

---
១ អ្នកចិញ្ចឹមជីវិតដោយការងូតទឹកឲ្យគេ ។

នាស្ស កិញ្ចិ សព្វាវតោ កាយស្ស សមាធិជេន បីតិសុខេន អប្ផុតំ ហោតិ ។ សេយ្យថាបិ ភិក្ខវេ ឧទករហទោ គម្ភីរោ[១] ឧព្ភិទោទកោ[២] តស្ស នេវស្ស បុរត្ថិមាយ ទិសាយ ឧទកស្ស អាយមុខំ ន បច្ឆិមាយ ទិសាយ ឧទកស្ស អាយមុខំ ន ឧត្តរាយ ទិសាយ ឧទកស្ស អាយមុខំ ន ទក្ខិណាយ ទិសាយ ឧទកស្ស អាយមុខំ ទេវោ បន[៣] កាលេន កាលំ សម្មាធារំ អនុបវេច្ឆេយ្យ អថខោ តម្ហា ច ឧទករហទា សីតា វារិធារា ឧព្ភិជ្ជិត្វា តមេវ ឧទករហទំ សីតេន វារិនា អភិសន្ទេយ្យ បរិសន្ទេយ្យ[៤] បរិបូរេយ្យ បរិប្ផរេយ្យ នាស្ស កិញ្ចិ សព្វាវតោ ឧទករហទស្ស សីតេន វារិនា អប្ផុតំ អស្ស ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ សមាធិជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស សមាធិជេន បីតិសុខេន អប្ផុតំ ហោតិ ។

១ ឱ. ម. គម្ភីរោតិ ន ទិស្សតិ ។ ២ ម. ឧព្ភិតោទកោ ។ ៣ ឱ. ច ន ។ ម. ច ។ ៤ ឱ. អភិសន្ទេយ្យ បរិសន្ទេយ្យាតិ ទិស្សតិ ។

សមាធិ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសមាធិនោះគ្មាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាអន្លង់ទឹកដ៏ជ្រៅ មានទឹកជោរឡើងមុខទឹកក្នុងទិសខាងកើតនោះ មិនមានឡើយ ទាំងមុខទឹកក្នុងទិសខាងលិចក៏មិនមាន មុខទឹកក្នុងទិសខាងជើងក៏មិនមាន មុខទឹកក្នុងទិសខាងត្បូងក៏មិនមាន កាលបើភ្លៀងបង្អោរធារទឹកស្រួលសព្វ ៗ កាលទៅ ក៏ស្រាប់តែទឹកត្រជាក់ជោរឡើងអំពីអន្លង់ទឹកនោះ ហើយញ៉ាំងអន្លង់ទឹកនោះឯងឲ្យជោកជាំ ឲ្យពេញពោរ ឲ្យពេញប្រៀប ឲ្យហូរហៀរដោយទឹកត្រជាក់ (នោះ) ប្រទេសបន្តិចបន្តួចនៃអន្លង់ទឹកទាំងអស់នោះ ដែលឈ្មោះថាមិនហូរហៀរដោយទឹកត្រជាក់នោះគ្មាន ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុញ៉ាំងករជកាយនេះឲ្យជោក ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយបីតិនិងសុខៈដែលកើតអំពីសមាធិ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសមាធិនោះគ្មាន ដូច្នោះដែរ ។

[១១៣] បុន ចបរំ ភិក្ខវេ ភិក្ខុ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខ-កោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ និប្បីតិកេន សុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស និប្បីតិកេន សុខេន អប្ផុតំ ហោតិ ។ សេយ្យថាបិ ភិក្ខវេ ឧប្បលិនិយំ វា បទុមិនិ-យំ វា បុណ្ឌរីកិនិយំ វា អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកានុគ្គតានិ អន្តោនិមុគ្គបោសិតានិ[១] យាវ ច អគ្គា[២] យាវ ច មូលា សីតេន វារិនា អភិសន្នានិ បរិសន្នានិ បរិបូរានិ បរិប្ផុតានិ[៣] នាស្ស កិញ្ចិ សព្វា-វតំ ឧប្បលានំ វា បទុមានំ វា បុណ្ឌរីកានំ វា សីតេន វារិនា អប្ផុតំ អស្ស ឯវមេវ ខោ ភិក្ខវេ

១ ឱ. ម. អន្តោនិមុគ្គបោសីនិ តានិ ។ ២ ឱ. ម. ចគ្គា ។ ៣ ឱ. ម. បរិប្ផុដានិ ។

[១១៣] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត ភិក្ខុព្រោះប្រាសចាកបីតិផង ប្រកបដោយឧបេក្ខាផង មានសតិនិងសម្បជញ្ញៈផង សោយនូវសេចក្តីសុខដោយនាមកាយផង បានដល់តតិយជ្ឈានដែលព្រះអរិយៈទាំងឡាយតែងប្រាប់នូវភិក្ខុអ្នកបានតតិយជ្ឈាននោះ ថាជាអ្នកមានឧបេក្ខា មានសតិ នៅជាសុខ ដូច្នេះ ។ ភិក្ខុនោះញុំាំងករជកាយនេះឯងឲ្យជោក ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយសេចក្តីសុខដែលប្រាសចាកបីតិ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយសុខដែលប្រាសចាកបីតិនោះគ្មាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងគុម្ពព្រលិតក្តី ក្នុងគុម្ពឈូកក្រហមក្តី ក្នុងគុម្ពឈូកសក្តី តែងដុះក្នុងទឹក ចម្រើនក្នុងទឹក លូតលាស់តាមទឹក លិចនៅក្នុងទឹក ជោកជាំ ឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយទឹកត្រជាក់ រហូតដល់ចុង រហូតដល់គល់ ប្រទេសបន្តិចបន្តួចនៃជលជាតិទាំងអស់ គឺព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយទឹកត្រជាក់នោះគ្មាន ដូចម្តេចមិញ ម្នាលភិក្ខុទាំង-

ភិក្ខុ ឥមមេវ កាយំ និប្បីតិកេន សុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្ពាវតោ កាយស្ស និប្បីតិកេន សុខេន អប្ផុតំ ហោតិ ។

[១១៤] បុន ចបរំ ភិក្ខវេ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ បរិសុទ្ធេន ចេតសា បរិយោទាតេន ផរិត្វា និសិន្នោ ហោតិ នាស្ស កិញ្ចិ សព្ពាវតោ កាយស្ស បរិសុទ្ធេន ចេតសា បរិយោទាតេន អប្ផុតំ ហោតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ ឱទាតេន វត្ថេន សសីសំ[១] បារុបិត្វា និសិន្នោ អស្ស នាស្ស កិញ្ចិ សព្ពាវតោ កាយស្ស ឱទាតេន វត្ថេន អប្ផុតំ អស្ស ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ បរិសុទ្ធេន ចេតសា បរិយោទាតេន ផរិត្វា និសិន្នោ ហោតិ នាស្ស កិញ្ចិ សព្ពាវតោ កាយស្ស បរិសុទ្ធេន ចេតសា បរិយោទាតេន អប្ផុតំ ហោតិ ។

---

១ សីសន្តិប្បត្តិ ។

ឡាយ ភិក្ខុញ៉ាំងករជកាយនេះឯង ឲ្យជោក ឲ្យឆ្អែតស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយសុខដែលមិនមានបីតិ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយសុខដែលមិនមានបីតិនោះគ្មាន ដូច្នោះឯង ។

[១១៨] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត ភិក្ខុព្រោះលះបង់នូវសេចក្តីសុខផង លះបង់នូវសេចក្តីទុក្ខផង រំលត់នូវសោមនស្សនិងទោមនស្សទាំងឡាយក្នុងកាលមុនផង ហើយក៏ដល់នូវចតុត្ថជ្ឈានមិនទុក្ខមិនសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ។ ភិក្ខុនោះរមែងញ៉ាំងករជកាយនេះឯងឲ្យផ្សព្វផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់ អង្គុយនៅ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់នោះគ្មាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសយកសំពត់សដណ្តប់កាយព្រមទាំងក្បាលអង្គុយនៅ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់បុរសនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយសំពត់សនោះគ្មាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុញ៉ាំងករជកាយនេះឯងឲ្យផ្សព្វផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់អង្គុយនៅ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់នោះគ្មាន យ៉ាងនោះដែរ ។

មហាយមកវគ្គស្ស មហាអស្សបុរសុត្តេ តីសុ បឋមាវិជ្ជា

[១១៩] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ ប-
រិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្ម-
និយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញ្ញាណា-
យ ចិត្តំ អភិនិន្នាមេតិ ។ សោ អនេកវិហិតំ បុព្វេនិ-
វាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិ-
យោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ
បុព្វេនិវាសំ អនុស្សរតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ
សកម្ហា គាមា អញ្ញំ គាមំ គច្ឆេយ្យ តម្ហាបិ គាមា
អញ្ញំ គាមំ គច្ឆេយ្យ តម្ហាបិ គាមា សកំយេវ គាមំ
បច្ចាគច្ឆេយ្យ តស្ស ឯវមស្ស អហំ ខោ សកម្ហា
គាមា អមុំ គាមំ អគញ្ឆឹ តត្រ ឯវំ អដ្ឋាសឹ ឯវំ និសីទឹ
ឯវំ អភាសឹ ឯវំ តុណ្ហី អហោសឹ តម្ហាបិ គាមា អមុំ គាមំ
អគញ្ឆឹ តត្រាបិ ឯវំ និសីទឹ ឯវំ អភាសឹ ឯវំ តុណ្ហី អហោ-
សឹ សោម្ហិ តម្ហា គាមា សកំយេវ គាមំ បច្ចាគតោតិ

[១១៥] កាលបើចិត្តខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ ភិក្ខុនោះក៏រលឹកឃើញនូវខន្ធដែលធ្លាប់អាស្រ័យនៅមកពីមុនជាច្រើន ដូចម្តេច គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកនូវខន្ធដែលសត្វធ្លាប់អាស្រ័យនៅអំពីមុនជាច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំង-ឡាយ ដូចជាបុរសចេញអំពីស្រុករបស់ខ្លួនទៅកាន់ស្រុកដទៃ ចេញអំពីស្រុកនោះទៅកាន់ស្រុកដទៃទៀត ត្រឡប់ពីស្រុកនោះមកកាន់ស្រុករបស់ខ្លួនវិញ បុរសនោះក៏រលឹកឃើញយ៉ាងនេះថា អាត្មាអញចេញពីស្រុករបស់ខ្លួនបានទៅកាន់ស្រុកឯណោះ ដែលទៅដល់ស្រុកនោះ អាត្មាអញបានឈរយ៉ាងនេះ អង្គុយយ៉ាងនេះ និយាយយ៉ាងនេះ នៅស្ងៀមយ៉ាងនេះ លុះអាត្មាអញចេញពីស្រុកនោះ បានទៅកាន់ស្រុកឯណោះទៀត ដែលទៅដល់ស្រុកនោះ អាត្មាអញបានឈរយ៉ាងនេះ អង្គុយយ៉ាងនេះ និយាយយ៉ាងនេះ នៅស្ងៀមយ៉ាងនេះ ឥឡូវនេះ អាត្មាអញនោះចេញពីស្រុកនោះ ត្រឡប់មកកាន់ស្រុករបស់ខ្លួនវិញហើយ ដូចម្តេចមិញ

ឯវមេវ ខោ ភិក្ខវេ ភិក្ខុ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។

[១១៦] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ។ សេយ្យថាបិ[១] ភិក្ខវេ ទ្វេ អគារា សទ្វារា[២] តត្ថ ចក្ខុមា បុរិសោ មជ្ឈេ ឋិតោ បស្សេយ្យ មនុស្សេ គេហំ បវិសន្តេបិ និក្ខមន្តេបិ អនុចង្កមន្តេបិ[៣] អនុសញ្ចរន្តេបិ[៤] អនុវិចរន្តេបិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ

១ ឱ. សេយ្យថា បស្សុ ។ ២ ម. សន្នទ្វារា ។ ៣ ឱ. អនុចង្កមន្តេបីតិ ន ទិស្សតិ ។ ៤ ម. អនុសញ្ចរន្តេបីតិ នត្ថិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុរលឹកបាននូវខន្ធដែលធ្លាប់អាស្រ័យនៅមកពីមុនជាច្រើនដូចម្តេច គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកនូវខន្ធដែលធ្លាប់អាស្រ័យនៅអំពីមុនជាច្រើន ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ យ៉ាងនោះឯង ។

[១១៦] កាលបើចិត្តខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនោកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រដោយអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅដើម្បីសត្តចុតូបបាតញ្ញាណ ។ ភិក្ខុនោះមានចក្ខុជាទិព្វដ៏បរិសុទ្ធកន្លងចក្ខុរបស់មនុស្សជាធម្មតា រមែងឃើញនូវសត្វទាំងឡាយកំពុងច្យុតកំពុងកើតឡើង ជាសត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។ បេ ។ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាផ្ទះពីរខ្នង មានទ្វារទល់មុខគ្នា បុរសដែលមានចក្ខុឈរនៅត្រង់កណ្តាលផ្ទះនោះ រមែងឃើញនូវពួកមនុស្សកំពុងចូលទៅកាន់ផ្ទះខ្លះ ចេញពីផ្ទះខ្លះ ដើរទៅមកខ្លះ ដើរហែ ៗ គ្នាខ្លះ ដើរប្រទាក់គ្នាខ្លះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធកន្លងនូវចក្ខុជារបស់មនុស្សធម្មតា រមែងឃើញនូវសត្វទាំងឡាយកំពុងច្យុត កំពុងកើតឡើង

ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ។

[១១៧] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ

ជាសត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។ បេ ។ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្ម របស់ខ្លួន យ៉ាងនោះដែរ ។

[១១៧] កាលបើចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រដោយអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ គឺប្រាជ្ញាដឹងនូវធម៌ជាគ្រឿងក្សយ នៃអាសវៈទាំងឡាយ ។ ភិក្ខុនោះដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាឧបាយដើម្បីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាផ្លូវសម្រាប់ដើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាអាសវៈ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះជាឧបាយដើម្បីរលត់អាសវៈ ដឹងច្បាស់តាមពិតថា នេះជាផ្លូវសម្រាប់ដើរទៅកាន់ឧបាយដើម្បីរលត់អាសវៈ ។ កាលភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតស្រឡះចាកភវាសវៈផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈផង កាលបើចិត្តផុតស្រឡះហើយ

២២០



វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ សេយ្យថាបិ ភិក្ខវេ បព្វតសង្ខេបេ ឧទករហទោ អច្ឆោ វិប្បសន្នោ អនាវិលោ តត្ថ ចក្ខុមា បុរិសោ តីរេ ឋិតោ បស្សេយ្យ សិប្បិក-សម្ពុកម្បិ[១] សក្ខរកឋលម្បិ មច្ឆគុម្ពម្បិ តិដ្ឋន្តំបិ ចរន្តំបិ[២] ។ តស្ស ឯវមស្ស អយំ ខោ ឧទក-រហទោ អច្ឆោ វិប្បសន្នោ អនាវិលោ តត្រិមេ សិប្បិកសម្ពុកាបិ សក្ខរកឋលាបិ មច្ឆគុម្ពាបិ តិដ្ឋន្តិបិ ចរន្តិបីតិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។

---

១ ឱ. សិប្បិសម្ពុកម្បិ ។ ២ ម. សក្ខរកឋលំបិ មច្ឆគុម្ពំបិ ចរន្តំបិ តិដ្ឋន្តំបិ ។ ឱ. សក្ខរកឋលម្បិ មច្ឆគុម្ពម្បិ ចរន្តម្បិ តិដ្ឋន្តម្បិ ។

ញាណក៏កើតឡើងថា ចិត្តរបស់អាត្មាអញផុតស្រឡះហើយ ដឹងច្បាស់ថា កំណើតអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តហើយ សោឡសកិច្ចអាត្មាអញក៏បានធ្វើស្រេចហើយ កិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាអន្លង់ទឹកលើកំពូលភ្នំ ដែលថ្លាស្អាត ឥតមានកករល្អក់ បុរសម្នាក់មានចក្ខុឈរទៀបឆ្នេរ គប្បីមើលឃើញនូវខ្យងនិងគ្រំខ្លះ ដុំក្រួសនិងដុំថ្មខ្លះ នូវហ្វូងត្រីដែលកំពុងសំកាំងខ្លះ ហែលទៅមកខ្លះ ក្នុងអន្លង់ទឹកនោះ ។ បុរសនោះក៏មានចិត្តត្រិះរិះយ៉ាងនេះថា អន្លង់ទឹកនេះឯងថ្លាស្អាត ឥតមានកករល្អក់ ខ្យងនិងគ្រំទាំងនេះក្តី ដុំក្រួសនិងដុំថ្មទាំងនេះក្តី ហ្វូងត្រីទាំងនេះកំពុងសំកាំងខ្លះ ហែលទៅមកខ្លះក្តី ក្នុងអន្លង់ទឹកនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់ថា កិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៅទៀតមិនមាន ក៏យ៉ាងនោះដែរ ។

[១១៨] អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សមណោ ឥតិបិ[១] ព្រាហ្មណោ ឥតិបិ ន្ហាតកោ ឥតិបិ វេទគូ ឥតិបិ សោត្តិយោ ឥតិបិ អរិយោ ឥតិបិ អរហា ឥតិបិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សមណោ ហោតិ ។ សមិតាស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ឯវំ ខោ ភិក្ខវេ ភិក្ខុ សមណោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ព្រាហ្មណោ ហោតិ ។ ពាហិតាស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ឯវំ ខោ ភិក្ខវេ ភិក្ខុ ព្រាហ្មណោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ន្ហាតកោ ហោតិ ។ ន្ហាតាស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា

១ ម. សមណោតិបិ ។ ឯវំ បរបទេសុបិ ។

មហាយមកវគ្គ មហាអស្សបុរសូត្រ ព្រះខីណាស្រពមានឈ្មោះ ៧

[១១៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ថានហាតកៈក៏បាន ថាវេទគូក៏បាន ថាសោ-ត្តិយៈក៏បាន ថាអរិយៈក៏បាន ថាអរហន្តក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា សមណៈ តើដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត ជាធម៌ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ភិក្ខុនោះបានរម្ងាប់ហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថា សមណៈ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា ព្រាហ្មណ៍ តើដោយប្រការដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមកប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ភិក្ខុនោះបានបន្សាត់ចោលហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថា ព្រាហ្មណ៍ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា នហាតកៈ តើដោយប្រការដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត ជាធម៌ប្រព្រឹត្តទៅមួយអន្លើដោយសេចក្តីក្រវល់ក្រវាយ មាន

ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ឯវំ ខោ ភិក្ខវេ ភិក្ខុ ឧហាតកោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ វេទគូ ហោតិ ។ វិទិតាស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា ពោនោ-ព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរា-មរណីយា ឯវំ ខោ ភិក្ខវេ ភិក្ខុ វេទគូ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ សោត្ថិយោ ហោតិ ។ និស្សុតាស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា ពោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ឯវំ ខោ ភិក្ខវេ ភិក្ខុ សោត្ថិយោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អរិយោ ហោតិ ។ អារកាស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា ពោនោព្ភវិកា

ទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ភិក្ខុនោះបានជម្រះចេញហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថា នហាតកៈ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា វេទគូ តើដោយប្រការដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត ជាធម៌ប្រព្រឹត្តទៅមួយអន្លើ ដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ភិក្ខុនោះបានដឹងច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា វេទគូ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា សោត្តិយៈ តើដោយប្រការដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត ជាធម៌ប្រព្រឹត្តទៅមួយអន្លើដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រ-កបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ភិក្ខុនោះមិនបានទទឹកហើយ (ដោយចិត្ត) ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថា សោត្តិយៈ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា អរិយៈ តើដោយប្រការដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត

២២៣



សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា ឯវំ ខោ ភិក្ខវេ ភិក្ខុ អរិយោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អរហា ហោតិ ។ អារកាស្ស ហោន្តិ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជ-រាមរណីយា ឯវំ ខោ ភិក្ខវេ ភិក្ខុ អរហា ហោ-តីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

មហាអស្សបុរសុត្តំ នវមំ និដ្ឋិតំ ។

ជាធម៌ប្រព្រឹត្តទៅមួយអន្ទើ ដោយសេចក្ដីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ជាកិលេសឆ្ងាយអំពីភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថា អរិយៈ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា អរហន្ត តើដោយប្រការដូចម្ដេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្ដីសៅហ្មង ធ្វើសត្វឲ្យកើត ក្នុងភពថ្មីទៀត ជាធម៌ប្រព្រឹត្តទៅមួយអន្ទើដោយសេចក្ដីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ជាកិលេសឆ្ងាយអំពីភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា អរហន្ត ដោយប្រការដូច្នេះឯង ។ លុះព្រះមានព្រះភាគ បានត្រាស់ភាសិតនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានសេចក្ដីពេញចិត្ត ត្រេកអរហើយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ មហាអស្សបុរសូត្រ ទី ៩ ។

# ទសមំ ចូឡអស្សបុរសុត្តំ

[១១៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា អង្គេសុ វិហរតិ អស្សបុរំ នាម អង្គានំ និគមោ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សមណា សមណាតិ វោ ភិក្ខវេ ជនោ សញ្ជានាតិ តុម្ហេ ច បន កេ តុម្ហេតិ បុដ្ឋា សមានា សមណាម្ហាតិ បដិជានាថ តេសំ វោ ភិក្ខវេ ឯវំសមញ្ញានំ សតំ ឯវំបដិញ្ញានំ សតំ[១] យា សមណសាមីចិប្បដិបទា តំ បដិបជ្ជិស្សាម ឯវន្នោ អយំ អម្ហាកំ សមញ្ញា ច សច្ចា ភវិស្សតិ បដិញ្ញា ច ភូតា យេសញ្ច មយំ បត្តចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារ បរិភុញ្ជាម តេសំ តេ ការា

១ កត្ថចិ បោត្ថកេ ឯវំ សមញ្ញាតានំ សតំ ឯវំបដិញ្ញាតានំ សតន្តិ ទិស្សន្តិ ។

# ចូឡអស្សបុរសូត្រ ទី ១០

[១១៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងនិគមឈ្មោះអស្សបុរៈ របស់អ្នកស្រុកអង្គៈទាំងឡាយ ក្នុងដែនអង្គៈ ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះក៏ទទួលស្តាប់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកផងតែងស្គាល់ច្បាស់នូវអ្នកទាំងឡាយថាជា សមណៈ ៗ ដូច្នេះ ចំណែកអ្នកទាំងឡាយ បើមានគេសួរថា លោកជាអ្វី តែងប្តេជ្ញាខ្លួនថា ពួកយើងជាសមណៈ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយនោះមានឈ្មោះយ៉ាងនេះហើយ ប្តេជ្ញាខ្លួនយ៉ាងនេះហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយគប្បីសិក្សាយ៉ាងនេះថា បដិបទាសមគួរដល់សមណៈណា យើងទាំងឡាយនឹងប្រតិបត្តិនូវបដិបទានោះ នេះជាឈ្មោះពិតផង ជាសេចក្តីប្តេជ្ញាពិតផង របស់យើងទាំងឡាយ យ៉ាងនេះ មួយទៀត យើងទាំង-ឡាយបរិភោគនូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ របស់ជនទាំងឡាយណា សក្ការៈទាំងឡាយនោះ ដែលជនទាំងនោះបាន

អម្ហេសុ មហាបួលា ភវិស្សន្តិ មហានិសំសា អម្ហាកញ្ចេវាយំ បព្វជ្ជា អវញ្ឈា ភវិស្សតិ សផលា សឧទ្រយាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។

[១៦០] កថញ្ច ភិក្ខវេ ភិក្ខុ សាមីចិប្បដិបទំ[១] បដិបន្នោ ហោតិ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុនោ អភិជ្ឈាលុស្ស អភិជ្ឈា អប្បហីនា ហោតិ ព្យាបន្នចិត្តស្ស ព្យាបាទោ អប្បហីនោ ហោតិ កោធនស្ស កោធោ អប្បហីនោ ហោតិ ឧបនាហិស្ស ឧបនាហោ អប្បហីនោ ហោតិ មក្ខិស្ស មក្ខោ អប្បហីនោ ហោតិ បឡាសិស្ស បឡាសោ អប្បហីនោ ហោតិ ឥស្សុកិស្ស ឥស្សា អប្បហីនា ហោតិ មច្ឆរិស្ស មច្ឆរិយំ អប្បហីនំ ហោតិ សឋស្ស សាឋេយ្យំ អប្បហីនំ ហោតិ មាយាវិស្ស មាយា អប្បហីនា ហោតិ បាបិច្ឆស្ស បាបិកា ឥច្ឆា អប្បហីនា ហោតិ មិច្ឆាទិដ្ឋិស្ស[២] មិច្ឆាទិដ្ឋិ អប្បហីនា ហោតិ ។ ឥមេសំ ខោ អហំ ភិក្ខវេ សមណមលានំ សមណទោសានំ សមណកសាវានំ[៣]

---

១ ឱ. ម. ន សមណសាមីចិប្បដិបទំ ។ ២ ម. មិច្ឆាទិដ្ឋិកស្ស ។ ៣ ឱ. ម. សមណកសដ្ឋានំ ។

(បូជា) ចំពោះយើងទាំងឡាយ នឹងជាសក្ការៈមានផលច្រើន មានអានិសង្សច្រើន ទាំងបព្វជ្ជារបស់ពួកយើងនេះសោត ក៏នឹងមិនទទេ គង់នឹងមានផល មានសេចក្តីចម្រើន ។

[១២០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិនូវបដិបទាដ៏សមគួរ (ដល់សមណៈ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយ មានអភិជ្ឈាច្រើន ជាអ្នកមិនលះបង់អភិជ្ឈាចេញ មានចិត្តព្យាបាទ ជាអ្នកមិនលះបង់ព្យាបាទចេញ មានសេចក្តីក្រោធ ជាអ្នកមិនលះបង់សេចក្តីក្រោធចេញ មានសេចក្តីគំនុំ ជាអ្នកមិនលះបង់សេចក្តីគំនុំចេញ មានសេចក្តីលុបគុណគេ ជាអ្នកមិនលះបង់សេចក្តីលុបគុណគេចេញ មានសេចក្តីលើកខ្លួន ជាអ្នកមិនលះបង់សេចក្តីលើកខ្លួនចេញ មានសេចក្តីច្រណែន ជាអ្នកមិនលះបង់សេចក្តីច្រណែនចេញ មានសេចក្តីកំណាញ់ ជាអ្នកមិនលះបង់សេចក្តីកំណាញ់ចេញ មានសេចក្តីអួតអាង ជាអ្នកមិនលះបង់អំនួតចេញ មានសេចក្តីលាក់ពុត ជាអ្នកមិនលះបង់សេចក្តីលាក់ពុតចេញ មានសេចក្តីប្រាថ្នាលាមក ជាអ្នកមិនលះបង់សេចក្តីប្រាថ្នាលាមកចេញ មានសេចក្តីយល់ខុស ជាអ្នកមិនលះបង់សេចក្តីយល់ខុសចេញ ។ ម្នាលភិក្ខុទាំងឡាយ ការមិនលះបង់ នូវមន្ទិលរបស់សមណៈ នូវទោសរបស់សមណៈ និងធម៌ជាអម្ចត់របស់សមណៈ ដែលជា

អាចាយិកានំ ហានានំ ទុក្ខតិវេទនីយានំ អប្បហានា សមណសាមីចិប្បដិបទំ បដិបន្នោតិ ន វទាមិ[១] ។ សេយ្យថាបិ ភិក្ខវេ មតជន្នាម[២] អាវុធជាតំ ឧភតោធារំ បីតនិស្សិតំ តទស្ស សង្ឃាដិយា សម្បារុតំ សម្បលិវេឋិតំ តថូបមាហំ ភិក្ខវេ ឥមស្ស ភិក្ខុនោ បព្វជ្ជំ វទាមិ ។

[១២១] នាហំ ភិក្ខវេ សង្ឃាដិកស្ស សង្ឃាដិធារណមត្តេន សាមញ្ញំ វទាមិ ។ នាហំ ភិក្ខវេ អចេលកស្ស អចេលកមត្តេន សាមញ្ញំ វទាមិ ។ នាហំ ភិក្ខវេ រជោជល្លិកស្ស

---

១ ឱ. ម. ន សមណសាមីចិប្បដិបទំ បដិបន្នោតិ វទាមិ ។ ២ ឱ. មដជន្នាម ។

ហេតុញុំាងសមណៈ ឲ្យកើតក្នុងអបាយ និងជាបច្ច័យឲ្យរងនូវវិបាក ជាទុក្ខ ក្នុងទុគ្គតិភូមិទាំងនេះ បោលចេញហើយ តថាគតមិនទាន់ហៅ ថា អ្នកប្រតិបត្តិនូវបដិបទា ដ៏សមគួរដល់សមណៈទេ ។ ម្នាលភិក្ខុទាំង-ឡាយ ដូចជាអាវុធឈ្មោះមតជៈ[១] មានមុខទាំងសងខាង ដែលបុគ្គល ធ្វើឲ្យជោកនឹងទឹកហើយសំលៀង (លើថ្ម) (រូបស៊ក) អាវុធនោះទុកក្នុង ស្រោម ហើយស្រែះព័ទ្ធព័ន្ធជុំវិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោល នូវបព្វជ្ជារបស់ភិក្ខុនេះថា មានឧបមេយ្យដូចអាវុធឈ្មោះមតជៈនោះដែរ ។

[១២១] ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវភាពនៃបុគ្គល មានសង្ឃាដី ថាជាសមណៈដោយគ្រាន់តែទ្រទ្រង់សង្ឃាដីប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នកឥតសំពត់ ថា ជាសមណៈដោយគ្រាន់តែឥតសំពត់ប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នកសៅហ្មង ដោយធូលីនិងភក្អែល ថា

---

១ អាវុធកើតអំពីធ្វើសត្វឲ្យស្លាប់ ។ សេចក្តីថា ពួកមនុស្សកោសដែកហើយយកកម្ទេចដែកនោះទៅលាយនឹងសាច់ឲ្យសត្វគ្រៀល ។ នោះបន្ទោបង់ឧច្ចារៈមិនរួចក៏ស្លាប់ទៅ បើមិនស្លាប់ទេ គេក៏វាយឲ្យស្លាប់ រួចវៈពោះយកកំទេចដែកនោះមកលាងទឹកលាយនឹងសាច់ឲ្យគ្រៀលស៊ីទៀត ធ្វើយ៉ាងនេះអស់ ៧ ដង ។ ក្នុងទីបំផុត គេយកកម្ទេចដែកនោះមកឲ្យជាងធ្វើជាអាវុធ ។ នោះមុតពេកណាស់ គេហៅថា អាវុធឈ្មោះមតជៈ ។ អដ្ឋកថា ។

វេជោជល្លិកាមត្តេន សាមញ្ញំ វទាមិ ។ ជាហំ ភិក្ខវេ ឧទកោរោហកស្ស ឧទកោរោហមត្តេន សាមញ្ញំ វទាមិ ។ ជាហំ ភិក្ខវេ រុក្ខមូលិកស្ស រុក្ខមូលិកាមត្តេន សាមញ្ញំ វទាមិ ។ ជាហំ ភិក្ខវេ អព្ភោកាសិកស្ស អព្ភោកាសិកាមត្តេន សាមញ្ញំ វទាមិ ។ ជាហំ ភិក្ខវេ ឧព្ភដ្ឋកស្ស[១] ឧព្ភដ្ឋកាមត្តេន សាមញ្ញំ វទាមិ ។ ជាហំ ភិក្ខវេ បរិយាយភត្តិកស្ស បរិយាយភត្តិកាមត្តេន សាមញ្ញំ វទាមិ ។ ជាហំ ភិក្ខវេ មន្តជ្ឈាយិកស្ស មន្តជ្ឈាយិកាមត្តេន សាមញ្ញំ វទាមិ ។ ជាហំ ភិក្ខវេ ជដិលកស្ស ជដាធារ-ណាមត្តេន សាមញ្ញំ វទាមិ ។ សង្ឃាដិកស្ស ចេ ភិក្ខវេ

---

១ ឧព្ភត្ថកស្សាតិប្បត្តិ ។

ជាសមណៈ ដោយគ្រាន់តែសៅហ្មង់ដោយធូលីនិង់ក្អែលប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំង់ឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នកចុះត្រាំទឹក ថាជាសមណៈដោយគ្រាន់តែចុះត្រាំទឹកប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំង់ឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នកអាស្រ័យនៅក្បែរគល់ឈើ ថាជាសមណៈដោយគ្រាន់តែអាស្រ័យនៅក្បែរគល់ឈើប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំង់ឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នកអាស្រ័យនៅក្នុង់ទីវាល ថាជាសមណៈ ដោយគ្រាន់តែអាស្រ័យនៅក្នុង់ទីវាលប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំង់ឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នកប្រកាន់ការអប់កាយ (ដោយគិតថានឹង់រម្ងាប់នូវកិលេស) ថាជាសមណៈដោយគ្រាន់តែប្រកាន់ការអប់កាយ (ដោយគិតថានឹង់រម្ងាប់កិលេស) ប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំង់ឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលដែលបរិភោគភត្ត ១ ដង់ ១ កាល[១] ថាជាសមណៈដោយគ្រាន់តែបរិភោគភត្ត ១ ដង់ ១ កាលប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំង់ឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នករៀនមន្ត ថាជាសមណៈដោយគ្រាន់តែរៀនមន្តប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំង់ឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលដែលទុកផ្នួង់សក់ថាជាសមណៈដោយគ្រាន់តែទុកផ្នួង់សក់ប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំង់ឡាយ បើ

---

១ ដែលថាបរិភោគភត្ត ១ ដង ១ កាលនោះ គឺក្នុង ១ ខែ ឬកន្លះខែ ទើបបរិភោគភត្តម្តង ។ នេះជាលទ្ធិរបស់ពួកសមណៈខាងក្រៅ ។ អដ្ឋកថា ។

សង្ឃាដិធារណមត្តេន អភិជ្ឈាលុស្ស បុគ្គលស្ស អភិជ្ឈា បហីយេថ ព្យាបន្នចិត្តស្ស ព្យាបាទោ បហីយេថ កោធនស្ស កោធោ បហីយេថ ឧប-នាហិស្ស ឧបនាហោ បហីយេថ មក្ខិស្ស មក្ខោ បហីយេថ បឡាសិស្ស បឡាសោ បហីយេថ ឥស្សុកិស្ស ឥស្សា បហីយេថ មច្ឆរិស្ស មច្ឆរិយំ បហីយេថ សឋស្ស សាឋេយ្យំ បហីយេថ មាយា-វិស្ស មាយា បហីយេថ បាបិច្ឆស្ស បាបិកា ឥច្ឆា បហីយេថ មិច្ឆាទិដ្ឋិស្ស មិច្ឆាទិដ្ឋិ បហីយេថ តមេនំ មិត្តាមច្ចា ញាតិសាលោហិតា ជាតមេវ នំ សង្ឃា-ដិកំ ករេយ្យុំ សង្ឃាដិកត្តមេវ[១] សមាទបេយ្យុំ ឯហិ ត្វំ ភទ្រមុខ សង្ឃាដិកោ ហោហិ សង្ឃាដិកស្ស តេ សតោ សង្ឃាដិធារណមត្តេន អភិជ្ឈាលុស្ស អភិជ្ឈា បហីយិស្សតិ ព្យាបន្នចិត្តស្ស ព្យាបាទោ បហីយិស្សតិ

១ ម. សង្ឃាដិកត្តេ ចេវ ។

បុគ្គលមានសង្ឃាដី មានអភិជ្ឈាច្រើន ដោយអាងថាទ្រទ្រង់សង្ឃាដី ត្រូវលះបង់អភិជ្ឈាចេញ បើមានចិត្តប្រកបដោយព្យាបាទ ត្រូវលះបង់ព្យាបាទចេញ មានសេចក្តីក្រោធ ត្រូវលះបង់សេចក្តីក្រោធចេញ មានការចងគំនុំ ត្រូវលះបង់ការចងគំនុំចេញ មានសេចក្តីលុបគុណគេ ត្រូវលះបង់សេចក្តីលុបគុណគេចេញ មានសេចក្តីលើកខ្លួន ត្រូវលះបង់សេចក្តីលើកខ្លួនចេញ មានសេចក្តីច្រណែន ត្រូវលះបង់សេចក្តីច្រណែនចេញ មានសេចក្តីកំណាញ់ ត្រូវលះបង់សេចក្តីកំណាញ់ចេញ មានសេចក្តីអួតអាង ត្រូវលះបង់អំនួតចេញ មានសេចក្តីលាក់ពុត ត្រូវលះបង់សេចក្តីលាក់ពុតចេញ មានសេចក្តីប្រាថ្នាលាមក ត្រូវលះបង់សេចក្តីប្រាថ្នាលាមកចេញ មានគំនិតយល់ខុស ត្រូវលះបង់គំនិតយល់ខុសចេញ មិត្តអាមាត្យញាតិសាលោហិត គប្បីធ្វើបុគ្គលអ្នកអាងមានសង្ឃាដីនោះឲ្យជាអ្នកទ្រទ្រង់សង្ឃាដី ក្នុងថ្ងៃនោះឯង ពន្យល់នូវភាពនៃបុគ្គលអ្នកទ្រ-ទ្រង់សង្ឃាដីថា នៃលោកមានមុខស្រស់បស់ លោកចូរមកនេះ លោកចូរជាអ្នកទ្រទ្រង់សង្ឃាដីចុះ កាលបើលោកមានសង្ឃាដីហើយ តែនៅមានអភិជ្ឈាច្រើន ដោយអាងទ្រទ្រង់សង្ឃាដី លោកគួរលះបង់អភិជ្ឈាចេញ មានចិត្តប្រកបដោយព្យាបាទ គួរលះបង់ព្យាបាទចេញ

២២៩

កោធនស្ស កោធោ បហីយិស្សតិ ឧបនាហិស្ស ឧបនាហោ បហីយិស្សតិ មក្ខិស្ស មក្ខោ បហីយិស្សតិ បឡាសិស្ស បឡាសោ បហីយិស្សតិ ឥស្សុកិស្ស ឥស្សា បហីយិស្សតិ មច្ឆរិស្ស មច្ឆរិយំ បហីយិស្សតិ សឋស្ស សាឋេយ្យំ បហីយិស្សតិ មាយាវិស្ស មាយា បហីយិស្សតិ បាបិច្ឆស្ស បាបិកា ឥច្ឆា បហីយិស្សតិ មិច្ឆាទិដ្ឋិស្ស មិច្ឆាទិដ្ឋិ បហីយិស្សតីតិ ។ យស្មា ច ខោ អហំ ភិក្ខវេ សង្ឃាដិកម្បិ ឯកច្ចំ បស្សាមិ អភិជ្ឈាលុំ ព្យាបន្នចិត្តំ កោធនំ ឧបនាហឹ មក្ខឹ បឡាសឹ ឥស្សុកឹ មច្ឆរឹ សឋំ មាយាវឹ បាបិច្ឆំ មិច្ឆាទិដ្ឋឹ[១] តស្មា ន សង្ឃាដិកស្ស សង្ឃាដិធារណមត្តេន សាមញ្ញំ វទាមិ ។

១ ម. មិច្ឆាទិដ្ឋិកំ ។

មានសេចក្តីក្រោធ គួរលះបង់សេចក្តីក្រោធចេញ មានការចងគំនុំ គួរលះបង់ការចងគំនុំចេញ មានសេចក្តីលុបគុណគេ គួរលះបង់សេចក្តីលុបគុណគេចេញ មានសេចក្តីលើកខ្លួន គួរលះបង់សេចក្តីលើកខ្លួនចេញ មានសេចក្តីច្រណែន គួរលះបង់សេចក្តីច្រណែនចេញ មានសេចក្តីកំណាញ់ គួរលះបង់សេចក្តីកំណាញ់ចេញ មានសេចក្តីអួតអាង គួរលះបង់អំនួតចេញ មានសេចក្តីលាក់ពុត គួរលះបង់សេចក្តីលាក់ពុតចេញ មានសេចក្តីប្រាថ្នាលាមក គួរលះបង់សេចក្តីប្រាថ្នាលាមកចេញ មានគំនិតយល់ខុស គួរលះបង់គំនិតយល់ខុសចេញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញច្បាស់នូវបុគ្គលពួកមួយ ក្នុងលោកនេះ សូម្បីជាអ្នកមានសង្ឃាដីហើយ តែនៅមានអភិជ្ឈាច្រើន មានចិត្តប្រកបដោយព្យាបាទ មានសេចក្តីក្រោធ មានការចងគំនុំ មានសេចក្តីលុបគុណគេ មានសេចក្តីលើកខ្លួន មានសេចក្តីច្រណែន មានសេចក្តីកំណាញ់ មានសេចក្តីអួតអាង មានសេចក្តីលាក់ពុត មានសេចក្តីប្រាថ្នាលាមក មានគំនិតយល់ខុសនៅឡើយ ព្រោះហេតុណា ហេតុនេះបានជាតថាគតមិនទាន់ហៅនូវភាពនៃបុគ្គលមានសង្ឃាដី ថាជាសមណៈ ដោយគ្រាន់តែទ្រទ្រង់សង្ឃាដីប៉ុណ្ណោះទេ ។

អចេលកស្ស ចេ ភិក្ខវេ ។ បេ ។ រជោជល្លិកស្ស ចេ ភិក្ខវេ... ឧទកោរោហកស្ស ចេ ភិក្ខវេ... រុក្ខមូលិកស្ស ចេ ភិក្ខវេ... អព្ភោកាសិកស្ស ចេ ភិក្ខវេ... ឧព្ភដ្ឋកស្ស ចេ ភិក្ខវេ... បរិយាយភត្តិកស្ស ចេ ភិក្ខវេ... មន្តជ្ឈាយិកស្ស ចេ ភិក្ខវេ... ជដិលកស្ស ចេ ភិក្ខវេ ជដាធារណាមត្តេន អភិជ្ឈាលុស្ស អភិជ្ឈា បហីយេថ ព្យាបន្នចិត្តស្ស ព្យាបាទោ បហីយេថ កោធនស្ស កោធោ បហីយេថ ឧបនាហិស្ស ឧបនាហោ បហីយេថ មក្ខិស្ស មក្ខោ បហីយេថ បឡាសិស្ស បឡាសោ បហីយេថ ឥស្សុកិស្ស ឥស្សា បហីយេថ មច្ឆរិស្ស មច្ឆរិយំ បហីយេថ សបស្ស សាបេយ្យំ បហីយេថ មាយាវិស្ស មាយា បហីយេថ ចាបិច្ឆស្ស ចាបិកា ឥច្ឆា បហីយេថ មិច្ឆាទិដ្ឋិស្ស មិច្ឆាទិដ្ឋិ បហីយេថ

ម្នាលភិក្ខុទាំងឡាយ បើបុគ្គលមិនមានសំពត់ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលសៅហ្មងដោយធូលីនិងក្អែល... ម្នាលភិក្ខុទាំង-ឡាយ បើបុគ្គលចុះត្រាំទឹក... ម្នាលភិក្ខុទាំងឡាយ បើបុគ្គលអាស្រ័យនៅក្បែរគល់ឈើ... ម្នាលភិក្ខុទាំងឡាយ បើបុគ្គលអាស្រ័យនៅក្នុងទីវាល... ម្នាលភិក្ខុទាំងឡាយ បើបុគ្គលប្រកាន់ការអប់កាយ... ម្នាលភិក្ខុទាំងឡាយ បើបុគ្គលបរិភោគភត្ត ១ ដង ១ កាល... ម្នាលភិក្ខុទាំង-ឡាយ បើបុគ្គលរៀនមន្ត... ម្នាលភិក្ខុទាំងឡាយ បើបុគ្គលទុកផ្នួងសក់មែន តែនៅមានអភិជ្ឈាច្រើន ដោយអាងថាទុកផ្នួងសក់ប៉ុណ្ណោះ បុគ្គលនោះត្រូវលះអភិជ្ឈាចេញ មានចិត្តប្រកបដោយព្យាបាទ ត្រូវលះព្យាបាទចេញ មានសេចក្តីក្រោធ ត្រូវលះបង់សេចក្តីក្រោធចេញ មានការចងគំនុំ ត្រូវលះបង់ការចងគំនុំចេញ មានសេចក្តីលុបគុណគេ ត្រូវលះបង់សេចក្តីលុបគុណគេចេញ មានសេចក្តីលើកខ្លួន ត្រូវលះបង់សេចក្តីលើកខ្លួនចេញ មានសេចក្តីច្រណែន ត្រូវលះបង់សេចក្តីច្រណែនចេញ មានសេចក្តីកំណាញ់ ត្រូវលះបង់សេចក្តីកំណាញ់ចេញ មានសេចក្តីអួតអាង ត្រូវលះបង់អំនួតចេញ មានសេចក្តីលាក់ពុត ត្រូវលះបង់សេចក្តីលាក់ពុតចេញ មានសេចក្តីប្រាថ្នាលាមក ត្រូវលះបង់សេចក្តីប្រាថ្នាលាមកចេញ មានគំនិតយល់ខុស ត្រូវលះបង់គំនិតយល់ខុសចេញ

តមេនំ មិត្តាមច្ចា ញាតិសាលោហិតា ជាតមេវ នំ ជដិលកំ ករេយ្យុំ ជដិលកត្តមេវ[១] សមាទបេយ្យុំ ឯហិ ត្វំ ភទ្រមុខ ជដិលកោ ហោហិ ជដិលកស្ស តេ សតោ ជដាជារណមត្តេន អភិជ្ឈាលុស្ស អភិជ្ឈា បហីយិស្សតិ ព្យាបន្នចិត្តស្ស ព្យាបាទោ បហីយិស្សតិ កោធនស្ស កោធោ បហីយិស្សតិ ឧបនាហិស្ស ឧបនាហោ បហីយិស្សតិ មក្ខិស្ស មក្ខោ បហីយិស្សតិ បឡាសិស្ស បឡាសោ បហីយិស្សតិ ឥស្សុកិស្ស ឥស្សា បហីយិស្សតិ មច្ឆរិស្ស មច្ឆរិយំ បហីយិស្សតិ សឋស្ស សាឋេយ្យំ បហីយិស្សតិ មាយាវិស្ស មាយា បហីយិស្សតិ បាបិច្ឆស្ស បាបិកា ឥច្ឆា បហីយិស្សតិ មិច្ឆាទិដ្ឋិស្ស មិច្ឆាទិដ្ឋិ បហីយិស្សតីតិ ។ យស្មា ច ខោ អហំ ភិក្ខវេ ជដិលកម្បិ ឥធេកច្ចំ បស្សាមិ អភិជ្ឈាលុំ

១ ម. ជដិលកត្តេ ចេវ ។

មិត្តអាមាត្យញាតិសាលោហិត គប្បីធ្វើបុគ្គលដែលទុកផ្នួងសក់នោះ ឲ្យជាអ្នកទុកផ្នួងសក់ក្នុងថ្ងៃនោះឯង ហើយពន្យល់នូវភាពនៃបុគ្គលអ្នកទ្រទ្រង់ផ្នួងសក់ថា នែលោកមានមុខស្រស់បស់ លោកចូរមកនេះ លោកចូរជាអ្នកទុកផ្នួងសក់ចុះ កាលបើលោកទុកផ្នួងសក់ហើយ តែនៅមានអភិជ្ឈាច្រើន ដោយអាងថា ទុកផ្នួងសក់នោះប៉ុណ្ណោះ លោកគួរលះបង់អភិជ្ឈាចេញ មានចិត្តប្រកបដោយព្យាបាទ គួរលះបង់ព្យាបាទចេញ មានសេចក្តីក្រោធ គួរលះបង់សេចក្តីក្រោធចេញ មានការចងគំនុំ គួរលះបង់ការចងគំនុំចេញ មានសេចក្តីលុបគុណគេ គួរលះបង់សេចក្តីលុបគុណគេចេញ មានសេចក្តីលើកខ្លួន គួរលះបង់សេចក្តីលើកខ្លួនចេញ មានសេចក្តីប្រណែន គួរលះបង់សេចក្តីប្រណែនចេញ មានសេចក្តីកំណាញ់ គួរលះបង់សេចក្តីកំណាញ់ចេញ មានសេចក្តីអួតអាង គួរលះបង់អំនួតចេញ មានសេចក្តីលាក់ពុត គួរលះបង់សេចក្តីលាក់ពុតចេញ មានសេចក្តីប្រាថ្នាលាមក គួរលះបង់សេចក្តីប្រាថ្នាលាមកចេញ មានគំនិតយល់ខុស គួរលះបង់គំនិតយល់ខុសចេញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតឃើញច្បាស់នូវបុគ្គលពួកមួយក្នុងលោកនេះ សូម្បីទុកផ្នួងសក់ តែនៅមានអភិជ្ឈាច្រើន

ព្យាបន្នចិត្តំ កោធនំ ឧបនាហឹ មក្ខឹ បឡាសឹ ឥស្សុកឹ មច្ឆរឹ សឋំ មាយាវឹ បាបិច្ឆំ មិច្ឆាទិដ្ឋឹ តស្មា ន ជដិលកស្ស ជដាធារណមត្តេន សាមញ្ញំ វទាមិ ។

[១៦២] កថញ្ច ភិក្ខវេ ភិក្ខុ សមណសាមីចិប្ប-ដិបទំ បដិបន្នោ ហោតិ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុនោ អភិជ្ឈាលុស្ស អភិជ្ឈា បហីនា ហោតិ ព្យាបន្នចិត្តស្ស ព្យាបាទោ បហីនោ ហោតិ កោធ-នស្ស កោធោ បហីនោ ហោតិ ឧបនាហិស្ស ឧបនា-ហោ បហីនោ ហោតិ មក្ខិស្ស មក្ខោ បហីនោ ហោតិ បឡាសិស្ស បឡាសោ បហីនោ ហោតិ ឥស្សុកិស្ស ឥស្សា បហីនា ហោតិ មច្ឆរិស្ស មច្ឆរិយំ បហីនំ ហោតិ សឋស្ស សាឋេយ្យំ បហីនំ ហោតិ

មានចិត្តប្រកបដោយព្យាបាទ មានសេចក្តីក្រោធ មានការចងគំនុំ មានសេចក្តីលុបគុណគេ មានសេចក្តីលើកខ្លួន មានសេចក្តីច្រណែន មានសេចក្តីកំណាញ់ មានសេចក្តីអួតអាង មានសេចក្តីលាក់ពុត មានសេចក្តីប្រាថ្នាលាមក មានគំនិតយល់ខុស នៅឡើយ ព្រោះហេតុណា ហេតុនោះបានជា តថាគតមិនហៅបុគ្គល ដែលទុកផ្នួងសក់ថា ជាសមណៈ ដោយត្រឹមតែទុកផ្នួងសក់ប៉ុណ្ណោះទេ ។

[១២២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិនូវបដិបទា ដ៏សមគួរដល់សមណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយ មានអភិជ្ឈាច្រើន ជាអ្នកលះបង់អភិជ្ឈាចេញ មានចិត្តប្រកបដោយព្យាបាទ ជាអ្នកលះបង់ព្យាបាទចេញ មានសេចក្តីក្រោធ ជាអ្នកលះបង់សេចក្តីក្រោធចេញ មានការចងគំនុំ ជាអ្នកលះបង់ការចងគំនុំចេញ មានសេចក្តីលុបគុណគេ ជាអ្នកលះបង់សេចក្តីលុបគុណគេចេញ មានសេចក្តីលើកខ្លួន ជាអ្នកលះបង់សេចក្តីលើកខ្លួនចេញ មានសេចក្តីច្រណែន ជាអ្នកលះបង់សេចក្តីច្រណែនចេញ មានសេចក្តីកំណាញ់ ជាអ្នកលះបង់សេចក្តីកំណាញ់ចេញ មានសេចក្តីអួតអាង ជាអ្នកលះបង់អំនួតចេញ មាន

មាយាវិស្ស មាយា បហីនា ហោតិ បាបិច្ឆស្ស បាបិកា ឥច្ឆា បហីនា ហោតិ មិច្ឆាទិដ្ឋិស្ស មិច្ឆាទិដ្ឋិ បហីនា ហោតិ ។ ឥមេសំ ខោ ភិក្ខវេ សមណមលានំ សមណទោសានំ សមណកសាវានំ អាបាយិកានំ ឋានានំ ទុគ្គតិវេទនីយានំ បហានា សមណសាមីចិប្បដិបទំ បដិបន្នោតិ វទាមិ ។ សោ សព្វេហិ ឥមេហិ បាបកេហិ អកុសលេហិ ធម្មេហិ វិសុទ្ធមត្តានំ សមនុបស្សតិ វិមុត្តមត្តានំ សមនុបស្សតិ ។ តស្ស សព្វេហិ ឥមេហិ បាបកេហិ អកុសលេហិ ធម្មេហិ វិសុទ្ធមត្តានំ សមនុបស្សតោ វិមុត្តមត្តានំ សមនុបស្សតោ បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ ។ សោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ[១]

១ ឱ. ចតុត្ថឹ ឧទ្ធមធោ ។

សេចក្តីលាក់ពុត ជាអ្នកលះបង់សេចក្តីលាក់ពុតចេញ មានសេចក្តីប្រាថ្នាលាមក ជាអ្នកលះបង់សេចក្តីប្រាថ្នាលាមកចេញ មានគំនិតយល់ខុស ជាអ្នកលះបង់គំនិតយល់ខុសចេញ ។ ម្នាលភិក្ខុទាំងឡាយ ការលះបង់នូវមន្ទិលរបស់សមណៈ នូវទោសរបស់សមណៈ នូវធម៌ជាគ្រឿងអម្ចត់របស់សមណៈ ដែលជាហេតុញ៉ាំងសមណៈឲ្យកើតក្នុងអបាយ ទាំងជាបច្ច័យឲ្យទទួលនូវវិបាកជាទុក្ខ ក្នុងទុគ្គតិភូមិទាំងនេះចេញហើយ ទើបតថាគតហៅថាជាអ្នកប្រតិបត្តិនូវបដិបទា ដ៏សមគួរដល់សមណៈមែន ។ ភិក្ខុនោះឃើញច្បាស់នូវខ្លួនថាបរិសុទ្ធ ឃើញច្បាស់នូវខ្លួនថា រួចហើយចាកពួកអកុសលធម៌ដ៏លាមកទាំងអស់នេះ ។ កាលបើភិក្ខុនោះឃើញច្បាស់នូវខ្លួនថាបរិសុទ្ធ ឃើញច្បាស់នូវខ្លួនថារួចចាកពួកអកុសលធម៌ដ៏លាមកទាំងអស់នេះហើយ បាមោជ្ជៈគឺសេចក្តីត្រេកអរទន់ក៏កើតឡើង កាលបើភិក្ខុមានបាមោជ្ជៈហើយ បីតិក៏កើតឡើង កាលបើភិក្ខុមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់ស្ងាត់ កាលបើភិក្ខុមានកាយស្ងប់ស្ងាត់ហើយ រមែងទទួលនូវសុខ ភិក្ខុដែលមានចិត្តទទួលសុខហើយ ចិត្តក៏នឹងធឹងល្អ ។ ភិក្ខុនោះមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ទាំងទិសខាងលើនិងទិស

តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ ករុណាសហគតេន ចេតសា... មុទិតាសហគតេន ចេតសា... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ សេយ្យថាបិ ភិក្ខវេ បោក្ខរណី អច្ឆោទកា សាតោទកា សីតោទកា សេតកា សុបតិត្ថា រមណីយា ។ បុរត្ថិមាយ ចេបិ ទិសាយ បុរិសោ អាគច្ឆេយ្យ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ តសិតោ បិបាសិតោ ។ សោ តំ បោក្ខរណឹ អាគម្ម

ខាងក្រោម ទិសទទឹង គឺទិសជុំវិញ ក៏ដូចគ្នា ទាំងមានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ គឺយកសត្វជាអនេកមកជាអារម្មណ៍ ជាចិត្តប្រកបដោយមហគ្គតភូមិ ឥតមានប្រមាណគឺបានចម្រើនហើយ ជាចិត្តមិនមានពៀរ គឺមិនមានទោស មិនមានព្យាបាទគឺមិនមានទុក្ខ ផ្សាយទៅកាន់សត្វ-លោកទាំងអស់ ព្រោះយកខ្លួនប្រៀបនឹងសត្វទាំងអស់គ្រប់ទិស ។ ភិក្ខុមានចិត្តប្រកបដោយករុណា... មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ទាំងទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសជុំវិញក៏ដូចគ្នា ទាំងមានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រកបក្នុងមហគ្គតភូមិ ឥតមានប្រមាណ ជាចិត្តមិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ព្រោះយកខ្លួនប្រៀបនឹងសត្វទាំងអស់គ្រប់ទិស ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្រះបោក្ខរណីដែលមានទឹកថ្លាឆ្វង់ មានទឹកឆ្ងាញ់ មានទឹកត្រជាក់ មានទឹកថ្លាស្អាត (មិនមានកករ) មានកំពង់ល្អគួរជាទីរីករាយ ។ ទោះបីបុរសមកអំពីទិសខាងកើត មានខ្លួនក្តៅក្រហាយ ដោកដាំដោយចំហាយកម្តៅ មានកាយនឿយព្រួយ តក់ស្លុត ស្រេក ។ បុរសនោះ មកដល់ស្រះបោក្ខរណីនោះ

វិនេយ្យ ឧទកបិចាសំ វិនេយ្យ ឃម្មបរិឡាហំ ។ បច្ឆិមាយ ចេបិ ទិសាយ បុរិសោ អាគច្ឆេយ្យ... ឧត្តរាយ ចេបិ ទិសាយ បុរិសោ អាគច្ឆេយ្យ... ទក្ខិណាយ ចេបិ ទិសាយ បុរិសោ អាគច្ឆេយ្យ... យតោ កុតោ ចេបិ[១] បុរិសោ អាគច្ឆេយ្យ ឃម្មាភិតត្តោ ឃម្មបរេតោ កិលន្តោ តសិតោ បិចាសិតោ ។ សោ តំ ចោក្ខរណឹ អាគម្ម វិនេយ្យ ឧទកបិចាសំ វិនេយ្យ ឃម្មបរិឡាហំ ឯវមេវ ខោ ភិក្ខវេ ខត្តិយកុលា ចេបិ អគារស្មា អនគារិយំ បព្វជិតោ ហោតិ ។ សោ ច តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម ឯវំ មេត្តំ ករុណំ មុទិតំ ឧបេក្ខំ ភាវេត្វា លភតិ អជ្ឈត្តំ វូបសមំ[២] សមណសាមីចិប្បដិបទំ បដិបន្នោតិ វទាមិ ។ ព្រាហ្មណកុលា ចេបិ... វេស្សកុលា ចេបិ... សុទ្ទកុលា ចេបិ... យស្មា កស្មា ចេបិ កុលា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ។ សោ ច តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម ឯវំ មេត្តំ

---

១ ឱ. ម. ចេបិ នំ ។ ២ ឱ. អជ្ឈត្តំ វូបសមំ អជ្ឈត្តំ វូបសមា ។ ម. អជ្ឈត្តំ វូបសមំ តមហំ ។

ហើយក៏បន្ទោបង់នូវសេចក្ដីស្រេកទឹក ទាំងបន្ទោបង់នូវសេចក្ដីក្ដៅក្រហាយ ដោយចំហាយកម្ដៅចេញបាន ។ ទោះបីបុរសមកពីទិសខាងលិច... ទោះបីបុរសមកពីទិសខាងជើង... ទោះបីបុរសមកពីទិសខាងត្បូង... ទោះបីបុរសមកអំពីទិសណា ៗ មានខ្លួនក្ដៅក្រហាយ ដោកដាំដោយចំហាយកម្ដៅ មានកាយនឿយព្រួយតក់ស្លុត មានសេចក្ដីស្រេក ។ បុរសនោះមកដល់ស្រះបោក្ខរណីនោះហើយ ក៏បន្ទោបង់សេចក្ដីស្រេកទឹកទាំងបន្ទោបង់នូវសេចក្ដីក្ដៅក្រហាយ ដោយចំហាយកម្ដៅចេញបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ទោះបីបុគ្គលចេញចាកខត្តិយត្រកូល ចេញចាកគេហស្ថានចូលទៅកាន់ផ្នួស ក៏យ៉ាងនោះដែរ ។ ក៏បព្វជិតនោះអាស្រ័យនូវធម៌វិន័យដែលតថាគតត្រាស់សំដែងហើយ បានចម្រើននូវមេត្តា ករុណា មុទិតា ឧបេក្ខា យ៉ាងនេះ តថាគតហៅបព្វជិតនោះថាជាអ្នកប្រតិបត្តិនូវបដិបទាដ៏សមគួរដល់សមណៈ ដ៏ស្ងប់រម្ងាប់ប្រព្រឹត្តទៅក្នុងសន្ដានមែន ។ ទោះបីបុគ្គលចេញចាកព្រាហ្មណត្រកូល ទោះបីបុគ្គលចេញចាកវេស្សត្រកូល... ទោះបីបុគ្គលចេញចាកសុទ្ទត្រកូល... ទោះបីបុគ្គលចេញចាកត្រកូលណា ៗ ចេញចាកគេហស្ថានណា ៗ ចូលទៅកាន់ផ្នួស ។ ក៏បព្វជិតនោះអាស្រ័យនូវធម៌វិន័យ ដែលតថាគតសំដែងហើយ បានចម្រើននូវមេត្តា

ការុណំ មុជិតំ ឧបេក្ខំ ភាវេត្វា លភតិ អជ្ឈត្តំ វូបសមំ សមណសាមីចិប្បដិបទំ បដិបន្នោតិ វទាមិ ។ ខត្តិយកុលា ចេបិ អគារស្មា អនគារិយំ បព្វជិតោ ហោតិ ។ សោ ច អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ អាសវានំ ខយា សមណោ ហោតីតិ វទាមិ[១] ។ ព្រាហ្មណកុលា ចេបិ... វេស្សកុលា ចេបិ... សុទ្ទកុលា ចេបិ... យស្មា កស្មា ចេបិ កុលា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ។ សោ ច អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ អាសវានំ ខយា សមណោ ហោតីតិ វទាមីតិ[២] ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ចូឡអស្សបុរសុត្តំ ទសមំ និដ្ឋិតំ ។

មហាយមកវគ្គោ ចតុត្ថោ ។

---

១-២ ឱ. ម. ឥតិ វទាមីតិ ន ទិស្សតិ ។

*ករុណា មុទិតា ឧបេក្ខាយ៉ាងនេះ តថាគតហៅបព្វជិតនោះថាជាអ្នកប្រតិបត្តិនូវបដិបទាដ៏សមគួរដល់សមណៈ ដ៏ស្ងប់រម្ងាប់ប្រព្រឹត្តទៅក្នុងសន្តានមែន ។ ទោះបីបុគ្គលចេញចាកខត្តិយត្រកូល ចេញចាកគេហស្ថានចូលទៅកាន់ផ្នួស ។ ក៏បព្វជិតនោះធ្វើឲ្យជាក់ច្បាស់បានសម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយខ្លួនឯងក្នុងបច្ចុប្បន្ន តថាគតហៅបព្វជិតនោះថាជាសមណៈ ព្រោះអស់ទៅ នៃអាសវៈទាំងឡាយ ។ ទោះបីបុគ្គលចេញចាកព្រាហ្មណត្រកូល... ទោះបីបុគ្គលចេញចាកវេស្សត្រកូល... ទោះបីបុគ្គលចេញចាកសុទ្ទត្រកូល... ទោះបីបុគ្គលចេញចាកត្រកូលណា ៗ ចេញចាកគេហស្ថានណា ៗ ចូលទៅកាន់ផ្នួស ។ ក៏បព្វជិតនោះធ្វើឲ្យជាក់ច្បាស់បានសម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយខ្លួនឯងក្នុងបច្ចុប្បន្ន តថាគតហៅបព្វជិតនោះថាជាសមណៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់នូវសុភាសិតនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរហើយចំពោះភាសិត របស់ព្រះមានព្រះភាគ ។*

ចប់ ចូឡអស្សបុរសូត្រ ទី ១០ ។

ចប់ មហាយមកវគ្គ ទី ៤ ។

២៣៧

មហាយមកវគ្គស្ស ឧទ្ទានំ

## តស្សុទ្ទានំ

**កិញ្ចកសាលវនំ បរិហាតុំ បញ្ញវតោ**

**បុន សច្ចនិសេវោ មុខវណ្ណប្បសីទត្តាទិ ។**

**តសិតោ កេវដ្ដស្ស បុរជដិលេនាតិ(១) ។**

---

១ មរម្មបោត្ថកេ

តស្សុទ្ទានំ

(គិញ្ចកស្សាលវនំ បដិភាគុ បញ្ញវតោ បុន សច្ចនិសេធោ ។ មុខវណ្ណបសីទនថាបិន្ទោ ។ កេវដ្ដអស្ស បុរជដិលេនាតិ) ទិស្សន្តិ ។

ឱរោបិយបោត្ថកេ

តស្សុទ្ទានំ

គិញ្ចកសាលវនំ បរិហាតុំ បញ្ញវតោ
បុន សច្ចនិសេវោ មុខវណ្ណបសីទត្តាទិ ។
តសីតោ កេវដ្ដស្ស បុរជដិលេនាតីតិ ន ទិស្សន្តិ ។

# ឧទ្ទាននៃមហាយមកវគ្គ

ឧទ្ទាន គឺបញ្ជីរឿង នៃមហាយមកវគ្គ ទី ៤ នោះ គឺ និយាយពីព្រះមានព្រះភាគ គង់ក្នុងពោងដែលកដោយឥដ្ឋ ក្នុងព្រៃគោសិង្គសាលវ័ន (មានក្នុង ចូឡគោសិង្គសាលសូត្រ និង មហាគោសិង្គសាលសូត្រ) ១ និយាយពីធម៌ប្រៀបដោយគោ-បាល គួររក្សាគោបាននិងមិនបាន (មានក្នុងមហាគោបាល-សូត្រ) ១ និយាយពីគោបាលមានប្រាជ្ញាម្តងទៀត (មានក្នុង ចូឡគោបាលសូត្រ) ១ និយាយពីព្រះមានព្រះភាគ ទ្រង់គង់ នៅក្នុងក្រុងវេសាលី (មានក្នុងចូឡសច្ចកសូត្រ) ១ និយាយ ពីព្រះមានព្រះភាគ មានព្រះកត្រ្គជ្រះថ្លាជាដើម (មានក្នុង មហាសច្ចកសូត្រ) ១ ។ និយាយពីព្រះឥន្ទ្រាធិរាជ ប្រកប ដោយតណ្ហា (មានក្នុងចូឡតណ្ហាសង្ខយសូត្រ) ១ និយាយ ពីសាតិភិក្ខុកេវដ្តបុត្រ (មានក្នុងមហាតណ្ហាសង្ខយសូត្រ) ១ និយាយពីពាក្យថាសមណៈ មានក្នុងមហាអស្សបុរសូត្រ ១ និយាយពីសមណៈទុកផ្នួងសក់ មានក្នុងចូឡអស្សបុរសូត្រ ១ ។

# ចូឡយមកវគ្គោ

## បឋមំ សាលេយ្យកសុត្តំ

[១៦៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន សាលំ នាម កោសលានំ ព្រាហ្មណគ្គាមោ តទវសរិ ។ អស្សោសុំ ខោ សាលេយ្យកា ព្រាហ្មណគហបតិកា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ សាលំ អនុប្បត្តោ ។ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា

# ចូឡយមកវគ្គ

## សាលេយ្យកសូត្រ ទី ១

[១២៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ទីចារិក ក្នុងកោសលជនបទ ជាមួយនឹងព្រះភិក្ខុសង្ឃច្រើនរូប បានស្តេចទៅដល់ស្រុកព្រាហ្មណ៍ឈ្មោះសាលៈ ជាខេត្ររបស់កោសលជនបទ ។ ពួកព្រាហ្មណ៍និងគហបតីអ្នកស្រុកសាលៈបានឮ (ដំណឹង) ហើយ ក៏ប្រកាសពាក្យនេះថា ម្នាលគ្នាយើង ឮថា ព្រះសមណ-គោតមជាសក្យបុត្រ ចេញចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួស ទ្រង់ស្តេចទៅកាន់ទីចារិកក្នុងកោសលជនបទ ព្រមដោយភិក្ខុសង្ឃច្រើនរូប ឥឡូវស្តេចមកដល់សាលគ្រាមហើយ ។ កិត្តិសព្ទដ៏ល្អ របស់ព្រះគោតមដ៏មានព្រះភាគនោះ ល្បីឮខ្ចរខ្ចាយយ៉ាងនេះថា ព្រះមានព្រះភាគ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឯង បរិបូណ៌ដោយវិជ្ជានិងចរណៈ គឺសេចក្តីដឹងនិងក្រឹត្យដែលបុគ្គលគប្បីប្រព្រឹត្ត មានដំណើរទៅកាន់ព្រះនិព្វាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូ

ចូឡយមកវគ្គស្ស សាលេយ្យកសុត្តេ ពុទ្ធគុណកថា

ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។ អថខោ សាលេយ្យកា ព្រាហ្មណគហបតិកា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ យេន ភគវា តេនញ្ជលិម្បណាមេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតោ សន្តិកេ នាមគោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ

នៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ចធម៌ លែង វិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះអង្គ ទ្រង់ធ្វើឲ្យជាក់ច្បាស់ ដោយ ប្រាជ្ញា ចំពោះព្រះអង្គឯង នូវលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ព្រមទាំង មនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយទ្រង់ប្រកាស ព្រះ អង្គ ទ្រង់សំដែងធម៌មានពីរោះបទដើម មានពីរោះបទកណ្តាល មាន ពីរោះបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈ ដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានឃើញនូវព្រះអរហន្ត ទាំងឡាយ មានសភាពយ៉ាងហ្នឹង ជាការប្រពៃពេក ។ គ្រានោះ ពួកព្រាហ្មណ៍ និងគហបតីអ្នកស្រុកសាលគ្រាម នាំគ្នាចូលទៅគាល់ព្រះ មានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះក៏ពោលពាក្យរាក់ទាក់ សំណេះសំ- ណាលជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះអង្គុយ ក្នុងទីដ៏សមគួរ ប្រណម្យអញ្ជលីឆ្ពោះទៅព្រះមានព្រះភាគ ពួកខ្លះប្រ- កាស នូវនាមនិងគោត្រក្នុងទីជិតព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ

អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ សាលេយ្យកា ព្រាហ្មណ-គហបតិកា ភគវន្តំ ឯតទវោចុំ កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យេនមិធេ-កច្ចេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ កោ បន ភោ គោតម ហេតុ កោ បច្ចយោ យេនមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។ អធម្មចរិយា វិសមចរិយាហេតុ ខោ គហបតយោ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ធម្មចរិយា សមចរិយាហេតុ ខោ គហប-តយោ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។

ពួកខ្លះអង្គុយស្ងៀម ក្នុងទីដ៏សមគួរ ។ កាលព្រាហ្មណ៍និងគហបតីអ្នកស្រុកសាលៈ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលសួរពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ហេតុដូចម្ដេច បច្ច័យដូចម្ដេច បានជាសត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ (ទីមិនមានសេចក្ដីចម្រើនគឺតិរច្ឆានកំណើត) ទុគ្គតិ (ដំណើរដែលផ្អែកនឹងទុក្ខគឺអសុរកាយ) វិនិបាត (ទីសម្រាប់ទម្លាក់នូវបុគ្គលធ្វើអំពើអាក្រក់គឺប្រេតវិស័យ) និរយៈ (ទីមិនមានសេចក្ដីសប្បាយគឺនរក) បពិត្រព្រះគោតមដ៏ចម្រើន ហេតុដូចម្ដេច បច្ច័យដូចម្ដេច បានជាសត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ទៅកើតក្នុងមនុស្ស សុគតិ សួគ៌ទេវលោក ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតីទាំងឡាយ សត្វទាំងឡាយពួកខ្លះក្នុងលោកនេះ ទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែកិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ យ៉ាងនេះឯង ម្នាលគហ-បតីទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺមនុស្ស សុគតិ ឋានសួគ៌ ព្រោះហេតុតែកិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌យ៉ាងនេះឯង ។

ន ខោ មយំ ឥមស្ស ភោតោ គោតមស្ស សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ អាជានាម សាធុ នោ ភវំ គោតមោ តថា ធម្មំ ទេសេតុ យថា មយំ ឥមស្ស ភោតោ គោតមស្ស សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ អាជានេយ្យាមាតិ ។ តេនហិ គហបតយោ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ សាលេយ្យកា ព្រាហ្មណគហបតិកា ភគវតោ បច្ចស្សោសុំ ។

[១២៤] ភគវា ឯតទវោច តិវិធំ ខោ គហបតយោ កាយេន អធម្មចរិយា វិសមចរិយា ហោតិ ចតុព្វិធំ វាចាយ អធម្មចរិយា វិសមចរិយា ហោតិ តិវិធំ មនសា អធម្មចរិយា វិសមចរិយា ហោតិ ។ កថញ្ច គហបតយោ តិវិធំ កាយេន អធម្មចរិយា វិសមចរិយា ហោតិ ។ ឥធ គហបតយោ ឯកច្ចោ

ព្រាហ្មណ៍និងគហបតី ក្រាបបង្គំទូលថា កាលបើព្រះគោតមដ៏ចម្រើននេះ សំដែងដោយខ្លេប មិនបានចែកអត្ថដោយពិស្តារហើយ យើងទាំង-ឡាយមិនអាចនឹងដឹងសេចក្ដីដោយពិស្ដារទៅបានទេ កាលបើព្រះគោតមដ៏ចម្រើននេះ សំដែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្ដារទេ តែថាយើងទាំងឡាយអាចនឹងដឹងសេចក្ដីដោយពិស្ដារទៅបាន ដោយប្រការយ៉ាងណា សូមព្រះគោតមដ៏ចម្រើនទ្រង់ព្រះមេត្តាប្រោស សំដែងធម៌ដល់យើងខ្ញុំទាំងឡាយដោយប្រការយ៉ាងនោះឲ្យទាន ។ ព្រះអង្គត្រាស់ថា ម្នាលគហបតីទាំងឡាយ បើដូច្នោះអ្នកទាំងឡាយចូរប្រុងស្ដាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ពួកព្រាហ្មណ៍និងគហបតីអ្នកស្រុកសាលៈទទួលស្ដាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[១២៤] ព្រះមានព្រះភាគ ត្រាស់ភាសិតនេះថា ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តិតាមធម៌ ដោយកាយមាន ៣ ប្រការ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ដោយវាចាមាន ៤ ប្រការ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយចិត្តមាន ៣ ប្រការ ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយកាយមាន ៣ ប្រការ តើដូចម្ដេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ

បាណាតិបាតី ហោតិ លុទ្ទោ[១] លោហិតបាណី ហតប្បហតេ និវិដ្ឋោ អលជ្ជី[២] អទយាបន្នោ សព្វបាណភូតេសុ[៣] ។ អទិន្នាទាយី ខោ បន ហោតិ យន្តំ បរស្ស បរវិត្តូបករណំ គាមគតំ វា អរញ្ញគតំ វា តំ អទិន្នំ ថេយ្យសង្ខាតំ អាទាតា ហោតិ ។ កាមេសុ មិច្ឆាចារី ខោ បន ហោតិ យា តា មាតុរក្ខិតា បិតុរក្ខិតា មាតាបិតុរក្ខិតា ភាតុរក្ខិតា ភគិនិរក្ខិតា ញាតិរក្ខិតា សស្សាមិកា

---

១ ម. ឯត្តន្តរេ ទារុណោតិ ទិស្សតិ ។ ២ ឱ. ម. អយំ បាឋោ ន ទិស្សតិ ។ ៣ ឱ. បាណាភូតេសុ ។

ជាអ្នកសម្លាប់សត្វ ជាមនុស្សអាក្រក់ មានបាតដៃប្រឡាក់ដោយឈាម មានចិត្តបោះជាប់ក្នុងការសម្លាប់សត្វ ជាអ្នកមិនមានសេចក្តីអៀនខ្មាស មានចិត្តមិនអាសូរចំពោះពួកសត្វទាំងអស់ ។ មួយទៀត ជាអ្នកកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដូចជាគ្រឿងឧបករណ៍គឺសម្បត្តិនៃបុគ្គលដទៃណាដែលគេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី ជាអ្នកកាន់យកគ្រឿងឧបករណ៍ដែលគេមិនបានឲ្យនោះ ដោយចំណែកនៃចិត្តលួច ។ មួយទៀត ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ដូចជាស្ត្រីទាំងឡាយណាគឺស្ត្រីដែលមាតារក្សា[១] ដែលបិតារក្សា ដែលញាតិរក្សា ដែលបងប្អូនប្រុសរក្សា ដែលបងប្អូនស្រីរក្សា ដែលញាតិរក្សា ដែលមានស្វាមី[២]

---

១ ស្ត្រីដែលមានមាតារក្សានោះ បិតាលែងគ្នាឬស្លាប់បាត់ទៅ នៅសល់តែមាតាហើយរក្សាទំនុកបម្រុង ដោយអាហារនិងសំពត់ស្លៀកជាដើម ។ ឯស្ត្រីដែលមានបិតារក្សា ក៏មានសេចក្តីដូចគ្នា ។ ២ ស្ត្រីដែលមានស្វាមីនោះ កាលស្ត្រីនោះនៅក្នុងផ្ទៃនៅឡើយ មានត្រកូលស្មើគ្នានិយាយណាត់គ្នាថា បើខ្ញុំមានកូនប្រុស អ្នកមានកូនស្រី ៗ នោះកុំឲ្យទៅត្រកូលដទៃ ត្រូវឲ្យមកកូនខ្ញុំ ។

សបរិទណ្ឌា អន្តមសោ មាលាគុឡបរិក្ខិត្តាបិ តថា-រូបាសុ ចារិត្តំ អាបជ្ជិតា ហោតិ ។ ឯវំ ខោ គហបតយោ តិវិធំ កាយេន អធម្មចរិយា វិសម-ចរិយា ហោតិ ។ កថញ្ច គហបតយោ ចតុព្វិធំ វាចាយ អធម្មចរិយា វិសមចរិយា ហោតិ ។ ឥធ គហបតយោ ឯកច្ចោ មុសាវាទី ហោតិ សភគ្គតោ វា បរិសគ្គតោ វា[១] ញាតិមជ្ឈគតោ វា បូគ-មជ្ឈគតោ វា រាជកុលមជ្ឈគតោ វា អភិនីតោ សក្ខី[២] បុដ្ឋោ ឯហម្ភោ[៣] បុរិស យំ ជានាសិ តំ វទេហីតិ ។ សោ អជានំ វា អាហ[៤] ជានាមីតិ ជានំ វា អាហ ន ជានាមីតិ អបស្សំ វា អាហ បស្សាមីតិ បស្សំ វា អាហ ន បស្សាមីតិ ។

១ ឱ. ម. សភាគតោ វា បរិសគតោ វា ។ ២ ឱ. ម. សក្ខិ ។ ៣ ឱ. ម. ឯវំ ភោ ។ ៤ ម. សោ អាហ អជានំ វា អហំ ។

ដែលប្រកបដោយអាជ្ញា[១] ដោយហោចទៅ សូម្បីតែស្ត្រីដែលបុរសបំពាក់កម្រងផ្កាឲ្យ[២] ជាអ្នកដល់នូវការប្រព្រឹត្តកន្ទង ក្នុងស្ត្រីទាំងឡាយមានសភាពដូច្នោះ ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយកាយមាន ៣ ប្រការ យ៉ាងនេះឯង ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយវាចាមាន ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកពោលពាក្យកុហក ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិស័ទក្តី ឋិតនៅក្នុងកណ្តាលញាតិក្តី ឋិតនៅកណ្តាលសេនីក្តី ឋិតនៅកណ្តាលរាជត្រកូលក្តី គេនាំទៅធ្វើជាសាក្សី ហើយសួរថា នែបុរសដ៏ចម្រើន ចូរអ្នកមកនេះ បើអ្នកដឹងហេតុណា ចូរនិយាយហេតុនោះ ។ បុរសនោះ កាលមិនដឹងនិយាយថា ខ្ញុំដឹង ឬកាលដឹង និយាយថា ខ្ញុំមិនដឹង កាលមិនឃើញនិយាយថា ខ្ញុំឃើញ ឬកាលឃើញ និយាយថា ខ្ញុំមិនឃើញ ។

១ ស្ត្រីដែលប្រកបដោយអាជ្ញានោះ គឺបានដល់ស្ត្រីដែលស្តេចដាក់អាជ្ញាចំពោះឈ្មោះ ឬចំពោះផ្ទះ ឬចំពោះថ្នល់ថា បុរសណាហ៊ានប្រព្រឹត្តនឹងស្ត្រីឈ្មោះនេះ នឹងត្រូវពិន័យប៉ុណ្ណេះ ។
២ ស្ត្រីដែលបុរសបំពាក់កម្រងផ្កាឲ្យនោះ បានដល់ស្ត្រីដែលបុរសនីមួយបោះភួងផ្កាទៅលើស្ត្រីនោះ បើជាប់ ក៏កំណត់ថា ស្ត្រីនេះជាភរិយារបស់ខ្លួន ។ អដ្ឋកថា ។

ឥតិ អត្តហេតុ វា បរហេតុ វា អាមិសកិញ្ចិក្ខហេតុ វា សម្បជានមុសា ភាសិតា ហោតិ ។ បិសុណាវាចោ[១] ខោ បន ហោតិ ឥតោ សុត្វា អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ សមគ្គានំ វា ភេទេតា[២] ភិន្នានំ វា អនុប្បយតា វគ្គារាមោ វគ្គរតោ វគ្គនន្ទី វគ្គករណឹ វាចំ ភាសិតា ហោតិ ។ ផរុសវាចោ ខោ បន ហោតិ យា សា វាចា អណ្ឌកា[៣] កក្កសា បរកដុកា បរាភិសជ្ជនី កោធសាមន្តា អសមាធិសំវត្តនិកា តថារូបី វាចំ ភាសិតា ហោតិ ។ សម្ផប្បលាបី ខោ បន ហោតិ អកាលវាទី អភូតវាទី អនត្ថវាទី អធម្មវាទី អវិនយវាទី អនិធានវតឹ វាចំ ភាសិតា ហោតិ[៤] អកាលេន អនបទេសំ អបរិយន្តវតឹ អនត្ថសញ្ហិតំ ។ ឯវំ ខោ គហបតយោ

១ ឱ. ម. បិសុណាវាចោ ។ ២ ឱ. ភេត្តា ។ ម. ភេទកា ។ ៣ ម. គណ្ឌកា ។
៤ ឱ. ម. ហោតីតិ ន ទិស្សតិ ។

ជាអ្នកពោលពាក្យកុហកទាំងដឹងខ្លួន ព្រោះហេតុតែខ្លួនក្តី ព្រោះហេតុអ្នកដទៃក្តី ព្រោះហេតុសំណូកគឺអាមិសៈបន្តិចបន្តួចក្តី ។ មួយទៀត ជាអ្នកពោលនូវពាក្យញុះញង់ គឺឮពាក្យអំពីសំណាក់ជននេះហើយនាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះ ឮពាក្យអំពីជនឯណោះ ហើយនាំយកមកប្រាប់ជននេះ ដើម្បីបំបែកជនឯណោះ ជាអ្នកបំបែកនូវពួកជនដែលព្រមព្រៀងគ្នាផង ជាអ្នកជម្រុលពួកជន ដែលបែកគ្នាហើយផង ជាអ្នកត្រេកអរតែក្នុងពួក មានតម្រេកក្នុងពួក ជាអ្នករីករាយតែក្នុងពួក ជាអ្នកពោលនូវវាចាដែលធ្វើឲ្យប្រកាន់ពួក ដូច្នេះឯង ។ មួយទៀត ជាអ្នកពោលពាក្យអាក្រក់ គឺវាចាណាទ្រគោះ ខ្មោះខ្មួរពោលពាល ស្ទាក់ដំណើរជនដទៃ ជាវាចាជិតនឹងសេចក្តីក្រោធ មិនប្រព្រឹត្តទៅដើម្បីសមាធិបាន ហើយជាអ្នកពោលនូវវាចា មានសភាពដូច្នោះ ។ មួយវិញទៀត ជាអ្នកពោលនូវពាក្យមិនមានប្រយោជន៍ ពោលពាក្យខុសកាល ពោលនូវពាក្យមិនពិត ពោលពាក្យមិនមែនជាអត្ថ ពោលពាក្យមិនមែនជាធម៌ ពោលពាក្យមិនមែនជាវិន័យ ពោលពាក្យដែលមិនគួរតាំងទុក ក្នុងហឫទ័យ ខុសកាល ប្រាសចាកគ្រឿងអាង ជាពាក្យមិនមានទីបំផុត មិនប្រកបដោយប្រយោជន៍ ។ ម្នាលគហបតីទាំងឡាយ

ចតុព្វិធំ វាចាយ អធម្មចរិយា វិសមចរិយា ហោតិ ។ កថញ្ច គហបតយោ តិវិធំ មនសា អធម្មចរិយា វិសមចរិយា ហោតិ ។ ឥធ គហបតយោ ឯកច្ចោ អភិជ្ឈាលុ ហោតិ យន្តំ បរស្ស បរវិត្តូបករណំ តំ អភិជ្ឈិតា[១] ហោតិ អហោ វត យំ បរស្ស តំ មម អស្សាតិ ។ ព្យាបន្នចិត្តោ ខោ បន ហោតិ បទុដ្ឋមនសង្កប្បោ[២] ឥមេ សត្តា ហញ្ញន្តុ វា វជ្ឈន្តុ វា ឧច្ឆិជ្ជន្តុ វា មា វា អហោសុន្តិ[៣] ។ មិច្ឆាទិដ្ឋិកោ[៤] ខោ បន ហោតិ វិបរីតទស្សនោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។

---

១ ឱ. ម. អភិជ្ឈាតា ។ ២ ម. ទុដ្ឋមនសង្កប្បោ ។ ៣ ឱ. ម. ឧច្ឆិជ្ជន្តុ វា វិនស្សន្តុ វា មា វា អហោសុំ ឥតិ វាតិ ។ ៤ ឱ. មិច្ឆាទិដ្ឋិ ។

កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយវាចា មាន ៤ ប្រការដូច្នេះឯង ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ ដោយចិត្តមាន ៣ ប្រការ តើដូចម្ដេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ច្រើនដោយ អភិជ្ឈា គយគន់នូវគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃ ដោយ គិតថា ឱហ្ន៎ គ្រឿងឧបករណ៍ដែលជាសម្បត្តិនៃបុគ្គលដទៃណា គ្រឿង ឧបករណ៍នោះ គប្បីបានមកអាត្មាអញ ។ មួយទៀត ជាអ្នកមាន ចិត្តព្យាបាទ មានតម្រិះក្នុងចិត្ត ដែលទោសប្រទូស្តហើយថា សត្វទាំង-ឡាយចូរលំបាកខ្លះ ចូរស្លាប់ចុះ ចូរវិនាសសាបសូន្យទៅខ្លះ ដែលថា មិនវិនាសកុំឲ្យមានឡើយ ។ មួយវិញទៀត ជាអ្នកមានគំនិតយល់ ខុស ឃើញនូវសេចក្ដីវិបរិតថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំមិនមានផល ការបូជាតូចក៏មិនមានផល ផលវិបាកនៃកុស-លាកុសលកម្ម ដែសត្វធ្វើល្អនិងអាក្រក់ មិនមាន លោកនេះមិន មាន លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ សត្វទាំងឡាយជាឱបបាតិកៈ មិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកព្រមព្រៀងគ្នា ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយ ខ្លួនឯង នូវលោកនេះនិងលោកខាងមុខ ហើយសំដែង ក៏មិនមាន ។

ឯវំ ខោ គហបតយោ តិវិធំ មនសា អធម្មចរិយា វិសមចរិយា ហោតិ ។ ឯវំ អធម្មចរិយាវិសមចរិយា-ហេតុ ខោ គហបតយោ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។

[១២៨] តិវិធំ ខោ គហបតយោ កាយេន ធម្មចរិយា សមចរិយា ហោតិ ។ ចតុព្វិធំ វាចាយ ធម្មចរិយា សមចរិយា ហោតិ ។ តិវិធំ មនសា ធម្មចរិយា សមចរិយា ហោតិ ។ កថញ្ច គហប-តយោ តិវិធំ កាយេន ធម្មចរិយា សមចរិយា ហោតិ ។ ឥធ គហបតយោ ឯកច្ចោ បាណាតិ-បាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ ។ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ យន្តំ បរស្ស បរវិត្តូបករណំ គាមគតំ វា អរញ្ញគតំ វា

ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ដោយចិត្ត មាន ៣ ប្រការ យ៉ាងនេះឯង ។ ម្នាលគហបតីទាំងឡាយ សត្វទាំងឡាយពួកខ្លះក្នុងលោកនេះ លុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ចូលទៅកាន់អបាយ ទុគ្គតិ វិនិបាត នរក យ៉ាងនេះ ព្រោះហេតុតែកិរិយាប្រព្រឹត្តមិនស្មើ ពោលគឺមិនប្រព្រឹត្តតាមធម៌ យ៉ាងនេះឯង ។

[១២៥] ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយកាយ មាន ៣ ប្រការ ។ កិរិយាប្រព្រឹត្តស្មើពោលគឺប្រព្រឹត្តតាមធម៌ ដោយវាចា មាន ៤ ប្រការ ។ កិរិយាប្រព្រឹត្តស្មើពោលគឺប្រព្រឹត្តតាមធម៌ដោយចិត្ត មាន ៣ ប្រការ ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយកាយ មាន ៣ ប្រការ តើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ជាអ្នកដាក់ចុះនូវអាជ្ញា ដាក់ចុះនូវសស្ត្រាវុធ ប្រកបដោយសេចក្តីខ្មាស ដល់នូវមេត្តាចិត្ត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះពួកសត្វទាំងអស់ ។ ជាអ្នកលះបង់នូវអទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន ដូចជាគ្រឿងឧបករណ៍គឺសម្បត្តិនៃបុគ្គលណា ដែលគេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី

ន តំ អទិន្នំ[១] ថេយ្យសង្ខាតំ អាទាតា ហោតិ ។ កាមេសុ មិច្ឆាចារំ បហាយ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ យា តា មាតុរក្ខិតា បិតុរក្ខិតា មាតាបិតុរក្ខិតា ភាតុរក្ខិតា ភគិនិរក្ខិតា ញាតិរក្ខិតា សស្សាមិកា សបរិទណ្ឌា អន្តមសោ មាលាគុឡបរិក្ខិត្តាបិ តថារូបាសុ ន ចារិត្តំ អាបជ្ជិតា ហោតិ ។ ឯវំ ខោ គហបតយោ តិវិធំ កាយេន ធម្មចរិយា សមចរិយា ហោតិ ។ កថញ្ច គហបតយោ ចតុព្វិធំ វាចាយ ធម្មចរិយា សមចរិយា ហោតិ ។ ឥធ គហបតយោ ឯកច្ចោ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សភគ្គតោ វា បរិសគ្គតោ វា ញាតិមជ្ឈគតោ វា បូគមជ្ឈគតោ វា រាជកុលមជ្ឈគតោ វា អភិនីតោ សក្ខី បុដ្ឋោ ឯហម្ភោ បុរិស យំ ជានាសិ តំ វទេហីតិ ។ សោ អជានំ វា អាហ ន ជានាមីតិ ជានំ វា អាហ ជានាមីតិ អបស្សំ

១ ឱ. ម. តំ នាទិន្នំ ។

ក៏ជាអ្នកមិនកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យនោះ ដោយចំណែកនៃចិត្តលួចឡើយ ។ ជាអ្នកលះបង់នូវកាមេសុមិច្ឆាចារ វៀរស្រឡះចាកកាមេសុមិច្ឆាចារ ទោះបីស្ត្រីណា ដែលមាតារក្សា បិតារក្សា មាតា-បិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា មានស្វាមីប្រកបដោយអាជ្ញា ដោយហោចទៅសូម្បីស្ត្រី ដែលបុរសបំពាក់កម្រងផ្កាឲ្យ ក៏ជាអ្នកមិនដល់នូវការប្រព្រឹត្តកន្លង ក្នុងស្ត្រីទាំងឡាយ មានសភាពដូច្នោះឡើយ ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយកាយ មាន ៣ ប្រការដូច្នោះឯង ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយវាចា មាន ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ លះបង់នូវមុសាវាទ វៀរស្រឡះចាកមុសាវាទ ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិស័ទក្តី ឋិតនៅកណ្តាលញាតិក្តី ឋិតនៅកណ្តាលសេនីយក្តី ឋិតនៅកណ្តាលរាជត្រកូលក្តី គេនាំទៅធ្វើជាសាក្សីហើយសួរថា នែបុរសដ៏ចម្រើន ចូរអ្នកមកនេះ បើអ្នកដឹងហេតុណា ចូរនិយាយប្រាប់ហេតុនោះដូច្នេះក្តី ។ បុរសនោះ កាលមិនដឹង និយាយថា ខ្ញុំមិនដឹង ឬកាលដឹង ក៏និយាយថា ខ្ញុំដឹង កាលមិនឃើញ

វា អាហ ន បស្សាមីតិ បស្សំ វា អាហ បស្សាមីតិ ។ ឥតិ អត្តហេតុ វា បរហេតុ វា អាមិសកិញ្ចិក្ខហេតុ វា ន សម្បជានមុសា ភាសិតា ហោតិ ។ បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ឥតោ សុត្វា ន អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្បទាតា សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតា ហោតិ ។ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា នេលា កណ្ណសុខា បេមនីយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា ហោតិ ។ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី

និយាយថា ខ្ញុំមិនឃើញ ឬកាលឃើញ ក៏និយាយថា ខ្ញុំឃើញ ។ ជាអ្នកមិនពោល នូវពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុខ្លួនក្តី ព្រោះហេតុអ្នកដទៃក្តី ព្រោះហេតុតែសំណូក គឺអាមិសៈបន្តិចបន្តួចក្តី ។ មួយវិញទៀត ជាអ្នកលះបង់នូវបិសុណវាចា វៀរស្រឡះចាកបិសុណ-វាចា គឺឮពាក្យអំពីជននេះ ហើយមិននាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះផង ឮពាក្យអំពីជនឯណោះហើយ មិននាំមកប្រាប់ជនទាំងនេះ ដើម្បីនឹងបំបែកជនឯណោះផង ជាអ្នកផ្សះផ្សានូវពួកជនដែលបែកគ្នាផង ជាអ្នកទំនុកបម្រុងនូវពួកជន ដែលព្រមព្រៀងគ្នាស្រាប់ហើយផង ជាអ្នកត្រេកអរតែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នកមានតម្រេកតែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នករីករាយក្នុងសេចក្តីព្រមព្រៀងគ្នា ពោលនូវវាចាដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀង ដោយប្រការដូច្នេះ ។ ជាអ្នកលះបង់នូវផរុសវាចា វៀរស្រឡះចាកផរុសវាចា គឺវាចាណាមិនមានទោស ជាសុខដល់ត្រចៀក គួរឲ្យកើតសេចក្តីស្រឡាញ់ ចូលទៅកាន់ហឫទ័យ ជាវាចាអ្នកបូរី ជាទីស្រឡាញ់ដល់ជនច្រើន ជាទីពេញចិត្តដល់ជនច្រើន ជាអ្នកពោលនូវវាចាមានសភាពដូច្នោះ ។ ជាអ្នកលះបង់នូវសម្ផប្បលាបៈ វៀរស្រឡះចាកសម្ផប្បលាបៈ ពោលពាក្យត្រូវតាមកាល ពោលពាក្យពិត ពោលពាក្យដែលជាអត្ថ ពោលពាក្យដែលជាធម៌ ពោលពាក្យជាវិន័យ

និធានវតឹ វាចំ ភាសិតា ហោតិ[១] កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ ។ ឯវំ ខោ គហបតយោ ចតុព្វិធំ វាចាយ ធម្មចរិយា សមចរិយា ហោតិ ។ កថញ្ច គហបតយោ តិវិធំ មនសា ធម្មាចរិយា សមចរិយា ហោតិ ។ ឥធ គហបតយោ ឯកច្ចោ អនភិជ្ឈាលុ ហោតិ យន្តំ បរស្ស បរវិត្តូបករណំ តំ នាភិជ្ឈិតា[២] ហោតិ អហោ វត យំ បរស្ស តំ មម អស្សាតិ ។ អព្យាបន្នចិត្តោ ខោ បន ហោតិ អប្បទុដ្ឋមនសង្កប្បោ ឥមេ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តូតិ ។ សម្មាទិដ្ឋិកោ[៣] ខោ បន ហោតិ អវិបរីតទស្សនោ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ អយំ លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ បិតា អត្ថិ សត្តា ឱបបាតិកា អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា

---

១ ឱ. ម. ហោតីតិ ន ទិស្សតិ ។ ២ ឱ. ម. នាភិជ្ឈាតា ។ ៣ ឱ. សម្មាទិដ្ឋិ ។

ពោលពាក្យដែលគួរឲ្យតាំងទុក ក្នុងហឫទ័យ ត្រូវតាមកាល ប្រកប ដោយគ្រឿងអាង ជាវាចាមានទីបំផុត ប្រកបដោយប្រយោជន៍ ។ ម្នាល គហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ដោយ វាចា មាន ៤ ប្រការយ៉ាងនេះឯង ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រ- ព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយចិត្ត មាន ៣ ប្រការដូចម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ មិនច្រើនដោយ អភិជ្ឈា គ្រឿងឧបករណ៍ដែលជាសម្បត្តិ នៃបុគ្គលដទៃណា ក៏មិនគយ គន់នូវគ្រឿងឧបករណ៍នោះថា ឱហ្ន៎ គ្រឿងឧបករណ៍ដែលជាសម្បត្តិនៃ បុគ្គលដទៃណា គ្រឿងឧបករណ៍នោះ គប្បីបានមកអាត្មាអញ ដូច្នេះ ឡើយ ។ មួយទៀត ជាអ្នកមានចិត្តមិនព្យាបាទ មានតម្រិះក្នុងចិត្តដែល ទោសមិនប្រទូស្តហើយថា សត្វទាំងឡាយនេះចូរកុំមានពៀរ កុំមាន ព្យាបាទ កុំមានទុក្ខ រក្សាខ្លួនឲ្យបានសេចក្តីសុខចុះ ។ មួយវិញទៀតជា អ្នកមានគំនិតយល់ត្រូវ ឃើញនូវសេចក្តីមិនវិបរិតថា ទានដែលបុគ្គលឲ្យ ហើយមានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាកនៃ កុសលាកុសលកម្ម ដែលសត្វធ្វើល្អនិងធ្វើអាក្រក់មាន លោកនេះមាន លោកខាងមុខមាន មាតាមានគុណ បិតាមានគុណ សត្វដែលជាឱប- បាតិកៈកំណើតមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកព្រមព្រៀង

សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ ឯវំ ខោ គហបតយោ តិវិធំ មនសា ធម្មចរិយា សមចរិយា ហោតិ ។ ឯវំ ធម្មចរិយាសមចរិយាហេតុ ខោ គហបតយោ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។

[១២៦] អាកង្ខេយ្យចេ គហបតយោ ធម្មចារី សមចារី អហោ វតាហំ កាយស្ស ភេទា បរម្មរណា ខត្តិយមហាសាលានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ កាយស្ស ភេទា បរម្មរណា ខត្តិយមហាសាលានំ សហព្យតំ ឧបបជ្ជេយ្យ តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារី ។ អាកង្ខេយ្យ ចេ គហបតយោ ធម្មចារី សមចារី អហោ វតាហំ កាយស្ស ភេទា បរម្មរណា ព្រាហ្មណមហាសាលានំ ។ បេ ។ គហបតិមហាសាលានំ សហព្យតំ

ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាចំពោះខ្លួនឯង នូវលោកនេះ និងលោកខាងមុខហើយប្រកាសក៏មាន ។ ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយចិត្ត មាន ៣ ប្រការ យ៉ាងនេះឯង ។ ម្នាលគហបតីទាំងឡាយ សត្វទាំងឡាយពួកខ្លះក្នុងលោកនេះ បែកធ្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ចូលទៅកាន់សុគតិ សួគ៌ ទេវលោក យ៉ាងនេះ ព្រោះហេតុតែកិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ យ៉ាងនេះឯង ។

[១២៦] ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកខត្តិយមហាសាល ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកខត្តិយមហាសាលមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកព្រាហ្មណមហាសាល ។ បេ ។ កើតជាមួយ

២៨១

ចូឡយមកវគ្គស្ស សាលេយ្យកសុត្តេ ធម្មចរិយាសមចរិយាផលំ

ឧបបជ្ជេយ្យន្តិ ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ កាយស្ស ភេទា បរម្មរណា គហបតិមហាសាលានំ សហព្យតំ ឧបបជ្ជេយ្យ តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារី ។ អាកង្ខេយ្យ ចេ គហ-បតយោ ធម្មចារី សមចារី អហោ វតាហំ កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារី ។ អាកង្ខេយ្យ ចេ គហប-តយោ ធម្មចារី សមចារី អហោ វតាហំ កាយស្ស ភេទា បរម្មរណា តាវត្តឹសានំ ទេវានំ សហព្យតំ ។ បេ ។ យាមានំ ទេវានំ... តុសិតានំ ទេវានំ... និម្មា-នរតីនំ ទេវានំ... បរនិម្មិតវសវត្តីនំ ទេវានំ... ព្រហ្មកា-

នឹងគហបតិមហាសាល ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបាន សម្រេច ព្រោះថាបុគ្គលនោះ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីម-រណៈ ក៏បានទៅកើតជាមួយនឹងពួកគហបតិមហាសាលមែន សេចក្ដីនោះ ព្រោះហេតុដូចម្ដេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកទេវតា ក្នុង ជាន់ចាតុម្មហារាជិកា ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ លុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ក៏ បានទៅកើតជាមួយនឹងពួកទេវតា ក្នុងជាន់ចាតុម្មហារាជិកាមែន សេចក្ដី នោះ ព្រោះហេតុដូចម្ដេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញ លុះទម្លាយរាង កាយខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកទេវតា ក្នុងជាន់តាវត្តិង្ស ។ បេ ។ ពួកទេវតាជាន់យាមៈ... ពួកទេវតាជាន់តុសិត... ពួកទេវតាជាន់និម្មានរតី... ពួកទេវតាជាន់បរនិម្មិតវសវត្តី... ពួកទេវតាជាន់

យិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ កាយស្ស ភេទា បរម្មរណា ព្រហ្មកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារី ។ អាកង្ខេយ្យ ចេ គហបតយោ ធម្មចារី សមចារី អហោ វតាហំ កាយស្ស ភេទា បរម្មរណា អាភានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ កាយស្ស ភេទា បរម្មរណា អាភានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារី ។ អាកង្ខេយ្យ ចេ គហបតយោ ធម្មចារី សមចារី អហោ វតាហំ កាយស្ស ភេទា បរម្មរណា បរិត្តាភានំ ទេវានំ ។ បេ ។ អប្បមាណាភានំ ទេវានំ... អាភស្សរានំ ទេវានំ... បរិត្តសុភានំ ទេវានំ... អប្បមាណសុភានំ ទេវានំ... សុភកិណ្ហកានំ ទេវានំ... វេហប្ផលានំ ទេវានំ... អវិហានំ ទេវានំ... អតប្បានំ ទេវានំ... សុទស្សានំ ទេវានំ... សុទស្សីនំ ទេវានំ...

ព្រហ្មកាយិកា ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះ លុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកទេវតាជាន់ព្រហ្មកាយិកាមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញ លុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកទេវតាជាន់អាភា ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ លុះបែកធ្លាយរាងកាយខាងមុខ បន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកទេវតាជាន់អាភាមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញ លុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកទេវតាជាន់បរិត្តាភា ។ បេ ។ នឹងពួកទេវតាជាន់អប្បមាណាភា... ពួកទេវតាជាន់អាភស្សរា... ពួកទេវតាជាន់បរិត្តសុភា... ពួកទេវតាជាន់អប្បមាណសុភា... ពួកទេវតាជាន់សុភកិណ្ហកា... ពួកទេវតាជាន់វេហប្ផលា... ពួកទេវតាជាន់អវិហា... ពួកទេវតាជាន់អតប្បា... ពួកទេវតាជាន់សុទស្សា... ពួក

អកនិដ្ឋកានំ ទេវានំ[១]... អាកាសានញ្ចាយតនូបគានំ ទេវានំ... វិញ្ញាណញ្ចាយតនូបគានំ ទេវានំ... អាកិញ្ចញ្ញាយតនូបគានំ ទេវានំ... នេវសញ្ញានាសញ្ញាយតនូបគានំ ទេវានំ... សហព្យតំ ឧបបជ្ជេយ្យន្តិ ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ កាយស្ស ភេទា បរម្មរណា នេវសញ្ញានាសញ្ញាយតនូបគានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារី ។ អាកង្ខេយ្យ ចេ គហបតយោ ធម្មចារី សមចារី អហោ វតាហំ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យ តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារី[២] ។

១ ឱ. ម. អកនិដ្ឋានំ ។ ២ ឱ. ម. សមចារីតិ ។

ទេវតាជាន់សុទស្សី... ពួកទេវតាជាន់អកនិដ្ឋកា... ពួកទេវតាដែលកើតក្នុងអាកាសានញ្ចាយតនៈ... ពួកទេវតាដែលកើតក្នុងវិញ្ញាណញ្ចាយ-តនៈ... ពួកទេវតាដែលកើតក្នុងជាន់អាកិញ្ចញ្ញាយតនៈ... និងពួកទេវតាដែលកើតក្នុងជាន់នេវសញ្ញានាសញ្ញាយតនៈ ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ លុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកទេវតា ដែលកើតក្នុងជាន់នេវសញ្ញានាសញ្ញាយតនៈមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱ ខ្លួនអាត្មាអញសូមឲ្យអស់អាសវៈទាំងឡាយ ហើយធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ដោយប្រាជ្ញាចំពោះខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថាបុគ្គលនោះ នឹងអស់អាសវៈទាំង-ឡាយ ហើយធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិដែលមិនមានអាសវៈ ដោយប្រាជ្ញាចំពោះខ្លួនឯង ក្នុងបច្ចុប្បន្នមែន សេចក្តីនោះព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្តស្មើពោលគឺប្រព្រឹត្តតាមធម៌ ។

[១២៧] ឯវំ វុត្តេ សាលេយ្យកា ព្រាហ្មណគហ-បតិកា ភគវន្តំ ឯតទវោចុំ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯតេ មយំ ភវន្តំ គោតមំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណង្គតេតិ ។

សាលេយ្យកសុត្តំ បឋមំ និដ្ឋិតំ ។

[១២៧] កាលបើព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ពួកព្រាហ្មណ៍និងគហបតី អ្នកនៅក្នុងស្រុកសាលៈ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គ ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើនប្រកាសហើយ ដោយអនេកបរិយាយនេះឯង (ភ្លឺច្បាស់ណាស់) ដូចជាបុគ្គលផ្ងាររបស់ដែលផ្កាប់ ឬដូចជាបុគ្គលបើកបង្ហាញនូវរបស់ដែលកំបាំង ពុំនោះដូចជាបុគ្គលប្រាប់ផ្លូវដល់មនុស្សវង្វេងទិស ពុំនោះសោតដូចគេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែកមើលឃើញរូបទាំងឡាយបាន យើងទាំងឡាយនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹង ទីរលឹកតាំងពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចម្រើនទ្រង់ជ្រាបនូវយើងខ្ញុំទាំងឡាយថាជាឧបាសក អ្នកដល់នូវទីពឹង ស្មើដោយជីវិត ។

ចប់ សាលេយ្យកសូត្រ ទី ១ ។

# ទុតិយំ វេរញ្ជកសុត្តំ

[១២៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន វេរញ្ជកា ព្រាហ្មណគហបតិកា សាវត្ថិយំ បដិវសន្តិ កេនចិទេវ ករណីយេន ។ អស្សោសុំ ខោ វេរញ្ជកា ព្រាហ្មណគហបតិកា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ

# វេរញ្ជកសូត្រ ទី ២

[១២៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏សម័យនោះឯង ពួកព្រាហ្មណ៍និងគហបតីអ្នកស្រុកវេរញ្ជា នៅអាស្រ័យក្នុងក្រុងសាវត្ថី ដោយកិច្ចនីមួយ ។ ពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកវេរញ្ជា បានឮដំណឹងថា ព្រះសមណគោតម ជាសក្យបុត្រ ចេញចាកសក្យត្រកូលទៅបួស ប្រថាប់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ កិត្តិសព្ទដ៏ល្អ នៃព្រះគោ-តមដ៏ចម្រើននោះ ល្បីឮខ្ចរខ្ចាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរបំផុត ព្រះអង្គជាសារថីទូន្មាននូវបុរស ព្រះអង្គជាសាស្តាចារ្យ នៃទេវតានិងមនុស្សទាំងឡាយ ជាព្រះពុទ្ធ ទ្រង់ចែកនូវធម៌ទាំងពួង ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញា ចំពោះព្រះអង្គ នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពួកសត្វ ព្រមទាំងសមណ-ព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ហើយប្រកាស

អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។ អថខោ វេរញ្ជកា ព្រាហ្មណគហបតិកា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ យេន ភគវា តេនញ្ជលិម្បណាមេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតោ សន្តិកេ នាមគោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ វេរញ្ជកា ព្រាហ្មណគហបតិកា ភគវន្តំ ឯតទវោចុំ កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យេនមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ

ទ្រង់សំដែងធម៌ មានលំអបទដើម បទកណ្តាល បទចុង ព្រះអង្គប្រ-កាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថទាំងព្យញ្ជនៈ ដ៏បរិបូណ៌បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានចួបប្រទះនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនេះ ជាការប្រពៃពេក ។ គ្រានោះឯង ពួកព្រាហ្មណ៍និងគហបតីអ្នកស្រុកវេរញ្ជា នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែនិយាយពាក្យសំណេះសំណាល ទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះអង្គុយប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគ ក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែប្រកាសនាមនិងគោត្រ ក្នុងសំណាក់ព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះអង្គុយនៅស្ងៀមក្នុងទីដ៏សមគួរ លុះពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកវេរញ្ជា អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកសត្វខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយ ខាងមុខ អំពីសេចក្តីស្លាប់ទៅកើត ក្នុងកំណើតសត្វតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក

២៤៧

ចូឡយមកវគ្គស្ស វេរញ្ជកសុត្តេ ទស អកុសលកម្មបថា

កោ បន ភោ គោតម ហេតុ កោ បច្ចយោ យេនមិដេ-
កច្ចេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ
លោកំ ឧបបជ្ជន្តីតិ ។ អដម្មចរិយាវិសមចរិយាហេតុ
ខោ គហបតយោ ឯវមិដេកច្ចេ សត្តា កាយស្ស
ភេទា បរម្មរណា អថាយំ ទុគ្គតឹ វិដិថាតំ ដិរយំ ឧប-
បជ្ជន្តិ ជម្មចរិយាសមចរិយាហេតុ ខោ គហបតយោ
ឯវមិដេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា
សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។ ន ខោ មយំ
ឥមស្ស ភោតោ គោតមស្ស សង្ខិត្តេន ភាសិតស្ស
វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ អាជាដាម
សាឌុ ខោ បន ករំ គោតមោ តថា ជម្មំ ដេសេតុ
យថា មយំ ឥមស្ស ភោតោ គោតមស្ស សង្ខិត្តេន
ភាសិតស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ
អាជាដេយ្យាមាតិ ។ តេនហិ គហបតយោ សុណាថ

បពិត្រព្រះគោតមដ៏ចម្រើន មួយទៀត អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកសត្វក្នុងលោកនេះ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ ទៅកើត ក្នុងសុគតិ សួគ៌ ទេវលោក ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលគហបតីទាំងឡាយ ព្រោះហេតុតែការប្រព្រឹត្តមិនស្មើ គឺប្រព្រឹត្តមិនត្រូវធម៌នុ៎ះឯង បានជាពួកសត្វខ្លះ ក្នុងលោកនេះ ដល់បែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត-វិស័យ អសុរកាយ នរក យ៉ាងនេះ ម្នាលគហបតីទាំងឡាយ ព្រោះហេតុតែសេចក្ដីប្រព្រឹត្តស្មើ គឺប្រព្រឹត្តត្រូវគន្លងធម៌ដែលនាំឲ្យពួកសត្វខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក យ៉ាងនេះ ។ ធម៌នេះព្រះគោតមដ៏ចម្រើនបានសំដែងដោយសេចក្ដីបំព្រួញ មិនទាន់ចែករំលែកសេចក្ដីដោយពិស្ដារទេ យើងខ្ញុំមិនទាន់ដឹងសេចក្ដីដោយពិស្ដារឡើយ សូមទ្រង់ព្រះមេត្តាប្រោសព្រះគោតមជាម្ចាស់សំដែងធម៌ ដែលព្រះគោតមជាម្ចាស់ សំដែងដោយសេចក្ដីសង្ខេប មិនទាន់ចែករំលែកសេចក្ដីពិស្ដារនៅឡើយនេះ ឲ្យយើងខ្ញុំបានយល់សេចក្ដីច្បាស់លាស់ ដោយពិស្ដារឲ្យទាន ។ ម្នាលគហបតីទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយប្រុងចាំស្ដាប់ចុះ ចូរធ្វើ

សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ វេរញ្ជកា ព្រាហ្មណគហបតិកា ភគវតោ បច្ចស្សោសុំ ។

[១២៩] ភគវា ឯតទវោច តិវិធំ ខោ គហបតយោ កាយេន អធម្មចារី វិសមចារី ហោតិ ចតុព្វិធំ វាចាយ អធម្មចារី វិសមចារី ហោតិ តិវិធំ មនសា អធម្មចារី វិសមចារី ហោតិ ។ កថញ្ច គហបតយោ តិវិធំ កាយេន អធម្មចារី វិសមចារី ហោតិ ។ ឥធ គហ-បតយោ ឯកច្ចោ បាណាតិបាតី ហោតិ លុទ្ទោ លោហិតបាណី ហតប្បហតេ និវិដ្ឋោ អលជ្ជី អទ-យាបន្នោ(១) សព្វបាណភូតេសុ ។ អទិន្នាទាយី ខោ បន ហោតិ យន្តំ បរស្ស បរវិត្តូបករណំ តំ អទិន្នំ ថេយ្យសង្ខាតំ អាទាតា ហោតិ ។ កាមេសុ មិច្ឆាចារី

១ ម. លុទ្ទោ ទារុណោ លោហិតបាណី ហតប្បហតេ និវិដ្ឋោ អទយាបន្នោតិ ទិស្សន្តិ ។

ទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ពួកព្រាហ្មណ៍និង គហបតី អ្នកស្រុកវេរញ្ជា ទទួលតបព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[១២៩] ព្រះមានព្រះភាគ បានត្រាស់យ៉ាងនេះថា ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងកាយ ៣ ចំណែក បុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងវាចា ៤ ចំណែក បុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងចិត្ត ៣ ចំណែក ។ ម្នាលគហបតីទាំងឡាយ ចុះបុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងកាយ ៣ ចំណែក តើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ប្រព្រឹត្តអាក្រក់ មានដៃប្រឡាក់ឈាម ជាអ្នកស្និទ្ធចិត្ត ក្នុងការសម្លាប់សត្វ ឥតមានសេចក្តីអៀនខ្មាស ឥតមានមេត្តាត្រាប្រណីចំពោះពួកសត្វដែលមានជីវិតទាំងអស់ ។ ជាអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យ ជាអ្នកកាន់យកទ្រព្យ ដែលជាគ្រឿងប្រើប្រាស់របស់បុគ្គលដទៃ ដែលគេមិនបានឲ្យជាចំណែកនៃថេយ្យចិត្ត ។ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ

ខោ បន ហោតិ យា តា មាតុរក្ខិតា ។ បេ ។ តថារូបាសុ ចារិត្តំ អាបជ្ជិតា ហោតិ ។ ឯវំ ខោ គហបតយោ តិវិធំ កាយេន អធម្មចារី វិសមចារី ហោតិ ។ កថញ្ច គហបតយោ ចតុព្វិធំ វាចាយ អធម្មចារី វិសមចារី ហោតិ ឥធ គហបតយោ ឯកច្ចោ មុសាវាទី ហោតិ ។ បេ ។ សម្បជានមុសា ភាសិតា ហោតិ ។ បិសុណាវាចោ ខោ បន ហោតិ ឥតោ សុត្វា អមុត្រ អក្ខាតា ។ បេ ។ វគ្គករណឹ វាចំ ភាសិតា ហោតិ ។ ផរុសវាចោ ខោ បន ហោតិ យា សា វាចា អណ្ឌកា[១] កក្កសា ។ បេ ។ តថារូបឹ វាចំ ភាសិតា ហោតិ ។ សម្ផប្បលាបី ខោ បន ហោតិ អកាលវាទី អភូតវាទី ។ បេ ។ អបរិយន្ត-វតឹ អនត្ថសញ្ហិតំ ។ ឯវំ ខោ គហបតយោ ចតុព្វិធំ វាចាយ អធម្មចារី វិសមចារី ហោតិ ។ កថញ្ច គហ-បតយោ តិវិធំ មនសា អធម្មចារី វិសមចារី ហោតិ ។ ឥធ គហបតយោ ឯកច្ចោ អភិជ្ឈាលុ ហោតិ ។ បេ ។

១ ម. គណ្ឋកា ។

ពួកស្ត្រីណាដែលមាតាគ្រប់គ្រងរក្សា ។ បេ ។ ជាអ្នកដល់នូវការប្រព្រឹត្ត ល្មើសចំពោះស្ត្រីដែលមានសភាពយ៉ាងនោះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើ ខាងកាយ ៣ ចំណែក យ៉ាងនេះឯង ។ ម្នាលគហបតីទាំងឡាយ ចុះបុគ្គលប្រព្រឹត្តមិនត្រូវ គន្លងធម៌ ប្រព្រឹត្តមិនស្មើខាងវាចា ៤ ចំណែក តើដូចម្តេច ។ ម្នាល គហបតីទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកនិយាយពាក្យ កុហក ។ បេ ។ និយាយកុហកទាំងដឹងខ្លួន ។ ជាអ្នកមានសំដីញុះញង់ គឺឮដំណឹងអំពីទីនេះទៅប្រាប់ក្នុងទីឯណោះ ។ បេ ។ ជាអ្នកនិយាយពាក្យ ដែលធ្វើឲ្យគេបែកគ្នាជាពួក ។ ជាអ្នកមានសំដីអាក្រក់ វាចាណាដែល កន្លួលចិត្ត ទាំងរបឹងរីងរូស ។ បេ ។ ជាអ្នកនិយាយពាក្យមានសភាព ដូច្នោះ ។ ជាអ្នកមានសំដីឥតប្រយោជន៍ និយាយពាក្យ ក្នុងកាល មិនគួរ និយាយពាក្យមិនពិត ។ បេ ។ និយាយពាក្យឥតមានកំណត់ មិនប្រកបដោយប្រយោជន៍ ។ ម្នាលគហបតីទាំងឡាយ បុគ្គល ប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងវាចា ៤ ចំណែក យ៉ាងនេះ ឯង ។ ម្នាលគហបតីទាំងឡាយ ចុះបុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងចិត្ត ៣ ចំណែក តើដូចម្តេច ។ ម្នាលគហបតីទាំង-ឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានចិត្តសំឡឹងរំពៃ ។ បេ ។

តំ មម អស្សាតិ ។ ព្យាបន្នចិត្តោ ខោ បន ហោតិ បទុដ្ឋមនសង្កប្បោ ឥមេ សត្តា ហញ្ញន្តុ វា ។ បេ ។ មា វា អហេសុន្តិ ។ មិច្ឆាទិដ្ឋិកោ ខោ បន ហោតិ វិបរីតទស្សនោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ ។ បេ ។ សច្ឆិកត្វា បវេទេន្តីតិ ។ ឯវំ ខោ គហបតយោ តិវិធំ មនសា អធម្មចារី វិសមចារី ហោតិ ។ ឯវំ អធម្មចរិយាវិសមចរិយាហេតុ ខោ គហបតយោ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។

[១៣០] តិវិធំ ខោ បន គហបតយោ កាយេន ធម្មចារី សមចារី ហោតិ ចតុព្វិធំ វាចាយ ធម្មចារី សមចារី ហោតិ តិវិធំ មនសា ធម្មចារី សមចារី ហោតិ ។ កថញ្ច គហបតយោ តិវិធំ កាយេន ធម្មចារី សមចារី ហោតិ ។ ឥធ គហបតយោ

ដោយការបង្អោនចិត្តទៅថា វត្ថុនោះគប្បីបានមកជារបស់អញ ។ បុគ្គលមានចិត្តព្យាបាទ ជាអ្នកមានសេចក្ដីត្រិះរិះ ដោយចិត្តដែលទោសប្រទូស្ត ហើយថា សត្វទាំងនេះចូរវិនាសទៅឬ ។ បេ ។ ដែលមិនវិនាសកុំបីមានឡើយ ។ បុគ្គលជាមិច្ឆាទិដ្ឋិមានសេចក្ដីឃើញវិបរិតថា ទានដែលបុគ្គលឲ្យ មិនមានផល បូជាធំមិនមានផល បូជាតូចមិនមានផល ។ បេ ។ ប្រកាសឲ្យជាក់ច្បាស់ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងចិត្ត ៣ ចំណែក យ៉ាងនេះឯង ។ ម្នាលគហបតីទាំងឡាយ ព្រោះហេតុតែការប្រព្រឹត្តមិនស្មើ គឺប្រព្រឹត្តមិនត្រូវគន្លងធម៌ បានជាពួកសត្វខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយនិងនរក យ៉ាងនេះ ។

[១៣០] ម្នាលគហបតីទាំងឡាយ ចំណែកខាងបុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើខាងកាយ ៣ ចំណែក បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើខាងវាចា ៤ ចំណែក បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើខាងចិត្ត ៣ ចំណែក ដូចគ្នាដែរ ។ ម្នាលគហបតីទាំងឡាយ ចុះបុគ្គលប្រព្រឹត្តធម៌ប្រប្រព្រឹត្តស្មើខាងកាយ ៣ ចំណែក តើដូចម្ដេច ។ ម្នាលគហបតីទាំងឡាយ

ឯកច្ចោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរ-
តោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ ។ បេ ។ សព្វ-
ប្បាណភូតហិតានុកម្បី វិហរតិ ។ អទិន្នាទានំ
បហាយ អទិន្នាទានា បដិវិរតោ ហោតិ យន្តំ បរស្ស
បរវិត្តូបករណំ ន តំ អទិន្នំ[១] ថេយ្យសង្ខាតំ អាទាតា
ហោតិ ។ កាមេសុ មិច្ឆាចារំ បហាយ ។ បេ ។
តថារូបាសុ ន ចារិត្តំ អាបជ្ជិតា ហោតិ ។ ឯវំ ខោ
គហបតយោ តិវិធំ កាយេន ធម្មចារី សមចារី ហោ-
តិ ។ កថញ្ច គហបតយោ ចតុព្វិធំ វាចាយ ធម្ម-
ចារី សមចារី ហោតិ ។ ឥធ គហបតយោ ឯកច្ចោ
មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ ស-
ភគ្គតោ វា[២] ។ បេ ។ ន សម្បជានមុសា ភាសិតា
ហោតិ ។ បិសុណំ វាចំ បហាយ បិសុណាយ វាចា-
យ បដិវិរតោ ។ បេ ។ សមគ្គករណឹ វាចំ ភាសិតា
ហោតិ ។ ផរុសំ វាចំ បហាយ ។ បេ ។

១ ម. តំ នាទិន្នំ ។ ២ ម. សភាគ្គតោ វា ។

បុគ្គលពួកខ្លះ ក្នុងលោកនេះ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត មានអាជ្ញាដាក់ចោលហើយ មានគ្រឿងសស្ត្រាដាក់ចោលហើយ ។ បេ ។ ជាអ្នកអនុគ្រោះដោយប្រយោជន៍ចំពោះសត្វដែលមានជីវិតទាំងអស់ ។ លះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន មិនបានកាន់យកទ្រព្យដែលជាគ្រឿងប្រើប្រាស់ របស់ជនឯទៀត ដែលគេមិនបានឲ្យជាចំណែកនៃថេយ្យចិត្ត ។ លះបង់កាមេសុមិច្ឆាចារ ។ បេ ។ ជាអ្នកមិនដល់នូវការប្រព្រឹត្តចំពោះពួកស្ត្រីដែលមានសភាពយ៉ាងនោះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលដែលប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើខាងកាយ ៣ ចំណែក យ៉ាងនេះឯង ។ ម្នាលគហបតីទាំងឡាយ ចុះបុគ្គលប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើខាងវាចា ៤ ចំណែក តើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ លះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ ទោះឋិតនៅក្នុងរោងប្រជុំក្តី ។ បេ ។ មិននិយាយកុហកទាំងដឹងខ្លួន ។ លះបង់ពាក្យញុះញង់ វៀរស្រឡះចាកពាក្យញុះញង់ ។ បេ ។ និយាយតែពាក្យដែលធ្វើឲ្យគេព្រមព្រៀងគ្នា ។ លះបង់ពាក្យអាក្រក់ ។ បេ ។

តថារូបឹ វាចំ ភាសិតា ហោតិ ។ សម្ផប្បលាបំ បហាយ ។ បេ ។ កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ ។ ឯវំ ខោ គហបតយោ ចតុព្វិធំ វាចាយ ធម្មចារី សមចារី ហោតិ ។ កថញ្ច គហបតយោ តិវិធំ មនសា ធម្មចារី សមចារី ហោតិ ។ ឥធ គហបតយោ ឯកច្ចោ អនភិជ្ឈាលុ ហោតិ យន្តំ បរស្ស បរវិត្តូបករណំ តំ នាភិជ្ឈិតា ហោតិ អហោ វត យំ បរស្ស តំ មម អស្សាតិ ។ អព្យាបន្នចិត្តោ ខោ បន ហោតិ អប្បទុដ្ឋមនសង្កប្បោ ឥមេ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តូតិ ។ សម្មាទិដ្ឋិកោ ខោ បន ហោតិ អវិបរីតទស្សនោ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ ។ បេ ។ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។

និយាយតែពាក្យមានសភាពដូច្នោះ ។ លះបង់ពាក្យរោយរាយឥតប្រ-យោជន៍ ។ បេ ។ ប្រកបដោយគ្រឿងអាង ពាក្យមានកំណត់ ពាក្យប្រកបដោយប្រយោជន៍ ដោយកាលគួរ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើខាងវាចា ៤ ចំណែក យ៉ាងនេះឯង ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើខាងចិត្ត ៣ ចំណែក តើដូចម្ដេច ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនរំពៃចង់បានទ្រព្យគេ មិនសំឡឹងចង់បានទ្រព្យរបស់ដែលជាគ្រឿងប្រើប្រាស់ របស់គេ ដោយគិតថា ធ្វើដូចម្ដេចហ្ន៎ ទ្រព្យរបស់អ្នកដទៃនោះ គប្បីបានមក ជារបស់អញដូច្នេះ ។ ជាអ្នកមានចិត្តមិនបានព្យាបាទ មានសេចក្ដីត្រិះរិះដោយចិត្តដែលទោសមិនប្រទូស្ដហើយថា សូមឲ្យសត្វទាំងនេះ កុំមានពៀរ កុំបៀតបៀនគ្នា កុំមានទុក្ខចូររក្សាខ្លួនប្រាណឲ្យបានសេចក្ដីសុខចុះ ។ ជាអ្នកសម្មាទិដ្ឋិ មានសេចក្ដីយល់មិនវិបរិតថា ទានដែលបុគ្គលឲ្យហើយមានផល បូជាធំក៏មានផល ។ បេ ។ ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែង ដោយខ្លួនឯង ។

ឯវំ ខោ គហបតយោ តិវិធំ មនសា ធម្មចារី សមចារី ហោតិ ។ ឯវំ ធម្មចរិយាសមចរិយាហេតុ ខោ គហបតយោ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។

[១៣១] អាកង្ខេយ្យ ចេ គហបតយោ ធម្មចារី សមចារី អហោ វតាហំ កាយស្ស ភេទា បរម្មរណា ខត្តិយមហាសាលានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ កាយស្ស ភេទា បរម្មរ-ណា ខត្តិយមហាសាលានំ សហព្យតំ ឧបបជ្ជេយ្យ តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារី ។ អាកង្ខេយ្យ ចេ គហបតយោ ធម្មចារី សមចារី អហោ វតាហំ កាយស្ស ភេទា បរម្មរណា ព្រាហ្ម-ណមហាសាលានំ ។ បេ ។ គហបតិមហាសាលានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ កាយស្ស ភេទា បរម្មរណា គហបតិមហាសាលានំ សហព្យតំ ឧបបជ្ជេយ្យ

ម្នាលគហបតីទាំងឡាយ បុគ្គលប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើខាងចិត្ត ៣ ចំណែក យ៉ាងនេះឯង ។ ម្នាលគហបតីទាំងឡាយ ព្រោះសេចក្តីប្រព្រឹត្តស្មើ គឺប្រព្រឹត្តធម៌ជាហេតុយ៉ាងនេះឯង បានជាពួកសត្វខ្លះ ក្នុងលោកនេះ ដល់បែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក យ៉ាងនេះ ។

[១៣១] ម្នាលគហបតីទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រសិនបើប្រាថ្នាថា ឱហ្ន៎ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ទៅ សូមឲ្យអាត្មាអញ បានទៅកើតជាមួយនឹងពួកខត្តិយមហាសាលដូច្នេះ ហេតុនុ៎ះឯងរមែងមាន បុគ្គលនោះលុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ទៅ មុខជានឹងបានទៅកើតជាមួយនឹងពួកខត្តិយមហាសាលបានមែន ដំណើរនោះតើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ដោយពិត ។ ម្នាលគហបតីទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ បើប្រសិនជាប្រាថ្នាថា ឱហ្ន៎ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ទៅ សូមឲ្យអាត្មាអញបានទៅកើតជាមួយនឹងពួកព្រាហ្មណមហាសាល ។ បេ ។ ពួកគហបតីមហាសាលដូច្នេះ ហេតុនុ៎ះឯងរមែងមាន បុគ្គលនោះលុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ទៅ មុខជានឹងបានទៅកើតជាមួយនឹងពួកគហបតីមហា-

តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារី ។ អាកង្ខេយ្យ ចេ គហបតយោ ធម្មចារី សមចារី អហោ វតាហំ កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិ-កានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារី ។ អាកង្ខេយ្យ ចេ គហបតយោ ធម្មចារី សមចារី អហោ វតាហំ កាយស្ស ភេទា បរម្មរណា តាវត្តឹសានំ ទេវានំ ។ បេ ។ យាមានំ ទេវានំ... តុសិតានំ ទេវានំ... និម្មានរតីនំ ទេវានំ... បរនិម្មិតវសវត្តីនំ ទេវានំ... ព្រហ្ម-កាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ កាយស្ស ភេទា បរម្មរណា ព្រហ្មកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារី ។

សាលបានមែន ដំណើរនោះតើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះឯង ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើដោយពិត ។ ម្នាលគហបតីទាំង-ឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ បើប្រសិនជាប្រាថ្នាថា ឱហ្ន៎ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ សូមឲ្យអាត្មាអញបានទៅកើតជាមួយនឹងទេវតាជាន់ចាតុម្មហារាជិកៈដូច្នេះ ហេតុនុ៎ះឯង រមែងមានដ្បិតបុគ្គលនោះលុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ទៅ មុខជានឹងបានទៅកើតជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិកៈបានមែន ដំណើរនោះតើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើដោយពិត ។ ម្នាលគហបតីទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ បើប្រសិនជាប្រាថ្នាថា ឱហ្ន៎ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ទៅ សូមឲ្យអាត្មាអញបានទៅកើតជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។ បេ ។ ពួកទេវតាជាន់យាមៈ... ពួកទេវតាជាន់តុសិតៈ... ពួកទេវតាជាន់និម្មានរតី... ពួកទេវតាជាន់បរនិម្មិតវសវត្តី... ពួកទេវតាដែលរាប់ចូលក្នុងព្រហ្មដូច្នេះ ហេតុនុ៎ះឯងរមែងមាន ដ្បិតបុគ្គលនោះ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ទៅ មុខជានឹងបានទៅកើតជាមួយនឹងពួកទេវតា ដែលរាប់ចូលក្នុងពួកព្រហ្មបានមែន ដំណើរនោះតើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើដោយពិត ។

២៦៤

ចូឡយមកវគ្គស្ស វេរញ្ជកសុត្តេ ធម្មចរិយាសមចរិយាផលំ

អាកង្ខេយ្យ ចេ គហបតយោ ធម្មចារី សមចារី អហោ វតាហំ កាយស្ស ភេទា បរម្មរណា អាភានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ កាយស្ស ភេទា បរម្មរណា អាភានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារី ។ អាកង្ខេយ្យ ចេ គហបតយោ ធម្មចារី សមចារី អហោ វតាហំ កាយស្ស ភេទា បរម្មរណា បរិត្តាភានំ ទេវានំ ។ បេ ។ អប្បមាណាភានំ ទេវានំ... អាភស្សរានំ ទេវានំ... បរិត្តសុភានំ ទេវានំ... អប្បមាណសុភានំ ទេវានំ... សុភកិណ្ហកានំ ទេវានំ... វេហប្ផលានំ ទេវានំ... អវិហានំ ទេវានំ... អតប្បានំ ទេវានំ... សុទស្សានំ ទេវានំ... សុទស្សីនំ ទេវានំ... អកនិដ្ឋកានំ ទេវានំ... អាកាសានញ្ចាយតនូបគានំ ទេវានំ... វិញ្ញាណញ្ចាយតនូបគានំ ទេវានំ... អាកិញ្ចញ្ញាយតនូបគានំ ទេវានំ... នេវសញ្ញានាសញ្ញាយតនូបគានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ

ម្នាលគហបតីទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ បើប្រសិនជាប្រាថ្នាថា ឱហ្ន៎ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ទៅ សូមឲ្យអាត្មាអញបានទៅកើតជាមួយនឹងពួកទេវតាជាន់អាភាដូច្នេះ ហេតុនុ៎ះឯងរមែងមាន ដ្បិតបុគ្គលនោះលុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ទៅ មុខជានឹងបានទៅកើតជាមួយនឹងពួកទេវតាជាន់អាភាបានមែនដំណើរនោះ តើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះ ជាអ្នកប្រព្រឹត្តធម៌ប្រព្រឹត្តស្មើដោយពិត ។ ម្នាលគហបតីទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ បើប្រសិនជាប្រាថ្នាថា ឱហ្ន៎ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ទៅ សូមឲ្យអាត្មាអញ បានទៅកើតជាមួយនឹងពួកទេវតាជាន់បរិត្តាភៈ ។ បេ ។ ពួកទេវតាជាន់អប្បមាណាភៈ... ពួកទេវ-តាជាន់អាភស្សរៈ... ពួកទេវតាជាន់បរិត្តសុភៈ... ពួកទេវតាជាន់អប្បមា-ណសុភៈ... ពួកទេវតាជាន់សុភកិណ្ហកៈ... ពួកទេវតាជាន់វេហប្ផលៈ... ពួកទេវតាជាន់អវិហៈ... ពួកទេវតាជាន់អតប្បៈ... ពួកទេវតាជាន់សុទ-ស្សៈ... ពួកទេវតាជាន់សុទស្សី... ពួកទេវតាជាន់អកនិដ្ឋកៈ... ពួកទេវតាជាអ្នកទៅកើតក្នុងអាកាសានញ្ចាយតនភព... ពួកទេវតាជាអ្នកទៅកើតក្នុងវិញ្ញាណញ្ចាយតនភព... ពួកទេវតាជាអ្នកទៅកើតក្នុងអាកិញ្ចញ្ញាយតន-ភព... ពួកទេវតាជាអ្នកទៅកើតក្នុងនេវសញ្ញានាសញ្ញាយតនភព ដូច្នេះ

ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ កាយស្ស ភេទា បរម្មរណា នេវសញ្ញានាសញ្ញាយតនូបគានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារី ។ អាកង្ខេយ្យ ចេ គហបតយោ ធម្មចារី សមចារី អហោ វតាហំ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ ឋានំ ខោ បនេតំ វិជ្ជតិ យំ សោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេ វ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យ តំ កិស្ស ហេតុ តថា ហិ សោ ធម្មចារី សមចារីតិ ។

[១៣២] ឯវំ វុត្តេ វេរញ្ជកា ព្រាហ្មណគហបតិកា ភគវន្តំ ឯតទវោចុំ អភិក្កន្តំ ភោ គោតម

ហេតុនុ៎ះឯងរមែងមាន ដ្បិតបុគ្គលនោះលុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងពួកទេវតាជាន់នេវសញ្ញានាសញ្ញាយតនភព បានមែន ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើដោយពិត ។ ម្នាលគហបតីទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ បើប្រសិនជាប្រាថ្នាថា ឱហ្ន៎ អាត្មាអញគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញារបស់ខ្លួនចំពោះចេតោ-វិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំង-ឡាយក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ដូច្នេះ ហេតុនោះឯងរមែងមាន ដ្បិតបុគ្គលនោះគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រា-ជ្ញារបស់ខ្លួន ចំពោះចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់ទៅនៃអាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ បានមែន ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះ ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើដោយពិត ។

[១៣២] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ពួកព្រាហ្មណ៍និងគហបតីទាំងឡាយ អ្នកស្រុកវេរញ្ជា ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ភាសិតដែលព្រះអង្គ

២៦៧

ចូឡយមកវគ្គស្ស   វេរញ្ជកសុត្តេ   បាណុបេតសរណគតតា

អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯតេ មយំ ភវន្តំ គោតមំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណាគតេតិ ។

វេរញ្ជកសុត្តំ ទុតិយំ និដ្ឋិតំ ។

សំដែងហើយ ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភាសិតដែលព្រះអង្គសំដែងហើយ ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (គឺច្បាស់ណាស់) ដូចបុគ្គលចាប់ផ្ងាររបស់ដែលផ្កាប់ ឬក៏ដូចជាគេបើកបង្ហាញ របស់ដែលកំបាំង ពុំនោះដូចបុគ្គលប្រាប់ផ្លូវ ដល់មនុស្សវង្វេងទិស ពុំនោះសោតដូចជាបុគ្គលទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានភ្នែកភ្លឺឃើញរូបបានយ៉ាងនោះឯង ពួកខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីរលឹក សូមព្រះគោតមចាំទុកនូវពួកខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវសរណៈ ស្មើដោយជីវិតចាប់ដើមតាំងពីថ្ងៃនេះជាដើមទៅ ។

ចប់ វេរញ្ជកសូត្រ ទី ១០ ។

# តតិយំ មហាវេទល្លសុត្តំ

[១៣៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា មហាកោដ្ឋិកោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

[១៣៤] ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាកោដ្ឋិកោ អាយស្មន្តំ សារីបុត្តំ ឯតទវោច ទុប្បញ្ញោ ទុប្បញ្ញោតិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ ទុប្បញ្ញោតិ វុច្ចតីតិ ។ នប្បជានាតិ នប្បជានាតីតិ ខោ អាវុសោ តស្មា ទុប្បញ្ញោតិ វុច្ចតិ កិញ្ច នប្បជានាតិ ឥទំ ទុក្ខន្តិ នប្បជានាតិ

# មហាវេទល្លសូត្រ ទី ៣

[១៣៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមហាកោដ្ឋិកៈមានអាយុ ចេញអំពីផលសមាបត្តិ ក្នុងសាយណ្ហសម័យ ហើយចូលទៅរកព្រះសារីបុត្រមានអាយុ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យរាក់ទាក់ សំណេះសំណាល ទៅរកព្រះសារីបុត្រមានអាយុ លុះបញ្ចប់ពាក្យសំណេះសំណាល និងពាក្យដែលគួររលឹកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។

[១៣៤] លុះព្រះមហាកោដ្ឋិកៈមានអាយុ គង់ក្នុងទីដ៏សមគួរហើយ ទើបសួរព្រះសារីបុត្រមានអាយុ យ៉ាងនេះថា ម្នាលអាវុសោ គេតែងនិយាយថា បុគ្គលគ្មានប្រាជ្ញា ៗ ម្នាលអាវុសោ បុគ្គលដែលហៅថា អ្នកគ្មានប្រាជ្ញា តើដោយហេតុដូចម្តេច ។ ព្រះសារីបុត្រតបថា ម្នាលអាវុសោ បុគ្គលដែលមិនចេះមិនដឹងច្បាស់ហ្នឹងឯង ហៅថាអ្នកគ្មានប្រាជ្ញា ចុះបុគ្គលនោះមិនដឹងច្បាស់នូវអ្វី មិនដឹងច្បាស់ថា នេះទុក្ខ

២៦៩



អយំ ទុក្ខសមុទយោតិ នប្បជានាតិ អយំ ទុក្ខនិរោធោតិ នប្បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ នប្បជានាតិ នប្បជានាតិ នប្បជានាតីតិ ខោ អាវុសោ តស្មា ទុប្បញ្ញោតិ វុច្ចតីតិ ។ សាធាវុសោតិ ខោ អាយស្មា មហាកោដ្ឋិកោ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា អាយស្មន្តំ សារីបុត្តំ ឧត្តរឹ បញ្ហំ អបុច្ឆិ បញ្ញវា បញ្ញវាតិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ បញ្ញវាតិ វុច្ចតីតិ ។ បជានាតិ បជានាតីតិ ខោ អាវុសោ តស្មា បញ្ញវាតិ វុច្ចតិ កិញ្ច បជានាតិ ឥទំ ទុក្ខន្តិ បជានាតិ អយំ ទុក្ខសមុទយោតិ បជានាតិ អយំ ទុក្ខនិរោធោតិ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ បជានាតិ បជានាតិ បជានាតីតិ ខោ អាវុសោ តស្មា បញ្ញវាតិ វុច្ចតីតិ ។ វិញ្ញាណំ វិញ្ញាណន្តិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ វិញ្ញាណន្តិ វុច្ចតីតិ ។ វិជានាតិ វិជានាតីតិ ខោ អាវុសោ តស្មា វិញ្ញាណន្តិ វុច្ចតិ

មិនដឹងច្បាស់ថា នេះហេតុឲ្យកើតទុក្ខ មិនដឹងច្បាស់ថា នេះជាគ្រឿងរំលត់ទុក្ខ មិនដឹងច្បាស់ថា នេះជាសេចក្តីប្រតិបត្តិដែលជាដំណើរទៅកាន់ទីរំលត់ទុក្ខ ម្នាលអាវុសោ ព្រោះតែបុគ្គលនោះ មិនចេះមិនដឹងដូច្នេះឯង ទើបហៅថា អ្នកគ្មានប្រាជ្ញា ។ ព្រះមហាកោដ្ឋិកៈមានអាយុក៏ត្រេកអរអនុមោទនាចំពោះភាសិត របស់ព្រះសារីបុត្រមានអាយុ ថា ម្នាលអាវុសោ ពីរោះណាស់ លុះអនុមោទនាហើយ ទើបសួរប្រស្នានឹងព្រះសារីបុត្រមានអាយុតទៅទៀតថា ម្នាលអាវុសោ គេតែងនិយាយថា អ្នកមានប្រាជ្ញា ៗ ម្នាលអាវុសោ ចុះបុគ្គលដែលហៅថា អ្នកមានប្រាជ្ញា តើដោយហេតុដូចម្តេចខ្លះ ។ ព្រះសារីបុត្រតបថា ម្នាលអាវុសោ បុគ្គលដែលចេះដឹងច្បាស់ហ្នឹងឯង ដែលហៅថា អ្នកមានប្រាជ្ញា ចុះបុគ្គលនោះដឹងច្បាស់នូវអ្វី ដឹងច្បាស់ថា នេះទុក្ខ ដឹងច្បាស់ថា នេះជាហេតុឲ្យកើតទុក្ខ ដឹងច្បាស់ថា នេះជាគ្រឿងរំលត់ទុក្ខ ដឹងច្បាស់ថា នេះជាសេចក្តីប្រតិបត្តិដែលជាដំណើរទៅកាន់ទីរំលត់ទុក្ខ ម្នាលអាវុសោ ព្រោះតែបុគ្គលនោះដឹងច្បាស់ដូច្នេះឯង ទើបហៅថា អ្នកមានប្រាជ្ញា ។ ម្នាលអាវុសោ គេតែងហៅថា វិញ្ញាណ វិញ្ញាណ ម្នាលអាវុសោ ចុះធម្មជាតដែលគេហៅថា វិញ្ញាណ តើដូចម្តេច ។ ម្នាលអាវុសោ ធម្មជាតដែលស្គាល់ច្បាស់ ដឹងច្បាស់នុ៎ះឯង ដែលគេហៅថា វិញ្ញាណ

កិញ្ច វិជានាតិ សុខន្តិបិ វិជានាតិ ទុក្ខន្តិបិ វិជានាតិ អទុក្ខមសុខន្តិបិ វិជានាតិ វិជានាតិ វិជានាតីតិ ខោ អាវុសោ តស្មា វិញ្ញាណន្តិ វុច្ចតីតិ ។ យា ចាវុសោ បញ្ញា យញ្ច វិញ្ញាណំ ឥមេ ធម្មា សំសដ្ឋា ឧទាហុ វិសំសដ្ឋា លព្ភា ច បនិមេសំ ធម្មានំ វិនិព្ភុជិត្វា វិនិព្ភុជិត្វា នានាករណំ បញ្ញាបេតុន្តិ ។ យា ចាវុសោ បញ្ញា យញ្ច វិញ្ញាណំ ឥមេ ធម្មា សំសដ្ឋា នោ វិសំសដ្ឋា ន ច លព្ភា ឥមេសំ ធម្មានំ វិនិព្ភុជិត្វា វិនិព្ភុជិត្វា នានាករណំ បញ្ញាបេតុំ យញ្ច អាវុសោ បជានាតិ តំ វិជានាតិ យំ វិជានាតិ តំ បជានាតិ តស្មា ឥមេ ធម្មា សំសដ្ឋា នោ វិសំសដ្ឋា ន ច លព្ភា ឥមេសំ ធម្មានំ វិនិព្ភុជិត្វា វិនិព្ភុជិត្វា នានាករណំ បញ្ញាបេតុន្តិ ។ យា ចាវុសោ បញ្ញា យញ្ច វិញ្ញាណំ ឥមេសំ ធម្មានំ សំសដ្ឋានំ នោ វិសំសដ្ឋានំ កឹ នានាករណន្តិ ។

ចុះវិញ្ញាណនោះស្គាល់អ្វីខ្លះ ស្គាល់ថាសុខខ្លះ ស្គាល់ថាទុក្ខខ្លះ ស្គាល់ថាមិនមែនទុក្ខមិនមែនសុខខ្លះ ម្នាលអាវុសោ ព្រោះតែធម្មជាតនោះស្គាល់ច្បាស់ ដឹងច្បាស់ដូច្នេះឯង ទើបហៅថា វិញ្ញាណ ។ ម្នាលអាវុសោ ចុះប្រាជ្ញានិងវិញ្ញាណ ធម៌ (ទាំងពីរ) នេះតើដូចគ្នា[១]ឬផ្សេងគ្នា មួយទៀត បុគ្គលចែករំលែកធម៌ (ទាំងពីរ) នេះ បញ្ញត្តឲ្យផ្សេង ៗ គ្នាបានឬទេ ។ ម្នាលអាវុសោ ប្រាជ្ញានិងវិញ្ញាណ ធម៌ (ទាំងពីរ) នេះ ជាធម៌ដូចគ្នា មិនមែនផ្សេងគ្នាទេ ទាំងបុគ្គលនឹងចែករំលែកបញ្ញត្តធម៌ទាំងពីរនេះ ឲ្យផ្សេងគ្នាមិនបានទេ ម្នាលអាវុសោ ប្រាជ្ញាដឹងច្បាស់នូវវត្ថុណា វិញ្ញាណក៏ដឹងច្បាស់នូវវត្ថុនោះដែរ វិញ្ញាណស្គាល់ច្បាស់នូវវត្ថុណា ប្រាជ្ញាក៏ដឹងច្បាស់នូវវត្ថុនោះដែរ ព្រោះហេតុនោះ បានជាធម៌ (ទាំងពីរ) នេះ ជាធម៌ដូចគ្នា មិនមែនផ្សេងគ្នាទេ ទាំងបុគ្គលនឹងចែករំលែក បញ្ញត្តធម៌ទាំងពីរនេះ ឲ្យផ្សេងគ្នាមិនបានឡើយ ។ ម្នាលអាវុសោ បើប្រាជ្ញានិងវិញ្ញាណ ធម៌ (ទាំងពីរ) នេះដូចគ្នា មិនមែនផ្សេងគ្នាទេ ចុះសេចក្តីប្លែកគ្នាត្រង់ណា ។

---

១ សំដៅសេចក្តីថា កើតរលត់ ទាំងមានវត្ថុមានអារម្មណ៍ជាមួយគ្នា ។

យា ចាវុសោ បញ្ញា យញ្ច វិញ្ញាណំ ឥមេសំ ធម្មានំ សំសដ្ឋានំ នោ វិសំសដ្ឋានំ បញ្ញា ភាវេតព្វា វិញ្ញាណំ បរិញ្ញេយ្យំ ឥទំ នេសំ នានាករណន្តិ ។

[១៣៥] វេទនា វេទនាតិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ វេទនាតិ វុច្ចតីតិ ។ វេទេតិ វេទេតីតិ ខោ អាវុសោ តស្មា វេទនាតិ វុច្ចតិ កិញ្ច វេទេតិ សុខម្បិ វេទេតិ ទុក្ខម្បិ វេទេតិ អទុក្ខមសុខម្បិ វេទេតិ វេទេតិ វេទេតីតិ ខោ អាវុសោ តស្មា វេទនាតិ វុច្ចតីតិ ។ សញ្ញា សញ្ញាតិ អាវុសោ វុច្ចតិ កិត្តាវតា នុ ខោ អាវុសោ សញ្ញាតិ វុច្ចតីតិ ។ សញ្ជានាតិ សញ្ជានាតីតិ ខោ អាវុសោ តស្មា សញ្ញាតិ វុច្ចតិ កិញ្ច សញ្ជានាតិ នីលកម្បិ សញ្ជានាតិ បីតកម្បិ សញ្ជានាតិ លោហិតកម្បិ សញ្ជានាតិ ឱទាតម្បិ សញ្ជានាតិ សញ្ជានាតិ សញ្ជានាតីតិ ខោ អាវុសោ តស្មា សញ្ញាតិ វុច្ចតីតិ ។ យា ចាវុសោ វេទនា យា ច សញ្ញា យញ្ច វិញ្ញាណំ ឥមេ ធម្មា សំសដ្ឋា

ម្នាលអាវុសោ ប្រាជ្ញានិងវិញ្ញាណ ធម៌ (ទាំងពីរ) នេះ ជាធម៌ដូចគ្នា មិនមែនផ្សេងគ្នាទេ តែប្រាជ្ញាបុគ្គលគួរចម្រើន វិញ្ញាណបុគ្គលគួរកំណត់ដឹង នេះជាសេចក្តីប្លែកគ្នានៃធម៌ (ទាំងពីរ) នោះ ។

[១៣៥] ម្នាលអាវុសោ គេតែងហៅថា វេទនា វេទនា ម្នាលអាវុសោ គេហៅថា វេទនា ដោយហេតុដូចម្តេច ។ ម្នាលអាវុសោ ធម្មជាតិទទួលដឹងនូវអារម្មណ៍ហ្នឹងឯង ដែលគេហៅថា វេទនា វេទនានោះដឹងអ្វីខ្លះ ដឹងសុខខ្លះ ដឹងទុក្ខខ្លះ ដឹងមិនមែនទុក្ខមិនមែនសុខខ្លះ ម្នាលអាវុសោ ព្រោះតែធម្មជាតិនោះ ទទួលដឹងអារម្មណ៍ដូច្នេះឯង ទើបហៅថាវេទនា ។ ម្នាលអាវុសោ គេតែងហៅថា សញ្ញា សញ្ញា ម្នាលអាវុសោ ដែលគេហៅថា សញ្ញា ដោយហេតុដូចម្តេច ។ ម្នាលអាវុសោ ព្រោះតែធម្មជាតិនោះកត់សំគាល់ ចំណាំ ទើបហៅថា សញ្ញា សញ្ញានោះតែងសំគាល់អ្វីខ្លះ សញ្ញានោះតែងសំគាល់ពណ៌ខៀវខ្លះ សំគាល់ពណ៌លឿងខ្លះ សំគាល់ពណ៌ក្រហមខ្លះ សំគាល់ពណ៌សខ្លះ ម្នាលអាវុសោ ព្រោះតែធម្មជាតិនោះកត់សំគាល់ហ្នឹងឯង ទើបហៅថា សញ្ញា ។ ម្នាលអាវុសោ វេទនា សញ្ញានិងវិញ្ញាណ ធម៌ទាំងនេះជាធម៌ប្រឡំគ្នា

ឧទាហុ វិសំសដ្ឋា លព្ភា ច បនិមេសំ ធម្មានំ វិនិព្ភុជិត្វា វិនិព្ភុជិត្វា នានាករណំ បញ្ញាបេតុន្តិ ។ យា ចាវុសោ វេទនា យា ច សញ្ញា យញ្ច វិញ្ញាណំ ឥមេ ធម្មា សំសដ្ឋា នោ វិសំសដ្ឋា ន ច លព្ភា ឥមេសំ ធម្មានំ វិនិព្ភុជិត្វា វិនិព្ភុជិត្វា នានាករណំ បញ្ញាបេតុំ យំ ចាវុសោ វេទេតិ តំ សញ្ជានាតិ យំ សញ្ជានាតិ តំ វិជានាតិ តស្មា ឥមេ ធម្មា សំសដ្ឋា នោ វិសំសដ្ឋា ន ច លព្ភា ឥមេសំ ធម្មានំ វិនិព្ភុជិត្វា វិនិព្ភុជិត្វា នានាករណំ បញ្ញាបេតុន្តិ ។

[១៣៦] និស្សដ្ឋេន ហាវុសោ បញ្ចហិ ឥន្ទ្រិយេហិ បរិសុទ្ធេន មនោវិញ្ញាណេន កឹ នេយ្យន្តិ ។ និស្សដ្ឋេន ច អាវុសោ បញ្ចហិ ឥន្ទ្រិយេហិ បរិសុទ្ធេន មនោវិញ្ញាណេន អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ នេយ្យំ អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ នេយ្យំ នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ នេយ្យន្តិ ។ នេយ្យំ បនាវុសោ ធម្មំ កេន ជានាតីតិ ។ នេយ្យំ ខោ អាវុសោ ធម្មំ បញ្ញាចក្ខុនា ជានាតីតិ ។

ឬមិនប្រទ្បំគ្នាទេ មួយទៀត បុគ្គលនឹងចែករំលែកធម៌ទាំងនេះ ហើយបញ្ញត្ត កុំឲ្យប្រទ្បំគ្នាបានឬទេ ។ ម្នាលអាវុសោ វេទនា សញ្ញា និងវិញ្ញាណ ធម៌ទាំងនេះប្រទ្បំគ្នា មិនមែនផ្សេងគ្នាទេ ហើយបុគ្គលចែករំលែកធម៌ទាំងនេះ បញ្ញត្តឲ្យផ្សេងគ្នាមិនបានទេ ម្នាលអាវុសោ វេទនាទទួលអារម្មណ៍ណា សញ្ញាក៏សំគាល់អារម្មណ៍នោះដែរ សញ្ញាសំគាល់នូវអារម្មណ៍ណា វិញ្ញាណក៏ដឹងច្បាស់ នូវអារម្មណ៍នោះដែរ ព្រោះហេតុនោះ ធម៌ទាំងនេះ ជាធម៌ដូចគ្នា មិនមែនផ្សេងគ្នាទេ បុគ្គលនឹងចែករំលែកធម៌ទាំងនេះ ហើយបញ្ញត្តឲ្យផ្សេងគ្នាមិនបានទេ ។

[១៣៦] ម្នាលអាវុសោ ធម្មជាតអ្វីដែលគេគប្បីដឹងដោយមនោ-វិញ្ញាណដ៏បរិសុទ្ធ ប្រាសចាកឥន្ទ្រិយទាំង ៥ ប្រការ ។ ម្នាលអាវុសោ អាកាសានញ្ចាយតនជ្ឈាន ដែលបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះ គប្បីដឹងដោយមនោវិញ្ញាណដ៏បរិសុទ្ធប្រាសចាកឥន្ទ្រិយទាំង ៥ ប្រការ វិញ្ញាណញ្ចាយតនជ្ឈាន ដែលបរិកម្មថា វិញ្ញាណមិនមានទីបំផុត និង អាកិញ្ចញ្ញាយតនៈ ដែលបរិកម្មថា អ្វីតិចតួចមិនមានដូច្នេះ គប្បីដឹងបាន ដោយមនោវិញ្ញាណដ៏បរិសុទ្ធប្រាសចាកឥន្ទ្រិយទាំង ៥ ប្រការ ។ ម្នាល អាវុសោ ធម៌ដែលគេគប្បីដឹង តើគេតែងដឹងបានដោយអ្វី ។ ម្នាល អាវុសោ ធម៌ដែលគេគប្បីដឹងនោះឯង គេតែងដឹងដោយបញ្ញាចក្ខុ ។

## ២៧៣



បញ្ញា បជាវុសោ ភិមត្ថិយាតិ ។ បញ្ញា ខោ អាវុសោ អភិញ្ញត្ថា បរិញ្ញត្ថា បហានត្ថាតិ ។

[១៣៧] កតី បជាវុសោ បច្ចយា សម្មា- ទិដ្ឋិយា ឧប្បាទាយ បរតោ ច ឃោសោ យោនិសោ ច មនសិការោ ឥមេ ខោ អាវុសោ ទ្វេ បច្ចយា សម្មាទិដ្ឋិយា ឧប្បាទាយាតិ ។ កតីហិ បជាវុសោ អង្គេហិ អនុគ្គហិតា សម្មាទិដ្ឋិ ចេតោវិមុត្តិផលា ច ហោតិ ចេតោវិមុត្តិផលានិសំសា ច បញ្ញាវិមុត្តិ- ផលា ច ហោតិ បញ្ញាវិមុត្តិផលានិសំសា ចាតិ ។ បញ្ចហិ ខោ អាវុសោ អង្គេហិ អនុគ្គហិតា សម្មាទិដ្ឋិ ចេតោវិមុត្តិផលា ច ហោតិ ចេតោវិមុត្តិផលានិសំសា ច បញ្ញាវិមុត្តិផលា ច ហោតិ បញ្ញាវិមុត្តិផលា- និសំសា ច ឥធាវុសោ សម្មាទិដ្ឋិ សីលានុគ្គហិតា ច ហោតិ សុតានុគ្គហិតា ច ហោតិ សាកច្ឆា- នុគ្គហិតា ច ហោតិ សមថានុគ្គហិតា ច ហោតិ

ម្នាលអាវុសោ ប្រាជ្ញាមានសេចក្តីថាដូចម្តេចខ្វះ ។ ម្នាលអាវុសោ ប្រាជ្ញាមានសេចក្តីថា ដឹងប្រាកដ មានសេចក្តីថា ដឹងសព្វ មានសេចក្តីថា លះបង់ ។

[១៣៧] ម្នាលអាវុសោ បច្ច័យដែលឲ្យសម្មាទិដ្ឋិកើតឡើង មានប៉ុន្មាន ។ ម្នាលអាវុសោ បច្ច័យដែលឲ្យសម្មាទិដ្ឋិកើតឡើង មាន ២ គឺ ការលាន់ឮអំពីសំណាក់ជនដទៃ ១ ការយកចិត្តទុកដាក់ ដោយឧបាយប្រាជ្ញា (ខ្លួនឯង) ១ ម្នាលអាវុសោ បច្ច័យដែលឲ្យសម្មាទិដ្ឋិកើតឡើង មាន ២ នេះឯង ។ ម្នាលអាវុសោ សម្មាទិដ្ឋិដែលមានចេតោវិមុត្តិជាផលផង មានផលគឺចេតោវិមុត្តិជាអានិសង្សផង មានបញ្ញាវិមុត្តិជាផលផង មានផលគឺបញ្ញាវិមុត្តិជាអានិសង្សផង មានអង្គប៉ុន្មាន ទំនុកបម្រុង ។ ម្នាលអាវុសោ សម្មាទិដ្ឋិដែលមានចេតោវិមុត្តិជាផលផង មានផលគឺបញ្ញាវិមុត្តិ ជាអានិសង្សផង មានបញ្ញាវិមុត្តិជាផលផង មានផលគឺបញ្ញាវិមុត្តិជាអានិសង្សផង មានអង្គ ៥ ជួយទំនុកបម្រុង ម្នាលអាវុសោ សម្មាទិដ្ឋិ ក្នុងទីនេះ មានសីលជួយទំនុកបម្រុង ១ មានសុតៈជួយទំនុកបម្រុង ១ មានសាកច្ឆាជួយទំនុកបម្រុង ១ មានសមថៈជួយទំនុកបម្រុង ១

វិបស្សនានុគ្គហិតា ច ហោតិ ឥមេហិ ខោ អាវុសោ បញ្ចហង្គេហិ អនុគ្គហិតា សម្មាទិដ្ឋិ ចេតោវិមុត្តិផលា ច ហោតិ ចេតោវិមុត្តិផលានិសំសា ច បញ្ញាវិមុត្តិ-ផលា ច ហោតិ បញ្ញាវិមុត្តិផលានិសំសា ចាតិ ។

[១៣៨] កតី បនាវុសោ ភវាតិ ។ តយោមេ អាវុសោ ភវា កាមភវោ រូបភវោ អរូបភវោ ចាតិ ។ កថំ បនាវុសោ អាយតឹ បុនព្ភវាភិនិព្វត្តិ ហោតីតិ ។ ជនានំ តត្រតត្រាភិនន្ទនា ឯវំ អាយតឹ បុនព្ភវាភិនិព្វត្តិ ហោតីតិ ។ កថំ បនាវុសោ អាយតឹ បុនព្ភវាភិ-និព្វត្តិ ន ហោតីតិ ។ អវិជ្ជាវិរាគា ខោ អាវុសោ វិជ្ជុប្បាទា តណ្ហានិរោធា ឯវំ អាយតឹ បុនព្ភវាភិនិព្វត្តិ ន ហោតីតិ ។

[១៣៩] កតមំ បនាវុសោ បឋមំ ឈានន្តិ ។ ឥធា-វុសោ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧប-

មានវិបស្សនាជួយទំនុកបម្រុង ១ ម្នាលអាវុសោ សម្មាទិដ្ឋិដែលមាន ចេតោវិមុត្តិជាផលផង មានផលគឺចេតោវិមុត្តិ ជាអានិសង្សផង មាន បញ្ញាវិមុត្តិជាផលផង មានផលគឺបញ្ញាវិមុត្តិជាអានិសង្សផង មានអង្គ ៥ នេះឯង ជួយទំនុកបម្រុង ។

[១៣៨] ម្នាលអាវុសោ ភពតើមានប៉ុន្មាន ។ ម្នាលអាវុសោ ភពនេះមាន ៣ គឺ កាមភព ១ រូបភព ១ អរូបភព ១ ។ ម្នាលអាវុសោ ការកើតក្នុងភពថ្មីតទៅទៀត ព្រោះហេតុដូចម្តេច ។ ម្នាលអាវុសោ ព្រោះសេចក្តីត្រេកអរក្នុងភពនោះ ៗ របស់ពួកសត្វ ដែលមានអវិជ្ជាជា នីវរណៈ មានតណ្ហាជាសំយោជនៈ ការកើតក្នុងភពថ្មីតទៅទៀតយ៉ាង នេះឯង ។ ម្នាលអាវុសោ ការមិនកើតក្នុងភពថ្មីតទៅទៀត ព្រោះហេតុ ដូចម្តេច ។ ម្នាលអាវុសោ ព្រោះប្រាសចាកអវិជ្ជា ព្រោះវិជ្ជាកើត ឡើង ព្រោះការរលត់នៃតណ្ហា ការមិនកើតក្នុងភពថ្មី តទៅទៀត យ៉ាងនេះឯង ។

[១៣៩] ម្នាលអាវុសោ បឋមជ្ឈានដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុ ក្នុងសាសនានេះ ជាអ្នកស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលកាន់បឋមជ្ឈាន ដែលប្រកប ដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខដែលកើតអំពីវិវេក

## ២៧៤

### ចូឡយមកវគ្គស្ស មហាវេទល្លសុត្តេ បញ្ចង្គិកំ បឋមជ្ឈានំ

សម្បជ្ជ វិហរតិ ឥធំ វុច្ចតាវុសោ បឋមំ ឈា-
ឆន្តិ ។ បឋមំ បជាវុសោ ឈានំ កតង្គិកន្តិ ។
បឋមំ ខោ អាវុសោ ឈានំ បញ្ចង្គិកំ ឥជាវុសោ
បឋមំ ឈានំ បញ្ចង្គិកំ សមាបន្នស្ស ភិក្ខុនោ
វិតក្កោ ច វត្តតិ វិចារោ ច បីតិ ច សុខញ្ច
ចិត្តេកគ្គតា ច បឋមំ ខោ អាវុសោ ឈានំ ឯវំ
បញ្ចង្គិកន្តិ ។ បឋមំ បជាវុសោ ឈានំ កតង្គ-
វិប្បហីនំ កតង្គសមន្នាគតន្តិ ។ បឋមំ ខោ អាវុ-
សោ ឈានំ បញ្ចង្គវិប្បហីនំ បញ្ចង្គសមន្នាគតំ ឥ-
ជាវុសោ បឋមំ ឈានំ សមាបន្នស្ស ភិក្ខុនោ កា-
មច្ឆន្ទោ បហីនោ ហោតិ ព្យាបាទោ បហីនោ ហោតិ
ថីនមិទ្ធំ បហីនំ ហោតិ ឧទ្ធច្ចកុក្កុច្ចំ បហីនំ ហោតិ
វិចិកិច្ឆា បហីនា ហោតិ វិតក្កោ ច វត្តតិ វិចា-
រោ ច បីតិ ច សុខំ ច ចិត្តេកគ្គតា ច បឋមំ
ខោ អាវុសោ ឈានំ ឯវំ បញ្ចង្គវិប្បហីនំ បញ្ចង្គស-
មន្នាគតន្តិ ។

ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលអាវុសោ នេះហៅថា បឋមជ្ឈាន ។ ម្នាលអាវុសោ បឋមជ្ឈានមានអង្គប៉ុន្មាន ។ ម្នាលអាវុសោ បឋមជ្ឈានមានអង្គ ៥ ម្នាលអាវុសោ កាលភិក្ខុក្នុងសាសនានេះ ចូលកាន់បឋមជ្ឈាន មានអង្គ ៥ វិតក្កៈ វិចារៈ បីតិ សុខៈនិងចិត្តេកគ្គតា រមែងប្រព្រឹត្តទៅ ម្នាលអាវុសោ បឋមជ្ឈានមានអង្គ ៥ យ៉ាងនេះឯង ។ ម្នាលអាវុសោ បឋមជ្ឈានលះអង្គប៉ុន្មាន ប្រកបដោយអង្គប៉ុន្មាន ។ ម្នាលអាវុសោ បឋមជ្ឈានលះអង្គ ៥ ប្រកបដោយអង្គ ៥ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ កាលចូលកាន់បឋមជ្ឈានជាអ្នកលះបង់កាមច្ឆន្ទៈ លះបង់ព្យាបាទ លះបង់ថីនមិទ្ធៈ លះបង់ឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ចំណែកខាងវិតក្កៈ វិចារៈ បីតិ សុខៈនិងចិត្តេកគ្គតា ក៏ប្រព្រឹត្តទៅ ម្នាលអាវុសោ បឋមជ្ឈាន លះអង្គ ៥ ប្រកបដោយអង្គ ៥ យ៉ាងនេះឯង ។

[៤៤០] បញ្ចិមានិ អាវុសោ ឥន្ទ្រិយានិ នានាវិសយានិ នានាគោចរានិ ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តិ សេយ្យថីទំ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ ឥមេសំ ខោ អាវុសោ បញ្ចន្នំ ឥន្ទ្រិយានំ នានាវិសយានំ នានាគោចរានំ ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តានំ កឹ បដិសរណំ កោ ច នេសំ គោចរវិសយំ បច្ចនុភោតីតិ ។ បញ្ចិមានិ អាវុសោ ឥន្ទ្រិយានិ នានាវិសយានិ នានាគោចរានិ ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តិ សេយ្យថីទំ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ ឥមេសំ ខោ អាវុសោ បញ្ចន្នំ ឥន្ទ្រិយានំ នានាវិសយានំ នានាគោចរានំ ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តានំ មនោ បដិសរណំ មនោ ច នេសំ គោចរវិសយំ បច្ចនុភោតីតិ ។

[១៤០] ម្នាលអាវុសោ ឥន្ទ្រិយទាំង ៥ ប្រការនេះ មានវិស័យផ្សេង ៗ គ្នា មានអារម្មណ៍ផ្សេង ៗ គ្នា ទទួលវិស័យដែលកើតជាអារម្មណ៍ជំនួសគ្នាមិនបានទេ ឥន្ទ្រិយទាំង ៥ គឺអ្វីខ្លះ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ម្នាលអាវុសោ កាលបើឥន្ទ្រិយទាំង ៥ ប្រការនេះ មានវិស័យផ្សេង ៗ គ្នា មានអារម្មណ៍ផ្សេង ៗ គ្នា មិនទទួលវិស័យដែលកើតជាអារម្មណ៍ជំនួសគ្នាបានទេ ចុះមានអ្វីជាទីពឹង មួយទៀត សភាពអ្វីទទួលវិស័យដែលកើតជាអារម្មណ៍ របស់ឥន្ទ្រិយទាំង ៥ ប្រការនោះ ។ ម្នាលអាវុសោ ឥន្ទ្រិយទាំង ៥ ប្រការនេះ មានវិស័យផ្សេង ៗ គ្នា មានអារម្មណ៍ផ្សេង ៗ គ្នា មិនទទួលវិស័យដែលកើតជាអារម្មណ៍ជំនួសគ្នាបានទេ ឥន្ទ្រិយទាំង ៥ គឺអ្វីខ្លះ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ម្នាលអាវុសោ កាលបើឥន្ទ្រិយទាំង ៥ ប្រការនេះឯង មានវិស័យផ្សេង ៗ គ្នា មានអារម្មណ៍ផ្សេង ៗ គ្នា មិនទទួលវិស័យដែលកើតជាអារម្មណ៍ជំនួសគ្នាបានទេ មានចិត្តជាទីពឹង មានចិត្តទទួលវិស័យ ដែលកើតជាអារម្មណ៍របស់ឥន្ទ្រិយទាំង ៥ នោះ ។

## ២៧៧

ចូឡយមកវគ្គស្ស មហាវេទល្លសុត្តេ បញ្ចិន្ទ្រិយានិ

[១៤១] បញ្ចិមានិ អាវុសោ ឥន្ទ្រិយានិ សេយ្យថីទំ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ ឥមានិ ខោ អាវុសោ បញ្ចិន្ទ្រិយានិ កឹ បដិច្ច តិដ្ឋន្តីតិ ។ បញ្ចិមានិ អាវុសោ ឥន្ទ្រិយានិ សេយ្យថីទំ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ ឥមានិ ខោ អាវុសោ បញ្ចិន្ទ្រិយានិ អាយុំ បដិច្ច តិដ្ឋន្តីតិ ។ អាយុ បនាវុសោ កឹ បដិច្ច តិដ្ឋតីតិ ។ អាយុ ឧស្មំ បដិច្ច តិដ្ឋតីតិ ។ ឧស្មា បនាវុសោ កឹ បដិច្ច តិដ្ឋតីតិ ។ ឧស្មា អាយុំ បដិច្ច តិដ្ឋតីតិ ។ ឥទានេវ ខោ មយំ អាយស្មតោ សារីបុត្តស្ស ភាសិតំ ឯវំ អាជានាម អាយុ ឧស្មំ បដិច្ច តិដ្ឋតីតិ ឥទានេវ ខោ មយំ អាយស្មតោ សារីបុត្តស្ស ភាសិតំ ឯវំ អាជានាម ឧស្មា អាយុំ បដិច្ច តិដ្ឋតីតិ ។ យថាកថំ បនាវុសោ ឥមស្ស ភាសិតស្ស អត្ថោ ទដ្ឋព្វោតិ ។ តេនហាវុសោ ឧបមន្តេ ករិស្សាមិ ឧបមាយមិធេកច្ចេ វិញ្ញូ[១]

១ ម. ឯត្តន្តរេ បុរិសាតិ បាឋោ ទិស្សតិ ។

ចូឡយមកវគ្គ មហាវេទល្លសូត្រ ឥន្ទ្រិយ ៥ ប្រការ

[១៨១] ម្នាលអាវុសោ ឥន្ទ្រិយ ៥ ប្រការនេះ គឺ ចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ម្នាលអាវុសោ ឥន្ទ្រិយទាំង ៥ នេះឯង អាស្រ័យនឹងអ្វី ទើបតាំងនៅបាន ។ ម្នាលអាវុសោ ឥន្ទ្រិយ ៥ នេះ គឺ ចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ម្នាលអាវុសោ ឥន្ទ្រិយទាំង ៥ នេះឯង អាស្រ័យនឹងអាយុទើបតាំងនៅបាន ។ ម្នាលអាវុសោ ចុះអាយុលុះតែអាស្រ័យនឹងអ្វីទើបតាំងនៅបាន ។ អាយុលុះតែអាស្រ័យចំហាយធាតុភ្លើង ទើបតាំងនៅបាន ។ ម្នាលអាវុសោ ចំហាយធាតុភ្លើង អាស្រ័យនឹងអ្វីទើបតាំងនៅបាន ។ ចំហាយធាតុភ្លើង លុះតែអាស្រ័យនឹងអាយុទើបតាំងនៅបាន ។ អម្បាញ់មិញនេះឯង ខ្ញុំដឹងច្បាស់ភាសិត របស់ព្រះសារីបុត្រមានអាយុ យ៉ាងនេះថា អាយុលុះតែអាស្រ័យចំហាយធាតុភ្លើង ទើបតាំងនៅបាន ឥឡូវនេះ ខ្ញុំដឹងច្បាស់ភាសិត របស់ព្រះសារីបុត្រមានអាយុយ៉ាងនេះថា ភ្លើងធាតុលុះតែអាស្រ័យនឹងអាយុ ទើបតាំងនៅបាន ដូច្នេះវិញ ។ ម្នាលអាវុសោ បើដូច្នេះ ខ្ញុំត្រូវយល់សេចក្តីនៃភាសិតនេះ ដូចម្តេច ។ ម្នាលអាវុសោ បើដូច្នោះ ខ្ញុំនឹងធ្វើសេចក្តីឧបមាប្រគេនលោក ដ្បិតជនជាអ្នកចេះដឹងពួកខ្លះក្នុងលោកនេះ

កាសិតស្ស អត្ថំ អាជានន្តិ សេយ្យថាបិ អាវុសោ តេ-
លប្បទីបស្ស ឈាយតោ អច្ចឹ បដិច្ច អាភា បញ្ញាយតិ
អាភំ បដិច្ច អច្ចិ បញ្ញាយតិ ឯវមេវ ខោ អាយុ
ឧស្មំ បដិច្ច តិដ្ឋតិ ឧស្មា អាយុំ បដិច្ច តិដ្ឋតីតិ ។
តេវ នុ ខោ អាវុសោ អាយុសង្ខារា តេ វេទនីយា
ធម្មា ឧទាហុ អញ្ញេ អាយុសង្ខារា អញ្ញេ វេទនីយា
ធម្មាតិ ។ ន ខោ អាវុសោ តេវ អាយុសង្ខារា
តេ វេទនីយា ធម្មា តេ អាវុសោ អាយុសង្ខារា
អភវិស្សំសុ តេ វេទនីយា ធម្មា នយិទំ សញ្ញាវេ-
ទយិតនិរោធំ សមាបន្នស្ស ភិក្ខុនោ វុដ្ឋានំ បញ្ញា-
យេថ យស្មា ច ខោ អញ្ញេ អាយុសង្ខារា
អញ្ញេ វេទនីយា ធម្មា តស្មា សញ្ញាវេទយិតនិរោធំ
សមាបន្នស្ស ភិក្ខុនោ វុដ្ឋានំ បញ្ញាយតីតិ ។

[១៤២] យទា នុ ខោ អាវុសោ ឥមំ កាយំ
កតី[១] ធម្មា ជហន្តិ អថាយំ កាយោ ឧជ្ឈិតោ
អវក្ខិត្តោ សេតិ យថា កដ្ឋំ អចេតនន្តិ ។
យទា ខោ អាវុសោ ឥមំ កាយំ តយោ ធម្មា

១ ឱ. កតិ ។

គង់យល់សេចក្តីនៃភាសិតដោយពាក្យឧបមាបានដែរ ម្នាលអាវុសោ ដូចប្រទីបប្រេងកាលឆេះ មានពន្លឺប្រាកដឡើង ព្រោះអាស្រ័យអណ្តាត អណ្តាតប្រាកដឡើងព្រោះអាស្រ័យពន្លឺ សេចក្តីនេះយ៉ាងណាមិញ អាយុតាំងនៅបាន ក៏ព្រោះអាស្រ័យចំហាយធាតុភ្លើង ចំហាយធាតុភ្លើងតាំងនៅបាន ព្រោះអាស្រ័យអាយុ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាយុ-សង្ខារ[១] ទាំងនោះ ជាវេទនីយធម៌[២] នោះ ឬថាអាយុសង្ខារផ្សេង វេទនីយធម៌ផ្សេង ។ ម្នាលអាវុសោ មិនមែនអាយុសង្ខារទាំងនោះ ជាវេទនីយធម៌នោះទេ ម្នាលអាវុសោ ប្រសិនបើ អាយុសង្ខារទាំងនោះ ជាវេទនីយធម៌នោះហើយ ភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធនោះ ចេញចាកសមាបត្តិមកវិញមិនកើតទេ គឺអាយុសង្ខារផ្សេង វេទនីយធម៌ផ្សេង ហេតុនោះ បានជាភិក្ខុចូលកាន់សញ្ញាវេទយិតនិរោធ ចេញចាកសមាបត្តិមកវិញបាន ។

[១៤២] ម្នាលអាវុសោ ធម៌ប៉ុន្មានដែលលះបង់កាយនេះ ក្នុងកាលណាហើយ កាយនេះគេចោលរាត់រាយ ដេកស្តូកស្តឹង ដូចជាកំណាត់ឈើដែលគ្មានចេតនា ។ ម្នាលអាវុសោ ធម៌ ៣ ប្រការ គឺ

---

១ សំដៅយកអាយុប៉ុណ្ណោះ ។ ២ វេទនា ។ អដ្ឋកថា ។

២៧៩

ជហន្តិ អាយុ ឧស្មា ច វិញ្ញាណំ អថាយំ កាយោ ឧជ្ឈិតោ អវក្ខិត្តោ សេតិ យថា កដ្ឋំ អចេតនន្តិ ។ យោ ចាយំ[1] អាវុសោ មតោ កាលកតោ យោ ចាយំ ភិក្ខុ សញ្ញាវេទយិតនិរោធសមាបន្នោ[2] ឥមេសំ កឹ នានាករណន្តិ ។ យោ ចាយំ អាវុសោ មតោ កាលកតោ តស្ស កាយសង្ខារា និរុទ្ធា បដិប្បស្សទ្ធា វចីសង្ខារា និរុទ្ធា បដិប្បស្សទ្ធា ចិត្តសង្ខារា និរុទ្ធា បដិប្បស្សទ្ធា អាយុ បរិក្ខីណា ឧស្មា វូបសន្តា ឥន្ទ្រិយានិ បរិភិន្នានិ យោ ចាយំ ភិក្ខុ សញ្ញាវេទយិតនិរោធំ សមាបន្នោ តស្សបិ កាយសង្ខារា និរុទ្ធា បដិប្បស្សទ្ធា វចីសង្ខារា និរុទ្ធា បដិប្បស្សទ្ធា ចិត្តសង្ខារា និរុទ្ធា បដិប្បស្សទ្ធា អាយុ អបរិក្ខីណា ឧស្មា អវូបសន្តា ឥន្ទ្រិយានិ វិប្បសន្នានិ យោ ចាយំ អាវុសោ មតោ កាលកតោ យោ ចាយំ ភិក្ខុ សញ្ញាវេទយិតនិរោធំ សមាបន្នោ ឥទំ នេសំ[3] នានាករណន្តិ ។

---

១ ឱ. ម. យ្វាយំ ។ ២ ឱ. ម. សញ្ញាវេទយិតនិរោធំ សមាបន្នោ ។ ៣ ឱ. ម. តេសំ ។

អាយុ ១ ចំហាយធាតុភ្លើង ១ វិញ្ញាណ ១ លះបង់កាយនេះក្នុងកាលឯណាហើយ កាយនេះគេចោលរាត់រាយ ដេកស្តូកស្តឹង ដូចកំណាត់ឈើដែលគ្មានចេតនា ។ ម្នាលអាវុសោ បុគ្គលដែលធ្វើកាលកិរិយាក្ស័យ ១ ភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធ ១ បុគ្គលទាំង ២ ពួកនេះ មានសេចក្តីប្លែកគ្នាដូចម្តេច ។ ម្នាលអាវុសោ បុគ្គលដែលធ្វើកាល-កិរិយាក្ស័យ បុគ្គលនោះ កាយសង្ខារគឺខ្យល់ដង្ហើមចេញចូល រលត់សូន្យឈឹង វចីសង្ខារគឺវិតក្កៈនិងវិចារៈ រលត់សូន្យឈឹង ចិត្តសង្ខារគឺសញ្ញានិងវេទនា រលត់សូន្យឈឹង អាយុក៏អស់ ចំហាយធាតុភ្លើងក៏រលត់សូន្យឈឹង ឥន្ទ្រិយក៏បែកធ្លាយ ឯភិក្ខុដែលចូលកាន់សញ្ញាវេទយិត-និរោធ ភិក្ខុនោះមានកាយសង្ខារ រលត់សូន្យឈឹង វចីសង្ខាររលត់សូន្យឈឹង ចិត្តសង្ខាររលត់សូន្យឈឹងដែរ តែអាយុមិនអស់ ចំហាយធាតុភ្លើងមិនរលត់សូន្យទេ ឥន្ទ្រិយនៅថ្លាល្អ ម្នាលអាវុសោ បុគ្គលដែលធ្វើមរណកាលក្ស័យ និងភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធ បុគ្គលទាំង ២ ពួកនេះ មានសេចក្តីផ្សេងគ្នា យ៉ាងនេះឯង ។

[១៤៣] កតី បនាវុសោ បច្ចយា អទុក្ខមសុ-ខាយ ចេតោវិមុត្តិយា សមាបត្តិយាតិ ។ ចត្តារោ ខោ អាវុសោ បច្ចយា អទុក្ខមសុខាយ ចេតោវិមុត្តិយា សមាបត្តិយា ឥធាវុសោ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ឥមេ ខោ អាវុសោ ចត្តារោ បច្ចយា អទុក្ខមសុខាយ ចេតោវិមុត្តិយា សមាបត្តិ-យាតិ ។ កតី បនាវុសោ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិយា សមាបត្តិយា ។ ទ្វេ ខោ អាវុសោ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិយា សមាបត្តិយា សព្វនិមិត្តានញ្ច អមនសិការោ អនិមិត្តាយ ច ធា-តុយា មនសិការោ ឥមេ ខោ អាវុសោ ទ្វេ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិយា សមាបត្តិយាតិ ។

[១៤៣] ម្នាលអាវុសោ អទុក្ខមសុខចេតោវិមុត្តិសមាបត្តិ មានបច្ច័យប៉ុន្មាន ។ ម្នាលអាវុសោ អទុក្ខមសុខចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ៤ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសេចក្តីសុខ ១ ព្រោះលះបង់នូវសេចក្តីទុក្ខ ១ ព្រោះរំលត់នូវសោមនស្សនិងទោមនស្សក្នុងកាលមុន ១ ចូលកាន់ចតុត្ថជ្ឈានដែលឥតទុក្ខឥតសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំងបួន ១ ម្នាលអាវុសោ អទុក្ខមសុខចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ៤ នេះឯង ។ ម្នាលអាវុសោ អនិមិត្តចេតោវិមុត្តិសមាបត្តិ មានបច្ច័យប៉ុន្មាន ។ ម្នាលអាវុសោ អនិមិត្តចេតោវិមុត្តិសមាបត្តិមានបច្ច័យ ២ គឺការមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្តទុកដាក់ចំពោះនិព្វានធាតុដែលប្រាសចាកអារម្មណ៍ ១ ម្នាលអាវុសោ អនិមិត្តចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ២ នេះឯង ។

២៨១



កតី បនាវុសោ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិយា ឋិតិយាតិ ។ តយោ ខោ អាវុសោ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិយា ឋិតិយា សព្វនិមិត្តានញ្ច អមនសិ-ការោ អនិមិត្តាយ ច ធាតុយា មនសិការោ បុព្វេ ច អភិសង្ខារោ ឥមេ ខោ អាវុសោ តយោ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិយា ឋិតិយាតិ ។ កតី បនាវុសោ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិយា វុដ្ឋានាយាតិ ។ ទ្វេ ខោ អាវុសោ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិយា វុដ្ឋានាយ សព្វនិមិត្តានញ្ច មនសិ-ការោ អនិមិត្តាយ ច ធាតុយា អមនសិការោ ឥមេ ខោ អាវុសោ ទ្វេ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិ-យា វុដ្ឋានាយាតិ ។

ម្នាលអាវុសោ បច្ច័យដែលឲ្យអនិមិត្តចេតោវិមុត្តិតាំងនៅបានយូរ តើមានប៉ុន្មាន ។ ម្នាលអាវុសោ បច្ច័យដែលឲ្យអនិមិត្តចេតោវិមុត្តិតាំងនៅបានយូរ មាន ៣ ប្រការ គឺការមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្តទុកដាក់ចំពោះនិព្វានធាតុដែលប្រាសចាកអារម្មណ៍ ១ ការបានតាក់តែងទុកពីខាងដើម ១ ម្នាលអាវុសោ បច្ច័យដែលឲ្យអនិមិត្តចេតោវិមុត្តិតាំងនៅបានយូរ មាន ៣ ប្រការនេះឯង ។ ម្នាលអាវុសោ បច្ច័យនៃការចេញចាកអនិមិត្តចេតោវិមុត្តិ មានប៉ុន្មាន ។ ម្នាលអាវុសោ បច្ច័យនៃការចេញចាកអនិមិត្តចេតោវិមុត្តិ មាន ២ ប្រការ គឺ ការយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការមិនយកចិត្តទុកដាក់ចំពោះនិព្វានធាតុដែលមិនមានអារម្មណ៍ ១ ម្នាលអាវុសោ បច្ច័យនៃការចេញចាកអនិមិត្តចេតោវិមុត្តិ មាន ២ ប្រការនេះឯង ។

[៤៤៤] យា ចាយំ អាវុសោ អប្បមាណា ចេតោ-វិមុត្តិ យា ច អាកិញ្ចញ្ញា ចេតោវិមុត្តិ យា សុញ្ញតា ចេតោវិមុត្តិ យា ច អនិមិត្តា ចេតោវិមុត្តិ ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ឧទាហុ ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។ យា ចាយំ អាវុសោ អប្បមាណា ចេតោវិមុត្តិ យា ច អាកិញ្ចញ្ញា ចេតោវិមុត្តិ យា ច សុញ្ញតា ចេតោវិមុត្តិ យា ច អនិមិត្តា ចេតោវិមុត្តិ អត្ថិ ខោ អាវុសោ បរិយាយោ យំ បរិយាយំ អាគម្ម ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច អត្ថិ ច[១] អាវុសោ បរិយាយោ យំ បរិយាយំ អាគម្ម ឥមេ ធម្មា ឯកត្ថា ព្យញ្ជនមេវ នានំ ។ កតមោ ចាវុសោ បរិយាយោ យំ បរិយាយំ អាគម្ម ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ឥធាវុសោ ភិក្ខុ

១ ម. ច ខោ ។

[១៤៤] ម្នាលអាវុសោ អប្បមាណចេតោវិមុត្តិ[១] អាកិញ្ចញ្ញចេតោវិមុត្តិ[២] សុញ្ញតចេតោវិមុត្តិ[៣] និងអនិមិត្តចេតោវិមុត្តិ[៤] ធម៌ទាំងនេះមានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ឬមានសេចក្តីដូចគ្នា គ្រាន់តែព្យញ្ជនៈផ្សេងគ្នាប៉ុណ្ណោះទេ ។ ម្នាលអាវុសោ អប្បមាណចេតោវិមុត្តិណា អាកិញ្ចញ្ញចេតោវិមុត្តិណា សុញ្ញតចេតោវិមុត្តិណា និងអនិមិត្តចេតោវិមុត្តិណា ម្នាលអាវុសោ មានបរិយាយ ដែលធម៌ទាំងនេះអាស្រ័យហើយ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ម្នាលអាវុសោ មួយទៀត មានបរិយាយ ដែលធម៌ទាំងនេះអាស្រ័យហើយ ក៏បែរជាមានសេចក្តីដូចគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ ម្នាលអាវុសោ ចុះបរិយាយដូចម្តេច ដែលធម៌ទាំងនេះអាស្រ័យហើយ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ មាន

---

១ អប្បមាណចេតោវិមុត្តិ នោះ សំដៅយកការផ្សាយមេត្តាចំពោះសត្វទាំងអស់មិនមានប្រមាណ បើពោលដោយលំដាប់ភូមិ ជាមហគ្គតរូបាវចរភូមិ បើពោលដោយអារម្មណ៍មានសត្វជាអារម្មណ៍ ។ ២ អាកិញ្ចញ្ញចេតោវិមុត្តិ ចេតោវិមុត្តិដែលមិនមានកង្វល់ក្នុងអារម្មណ៍ បើពោលតាមលំដាប់ភូមិជាអរូបាវចរភូមិ ចំណែកខាងអារម្មណ៍មិនមានទេ ។ ៣ សុញ្ញតចេតោវិមុត្តិ សំដៅយកវិបស្សនា បើពោលដោយភូមិ ជាកាមាវចរភូមិ បើពោលដោយអារម្មណ៍មានសង្ខារជាអារម្មណ៍ ។ ៤ អនិមិត្តចេតោវិមុត្តិ ចេតោវិមុត្តិដែលមិនមានរាគនិមិត្តជាដើម បើពោលដោយភូមិ ជាលោកុត្តរភូមិ បើពោលដោយអារម្មណ៍ មាននិព្វានជាអារម្មណ៍ ។

២៨៣



មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ករុណាសហគតេន... មុទិតាសហគតេន... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ អយំ វុច្ចតាវុសោ អប្បមាណា ចេតោវិមុត្តិ ។ កតមា ចាវុសោ អាកិញ្ចញ្ញា ចេតោវិមុត្តិ ឥធាវុសោ ភិក្ខុ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតាវុសោ

ចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តាធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសកណ្ដាល ព្រោះយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ។ មានចិត្តប្រកបដោយករុណា... ប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង ព្រោះបង្អោនខ្លួនទៅប្រៀបធៀបនឹងសត្វទាំងពួង ក្នុងទីទាំងពួង ម្នាលអាវុសោ នេះហៅថា អប្បមាណចេតោវិមុត្តិ ។ ម្នាលអាវុសោ អាកិញ្ចញ្ញចេតោវិមុត្តិ តើដូចម្ដេច ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ កន្លងបង់នូវវិញ្ញាណញ្ចាយតនៈ ដោយសព្វអន្លើ ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនជ្ឈានដោយបរិកម្មថា អ្វីបន្តិចបន្តួចមិនមានដូច្នេះ ម្នាលអាវុសោ នេះហៅថា

អាកិញ្ចញ្ញា ចេតោវិមុត្តិ ។ កតមា ចាវុសោ សុញ្ញតា ចេតោវិមុត្តិ ឥធ អាវុសោ ភិក្ខុ អរញ្ញ-គតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ សុញ្ញមិទំ អត្តេន វា អត្ត-និយេន វាតិ អយំ វុច្ចតាវុសោ សុញ្ញតា ចេតោ-វិមុត្តិ ។ កតមា ចាវុសោ អនិមិត្តា ចេតោវិមុត្តិ ឥធាវុសោ ភិក្ខុ សព្វនិមិត្តានំ អមនសិការា អនិមិត្តំ ចេតោសមាធឹ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតាវុសោ អនិមិត្តា ចេតោវិមុត្តិ ។ អយំ ខោ អាវុសោ បរិយា-យោ យំ បរិយាយំ អាគម្ម ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ។ កតមោ អាវុសោ បរិយាយោ យំ បរិយាយំ អាគម្ម ឥមេ ធម្មា ឯកត្ថា ព្យញ្ជន-មេវ នានំ ភតោ ខោ អាវុសោ បមាណករណោ

អាកិញ្ចញ្ញាចេតោវិមុត្តិ ។ ម្នាលអាវុសោ សុញ្ញតចេតោវិមុត្តិ តើដូចម្តេច ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងសុញ្ញាគារស្ថានក្តី រមែងពិចារណាយ៉ាងនេះថា របស់នេះតែងសាបសូន្យចាកអត្តភាព ឬចាកវត្ថុសម្រាប់ទំនុកបម្រុងខ្លួនមានចីវរជាដើម ម្នាលអាវុសោ នេះលោកហៅថា សុញ្ញតចេតោវិមុត្តិ ។ ម្នាលអាវុសោ អនិមិត្តចេតោវិមុត្តិ តើដូចម្តេច ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ចូលកាន់ចេតោសមាធិដែលមិនមាននិមិត្ត ព្រោះមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង នេះហៅថា អនិមិត្តចេតោវិមុត្តិ ។ ម្នាលអាវុសោ នេះឯងជាបរិយាយដែលធម៌ទាំងនេះអាស្រ័យហើយ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ។ ម្នាលអាវុសោ ចុះបរិយាយដូចម្តេច ដែលពួកធម៌ទាំងនេះ អាស្រ័យហើយ បែរជាមានសេចក្តីដូចគ្នា តែមានព្យញ្ជនៈផ្សេងគ្នា ម្នាលអាវុសោ រាគៈជាកិលេសធ្វើនូវប្រមាណ[១]

---

១ កិលេសមានរាគៈជាដើមមិនទាន់កើតឡើង ដរាបណា ដរាបនោះ គេមិនអាចស្គាល់បុគ្គលនោះថាជាមនុស្សថ្នាក់ណាទេ ព្រោះបុគ្គលនោះប្រហែលនឹងសោតាបន្នបុគ្គលជាដើម ។ លុះតែរាគៈជាដើមកើតឡើង ទើបគេស្គាល់ប្រមាណបុគ្គលនោះបានថា អ្នកនេះ ជាមនុស្សថ្នាក់នេះយ៉ាងនេះជាដើម បានជាហៅថា ជាកិលេសធ្វើនូវប្រមាណបាន ។ អដ្ឋកថា ។

ទោសោ បមាណករណោ មោហោ បមាណករណោ តេ ខីណាសវស្ស ភិក្ខុនោ បហីនា ឧច្ឆិន្នមូលា តា-លាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ យាវតា ខោ អាវុសោ អប្បមាណា ចេតោវិមុត្តិយោ អកុប្បា តាសំ ចេតោវិមុត្តិ អគ្គមក្ខាយតិ សា ខោ បនាកុប្បា ចេតោវិមុត្តិ សុញ្ញា រាគេន សុញ្ញា ទោ-សេន សុញ្ញា មោហេន ។ រាគោ ខោ អាវុសោ កិញ្ចនោ ទោសោ កិញ្ចនោ មោហោ កិញ្ចនោ តេ ខីណាសវស្ស ភិក្ខុនោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ យាវតា ខោ អាវុសោ អាកិញ្ចញ្ញា ចេតោវិមុត្តិ-យោ អកុប្បា តាសំ ចេតោវិមុត្តិ អគ្គមក្ខាយតិ

*ទោសៈជាកិលេសធ្វើនូវប្រមាណ មោហៈជាកិលេសធ្វើនូវប្រមាណ កិលេសទាំងនោះ ភិក្ខុដែលជាខីណាស្រពបានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យកើតតទៅទៀត ដូចដើមត្នោតដែលគេក្របែលមិនឲ្យដុះតទៅទៀត ធ្វើមិនឲ្យមានបែបភាពតទៅទៀត ជាធម៌មិនកើតតទៅទៀត ។ ម្នាលអាវុសោ បណ្តាអប្បមាណចេតោវិមុត្តិ[១] ទាំងប៉ុន្មានមានអកុប្បាចេតោវិមុត្តិ[២] ប្រសើរជាងវិមុត្តិទាំងនោះ ព្រោះអកុប្បាចេតោវិមុត្តិនោះ សូន្យរាគៈ សូន្យទោសៈ សូន្យមោហៈ ។ ម្នាលអាវុសោ រាគៈជាគ្រឿងកង្វល់ ទោសៈជាគ្រឿងកង្វល់ មោហៈក៏ជាគ្រឿងកង្វល់ កិលេសទាំងនោះ ភិក្ខុជាខីណាស្រព បានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីង ដូចដើមត្នោតដែលគេកាប់ក្របែលធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅទៀតហើយ ។ ម្នាលអាវុសោ អាកិញ្ចញ្ញចេតោវិមុត្តិ[៣] ទាំងប៉ុន្មាន មានអកុប្បាចេតោវិមុត្តិប្រសើរជាងវិមុត្តិទាំងនោះ*

---

១ អប្បមាណចេតោវិមុត្តិ ១២ គឺ ព្រហ្មវិហារ ៤ មគ្គ ៤ ផល ៤ ។ ២ សំដៅយកអប្បមាណចេតោវិមុត្តិ ទី ១២ គឺអរហត្តផលចេតោវិមុត្តិ ។ ៣ បានដល់ធម៌ ៩ គឺអាកិញ្ចញ្ញាយតនជ្ឈាន ១ មគ្គ ៤ ផល ៤ ។ ឈានដែលឈ្មោះថាអាកិញ្ចញ្ញៈ ព្រោះគ្មានអារម្មណ៍ជាគ្រឿងកង្វល់ មគ្គ ផល ក៏ឈ្មោះថា អាកិញ្ចញ្ញៈ ព្រោះគ្មានកិលេសជាគ្រឿងកង្វល់ ។ ឯព្រះនិព្វាន ក៏ឈ្មោះថាអាកិញ្ចញ្ញៈដែរ តែព្រោះគ្មានចេតោវិមុត្តិ បានជាលោកមិនរាប់បញ្ចូលក្នុងពួកអាកិញ្ចញ្ញចេតោវិមុត្តិនេះ ។

សា ខោ បនាកុប្បា ចេតោវិមុត្តិ សុញ្ញា រាគេន សុញ្ញា ទោសេន សុញ្ញា មោហេន ។ រាគោ ខោ អាវុសោ និមិត្តករណោ ទោសោ និមិត្តករណោ មោហោ និមិត្តករណោ តេ ខីណាសវស្ស ភិក្ខុនោ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា ។ យាវតា ខោ អាវុសោ និមិត្តា ចេតោវិមុត្តិយោ

ព្រោះអកុប្បាចេតោវិមុត្តិនោះ សូន្យរាគៈ សូន្យទោសៈ សូន្យមោហៈ ។ ម្នាលអាវុសោ រាគៈជាកិលេសធ្វើនិមិត្ត[១] ទោសៈជាកិលេសធ្វើនិមិត្ត មោហៈជាកិលេសធ្វើនិមិត្ត ពួកកិលេសធ្វើនិមិត្តទាំងនោះ ភិក្ខុជាព្រះខីណាស្រព បានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់ហើយ ធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីង ដូចដើមត្នោតដែលគេក្របែលចោលហើយ ធ្វើឲ្យលែងមានបែបភាពតទៅទៀត ជាធម៌លែងមានកំណើតតទៅទៀតហើយ ។ ម្នាលអាវុសោ និមិត្តចេតោវិមុត្តិទាំងប៉ុន្មាន

---

១ មានសេចក្តីដូចគ្នានឹងពាក្យដែលថាកិលេសជាគ្រឿងធ្វើនូវប្រមាណដែរ តែចំណែកអនិមិត្តចេតោវិមុត្តិនេះ សង្គ្រោះយកធម៌ ១៣ គឺវិបស្សនា ១ អារុប្បជ្ឈាន ៤ មគ្គ ៤ ផល ៤ ។ វិបស្សនា ហៅថា អនិមិត្ត ព្រោះគាស់រំលើងនូវនិច្ចនិមិត្ត សុខនិមិត្ត និងអត្តនិមិត្ត ។ អារុប្បជ្ឈាន ៤ ឈ្មោះថា អនិមិត្ត ព្រោះគ្មានរូបនិមិត្ត ។ មគ្គនិងផល ឈ្មោះថា អនិមិត្ត ព្រោះគ្មានកិលេសជាគ្រឿងធ្វើនូវនិមិត្ត ។ ព្រះនិព្វាន ក៏ឈ្មោះថា អនិមិត្តដែរ តែព្រោះគ្មានចេតោវិមុត្តិ បានជាលោកមិនរាប់បញ្ចូល ក្នុងពួកអនិមិត្តចេតោវិមុត្តិនេះ ។ អដ្ឋកថា ។

២៨៧

ចូឡយមកវគ្គស្ស មហាវេទល្លសុត្តេ អាយស្មតោ សារីបុត្តស្ស ភាសិតស្ស អភិនន្ទនំ

អកុប្បា តាសំ ចេតោវិមុត្តិ អគ្គមក្ខាយតិ សា ខោ បនាកុប្បា ចេតោវិមុត្តិ សុញ្ញា រាគេន សុញ្ញា ទោសេន សុញ្ញា មោហេន ។ អយំ ខោ អាវុសោ បរិយាយោ យំ បរិយាយំ អាគម្ម ឥមេ ធម្មា ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។ ឥទម-វោចាយស្មា សារីបុត្តោ អត្តមនោ អាយស្មា មហាកោដ្ឋិកោ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទីតិ ។

មហាវេទល្លសុត្តំ តតិយំ និដ្ឋិតំ ។

មានអកុប្បាចេតោវិមុត្តិប្រសើរជាងវិមុត្តិទាំងនោះ ព្រោះអកុប្បាចេតោ-វិមុត្តិនោះ សូន្យរាគៈ សូន្យទោសៈ សូន្យមោហៈ ។ ម្នាលអាវុសោ នេះឯងជាបរិយាយដែលធម៌ទាំងនេះអាស្រ័យហើយ មានសេចក្ដីដូចគ្នា តែមានព្យញ្ជនៈផ្សេងគ្នា ។ លុះព្រះសារីបុត្រមានអាយុ បានពោលពាក្យនេះហើយ ព្រះមហាកោដ្ឋិកត្ថេរមានអាយុ ក៏មានចិត្តរីករាយ ត្រេកអរហើយ ចំពោះភាសិត របស់ព្រះសារីបុត្រមានអាយុ ។

ចប់ មហាវេទល្លសូត្រ ទី ៣ ។

# ចតុត្ថំ ចូឡវេទល្លសុត្តំ

[១៤៥] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ វិសាខោ ឧបាសកោ យេន ធម្មទិន្នាភិក្ខុនី តេនុបសង្កមិ ឧបសង្កមិត្វា ធម្មទិន្នំ ភិក្ខុនឹ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[១៤៦] ឯកមន្តំ និសិន្នោ ខោ វិសាខោ ឧបាសកោ ធម្មទិន្នំ ភិក្ខុនឹ ឯតទវោច សក្កាយោ សក្កាយោតិ អយ្យេ វុច្ចតិ កតមោ នុ ខោ អយ្យេ សក្កាយោ វុត្តោ ភគវតាតិ ។ បញ្ច ខោ ឥមេ អាវុសោ វិសាខ ឧបាទានក្ខន្ធា សក្កាយោ វុត្តោ ភគវតា សេយ្យថីទំ រូបូបាទានក្ខន្ធោ វេទនូបាទានក្ខន្ធោ សញ្ញូបាទានក្ខន្ធោ សង្ខារូបាទានក្ខន្ធោ វិញ្ញាណូបាទានក្ខន្ធោ ឥមេ ខោ អាវុសោ វិសាខ បញ្ចុបាទានក្ខន្ធា សក្កាយោ វុត្តោ ភគវតាតិ ។

# ចូឡវេទល្លសូត្រ ទី ៤

[១៤៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ឧបាសកឈ្មោះវិសាខ បានចូលទៅរកធម្ម-ទិន្នាភិក្ខុនី លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំធម្មទិន្នាភិក្ខុនី ហើយក៏អង្គុយក្នុងទីដ៏សមគួរ ។

[១៤៦] លុះវិសាខឧបាសកអង្គុយក្នុងទីដ៏សមគួរហើយ ទើបទូលសួរធម្មទិន្នាភិក្ខុនីយ៉ាងនេះថា បពិត្រព្រះនាងជាម្ចាស់ ព្រះមានព្រះភាគ តែងត្រាស់ថា សក្កាយៈ សក្កាយៈ បពិត្រព្រះនាងជាម្ចាស់ ធម៌ដូចម្តេចខ្លះ ដែលព្រះមានព្រះភាគត្រាស់ថា សក្កាយៈ ។ ធម្ម-ទិន្នាភិក្ខុនីតបថា ម្នាលអាវុសោវិសាខ ឧបាទានក្ខន្ធ ៥ ប្រការនេះឯង ដែលព្រះមានព្រះភាគត្រាស់ថា សក្កាយៈ ឧបាទានក្ខន្ធ ៥ គឺ រូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបា-ទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ម្នាលអាវុសោវិសាខ ឧបាទានក្ខន្ធទាំង ៥ ប្រការនេះឯង ដែលព្រះមានព្រះភាគត្រាស់ថា សក្កាយៈ ។

១៨៩

ចូឡយមកវគ្គស្ស ចូឡវេទល្លសុត្តេ សក្កាយសមុទយប្បញ្ហា

សាធយ្យេតិ ខោ វិសាខោ ឧបាសកោ ធម្មទិន្នាយ ភិក្ខុនិយា ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ធម្មទិន្នំ ភិក្ខុនឹ ឧត្តរឹ បញ្ហំ អបុច្ឆិ សក្កាយសមុទយោ សក្កាយសមុទយោតិ អយ្យេ វុច្ចតិ កតមោ នុ ខោ អយ្យេ សក្កាយសមុទយោ វុត្តោ ភគវតាតិ ។ យាយំ អាវុសោ វិសាខ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា អយំ ខោ អាវុសោ វិសាខ សក្កាយសមុទយោ វុត្តោ ភគវតាតិ ។ សក្កាយនិរោធោ សក្កាយនិរោធោតិ អយ្យេ វុច្ចតិ កតមោ នុ ខោ អយ្យេ សក្កាយនិរោធោ វុត្តោ ភគវតាតិ ។ យោ ខោ អាវុសោ វិសាខ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ អយំ ខោ អាវុសោ វិសាខ

វិសាខឧបាសកក៏ត្រេកអរនឹងភាសិតរបស់ធម្មទិន្នាភិក្ខុនីថា ពីរោះណាស់ព្រះនាងជាម្ចាស់ ហើយក៏បានសួរប្រស្នានឹងធម្មទិន្នាភិក្ខុនីតទៅទៀតថា បពិត្រព្រះនាងជាម្ចាស់ ព្រះមានព្រះភាគ ទ្រង់តែងត្រាស់ថា ហេតុដែលនាំឲ្យកើតសក្កាយៈ ហេតុដែលនាំឲ្យកើតសក្កាយៈ បពិត្រព្រះនាងជាម្ចាស់ ធម៌ដូចម្ដេចហ្ន៎ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាហេតុនាំឲ្យកើតសក្កាយៈ ។ ធម្មទិន្នាភិក្ខុនីតបថា ម្នាលអាវុសោវិសាខ តណ្ហាដែលនាំឲ្យសត្វកើតក្នុងភពថ្មីទៀត ប្រកបដោយនន្ទិរាគ មានសេចក្ដីត្រេកអរក្នុងភពនោះ ៗ តណ្ហានោះគឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ម្នាលអាវុសោវិសាខ នេះឯងហើយដែលព្រះមានព្រះភាគត្រាស់ថា ហេតុនាំឲ្យកើតសក្កាយៈ ។ បពិត្រព្រះនាងជាម្ចាស់ ព្រះមានព្រះភាគត្រាស់ថា ការរំលត់សក្កាយៈ ការរំលត់សក្កាយៈ បពិត្រព្រះនាងជាម្ចាស់ ធម៌ដូចម្ដេចហ្ន៎ ដែលព្រះមានព្រះភាគត្រាស់ថា ជាគ្រឿងរំលត់សក្កាយៈ ។ ម្នាលអាវុសោវិសាខ សេចក្ដីនឿយណាយនិងការរំលត់ដោយមិនសល់ ការលះបង់ ការជម្រុះចោល ការរួចស្រឡះ ការលែងអាឡោះអាល័យ ចំពោះតណ្ហានោះឯង ម្នាលអាវុសោវិសាខ នេះឯងហើយដែល

សក្កាយនិរោធោ វុត្តោ ភគវតាតិ ។ សក្កាយនិរោធគាមនី បដិបទា សក្កាយនិរោធគាមិនី បដិបទាតិ អយ្យេ វុច្ចតិ កតមា នុ ខោ អយ្យេ សក្កាយនិរោធគាមិនី បដិបទា វុត្តា ភគវតាតិ ។ អយមេវ ខោ អាវុសោ វិសាខ អរិយោ អដ្ឋង្គិកោ មគ្គោ សក្កាយនិរោធគាមិនី បដិបទា វុត្តា ភគវតា សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធីតិ ។ តញ្ញេវ នុ ខោ អយ្យេ ឧបាទានំ តេ បញ្ចុបាទានក្ខន្ធា ឧទាហុ អញ្ញត្រ បញ្ចហុបាទានក្ខន្ធេហិ ឧបាទានន្តិ ។ ន ខោ អាវុសោ វិសាខ តញ្ញេវុបាទានំ តេ បញ្ចុបាទានក្ខន្ធា នបិ អញ្ញត្រ បញ្ចហុបាទានក្ខន្ធេហិ ឧបាទានំ យោ ខោ អាវុសោ វិសាខ បញ្ចសុ ឧបាទានក្ខន្ធេសុ ឆន្ទរាគោ តំ តត្ថ ឧបាទានន្តិ ។

ព្រះមានព្រះភាគត្រាស់ថា ការរំលត់សក្កាយៈ ។ បពិត្រព្រះនាងជាម្ចាស់ ព្រះមានព្រះភាគទ្រង់ត្រាស់ថា បដិបទាជាដំណើរទៅកាន់សេចក្តីរំលត់សក្កាយៈ បដិបទាជាដំណើរទៅកាន់សេចក្តីរំលត់សក្កាយៈ បពិត្រព្រះនាងជាម្ចាស់ ធម្មជាតិដូចម្តេចហ្ន៎ ដែលព្រះមានព្រះភាគត្រាស់ថា បដិបទាជាដំណើរទៅកាន់សេចក្តីរំលត់សក្កាយៈ ។ ម្នាលអាវុសោវិសាខ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ដែលព្រះមានព្រះភាគត្រាស់ថា បដិបទាជាដំណើរទៅកាន់សេចក្តីរំលត់សក្កាយៈ មគ្គដែលប្រកបដោយអង្គ ៨ នោះ គឺ សេចក្តីយល់ត្រូវ ១ ការត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្តីព្យាយាមត្រូវ ១ ស្មារតីត្រូវ ១ ការតម្កល់ចិត្តនឹងត្រូវ ១ ។ បពិត្រព្រះនាងជាម្ចាស់ ឧបាទាននោះ គឺឧបាទានក្ខន្ធទាំង ៥ នោះឯង ឬក៏ឧបាទានដោយឡែកអំពីឧបាទានក្ខន្ធទាំង ៥ (នោះ) ទេ ។ ម្នាលអាវុសោវិសាខ ឧបាទាននោះឯង មិនមែនជាឧបាទានក្ខន្ធទាំង ៥ នោះទេ ឯឧបាទាន (នោះ) សោតក៏មិនមែនដោយឡែកអំពីឧបាទានក្ខន្ធទាំង ៥ ដែរ ម្នាលអាវុសោវិសាខ ឧបាទាននោះឯង មិនមែនជាឧបាទានក្ខន្ធទាំង ៥ នោះទេ តែឧបាទាននឹងញែកចេញអំពីឧបាទានក្ខន្ធមិនបានដែរ ម្នាលអាវុសោវិសាខ សេចក្តីត្រេកត្រអាលក្នុងឧបាទានក្ខន្ធទាំង ៥ ឈ្មោះថា ឧបាទាន ក្នុងឧបាទានក្ខន្ធនោះ ។

ចូឡយមកវគ្គស្ស ចូឡវេទល្លសុត្តេ សក្កាយទិដ្ឋិបញ្ហា

[១៤៧] កថំ បនយ្យេ សក្កាយទិដ្ឋិ ហោតីតិ ។ ឥធាវុសោ វិសាខ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ... សញ្ញំ... សង្ខារេ... វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ឯវំ ខោ អាវុសោ វិសាខ សក្កាយទិដ្ឋិ ហោតីតិ ។ កថំ បនយ្យេ សក្កាយទិដ្ឋិ ន ហោតីតិ ។ ឥធាវុសោ វិសាខ សុតវា អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ

ចូឡយមកវគ្គ ចូឡវេទល្លសូត្រ សំនួរពីសក្កាយទិដ្ឋិ

[១៨៧] បពិត្រព្រះនាងជាម្ចាស់ ចុះសក្កាយទិដ្ឋិដូចម្ដេច ។ ម្នាលអាវុសោវិសាខ បុថុជ្ជនក្នុងលោកនេះជាអ្នកមិនចេះដឹង មិនបានចួបប្រទះនឹងពួកព្រះអរិយៈ[១] មិនឈ្លាសវៃក្នុងធម៌ព្រះអរិយៈ មិនបានហាត់ខ្លួនក្នុងធម៌របស់ព្រះអរិយៈ ទាំងមិនបានឃើញពួកសប្បុរស[២] មិនឈ្លាសវៃក្នុងធម៌របស់សប្បុរស មិនបានហាត់ចិត្តក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញនូវរូបថាខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាមានរូបខ្លះ ពិចារណាឃើញរូបក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួនក្នុងរូបខ្លះ ពិចារណាឃើញវេទនា... សញ្ញា... សង្ខារទាំងឡាយ... ពិចារណាឃើញវិញ្ញាណថាខ្លួនខ្លះ ពិចារណាឃើញខ្លួនថាមានវិញ្ញាណខ្លះ ពិចារណាឃើញវិញ្ញាណក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួនក្នុងវិញ្ញាណខ្លះ ម្នាលអាវុសោវិសាខ យ៉ាងនេះឯងហើយដែលហៅថាសក្កាយទិដ្ឋិ ។ បពិត្រព្រះនាងជាម្ចាស់ ដែលហៅថាមិនមានសក្កាយទិដ្ឋិដូចម្ដេច ។ ម្នាលអាវុសោវិសាខ អរិយសាវ័កក្នុងលោកនេះ ជាអ្នកចេះដឹង បានឃើញពួកព្រះអរិយៈ ឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ បានហាត់ចិត្តល្អក្នុងធម៌ព្រះអរិយៈ ទាំងបានជួបប្រទះនឹងពួកសប្បុរស ឈ្លាសវៃក្នុងធម៌របស់សប្បុ-

---

១ បុគ្គលដែលឆ្ងាយចាកកិលេស ហៅថា អរិយៈ ។ ២ បុរសដែលល្អដោយលោកុត្តរគុណ ហៅថា សប្បុរស ឈ្មោះទាំងពីរនេះសំដៅយកព្រះពុទ្ធ ព្រះបច្ចេកពុទ្ធនិងព្រះពុទ្ធសាវ័ក ។ អដ្ឋកថា ។

សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា[1] អត្តានំ ន អត្តនិ វា[2] រូបំ ន រូបស្មឹ វា[3] អត្តានំ ន វេទនំ... ន សញ្ញំ... ន សង្ខារេ... ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ ឯវំ ខោ អាវុសោ វិសាខ សក្កាយទិដ្ឋិ ន ហោតីតិ ។

[២៤៨] កតមោ បនយ្យេ អរិយោ អដ្ឋង្គិកោ មគ្គោតិ ។ អយមេវ ខោ អាវុសោ វិសាខ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធីតិ ។ អរិយោ បនយ្យេ អដ្ឋង្គិកោ មគ្គោ សង្ខតោ ឧទាហុ អសង្ខតោតិ ។ អរិយោ ខោ អាវុសោ វិសាខ

១-២-៣ ឱ. វា សទ្ទោ នត្ថិ ។

រស បានហាត់ចិត្តដោយល្អក្នុងធម៌របស់សប្បុរស មិនបានពិចារណាឃើញនូវរូបថាខ្លួនខ្វះ មិនបានពិចារណាឃើញនូវខ្លួនថាមានរូបខ្វះ មិនពិចារណាឃើញរូបក្នុងខ្លួនខ្វះ មិនពិចារណាឃើញខ្លួនក្នុងរូបខ្វះ មិនបានពិចារណាឃើញវេទនា... សញ្ញា... សង្ខារទាំងឡាយ... មិនបានពិចារណាឃើញវិញ្ញាណថាខ្លួនខ្វះ មិនបានពិចារណាឃើញខ្លួនថាមានវិញ្ញាណខ្វះ មិនបានពិចារណាឃើញវិញ្ញាណក្នុងខ្លួនខ្វះ និងមិនពិចារណាឃើញខ្លួនក្នុងវិញ្ញាណខ្វះ ម្នាលអាវុសោវិសាខ យ៉ាងនេះឯងហើយដែលហៅថា មិនមានសក្កាយទិដ្ឋិ ។

[១៤៨] បពិត្រព្រះនាងជាម្ចាស់ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្តេច ។ ម្នាលអាវុសោវិសាខ មគ្គដែលប្រកបដោយអង្គ ៨ ប្រការដ៏ប្រសើរនេះឯង គឺសេចក្តីយល់ត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ ស្មារតីត្រូវ ១ ការតម្កល់ចិត្តនឹងត្រូវ ១ ។ បពិត្រព្រះនាងជាម្ចាស់ ចុះអដ្ឋង្គិកមគ្គដ៏ប្រសើរនោះជាសង្ខតធម៌[១] ឬជាអសង្ខតធម៌ ។ ម្នាលអាវុសោវិសាខ

១ ជាធម៌ដែលព្រះអរិយៈនៅធ្វើ នៅតាក់តែង ត្រូវតែប្រតិបត្តិ ហៅថា សង្ខតៈ ។

៤៩៣



អដ្ឋង្គិកោ មគ្គោ សង្ខតោតិ ។ អរិយេន នុ ខោ អយ្យេ អដ្ឋង្គិកេន មគ្គេន តយោ ខន្ធា សង្គហិតា ឧទាហុ តីហិ ខន្ធេហិ អរិយោ អដ្ឋង្គិកោ មគ្គោ សង្គហិតោតិ ។ ន ខោ អាវុសោ វិសាខ អរិយេន អដ្ឋង្គិកេន មគ្គេន តយោ ខន្ធា សង្គហិតា តីហិ ច ខោ អាវុសោ វិសាខ ខន្ធេហិ អរិយោ អដ្ឋង្គិកោ មគ្គោ សង្គហិតោ យា ចាវុសោ វិសាខ សម្មាវាចា យោ ច សម្មាកម្មន្តោ យោ ច សម្មាអាជីវោ ឥមេ ធម្មា សីលក្ខន្ធេ[១] សង្គហិតា យោ ច សម្មាវាយាមោ យា ច សម្មាសតិ យោ ច សម្មាសមាធិ ឥមេ ធម្មា សមាធិក្ខន្ធេ[២] សង្គហិតា យា ច សម្មាទិដ្ឋិ យោ ច សម្មាសង្កប្បោ ឥមេ ធម្មា បញ្ញាខន្ធេ[៣] សង្គហិតាតិ ។ កតមោ បនយ្យេ សមាធិ កតមេ ធម្មា សមាធិនិមិត្តា កតមេ ធម្មា សមាធិបរិក្ខារា កតមា សមាធិភាវនាតិ ។ យា ខោ អាវុសោ វិសាខ ចិត្តស្សេកគ្គតា អយំ សមាធិ

១ ឱ. សីលក្ខន្ធេ ។ ២ សមាធិក្ខន្ធេ ។ ៣ បញ្ញាខន្ធេ ។

អដ្ឋង្គិកមគ្គដ៏ប្រសើរជាសង្ខតធម៌ ។ បពិត្រព្រះនាងជាម្ចាស់ ខន្ធទាំង ៣ ប្រការលោកសង្គ្រោះចូលក្នុងអដ្ឋង្គិកមគ្គដ៏ប្រសើរ ឬអដ្ឋង្គិកមគ្គដ៏ប្រសើរ លោកសង្គ្រោះចូលក្នុងខន្ធទាំង ៣ ប្រការវិញ ។ ម្នាលអាវុសោវិសាខ ខន្ធទាំង ៣ ប្រការ លោកមិនបានសង្គ្រោះចូលក្នុងអដ្ឋង្គិកមគ្គដ៏ប្រសើរទេ ម្នាលអាវុសោវិសាខ តែអដ្ឋង្គិកមគ្គទាំង ៨ ប្រការដ៏ប្រសើរ លោកសង្គ្រោះចូលក្នុងខន្ធទាំង ៣ ប្រការវិញ ម្នាលអាវុសោវិសាខ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ ធម៌ទាំង (៣) នេះ លោកសង្គ្រោះចូលក្នុងសីលក្ខន្ធ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ធម៌ទាំង (៣) នេះ លោកសង្គ្រោះចូលក្នុងសមាធិក្ខន្ធ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ ធម៌ទាំង (២) នេះ លោកសង្គ្រោះចូលក្នុងបញ្ញាខន្ធ ។ បពិត្រព្រះនាងជាម្ចាស់ សមាធិដូចម្តេច ពួកធម៌ជាសមាធិនិមិត្តដូចម្តេច ពួកធម៌ជាសមាធិបរិក្ខារដូចម្តេច សមាធិភាវនាដូចម្តេច ។ ម្នាលអាវុសោវិសាខ សភាវៈដែលធ្វើចិត្តឲ្យនឹងនៅក្នុងអារម្មណ៍តែមួយហៅថា សមាធិ

ចត្តារោ សតិប្បដ្ឋានា សមាធិនិមិត្តា ចត្តារោ សម្មប្បធានា សមាធិបរិក្ខារា យា តេសញ្ញេវ(១) ធម្មានំ អាសេវនា ភាវនា ពហុលីកម្មំ អយំ តត្ថ សមាធិភាវនា ។

[៤៦៩] កតី បនយ្យេ សង្ខារាតិ ។ តយោមេ អាវុសោ វិសាខ សង្ខារា កាយសង្ខារោ វចីសង្ខារោ ចិត្តសង្ខារោតិ ។ កតមោ បនយ្យេ កាយសង្ខារោ កតមោ វចីសង្ខារោ កតមោ ចិត្តសង្ខារោតិ ។ អស្សាសបស្សាសា ខោ អាវុសោ វិសាខ កាយសង្ខារោ វិតក្កវិចារា វចីសង្ខារោ សញ្ញា ច វេទនា ច ចិត្តសង្ខារោតិ ។ កស្មា បនយ្យេ អស្សាសបស្សាសា កាយសង្ខារោ កស្មា វិតក្កវិចារា វចីសង្ខារោ កស្មា សញ្ញា ច វេទនា ច ចិត្តសង្ខារោតិ ។ អស្សាសបស្សាសា ខោ អាវុសោ វិសាខ កាយិកា ឯតេ ធម្មា កាយប្បដិពទ្ធា តស្មា អស្សាសបស្សាសា កាយសង្ខារោ បុព្វេ ខោ អាវុសោ វិសាខ វិតក្កេត្វា វិចារេត្វា វាចំ ភិន្ទតិ តស្មា វិតក្កវិចារា

១ ឱ. តេសំយេវ ។

*សតិប្បដ្ឋានទាំង ៤ ហៅថា សមាធិនិមិត្ត សម្មប្បធាន ៤ ហៅថា សមាធិ-បរិក្ខារ ការធ្វើចិត្តឲ្យតម្កល់នឹង ការចម្រើន និងការធ្វើឲ្យច្រើនចំពោះធម៌ទាំងនោះឯង ហៅថា សមាធិភាវនា ។*

*[១៤៩] បពិត្រព្រះនាងជាម្ចាស់ ចុះសង្ខារទាំងឡាយ មានប៉ុន្មាន ។ ម្នាលអាវុសោវិសាខ សង្ខារទាំងឡាយនេះមាន ៣ គឺ កាយ-សង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ។ បពិត្រព្រះនាងជាម្ចាស់ កាយ-សង្ខារតើដូចម្តេច វចីសង្ខារដូចម្តេច ចិត្តសង្ខារដូចម្តេច ។ ម្នាលអាវុសោវិសាខ ខ្យល់ដង្ហើមចេញចូលហ្នឹងឯង ហៅថាកាយសង្ខារ វិតក្កៈនិងវិចារៈហៅថាវចីសង្ខារ សញ្ញានិងវេទនា ហៅថាចិត្តសង្ខារ ។ បពិត្រព្រះនាងជាម្ចាស់ ព្រោះហេតុអ្វីបានជាខ្យល់ដង្ហើមចេញចូល ហៅថាកាយសង្ខារ ព្រោះហេតុអ្វីបានជាវិតក្កៈនិងវិចារៈ ហៅថាវចីសង្ខារ ព្រោះហេតុអ្វីបានជាសញ្ញានិងវេទនា ហៅថាចិត្តសង្ខារ ។ ម្នាលអាវុសោវិសាខ ការដកដង្ហើមចេញចូលហ្នឹងឯង ជាធម៌ប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនុ៎ះជាធម៌ជាប់ទាក់ទងនឹងកាយ ព្រោះហេតុនោះ បានជាខ្យល់ដកដង្ហើមចេញចូលហៅថាកាយសង្ខារ ម្នាលអាវុសោវិសាខ បុគ្គលត្រិះរិះពិចារណាមុនសិនទើបបញ្ចេញវាចា (ក្រោយ) ព្រោះហេតុនោះបានជាវិតក្កៈនិងវិចារៈ ហៅ*

វចីសង្ខារោ សញ្ញា ច វេទនា ច ចេតសិកា ឯតេ ធម្មា ចិត្តប្បដិពទ្ធា តស្មា សញ្ញា ច វេទនា ច ចិត្តសង្ខារោតិ ។

[៤៦០] កថំ[១] បនយ្យេ សញ្ញាវេទយិតនិរោធសមាបត្តិ ហោតីតិ ។ ន ខោ អាវុសោ វិសាខ សញ្ញាវេទយិតនិរោធំ សមាបជ្ជន្តស្ស ភិក្ខុនោ ឯវំ ហោតិ អហំ សញ្ញាវេទយិតនិរោធំ សមាបជ្ជិស្សន្តិ វា អហំ សញ្ញាវេទយិតនិរោធំ សមាបជ្ជាមីតិ វា អហំ សញ្ញាវេទយិតនិរោធំ សមាបន្នោតិ វា អថខ្វស្ស បុព្វេវ តថា ចិត្តំ ភាវិតំ ហោតិ យន្តំ តថត្តាយ ឧបនេតីតិ ។ សញ្ញាវេទយិតនិរោធំ សមាបជ្ជន្តស្ស បនយ្យេ ភិក្ខុនោ កតមេ ធម្មា បឋមំ និរុជ្ឈន្តិ យទិ វា កាយសង្ខារោ យទិ វា វចីសង្ខារោ យទិ វា

---
១ ឱ. កថញ្ច ។

ថាវចីសង្ខារ ឯសញ្ញានិងវេទនា ជាធម៌ប្រព្រឹត្តទៅក្នុងចិត្ត ធម៌ទាំងនុ៎ះជាធម៌ជាប់ទាក់ទងនឹងចិត្ត ព្រោះហេតុនោះបានជា សញ្ញានិងវេទនា ហៅថា ចិត្តសង្ខារ ។

[១៥០] បពិត្រព្រះនាងជាម្ចាស់ ចុះសញ្ញាវេទយិតនិរោធសមាបត្តិដូចម្ដេច ។ ម្នាលអាវុសោវិសាខ ភិក្ខុដែលកំពុងចូលសញ្ញាវេទយិតនិរោធ (នោះ) មិនមានគំនិតយ៉ាងនេះថា អាត្មាអញនឹងចូលសញ្ញាវេទយិតនិរោធ ឬថាអាត្មាអញកំពុងចូលសញ្ញាវេទយិតនិរោធ ឬក៏ថាអាត្មាអញចូលសញ្ញាវេទយិតនិរោធហើយដូច្នេះឡើយ តែថាមុននឹងដល់និរោធសមាបត្តិនោះ ភិក្ខុនោះបានចម្រើនចិត្តយ៉ាងនោះ បានជាបង្អោនទៅដើម្បីជាបុគ្គលរលត់ចិត្តសង្ខារ[១] ។ បពិត្រព្រះនាងជាម្ចាស់ ចុះភិក្ខុដែលចូលសញ្ញាវេទយិតនិរោធ ពួកធម៌ណារលត់មុន កាយសង្ខារ ឬវចីសង្ខារ ឬក៏ចិត្ត-

---

១ តាមសេចក្ដីយល់ថារបៀបចូលសញ្ញាវេទយិតនិរោធនោះ ត្រូវចូលរូបជ្ឈាននិងអរូបជ្ឈានសិន រួចទើបចូលសញ្ញាវេទយិតនិរោធ ។ មុននឹងដល់សញ្ញាវេទយិតនិរោធនោះ ភិក្ខុនៅមានគំនិតថា នឹងចូល ឬចូលយ៉ាងនេះ តែបន្ទាប់ពីនេវសញ្ញានាសញ្ញាយតនៈទៅ ភិក្ខុនោះមិនមានគំនិតថានឹងចូលនិរោធនោះទេ តែដោយអំណាចដែលបានហាត់ចិត្តស្ទាត់មកហើយនោះ ក៏ស្រាប់តែរអិលដល់និរោធនោះតែម្ដង ។ ក្នុងនិរោធនោះសោតគ្មានចិត្តសង្ខារទេ គឺរលត់សញ្ញានិងវេទនាអស់ ដូចជាបុគ្គលគ្មានចិត្ត ។

ចិត្តសង្ខារោតិ ។ សញ្ញាវេទយិតនិរោធំ សមាបជ្ជន្តស្ស ខោ អាវុសោ វិសាខ ភិក្ខុនោ បឋមំ និរុជ្ឈតិ វចីសង្ខារោ តតោ កាយសង្ខារោ តតោ ចិត្តសង្ខារោតិ ។ កថំ បនយ្យេ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋានំ ហោតីតិ ។ ន ខោ អាវុសោ វិសាខ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋហន្តស្ស ភិក្ខុនោ ឯវំ ហោតិ អហំ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋហិស្សន្តិ វា អហំ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋហាមីតិ វា អហំ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋិតោតិ វា អថខ្វស្ស បុព្វេវ តថា ចិត្តំ ភាវិតំ ហោតិ យន្តំ តថត្តាយ ឧបនេតីតិ ។ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋហន្តស្ស បនយ្យេ ភិក្ខុនោ កតមេ ធម្មា បឋមំ ឧប្បជ្ជន្តិ យទិ វា កាយសង្ខារោ យទិ វា វចីសង្ខារោ យទិ វា ចិត្តសង្ខារោតិ ។ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋហន្តស្ស ខោ អាវុសោ វិសាខ ភិក្ខុនោ បឋមំ ឧប្បជ្ជតិ ចិត្តសង្ខារោ តតោ កាយសង្ខារោ តតោ

សង្ខារ (រលត់មុន) ។ ម្នាលអាវុសោវិសាខៈ ភិក្ខុដែលចូលសញ្ញាវេទយិតនិរោធនោះ វចីសង្ខាររលត់មុន តមក ទើបកាយសង្ខារ (រលត់) តពីនោះមកទៀត ទើបចិត្តសង្ខារ (រលត់) ។ បពិត្រព្រះនាងជាម្ចាស់ ការចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិមកវិញ ដោយប្រការដូចម្តេច ។ ម្នាលអាវុសោវិសាខៈ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ (នោះ) មិនមានគំនិតយ៉ាងនេះថា អាត្មាអញ នឹងចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ឬថាអាត្មាអញចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិឥឡូវនេះ ឬក៏ថាអាត្មាអញចេញហើយ អំពីសញ្ញាវេទយិតនិរោធសមាបត្តិដូច្នេះឡើយ តែថាមុននឹងចេញអំពីនិរោធសមាបត្តិនោះ ភិក្ខុនោះចម្រើនចិត្តយ៉ាងនេះ បានជាបង្អោនចិត្តទៅ ដើម្បីជាបុគ្គលមានចិត្តសង្ខារឡើងវិញ ។ បពិត្រព្រះនាងជាម្ចាស់ ចុះភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធ ពួកធម៌ណាកើតមុន កាយសង្ខារ ឬវចីសង្ខារ ឬក៏ចិត្តសង្ខារ (កើតមុន) ។ ម្នាលអាវុសោវិសាខៈ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ (នោះ) ចិត្តសង្ខារកើតមុន តមក ទើបកាយសង្ខារ (កើត) តអំពីនោះមក

វចីសង្ខារោតិ ។ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋិតំ បនយ្យេ ភិក្ខុំ កតី ផស្សា ផុស្សន្តីតិ ។ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋិតំ ខោ អាវុសោ វិសាខ ភិក្ខុំ តយោ ផស្សា ផុស្សន្តិ សុញ្ញតោ ផស្សោ អនិមិត្តោ ផស្សោ អប្បណិហិតោ ផស្សោតិ ។ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋិតស្ស បនយ្យេ ភិក្ខុនោ កឹនិន្នំ ចិត្តំ ហោតិ កឹបោណំ កឹបព្ភារន្តិ ។ សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋិតស្ស ខោ អាវុសោ វិសាខ ភិក្ខុនោ វិវេកនិន្នំ ចិត្តំ ហោតិ វិវេកបោណំ វិវេកបព្ភារន្តិ ។

[១៩១] កតី បនយ្យេ វេទនាតិ ។ តិស្សោ ខោ ឥមា អាវុសោ វិសាខ វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនាតិ ។ កតមា បនយ្យេ សុខា វេទនា កតមា ទុក្ខា វេទនា កតមា អទុក្ខមសុខា វេទនាតិ ។ យំ ខោ អាវុសោ វិសាខ

ទៀត ទើបវចីសង្ខារ (កើត) ។ បពិត្រព្រះនាងជាម្ចាស់ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិមកវិញ មានផស្សៈប៉ុន្មានពាល់ត្រូវ ។ ម្នាលអាវុសោវិសាខ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធ-សមាបត្តិមកវិញ មានផស្សៈ ៣ ប្រការពាល់ត្រូវគឺ សុញ្ញតផស្សៈ[១] ១ អនិមិត្តផស្សៈ[២] ១ អប្បណិហិតផស្សៈ[៣] ១ ។ បពិត្រព្រះនាងជាម្ចាស់ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ចិត្ត (លោក) បង្អោនទៅរកអ្វី ទោរទន់ទៅរកអ្វី ឈមទៅរកអ្វី ។ ម្នាលអាវុសោវិសាខ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ចិត្តលោកបង្អោនទៅរកវិវេក ទោរទន់ទៅរកវិវេក ឈមទៅរកវិវេក ។

[១៥១] បពិត្រព្រះនាងជាម្ចាស់ វេទនាតើមានប៉ុន្មាន ។ ម្នាលអាវុសោវិសាខ វេទនានេះមាន ៣ ប្រការគឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ បពិត្រព្រះនាងជាម្ចាស់ ចុះសុខវេទនាតើដូចម្តេច ទុក្ខវេទនាដូចម្តេច អទុក្ខមសុខវេទនាដូចម្តេច ។ ម្នាលអាវុសោវិសាខ

---

១ ដែលកើតជាមួយនឹងសុញ្ញតផលសមាបត្តិ ឈ្មោះថា សុញ្ញតផស្សៈ ។ ២ ផស្សៈដែលកើតជាមួយនឹងអនិមិត្តផលសមាបត្តិនោះ ហៅថា អនិមិត្តផស្សៈ ។ ៣ ផស្សៈ ដែលកើតជាមួយនឹងអប្បណិហិតផលសមាបត្តិនោះ ហៅថា អប្បណិហិតផស្សៈ ។ អដ្ឋកថា ។

កាយិកំ វា ចេតសិកំ វា សុខំ សាតំ វេទយិតំ អយំ សុខា វេទនា យំ ខោ អាវុសោ វិសាខ កា-យិកំ វា ចេតសិកំ វា ទុក្ខំ អសាតំ វេទយិតំ អយំ ទុក្ខា វេទនា យំ ខោ អាវុសោ វិសាខ កាយិកំ វា ចេតសិកំ វា នេវ សាតំ នាសាតំ វេទយិតំ អយំ អទុក្ខមសុខា វេទនាតិ ។ សុខា បនាយ្យេ វេទនា កឹសុខា កឹទុក្ខាតិ ។ សុខា ខោ អាវុសោ វិសាខ វេទនា ឋិតិសុខា វិបរិណាមទុក្ខា ទុក្ខា វេទនា ឋិតិទុក្ខា វិបរិណាមសុខា អទុក្ខមសុខា វេទនា សញ្ញាណសុខា អញ្ញាណទុក្ខាតិ ។ សុខាយ ប-នាយ្យេ វេទនាយ កឹ អនុសយោ អនុសេតិ ទុក្ខាយ វេទនាយ កឹ អនុសយោ អនុសេតិ អទុក្ខមសុខាយ វេទនាយ កឹ អនុសយោ អនុសេតីតិ ។ សុខាយ ខោ អាវុសោ វិសាខ វេទនាយ រាគានុសយោ អនុសេតិ ទុក្ខាយ វេទនាយ បដិឃានុសយោ អនុសេតិ អទុក្ខមសុខាយ វេទនាយ អវិជ្ជានុស-យោ អនុសេតីតិ ។ សព្វាយ នុ ខោ អយ្យេ

ធម្មជាតដែលទទួលអារម្មណ៍ជាសុខដ៏ឆ្ងាញ់ ប្រព្រឹត្តទៅក្នុងកាយ ឬប្រព្រឹត្តទៅក្នុងចិត្ត នេះហៅថាសុខវេទនា ម្នាលអាវុសោវិសាខៈ ធម្មជាតដែលទទួលអារម្មណ៍ជាទុក្ខមិនឆ្ងាញ់ ប្រព្រឹត្តទៅក្នុងកាយ ឬប្រព្រឹត្តទៅក្នុងចិត្ត នេះហៅថាទុក្ខវេទនា ម្នាលអាវុសោវិសាខៈ ធម្មជាតដែលទទួលអារម្មណ៍ដែលឆ្ងាញ់ ក៏មិនមែន មិនឆ្ងាញ់ ក៏មិនមែន ប្រព្រឹត្តទៅក្នុងកាយ ឬប្រព្រឹត្តទៅក្នុងចិត្ត នេះហៅថាអទុក្ខមសុខវេទនា ។ បពិត្រព្រះនាងជាម្ចាស់ ចុះសុខវេទនាមានអ្វីជាសុខ មានអ្វីជាទុក្ខ ។ ម្នាលអាវុសោវិសាខៈ សុខវេទនា មានកិរិយាឋិតនៅដដែលជាសុខ មានការប្រែប្រួលទៅវិញជាទុក្ខ ទុក្ខវេទនា មានកិរិយាឋិតនៅជាទុក្ខ មានកិរិយាប្រែប្រួលទៅវិញជាសុខ ឯអទុក្ខមសុខវេទនា មានការដឹងច្បាស់ជាសុខ មានការមិនដឹងជាទុក្ខ ។ បពិត្រព្រះនាងជាម្ចាស់ ចុះអនុស័យអ្វី ដេកសម្ងំនៅក្នុងសុខវេទនា អនុស័យអ្វីដេកសម្ងំនៅក្នុងទុក្ខវេទនា អនុស័យអ្វី ដេកសម្ងំនៅក្នុងអទុក្ខមសុខវេទនា ។ ម្នាលអាវុសោវិសាខៈ រាគានុស័យ ដេកសម្ងំនៅក្នុងសុខវេទនា បដិឃានុស័យដេកសម្ងំនៅក្នុងទុក្ខវេទនា អវិជ្ជានុស័យ ដេកសម្ងំនៅក្នុងអទុក្ខមសុខវេទនា ។ បពិត្រព្រះនាងជាម្ចាស់

សុខាយ វេទនាយ រាគានុសយោ អនុសេតិ សព្វាយ ទុក្ខាយ វេទនាយ បដិឃានុសយោ អនុសេតិ សព្វាយ អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយោ អនុសេតីតិ ។ ន ខោ អាវុសោ វិសាខ សព្វាយ សុខាយ វេទនាយ រាគានុសយោ អនុសេតិ ន សព្វាយ ទុក្ខាយ វេទនាយ បដិឃានុសយោ អនុសេតិ ន សព្វាយ អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយោ អនុសេតីតិ ។ សុខាយ បនយ្យេ វេទនាយ កឹ បហាតព្វំ ទុក្ខាយ វេទនាយ កឹ បហាតព្វំ អទុក្ខមសុខាយ វេទនាយ កឹ បហាតព្វន្តិ ។ សុខាយ ខោ អាវុសោ វិសាខ វេទនាយ រាគានុសយោ បហាតព្វោ ទុក្ខាយ វេទនាយ បដិឃានុសយោ បហាតព្វោ អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយោ បហាតព្វោតិ ។ សព្វាយ នុ ខោ អយ្យេ សុខាយ វេទនាយ រាគានុសយោ បហាតព្វោ សព្វាយ ទុក្ខាយ វេទនាយ បដិឃានុសយោ បហាតព្វោ

រាគានុស័យសុទ្ធតែដេកសម្ងំនៅក្នុងសុខវេទនាទាំងអស់ បដិឃានុស័យសុទ្ធតែដេកសម្ងំនៅក្នុងទុក្ខវេទនាទាំងអស់ អវិជ្ជានុស័យសុទ្ធតែដេកសម្ងំនៅក្នុងអទុក្ខមសុខវេទនាទាំងអស់ឬដូចម្តេច ។ ម្នាលអាវុសោវិសាខ រាគានុស័យមិនសុទ្ធតែដេកសម្ងំនៅខាងក្នុងសុខវេទនាទាំងអស់ទេ បដិឃានុស័យមិនសុទ្ធតែដេកសម្ងំនៅខាងក្នុងទុក្ខវេទនាទាំងអស់ទេ អវិជ្ជានុស័យមិនសុទ្ធតែដេកសម្ងំនៅខាងក្នុងអទុក្ខមសុខវេទនាទាំងអស់ទេ ។ បពិត្រព្រះនាងជាម្ចាស់ ចុះអ្វីដែលបុគ្គលត្រូវលះបង់ដោយសុខវេទនា អ្វីដែលត្រូវលះបង់ដោយទុក្ខវេទនា អ្វីដែលត្រូវលះបង់ដោយអទុក្ខមសុខវេទនា ។ ម្នាលអាវុសោវិសាខ រាគានុស័យត្រូវលះបង់ដោយសុខវេទនា បដិឃានុស័យត្រូវលះបង់ដោយទុក្ខវេទនា អវិជ្ជានុស័យត្រូវលះបង់ដោយអទុក្ខមសុខវេទនា ។ បពិត្រព្រះនាងជាម្ចាស់ រាគានុស័យត្រូវលះបង់ដោយសុខវេទនាទាំងអស់ បដិឃានុស័យត្រូវលះបង់ដោយទុក្ខវេទនាទាំងអស់

សព្វាយ អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយោ បហាតព្វោតិ ។ ន ខោ អាវុសោ វិសាខ សព្វាយ សុខាយ វេទនាយ រាគានុសយោ បហាតព្វោ ន សព្វាយ ទុក្ខាយ វេទនាយ បដិឃានុសយោ បហាតព្វោ ន សព្វាយ អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយោ បហាតព្វោ ឥធាវុសោ វិសាខ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ រាគន្តេន បជហតិ ន តត្ថ រាគានុសយោ អនុសេតិ ឥធាវុសោ វិសាខ ភិក្ខុ ឥតិ បដិសញ្ចិក្ខតិ កុទាស្សុ នាមហំ[១] តទាយតនំ ឧបសម្បជ្ជ វិហរិស្សាមិ យទរិយា ឯតរហិ អាយតនំ ឧបសម្បជ្ជ វិហរន្តីតិ ឥតិ អនុត្តរេសុ វិមោក្ខេសុ បិហំ ឧបដ្ឋាបយតោ

អវិជ្ជានុស័យ ត្រូវលះបង់ដោយអទុក្ខមសុខវេទនា ទាំងអស់ឬ ។ ម្នាល អាវុសោវិសាខៈ រាគានុស័យ មិនត្រូវលះបង់ដោយសុខវេទនាទាំងអស់ទេ បដិឃានុស័យ មិនត្រូវលះបង់ដោយទុក្ខវេទនាទាំងអស់ទេ អវិជ្ជា-នុស័យ មិនត្រូវលះបង់ដោយអទុក្ខមសុខវេទនាទាំងអស់ទេ ។ ម្នាល អាវុសោវិសាខៈ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងប់ស្ងាត់ចាកកាម ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខដែលកើតអំពីវិវេក លោកលះបង់រាគៈដោយបឋមជ្ឈាននោះ ឯរាគានុស័យ ដេកសម្ងំនៅក្នុងបឋ-មជ្ឈាននោះ មិនបានទេ ម្នាលអាវុសោវិសាខៈ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញដូច្នេះថា កាលណាហ្ន៎ អាត្មាអញនឹងបានចូលកាន់អាយតនៈ គឺអរហត្ត ដែលពួកព្រះអរិយៈ តែងចូលក្នុងកាលឥឡូវនេះ កាលបើភិក្ខុតាំងនូវសេចក្តីប្រាថ្នា ចំពោះពួកវិមោក្ខដ៏ប្រសើរ ដូច្នេះហើយ

ឧប្បជ្ជតិ បិហប្បច្ចយា[១] ទោមនស្សំ បដិឃេន្តេន បជហាតិ ន តត្ថ បដិឃានុសយោ អនុសេតិ ឥធា- វុសោ វិសាខ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អវិជ្ជំ តេន បជហាតិ ន តត្ថ អវិជ្ជានុសយោ អនុសេតីតិ ។

[១៨២] សុខាយ បនយ្យេ វេទនាយ កឹ បដិភា- គោតិ ។ សុខាយ ខោ អាវុសោ វិសាខ វេទនាយ រាគោ បដិភាគោតិ ។ ទុក្ខាយ បនយ្យេ វេទនាយ កឹ

១ ឱ. បិហាបច្ចយា ។

ទោមនស្សរមែងកើតឡើង ព្រោះសេចក្តីប្រាថ្នាជាបច្ច័យ ភិក្ខុនោះរមែងលះបង់នូវបដិឃៈដោយទោមនស្ស[១] ឯបដិឃានុស័យ ក៏ដេកសម្ងំនៅក្នុងទោមនស្សនោះមិនបានទេ ម្នាលអាវុសោវិសាខ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់សេចក្តីសុខផង លះបង់សេចក្តីទុក្ខផង រំលត់សោមនស្សនិងទោមនស្សក្នុងកាលមុនផង ក៏ចូលកាន់ចតុត្ថជ្ឈានដែលឥតសុខឥតទុក្ខ មានតែសតិដ៏បរិសុទ្ធដោយឧបេក្ខា សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ភិក្ខុនោះរមែងលះបង់អវិជ្ជាដោយចតុត្ថជ្ឈាននោះ អវិជ្ជានុស័យដេកសម្ងំនៅក្នុងចតុត្ថជ្ឈាននោះ មិនបានឡើយ ។

[១៩២] បពិត្រព្រះនាងជាម្ចាស់ ចុះសុខវេទនា មានអ្វីជាគ្រឿងប្រៀបធៀបឲ្យប្រហែលគ្នា ។ ម្នាលអាវុសោវិសាខ សុខវេទនាមានរាគៈជាគ្រឿងប្រៀបធៀប ។ បពិត្រព្រះនាងជាម្ចាស់ ចុះទុក្ខវេទនា មានអ្វីជា

---

១ អដ្ឋកថាពន្យល់ថាមិនមែនលះបង់បដិឃៈដោយទោមនស្សតែម្តងទេ គឺភិក្ខុដែលមានសេចក្តីប្រាថ្នាចង់បានអរហត្តផល ហើយមិនបានដូចប្រាថ្នា ទោមនស្សក៏កើតឡើង ម្ល៉ោះហើយភិក្ខុនោះខំប្រឹងធ្វើសេចក្តីព្យាយាមរហូតដល់បានរលាស់បដិឃៈចោលដោយអនាគាមិមគ្គបាន ។ ម្យ៉ាងទៀត ទោមនស្សនេះ ពិតជាអកុសលដោយចំណែកមួយ មែនហើយ តែទោមនស្សនេះគួរសេពគប់ ។

បដិភាគោតិ ។ ទុក្ខាយ ខោ អាវុសោ វិសាខ វេទនាយ បដិឃោ បដិភាគោតិ ។ អទុក្ខមសុខាយ បនយ្យេ វេទនាយ កឹ បដិភាគោតិ ។ អទុក្ខម-សុខាយ ខោ អាវុសោ វិសាខ វេទនាយ អវិជ្ជា បដិ-ភាគោតិ ។ អវិជ្ជាយ បនយ្យេ កឹ បដិភាគោតិ ។ អវិជ្ជាយ ខោ អាវុសោ វិសាខ វិជ្ជា បដិភាគោតិ ។ វិជ្ជាយ បនយ្យេ កឹ បដិភាគោតិ ។ វិជ្ជាយ ខោ អាវុសោ វិសាខ វិមុត្តិ បដិភាគោតិ ។ វិមុត្តិយា បនយ្យេ កឹ បដិភាគោតិ ។ វិមុត្តិយា ខោ វិសាខ និព្វានំ បដិភាគោតិ ។ និព្វានស្ស បនយ្យេ កឹ បដិភាគោតិ ។ អច្ចសរាវុសោ[១] វិសាខ បញ្ហំ នាសក្ខិ បញ្ហានំ បរិយន្តំ គហេតុំ និព្វានោគធំ ហិ អាវុសោ វិសាខ ព្រហ្មចរិយំ និព្វានបរាយនំ និព្វានបរិយោសានំ អាកង្ខមានោ ចេ[២] ត្វំ អាវុសោ វិសាខ ភគវន្តំ ឧបសង្កមិត្វា ឯតមត្ថំ បុច្ឆេយ្យាសិ យថា ច តេ ភគវា ព្យាករេតិ តថា នំ ធារេយ្យាសីតិ ។

---

១ ឥទមដ្ឋកថាយំ អច្ចយាសីតិ បាឋោ ទិស្សតិ ។ ២ ឱ. ម. ច ។ បញ្ហំ អតិក្កមិត្វា គតោសីតិ ឯតស្សត្ថោ ។

គ្រឿងប្រៀបធៀប ។ ម្នាលអាវុសោវិសាខៈ ទុក្ខវេទនាមានបដិឃៈជាគ្រឿងប្រៀបធៀប ។ បពិត្រព្រះនាងជាម្ចាស់ ចុះអទុក្ខមសុខវេទនាមានអ្វីជាគ្រឿងប្រៀបធៀប ។ ម្នាលអាវុសោវិសាខៈ អទុក្ខមសុខវេទនាមានអវិជ្ជាជាគ្រឿងប្រៀបធៀប ។ បពិត្រព្រះនាងជាម្ចាស់ ចុះអវិជ្ជាមានអ្វីជាគ្រឿងប្រៀបធៀប ។ ម្នាលអាវុសោវិសាខៈ អវិជ្ជាមានវិជ្ជាជាគ្រឿងប្រៀបធៀប ។ បពិត្រព្រះនាងជាម្ចាស់ វិជ្ជាមានអ្វីជាគ្រឿងប្រៀបធៀប ។ ម្នាលអាវុសោវិសាខៈ វិជ្ជាមានវិមុត្តិជាគ្រឿងប្រៀបធៀប ។ បពិត្រព្រះនាងជាម្ចាស់ ចុះវិមុត្តិមានអ្វីជាគ្រឿងប្រៀបធៀប ។ ម្នាលអាវុសោវិសាខៈ វិមុត្តិមានព្រះនិព្វានជាគ្រឿងប្រៀបធៀប ។ បពិត្រព្រះនាងជាម្ចាស់ ចុះនិព្វានមានអ្វីជាគ្រឿងប្រៀបធៀប ។ ម្នាលអាវុសោវិសាខៈ អ្នកសួរជ្រុលហួសពេកហើយ អ្នកណាក៏មិនអាចនឹងកាន់យកទីបំផុតរបស់ប្រស្នាទាំងឡាយ (នេះ) បានទេ ម្នាលអាវុសោវិសាខៈ ព្រោះព្រហ្មចរិយធម៌ ឈមទៅកាន់ព្រះនិព្វាន មានព្រះនិព្វានជាទីប្រព្រឹត្តទៅខាងមុខ មានព្រះនិព្វានជាទីបំផុត ម្នាលអាវុសោវិសាខៈ បើអ្នកត្រូវការ គប្បីចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលសួរសេចក្តីនេះចុះ បើព្រះមានព្រះភាគទ្រង់ព្យាករដល់អ្នក យ៉ាងណា ត្រូវអ្នកចាំទុកនូវសេចក្តីនោះ យ៉ាងនោះចុះ ។

៣០៣

ចូឡយមកវគ្គស្ស ចូឡវេទល្លសុត្តេ ធម្មទិន្នាបសំសា

[១៨៣] អថខោ វិសាខោ ឧបាសកោ ធម្មទិន្នាយ ភិក្ខុនិយា ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ធម្មទិន្នំ ភិក្ខុនឹ អភិវាទេត្វា បទក្ខិណំ កត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វិសាខោ ឧបាសកោ យាវតកោ អហោសិ ធម្មទិន្នាយ ភិក្ខុនិយា សទ្ធឹ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។ ឯវំ វុត្តេ ភគវា វិសាខំ ឧបាសកំ ឯតទវោច បណ្ឌិតា វិសាខ ធម្មទិន្នា ភិក្ខុនី មហាបញ្ញា វិសាខ ធម្មទិន្នា ភិក្ខុនី មមញ្ចេបិ ត្វំ វិសាខ ឯតមត្ថំ បដិបុច្ឆេយ្យាសិ អហម្បិ តំ ឯវមេវ ព្យាករេយ្យំ យថា តំ ធម្មទិន្នាយ ភិក្ខុនិយា ព្យាកតំ ឯសោចេវេតស្ស[១] អត្ថោ ឯវមេតំ ធារេហីតិ ។ ឥទមវោច ភគវា អត្តមនោ វិសាខោ ឧបាសកោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ចូឡវេទល្លសុត្តំ ចតុត្ថំ និដ្ឋិតំ ។

១ ឱ. ឯសោ ចេវេតស្ស ។ ម. ឯសោ ចេវ តស្ស ។

[១៩៣] លំដាប់នោះឯង វិសាខឧបាសក បានត្រេកអររីករាយនឹងភាសិតរបស់ធម្មទិន្នាភិក្ខុនី ហើយក្រោកចាកអាសនៈថ្វាយបង្គំធម្មទិន្នា-ភិក្ខុនី ធ្វើប្រទក្សិណហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានបុញ្ញរាសី ហើយអង្គុយក្នុងទីដ៏សម-គួរ ។ លុះវិសាខឧបាសកអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលពាក្យដែលខ្លួនបានចរចា នឹងធម្មទិន្នាភិក្ខុនីទាំងប៉ុន្មាន ចំពោះព្រះមានព្រះភាគ ដោយសព្វគ្រប់ ។ លុះវិសាខឧបាសក ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងវិសាខឧបាសកយ៉ាងនេះថា ម្នាលវិសាខៈ ធម្មទិន្នាភិក្ខុនី ជាបណ្ឌិត ម្នាលវិសាខៈ ធម្មទិន្នាភិក្ខុនីជាស្ត្រីមានប្រាជ្ញាច្រើន ម្នាលវិសាខៈ បើទុកជាអ្នកត្រឡប់សួរសេចក្តីនុ៎ះនឹងតថាគតវិញ តថាគតក៏ត្រូវព្យាករសេចក្តីនុ៎ះ ដូចសេចក្តីដែលនាងធម្មទិន្នាភិក្ខុនីព្យាករហើយ យ៉ាងនោះដែរ សេចក្តីនៃប្រស្នានោះ យ៉ាងហ្នឹងហើយ ចូរអ្នកចាំទុកប្រស្នានុ៎ះយ៉ាងនេះចុះ ។ លុះព្រះមានព្រះភាគត្រាស់ភាសិតនេះហើយ វិសាខឧបាសកក៏ត្រេកអរនឹងភាសិត របស់ព្រះមានព្រះភាគ ។

ចប់ ចូឡវេទល្លសូត្រ ទី ៤ ។

# បញ្ចមំ  ចូឡធម្មសមាទានសុត្តំ

[១៨៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[១៨៥] ភគវា ឯតទវោច ចត្តារិមានិ ភិក្ខវេ ធម្មសមាទានានិ កតមានិ ចត្តារិ អត្ថិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នសុខំ អាយតឹ ទុក្ខវិបាកំ អត្ថិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នទុក្ខញ្ចេវ អាយតិញ្ច ទុក្ខវិបាកំ អត្ថិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នទុក្ខំ អាយតឹ សុខវិបាកំ អត្ថិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នសុខញ្ចេវ អាយតិញ្ច សុខវិបាកំ ។

[១៨៦] កតមញ្ច ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នសុខំ អាយតឹ ទុក្ខវិបាកំ ។ សន្តិ ភិក្ខវេ ឯកេ

# ចូឡធម្មសមាទានសូត្រ ទី ៥

[១៥៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[១៥៥] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានទាំងឡាយនេះ មាន ៤ យ៉ាង ធម្មសមាទាន ៤ យ៉ាង តើដូចម្តេចខ្លះ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាន មានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកទៅ ១ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាន មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានទុក្ខជាវិបាកតទៅ ១ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាន មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ១ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាន មានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ១ ។

[១៥៦] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានដែលមានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ តើដូចម្តេច ។ ម្នាលភិក្ខុ

៣០៤



សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នត្ថិ កាមេសុ ទោសោតិ តេ កាមេសុ បាតព្យតំ អាបជ្ជន្តិ ។ តេ ខោ[១] មោលិពន្ធាហិ[២] បរិព្វាជិកាហិ បរិចារេន្តិ តេ ឯវមាហំសុ កឹសុ នាម តេ ភោន្តោ សមណព្រាហ្មណា កាមេសុ អនាគតភយំ សម្បស្សមានា កាមានំ បហានមាហំសុ កាមានំ បរិញ្ញំ បញ្ញាបេន្តិ សុខោ ឥមិស្សា បរិព្វាជិកាយ តរុណាយ មុទុកាយ លោមសាយ ពាហាយ សម្ផស្សោតិ តេ កាមេសុ បាតព្យតំ អាបជ្ជន្តិ ។ តេ កាមេសុ បាតព្យតំ អាបជ្ជិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។ តេ តត្ថ ទុក្ខា តិព្វា[៣] កដុកា វេទនា វេទិយន្តិ តេ ឯវមាហំសុ ឥទំ ខោ តេ ភោន្តោ សមណព្រាហ្មណា កាមេសុ អនាគតភយំ សម្បស្សមានា កាមានំ បហានមាហំសុ កាមានំ បរិញ្ញំ បញ្ញាបេន្តិ

១ ម. ខោសទ្ទោ ន ទិស្សតិ ។ ២ ឱ. មោលិពទ្ធាហិ ។ ឯត្ថន្តរេ ខរាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ទាំងឡាយ មានសមណព្រាហ្មណ៍ពួកខ្លះ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទោសក្នុងកាមទាំងឡាយមិនមាន បានជាអ្នកទាំងនោះដល់នូវសេចក្តីស្រួលចិត្តក្នុងកាមទាំងឡាយ ។ សមណព្រាហ្មណ៍ទាំងនោះក៏ឲ្យនាងបរិព្វាជិកាទាំងឡាយ ដែលមានផ្នួងសក់បួងហើយបម្រើខ្លួន អ្នកទាំងនោះពោលយ៉ាងនេះថា ចុះហេតុអ្វីបានជាសមណព្រាហ្មណ៍ដ៏ចម្រើនអម្បាលនោះ ពិចារណាឃើញអនាគតភ័យ ក្នុងកាមទាំងឡាយ ហើយពោលនូវការលះបង់ នូវកាមទាំងឡាយ បញ្ញត្តនូវការកន្ទង់កាមទាំងឡាយ ដ្បិតថាសម្ផស្សកំភួនដៃ របស់នាងបរិព្វាជិកាជំទង់ ប្រកបដោយរោមទន់នេះ ជាសុខម្ល៉េះ សមណព្រាហ្មណ៍ទាំងនោះ ក៏ដល់នូវសេចក្តីស្រួលចិត្តក្នុងកាមទាំងឡាយ ។ សមណព្រាហ្មណ៍ទាំងនោះ ដល់នូវសេចក្តីស្រួលចិត្តក្នុងកាមទាំងឡាយ លុះទម្លាយរាងកាយបន្ទាប់អំពីមរណៈទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ សមណព្រាហ្មណ៍ទាំងនោះរងនូវទុក្ខវេទនាដ៏ក្លាខ្លាំង ខ្លោចផ្សាក្នុងអបាយនោះ ទើបអ្នកទាំងនោះពោលយ៉ាងនេះថា ឱ នេះហើយតើ បានជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ពិចារណាឃើញអនាគតភ័យ ក្នុងកាមទាំងឡាយ ហើយពោលនូវការលះបង់ នូវកាមទាំងឡាយ បញ្ញត្តនូវការកន្ទង់កាមទាំងឡាយ

ឥមេ ហិ មយំ កាមហេតុ កាមនិទានំ ទុក្ខា តិប្បា កដុកា វេទនា វេទិយាមាតិ ។ សេយ្យថាបិ ភិក្ខវេ គិម្ហានំ បច្ឆិមេ មាសេ មាលុវាសិបាដិកា ផលេយ្យ ។ អថខោ តំ ភិក្ខវេ មាលុវាពីជំ អញ្ញតរស្មឹ សាលមូលេ និបតេយ្យ ។ អថខោ ភិក្ខវេ យា តស្មឹ សាលេ អធិវត្ថា ទេវតា សា ភីតា ឧព្វិគ្គា[១] សន្តាសំ អាបជ្ជេយ្យ ។ អថខោ ភិក្ខវេ តស្មឹ សាលេ អធិវត្ថាយ ទេវតាយ មិត្តាមច្ចា ញាតិសាលោហិតា អារាមទេវតា វនទេវតា រុក្ខទេវតា ឱសធិតិណវនប្បតីសុ អធិវត្ថា ទេវតា សង្គម្ម សមាគម្ម ឯវំ សមស្សាសេយ្យុំ មា ភវំ ភាយិ មា ភវំ ភាយិ អប្បេវនាមេតំ មាលុវាពីជំ មោរោ វា គិលេយ្យ មិគោ វា ខាទេយ្យ ទវឌាហោ[២] វា ឌហេយ្យ វនកម្មិកា វា ឧទ្ធរេយ្យុំ ឧបចិកា វា ឧដ្ឋហេយ្យុំ[៣] អពីជំ វា បនស្សាតិ ។ អថខោ តំ ភិក្ខវេ មាលុវាពីជំ នេវ មោរោ គិលេយ្យ ន មិគោ ខាទេយ្យ ន ទវឌាហោ ឌហេយ្យ ន វនកម្មិកា ឧទ្ធរេយ្យុំ

១ ឱ. ម. សំវិគ្គា ។ ២ ម. វនឌាហោ ។ ៣ ម. ឧទ្រហេយ្យុំ ។

ឥឡូវយើងទាំងនេះ ក៏រងទុក្ខវេទនាដ៏ក្លាខ្លាំង ខ្លោចផ្សាព្រោះមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផលមែន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាផ្លែជ្រៃទុំ បែកក្នុងខែជាទីបំផុតនៃគិម្ហរដូវទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ពូជជ្រៃនោះក៏ជ្រុះចុះ ទៀបគល់រាំងភ្នំមួយដើម ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទេវតាណា ដែលអាស្រ័យនៅលើដើមរាំងភ្នំនោះ ទេវតានោះក៏ភិតភ័យភ្ញាក់ផ្អើល ដល់នូវសេចក្ដីតក់ស្លុត ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង អារាមទេវតា វនទេវតា រុក្ខទេវតានិងទេវតាដែលអាស្រ័យលើដើមឈើជាថ្នាំនឹងស្មៅ និងដើមឈើជាធំ ក្នុងព្រៃទាំងឡាយ ជាមិត្តជាអាមាត្យជាញាតិសាលោហិត របស់ទេវតាដែលអាស្រ័យនៅលើដើមរាំងភ្នំនោះ មកប្រជុំព្រមគ្នា លួងលោមយ៉ាងនេះថា អ្នកដ៏ចម្រើន កុំខ្លាចឡើយ អ្នកដ៏ចម្រើន កុំខ្លាចឡើយ ធ្វើម្ដេចឲ្យតែក្ងោកចឹកលេប ម្រឹគទំពាស៊ី ភ្លើងព្រៃឆេះ អ្នកធ្វើការងារក្នុងព្រៃបោចរោច ឬកណ្ដៀរពូនលុបនូវពូជជ្រៃនោះ ពុំនោះសោត ធ្វើម្ដេចឲ្យតែមិនមានពូជក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ក្ងោកក៏មិនចឹកលេប ម្រឹគមិនទំពាស៊ី ភ្លើងព្រៃមិនឆេះ អ្នកធ្វើការងារក្នុងព្រៃមិនបោចរោច

ន ឧបចិកា ឧដ្ឋហេយ្យុំ វីជញ្ច[១] បនស្ស ។ តំ ចាវុស្សកោ មេឃេន អភិវុដ្ឋំ សម្មទេវ វិរូហេយ្យ ។ សាស្ស មាលុវាលតា តរុណា មុទុកា លោមសា វិលម្ពិនី ។ សា តំ សាលំ ឧបនិសេវេយ្យ ។ អថខោ ភិក្ខវេ តស្មឹ សាលេ អធិវត្ថាយ ទេវតាយ ឯវមស្ស កឹសុ នាម តេ ភោន្តោ មិត្តាមច្ចា ញាតិសាលោហិតា អារាមទេវតា វនទេវតា រុក្ខទេវតា ឱសធិតិណវនប្បតីសុ អធិ-វត្ថា ទេវតា មាលុវាវីជេ អនាគតភយំ សម្បស្ស-មានា សង្គម្ម សមាគម្ម ឯវំ សមស្សាសេសុំ មា ភវំ ភាយិ មា ភវំ ភាយិ អប្បេវ នាមេតំ មាលុវាវីជំ មោរោ វា គិលេយ្យ មិគោ វា ខា-ទេយ្យ ទវឌាហោ វា ឌហេយ្យ វនកម្មិកា វា ឧទ្ធរេយ្យុំ ឧបចិកា វា ឧដ្ឋហេយ្យុំ អវីជំ វា បនស្សាតិ សុខោ ឥមិស្សា មាលុវាលតាយ តរុណាយ មុទុកាយ លោមសាយ វិលម្ពិនិយា សម្ផស្សោតិ ។ សា តំ សាលំ អនុបរិវារេយ្យ[២] ។ សា តំ សាលំ

១ ឱ. ពីជំ ។ ម. ពីជំ វា ។ ២ ឱ. ម. អនុបរិហរេយ្យ ។

កណ្ដៀរមិនពូនលុបនូវពូជជ្រៃនុ៎ះ ពូជក៏នៅតែមាន ។ លុះមេឃមានភ្លៀងបង្អុរចុះមក ពូជជ្រៃនោះក៏ដុះលូតលាស់ឡើង ។ ពូជជ្រៃនោះ ខ្ចីទន់មានព្រុយសំយុងចុះ ។ ពូជជ្រៃនោះក៏រួបរឹតដើមរាំងភ្នំនោះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទេវតាដែលអាស្រ័យលើដើមរាំងភ្នំនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ហេតុអ្វីបានជា អារាមទេវតា វនទេវតា រុក្ខ-ទេវតានិងទេវតា ដែលអាស្រ័យនៅ លើដើមឈើជាថ្នាំនឹងស្មៅ និងឈើជាធំក្នុងព្រៃទាំងឡាយ ជាមិត្តជាអាមាត្យជាញាតិសាលោហិត ពិចារណាឃើញនូវអនាគតភ័យ ក្នុងពូជជ្រៃទាំងឡាយ ហើយប្រជុំព្រមគ្នា លួងលោមយ៉ាងនេះថា អ្នកដ៏ចម្រើន កុំខ្លាចឡើយ អ្នកដ៏ចម្រើន កុំខ្លាចឡើយ ធ្វើម្ដេចឲ្យតែក្ងោកចឹកលេប ម្រឹគទំពាស៊ី ភ្លើងព្រៃឆេះ អ្នកធ្វើការងារក្នុងព្រៃបោចរោច កណ្ដៀរពូនលុបនូវពូជជ្រៃនុ៎ះ ពុំនោះសោត ធ្វើម្ដេចឲ្យតែមិនមានពូជ ដូច្នេះ (បើ) សម្ផស្សរបស់ពួរជ្រៃនោះ ខ្ចីទន់មានព្រុយសំយុងចុះស្រួលម៉្លេះ ។ (លុះកាលតមក) ពួរជ្រៃនោះ ក៏រួបរឹតដើមរាំងភ្នំនោះ ។ លុះពួរជ្រៃនោះ រួបរឹតដើមរាំងភ្នំនោះហើយ

អនុបរិហរិត្វា ឧបរិ វិដភំ ករិត្វា ឱឃនំ ជនេត្វា[១] យេ តស្ស សាលស្ស មហន្តា មហន្តា ខន្ធា តេ បទាលេយ្យ ។ អថ ខោ ភិក្ខវេ តស្មឹ សាលេ អធិវត្ថាយ ទេវតាយ ឯវមស្ស ឥទំ ខោ តេ ភោន្តោ មិត្តាមច្ចា ញាតិសាលោហិតា អារាមទេវតា វនទេវតា រុក្ខទេវតា ឱសធិតិណវនប្បតីសុ អធិវត្ថា ទេវតា មាលុវាវីជេ អនាគតភយំ សម្បស្សមានា សង្គម្ម សមាគម្ម ឯវំ សមស្សាសេសុំ មា ភវំ ភាយិ មា ភវំ ភាយិ អប្បេវ នាមេតំ មាលុវាវីជំ មោរោ វា គិលេយ្យ មិគោ វា ខាទេយ្យ ទវឌាហោ វា ឌហេយ្យ វនកម្មិកា វា ឧទ្ធរេយ្យុំ ឧបចិកា វា ឧដ្ឋហេយ្យុំ អវីជំ វា បនស្សាតិ ស្វាហំ[២] មាលុវាវីជហេតុ ទុក្ខា តិប្បា កដុកា វេទនា វេទិយាមីតិ ។ ឯវមេវ ខោ ភិក្ខវេ សន្តិ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ នត្ថិ កាមេសុ ទោសោតិ តេ កាមេសុ បាតព្យតំ អាបជ្ជន្តិ ។ តេ ខោ មោលិពទ្ធាហិ បរិព្វាជិកាហិ

---

១ ឱ. ម. អនុបរិហរិត្វា ឧបរិវិដភំ ករេយ្យ ឧបរិ វិដភំ ករិត្វា ឱឃនំ ជនេយ្យ ឱឃនំ ជនេត្វាតិ ទិស្សន្តិ ។ ២ ឱ. យញ្ចាហំ ។ ម. យំ ចាហំ ។

ក៏ធ្វើជាប្រគាបស៊ុមទ្រុមខាងលើ សំយុងពួរចុះចាប់ផែនដី ទម្លាយនូវដើមរាំងភ្នំធំ ៗ នោះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ទេវតាដែលអាស្រ័យនៅដើមរាំងភ្នំនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱ នេះហើយបានជា អារាមទេវតា វនទេវតា រុក្ខទេវតា និងទេវតាដែលអាស្រ័យលើដើមឈើជាថ្នាំនឹងស្មៅ និងដើមឈើធំក្នុងព្រៃទាំងឡាយជាមិត្តជាអាមាត្យ ជាញាតិសាលោហិត ពិចារណាឃើញអនាគតភ័យក្នុងពូជព្រៃ ហើយមកប្រជុំព្រមគ្នា លួងលោមយ៉ាងនេះថា អ្នកដ៏ចម្រើនកុំខ្លាចឡើយ អ្នកដ៏ចម្រើន កុំខ្លាចឡើយ ធ្វើម្តេចឲ្យតែក្ងោកចឹកលេបម្រឹគទំពាស៊ី ភ្លើងព្រៃឆេះ អ្នកធ្វើការងារក្នុងព្រៃបោចរោច កណ្ដៀរពូនលុបនូវពូជព្រៃនុ៎ះ ពុំនោះសោត ធ្វើម្តេចឲ្យតែមិនមានពូជ ឥឡូវអញក៏បានរងទុក្ខវេទនា ដ៏ក្លាខ្លាំង ខ្លោចផ្សា ព្រោះហេតុតែពូជព្រៃសេចក្តីនេះមានឧបមាយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចជាសមណព្រាហ្មណ៍ពួកខ្លះ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទោសក្នុងកាមទាំងឡាយមិនមាន បានជាអ្នកទាំងនោះដល់នូវសេចក្តីស្រួលចិត្ត ក្នុងកាមទាំងឡាយ ។ សមណព្រាហ្មណ៍ទាំងនោះក៏ឲ្យពួកនាងបរិព្វាជិកា ដែលមានផ្នួងសក់បួងហើយ បម្រើខ្លួន

បរិចារេន្តិ តេ ឯវមាហំសុ កឹសុ ណាម តេ ភោន្តោ សមណព្រាហ្មណា កាមេសុ អនាគតភយំ សម្បស្សមានា កាមានំ បហានមាហំសុ កាមានំ បរិញ្ញំ បញ្ញាបេន្តិ សុខោ ឥមិស្សា បរិព្វាជិកាយ តរុណាយ មុទុកាយ លោមសាយ ពាហាយ សម្ផស្សោតិ តេ កាមេសុ បាតព្យតំ អាបជ្ជន្តិ ។ តេ កាមេសុ បាតព្យតំ អាបជ្ជិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។ តេ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទិយន្តិ តេ តត្ថ[១] ឯវមាហំសុ ឥទំ ខោ តេ ភោន្តោ សមណព្រាហ្មណា កាមេសុ អនាគតភយំ សម្បស្សមានា កាមានំ បហានមាហំសុ កាមានំ បរិញ្ញំ បញ្ញាបេន្តិ ឥមេ ហិ មយំ កាមហេតុ កាមនិទានំ ទុក្ខា តិព្វា កដុកា វេទនា វេទិយាមាតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នសុខំ អាយតឹ ទុក្ខវិបាកំ ។

១ ឱ. ម. តត្ថាតិ ន ទិស្សតិ ។

អ្នកទាំងនោះពោលយ៉ាងនេះថា ចុះហេតុអ្វីបានជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ពិចារណាឃើញនូវអនាគតភ័យ ក្នុងកាមទាំងឡាយ ហើយពោលនូវការលះបង់ នូវកាមទាំងឡាយ បញ្ញត្តនូវការកន្លងកាមទាំងឡាយ ដ្បិតជាសម្ផស្សកំភួនដៃរបស់នាងបរិព្វាជិកាជំទង់ ប្រកបដោយរោមទន់នេះ ជាសុខម្ល៉េះ សមណព្រាហ្មណ៍ទាំងនោះក៏ដល់នូវសេចក្តីស្រួលចិត្តក្នុងកាមទាំងឡាយ ។ លុះសមណព្រាហ្មណ៍ទាំងនោះ ដល់នូវសេចក្តីស្រួលចិត្តក្នុងកាមទាំងឡាយហើយ ទម្លាយរាងកាយបន្ទាប់អំពីមរណៈទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ សមណព្រាហ្មណ៍ទាំងនោះរងនូវទុក្ខវេទនាដ៏ក្លាខ្លាំង ខ្លោចផ្សា ក្នុងអបាយនោះ ទើបសមណព្រាហ្មណ៍ទាំងនោះ ពោលយ៉ាងនេះ ក្នុងទីនោះថា ឱ នេះហើយតើបានជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ពិចារណាឃើញអនាគតភ័យក្នុងកាមទាំងឡាយ ហើយពោលនូវការលះបង់ នូវកាមទាំងឡាយ បញ្ញត្តនូវការកន្លងកាមទាំងឡាយ ឥឡូវយើងទាំងនេះ ក៏រងនូវទុក្ខវេទនា ដ៏ក្លាខ្លាំង ខ្លោចផ្សា ព្រោះមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតពោលថា មានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ ។

[១៨៧] កតមញ្ច ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នទុក្ខញ្ចេវ អាយតិញ្ច ទុក្ខវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ អចេលកោ ហោតិ មុត្តាចារោ ហត្ថាវលេខនោ ន ឯហិភទន្តិកោ ន តិដ្ឋភទន្តិកោ ន អភិហតំ ន ឧទ្ទិស្ស កតំ ន និមន្តនំ សាទិយតិ ។ សោ ន កុម្ភិមុខា បដិគ្គណ្ហាតិ ន កឡោបិមុខា បដិគ្គណ្ហាតិ ន ឯឡកមន្តរំ ន មូសលន្តរំ ន ទណ្ឌមន្តរំ[១] ន ទ្វិន្នំ ភុញ្ជមានានំ ន គព្ភិនិយា ន បាយមានាយ ន បុរិសន្តរគតាយ ន សង្កិត្តីសុ ន យត្ថ សា ឧបដ្ឋិតោ ហោតិ ន យត្ថ មក្ខិកា សណ្ឌសណ្ឌចារិនី ន មច្ឆំ ន មំសំ ន សុរំ ន មេរយំ ន ថុសោទកំ បិវតិ ។ សោ ឯកាគារិកោ វា ហោតិ ឯកាលោបិកោ

១ ឱ. ន ទណ្ឌមន្តរំ ន មូសលមន្តរន្តិ ទិស្សតិ ។

[១៩៧] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាន ដែលមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីទុក្ខជាវិបាកតទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអចេលក៍ (អ្នកប្រព្រឹត្តអាក្រាត) លះបង់មារយាទល្អ បរិភោគលិទ្ធដៃ គេអញ្ជើញថាចូរមក មិនចូល គេឃាត់ថាឈប់ មិនឈប់ មិនត្រេកអរនឹងភត្ត ដែលគេនាំមកចំពោះ មិកត្រេកអរនឹងភត្តដែលគេធ្វើចំពោះខ្លួន មិនត្រេកអរនឹងការនិមន្ត ។ អចេលក៍នោះ មិនទទួលភត្តដែលគេដួសអំពីមាត់ឆ្នាំង មិនទទួលភត្តអំពីមាត់ចង្អេរកឡោបី មិនទទួលភត្តដែលគេឲ្យត្រង់ចន្លោះ(១) ធរណីទ្វារ មិនទទួលភត្តដែលគេឲ្យត្រង់ចន្លោះ(២)អង្រែ មិនទទួលភត្តដែលគេឲ្យត្រង់ចន្លោះកំណាត់ឈើ មិនទទួលភត្តដែលជនពីរនាក់កំពុងបរិភោគនាំមកឲ្យ មិនទទួលភត្តរបស់ស្រីមានគភ៌ មិនទទួលភត្តរបស់ស្រីកំពុងបំបៅកូន មិនទទួលភត្តរបស់ស្រីនៅក្នុងចន្លោះបុរស មិនទទួលភត្តក្នុងកាលដែលពួកគ្នាឯងធ្វើអង្គាសបាន មិនទទួលភត្តក្នុងទីមានឆ្កែចាំ មិនទទួលភត្តក្នុងទីមានរុយរោម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកត្រាំថ្នាំ ។ អចេលក៍នោះ ទទួលភត្តចំពោះតែផ្ទះមួយខ្វះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយមួយពំនូតខ្វះ

---

១ ក្នុងវេលាដែលគេកំពុងឈរត្រង់ធរណីទ្វារ ។ ២ ក្នុងវេលាដែលគេកំពុងកាន់អង្រែបុក ។

ទ្វាគារិកោ វា ហោតិ ទ្វាលោបិកោ ។ បេ ។ សត្តាគារិកោ វា ហោតិ សត្តាលោបិកោ ឯកិស្សាបិ ទត្តិយា យាបេតិ ទ្វីហិបិ ទត្តីហិ យាបេតិ ។ បេ ។ សត្តហិបិ ទត្តីហិ យាបេតិ ឯកាហិកម្បិ អាហារំ អាហារេតិ ទ្វីហិកម្បិ អាហារំ អាហារេតិ ។ បេ ។ សត្តាហិកម្បិ អាហារំ អាហារេតិ ឥតិ ឯវរូបំ អឌ្ឍមាសិកំបិ បរិយាយភត្តភោជនានុយោគមនុយុត្តោ វិហរតិ ។ សោ សាកភក្ខោ វា ហោតិ សាមាកភក្ខោ វា ហោតិ និវារភក្ខោ វា ហោតិ ទទ្ទុលភក្ខោ វា ហោតិ ហដភក្ខោ វា ហោតិ កណភក្ខោ វា ហោតិ អាចាមភក្ខោ វា ហោតិ បិញ្ញាកភក្ខោ វា ហោតិ តិណភក្ខោ វា ហោតិ គោមយភក្ខោ វា ហោតិ វនមូលផលាហារោ យាបេតិ បវត្តផលភោជី ។ សោ សាណានិបិ ធារេតិ មសាណានិបិ ធារេតិ ឆវទុស្សានិបិ ធារេតិ បំសុកូលានិបិ ធារេតិ តិរីដានិបិ ធារេតិ អជ្ជិនានិបិ[១] ធារេតិ អជ្ជិនក្ខិបម្បិ[២] ធារេតិ កុសចីរម្បិ ធារេតិ

១ ម. អជ្ជិនំបិ ។ ២ ម. អជ្ជិនក្ខិបំបិ ។

ទទួលកត្តុចំពោះតែផ្ទះពីរខ្លះ ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយពីរពំនូតខ្លះ ។ បេ ។ ទទួលកត្តុចំពោះតែផ្ទះ ៧ ខ្លះ ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយ ៧ ពំនូតខ្លះ ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយកត្តក្នុងភាជន៍មួយខ្លះ ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយកត្តក្នុងភាជន៍ពីរខ្លះ ។ បេ ។ ញុាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយកត្តក្នុងភាជន៍ ៧ ខ្លះ បរិភោគអាហាររំលង ១ ថ្ងៃខ្លះ បរិភោគអាហាររំលង ៧ ថ្ងៃខ្លះ អចេលក៍នោះ ប្រកបនូវភត្តភោជនដោយការផ្លាស់ប្តូរគ្នាអស់កន្លះខែ មានសភាពយ៉ាងនេះ ដោយប្រការដូច្នេះឯង ។ អចេលក៍នោះ មានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្លូយជាអាហារខ្លះ មានចំនៀរស្បែកជាអាហារខ្លះ មានសារាយជាអាហារខ្លះ មានកុណ្ឌកជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានកំញ៉ានជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមផ្លែឈើក្នុងព្រៃជាអាហារ និងផ្លែឈើដែលជ្រុះចុះឯងជាភោជនខ្លះ ។ អចេលក៍នោះ ប្រើប្រាស់សំពត់សម្បកធ្មៃខ្លះ ប្រើប្រាស់សំពត់ដែលត្បាញលាយគ្នាខ្លះ ប្រើប្រាស់សំពត់ស្នបខ្លះ ប្រើប្រាស់សំពត់បំសុកូលខ្លះ ប្រើប្រាស់សំពត់សំបកឈើខ្លះ ប្រើប្រាស់ស្បែកខ្លាខ្លះ ប្រើប្រាស់ស្បែកខ្លាទាំងក្រចកខ្លះ ប្រើប្រាស់សំពត់ដែលក្រងដោយស្បូវភ្លាំងខ្លះ ប្រើប្រាស់

ផលកចីរម្បិ ធារេតិ កេសកម្ពលម្បិ ធារេតិ ឧលូ្ល-
កបក្ខម្បិ ធារេតិ កេសមស្សុលោចកោបិ ហោតិ
កេសមស្សុលោចនានុយោគមនុយុត្តោ ឧព្ភដ្ឋកោបិ
ហោតិ អាសនប្បដិក្ខិត្តោបិ ឧក្កុដិកោបិ ហោតិ
ឧក្កុដិកប្បធានមនុយុត្តោ កណ្ដកាបស្សយិកោបិ
ហោតិ កណ្ដកាបស្សយេ សេយ្យំ កប្បេតិ សា-
យតតិយកម្បិ ឧទកោរោហនានុយោគមនុយុត្តោ
វិហរតិ ឥតិ ឯវរូបំ អនេកវិហិតំ កាយស្ស អាតា-
បនបរិតាបនានុយោគមនុយុត្តោ វិហរតិ ។ សោ
កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ
និរយំ ឧបបជ្ជតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ធម្មសមា-
ទានំ បច្ចុប្បន្នទុក្ខញ្ចេវ អាយតិញ្ច ទុក្ខវិបាកំ ។

[១៩៨] កតមញ្ច ភិក្ខវេ ធម្មសមាទានំ
បច្ចុប្បន្នទុក្ខំ អាយតឹ សុខវិបាកំ ។ ឥធ ភិក្ខវេ
ឯកច្ចោ បកតិយា តិព្វរាគជាតិកោ ហោតិ សោ
អភិក្ខណំ រាគជំ ទុក្ខំ ទោមនស្សំ បដិសំវេ-
ទេតិ ។ បកតិយា តិព្វទោសជាតិកោ ហោតិ

សំពត់ដែលធ្វើដោយបន្ទះឈើខ្លះ ប្រើប្រាស់សំពត់កម្ពល ដែលត្បាញដោយសក់មនុស្សខ្លះ ប្រើប្រាស់សំពត់ដែលត្បាញដោយស្លាបមៀមខ្លះ ជាអ្នកដកសក់និងពុកមាត់ខ្លះ ប្រកបរឿយ ៗ នូវការដកសក់និងពុកមាត់ខ្លះ ជាអ្នកឈរសម្រឹងខាងលើខ្លះ ហាមឃាត់អាសនៈខ្លះ អង្គុយច្រហោងខ្លះ ជាអ្នកប្រកបរឿយ ៗ នូវការព្យាយាមក្នុងការអង្គុយច្រហោងខ្លះ ដេកលើបន្លាខ្លះ សម្រេចការដេកលើបន្លាខ្លះ ប្រកបរឿយ ៗ ក្នុងការព្យាយាមចុះត្រាំទឹកគម្រប់ ៣ ដង ទាំងវេលាល្ងាចខ្លះ អបេលក៏នោះ ជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមធ្វើកាយឲ្យក្តៅក្រហាយច្រើនយ៉ាង មានសភាពយ៉ាងនេះ ដោយប្រការដូច្នេះឯង ។ អបេលក៏នោះ លុះទម្លាយកាយបន្ទាប់អំពីមរណៈទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតពោលថា មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន និងមានសេចក្តីទុក្ខជាវិបាកតទៅ ។

[១៩៨] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានដែលមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកមានជាតិប្រកបដោយរាគៈដ៏ក្លៀវក្លាតាមប្រក្រតី បុគ្គលនោះតែងរងសេចក្តីទុក្ខ ទោមនស្សដែលកើតអំពីរាគៈរឿយ ៗ ។ ជាអ្នកមានជាតិប្រកបដោយទោសៈដ៏ក្លៀវក្លា

សោ អភិក្ខណំ ទោសជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ បកតិយា តិព្វមោហជាតិកោ ហោតិ សោ អភិក្ខណំ មោហជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សោ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន ផុដ្ឋោ សមានោ[១] អស្សុមុខោបិ រោទមានោ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរតិ ។ សោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ឥទំ វុច្ចតិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នទុក្ខំ អាយតឹ សុខវិបាកំ ។

[១៥៩] កតមញ្ច ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នសុខញ្ចេវ អាយតិញ្ច សុខវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ បកតិយា ន តិព្វរាគជាតិកោ ហោតិ សោ អភិក្ខណំ ន រាគជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ បកតិយា ន តិព្វទោសជាតិកោ ហោតិ

១ ឱ. ម. ផុដ្ឋោ សមានោតិ ន ទិស្សតិ ។

តាមប្រក្រតី បុគ្គលនោះតែងរងសេចក្តីទុក្ខទោមនស្ស ដែលកើតអំពីទោសៈរឿយ ៗ ។ ជាអ្នកមានជាតិប្រកបដោយមោហៈដ៏ក្លៀវក្លាតាមប្រក្រតី បុគ្គលនោះតែងរងសេចក្តីទុក្ខទោមនស្ស ដែលកើតអំពីមោហៈរឿយ ៗ ។ បុគ្គលនោះ ទោះបីសេចក្តីទុក្ខពាល់ត្រូវក្តី ទោះបីទោមនស្សពាល់ត្រូវក្តី ទោះបីមានមុខទទឹកដោយទឹកភ្នែក ទួញយំក្តី ក៏គង់តែប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌ បរិសុទ្ធបាន ។ បុគ្គលនោះលុះទម្លាយរាងកាយបន្ទាប់អំពីមរណៈទៅ តែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតហៅថាមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ។

[១៥៩] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានដែលមានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ មិនជាអ្នកមានជាតិប្រកបដោយរាគៈដ៏ក្លៀវក្លាតាមប្រក្រតី បុគ្គលនោះមិនរងទុក្ខទោមនស្សដែលកើតអំពីរាគៈរឿយ ៗ ។ មិនជាអ្នកមានជាតិប្រកបដោយទោសៈដ៏ក្លៀវក្លាតាម

សោ អភិក្ខណំ ច ទោសជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ បកតិយា ច តិព្វមោហជាតិកោ ហោតិ សោ អភិក្ខណំ ច មោហជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ... តតិយំ ឈានំ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នសុខញ្ចេវ អាយតិញ្ច សុខវិបាកំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ធម្មសមាទានានីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ចូឡធម្មសមាទានសុត្តំ បញ្ចមំ និដ្ឋិតំ ។

ប្រក្រតី បុគ្គលនោះ មិនរងទុក្ខទោមនស្ស ដែលកើតអំពីទោសៈរឿយ ៗ ។ មិនជាអ្នកមានជាតិប្រកបដោយមោហៈដ៏ក្លៀវក្លាតាមប្រក្រតី បុគ្គលនោះ មិនរងទុក្ខទោមនស្សដែលកើតអំពីមោហៈរឿយ ៗ ។ បុគ្គលនោះជាអ្នកស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំង-ឡាយ ក៏ចូលកាន់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈវិចារៈ មានបីតិនិងសុខកើតអំពីសេចក្តីស្ងប់ស្ងាត់ ។ លុះបុគ្គលនោះបានរម្ងាប់វិតក្កៈវិចារៈហើយ ក៏ចូលកាន់ទុតិយជ្ឈានដែលមានក្នុងខ្លួន ជាទីជ្រះថ្លា មានភាពនៃចិត្តដ៏ខ្ពស់ឯក គ្មានវិតក្កៈ គ្មានវិចារៈ មានតែបីតិនិងសុខកើតអំពីសមាធិ... ចូលកាន់តតិយជ្ឈាន... ចូលកាន់ចតុត្ថជ្ឈាន ។ បុគ្គលនោះលុះទម្លាយរាងកាយបន្ទាប់អំពីមរណៈទៅ តែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតហៅថាមានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាធម្មសមាទានមាន ៤ ប្រការ ។ លុះព្រះមានព្រះភាគសំដែងភាសិតនេះចប់ហើយ ភិក្ខុទាំងនោះក៏មានចិត្តត្រេកអរ រីករាយហើយនឹងភាសិត របស់ព្រះមានព្រះភាគ ។

ចប់ ចូឡធម្មសមាទានសូត្រ ទី ៥ ។

# ឆដ្ឋំ មហាធម្មសមាទានសុត្តំ

[១៦០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារា-មេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[១៦១] ភគវា ឯតទវោច យេភុយ្យេន ភិក្ខវេ សត្តា ឯវំកាមា ឯវំឆន្ទា ឯវំអធិប្បាយា អហោ វត អនិដ្ឋា អកន្តា អមនាបា[១] បរិហាយេយ្យុំ ឥដ្ឋា កន្តា មនាបា[២] អភិវឌ្ឍេយ្យុន្តិ តេសំ ភិក្ខវេ សត្តានំ ឯវំកាមានំ ឯវំឆន្ទានំ ឯវំអធិប្បាយានំ អនិដ្ឋា អកន្តា អមនាបា ធម្មា អភិវឌ្ឍន្តិ ឥដ្ឋា កន្តា មនាបា ធម្មា បរិហាយន្តិ តត្រ តុម្ហេ ភិក្ខវេ តំ កិស្ស ហេតុ បច្ចេថាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា

---

១-២ ឱ. ម. ឯត្ថន្តរេ ធម្មាតិ ទិស្សតិ ។

# មហាធម្មសមាទានសូត្រ ទី ៦

[១៦០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[១៦១] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំង-ឡាយ សត្វទាំងឡាយច្រើនតែមានសេចក្តីប្រាថ្នាយ៉ាងនេះ មានអធ្យា-ស្រ័យយ៉ាងនេះ មានបំណងយ៉ាងនេះថា ធ្វើម្តេចហ្ន៎ អារម្មណ៍ទាំងឡាយមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត គប្បីសាបសូន្យទៅ អារម្មណ៍ទាំងឡាយដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត គប្បីចម្រើនឡើង ម្នាលភិក្ខុទាំងឡាយ កាលសត្វអម្បាលនោះ មានសេចក្តីប្រាថ្នាយ៉ាងនេះ មានអធ្យាស្រ័យយ៉ាងនេះ មានបំណងយ៉ាងនេះ អារម្មណ៍មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងចម្រើនឡើង អារម្មណ៍ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងសាបសូន្យទៅ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយពិចារណាឃើញនូវដំណើរនោះដូចម្តេចក្នុងអារម្មណ៍ទាំងនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ពួក

ភគវំនេត្តិកា ភគវំបដិសរណា សាធុ វត ភន្តេ ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[១៦២] ភគវា ឯតទវោច ឥធ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ សេវិតព្វេ ធម្មេ ន ជានាតិ អសេវិតព្វេ ធម្មេ ន ជានាតិ ភជិតព្វេ ធម្មេ ន ជានាតិ អភជិតព្វេ ធម្មេ ន ជានាតិ ។ សោ សេវិតព្វេ ធម្មេ អជានន្តោ អសេវិតព្វេ ធម្មេ អជានន្តោ ភជិតព្វេ ធម្មេ អជានន្តោ អភជិតព្វេ ធម្មេ អជានន្តោ អសេវិតព្វេ ធម្មេ សេវតិ សេវិតព្វេ ធម្មេ ន សេវតិ អភជិតព្វេ ធម្មេ ភជតិ ភជិតព្វេ ធម្មេ ន ភជតិ ។ តស្ស

ខ្ញុំព្រះអង្គ មានព្រះមានព្រះភាគជាមូល មានព្រះមានព្រះភាគ ជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់បំភ្លឺនូវអត្ថនៃភាសិតនុ៎ះ ភិក្ខុទាំងឡាយបើបានស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគហើយនឹងចងចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះអ្នកទាំងឡាយចូរស្តាប់ ចូរធ្វើមនសិការៈដោយប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[១៦២] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនដែលបានស្តាប់ មិនដែលបានឃើញព្រះអរិយៈទាំងឡាយ មិនឈ្លាសក្នុងអរិយធម៌ មិនទូន្មានខ្លួនក្នុងអរិយធម៌ មិនឃើញសប្បុរសទាំងឡាយ មិនឈ្លាសក្នុងធម៌របស់សប្បុរស មិនទូន្មានខ្លួនក្នុងធម៌របស់សប្បុរស មិនស្គាល់ធម៌[១] ដែលគួរសេព មិនស្គាល់ធម៌ដែលមិនគួរសេព មិនស្គាល់ធម៌ដែលគួរគប់ មិនស្គាល់ធម៌ដែលមិនគួរគប់ ។ កាលបុថុជ្ជននោះ មិនស្គាល់ធម៌ដែលគួរសេព មិនស្គាល់ធម៌ដែលមិនគួរសេព មិនស្គាល់ធម៌ដែលគួរគប់ មិនស្គាល់ធម៌ដែលមិនគួរគប់ តែងសេពនូវធម៌ដែលមិនគួរសេព មិនសេពនូវធម៌ដែលគួរសេព គប់នូវធម៌ដែលមិនគួរគប់ មិនគប់នូវធម៌ដែលគួរគប់ ។ កាលបើបុថុជ្ជននោះ

---

១ ធម៌ ក្នុងទីនេះ សំដៅយកអារម្មណ៍មានរូបារម្មណ៍ជាដើម ។

៣១៧

ចូឡយមកវគ្គស្ស  មហាធម្មសមាទានសុត្តេ  សេវិតព្វាសេវិតព្វធម្មា

អសេវិតព្វេ ធម្មេ សេវតោ សេវិតព្វេ ធម្មេ អសេវតោ អភជិតព្វេ ធម្មេ ភជតោ ភជិតព្វេ ធម្មេ អភជតោ អនិដ្ឋា អកន្តា អមនាបា ធម្មា អភិវឌ្ឍន្តិ ឥដ្ឋា កន្តា មនាបា ធម្មា បរិហាយន្តិ តំ កិស្ស ហេតុ ឯវំ ហេតំ ភិក្ខវេ ហោតិ យថាតំ អវិទ្ទសុនោ ។ សុតវា ច ខោ ភិក្ខវេ អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនី-តោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុរិសធម្មេ សុវិនីតោ សេវិតព្វេ ធម្មេ ជានាតិ[១] អសេវិតព្វេ ធម្មេ ជានាតិ[២] ភជិតព្វេ ធម្មេ ជានាតិ[៣] អភជិតព្វេ ធម្មេ ជានាតិ[៤] ។ សោ សេវិតព្វេ ធម្មេ ញត្វា អសេវិតព្វេ ធម្មេ ញត្វា ភជិតព្វេ ធម្មេ ញត្វា អភជិតព្វេ ធម្មេ ញត្វា អសេវិតព្វេ ធម្មេ ន សេវតិ សេវិតព្វេ ធម្មេ សេវតិ អភជិតព្វេ ធម្មេ ន ភជតិ ភជិតព្វេ ធម្មេ ភជតិ ។ តស្ស អសេវិតព្វេ ធម្មេ អសេវតោ សេវិតព្វេ ធម្មេ សេវតោ

១-២-៣-៤ ឱ. បជានាតិ ។

សេពនូវធម៌ដែលមិនគួរសេព មិនសេពនូវធម៌ដែលគួរសេព គប់នូវធម៌ដែលមិនគួរគប់ មិនគប់នូវធម៌ដែលគួរគប់ អារម្មណ៍ទាំងឡាយមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត តែងចម្រើនឡើង អារម្មណ៍ទាំងឡាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ក៏សាបសូន្យទៅ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះបុថុជ្ជនអន្ធពាលមិនដឹងតាមពិត ក៏រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងអរិយសាវ័កដែលបានស្តាប់ បានឃើញព្រះអរិយៈទាំងឡាយ ជាអ្នកឈ្លាសក្នុងអរិយធម៌ ទូន្មានខ្លួនល្អក្នុងសប្បុរិសធម៌ ស្គាល់ធម៌ដែលគួរសេព ស្គាល់ធម៌ដែលមិនគួរសេព ស្គាល់ធម៌ដែលគួរគប់ ស្គាល់ធម៌ដែលមិនគួរគប់ ។ កាលអរិយសាវ័កនោះ ស្គាល់ធម៌ដែលគួរសេព ស្គាល់ធម៌ដែលមិនគួរសេព ស្គាល់ធម៌ដែលគួរគប់ ស្គាល់ធម៌ដែលមិនគួរគប់ ទើបមិនសេពធម៌ដែលមិនគួរសេព សេពតែធម៌ដែលគួរសេព មិនគប់ធម៌ដែលមិនគួរគប់ គប់តែធម៌ដែលគួរគប់ ។ កាលបើអរិយ-សាវ័កនោះ មិនសេពធម៌ដែលមិនគួរសេព សេពតែធម៌ដែលគួរសេព

អកុសលញ្ច ធម្មំ អកុសលតោ កុសលញ្ច ធម្មំ កុសលតោ អជានន្តា អបស្សន្តា អមត្តញ្ញុតាយ ធម្មា បរិហាយន្តិ ឥច្ចេតំ កាមានំ អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ អប្បជានន្តា ... ហេតុ ឯវំ ហេតំ ភិក្ខវេ ហោតិ យថាតំ វិញ្ញូសុ ជាតិ(១) ។

[១៦៣] ចត្តារិមានិ ភិក្ខវេ ធម្មសមាទានានិ កតមានិ ចត្តារិ អត្ថិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នទុក្ខញ្ចេវ អាយតិញ្ច ទុក្ខវិបាកំ អត្ថិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នសុខំ អាយតឹ ទុក្ខវិបាកំ អត្ថិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នទុក្ខំ អាយតឹ សុខវិបាកំ អត្ថិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នសុខញ្ចេវ អាយតិញ្ច សុខវិបាកំ ។

[១៦៤] តត្រ ភិក្ខវេ យមិទំ ធម្មសមាទានំ បច្ចុប្បន្នទុក្ខញ្ចេវ អាយតិញ្ច ទុក្ខវិបាកំ

---

១ ឱ. ម. ឥតិសទ្ទោ ន ទិស្សតិ ។

មិនគប់ធម៌ដែលមិនគួរគប់ គប់តែធម៌ដែលគួរគប់ អារម្មណ៍ទាំងឡាយមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងសាបសូន្យទៅ អារម្មណ៍ទាំងឡាយដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត តែងចម្រើនឡើង ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះអរិយសាវ័កជាអ្នកដឹងតាមពិត ក៏រមែងដូច្នោះឯង ។

[១៦៣] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានទាំងឡាយនេះមាន ៤ យ៉ាង ធម្មសមាទានទាំង ៤ យ៉ាង តើដូចម្ដេចខ្លះ ម្នាលភិក្ខុទាំង-ឡាយ ធម្មសមាទាន ដែលមានសេចក្ដីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្ដីទុក្ខជាវិបាកតទៅ ១ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាន មានសេចក្ដីសុខក្នុងបច្ចុប្បន្ន តែមានសេចក្ដីទុក្ខជាវិបាកតទៅ ១ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាន មានសេចក្ដីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្ដីសុខជាវិបាកតទៅ ១ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាន មានសេចក្ដីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្ដីសុខជាវិបាកតទៅ ១ ។

[១៦៤] ម្នាលភិក្ខុទាំងឡាយ បណ្ដាធម្មសមាទានអម្បាលនោះ ធម្ម-សមាទានណា មានសេចក្ដីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្ដីទុក្ខជាវិបាក

ចូឡយមកវគ្គ  មហាធម្មសមាទានសុត្តេ  អវិជ្ជាគតគតិ

តំ អវិទ្វា អវិជ្ជាគតោ យថាភូតំ នប្បជានាតិ ឥទំ ខោ ធម្មសមាទានំ បច្ចុប្បន្នទុក្ខញ្ចេវ អាយតិញ្ច ទុក្ខវិបាកន្តិ ។ តំ អវិទ្វា អវិជ្ជាគតោ យថាភូតំ នប្បជានន្តោ តំ សេវតិ តំ ន បរិវជ្ជេតិ ។ តស្ស តំ សេវតោ តំ អបរិវជ្ជយតោ អនិដ្ឋា អកន្តា អមនាបា ធម្មា អភិវឌ្ឍន្តិ ឥដ្ឋា កន្តា មនាបា ធម្មា បរិហាយន្តិ តំ កិស្ស ហេតុ ឯវំ ហេតំ ភិក្ខវេ ហោតិ យថាតំ អវិទ្ទសុនោតិ ។ តត្រ ភិក្ខវេ យមិទំ ធម្មសមាទានំ បច្ចុប្បន្នសុខំ អាយតឹ ទុក្ខវិបាកំ តំ អវិទ្វា អវិជ្ជាគតោ យថាភូតំ នប្បជានាតិ ឥទំ ខោ ធម្មសមាទានំ បច្ចុប្បន្នសុខំ អាយតឹ ទុក្ខវិបាកន្តិ ។ តំ អវិទ្វា អវិជ្ជាគតោ យថាភូតំ នប្បជានន្តោ តំ សេវតិ តំ ន បរិវជ្ជេតិ ។

តទៅ ភិក្ខុជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្តីពិតថា ធម្មសមាទាននេះឯង មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីទុក្ខជាវិបាកតទៅ ។ កាលបើភិក្ខុជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្តីពិត ក៏រមែងសេពនូវធម្មសមាទាននោះ មិនវៀរចាកនូវធម្មសមាទាននោះឡើយ ។ កាលបើភិក្ខុនោះ សេពនូវធម្មសមាទាននោះ មិនវៀរធម្មសមាទាននោះហើយ អារម្មណ៍ទាំងឡាយដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងចម្រើនឡើង អារម្មណ៍ទាំងឡាយដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងសាបសូន្យទៅ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះបុថុជ្ជនមិនដឹងតាមពិត រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម្មសមាទានទាំងនោះ ធម្មសមាទានណា ដែលមានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្តីពិតថា ធម្មសមាទាននេះឯង មានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ ។ កាលភិក្ខុជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្តីពិត ក៏រមែងសេពនូវធម្មសមាទាននោះ មិនវៀរចាកធម្មសមាទាននោះឡើយ ។

តស្ស តំ សេវតោ តំ អបរិវជ្ជយតោ អនិដ្ឋា អកន្តា អមនាបា ធម្មា អភិវឌ្ឍន្តិ ឥដ្ឋា កន្តា មនាបា ធម្មា បរិហាយន្តិ តំ កិស្ស ហេតុ ឯវំ ហេតំ ភិក្ខវេ ហោតិ យថាតំ អវិទ្ទសុនោតិ ។ តត្រ ភិក្ខវេ យមិទំ ធម្មសមាទានំ បច្ចុប្បន្នទុក្ខំ អាយតឹ សុខវិបាកំ តំ អវិទ្វា អវិជ្ជាគតោ យថាភូតំ នប្បជា-នាតិ ឥទំ ខោ ធម្មសមាទានំ បច្ចុប្បន្នទុក្ខំ អាយតឹ សុខវិបាកន្តិ ។ តំ អវិទ្វា អវិជ្ជាគតោ យថាភូតំ នប្ប-ជានន្តោ តំ សេវតិ តំ ន បរិវជ្ជេតិ ។ តស្ស តំ សេវតោ តំ អបរិវជ្ជយតោ អនិដ្ឋា អកន្តា អមនាបា ធម្មា អភិវឌ្ឍន្តិ ឥដ្ឋា កន្តា មនាបា ធម្មា បរិហាយន្តិ តំ

កាលបើភិក្ខុនោះ សេពនូវធម្មសមាទាននោះ មិនវៀរចាកធម្មសមាទាននោះហើយ អារម្មណ៍ទាំងឡាយដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងចម្រើនឡើង អារម្មណ៍ទាំងឡាយដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត រមែងសាបសូន្យទៅ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះបុថុជ្ជនមិនដឹងតាមពិត រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម្មសមាទានទាំងនោះ ធម្មសមាទានណា ដែលមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ភិក្ខុមិនដឹងនូវធម្មសមាទាននោះ ជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្តីពិតថា ធម្មសមាទាននេះឯង មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ។ កាលភិក្ខុជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្តីពិត ក៏រមែងសេពនូវធម្មសមាទាននោះ មិនវៀរចាកធម្មសមាទាននោះឡើយ ។ កាលបើភិក្ខុនោះសេពនូវធម្មសមាទាននោះ មិនវៀរចាកធម្មសមាទាននោះហើយ អារម្មណ៍ទាំងឡាយដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងចម្រើនឡើង អារម្មណ៍ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងសាបសូន្យទៅ ដំណើរនោះ

៣២១



កិស្ស ហេតុ ឯវំ ហេតំ ភិក្ខវេ ហោតិ យថាតំ អវិទ្ទសុនោតិ ។ តត្រ ភិក្ខវេ យមិទំ ធម្មសមាទានំ បច្ចុប្បន្នសុខញ្ចេវ អាយតិញ្ច សុខវិបាកំ តំ អវិទ្វា អវិជ្ជាគតោ យថាភូតំ នប្បជានាតិ ឥទំ ខោ ធម្មស-មាទានំ បច្ចុប្បន្នសុខញ្ចេវ អាយតិញ្ច សុខវិបាកន្តិ ។ តំ អវិទ្វា អវិជ្ជាគតោ យថាភូតំ នប្បជានន្តោ តំ សេវតិ តំ ន បរិវជ្ជេតិ ។ តស្ស តំ សេវតោ តំ អបរិវជ្ជយតោ អនិដ្ឋា អកន្តា អមនាបា ធម្មា អភិវឌ្ឍន្តិ ឥដ្ឋា កន្តា មនាបា ធម្មា បរិហាយន្តិ តំ កិស្ស ហេតុ ឯវំ ហេតំ ភិក្ខវេ ហោតិ យថាតំ អវិទ្ទសុនោតិ ។

ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះបុថុជ្ជនមិនដឹង តាមពិត រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម្មសមា-ទាននោះ ធម្មសមាទានណា ដែលមានសេចក្តីសុខ ក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយអវិជ្ជា មិនដឹង នូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្តីពិតថា ធម្មសមាទាននេះឯង មានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ។ កាល ភិក្ខុជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាម សេចក្តីពិត ក៏រមែងសេពនូវធម្មសមាទាននោះ មិនវៀរចាកធម្មសមាទាន នោះឡើយ ។ កាលបើភិក្ខុនោះសេពនូវធម្មសមាទាននោះ មិនវៀរចាក ធម្មសមាទាននោះ អារម្មណ៍ទាំងឡាយមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងចម្រើនឡើង អារម្មណ៍ទាំងឡាយជាទីប្រាថ្នា ជាទី ត្រេកអរ ជាទីគាប់ចិត្ត រមែងសាបសូន្យទៅ ដំណើរនោះ ព្រោះហេតុ អ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះបុថុជ្ជនមិនដឹងតាមពិត រមែងដូច្នោះឯង ។

[១៦៤] តត្រ ភិក្ខវេ យមិទំ ធម្មសមាទានំ បច្ចុប្បន្នទុក្ខញ្ចេវ អាយតិញ្ច ទុក្ខវិបាកំ តំ អវិទ្វា អវិជ្ជាគតោ យថាភូតំ នប្បជានាតិ ឥទំ ខោ ធម្មសមាទានំ បច្ចុប្បន្នទុក្ខញ្ចេវ អាយតិញ្ច ទុក្ខវិបាកន្តិ ។ តំ អវិទ្វា អវិជ្ជាគតោ យថាភូតំ អប្បជានន្តោ តំ ន សេវតិ តំ បរិវជ្ជេតិ ។ តស្ស តំ អសេវតោ បរិវជ្ជយតោ អនិដ្ឋា អកន្តា អមនាបា ធម្មា បរិហាយន្តិ ឥដ្ឋា កន្តា មនាបា ធម្មា អភិវឌ្ឍន្តិ តំ កិស្ស ហេតុ ឯវំ ហេតំ ភិក្ខវេ ហោតិ យថាតំ វិទ្វសុនោតិ ។ តត្រ ភិក្ខវេ យមិទំ ធម្មសមាទានំ បច្ចុប្បន្នសុខំ អាយតឹ ទុក្ខវិបាកំ តំ អវិទ្វា អវិជ្ជាគតោ យថាភូតំ នប្បជានាតិ ឥទំ ខោ ធម្មសមាទានំ បច្ចុប្បន្នសុខំ អាយតឹ ទុក្ខវិ-បាកន្តិ ។ តំ វិទ្វា វិជ្ជាគតោ យថាភូតំ បជានន្តោ

[១៦៥] ម្នាលភិក្ខុទាំងឡាយ បណ្ដាធម្មសមាទាននោះ ធម្មសមាទានណា ដែលមានសេចក្ដីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្ដីទុក្ខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយវិជ្ជា ដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្ដីពិតថា ធម្មសមាទាននេះឯង មានសេចក្ដីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្ដីទុក្ខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយវិជ្ជា ដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្ដីពិត រមែងមិនសេពនូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះ ។ កាលបើភិក្ខុនោះមិនសេពនូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះហើយ អារម្មណ៍ទាំងឡាយដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងសាបសូន្យទៅ អារម្មណ៍ទាំងឡាយ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងចម្រើនឡើង ចុះដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះភិក្ខុជាអ្នកដឹងតាមពិត រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម្មសមាទានទាំងនោះ ធម្មសមាទានណា ដែលមានសេចក្ដីសុខក្នុងបច្ចុប្បន្ន តែមានសេចក្ដីទុក្ខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយវិជ្ជា ដឹងធម្មសមាទាននោះ ស្គាល់តាមសេចក្ដីពិតថា ធម្មសមាទាននេះឯង មានសេចក្ដីសុខក្នុងបច្ចុប្បន្ន តែមានសេចក្ដីទុក្ខជាវិបាកតទៅ ។ កាលភិក្ខុជាអ្នកប្រកបដោយវិជ្ជា ដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្ដីពិត

តំ ន សេវតិ តំ បរិវជ្ជេតិ ។ តស្ស តំ អសេវតោ តំ បរិវជ្ជយតោ អនិដ្ឋា អកន្តា អមនាបា ធម្មា បរិហាយន្តិ ឥដ្ឋា កន្តា មនាបា ធម្មា អភិវឌ្ឍន្តិ តំ កិស្ស ហេតុ ឯវំ ហេតំ ភិក្ខវេ ហោតិ យថាតំ វិទ្ទសុនោតិ ។ តត្រ ភិក្ខវេ យមិទំ ធម្មសមាទានំ បច្ចុប្បន្នទុក្ខំ អាយតឹ សុខវិបាកំ តំ វិទ្វា វិជ្ជាគតោ យថាភូតំ បជានាតិ ឥទំ ខោ ធម្មសមាទានំ បច្ចុប្បន្នទុក្ខំ អាយតឹ សុខវិបាកន្តិ ។ តំ វិទ្វា វិជ្ជាគតោ យថាភូតំ បជានន្តោ តំ ន សេវតិ តំ បរិវជ្ជេតិ ។ តស្ស តំ អសេវតោ តំ បរិវជ្ជយតោ[១] អនិដ្ឋា អកន្តា អមនាបា ធម្មា បរិហាយន្តិ ឥដ្ឋា កន្តា មនាបា ធម្មា អភិវឌ្ឍន្តិ

១ ឱ. ម. តំ សេវតោ តំ អបរិវជ្ជយតោតិ ទិស្សតិ ។

រមែងមិនសេពនូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះហើយ ។ កាលបើភិក្ខុនោះមិនសេព នូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះ អារម្មណ៍ទាំងឡាយ មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងសាបសូន្យទៅ អារម្មណ៍ទាំងឡាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងចម្រើនឡើង ចុះដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះភិក្ខុជាអ្នកដឹងតាមពិត រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម្មសមាទានទាំងនោះ ធម្មសមាទានណា ដែលមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយវិជ្ជា ដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្តីពិតថា ធម្មសមាទាននេះឯង មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ។ ភិក្ខុជាអ្នកប្រកបដោយវិជ្ជា ដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្តីពិត រមែងមិនសេពនូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះ ។ កាលបើភិក្ខុនោះ មិនសេពនូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះហើយ អារម្មណ៍ទាំងឡាយដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងសាបសូន្យទៅ អារម្មណ៍ទាំងឡាយដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងចម្រើនឡើង

តំ កិស្ស ហេតុ ឯវំ ហេតំ ភិក្ខវេ ហោតិ យថាតំ វិទ្ទសុនោតិ ។ តត្រ ភិក្ខវេ យមិទំ ធម្មសមាទានំ បច្ចុប្បន្នសុខញ្ចេវ អាយតិញ្ច សុខវិបាកំ តំ វិទ្វា វិជ្ជាគតោ យថាភូតំ បជានាតិ ឥទំ ខោ ធម្មសមាទានំ បច្ចុប្បន្នសុខញ្ចេវ អាយតិញ្ច សុខវិបាកន្តិ ។ តំ វិទ្វា វិជ្ជាគតោ យថាភូតំ បជានន្តោ តំ ន សេវតិ តំ បរិវជ្ជេតិ ។ តស្ស តំ អសេវតោ តំ បរិវជ្ជយតោ អនិដ្ឋា អកន្តា អមនាបា ធម្មា បរិហាយន្តិ ឥដ្ឋា កន្តា មនាបា ធម្មា អភិវឌ្ឍន្តិ តំ កិស្ស ហេតុ ឯវំ ហេតំ ភិក្ខវេ ហោតិ យថាតំ វិទ្ទសុនោតិ ។

[១៦៦] កាតមញ្ច ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នទុក្ខញ្ចេវ អាយតិញ្ច ទុក្ខវិបាកំ ។ ឥធ ភិក្ខវេ

ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះភិក្ខុជាអ្នកដឹងតាមសេចក្ដីពិត រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម្មសមាទានទាំងនោះ ធម្មសមាទានណា ដែលមានសេចក្ដីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្ដីសុខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយវិជ្ជា ដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្ដីពិតថា ធម្មសមាទាននេះឯង មានសេចក្ដីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្ដីសុខជាវិបាកតទៅ ។ កាលភិក្ខុជាអ្នកប្រកបដោយវិជ្ជា ដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្ដីពិត រមែងមិនសេពនូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះ ។ កាលបើភិក្ខុនោះមិនសេពនូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះហើយ អារម្មណ៍ទាំងឡាយដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងសាបសូន្យទៅ អារម្មណ៍ទាំងឡាយជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត តែងចម្រើនឡើង ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះភិក្ខុជាអ្នកដឹងតាមពិត រមែងដូច្នោះឯង ។

[១៦៦] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានដែលមានសេចក្ដីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្ដីទុក្ខជាវិបាកតទៅ តើដូចម្ដេច ។ ម្នាលភិក្ខុ

ឯកច្ចោ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន បាណាតិបាតី ហោតិ បាណាតិបាតប្បច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន អទិន្នាទាយី ហោតិ អទិន្នា-ទានប្បច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន កាមេសុ មិច្ឆាចារី ហោតិ កាមេសុ មិច្ឆាចារប្បច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន មុសាវាទី ហោតិ មុសាវា-ទប្បច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន បិសុណាវា-ចោ[១] ហោតិ បិសុណាវាចប្បច្ចយា[២] ច ទុក្ខំ ទោម-នស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន សហាបិ ទោ-មនស្សេន ផរុសាវាចោ[៣] ហោតិ ផរុសាវាចប្បច្ចយា[៤] ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន សម្ផប្បលាបី ហោតិ

---

១ ឱ. ម. បិសុណាវាចោ ។ ២ ឱ. ម. បិសុណាវាចាបច្ចយា ។ ៣ ឱ. ម. ផរុសាវាចោ ។ ៤ ឱ. ម. ផរុសាវាចាបច្ចយា ។

ទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះបាណាតិបាតជាបច្ច័យ ។ ជាអ្នកកាន់យកវត្ថុដែលគេមិនបានឲ្យ (ដោយកាយឬវាចា) ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះអទិន្នាទានជាបច្ច័យ ។ ជាអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះកាមេសុមិច្ឆាចារជាបច្ច័យ ។ ជាអ្នកពោលនូវពាក្យកុហក ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះមុសាវាទជាបច្ច័យ ។ ជាអ្នកពោលពាក្យញុះញង់ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះបិសុណវាចាជាបច្ច័យ ។ ជាអ្នកមានវាចាអាក្រក់ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខនិងទោមនស្ស ព្រោះផរុសវាចាជាបច្ច័យ ។ ជាអ្នកពោលពាក្យរោយរាយឥតប្រយោជន៍ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស

សម្ផប្បលាបប្បច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន អភិជ្ឈាលុ ហោតិ អភិជ្ឈាបច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន ព្យាបន្នចិត្តោ ហោតិ ព្យាបាទប្បច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន មិច្ឆាទិដ្ឋិ ហោតិ មិច្ឆាទិដ្ឋិប្បច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នទុក្ខញ្ចេវ អាយតិញ្ច ទុក្ខវិបាកំ ។

[១៦៧] កតមញ្ច ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នសុខំ អាយតឹ ទុក្ខវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ សហាបិ សុខេន សហាបិ សោមនស្សេន បាណាតិបាតី ហោតិ បាណាតិបាតប្បច្ចយា ច សុខំ សោមនស្សំ បដិសំវេទេតិ ។ សហាបិ សុខេន សហាបិ សោមនស្សេន អទិន្នាទាយី ហោតិ

ក៏រមែងរងនូវសេចក្ដីទុក្ខនិងទោមនស្ស ព្រោះសម្ផប្បលាប:ជាបច្ច័យ ។ ជាអ្នកមានអភិជ្ឈាច្រើន ទាំងសេចក្ដីទុក្ខ ទាំងទោមនស្ស ក៏រមែងរង នូវសេចក្ដីទុក្ខ និងទោមនស្ស ព្រោះអភិជ្ឈាជាបច្ច័យ ។ ជាអ្នកមាន ចិត្តព្យាបាទ ទាំងសេចក្ដីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្ដី ទុក្ខ និងទោមនស្ស ព្រោះព្យាបាទជាបច្ច័យ ។ ជាអ្នកយល់ខុស ទាំង សេចក្ដីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្ដីទុក្ខ និងទោ-មនស្ស ព្រោះមិច្ឆាទិដ្ឋិជាបច្ច័យ ។ បុគ្គលនោះ លុះទម្លាយរាង កាយបន្ទាប់អំពីមរណៈទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតហៅថា មានសេចក្ដីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្ដីទុក្ខជាវិបាកតទៅ ។

[១៦៧] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានមានសេចក្ដីសុខក្នុង បច្ចុប្បន្ន តែមានសេចក្ដីទុក្ខជាវិបាកតទៅ តើដូចម្ដេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ទាំងសេច-ក្ដីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្ដីសុខនិងទោមនស្ស ព្រោះបាណាតិបាតជាបច្ច័យ ។ ជាអ្នកកាន់យកទ្រព្យដែលគេមិន បានឲ្យ (ដោយកាយឬវាចា) ទាំងសេចក្ដីសុខ ទាំងសោមនស្ស

អភិជ្ឈាបានប្បច្ចយា ច សុខំ សោមនស្សំ បដិសំវេ-
ទេតិ ។ សហាបិ សុខេន សហាបិ សោមនស្សេន កា-
មេសុ មិច្ឆាចារី ហោតិ កាមេសុ មិច្ឆាចារប្បច្ចយា ច
សុខំ សោមនស្សំ បដិសំវេទេតិ ។ សហាបិ សុខេន ស-
ហាបិ សោមនស្សេន មុសាវាទី ហោតិ មុសាវាទប្បច្ច-
យា ច សុខំ សោមនស្សំ បដិសំវេទេតិ ។ សហាបិ
សុខេន សហាបិ សោមនស្សេន បិសុណាវាចោ ហោតិ
បិសុណាវាចប្បច្ចយា ច សុខំ សោមនស្សំ បដិសំវេ-
ទេតិ ។ សហាបិ សុខេន សហាបិ សោមនស្សេន
ផរុសវាចោ ហោតិ ផរុសវាចប្បច្ចយា ច សុខំ សោម-
នស្សំ បដិសំវេទេតិ ។ សហាបិ សុខេន សហាបិ
សោមនស្សេន សម្ផប្បលាបី ហោតិ សម្ផប្ប-
លាបប្បច្ចយា ច សុខំ សោមនស្សំ បដិសំវេ-
ទេតិ ។ សហាបិ សុខេន សហាបិ សោមនស្សេន
អភិជ្ឈាលុ ហោតិ អភិជ្ឈាបច្ចយា ច សុខំ
សោមនស្សំ បដិសំវេទេតិ ។ សហាបិ សុខេ-
ន សហាបិ សោមនស្សេន ព្យាបន្នចិត្តោ ហោតិ

ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះអទិន្នាទានជាបច្ច័យ ។ ជាអ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ទាំងសេចក្តីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះកាមេសុមិច្ឆាចារជាបច្ច័យ ។ ជាអ្នកពោលពាក្យកុហក ទាំងសេចក្តីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះមុសាវាទជាបច្ច័យ ។ ជាអ្នកមានវាចាញុះញង់ ទាំងសេចក្តីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះបិសុណាវាចាជាបច្ច័យ ។ ជាអ្នកមានវាចាអាក្រក់ ទាំងសេចក្តីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះផរុសវាចាជាបច្ច័យ ។ ជាអ្នកពោលពាក្យឥតប្រយោជន៍ ទាំងសេចក្តីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះសម្ផប្បលាបៈជាបច្ច័យ ។ ជាអ្នកមានអភិជ្ឈាច្រើន ទាំងសេចក្តីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះអភិជ្ឈាជាបច្ច័យ ។ ជាអ្នកមានចិត្តព្យាបាទ ទាំងសេចក្តីសុខ

ព្យាបាទបច្ចយា ច សុខំ សោមនស្សំ បដិសំ-
វេទេតិ ។ សហាបិ សុខេន សហាបិ សោម-
នស្សេន មិច្ឆាទិដ្ឋិ ហោតិ មិច្ឆាទិដ្ឋិប្បច្ចយា
ច សុខំ សោមនស្សំ បដិសំវេទេតិ ។ សោ
កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ
វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឥទំ វុច្ចតិ ភិក្ខវេ
ធម្មសមាទានំ បច្ចុប្បន្នសុខំ អាយតឹ ទុក្ខវិបាកំ ។

[១៦៨] កាតមញ្ច ភិក្ខវេ ធម្មសមាទានំ បច្ចុ-
ប្បន្នទុក្ខំ អាយតឹ សុខវិបាកំ ។ ឥធ ភិក្ខវេ ឯ-
កច្ចោ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន
បាណាតិបាតា បដិវិរតោ ហោតិ បាណាតិបាតា
វេរមណីបច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។
សហាបិ ទុក្ខេន សហាបិ ទោមនស្សេន អទិន្នាទានា
បដិវិរតោ ហោតិ អទិន្នាទានា វេរមណីបច្ចយា ច ទុក្ខំ
ទោមនស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន សហាបិ
ទោមនស្សេន កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ

ទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខនិងសោមនស្ស ព្រោះព្យាបាទជាបច្ច័យ ។ ជាអ្នកយល់ខុស ទាំងសេចក្តីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខនិងសោមនស្ស ព្រោះមិច្ឆាទិដ្ឋិជាបច្ច័យ ។ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់ពីមរណៈទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតហៅថា មានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ ។

[១៦៨] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានដែលមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខនិងទោមនស្ស ព្រោះវៀរចាកបាណាតិបាតជាបច្ច័យ ។ ជាអ្នកវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខនិងទោមនស្ស ព្រោះវៀរចាកអទិន្នាទានជាបច្ច័យ ។ ជាអ្នកវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស

កាមេសុ មិច្ឆាចារា វេរមណីបច្ចយា ច ទុក្ខំ ទោម-
នស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន សហាបិ
ទោមនស្សេន មុសាវាទា បដិវិរតោ ហោតិ មុសា-
វាទា វេរមណីបច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំ-
វេទេតិ ។ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន
បិសុណាយ វាចាយ បដិវិរតោ ហោតិ បិសុណាយ
វាចាយ វេរមណីបច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំ-
វេទេតិ ។ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន
ផរុសាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ
វេរមណីបច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។
សហាបិ ទុក្ខេន សហាបិ ទោមនស្សេន សម្ផប្បលាបា
បដិវិរតោ ហោតិ សម្ផប្បលាបា វេរមណីបច្ចយា ច ទុក្ខំ
ទោមនស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន សហាបិ
ទោមនស្សេន អនភិជ្ឈាលុ ហោតិ អនភិជ្ឈាបច្ចយា
ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន
សហាបិ ទោមនស្សេន អព្យាបន្នចិត្តោ ហោតិ

ក៏រមែងរងសេចក្តីទុក្ខ និងទោមនស្ស ព្រោះវៀរចាកកាមេសុមិច្ឆាចារជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យកុហក ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខនិងទោមនស្ស ព្រោះវៀរចាកមុសាវាទជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យញុះញង់ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះវៀរចាកបិសុណាវាចាជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យអាក្រក់ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខ និងទោមនស្ស ព្រោះវៀរចាកផរុសវាចាជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យឥតប្រយោជន៍ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខ និងទោមនស្ស ព្រោះវៀរចាកសម្ផប្បលាបៈជាបច្ច័យ ។ ជាអ្នកមិនមានអភិជ្ឈាច្រើន ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខ និងទោមនស្ស ព្រោះការមិនមានអភិជ្ឈាជាបច្ច័យ ។ ជាអ្នកមិនមានព្យាបាទ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស

អព្យាបាទប្បច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សហាបិ ទុក្ខេន សហាបិ ទោមនស្សេន សម្មាទិដ្ឋិ ហោតិ សម្មាទិដ្ឋិប្បច្ចយា ច ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ សោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នទុក្ខំ អាយតឹ សុខវិ-បាកំ ។

[១៦៩] កតមញ្ច ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្ន-សុខញ្ចេវ អាយតិញ្ច សុខវិបាកំ ។ ឥធ ភិក្ខវេ ឯកច្ចោ សហាបិ សុខេន សហាបិ សោមនស្សេន បាណាតិបាតា បដិវិរតោ ហោតិ បាណាតិបាតា វេរម-ណីបច្ចយា ច សុខំ សោមនស្សំ បដិសំវេទេតិ ។ សហាបិ សុខេន សហាបិ សោមនស្សេន អទិន្នាទានា បដិវិរតោ ហោតិ អទិន្នាទានា វេរមណីបច្ចយា ច សុខំ សោមនស្សំ បដិសំវេទេតិ ។ សហាបិ សុខេន សហាបិ សោមនស្សេន កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ

ក៏រមែងរងសេចក្តីទុក្ខ និងទោមនស្ស ព្រោះមិនមានព្យាបាទជាបច្ច័យ ។ ជាអ្នកយល់ត្រូវ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខនិងទោមនស្ស ព្រោះសម្មាទិដ្ឋិជាបច្ច័យ ។ បុគ្គលនោះលុះទម្លាយរាងកាយបន្ទាប់អំពីមរណៈទៅ ក៏រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតហៅថាមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ។

[១៦៩] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានមានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស រមែងបានសេចក្តីសុខនិងសោមនស្ស ព្រោះវៀរចាកបាណាតិបាតជាបច្ច័យ ។ ជាអ្នកវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបានសេចក្តីសុខនិងសោមនស្ស ព្រោះវៀរចាកអទិន្នាទានជាបច្ច័យ ។ ជាអ្នកវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំង-ឡាយ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែង

កាមេសុ មិច្ឆាចារា វេរមណីបច្ចយា ច សុខំ សោ-
មនស្សំ បដិសំវេទេតិ ។ សហាបិ សុខេន សហាបិ
សោមនស្សេន មុសាវាទា បដិវិរតោ ហោតិ មុសា-
វាទា វេរមណីបច្ចយា ច សុខំ សោមនស្សំ បដិសំវេ-
ទេតិ ។ សហាបិ សុខេន សហាបិ សោមនស្សេន
បិសុណាយ វាចាយ បដិវិរតោ ហោតិ បិសុណាយ
វាចាយ វេរមណីបច្ចយា ច សុខំ សោមនស្សំ បដិសំ-
វេទេតិ ។ សហាបិ សុខេន សហាបិ សោមនស្សេន
ផរុសាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ
វេរមណីបច្ចយា ច សុខំ សោមនស្សំ បដិសំវេទេតិ ។
សហាបិ សុខេន សហាបិ សោមនស្សេន សម្ផប្ប-
លាបា បដិវិរតោ ហោតិ សម្ផប្បលាបា វេរមណីបច្ចយា
ច សុខំ សោមនស្សំ បដិសំវេទេតិ ។ សហាបិ សុខេន
សហាបិ សោមនស្សេន អនភិជ្ឈាលុ ហោតិ អនភិជ្ឈា-
បច្ចយា ច សុខំ សោមនស្សំ បដិសំវេទេតិ ។ សហាបិ
សុខេន សហាបិ សោមនស្សេន អព្យាបន្នចិត្តោ ហោតិ

បានសេចក្តីសុខនិងសោមនស្ស ព្រោះវៀរចាកកាមេសុមិច្ឆាចារ ជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យកុហក ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបានសេចក្តីសុខនិងសោមនស្ស ព្រោះវៀរចាកមុសាវាទជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យញុះញង់ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបានសេចក្តីសុខនិងសោមនស្ស ព្រោះវៀរចាកបិសុណាវាចាជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យអាក្រក់ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបាននូវសេចក្តីសុខនិងសោមនស្ស ព្រោះវៀរចាកផរុសវាចាជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យឥតប្រយោជន៍ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបានសេចក្តីសុខនិងសោមនស្ស ព្រោះវៀរចាកសម្ផប្បលាបៈជាបច្ច័យ ។ ជាអ្នកមិនមានអភិជ្ឈាច្រើន ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបានសេចក្តីសុខនិងសោមនស្ស ព្រោះមិនមានអភិជ្ឈាជាបច្ច័យ ។ ជាអ្នកមិនមានចិត្តព្យាបាទ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែង

អព្យាបាទប្បច្ចយា ច សុខំ សោមនស្សំ បដិសំវេទេតិ ។ សហាបិ សុខេន សហាបិ សោមនស្សេន សម្មាទិដ្ឋិ ហោតិ សម្មាទិដ្ឋិប្បច្ចយា ច សុខំ សោមនស្សំ បដិសំវេទេតិ ។ សោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ធម្មសមាទានំ បច្ចុប្បន្នសុខញ្ចេវ អាយតិញ្ច សុខវិបាកំ ។ ឥមានិ ខោ ភិក្ខវេ ចត្តារិ ធម្មសមាទានានិ ។

[១៧០] សេយ្យថាបិ ភិក្ខវេ តិត្តិកាលាពុ[១] វិសេន សំសដ្ឋោ ។ អថ បុរិសោ អាគច្ឆេយ្យ ជីវិតុកាមោ អមរិតុកាមោ សុខកាមោ ទុក្ខប្បដិកូលោ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស អយំ តិត្តិកាលាពុ វិសេន សំសដ្ឋោ សចេ អាកង្ខសិ បិវ តស្ស តំ បិវតោ[២] ចេវ ន ឆាទេស្សតិ វណ្ណេនបិ គន្ធេនបិ រសេនបិ បិវិត្វា[៣] ច បន មរណំ វា និគច្ឆសិ មរណមត្តំ វា ទុក្ខន្តិ ។ សោ តំ អប្បដិសង្ខាយ

១ ឱ. ម. តិត្តកាលាពុ ។ ២ ឱ. តេ បិវតោ ។ ៣ ឱ. បិត្វា ។

បានសេចក្តីសុខនិងសោមនស្ស ព្រោះមិនមានចិត្តព្យាបាទជាបច្ច័យ ។ ជាអ្នកយល់ត្រូវ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែង បានសេចក្តីសុខនិងសោមនស្ស ព្រោះសម្មាទិដ្ឋិជាបច្ច័យ ។ បុគ្គល នោះលុះទម្លាយរាងកាយបន្ទាប់អំពីមរណៈទៅ ក៏រមែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតហៅថា មានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ។ ម្នាល ភិក្ខុទាំងឡាយ នេះឯងជាធម្មសមាទានមាន ៤ ប្រការ ។

[១៧០] ម្នាលភិក្ខុទាំងឡាយ ដូចជានរនោងព្រៃ[១] លាយដោយ ថ្នាំពិស ។ គ្រានោះ បុរសមានប្រាថ្នាដើម្បីរស់នៅ មិនប្រាថ្នាដើម្បី ស្លាប់ ប្រាថ្នាសេចក្តីសុខ ខ្ពើមសេចក្តីទុក្ខ បានមកដល់ ។ ពួកជន និយាយនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ននោងព្រៃនេះ លាយដោយថ្នាំពិស បើអ្នកត្រូវការចូរផឹកចុះ កាលបើបុរសផឹកនូវននោង ព្រៃនោះ ក៏ននោងព្រៃនោះមិនគាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹកហើយ ក៏ដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខ ស្មើរតែនឹងស្លាប់ ។ បើបុរសនោះមិនបានពិចារណានូវននោងព្រៃនោះ

១ ប្រែថា ត្រសក់ក្អែក ឬពុលអែក ក៏បាន ។

បិវេយ្យ នប្បដិនិស្សជ្ជេយ្យ តស្ស តំ បិវតោ ចេវ ន ឆាទេយ្យ វណ្ណេនបិ គន្ធេនបិ រសេនបិ បិវិត្វា ច បន មរណំ វា និគ្គច្ឆេយ្យ មរណមត្តំ វា ទុក្ខំ តថូបមាហំ ភិក្ខវេ ឥមំ ធម្មសមាទានំ វទាមិ យយិទំ ធម្មសមាទានំ បច្ចុប្បន្នទុក្ខញ្ចេវ អាយតិញ្ច ទុក្ខវិបាកំ ។

[១៧១] សេយ្យថាបិ ភិក្ខវេ អាពានីយកំសោ វណ្ណសម្បន្នោ គន្ធសម្បន្នោ រសសម្បន្នោ សោ ច ខោ វិសេន សំសដ្ឋោ ។ អថ បុរិសោ អាគច្ឆេយ្យ ជីវិតុកាមោ អមរិតុកាមោ សុខកាមោ ទុក្ខប្បដិក្កូលោ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស[១] អាពានីយកំសោ វណ្ណសម្បន្នោ គន្ធសម្បន្នោ រសសម្បន្នោ សោ ច ខោ វិសេន សំសដ្ឋោ សចេ អាកង្ខសិ បិវ តស្ស តំ បិវតោ ហិ ខោ ឆាទេស្សតិ វណ្ណេនបិ គន្ធេនបិ រសេនបិ បិវិត្វា ច បន មរណំ វា និគ្គច្ឆសិ មរណមត្តំ វា ទុក្ខន្តិ ។ សោ

១ ឱ. ម. ឯត្ថន្តរេ អយន្តិ ទិស្សតិ ។

មុខជាផឹក មិនលះបង់ទេ កាលបុរសនោះផឹក នូវនទោង់ព្រៃហើយ មិនគាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹកហើយ ក៏ដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតហៅធម្មសមាទាននេះថា មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីទុក្ខជាវិបាកតទៅ ក៏មានឧបមេយ្យដូច្នោះឯង ។

[១៧១] ម្នាលភិក្ខុទាំងឡាយ ដូចជាភាជន៍សំរឹទ្ធិពេញដោយទឹកផ្អែម បរិបូណ៌ដោយពណ៌ បរិបូណ៌ដោយក្លិន បរិបូណ៌ដោយរស តែភាជន៍សំរឹទ្ធិពេញដោយទឹកផ្អែមនោះឯង លាយដោយថ្នាំពិស ។ គ្រានោះ បុរសមានប្រាថ្នាដើម្បីរស់នៅ មិនប្រាថ្នាដើម្បីស្លាប់ ប្រាថ្នាសេចក្តីសុខ ខ្ពើមសេចក្តីទុក្ខ បានមកដល់ ។ ពួកជននិយាយនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ភាជន៍សំរឹទ្ធិពេញដោយទឹកផ្អែម បរិបូណ៌ដោយពណ៌ បរិបូណ៌ដោយក្លិន បរិបូណ៌ដោយរស តែភាជន៍សំរឹទ្ធិពេញដោយទឹកផ្អែមនោះឯង លាយទៅដោយថ្នាំពិស បើអ្នកត្រូវការ ចូរផឹកចុះ កាលបើបុរសនោះផឹកទឹកនោះហើយ ក៏គាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹកហើយ ក៏ដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ ។ បើបុរសនោះ

តំ អប្បដិសង្ខាយ បិវេយ្យ ឧប្បដិនិស្សជ្ជេយ្យ តស្ស តំ បិវតោ ហិ ខោ ឆាទេយ្យ វណ្ណេនបិ គន្ធេនបិ រសេនបិ បិវិត្វា ច បន មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ តថូបមាហំ ភិក្ខវេ ឥមំ ធម្មសមាទានំ វទាមិ យមិទំ ធម្មសមាទានំ បច្ចុប្បន្នសុខំ អាយតឹ ទុក្ខវិបាកំ ។

[១៧២] សេយ្យថាបិ ភិក្ខវេ បូតិមុត្តំ នានាភេសជ្ជេហិ សំសដ្ឋំ ។ អថ បុរិសោ អាគច្ឆេយ្យ បណ្ឌុរោគី ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស ឥទំ បូតិមុត្តំ នានាភេសជ្ជេហិ សំសដ្ឋំ សចេ អាកង្ខសិ បិវ តស្ស តំ បិវតោ ហិ ខោ នច្ឆាទេស្សតិ វណ្ណេនបិ គន្ធេនបិ រសេនបិ បិវិត្វា ច បន សុខី ភវិស្សតីតិ ។ សោ តំ បដិសង្ខាយ បិវេយ្យ នប្បដិនិស្សជ្ជេយ្យ តស្ស តំ បិវតោ ចេវ[១] នច្ឆាទេយ្យ វណ្ណេនបិ គន្ធេនបិ រសេនបិ

១ ឱ. ម. ហិ ខោ ។

មិនបានពិចារណានូវភាជន៍សំរឹទ្ធិដែលពេញដោយទឹកផ្អែមនោះហើយ មុខជាផឹក មិនលះបង់ទេ កាលបុរសនោះផឹកនូវទឹកនោះ ក៏គាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹកហើយ ក៏ដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតហៅធម្មសមាទាននេះថា មានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ ក៏មានឧបមេយ្យដូច្នោះឯង ។

[១៧២] ម្នាលភិក្ខុទាំងឡាយ ដូចជាទឹកមូត្រស្អុយលាយដោយភេសជ្ជៈទាំងឡាយផ្សេង ៗ ។ គ្រានោះ បុរសមានរោគលឿង បានមកដល់ ។ ពួកជននិយាយនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ទឹកមូត្រស្អុយនេះ លាយដោយភេសជ្ជៈទាំងឡាយផ្សេង ៗ បើអ្នកត្រូវការ ចូរផឹកចុះ កាលបើបុរសនោះផឹកទឹកមូត្រស្អុយនោះ ក៏មិនគាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹកហើយ ក៏ជាអ្នកបានសេចក្តីសុខ ។ បើបុរសនោះបានពិចារណាទឹកមូត្រស្អុយនោះហើយ ក៏មុខជាផឹក មិនលះបង់ទេ កាលបើបុរសនោះផឹកទឹកមូត្រស្អុយនោះ ក៏មិនគាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង

បិវិត្វា ច បន សុខី អស្ស តថូបមាហំ ភិក្ខវេ ឥមំ ធម្មសមាទានំ វទាមិ យទិទំ ធម្មសមាទានំ បច្ចុប្បន្នទុក្ខំ អាយតឹ សុខវិបាកំ ។

[១៧៣] សេយ្យថាបិ ភិក្ខវេ ទធិ ច មធុ ច សប្បិ ច ផាណិតញ្ច[១] ឯកជ្ឈំ សំសដ្ឋំ ។ អថ បុរិសោ អាគច្ឆេយ្យ លោហិតបក្ខន្ទិកោ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស ឥទំ ទធិ ច មធុ ច សប្បិ ច ផាណិតញ្ច ឯកជ្ឈំ សំសដ្ឋំ សចេ អាកង្ខសិ បិវ តស្ស តេ បិវតោ ចេវ ឆាទេស្សតិ វណ្ណេនបិ គន្ធេនបិ រសេនបិ បិវិត្វា ច បន សុខី ភវិស្សតីតិ ។ សោ តំ បដិសង្ខាយ បិវេយ្យ នប្បដិនិស្សជ្ជេយ្យ តស្ស តំ បិវតោ ចេវ ឆាទេយ្យ វណ្ណេនបិ គន្ធេនបិ រសេនបិ បិវិត្វា ច បន សុខី អស្ស តថូបមាហំ ភិក្ខវេ ឥមំ ធម្មសមាទានំ វទាមិ យទិទំ ធម្មសមាទានំ បច្ចុប្បន្នសុខញ្ចេវ អាយតិញ្ច សុខវិបាកំ ។

---
១ ឱ. ម. ទធិញ្ច មធុញ្ច សប្បិញ្ច ផាណិតញ្ច ។

លុះផឹកហើយ ក៏ជាអ្នកបានសេចក្តីសុខ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតហៅធម្មសមាទាននេះថា មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ក៏មានឧបមេយ្យដូច្នោះឯង ។

[១៧៣] ម្នាលភិក្ខុទាំងឡាយ ដូចជាទឹកដោះក្តី ទឹកឃ្មុំក្តី ទឹកដោះថ្លាក្តី ទឹកអំពៅក្តី លាយច្រឡំជាមួយគ្នា ។ គ្រានោះ បុរសមានរោគចុះឈាម បានមកដល់ ។ ពួកជននិយាយនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ទឹកដោះជូរក្តី ទឹកឃ្មុំក្តី ទឹកដោះថ្លាក្តី ទឹកអំពៅក្តី ទាំងនេះ លាយច្រឡំជាមួយគ្នា បើអ្នកត្រូវការចូរផឹកចុះ កាលបើបុរសនោះផឹកទឹកអម្បាលនោះ ក៏គាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹកហើយ ជាអ្នកបានសេចក្តីសុខ ។ បើបុរសនោះបានពិចារណាទឹកនោះហើយ ក៏មុខជាផឹក មិនលះបង់ទេ កាលបុរសនោះផឹកទឹកនោះហើយ ក៏គាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹកហើយជាអ្នកបានសេចក្តីសុខ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតហៅធម្មសមាទាននេះថា មានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ។

[១៧៤] សេយ្យថាបិ ភិក្ខវេ វស្សានំ បច្ឆិមេ មាសេ សរទសមយេ វិទ្ធេ វិគតវលាហកេ ទេវេ អាទិច្ចោ នភំ អព្ភុស្សក្កមានោ សព្វំ អាកាសគតំ តមគតំ អភិវិហច្ច ភាសតិ ច តបតិ ច វិរោចតិ ច ឯវមេវ ខោ ភិក្ខវេ យមិទំ ធម្មសមាទានំ បច្ចុប្បន្នសុខញ្ចេវ អាយតិញ្ច សុខវិបាកំ តទញ្ញេ បុថុសមណព្រាហ្ម-ណបរប្បវាទេ អភិវិហច្ច ភាសតិ ច តបតិ ច វិរោចតិ ចាតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

មហាធម្មសមាទានសុត្តំ ឆដ្ឋំ និដ្ឋិតំ ។

[១៧៤] ម្នាលភិក្ខុទាំងឡាយ ដូចជាព្រះអាទិត្យ កាលអាកាសរាំងភ្លៀង ឃ្លាតទៅចាកពពកហើយ ក្នុងសរទសម័យ នាខែជាទីបំផុតនៃវស្សានរដូវទាំងឡាយ ក៏រះឡើងកាន់ផ្ទៃមេឃ កម្ចាត់បង់នូវងងឹតដែលមានឰដ៏អាកាសទាំងអស់ ភ្លឺផង ក្តៅផង រុងរឿងផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះមានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ធម្មសមាទាននោះអាចគ្របសង្កត់នូវពាក្យបរប្បវាទរបស់ពួកសមណព្រាហ្មណ៍ដទៃផង ភ្លឺផង ក្តៅផង រុងរឿងផង ក៏មានឧបមេយ្យដូច្នោះឯង ។ លុះព្រះមានព្រះភាគបានត្រាស់ភាសិតនេះចប់ហើយ ភិក្ខុទាំងនោះក៏ពេញចិត្ត រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ មហាធម្មសមាទានសូត្រ ទី ៦ ។

# សត្តមំ វីមំសកសុត្តំ

[១៧៥] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារា-មេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[១៧៦] ភគវា ឯតទវោច វីមំសកេន ភិក្ខវេ ភិក្ខុនា បរស្ស ចេតោបរិយាយំ អជានន្តេន តថាគតេ សមន្នេសនា កាតព្វា សម្មាសម្ពុទ្ធោ វា នោ វា ឥតិ វិញ្ញាណាយាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគ-វំនេត្តិកា ភគវំបដិសរណា សាធុ វត ភន្តេ ភគវន្តំ-យេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ

# វីមំសកសូត្រ ទី ៧

[១៧៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនេះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។

[១៧៦] ព្រះមានព្រះភាគបានត្រាស់ភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកពិចារណា[១] កាលមិនដឹងវារៈចិត្តរបស់បុគ្គលដទៃទេ ត្រូវធ្វើការស្វែងរកក្នុងព្រះតថាគតដើម្បីឲ្យដឹងថា ព្រះសម្មាសម្ពុទ្ធ ឬមិនមែន ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ មានព្រះមានព្រះភាគជាមូល មានព្រះមានព្រះភាគជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹងចំពោះ របស់យើងទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ព្រះមេត្តាប្រោសសំដែងនូវអត្ថនៃភាសិតនេះ ភិក្ខុទាំងឡាយ បានស្តាប់ភាសិតព្រះមានព្រះភាគហើយនឹងបានចាំទុក ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

---

១ ភិក្ខុអ្នកពិចារណា មាន ៣ គឺ អត្ថវីមំសកៈ អ្នកពិចារណារកអត្ថ ១ សង្ខារវីមំសកៈ អ្នកពិចារណាសង្ខារ ១ សត្ថុវីមំសកៈ អ្នកពិចារណារកគ្រូ ១ ។ អដ្ឋកថា ។

សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[១៧៧] ភគវា ឯតទវោច វីមំសកេន ភិក្ខវេ ភិក្ខុនា បរស្ស ចេតោបរិយាយំ អជានន្តេន ទ្វីសុ ធម្មេសុ តថាគតោ សមន្នេសិតព្វោ ចក្ខុសោតវិញ្ញេយ្យេសុ ធម្មេសុ យេ សង្កិលិដ្ឋា ចក្ខុសោតវិញ្ញេយ្យា ធម្មា សំវិជ្ជន្តិ វា តេ តថាគតស្ស នោ វាតិ ។ តមេនំ សមន្នេសមានោ ឯវំ ជានាតិ យេ សង្កិលិដ្ឋា ចក្ខុសោតវិញ្ញេយ្យា ធម្មា ន តេ តថាគតស្ស សំវិជ្ជន្តីតិ ។ យតោ នំ សមន្នេសមានោ ឯវំ ជានាតិ យេ សង្កិលិដ្ឋា ចក្ខុសោតវិញ្ញេយ្យា ធម្មា ន តេ តថាគតស្ស សំវិជ្ជន្តីតិ តតោ នំ ឧត្តរឹ សមន្នេសតិ យេ វីតិមិស្សា ចក្ខុសោតវិញ្ញេយ្យា ធម្មា សំវិជ្ជន្តិ

បើដូច្នោះ អ្នកទាំងឡាយចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែងឥឡូវនេះ ។ ភិក្ខុទាំងឡាយនោះ បានទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[១៧៧] ព្រះមានព្រះភាគបានត្រាស់នូវភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកពិចារណា កាលមិនដឹងនូវវារៈចិត្តរបស់បុគ្គលដទៃទេ ត្រូវស្វែងរកព្រះតថាគតក្នុងធម៌ពីរប្រការ គឺធម៌ដែលគប្បីដឹងបានដោយចក្ខុ ១ ដឹងបានដោយសោតៈ[១] ១ ថា ធម៌ទាំងឡាយដ៏សៅហ្មងដែលគប្បីដឹងបាន ដោយចក្ខុនិងសោតៈ នៃព្រះតថាគត មាន ឬមិនមានទេ ។ កាលភិក្ខុស្វែងរកនូវហេតុនោះហើយ ក៏គង់ដឹងយ៉ាងនេះថា ធម៌ទាំងឡាយដ៏សៅហ្មងដែលគប្បីដឹងដោយចក្ខុនិងសោតៈ នៃព្រះតថាគត មិនមានទេ ។ កាលណាភិក្ខុស្វែងរកហេតុនោះហើយ ដឹងយ៉ាងនេះថា ធម៌ទាំងឡាយដ៏សៅហ្មង ដែលគប្បីដឹងបានដោយចក្ខុនិងសោតៈ នៃព្រះតថាគតមិនមានទេ តពីនោះទៅទើបស្វែងរកហេតុនោះទៀតថា ធម៌ទាំងឡាយ ដ៏ច្រឡូកច្រឡំ[២] ដែលគប្បីដឹងដោយចក្ខុនិងសោតៈ

---

១ ធមិដែលត្រូវដឹងបានដោយចក្ខុ សំដៅយកកាយសមាចារៈ ធមិដែលត្រូវដឹងបានដោយសោតៈ សំដៅយកវចីសមាចារៈ ។ ២ សំដៅយកការប្រព្រឹត្តដោយកាយសមាចារៈ និងវចីសមាចារៈ ជួនកាលប្រព្រឹត្តល្អ ជួនកាលប្រព្រឹត្តអាក្រក់ ។

វា តេ តថាគតស្ស នោ វាតិ ។ តមេនំ សមន្នេសមានោ ឯវំ ជានាតិ យេ វីតិមិស្សា ចក្ខុសោតវិញ្ញេយ្យា ធម្មា ន តេ តថាគតស្ស សំវិជ្ជន្តីតិ ។ យតោ នំ សមន្នេសមានោ ឯវំ ជានាតិ យេ វីតិមិស្សា ចក្ខុសោតវិញ្ញេយ្យា ធម្មា ន តេ តថាគតស្ស សំវិជ្ជន្តីតិ តតោ នំ ឧត្តរឹ សមន្នេសតិ យេ វោទាតា ចក្ខុសោតវិញ្ញេយ្យា ធម្មា សំវិជ្ជន្តិ វា តេ តថាគតស្ស នោ វាតិ ។ តមេនំ សមន្នេសមានោ ឯវំ ជានាតិ យេ វោទាតា ចក្ខុសោតវិញ្ញេយ្យា ធម្មា សំវិជ្ជន្តិ តេ តថាគតស្សាតិ ។ យតោ នំ សមន្នេសមានោ ឯវំ ជានាតិ យេ វោទាតា ចក្ខុសោតវិញ្ញេយ្យា ធម្មា សំវិជ្ជន្តិ តេ តថាគតស្សាតិ តតោ នំ ឧត្តរឹ សមន្នេសតិ ទីឃរត្តំ សមាបន្នោ អយមាយស្មា ឥមំ កុសលំ ធម្មំ ឧទាហុ ឥត្តរសមាបន្នោតិ ។ តមេនំ សមន្នេសមានោ ឯវំ ជានាតិ ទីឃរត្តំ សមាបន្នោ អយមាយស្មា ឥមំ កុសលំ ធម្មំ

នៃព្រះតថាគត មានឬមិនមានទេ ។ កាលភិក្ខុស្វែងរកនូវហេតុនោះហើយ ក៏គង់ដឹងយ៉ាងនេះថា ធម៌ទាំងឡាយដ៏ប្រឡូកប្រឡំដែលគប្បីដឹងដោយចក្ខុនិងសោតៈ នៃព្រះតថាគត មិនមានទេ ។ កាលណាភិក្ខុស្វែងរកហេតុនោះហើយ ដឹងយ៉ាងនេះថា ធម៌ទាំងឡាយដ៏ប្រឡូកប្រឡំដែលគប្បីដឹងដោយចក្ខុនិងសោតៈ នៃព្រះតថាគត មិនមានទេ តពីនោះទៅទើបស្វែងរកហេតុនោះថា ធម៌ទាំងឡាយដ៏ផូរផង់ដែលគប្បីដឹងដោយចក្ខុនិងសោតៈ នៃព្រះតថាគត មានឬមិនមានទេ ។ កាលភិក្ខុស្វែងរកនូវហេតុនោះហើយ ក៏គង់ដឹងយ៉ាងនេះថា ធម៌ទាំងឡាយដ៏ផូរផង់ដែលគប្បីដឹងដោយចក្ខុនិងសោតៈ នៃព្រះតថាគត មានពិត ។ កាលណាភិក្ខុស្វែងរកហេតុនោះហើយ ដឹងយ៉ាងនេះថា ធម៌ទាំងឡាយដ៏ផូរផង់ដែលគប្បីដឹងដោយចក្ខុនិងសោតៈ នៃព្រះតថាគត មានពិតហើយ តទៅទើបស្វែងរកនូវហេតុនោះទៀតថា លោកមានអាយុនេះ បានសមាទានកុសលនេះអស់កាលយូរអង្វែងហើយ ឬទើបនឹងសមាទានទេ ។ កាលភិក្ខុស្វែងរកហេតុនោះហើយ ក៏គង់ដឹងយ៉ាងនេះថា លោកមានអាយុនេះបានសមាទានកុសលធម៌នេះ អស់កាលជាយូរអង្វែងមកហើយ

នាយមាយស្មា ឥត្តរសមាបន្នោតិ ។ យតោ នំ សមន្នេសមានោ ឯវំ ជានាតិ ទីឃរត្តំ សមាបន្នោ អយមាយស្មា ឥមំ កុសលំ ធម្មំ នាយមាយស្មា ឥត្តរសមាបន្នោតិ តតោ នំ ឧត្តរឹ សមន្នេសតិ ញាតជ្ឈាបន្នោ[1] អយមាយស្មា ភិក្ខុ យសប្បត្តោ[2] សំវិជ្ជន្តស្ស ឥធេកច្ចេ អាទីនវាតិ ។ ន តាវ ភិក្ខវេ ភិក្ខុនោ ឥធេកច្ចេ អាទីនវា សំវិជ្ជន្តិ យាវ ន ញាតជ្ឈាបន្នោ ហោតិ យសប្បត្តោ ។ យតោ ច ខោ ភិក្ខវេ ភិក្ខុ ញាតជ្ឈាបន្នោ ហោតិ យសប្បត្តោ អថស្ស ឥធេកច្ចេ អាទីនវា សំវិជ្ជន្តិ ។ តមេនំ សមន្នេសមានោ ឯវំ ជានាតិ ញាតជ្ឈាបន្នោ អយមាយស្មា ភិក្ខុ យសប្បត្តោ នាស្ស ឥធេកច្ចេ អាទីនវា សំវិជ្ជន្តីតិ ។ យតោ នំ សមន្នេសមានោ ឯវំ ជានាតិ ញាតជ្ឈាបន្នោ អយមាយស្មា ភិក្ខុ យសប្បត្តោ នាស្ស ឥធេកច្ចេ អាទីនវា សំវិជ្ជន្តីតិ

១ ឱ. ញត្តជ្ឈាបន្នោ ។ ២ ឱ. យសម្បត្តោ ។

លោកមានអាយុនេះមិនមែនទើបតែនឹងសមាទានឥឡូវនេះទេ ។ កាលភិក្ខុស្វែងរកហេតុនោះហើយ ដឹងយ៉ាងនេះថា លោកមានអាយុនេះបានសមាទានកុសលធម៌នេះ អស់កាលជាយូរអង្វែងណាស់មកហើយ លោកមាអាយុ មិនមែនទើបតែនឹងសមាទានឥឡូវនេះទេ តទៅទើបស្វែងរកនូវហេតុនោះទៀតថា ភិក្ខុមានអាយុនេះ មានកិត្តិសព្ទបរិបូណ៌ មានយសស័ក្តិបរិបូណ៌ហើយ តើទោសចំពូកខ្លះក្នុងលោកនេះ នៃភិក្ខុនោះមានដែរឬទេ ។ ម្នាលភិក្ខុទាំងឡាយ (តាមធម្មតា) ភិក្ខុមិនទាន់មានកិត្តិសព្ទបរិបូណ៌ មិនទាន់មានយសបរិបូណ៌ ដរាបណា ទោសទាំងឡាយចំពូកខ្លះ ភិក្ខុក៏មិនទាន់មាន ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានកិត្តិសព្ទបរិបូណ៌ មានយសបរិបូណ៌ក្នុងកាលណាហើយ ទោសទាំងឡាយចំពូកខ្លះ ក្នុងលោកនេះ នៃភិក្ខុនោះ ក៏មានក្នុងកាលនោះ ។ កាលភិក្ខុស្វែងរកហេតុនោះហើយ ក៏គង់ដឹងយ៉ាងនេះថា ភិក្ខុមានអាយុនេះ មានកិត្តិសព្ទបរិបូណ៌ មានយសបរិបូណ៌ហើយ ទោសទាំងឡាយចំពូកខ្លះក្នុងលោកនេះ នៃភិក្ខុនោះ ក៏មិនមាន ។ កាលភិក្ខុស្វែងរកហេតុនោះហើយ ដឹងយ៉ាងនេះថា ភិក្ខុមានអាយុនេះ មានកិត្តិសព្ទបរិបូណ៌ មានយសបរិបូណ៌ ទោសទាំងឡាយចំពូកខ្លះក្នុងលោកនេះ នៃភិក្ខុនោះ

តតោ នំ ឧត្តរឹ សមន្នេសតិ អកយូបរតោ អយមាយ-ស្មា ឆាយមាយស្មា ភយូបរតោ វីតរាគត្តា កាមេ ន សេវតិ ខយា រាគស្សាតិ ។ តមេនំ សមន្នេសមានោ ឯវំ ជានាតិ អកយូបរតោ អយមាយស្មា ឆាយមា-យស្មា ភយូបរតោ វីតរាគត្តា កាមេ ន សេវតិ ខយា រាគស្សាតិ ។ តញ្ចេ ភិក្ខវេ ភិក្ខុំ បរេ ឯវំ បុច្ឆេយ្យុំ កោ បនាយស្មតោ អាការា កោ អន្វយា យេនាយស្មា ឯវំ វទេតិ អកយូបរតោ អយមាយស្មា ឆាយមាយស្មា ភយូបរតោ វីតរាគត្តា កាមេ ន សេវតិ ខយា រាគស្សាតិ ។ សម្មា ព្យាករ-មានោ ភិក្ខវេ ភិក្ខុ ឯវំ ព្យាករេយ្យ តថា ហិ បន អយមាយស្មា សង្ឃេ វា វិហរន្តោ

មិនមានឡើយ តទៅទើបស្វែងរកហេតុនោះទៀតថា លោកមានអាយុនេះមិនវិនាសដោយភ័យ[១] ឬលោកមានអាយុនេះដែលមិនវិនាសដោយភ័យហើយ មិនសេពកាមទាំងឡាយទេ ព្រោះលោកប្រាសចាករាគៈហើយ ព្រោះអស់រាគៈហើយ ។ ភិក្ខុនោះកាលស្វែងរកហេតុនោះហើយដឹងយ៉ាងនេះថា លោកមានអាយុនេះមិនវិនាសដោយភ័យ លោកមានអាយុនេះដែលមិនវិនាសដោយភ័យហើយ មិនសេពនូវកាមទាំងឡាយទេ ព្រោះលោកប្រាសចាករាគៈហើយ ព្រោះអស់រាគៈហើយ ។ ម្នាលភិក្ខុទាំងឡាយ បើពួកជនឯទៀត សួរហេតុនោះនឹងភិក្ខុយ៉ាងនេះថា ចុះអាការរបស់លោកមានអាយុដូចម្ដេច សេចក្ដីត្រាស់ដឹងដូចម្ដេច បានជាលោកមានអាយុពោលយ៉ាងនេះថា លោកមានអាយុនេះមិនវិនាសដោយភ័យ លោកមានអាយុនេះដែលមិនវិនាសដោយភ័យហើយ មិនសេពនូវកាមទាំងឡាយទេ ព្រោះលោកប្រាសចាករាគៈហើយ ព្រោះអស់រាគៈហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលនឹងព្យាករឲ្យត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា លោកមានអាយុនេះ ទុកជានៅកណ្ដាលជំនុំសង្ឃក្ដី

---

១ អដ្ឋកថាថា ភ័យ ៤ យ៉ាង គឺ កិលេសភ័យ ១ វដ្តភ័យ ១ ទុគ្គតិភ័យ ១ ឧបវាទភ័យ ១ ។ បុថុជ្ជនតែងប្រកបដោយភ័យទាំង ៤ នេះ ។ ឯសេក្ខបុគ្គលប្រកបដោយភ័យ ៣ ព្រោះលះទុគ្គតិភ័យ ១ ចោល ចំណែកខាងព្រះខីណាស្រពឥតមានភ័យទាំងនេះគ្របសង្កត់លោកទេ ។

ឯកោ វា វិហរន្តោ យេ ច តត្ថ សុគតា យេ ច តត្ថ ទុគ្គតា យេ ច តត្ថ គណមនុសាសន្តិ យេ ច ឥធេកច្ចេ អាមិសេសុ សន្ទិស្សន្តិ យេ ច ឥធេកច្ចេ អាមិសេន អនុបលិត្តា នាយស្មា តំ តេន អវជានាតិ ។ សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ អភយូបរតោហមស្មិ នាហមស្មិ ភយូបរតោ វីតរាគត្តា កាមេ ន សេវាមិ ខយា រាគស្សាតិ ។

[២៧៨] តត្រ ភិក្ខវេ តថាគតោ[១] ឧត្តរឹ បដិបុច្ឆិតព្វោ យេ សង្កិលិដ្ឋា ចក្ខុសោតវិញ្ញេយ្យា ធម្មា សំវិជ្ជន្តិ វា តេ តថាគតស្ស នោ វាតិ ។ ព្យាករមានោ ភិក្ខវេ តថាគតោ ឯវំ ព្យាករេយ្យ យេ សង្កិលិដ្ឋា ចក្ខុសោតវិញ្ញេយ្យា ធម្មា ន តេ តថាគតស្ស សំវិជ្ជន្តីតិ ។ យេ វីតិមិស្សា ចក្ខុសោតវិញ្ញេយ្យា ធម្មា សំវិជ្ជន្តិ វា តេ តថាគតស្ស នោ វាតិ ។ ព្យាករមានោ ភិក្ខវេ តថាគតោ

១ ឱ. ម. តថាគតោ វ ។

នៅតែម្នាក់ឯងក្តី លោកមានអាយុនេះ មិនមើលងាយ នូវពួកជនដែលប្រតិបត្តិត្រូវក្នុងទីនោះផង នូវពួកជនដែលប្រតិបត្តិខុស ក្នុងទីនោះផង នូវពួកជនដែលប្រៀនប្រដៅគណៈក្នុងទីនោះផង នូវពួកជនខ្លះក្នុងលោកនេះដែលសំឡឹងអាមិសៈផង នូវពួកជនខ្លះក្នុងលោកនេះដែលមិនជាប់ចិត្តដោយអាមិសៈផង ដោយសេចក្តីប្រតិបត្តិ (របស់ជនទាំងនោះ) ឡើយ ។ ពាក្យនេះខ្ញុំបានស្តាប់មកអំពីទីចំពោះព្រះកក្រ្តព្រះមានព្រះភាគ ខ្ញុំបានចេះចាំមក អំពីទីចំពោះព្រះកក្រ្តព្រះមានព្រះភាគថា ខ្ញុំជាបុគ្គលមិនវិនាសដោយភ័យ លុះខ្ញុំមិនវិនាសដោយភ័យហើយក៏មិនសេពនូវកាមទាំងឡាយ ព្រោះប្រាសចាករាគៈហើយ ព្រោះអស់រាគៈហើយ ។

[១៧៨] ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកពិចារណានូវធម៌ទាំងពីរនោះ គួរឲ្យភិក្ខុអ្នកពិចារណាធម៌មួយរូប សាកសួរតថាគតទៅទៀតថា ធម៌ទាំងឡាយដ៏សៅហ្មង ដែលគប្បីដឹងដោយចក្ខុនិងសោតៈ នៃព្រះតថាគត មានឬមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតកាលនឹងព្យាករគប្បីព្យាករយ៉ាងនេះថា ធម៌ទាំងឡាយដ៏សៅហ្មងដែលគប្បីដឹងដោយចក្ខុនិងសោតៈ នៃព្រះតថាគត មិនមានទេ ។ ធម៌ទាំងឡាយដ៏ច្រឡូកច្រឡំ ដែលគប្បីដឹងដោយចក្ខុនិងសោតៈ នៃព្រះតថាគតមាន ឬមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតកាលនឹងព្យាករ

ចូឡយមកវគ្គស្ស វីមំសកសុត្តេ ឧត្តរឹ បដិបុច្ឆា

ឯវំ ព្យាករេយ្យ យេ វីតិមិស្សា ចក្ខុសោតវិញ្ញេយ្យា ធម្មា ន តេ តថាគតស្ស សំវិជ្ជន្តីតិ ។ យេ វោទាតា ចក្ខុសោតវិញ្ញេយ្យា ធម្មា សំវិជ្ជន្តិ វា តេ តថាគតស្ស នោ វាតិ ។ ព្យាករមានោ ភិក្ខវេ តថាគតោ ឯវំ ព្យាករេយ្យ យេ វោទាតា ចក្ខុសោតវិញ្ញេយ្យា ធម្មា សំវិជ្ជន្តិ តេ តថាគតស្ស ឯតបថោហមស្មិ ឯតគោចរោ នោ ច តេន តម្មយោតិ ។ ឯវំវាទឹ ខោ ភិក្ខវេ សត្ថារំ អរហតិ សាវកោ ឧបសង្កមិតុំ ធម្មស្សវនាយ តស្ស សត្ថា ធម្មំ ទេសេតិ ឧត្តរុត្តរឹ បណីតប្បណីតំ កណ្ហាសុក្កសប្បដិភាគំ យថាយថា ខោ ភិក្ខវេ ភិក្ខុនោ សត្ថា ធម្មំ ទេសេតិ ឧត្តរុត្តរឹ បណីតប្បណីតំ កណ្ហាសុក្កសប្បដិភាគំ តថាតថា សោ តស្មឹ ធម្មេ អភិញ្ញាយ ឥធេកច្ចំ ធម្មំ ធម្មេសុ និដ្ឋង្គច្ឆតិ សត្ថរិ បសីទតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ

គប្បីព្យាករយ៉ាងនេះថា ធម៌ទាំងឡាយ ដ៏ច្រឡូកច្រឡំ ដែលគប្បីដឹងដោយចក្ខុនិងសោតៈ នៃព្រះតថាគតមិនមានទេ ។ ធម៌ទាំងឡាយដ៏ផូរផង់ ដែលគប្បីដឹងដោយចក្ខុនិងសោតៈ នៃព្រះតថាគត មានឬមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតកាលនឹងព្យាករដោយត្រឹមត្រូវគប្បីព្យាករយ៉ាងនេះថា ធម៌ទាំងឡាយដ៏ផូរផង់ ដែលគប្បីដឹងដោយចក្ខុនិងសោតៈ នៃព្រះតថាគតមានពិត តថាគតមានគន្លងបែបនេះ មានអារម្មណ៍ជាទីគោចរបែបនេះ មិនប្រកបដោយតណ្ហា ព្រោះសីលដ៏បរិសុទ្ធនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ សាវ័កគួរចូលទៅរកសាស្តាដែលមានវាទៈយ៉ាងនេះ ដើម្បីនឹងបានស្តាប់នូវធម្មទេសនា សាស្តាសំដែងធម៌ដ៏ប្រសើរក្រៃលែង ដ៏ឧត្តមក្រៃលែង មានចំណែកប្រៀបស្មើដោយធម៌ខ្មៅនិងធម៌ស ដល់សាវ័កនោះ ម្នាលភិក្ខុទាំងឡាយ សាស្តាតែងសំដែងធម៌ដ៏ប្រសើរក្រៃលែង ដ៏ឧត្តមក្រៃលែង មានចំណែកប្រៀបស្មើដោយធម៌ខ្មៅនិងធម៌ស ដល់ភិក្ខុ ដោយប្រការណា ៗ ភិក្ខុនោះបានដឹងច្បាស់នូវបដិវេធធម៌ចំពូកខ្លះ ក្នុងសាសនានេះ ក្នុងធម៌ដែលព្រះមានព្រះភាគសំដែងហើយនោះ ហើយដល់នូវសេចក្តីចូលចិត្តក្នុងទេសនាធម៌ទាំងឡាយ ជ្រះថ្លាក្នុងព្រះសាស្តាថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ធម៌ព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដោយប្រពៃ

សុប្បដិបន្នោ សង្ឃោតិ ។ តញ្ចេ ភិក្ខវេ ភិក្ខុំ បរេវំ បុច្ឆេយ្យុំ កេ បនាយស្មតោ អាការា កេ អន្វយា យេនាយស្មា ឯវំ វទេតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ សង្ឃោតិ ។ សម្មា ព្យាករមានោ ភិក្ខវេ ភិក្ខុ ឯវំ ព្យាករេយ្យ ឥធាហំ អាវុសោ យេន ភគវា តេនុបសង្កមឹ ធម្មស្សវនាយ តស្ស មេ ភគវា ធម្មំ ទេសេតិ ឧត្តរុត្តរឹ បណីតប្បណីតំ កណ្ហសុក្កសប្បដិភាគំ យថាយថា មេ អាវុសោ ភគវា ធម្មំ ទេសេតិ ឧត្តរុត្តរឹ បណីតប្បណីតំ កណ្ហសុក្កសប្បដិភាគំ តថាតថាហំ តស្មឹ ធម្មេ អភិញ្ញាយ ឥធេកច្ចំ ធម្មំ ធម្មេសុ និដ្ឋង្គមំ សត្ថរិ បសីទឹ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ សង្ឃោតិ ។

ព្រះសង្ឃប្រតិបត្តិប្រពៃហើយ ដូច្នេះ ដោយប្រការនោះ ៗ ។ ម្នាលភិក្ខុទាំងឡាយ បើពួកជនសួរសេចក្តីនោះនឹងភិក្ខុ យ៉ាងនេះទៀតថា ចុះអាការរបស់លោកមានអាយុដូចម្តេច សេចក្តីត្រាស់ដឹងដូចម្តេច បានជាលោកមានអាយុពោល យ៉ាងនេះថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ធម៌ព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដោយប្រពៃ ព្រះសង្ឃប្រតិបត្តិប្រពៃហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលនឹងព្យាករឲ្យត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគក្នុងទីនេះ ដើម្បីស្តាប់ធម៌ ព្រះមានព្រះភាគក៏ទ្រង់សំដែងធម៌ ដ៏ប្រសើរក្រៃលែង ដ៏ឧត្តមក្រៃលែង មានចំណែកប្រៀបស្មើដោយធម៌ខ្មៅនិងធម៌សដល់ខ្ញុំ ម្នាលអាវុសោ ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ដ៏ប្រសើរក្រៃលែង ដ៏ឧត្តមក្រៃលែង មានចំណែកប្រៀបស្មើដោយធម៌ខ្មៅនិងធម៌សដល់ខ្ញុំនោះ ដោយប្រការណា ៗ ខ្ញុំក៏ដឹងច្បាស់នូវបដិវេធធម៌ចំពូកខ្លះ ក្នុងសាសនានេះ ក្នុងធម៌ដែលព្រះមានព្រះភាគសំដែងហើយនោះ ហើយដល់នូវសេចក្តីចូលចិត្តក្នុងទេសនាធម៌ទាំងឡាយ ជ្រះថ្លាក្នុងព្រះសាស្តាថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ព្រះមានព្រះភាគ ទ្រង់សំដែងប្រពៃហើយ ព្រះសង្ឃប្រតិបត្តិប្រពៃហើយ ដូច្នេះ ដោយប្រការនោះ ៗ ។

ចូឡយមកវគ្គស្ស វីមំសកសុត្តេ តថាគតអចលសទ្ធា

[១៧៩] យស្ស កស្សចិ ភិក្ខវេ ឥមេហិ អាការេហិ ឥមេហិ បទេហិ ឥមេហិ ព្យញ្ជនេហិ តថាគតេ សទ្ធា និវិដ្ឋា ហោតិ មូលជាតា បតិដ្ឋាជាតា[១] អយំ វុច្ចតិ ភិក្ខវេ អាការវតី សទ្ធា ទស្សនមូលិកា ទឡ្ហា អសំហារិយា សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ ។ ឯវំ ខោ ភិក្ខវេ តថាគតេ ធម្មសមន្នេសនា ហោតិ ឯវញ្ច បន តថាគតោ ធម្មតោ[២] សុសមន្និដ្ឋោ ហោតីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

វីមំសកសុត្តំ សត្តមំ និដ្ឋិតំ ។

---

១ ឱ. បតិដ្ឋិតា ។ ម. បតិដ្ឋា ។ ២ ឱ. ម. ធម្មតា ។

[១៧៩] ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ មានសទ្ធាមិនកម្រើក ចាក់ឫសខ្ជាប់ តម្កល់ស៊ប់ក្នុងព្រះតថាគត ដោយអាការទាំង-ឡាយនេះ ដោយបទទាំងឡាយនេះ ដោយព្យញ្ជនៈទាំងឡាយនេះហើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះទើបតថាគតហៅថា អ្នកមានសទ្ធា ប្រកបដោយហេតុ មានសោតាបត្តិមគ្គជាមូលដ៏មាំមួន ឥតមានសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយ ក្នុងលោកក្តី ដឹកនាំទៅបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកធម៌ក្នុងព្រះតថាគត យ៉ាងនេះ ចំណែកខាងព្រះតថាគត (ត្រូវតែ) បុគ្គលស្វះស្វែងរក តាមធម្មតា យ៉ាងនេះដែរ ។ លុះព្រះមានព្រះភាគ បានត្រាស់ភាសិតនេះចប់ហើយ ពួកភិក្ខុទាំងនោះមានសេចក្តីពេញចិត្ត ត្រេកអរនឹងភាសិត របស់ព្រះមានព្រះភាគ ។

ចប់ វីមំសកសូត្រ ទី ៧ ។

# អដ្ឋមំ កោសម្ពិយសុត្តំ

[១៨០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន កោសម្ពិយំ ភិក្ខូ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុ-ទន្តា វិហរន្តិ តេ ន ចេវ អញ្ញមញ្ញំ សញ្ញាបេន្តិ ន ច សញ្ញត្តឹ ឧបេន្តិ ន ច អញ្ញមញ្ញំ និជ្ឈា-បេន្តិ ន ច និជ្ឈត្តឹ ឧបេន្តិ ។ អថខោ អញ្ញ-តរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្ក-មិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទ-វោច ឥធ ភន្តេ កោសម្ពិយំ ភិក្ខូ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ តេ ន ចេវ អញ្ញមញ្ញំ សញ្ញា-បេន្តិ ន ច សញ្ញត្តឹ ឧបេន្តិ ន ច អញ្ញមញ្ញំ និជ្ឈាបេន្តិ ន ច និជ្ឈត្តឹ ឧបេន្តីតិ ។ អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ

# កោសម្ពិយសូត្រ ទី ៨

[១៨០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ ក៏សម័យនោះឯង ពួកភិក្ខុក្នុងក្រុងកោសម្ពី បង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ចាក់ដោតគ្នានិងគ្នាដោយលំពែងគឺមាត់ ពួកភិក្ខុទាំងនោះ មិនញ៉ាំងគ្នានិងគ្នាឲ្យសុខចិត្តផង មិនប្រាថ្នានូវសេចក្តីសុខចិត្តផង មិនញ៉ាំងគ្នានិងគ្នាឲ្យយល់ព្រមផង មិនប្រាថ្នានូវសេចក្តីយល់ព្រមផង ។ គ្រានោះ ភិក្ខុ ១ រូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុក្នុងនគរកោសម្ពីនេះ បង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ចាក់ដោតគ្នានិងគ្នាដោយលំពែងគឺមាត់ ភិក្ខុទាំងនោះ មិនញ៉ាំងគ្នានិងគ្នាឲ្យសុខចិត្តផង មិនប្រាថ្នានូវសេចក្តីសុខចិត្តផង មិនញ៉ាំងគ្នានិងគ្នាឲ្យយល់ព្រមផង មិនប្រាថ្នានូវសេចក្តីយល់ព្រមផង ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុមួយរូបមកថា ម្នាលភិក្ខុ អ្នកចូរមកនេះ

មម វចនេន តេ ភិក្ខូ អាមន្តេហិ សត្ថា វោ អាយស្មន្តេ(១) អាមន្តេតីតិ(២) ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច សត្ថា អាយស្មន្តេ អាមន្តេតីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ តស្ស ភិក្ខុនោ បដិស្សុត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។

[១៨១] ឯកមន្តំ និសិន្នេ ខោ តេ ភិក្ខូ ភគវា ឯតទវោច សច្ចំ កិរ តុម្ហេ ភិក្ខវេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរថ តេ ន ចេវ អញ្ញមញ្ញំ សញ្ញាបេថ ន ច សញ្ញត្តឹ ឧបេថ ន ច អញ្ញមញ្ញំ និជ្ឈាបេថ ន ច និជ្ឈត្តឹ ឧបេថាតិ ។ ឯវំ ភន្តេតិ(៣) ។ តំ កឹ មញ្ញថ ភិក្ខវេ យស្មឹ តុម្ហេ សមយេ

---

១ ឱ. សត្ថាយស្មន្តេតិ ទិស្សតិ ។ ២ ម. អាមន្តេសីតិ ។ ៣ ឱ. ម. ឥតិសទ្ទោ ន ទិស្សតិ ។

អ្នកចូរហៅភិក្ខុទាំងឡាយនោះ តាមពាក្យតថាគតថា ព្រះសាស្តាត្រាស់ហៅលោកមានអាយុទាំងឡាយ ។ ភិក្ខុនោះបានទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយចូលទៅរកពួកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងភិក្ខុទាំងនោះដូច្នេះថា ព្រះសាស្តាទ្រង់ត្រាស់ហៅលោកមានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះបានទទួលស្តាប់ពាក្យភិក្ខុនោះថា ករុណា អាវុសោ ដូច្នេះហើយក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចទើបអង្គុយក្នុងទីដ៏សមគួរ ។

[១៨១] លុះពួកភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគបានត្រាស់ភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ បានឮថាអ្នកទាំងឡាយ បង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ចាក់ដោតគ្នានិងគ្នាដោយលំពែងគឺមាត់ អ្នកទាំងឡាយនោះ មិនញ៉ាំងគ្នានិងគ្នាឲ្យសុខចិត្តផង មិនប្រាថ្នានូវសេចក្តីសុខចិត្តផង មិនញ៉ាំងគ្នានិងគ្នាឲ្យយល់ព្រមផង មិនប្រាថ្នានូវសេចក្តីយល់ព្រមផង ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា ព្រះករុណា ព្រះអង្គ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះ ដូចម្តេច សម័យណា

ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរថ អបិ នុ តុម្ហាកំ តស្មឹ សមយេ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវី ចេវ រហោ ច មេត្តំ វចីកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវី ចេវ រហោ ច មេត្តំ មនោកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវី ចេវ រហោ ចាតិ ។ នោ ហេតំ ភន្តេ ។ ឥតិ កិរ ភិក្ខវេ យស្មឹ តុម្ហេ សមយេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរថ នេវ តុម្ហាកំ តស្មឹ សមយេ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវី ចេវ រហោ ច ន មេត្តំ វចីកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវី ចេវ រហោ ច ន មេត្តំ មនោកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវី ចេវ រហោ ច អថ កិញ្ចរហិ តុម្ហេ មោឃបុរិសា កឹ ជានន្តា កឹ បស្សន្តា ភណ្ឌនជាតា កលហជាតា

ដែលអ្នកទាំងឡាយ បង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ចាក់ដោតគ្នានិង គ្នាដោយលំពែងគឺមាត់ សម័យនោះ អ្នកទាំងឡាយបានតាំងកាយកម្ម ប្រកបដោយមេត្តា ចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ក្នុងទីចំពោះមុខ និងទីកំបាំងមុខ ឬបានតាំងវចីកម្មប្រកបដោយមេត្តា ឬបានតាំងមនោកម្ម ប្រកបដោយមេត្តា ចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ក្នុងទីចំពោះ មុខនិងទីកំបាំងមុខ ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនបានតាំង យ៉ាងនោះទេ ។ ម្នាលភិក្ខុទាំងឡាយ បានឮដូច្នេះថា សម័យណា ដែលអ្នកទាំងឡាយ បង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ចាក់ដោតគ្នា និងគ្នា ដោយលំពែងគឺមាត់ សម័យនោះ អ្នកទាំងឡាយមិនបានតាំង កាយកម្មប្រកបដោយមេត្តា ចំពោះពួកសព្រហ្មចារីបុគ្គល ក្នុងទីចំពោះ មុខនិងទីកំបាំងមុខផង មិនបានតាំងវចីកម្មប្រកបដោយមេត្តាចំពោះពួក សព្រហ្មចារីបុគ្គល ក្នុងទីចំពោះមុខនិងទីកំបាំងមុខផង មិនបានតាំង មនោកម្មប្រកបដោយមេត្តា ចំពោះពួកសព្រហ្មចារីបុគ្គល ក្នុងទីចំពោះ មុខនិងទីកំបាំងមុខផង ម្នាលមោឃបុរសទាំងឡាយ ឥឡូវនេះ អ្នក ទាំងឡាយដឹងដូចម្តេច ឃើញដូចម្តេច បានជាបង្កហេតុ ឈ្លោះ

វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរថ តេ ន ចេវ អញ្ញមញ្ញំ សញ្ញាបេថ ន ច សញ្ញត្តឹ ឧបេថ ន ច អញ្ញមញ្ញំ និជ្ឈាបេថ ន ច និជ្ឈត្តឹ ឧបេថ តញ្ហិ តុម្ហាកំ មោឃបុរិសា ភវិស្សតិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។

[១៨២] អថខោ ភគវា ភិក្ខូ អាមន្តេសិ ឆយិមេ ភិក្ខវេ ធម្មា សារាណីយា បិយករណា គរុករណា សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តន្តិ ។ កតមេ ឆ ។ ឥធ ភិក្ខវេ ភិក្ខុនោ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវី ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ មេត្តំ វចីកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវី ចេវ រហោ ច អយម្បិ

ទាស់ទែងគ្នា ចាក់ដោតគ្នានិងគ្នា ដោយលំពែងគឺមាត់ អ្នកទាំងឡាយនោះ មិនញុំាងគ្នានិងគ្នាឲ្យសុខចិត្តផង មិនប្រាថ្នានូវសេចក្តីសុខចិត្តផង មិនញុំាងគ្នានិងគ្នាឲ្យយល់ព្រមផង មិនប្រាថ្នា នូវសេចក្តីយល់ព្រមផង ម្នាលមោឃបុរសទាំងឡាយ ហេតុនោះនឹងប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនចម្រើន ដើម្បីសេចក្តីទុក្ខដល់អ្នកទាំងឡាយ អស់កាលជាយូរអង្វែង ។

[១៨២] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៦ ប្រការនោះ ជាទីរលឹក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ។ ធម៌ទាំងឡាយ ៦ ប្រការ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរតាំងកាយកម្មប្រកបដោយមេត្តា ចំពោះពួកសព្រហ្មចារីបុគ្គល ក្នុងទីចំពោះមុខនិងទីកំបាំងមុខផង នេះឯងជាធម៌គួរឲ្យរលឹក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត ភិក្ខុគួរតាំងវចីកម្មប្រកបដោយមេត្តាចំពោះពួកសព្រហ្មចារីបុគ្គល ក្នុងទីចំពោះមុខនិងទីកំបាំងមុខផង នេះឯង

ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គ-ហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ មេត្តំ មនោកម្មំ បច្ចុ-បដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវី ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករ-ណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភា-វាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ[១] យេ តេ លាភា ធម្មិកា ធម្មលទ្ធា អន្តមសោ បត្តបរិយា-បន្នមត្តំបិ តថារូបេហិ លាភេហិ អប្បដិវិភត្តភោគី ហោតិ សីលវន្តេហិ សព្រហ្មចារីហិ សាធារណភោគី អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករ-ណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ យានិ តានិ សីលានិ អក្ខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អ-កម្មាសានិ ភុជិស្សានិ វិញ្ញូបសដ្ឋានិ អបរាមដ្ឋានិ

១ ម. ភិក្ខុនោ ។

ជាធម៌គួរឲ្យរលឹក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត ភិក្ខុគួរតាំងមនោកម្មប្រកបដោយមេត្តា ចំពោះពួកសព្រហ្មចារីបុគ្គល ក្នុងទីចំពោះមុខនិងទីកំបាំងមុខផង នេះឯងជាធម៌គួរឲ្យរលឹក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត លាភណា ដែលប្រកបដោយធម៌ បានមកដោយធម៌ ដោយហោចទៅ សូម្បីតែវត្ថុដែលរាប់ចូលក្នុងបាត្រ ភិក្ខុជាអ្នកបរិភោគមិនចែករំលែកលាភទាំងឡាយ មានសភាពដូច្នោះទេ គឺជាអ្នកបរិភោគសាធារណ៍ដោយពួកសព្រហ្មចារីបុគ្គលដែលមានសីល នេះឯងជាធម៌គួរឲ្យរលឹក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត សីលណា មិនដាច់ មិនធ្លុះធ្លាយ មិនពពាល មិនពព្រុស ជាសីលល្អ ដែលវិញ្ញូជន តែងសរសើរ មិនប៉ះពាល់ ដោយតណ្ហា

៣៤១



សមាធិសំវត្តនិកានិ តថារូបេសុ សីលេសុ សីលសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវី ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ យាយំ ទិដ្ឋិ អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មា ទុក្ខក្ខយាយ តថារូបាយ ទិដ្ឋិយា ទិដ្ឋិសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវី ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ ឆ សារាណីយា ធម្មា បិយករណា គរុករណា សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ ឥមេសំ ខោ ភិក្ខវេ

និងទិដ្ឋិ ប្រព្រឹត្តទៅដើម្បីសមាធិ ភិក្ខុជាអ្នកមានសីលស្មើគ្នានឹងពួកសព្រហ្មចារីបុគ្គល ក្នុងសីលទាំងឡាយមានសភាពដូច្នោះ ទាំងក្នុងទីចំពោះមុខទាំងទីកំបាំងមុខ នេះឯងជាធម៌គួរឲ្យរលឹក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រការមួយវិញទៀត ទិដ្ឋិ[១] ណា ដ៏ប្រសើរ ជាទីស្រោចស្រង់សត្វ រមែងដឹកនាំសត្វដែលធ្វើតាមឲ្យអស់ទៅនៃសេចក្តីទុក្ខបាន ដោយប្រពៃ ភិក្ខុប្រកបដោយទិដ្ឋិស្មើគ្នានឹងពួកសព្រហ្មចារីបុគ្គល ក្នុងទិដ្ឋិមានសភាពដូច្នោះ ទាំងក្នុងទីចំពោះមុខទាំងទីកំបាំងមុខ នេះឯងជាធម៌គួរឲ្យរលឹក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ សារាណីយធម៌ទាំង ៦ ប្រការនេះឯង ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ។ ម្នាលភិក្ខុទាំងឡាយ

---

១ អដ្ឋកថា ថា សម្មាទិដ្ឋិ ប្រកបដោយសោតាបត្តិមគ្គ ។

ឆន្នំ សាភាណីយានំ ធម្មានំ ឯតំ អគ្គំ ឯតំ សង្គាហិកំ ឯតំ សង្ឃាដនិយំ[១] យទិទំ យាយំ ទិដ្ឋិ អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយ ។ សេយ្យថាបិ ភិក្ខវេ កូដាគារស្ស ឯតំ អគ្គំ ឯតំ សង្គាហិកំ ឯតំ សង្ឃាដនិយំ យទិទំ កូដំ ឯវមេវ ខោ ភិក្ខវេ ឥមេសំ ឆន្នំ សាភាណីយានំ ធម្មានំ ឯតំ អគ្គំ ឯតំ សង្គាហិកំ ឯតំ សង្ឃាដនិយំ យទិទំ យាយំ ទិដ្ឋិ អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មា ទុក្ខក្ខយាយ ។

[១៨៣] កាថញ្ច ភិក្ខវេ យាយំ ទិដ្ឋិ អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មា ទុក្ខក្ខយាយ ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ អត្ថិ នុ ខោ មេ តំ បរិយុដ្ឋានំ អជ្ឈត្តំ អប្បហីនំ យេនាហំ បរិយុដ្ឋានេន បរិយុដ្ឋិតចិត្តោ យថាភូតំ នប្បជានេយ្យំ ន បស្សេយ្យន្តិ[២] ។ សចេ ភិក្ខវេ ភិក្ខុ កាមរាគបរិ-

១ ឱ. ម. សង្ឃាដនិកន្តិ ទិស្សតិ ។ ២ ឱ. ម. ន ជានេយ្យំ ន បស្សេយ្យន្តីតិ ទិស្សន្តិ ។

បណ្តាសាវណីយធម៌ទាំង ៦ ប្រការនេះ មានតែទិដ្ឋិដ៏ប្រសើរ ជាទីស្រោចស្រង់នេះឯង ដែលជាច្បង ជាទីរួបរួម ជាទីប្រជុំចុះ (នៃធម៌ទាំង ៥ នោះ) អាចដឹកនាំសត្វដែលប្រតិបត្តិតាម ឲ្យអស់ទៅនៃទុក្ខដោយប្រពៃបាន ។ ម្នាលភិក្ខុទាំងឡាយ កំពូលនៃផ្ទះមានកំពូល ជាច្បង ជាទីរួបរួម ជាទីប្រជុំចុះ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ បណ្តាសាវ-ណីយធម៌ទាំង ៦ ប្រការនេះ មានតែទិដ្ឋិដ៏ប្រសើរ ជាទីស្រោចស្រង់នេះឯង ដែលជាច្បង ជាទីរួបរួម ជាទីប្រជុំចុះ (នៃធម៌ទាំង ៥ នោះ) អាចដឹកនាំសត្វដែលប្រតិបត្តិតាម ឲ្យអស់ទុក្ខដោយប្រពៃបាន យ៉ាងនោះដែរ ។

[១៨៣] ម្នាលភិក្ខុទាំងឡាយ ទិដ្ឋិដ៏ប្រសើរដែលជាទីស្រោចស្រង់ដឹកនាំសត្វដែលប្រតិបត្តិតាម ឲ្យអស់សេចក្តីទុក្ខបានដោយប្រពៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងសុញ្ញាគារស្ថានក្តី រមែងពិចារណាដូច្នេះថា អាត្មាអញមានចិត្តដែលបរិយុដ្ឋានកិលេសណា គ្របសង្កត់ហើយ មិនដឹងច្បាស់ មិនឃើញច្បាស់ តាមសភាវៈពិត បរិយុដ្ឋានកិលេសនោះតាំងនៅក្នុងសន្តាន អាត្មាអញមិនទាន់លះបង់បាន មានដែរឬទេ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុ មានកាមរាគ គ្របសង្កត់ហើយ

យុដ្ឋិតោ ហោតិ បរិយុដ្ឋិតចិត្តោ វ ហោតិ សចេ ភិក្ខវេ ភិក្ខុ ព្យាបាទបរិយុដ្ឋិតោ ហោតិ បរិយុដ្ឋិត-ចិត្តោ វ ហោតិ សចេ ភិក្ខវេ ភិក្ខុ ថីនមិទ្ធបរិយុដ្ឋិតោ ហោតិ បរិយុដ្ឋិតចិត្តោ វ ហោតិ សចេ ភិក្ខវេ ភិក្ខុ ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតោ ហោតិ បរិយុដ្ឋិតចិត្តោ វ ហោតិ សចេ ភិក្ខវេ ភិក្ខុ វិចិកិច្ឆាបរិយុដ្ឋិតោ ហោតិ បរិយុដ្ឋិតចិត្តោ វ ហោតិ សចេ ភិក្ខវេ ភិក្ខុ ឥធ លោកចិន្តាយ បសុតោ ហោតិ បរិយុដ្ឋិតចិត្តោ វ ហោតិ សចេ ភិក្ខវេ ភិក្ខុ បរលោកចិន្តាយ បសុតោ ហោតិ បរិយុដ្ឋិតចិត្តោ វ ហោតិ សចេ ភិក្ខវេ ភិក្ខុ ភណ្ឌនជាតោ កលហជាតោ វិវាទាបន្នោ អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តោ វិហរតិ បរិយុដ្ឋិតចិត្តោ វ ហោតិ

ក៏ឈ្មោះថាជាអ្នកមានចិត្តដែលបរិយុដ្ឋានកិលេសគ្របសង្កត់ពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានព្យាបាទគ្របសង្កត់ហើយ ក៏ឈ្មោះថាជាអ្នកមានចិត្តដែលបរិយុដ្ឋានកិលេសគ្របសង្កត់ពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុ មានថីនមិទ្ធៈគ្របសង្កត់ហើយ ក៏ឈ្មោះថាជាអ្នកមានចិត្តដែលបរិយុដ្ឋានកិលេស គ្របសង្កត់ពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ហើយ ក៏ឈ្មោះថាជាអ្នកមានចិត្តដែលបរិយុដ្ឋានកិលេសគ្របសង្កត់ពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានវិចិកិច្ឆាគ្របសង្កត់ហើយ ក៏ឈ្មោះថាជាអ្នកមានចិត្តដែលបរិយុដ្ឋាន-កិលេសគ្របសង្កត់ពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុខ្វល់ខ្វាយដោយការគិតនូវលោកនេះហើយ ឈ្មោះថាជាអ្នកមានចិត្តដែលបរិយុដ្ឋាន-កិលេសគ្របសង្កត់ពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានសេចក្តីខ្វល់ខ្វាយដោយការគិតនូវលោកខាងមុខហើយ ឈ្មោះថាជាអ្នកមានចិត្តដែលបរិយុដ្ឋានកិលេសគ្របសង្កត់ពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុបង្កហេតុ ឈ្លោះ ទាស់ទែងគ្នា ចាក់ដោតគ្នានិងគ្នាដោយលំពែងគឺមាត់ហើយ ឈ្មោះថាជាអ្នកមានចិត្តដែលបរិយុដ្ឋានកិលេសគ្របសង្កត់ពិត

សោ ឯវំ បជានាតិ នត្ថិ ខោ មេ តំ បរិយុដ្ឋានំ អជ្ឈត្តំ អប្បហីនំ យេនាហំ បរិយុដ្ឋានេន បរិយុដ្ឋិតចិត្តោ យថាភូតំ នប្បជានេយ្យំ ន បស្សេយ្យំ សុប្បណិហិតំ មេ មានសំ សច្ចានំ ពោធាយាតិ ។ ឥទមស្ស បឋមំ ញាណំ អធិគតំ ហោតិ អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ ។

[១៨៤] បុន ចបរំ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ ឥមំ នុ ខោ អហំ ទិដ្ឋឹ អាសេវន្តោ ភាវេន្តោ ពហុលីករោន្តោ លភាមិ បច្ចត្តំ សមថំ លភាមិ បច្ចត្តំ និព្ពុតិន្តិ ។ សោ ឯវំ បជានាតិ ឥមំ ខោ អហំ ទិដ្ឋឹ អាសេវន្តោ ភាវេន្តោ ពហុលីករោន្តោ លភាមិ បច្ចត្តំ សមថំ លភាមិ បច្ចត្តំ និព្ពុតិន្តិ ។ ឥទមស្ស ទុតិយំ ញាណំ អធិគតំ ហោតិ អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ ។

ភិក្ខុនោះរមែងដឹងយ៉ាងនេះថា អាត្មាអញមានចិត្តដែលបរិយុដ្ឋានកិលេសណាគ្របសង្កត់ហើយ មិនបានដឹងច្បាស់ មិនបានឃើញច្បាស់ តាមសភាវៈពិត បរិយុដ្ឋានកិលេសដែលតាំងនៅក្នុងសន្តាននោះ ដែលថា អាត្មាអញមិនទាន់លះបង់បាន មិនមានឡើយ ចិត្តរបស់អាត្មាអញបានតម្កល់ទុកប្រពៃហើយ ដើម្បីត្រាស់ដឹងនូវអរិយសច្ចធម៌ទាំងឡាយ ។ នេះជាញាណទី ១ ដែលភិក្ខុនោះបានត្រាស់ដឹងហើយ ជាញាណដ៏ប្រសើរ ជាលោកុត្តរៈ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

[១៨៤] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត អរិយសាវ័ករមែងពិចារណាដូច្នេះថា អាត្មាអញកាលសេព កាលចម្រើន កាលធ្វើរឿយ ៗ នូវទិដ្ឋិនេះឯង តើបាននូវសេចក្តីស្ងប់រម្ងាប់ ក្នុងចិត្តរបស់ខ្លួន បាននូវការរំលត់កិលេស ក្នុងចិត្តរបស់ខ្លួន ឬហ្ន៎ ។ អរិយសាវ័កនោះរមែងដឹងយ៉ាងនេះថា អាត្មាអញកាលសេព កាលចម្រើន កាលធ្វើរឿយ ៗ នូវទិដ្ឋិនេះឯង តែងបាននូវសេចក្តីស្ងប់រម្ងាប់ ក្នុងចិត្តរបស់ខ្លួន បាននូវការរំលត់កិលេស ក្នុងចិត្តរបស់ខ្លួន ។ នេះជាញាណទី ២ ដែលភិក្ខុនោះបានត្រាស់ដឹងហើយ ជាញាណដ៏ប្រសើរ ជាលោកុត្តរៈ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

[១៨៥] បុន ចបរំ ភិក្ខវេ អរិយស្សាវកោ ឥតិ បដិសញ្ចិក្ខតិ យថារូបាយាហំ ទិដ្ឋិយា សមន្នាគតោ អត្ថិ នុខោ ឥតោ ពហិទ្ធា អញ្ញោ សមណោ វា ព្រាហ្មណោ វា តថារូបាយ ទិដ្ឋិយា សមន្នាគតោតិ ។ សោ ឯវំ បជានាតិ យថារូបាយាហំ ទិដ្ឋិយា សមន្នាគតោ នត្ថិ ឥតោ ពហិទ្ធា អញ្ញោ សមណោ វា ព្រាហ្មណោ វា តថារូបាយ ទិដ្ឋិយា សមន្នាគតោតិ ។ ឥទមស្ស តតិយំ ញាណំ អធិគតំ ហោតិ អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ ។

[១៨៦] បុន ចបរំ ភិក្ខវេ អរិយស្សាវកោ ឥតិ បដិសញ្ចិក្ខតិ យថារូបាយ ធម្មតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ អហម្បិ តថារូបាយ ធម្មតាយ សមន្នាគតោតិ ។ កថំរូបាយ ច ភិក្ខវេ ធម្មតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ ធម្មតា ឯសា ភិក្ខវេ ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស

ចូឡយមកវគ្គ កោសម្ពិយសូត្រ ញាណ ទី ៣ និង ទី ៤ ក្នុងអង្គ ៧

[១៨៥] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត អរិយសាវ័ករមែង ពិចារណាដូច្នេះថា អាត្មាអញប្រកបដោយទិដ្ឋិ មានសភាពយ៉ាងណា សមណៈនិងព្រាហ្មណ៍ដទៃក្រៅអំពីនេះ ដែលប្រកបដោយទិដ្ឋិមានសភាព យ៉ាងនោះដែរ តើមានឬហ្ន៎ ។ អរិយសាវ័កនោះ ក៏ដឹងយ៉ាងនេះថា អាត្មាអញប្រកបដោយទិដ្ឋិមានសភាពយ៉ាងណា សមណៈនិងព្រាហ្មណ៍ ដទៃក្រៅអំពីនេះ ដែលប្រកបដោយទិដ្ឋិ មានសភាពយ៉ាងនោះ មិន មានទេ ។ នេះជាញាណទី ៣ ដែលភិក្ខុនោះបានត្រាស់ដឹងហើយ ជា ញាណដ៏ប្រសើរ ជាលោកុត្តរៈ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

[១៨៦] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត អរិយសា-វ័ក រមែងពិចារណាដូច្នេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកប ដោយទិដ្ឋិតាមធម្មតា មានសភាពយ៉ាងណា អាត្មាអញក៏ប្រកបដោយ ទិដ្ឋិតាមធម្មតា មានសភាពយ៉ាងនោះដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ចុះ បុគ្គលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិ តាមធម្មតា មានសភាពដូច ម្តេច ម្នាលភិក្ខុទាំងឡាយ ធម្មតារបស់បុគ្គល ដែលបរិបូណ៌ដោយទិដ្ឋិ

កិញ្ចាបិ តថារូបឹ អាបត្តឹ អាបជ្ជតិ យថារូបាយ អាបត្តិយា វុដ្ឋានំ បញ្ញាយតិ អថខោ នំ ខិប្បមេវ សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ ទេសេតិ វិវរតិ ឧត្តានីករោតិ ទេសេត្វា វិវរិត្វា ឧត្តានីកត្វា អាយតឹ សំវរំ អាបជ្ជតិ ។ សេយ្យថាបិ ភិក្ខវេ ទហរោ កុមារោ មន្ទោ ឧត្តានសេយ្យកោ ហត្ថេន វា បាទេន វា អង្គារំ អក្កមិត្វា ខិប្បមេវ បដិសំហរតិ ឯវមេវ ខោ ភិក្ខវេ ធម្មតា ឯសា ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស កិញ្ចាបិ តថារូបឹ អាបត្តឹ អាបជ្ជតិ យថារូបាយ អាបត្តិយា វុដ្ឋានំ បញ្ញាយតិ អថខោ នំ ខិប្បមេវ សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ ទេសេតិ វិវរតិ ឧត្តានីករោតិ ទេសេត្វា វិវរិត្វា ឧត្តានីកត្វា អាយតឹ សំវរំ អាបជ្ជតិ ។ សោ ឯវំ បជានាតិ យថារូបាយ ធម្មតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ អហម្បិ តថារូបាយ ធម្មតាយ សមន្នាគតោតិ ។

ឥទមស្ស ចតុត្ថំ ញាណំ អធិគតំ ហោតិ អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ ។

គឺការចេញចាកអាបត្តិមានសភាពយ៉ាងណា ភិក្ខុក៏គង់ត្រូវអាបត្តិមានសភាពយ៉ាងនោះខ្លះដែរ តែថាភិក្ខុនោះរមែងសំដែង បើក ធ្វើឲ្យច្បាស់ឡើងនូវអាបត្តិនោះ ក្នុងសំណាក់សាស្តា ឬក្នុងពួកសព្រហ្មចារីបុគ្គលជាអ្នកប្រាជ្ញដោយឆាប់រហ័ស លុះសំដែង បើក ធ្វើឲ្យច្បាស់ឡើងហើយ ក៏ដល់នូវការសង្រួមតទៅ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាកុមារក្មេងជាកូនខ្ចីនៅដេកផ្ងារនៅឡើយ ប៉ះពាល់រងើកភ្លើងដោយដៃក្តី ដោយជើងក្តី ក៏ដកមកវិញជាប្រញាប់ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ធម្មតារបស់បុគ្គលដែលប្រកបដោយទិដ្ឋិ គឺការចេញចាកអាបត្តិមានសភាពយ៉ាងណា ភិក្ខុក៏គង់ត្រូវអាបត្តិមានសភាព យ៉ាងនោះខ្លះដែរ តែថាភិក្ខុនោះសំដែង បើក ធ្វើឲ្យច្បាស់ឡើងនូវអាបត្តិនោះក្នុងសំណាក់សាស្តា ឬក្នុងពួកសព្រហ្មចារីបុគ្គលជាអ្នកប្រាជ្ញដោយឆាប់រហ័ស លុះសំដែង បើក ធ្វើឲ្យច្បាស់ឡើងហើយក៏ដល់នូវកិរិយាសង្រួមតទៅ យ៉ាងនោះដែរ ។ ភិក្ខុនោះក៏ដឹងយ៉ាងនេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមធម្មតាមានសភាពយ៉ាងណា អាត្មាអញក៏ប្រកបដោយទិដ្ឋិតាមធម្មតាមានសភាពយ៉ាងនោះដែរ ។ នេះជាញាណទី ៤ ដែលភិក្ខុនោះបានត្រាស់ដឹងហើយ ជាញាណដ៏ប្រសើរ ជាលោកុត្តរៈ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

[១៨៧] បុន ចបរំ ភិក្ខវេ អរិយស្សាវកោ ឥតិ បដិសញ្ចិក្ខតិ យថារូបាយ ជម្មតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ អហម្បិ តថារូបាយ ជម្មតាយ សមន្នាគតោតិ ។ កថំរូបាយ ច ភិក្ខវេ ជម្មតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ ជម្មតា ឯសា ភិក្ខវេ ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស កិញ្ចាបិ យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ តត្ថ ឧស្សុក្កំ អាបន្នោ ហោតិ អថខ្វស្ស តិព្វាបេក្ខា ហោតិ អធិសីលសិក្ខាយ អធិចិត្តសិក្ខាយ អធិប្បញ្ញាសិក្ខាយ ។ សេយ្យថាបិ ភិក្ខវេ គាវី តរុណវច្ឆា ថព្ភញ្ច[១] អាលុម្បតិ វច្ឆកញ្ច អបចិនតិ[២] ឯវមេវ ខោ ភិក្ខវេ ជម្មតា ឯសា ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស កិញ្ចាបិ យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ តត្ថ ឧស្សុក្កំ អាបន្នោ ហោតិ អថខ្វស្ស តិព្វាបេក្ខា ហោតិ អធិសីលសិក្ខាយ អធិចិត្តសិក្ខាយ អធិប្បញ្ញាសិក្ខាយ ។ សោ ឯវំ បជានាតិ យថារូបាយ ជម្មតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ អហម្បិ

១ ឱ. ថម្ភញ្ច ។ ម. តថព្ភញ្ច ។ ២ ឱ. អបវីណាតិ ។ ម. អបប្បវីនតិ ។

ចូឡយមកវគ្គ កោសម្ពិយសូត្រ ញាណ ទី ៥ ក្នុងអង្គ ៧

[១៨៧] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត អរិយសាវ័ករមែងពិចារណាដូច្នេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមធម្មតា មានសភាពយ៉ាងណា អាត្មាអញក៏ប្រកបដោយទិដ្ឋិតាមធម្មតាមានសភាពយ៉ាងនោះដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមធម្មតាមានសភាពដូចម្តេច ម្នាលភិក្ខុទាំងឡាយ ធម្មតារបស់បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិនេះ គង់មានសេចក្តីខ្វល់ខ្វាយធ្វើការងារអ្វី ៗ ខ្ពស់និងទាបរបស់ពួកសព្រហ្មចារីបុគ្គលខ្វះដែរ តែថាគេមានសេចក្តីប្រាថ្នាក្លៀវក្លាក្នុងអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ ដូចជាមេគោមានកូនខ្ចី ខំប្រឹងស៊ីស្មៅផង ថ្មិតថ្មមកូនផង យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ធម្មតារបស់បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិនេះ គង់មានសេចក្តីខ្វល់ខ្វាយ ធ្វើការងារអ្វី ៗ ខ្ពស់និងទាបរបស់ពួកសព្រហ្មចារីបុគ្គលខ្វះដែរ តែថាគេមានសេចក្តីប្រាថ្នាក៏ក្លៀវក្លា ក្នុងអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខាក៏យ៉ាងនោះដែរ ។ ភិក្ខុនោះរមែងដឹងយ៉ាងនេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមធម្មតា មានសភាពយ៉ាងណា អាត្មាអញ

តថារូបាយ ធម្មតាយ សមន្នាគតោតិ ។ ឥទមស្ស បឋមំ ញាណំ អធិគតំ ហោតិ អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ ។

[១៨៨] បុន ចបរំ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យថារូបាយ ពលតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ អហម្បិ តថារូបាយ ពលតាយ សមន្នាគតោតិ ។ កាថំរូបាយ ច ភិក្ខវេ ពលតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ ពលតា ឯសា ភិក្ខវេ ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស យំ តថាគតប្បវេទិតេ ធម្មវិនយេ ទេសិយមានេ អដ្ឋិកត្វា មនសិកត្វា សព្វចេតសោ សមន្នាហរិត្វា ឱហិតសោតោ ធម្មំ សុណាតិ ។ សោ ឯវំ បជានាតិ យថារូបាយ ពលតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ អហម្បិ តថារូបាយ ពលតាយ សមន្នាគតោតិ ។ ឥទមស្ស ឆដ្ឋំ ញាណំ អធិគតំ ហោតិ អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ ។

ក៏ប្រកបដោយទិដ្ឋិ តាមធម្មតា មានសភាពយ៉ាងនោះដែរ ។ នេះជាញាណទី ៥ ដែលភិក្ខុនោះបានត្រាស់ដឹងហើយ ជាញាណដ៏ប្រសើរ ជាលោកុត្តរៈ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

[១៨៨] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត អរិយសាវ័ករមែងពិចារណាដូច្នេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាពយ៉ាងណា អាត្មាអញក៏ប្រកបដោយទិដ្ឋិតាមកម្លាំងមានសភាពយ៉ាងនោះដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមកម្លាំងមានសភាពដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភាពនៃបុគ្គលដែលបរិបូណ៌ដោយទិដ្ឋិមានកម្លាំងនុ៎ះ តែងត្រូវការយកចិត្តទុកដាក់ចំពោះអ្នកសំដែងធម៌វិន័យ ដែលតថាគតបានសំដែងទុកមក ហើយប្រមូលចិត្តមកឲ្យមូល ផ្ទៀងត្រចៀកប្រុងស្តាប់ធម៌ (នោះ) ។ ភិក្ខុនោះរមែងដឹងយ៉ាងនេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាពយ៉ាងណា អាត្មាអញក៏ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាពយ៉ាងនោះដែរ ។ នេះជាញាណទី ៦ ដែលភិក្ខុនោះបានត្រាស់ដឹងហើយ ជាញាណដ៏ប្រសើរ ជាលោកុត្តរៈ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

ចូឡយមកវគ្គស្ស កោសម្ពិយសុត្តេ សត្តង្គេសុ សត្តមញ្ញាណំ

[១៨៩] បុន ចបរំ ភិក្ខវេ អរិយស្សាវកោ ឥតិ បដិសញ្ចិក្ខតិ យថារូបាយ ពលតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ អហម្បិ តថារូបាយ ពល-តាយ សមន្នាគតោតិ ។ កាចំរូបាយ ច ភិក្ខវេ ពលតាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ ពលតា ឯសា ភិក្ខវេ ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស យំ តថាគតប្បវេទិតេ ធម្មវិនយេ ទេសិយមានេ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ ។ សោ ឯវំ បជានាតិ យថារូបាយ ពល-តាយ ទិដ្ឋិសម្បន្នោ បុគ្គលោ សមន្នាគតោ អហម្បិ តថារូបាយ ពលតាយ សមន្នាគតោតិ ។ ឥធមស្ស សត្តមំ ញាណំ អធិគតំ ហោតិ អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ ។

ចូឡយមកវគ្គ កោសម្ពិយសូត្រ ញាណទី ៧ ក្នុងអង្គ ៧

[១៨៩] ម្នាលភិក្ខុទាំងឡាយ ប្រការមួយវិញទៀត អរិយសាវ័ក រមែងពិចារណា ដូច្នេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាពយ៉ាងណា អាត្មាអញក៏ប្រកបដោយទិដ្ឋិតាមកម្លាំងមានសភាពយ៉ាងនោះដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមកម្លាំងមានសភាពដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភាពនៃបុគ្គលដែលបរិបូណ៌ដោយទិដ្ឋិមានកម្លាំងនោះ រមែងបានអត្ថវេទ បានធម្មវេទ និងបាមោជ្ជៈ ដែលប្រកបដោយធម៌ ចំពោះអ្នកសំដែងធម្មវិន័យ ដែលតថាគតបានសំដែងទុកមក ។ ភិក្ខុនោះរមែងដឹងយ៉ាងនេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមកម្លាំងមានសភាពយ៉ាងណា អាត្មាអញក៏ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាពដូច្នោះដែរ ។ នេះជាញាណទី ៧ ដែលភិក្ខុនោះបានត្រាស់ដឹងហើយ ជាញាណដ៏ប្រសើរ ជាលោកុត្តរៈ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

[១៩០] ឯវំ សត្តង្គសមន្នាគតស្ស ខោ ភិក្ខវេ អរិយសាវកស្ស ធម្មតា សុសមន្និដ្ឋា ហោតិ សោ-តាបត្តិផលសច្ឆិកិរិយាយ ។ ឯវំ សត្តង្គសមន្នាគតោ ខោ ភិក្ខវេ អរិយសាវកោ សោតាបត្តិផលសមន្នា-គតោ ហោតីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

កោសម្ពិយសុត្តំ អដ្ឋមំ និដ្ឋិតំ ។

[១៩០] ម្នាលភិក្ខុទាំងឡាយ ធម្មតានៃអរិយសាវ័កដែលប្រកបដោយអង្គទាំង ៧ ប្រការយ៉ាងនេះ សម្រេចល្អហើយ ក្នុងការធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កដែលប្រកបដោយអង្គទាំង ៧ ប្រការយ៉ាងនេះ ឈ្មោះថាជាអ្នកប្រកបដោយសោតាបត្តិផល ។ លុះព្រះមានព្រះភាគ បានត្រាស់ភាសិតនេះចប់ហើយ ពួកភិក្ខុទាំងនោះក៏មានសេចក្តីពេញចិត្ត ត្រេកអរនឹងភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ កោសម្ពិយសូត្រ ទី ៨ ។

# នវមំ ព្រហ្មនិមន្តនិកសុត្តំ

[១៩១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[១៩២] ភគវា ឯតទវោច ឯកមិទាហំ ភិក្ខវេ សមយំ ឧក្កដ្ឋាយំ វិហរាមិ សុភគវនេ សាលរាជមូលេ ។ តេន ខោ បន ភិក្ខវេ សមយេន ពកស្ស ព្រហ្មុនោ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ ឥទំ និច្ចំ ឥទំ ធុវំ ឥទំ សស្សតំ ឥទំ កេវលំ ឥទំ អចវនធម្មំ ឥទំ ហិ ន ជាយតិ ន ជីយតិ ន មីយតិ ន ចវតិ ន ឧបបជ្ជតិ ឥតោ ច បនញ្ញំ ឧត្តរឹ និស្សរណំ នត្ថីតិ ។

# ព្រហ្មនិមន្តនិកសូត្រ ទី ៩

[១៩១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំង-ឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះបានទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។

[១៩២] ព្រះមានព្រះភាគ បានត្រាស់ភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ សម័យមួយ តថាគតនៅក្នុងសុភគវ័ននេះ ទៀបគល់សាល-រាជព្រឹក្ស នាដែនឧក្កដ្ឋា ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង ទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះ កើតឡើងដល់ព្រហ្មឈ្មោះពកៈថា ឋានព្រហ្មនេះជារបស់ទៀង ជារបស់ឋិតថេរ ជារបស់មាននៅគ្រប់កាល ជារបស់មិនផ្ទុះផ្ទាយ ជារបស់មិនឃ្លៀងឃ្លាត ព្រោះថាឋានព្រហ្មនេះមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនកើតឡើង ឯឋានដទៃ ជាទីរលាស់ខ្លួនចេញចាកទុក្ខ ឲ្យក្រៃលែងជាងឋានព្រហ្មនេះ មិនមានឡើយ ។

អថខ្វាហំ ភិក្ខវេ ពកស្ស ព្រហ្មុនោ ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ឧក្កដ្ឋាយំ សុភគវនេ សាលរាជមូលេ អន្តរហិតោ តស្មឹ ព្រហ្មលោកេ បាតុរហោសឹ ។ អទ្ទសា ខោ មំ ភិក្ខវេ ពកោ ព្រហ្មា ទូរតោវ អាគច្ឆន្តំ ទិស្វាន មំ ឯតទវោច ឯហិ ខោ មារិស ស្វាគតំ មារិស ចិរស្សំ ខោ មារិស ឥមំ បរិយាយមកាសិ យទិទំ ឥធាគមនាយ ឥទំ ហិ មារិស និច្ចំ ឥទំ ធុវំ ឥទំ សស្សតំ ឥទំ កេវលំ ឥទំ អចវនធម្មំ ឥទំ ហិ ន ជាយតិ ន ជីយតិ ន មីយតិ ន ចវតិ ន ឧបបជ្ជតិ ឥតោ ច បនញ្ញំ ឧត្តរឹ និស្សរណំ នត្ថីតិ ។ ឯវំ វុត្តេ អហំ ភិក្ខវេ ពកំ ព្រហ្មានំ ឯតទវោចំ អវិជ្ជាគតោ វត ភោ ពកោ ព្រហ្មា អវិជ្ជាគតោ វត ភោ ពកោ

ម្នាលភិក្ខុទាំងឡាយ គ្រានោះ តថាគតបានដឹងនូវសេចក្តីត្រិះរិះ ក្នុងចិត្តរបស់ពកព្រហ្ម ដោយចិត្តរបស់តថាគត ហើយក៏បាត់អំពីសុភគវ័នទៀបគល់សាលពជព្រឹក្សក្នុងក្រុងឧក្កដ្ឋា ទៅប្រាកដក្នុងព្រហ្មលោកនោះ ដូចជាបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ដៃដែលលាចេញដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ ពកព្រហ្មបានឃើញតថាគតកំពុងមកអំពីចម្ងាយ លុះឃើញហើយទើបក្រាបបង្គំទូលតថាគត យ៉ាងនេះថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ សូមព្រះអង្គទ្រង់ស្តេចចូលមក បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ដំណើរដែលព្រះអង្គស្តេចមកនេះ ប្រពៃហើយ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះអង្គខានធ្វើដំណើរនិមន្តមកក្នុងទីនេះ អស់កាលជាយូរអង្វែងណាស់ហើយ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ធម្មតាឋានព្រហ្មនេះ ជាទីទៀង ជាទីឋិតថេរមាននៅសព្វកាល មិនធ្លុះធ្លាយ មិនឃ្លៀងឃ្លាត ព្រោះថាឋានព្រហ្មនេះ រមែងមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនកើតឡើងទៀតទេ ឯឋានដទៃ ជាទីរលាស់ខ្លួនចេញចាកទុក្ខ ឲ្យក្រៃលែងជាងស្ថានព្រហ្មនេះ មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលពកព្រហ្ម ពោលយ៉ាងនេះហើយ តថាគតបានពោលនឹងពកព្រហ្មយ៉ាងនេះថា អើហ្ន៎ ពក-ព្រហ្មប្រកបដោយអវិជ្ជាទេតើ អើហ្ន៎ ពកព្រហ្មប្រកបដោយអវិជ្ជាទេតើ

ព្រហ្មា យត្រ ហិ នាម អនិច្ចំយេវ សមានំ និច្ចន្តិ វក្ខតិ អធុវំយេវ សមានំ ធុវន្តិ វក្ខតិ អសស្សតំ-យេវ សមានំ សស្សតន្តិ វក្ខតិ អកេវលំយេវ សមានំ កេវលន្តិ វក្ខតិ ចវនធម្មំយេវ សមានំ អចវនធម្មន្តិ វក្ខតិ យត្ថ ច បន ជាយតិ ច ជីយតិ ច មីយតិ ច ចវតិ ច ឧបបជ្ជតិ ច តំ តថា វក្ខតិ ឥទំ ហិ ន ជាយតិ ន ជីយតិ ន មីយតិ ន ចវតិ ន ឧបបជ្ជតីតិ សន្តញ្ច បនញ្ញំ ឧត្តរឹ និស្សរណំ នត្ថញ្ញំ ឧត្តរឹ និស្សរណន្តិ វក្ខតីតិ ។

[១៩៣] អថខោ ភិក្ខវេ មារោ បាបិមា អញ្ញតរំ ព្រហ្មបារិសជ្ជំ អន្វាវិសិត្វា មំ ឯតទវោច ភិក្ខុ ភិក្ខុ មេតមាសទោ មេតមាសទោ ឯសោ ហិ ភិក្ខុ ព្រហ្មា មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុ ទសោ វសវត្តី ឥស្សរោ កត្តា និម្មិតា សេដ្ឋោ សជ្ជិតា[១] វសី បិតា ភូតភព្យានំ ។ អហោសុំ ខោ ភិក្ខុ[២]

---

១ ឱ. សញ្ជិតា ។ ២ ម. យេ ភិក្ខូ ។

បានជាពោលនូវរបស់ដែលមិនទៀងទាត់ថាជារបស់ទៀងទាត់វិញ ពោលរបស់ដែលមិនឋិតថេរ ថាជារបស់ឋិតថេរវិញ ពោលរបស់គ្មាននៅគ្រប់កាល ថាជារបស់មាននៅគ្រប់កាលវិញ ពោលរបស់ដែលមិនផ្ទុះផ្ដាយ ថាជារបស់ផ្ទុះផ្ដាយវិញ ពោលរបស់ដែលឃ្លៀងឃ្លាតថាជារបស់មិនឃ្លៀងឃ្លាតវិញ មួយទៀត ពកព្រហ្មពោលចំពោះឋានព្រហ្មដែលនៅកើត នៅចាស់ នៅស្លាប់ នៅច្យុត នៅកើតទៀតថា ឋានព្រហ្មនេះមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនកើតឡើងវិញ ឯឋានដទៃ ជាទីរលាស់ខ្លួនចេញចាកទុក្ខ ឲ្យក្រៃលែងជាងឋានព្រហ្មនេះមិនមានឡើយ ។

[១៩៣] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មារមានចិត្តបាបចូលជ្រែកព្រហ្មមួយរូបឈ្មោះបារិសជ្ជៈ ហើយពោលពាក្យនេះនឹងតថាគតថា ម្នាលភិក្ខុ ភិក្ខុកុំបណ្ដោញព្រហ្មនេះឡើយ ភិក្ខុកុំបណ្ដោញព្រហ្មនេះឡើយ ម្នាលភិក្ខុ ព្រោះព្រហ្មនេះជាមហាព្រហ្ម ជាច្បង ឥតមានអ្នកដទៃគ្របសង្កត់បាន ជាអ្នកឃើញហេតុពិត ជាអ្នកធ្វើជនទាំងអស់ឲ្យលុះក្នុងអំណាចខ្លួនបាន ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក និមិត្តលោក ជាអ្នកប្រសើរ ជាអ្នកចាត់ចែងលោក ជាអ្នកស្ទាត់ជំនាញ ជាបិតារបស់ពួកសត្វដែលកើតហើយ និងសត្វដែលនៅក្នុងគភ៌ ។ ម្នាលភិក្ខុ

តយា បុព្វេ សមណព្រាហ្មណា លោកស្មឹ បឋវិគរហកា បឋវិជិគុច្ឆកា អាបគរហកា អាបជិគុច្ឆកា តេជគរហកា តេជជិគុច្ឆកា វាយគរហកា វាយជិគុច្ឆកា ភូតគរហកា ភូតជិគុច្ឆកា ទេវគរហកា ទេវជិគុច្ឆកា បជាបតិគរហកា បជាបតិជិគុច្ឆកា ព្រហ្មគរហកា ព្រហ្មជិគុច្ឆកា តេ កាយស្ស ភេទា ចាណុបច្ឆេទា ហីនេ កាយេ បតិដ្ឋិតា ។ អហោសុំ ខោ បន ភិក្ខុ[១] តយា បុព្វេ សមណព្រាហ្មណា លោកស្មឹ បឋវិបសំសកា បឋវាភិនន្ទិនោ អាបបសំសកា អាបាភិនន្ទិនោ តេជបសំសកា តេជាភិនន្ទិនោ វាយបសំសកា វាយាភិនន្ទិនោ ភូតបសំសកា ភូតាភិនន្ទិនោ ទេវបសំសកា ទេវាភិនន្ទិនោ បជាបតិបសំសកា បជាបតាភិនន្ទិនោ ព្រហ្មបសំសកា ព្រហ្មាភិនន្ទិនោ តេ កាយស្ស ភេទា ចាណុបច្ឆេទា បណីតេ កាយេ បតិដ្ឋិតោ ។ តិណ្ហាហំ[២] ភិក្ខុ ឯវំ វទាមិ

---

១ ម. យេ បន ភិក្ខូតិ ទិស្សតិ ។ ២ ឱ. ម. តន្ទាហំ ។

ក្នុងកាលមុនអំពីខ្លួនលោក មានពួកសមណព្រាហ្មណ៍ក្នុងលោកជាអ្នកតិះដៀលផែនដី[១] ខ្ពើមផែនដី តិះដៀលទឹក ខ្ពើមទឹក តិះដៀលភ្លើង ខ្ពើមភ្លើង តិះដៀលខ្យល់ ខ្ពើមខ្យល់ តិះដៀលពួកសត្វ ខ្ពើមពួកសត្វ តិះដៀលទេវតា ខ្ពើមទេវតា តិះដៀលបជាបតិទេវរាជ ខ្ពើមបជាបតិទេវរាជ តិះដៀលព្រហ្ម ខ្ពើមព្រហ្ម ពួកសមណព្រាហ្មណ៍ទាំងនោះ លុះទម្លាយកាយផ្តាច់បង់ជីវិតទៅ ក៏កើតក្នុងពួកដ៏ថោកទាប គឺអបាយភូមិ ៤ ។ ម្នាលភិក្ខុ មួយវិញទៀត ក្នុងកាលមុនអំពីខ្លួនលោក មានពួកសមណព្រាហ្មណ៍ក្នុងលោកជាអ្នកសរសើរផែនដី ត្រេកអរនឹងផែនដី សរសើរទឹក ត្រេកអរនឹងទឹក សរសើរភ្លើង ត្រេកអរនឹងភ្លើង សរសើរខ្យល់ ត្រេកអរនឹងខ្យល់ សរសើរពួកសត្វ ត្រេកអរនឹងពួកសត្វ សរសើរទេវតា ត្រេកអរនឹងទេវតា សរសើរបជាបតិទេវរាជ ត្រេកអរនឹងបជាបតិទេវរាជ សរសើរព្រហ្ម ត្រេកអរនឹងព្រហ្ម ពួកសមណព្រាហ្មណ៍ទាំងនោះ លុះទម្លាយកាយ ផ្តាច់បង់ជីវិតទៅ ក៏កើតក្នុងពួកដ៏ប្រសើរ គឺព្រហ្មលោក ។ ម្នាលភិក្ខុ ព្រោះហេតុនោះ ខ្ញុំសូមនិយាយនឹងលោកយ៉ាងនេះ

---

១ អដ្ឋកថា ថា តិះដៀលផែនដីថា អនិច្ចំ ទុក្ខំ អនត្តា ។

ឥច្ឆ ត្វំ មារិស យទេវ តេ ព្រហ្មា អាហ តទេវ ត្វំ ករោហិ មា ត្វំ ព្រហ្មុនោ វចនំ ឧបាតិវត្តិត្ថោ សចេ ខោ ត្វំ ភិក្ខុ ព្រហ្មុនោ វចនំ ឧបាតិវត្តិស្សសិ ។ សេយ្យថាបិ នាម បុរិសោ សិរឹ អាគច្ឆន្តឹ ទណ្ឌេន បដិប្បណាមេយ្យ សេយ្យថាបិ វា បន ភិក្ខុ បុរិសោ នរកប្បបាតេ បបតន្តោ ហត្ថេហិ ច បាទេហិ ច បឋវឹ វិរាធេយ្យ[១] ឯវំ សម្បទមិទំ ភិក្ខុ តុយ្ហំ ភវិស្សតិ ។ ឥច្ឆ ត្វំ មារិស យទេវ តេ ព្រហ្មា អាហ តទេវ ត្វំ ករោហិ មា ត្វំ ព្រហ្មុនោ វចនំ ឧបាតិវត្តិត្ថោ ននុ ត្វំ ភិក្ខុ បស្សសិ ព្រហ្មបរិសំ[២] សន្និសិន្នន្តិ ។ ឥតិ ខោ មំ ភិក្ខវេ មារោ បាបិមា ព្រហ្មបរិសំ ឧបនេសិ ។ ឯវំ វុត្តេ អហំ ភិក្ខវេ មារំ បាបិមន្តំ ឯតទវោចំ ជានាមិ ខោ តាហំ បាបិម មា ត្វំ មញ្ញិត្ថោ ន មំ ជានាតីតិ មារោ ត្វមសិ បាបិម យោ ចេវ បាបិម ព្រហ្មា យា ច ព្រហ្មបរិសា យេ ច ព្រហ្មបារិសជ្ជា សព្វេវ

---

១ ឱ. ម. វិរាគេយ្យ ។ ២ ឱ. ព្រហ្មឹ បរិសំ ។ ៣ ម. យា ។

បពិត្រលោកអ្នកនិទ៌ុក្ខ ខ្ញុំសូមដាស់តឿនលោក ចូរលោកធ្វើតាមពាក្យព្រហ្មដែលបាននិយាយហើយដល់លោក លោកកុំកន្លងពាក្យរបស់ព្រហ្មឡើយ ម្នាលភិក្ខុ ប្រសិនបើលោកកន្លងពាក្យរបស់ព្រហ្មហើយ ។ ដូចជាបុរសយកដំបងវាយបណ្តេញនូវសិរីដែលកំពុងមកដល់ យ៉ាងណា ម្នាលភិក្ខុ ពុំនោះសោត ដូចជាបុរសធ្លាក់ក្នុងអណ្តូងធំជ្រៅ មិនអាចនឹងចាប់ផែនដីដោយដៃនិងជើងទាំងឡាយបាន យ៉ាងណា ម្នាលភិក្ខុ សេចក្តីឧបមេយ្យនេះនឹងមានដល់លោក ក៏យ៉ាងនោះដែរ ។ បពិត្រលោកអ្នកនិទ៌ុក្ខ ខ្ញុំសូមដាស់តឿនលោក ចូរលោកធ្វើតាមពាក្យព្រហ្មដែលបាននិយាយហើយដល់លោក ចូរលោកកុំកន្លងពាក្យរបស់ព្រហ្មឡើយ ម្នាលភិក្ខុ ក្រែងលោកឃើញព្រហ្មបរិស័ទកំពុងប្រជុំគ្នាដែរឬទេ ។ ម្នាលភិក្ខុទាំងឡាយ មារមានចិត្តបាបបានបង្អោនតថាគតឲ្យដូចជាព្រហ្មបរិស័ទដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលមារនិយាយយ៉ាងនេះហើយ តថាគតបានពោលនឹងមារមានចិត្តបាបយ៉ាងនេះវិញថា ម្នាលមារមានចិត្តបាប តថាគតស្គាល់អ្នកច្បាស់ហើយ អ្នកកុំមើលងាយថា ឥតមានអ្នកណាមួយស្គាល់អញដូច្នេះឡើយ ម្នាលមារមានចិត្តបាប អ្នកហ្នឹងហើយជាមារ ម្នាលមារមានចិត្តបាប ព្រហ្មណាក៏ដោយ ព្រហ្ម-បរិស័ទណាក៏ដោយ ព្រហ្មបារិសជ្ជាណាក៏ដោយ អ្នកទាំងអស់នោះ

តវ ហត្ថគតា សព្វេ តវ វសង្គតា តុយ្ហំ ហិ បាបិម ឯវំ ហោតិ ឯសោបិ មេ អស្ស ហត្ថគតោ ឯសោបិ មេ អស្ស វសង្គតោតិ អហំ ខោ បន បាបិម នេវ តវ ហត្ថគតោ នេវ តវ វសង្គតោតិ ។

[១៩៤] ឯវំ វុត្តេ ភិក្ខវេ ពកោ ព្រហ្មា[១] ឯតទវោច អហំ ហិ មារិស និច្ចំយេវ សមានំ និច្ចន្តិ វទាមិ ធុវំយេវ សមានំ ធុវន្តិ វទាមិ សស្សតំយេវ សមានំ សស្សតន្តិ វទាមិ កេវលំយេវ សមានំ កេវលន្តិ វទាមិ អចវនធម្មំយេវ សមានំ អចវនធម្មន្តិ វទាមិ ។ យត្ថ ច បន ន ជាយតិ ន ជីយតិ ន មីយតិ ន ចវតិ ន ឧបបជ្ជតិ តទេវាហំ វទាមិ ឥទំ ហិ ន ជាយតិ ន ជីយតិ ន មីយតិ ន ចវតិ ន ឧបបជ្ជតិ អសន្តញ្ច បនញ្ញំ ឧត្តរឹ និស្សរណំ នត្ថញ្ញំ ឧត្តរឹ និស្សរណន្តិ វទាមិ ។ អហោសុំ ខោ ភិក្ខុ

១ ឱ. ម. ឯត្ថន្តរេ មន្តិ ទិស្សតិ ។

សុទ្ធតែលុះក្នុងកណ្តាប់ដៃរបស់អ្នក អ្នកទាំងអស់នោះ សុទ្ធតែលុះក្នុងអំណាចរបស់អ្នក ម្នាលមារមានចិត្តបាប ព្រោះហេតុនោះ បានជាអ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះសមណគោតម គប្បីលុះក្នុងកណ្តាប់ដៃរបស់អញ ព្រះសមណគោតម គប្បីលុះក្នុងអំណាចរបស់អញ ម្នាលមារមានចិត្តបាប ឯតថាគតមិនលុះក្នុងកណ្តាប់ដៃរបស់អ្នកទេ មិនលុះក្នុងអំណាចរបស់អ្នកទេ ។

[១៩៤] ម្នាលភិក្ខុទាំងឡាយ កាលតថាគត ពោលយ៉ាងនេះហើយ ពកព្រហ្មបានពោលនូវពាក្យនេះថា បពិត្រព្រះអង្គ អ្នកនិទ៌ុក្ខ ខ្ញុំព្រះអង្គពោលរបស់ដែលទៀង ថាជារបស់ទៀងពិត ពោលរបស់ដែលឋិតថេរ ថាជារបស់ឋិតថេរពិត ពោលរបស់ដែលមាននៅសព្វកាល ថាជារបស់មាននៅសព្វកាលពិត ពោលរបស់ដែលដាច់ដុះឆ្ងាយ ថាជារបស់ដាច់ដុះឆ្ងាយពិត ពោលរបស់ដែលមិនឃ្លៀងឃ្លាត ថាជារបស់មិនឃ្លៀងឃ្លាតពិត ។ មួយវិញទៀត ទីណាមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនកើតឡើង ខ្ញុំព្រះអង្គពោលទីនោះឯង ថាទីនេះមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនកើតឡើង មួយវិញទៀត ឋានដទៃ ជាទីរលាស់ខ្លួនចេញចាកទុក្ខឲ្យក្រៃលែងមិនមាន បានជាខ្ញុំព្រះអង្គពោលថា ឋានដទៃ ជាទីរលាស់ខ្លួនចេញចាកទុក្ខឲ្យក្រៃលែងមិនមាន ។ ម្នាលភិក្ខុ

៣៦៧



តយា បុព្វេ សមណព្រាហ្មណា លោកស្មឹ យាវតកំ តុយ្ហំ កសិណំ អាយុំ(១) តាវតកំ តេ(២) តបោកម្មមេវ អហោសិ ។ តេ ខោ ឯវំ ជានេយ្យុំ សន្តំ វា អញ្ញំ ឧត្តរឹ និស្សរណំ អត្ថញ្ញំ ឧត្តរឹ និស្សរណន្តិ អសន្តំ វា អញ្ញំ ឧត្តរឹ និស្សរណំ នត្ថញ្ញំ ឧត្តរឹ និស្សរណន្តិ ។ តិន្តាហំ(៣) ភិក្ខុ ឯវំ វទាមិ ន ចេវញ្ញំ ឧត្តរឹ និស្សរណំ ទក្ខិស្សសិ យាវទេវ ច បន កិលមថស្ស វិឃាតស្ស ភាគី ភវិស្សសិ ។ សចេ ខោ ត្វំ ភិក្ខុ បឋវឹ អជ្ឈោសិស្សសិ ឱបសាយិកោ មេ ភវិស្សសិ វត្ថុសាយិកោ យថាកាមករណីយោ ពាហិតេយ្យោ ។ សចេ បន(៤) អាបំ តេជំ វាយំ ភូតេ ទេវេ បជាបតឹ ព្រហ្មំ អជ្ឈោសិស្សសិ ឱបសាយិកោ មេ ភវិស្សសិ វត្ថុសាយិកោ យថាកាមករណីយោ ពាហិតេយ្យោតិ ។ អហម្បិ ខោ ឯតំ ព្រហ្មេ ជានាមិ ។ សចេ បឋវឹ អជ្ឈោសិស្សាមិ ឱបសាយិកោ តេ ភវិស្សាមិ វត្ថុសាយិកោ

១ ឱ. ម. អាយុ ។ ២ ឱ. ម. តេសំ ។ ៣ ឱ. ម. តន្តាហំ ។ ៤ ឱ. ម. បនាតិ ន ទិស្សតិ ។

កាលមុនខ្លួនអ្នកទៅទៀត មានពួកសមណព្រាហ្មណ៍ក្នុងលោក មានតបៈ-កម្មប្រហែលនឹងអាយុទាំងអស់របស់អ្នក ។ ពួកសមណព្រាហ្មណ៍នោះដឹងយ៉ាងនេះថា ឋានដទៃជាទីរលាស់ខ្លួនចេញចាកទុក្ខតទៅទៀត មាន ឋានដទៃជាទីរលាស់ខ្លួនចេញចាកទុក្ខតទៅទៀត មាន ថាឋានដទៃជាទីរលាស់ខ្លួនចេញចាកទុក្ខតទៅទៀតមិនមាន ឋានដទៃជាទីរលាស់ខ្លួនចេញចាកទុក្ខតទៅទៀតមិនមាន ។ ម្នាលភិក្ខុ ព្រោះហេតុនោះ បានជាខ្ញុំនិយាយនឹងលោកយ៉ាងនេះ លោកមិនឃើញនូវឋានដទៃជាទីរលាស់ខ្លួនចេញចាកទុក្ខតទៅទៀតទេ លោកជាអ្នកមានចំណែកនៃសេចក្តីលំបាក និងសេចក្តីចង្អៀតចង្អល់តែមួយយ៉ាង ។ ម្នាលភិក្ខុ ប្រសិនបើលោកប្រកាន់ផែនដី ឈ្មោះថាដេកនៅក្បែរខ្ញុំ ឈ្មោះថាដេកត្រាំនៅក្នុងវត្ថុរបស់ខ្ញុំ ខ្ញុំនឹងធ្វើលោកតាមសេចក្តីប្រាថ្នារបស់ខ្ញុំ ឲ្យលោកជាមនុស្សថោកទាបក៏បាន ។ មួយវិញទៀត ប្រសិនបើលោកប្រកាន់ទឹក ភ្លើង ខ្យល់ ពពួកសត្វ ទេវតា បជាបតិទេវរាជ ព្រហ្ម ឈ្មោះថាដេកនៅក្បែរខ្ញុំ ឈ្មោះថាដេកត្រាំក្នុងវត្ថុរបស់ខ្ញុំ ខ្ញុំនឹងធ្វើលោកតាមសេចក្តីប្រាថ្នារបស់ខ្ញុំ ឲ្យលោកជាមនុស្សថោកទាបក៏បាន ។ ម្នាលព្រហ្ម តថាគតក៏ដឹងហេតុនេះដែរ ។ ប្រសិនបើតថាគតប្រកាន់ផែនដី ឈ្មោះថាដេកនៅក្បែរអ្នក ឈ្មោះថាដេកត្រាំក្នុង

យថាកាមករណីយោ ពាហិតេយ្យោ ។ សចេ បន[១] អាបំ តេជំ វាយំ ភូតេ ទេវេ បជាបតឹ ព្រហ្មំ អជ្ឈោសិស្សាមិ ឱបសាយិកោ តេ ភវិស្សាមិ វត្ថុសាយិកោ យថាកាមករណីយោ ពាហិតេយ្យោ ។ អបិច តេ អហំ ព្រហ្មេ គតិញ្ច បជានាមិ ជុតិញ្ច បជានាមិ ឯវំមហិទ្ធិកោ ពកោ ព្រហ្មា ឯវំមហានុភាវោ ពកោ ព្រហ្មា ឯវំមហេសក្ខោ ពកោ ព្រហ្មាតិ ។ យថាកថំ បន មេ ត្វំ មារិស គតិញ្ច បជានាសិ ជុតិញ្ច បជានាសិ ឯវំមហិទ្ធិកោ ពកោ ព្រហ្មា ឯវំមហានុភាវោ ពកោ ព្រហ្មា ឯវំមហេសក្ខោ ពកោ ព្រហ្មាតិ ។

យាវតា ចន្ទិមសុរិយា បរិហរន្តិ
ទិសា ភន្តិ វិរោចនា[២]
តាវ សហស្សធា លោកោ
ឯត្ថ តេ វត្តតី[៣] វសោ

១ ឱ. ម. បនាតិ ន ទិស្សតិ ។ ២ ម. វិរោចមានា ។ ៣ ម. វត្តតេ ។

វត្ថុរបស់អ្នក អ្នកគួរនឹងធ្វើតថាគតតាមសេចក្តីប្រាថ្នារបស់អ្នក ឲ្យតថាគតជាមនុស្សថោកទាបបានមែន ។ មួយវិញទៀត ប្រសិនបើតថាគតប្រកាន់ទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា បជាបតិទេវរាជ ព្រហ្ម ឈ្មោះថាដេកនៅក្បែរអ្នក ឈ្មោះថាដេកត្រាំក្នុងវត្ថុរបស់អ្នក អ្នកគួរនឹងធ្វើតថាគតតាមសេចក្តីប្រាថ្នា ឲ្យតថាគតជាមនុស្សថោកទាប បានមែន ។ ម្នាលព្រហ្ម ប៉ុន្តែតថាគតស្គាល់គតិរបស់អ្នក ស្គាល់អានុភាពរបស់អ្នកហើយថា ពកព្រហ្មមានឫទ្ធិច្រើនយ៉ាងនេះ ពកព្រហ្មមានអានុភាពច្រើនយ៉ាងនេះ ពកព្រហ្មមានស័ក្តិធំយ៉ាងនេះ ។ ពកព្រហ្មទូលសួរថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ចុះព្រះអង្គស្គាល់គតិរបស់ខ្ញុំ ស្គាល់អានុភាពរបស់ខ្ញុំថា ពកព្រហ្ម មានឫទ្ធិច្រើនយ៉ាងនេះ ពកព្រហ្ម មានអានុភាពច្រើនយ៉ាងនេះ ពកព្រហ្ម មានស័ក្តិធំយ៉ាងនេះ តើដោយប្រការដូចម្តេច ។

ព្រះអង្គត្រាស់ថា ព្រះចន្ទ្រនិងព្រះអាទិត្យទាំងឡាយដើរបំភ្លឺ
ទិសទាំងឡាយឲ្យភ្លឺបានត្រឹមណា លោកគឺចក្កវាឡទាំងមួយ
ពាន់ក៏កំណត់ត្រឹមនោះ អំណាចរបស់អ្នកប្រព្រឹត្តទៅបានតែ

បរោបរញ្ច ជានាសិ
អថោ ភគវិភគិនំ
ឥត្ថភាវញ្ញថាភាវំ
សត្តានំ អាគតឹ គតិន្តិ ។

ឯវំ ខោ តេ អហំ ព្រហ្មេ គតិញ្ច បជានាមិ ជុតិញ្ច បជានាមិ ឯវំមហិទ្ធិកោ ពកោ ព្រហ្មា ឯវំមហានុភាវោ ពកោ ព្រហ្មា ឯវំមហេសក្ខោ ពកោ ព្រហ្មាតិ ។ អត្ថិ ខោ ព្រហ្មេ អញ្ញោ តយោ កាយា(១) តត្ថ(២) ត្វំ ន ជានាសិ ន បស្សសិ ត្យាហំ(៣) ជានាមិ បស្សាមិ ។ អត្ថិ ខោ ព្រហ្មេ អាភស្សរា នាម កាយោ ។ យតោ(៤) ត្វំ ចុតោ ឥធូបបន្នោ តស្ស តេ អតិចិរនិវាសេន សា សតិ មុដ្ឋា តេន តំ ត្វំ ន ជានាសិ ន បស្សសិ តមហំ ជានាមិ បស្សាមិ ។ ឯវម្បិ ខោ អហំ ព្រហ្មេ នេវ តេ សមសមោ អភិញ្ញាយ

១ ម. អញ្ញោ កាយោតិ ទិស្សតិ ។ ២ ម. តំ ។ ៣ ម. តមហំ ។ ៤ ម. ឥតោ ។

ត្រឹមចក្កវាឡមួយពាន់ទុំះ មួយទៀត អ្នកស្គាល់ពួកសត្វ ថោកទាប និងពួកសត្វខ្ពង់ខ្ពស់ សត្វដែលប្រកបដោយរាគៈ និងសត្វដែលប្រាសចាករាគៈ ស្គាល់ចក្កវាឡនេះ ចក្រវាឡដទៃ ស្គាល់ដំណើរមក និងដំណើរទៅ របស់សត្វទាំង-ឡាយ ។

ម្នាលព្រហ្ម តថាគតស្គាល់គតិ ស្គាល់អានុភាពរបស់អ្នកយ៉ាងនេះ ថា ពកព្រហ្មមានឫទ្ធិច្រើនយ៉ាងនេះ ពកព្រហ្មមានអានុភាពច្រើន យ៉ាងនេះ ពកព្រហ្មមានស័ក្តិធំយ៉ាងនេះ ។ ម្នាលព្រហ្ម នៅមាន ព្រហ្ម ៣ ពួកដទៃទៀត អ្នកមិនដឹង មិនឃើញព្រហ្មទាំង ៣ ពួកនោះ ទេ តថាគតទើបដឹង ទើបឃើញព្រហ្មទាំង ៣ ពួកនោះបាន ។ ម្នាល ព្រហ្ម មានពួកព្រហ្មមួយ ឈ្មោះអាភស្សរៈ ។ ខ្លួនអ្នកច្យុតអំពីទីនោះ បានមកកើតក្នុងទីនេះ ស្មារតីរបស់អ្នកនោះក៏ភ្លេចបាត់ទៅ ដោយសារ នៅក្នុងទីនេះយូរពេក ព្រោះហេតុនោះបានជាអ្នកមិនដឹង មិនឃើញ អាភស្សរព្រហ្មនោះ តថាគតទើបដឹង ទើបឃើញព្រហ្មនោះបាន ។ ម្នាលព្រហ្ម យ៉ាងនេះឯង តថាគតមិនមែនស្មើនឹងអ្នកទេ តថាគតដឹង

កុតោ នីចេយ្យំ អថខោ អហមេវ តយា ភិយ្យោ ។ អត្ថិ ខោ ព្រហ្មេ សុភកិណ្ហា នាម កាយោ វេហប្ផលា នាម កាយោ[១] តំ ត្វំ ន ជានាសិ ន បស្សសិ តមហំ ជានាមិ បស្សាមិ ។ ឯវម្បិ ខោ អហំ ព្រហ្មេ នេវ តេ សមសមោ អភិញ្ញាយ កុតោ នីចេយ្យំ អថខោ អហមេវ តយា ភិយ្យោ ។ បឋវឹ ខោ អហំ ព្រហ្មេ បឋវិតោ អភិញ្ញាយ យាវតា បឋវិយា បឋវិត្តេន[២] អននុភូតំ តទភិញ្ញាយ បឋវី នាហោសឹ[៣] បឋវិយា នាហោសឹ បឋវិតោ នាហោសឹ បឋវី មេតិ នាហោសឹ បឋវឹ នាភិវទឹ ។ ឯវម្បិ ខោ អហំ ព្រហ្មេ នេវ តេ សមសមោ អភិញ្ញាយ កុតោ នីចេយ្យំ អថខោ អហមេវ តយា ភិយ្យោ ។ អាបំ ខោ អហំ ព្រហ្មេ ។ បេ ។ តេជំ ខោ អហំ ព្រហ្មេ...

---

១ ម. ឯត្ថន្តរេ អភិភូ នាម កាយោតិ ទិស្សតិ ។ ២ ឱ. ម. បឋវត្តេន ។ ៣ ឱ. នាហោសិ ។ ម. នាបហោសឹ ។

ច្បាស់ហើយ នឹងឲ្យថោកទាបជាងអ្នកដូចម្ដេចបាន តថាគតត្រូវតែប្រ-សើរជាងអ្នកដោយពិត ។ ម្នាលព្រហ្ម នៅមានពួកព្រហ្មឈ្មោះសុក-កិណ្ហ: និងពួកព្រហ្មឈ្មោះវេហប្ផល: អ្នកមិនដឹង មិនឃើញពួកព្រហ្មទាំងនោះទេ តថាគតទើបដឹង ទើបឃើញពួកព្រហ្មនោះបាន ។ ម្នាលព្រហ្ម យ៉ាងនេះឯង តថាគតមិនមែនស្មើនឹងអ្នកទេ តថាគតដឹងហើយ នឹងឲ្យថោកទាបជាងអ្នកដូចម្ដេចបាន តថាគតត្រូវតែប្រសើរជាងអ្នកដោយពិត ។ ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវផែនដី ថាជាផែនដីពិត ដឹងច្បាស់នូវព្រះនិព្វានដែលសត្វមិនធ្លាប់ដល់ដោយសភាពនៃផែនដីពិត បានជាតថាគតមិនប្រកាន់នូវផែនដី មិនប្រកាន់ក្នុងផែនដី មិនប្រកាន់អំពីផែនដី មិនប្រកាន់ថាផែនដីរបស់តថាគត មិនប្រកាសផែនដី ។ ម្នាលព្រហ្ម កាលបើយ៉ាងនេះ តថាគតមិនមែនជាបុគ្គលស្មើនឹងអ្នកទេ តថាគតត្រាស់ដឹងហើយ នឹងឲ្យថោកទាបជាងអ្នកដូចម្ដេចបាន តថាគតត្រូវតែប្រសើរជាងអ្នកដោយពិត ។ ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវទឹក ។ បេ ។ ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវភ្លើង...

៣៧១

ចូឡយមកវគ្គស្ស ព្រហ្មនិមន្តនិកសុត្តេ ពកស្ស ទិដ្ឋិវិវេចនំ

វាយំ ខោ អហំ ព្រហ្មេ... ភូតេ ខោ អហំ ព្រហ្មេ... ទេវេ ខោ អហំ ព្រហ្មេ... បជាបតឹ ខោ អហំ ព្រហ្មេ... ព្រហ្មំ ខោ អហំ ព្រហ្មេ... អាភស្សរេ ខោ អហំ ព្រហ្មេ... សុភកិណ្ហេ ខោ អហំ ព្រហ្មេ... វេហប្ផលេ ខោ អហំ ព្រហ្មេ... អភិភុំ ខោ អហំ ព្រហ្មេ... សព្វំ ខោ អហំ ព្រហ្មេ សព្វតោ អភិញ្ញាយ យាវតា សព្វស្ស សព្វត្តេន អននុភូតំ តទភិញ្ញាយ សព្វំ នាហោសឹ សព្វស្មឹ នាហោសឹ សព្វតោ នាហោសឹ សព្វំ មេតិ នាហោសឹ សព្វំ នាភិវទឹ ។ ឯវំ ខោ អហំ ព្រហ្មេ នេវ តេ សមសមោ អភិញ្ញាយ កុតោ នីចេយ្យំ អថខោ អហមេវ តយា ភិយ្យោ ។ សចេ ខោ តេ[១] មារិស សព្វស្ស សព្វត្តេន អននុភូតំ តទភិញ្ញាយ មា ហេវ តេ រិត្តកមេវ អហោសិ តុច្ឆកមេវ អហោសិ ។ វិញ្ញាណំ

១ ម. តេតិ បទំ ន ទិស្សតិ ។

ម្នាលព្រហ្ម តថាគតដឹងច្បាស់ នូវខ្យល់... ម្នាលព្រហ្ម តថាគតដឹងច្បាស់ នូវពួកសត្វ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវពួកទេវតា... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវបជាបតិទេវរាជ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវព្រហ្ម... ម្នាលព្រហ្ម តថាគតដឹងច្បាស់ នូវពួកព្រហ្មឈ្មោះអាភស្សរៈ ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវព្រហ្មឈ្មោះសុភកិណ្ហៈ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវព្រហ្មឈ្មោះវេហប្ផលៈ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវព្រហ្មជាច្បងគេ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវវត្ថុទាំងពួង ថាជាវត្ថុទាំងពួងពិត ដឹងច្បាស់នូវព្រះនិព្វានដែលសត្វមិនធ្លាប់ដល់ ដោយសភាពនៃវត្ថុទាំងពួង បានជាតថាគតមិនប្រកាន់វត្ថុទាំងពួង មិនប្រកាន់ក្នុងវត្ថុទាំងពួង មិនប្រកាន់អំពីវត្ថុទាំងពួង មិនប្រកាន់វត្ថុទាំងពួងថាជារបស់តថាគត មិនប្រកាសនូវវត្ថុទាំងពួង ។ ម្នាលព្រហ្ម កាលបើយ៉ាងនេះ តថាគតមិនមែនស្មើនឹងអ្នកទេ តថាគតត្រាស់ដឹងហើយ នឹងឲ្យថោកទាបជាងអ្នកដូចម្ដេចបាន តថាគតត្រូវតែប្រសើរជាងអ្នកដោយពិត ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ បើព្រះអង្គដឹងនូវព្រះនិព្វានដែលសត្វមិនធ្លាប់ដល់ដោយសភាពនៃវត្ថុទាំងពួងហើយ សូមកុំឲ្យពាក្យរបស់ព្រះអង្គសោះសូន្យទទេឥតអំពើឡើយ ។ វិញ្ញាណឈ្មោះ

អនិទស្សនំ អនន្តំ សព្វតោបភំ[1] បថវិយា បថវិត្តេន អននុភូតំ អាបស្ស អាបត្តេន អននុភូតំ តេជស្ស តេជត្តេន អននុភូតំ វាយស្ស វាយត្តេន អននុភូតំ ភូតានំ ភូតត្តេន អននុភូតំ ទេវានំ ទេវត្តេន អននុភូតំ បជាបតិស្ស បជាបតិត្តេន អននុភូតំ ព្រហ្មុនោ[2] ព្រហ្មត្តេន អននុភូតំ អាភស្សរានំ អាភស្សរត្តេន អននុភូតំ សុភកិណ្ហានំ សុភកិណ្ហត្តេន អននុភូតំ វេហប្ផលានំ វេហប្ផលត្តេន អននុភូតំ អភិភុស្ស អភិភុត្តេន អននុភូតំ សព្វស្ស សព្វត្តេន អននុភូតំ ។ ហន្ទ ចរហិ តេ មារិស[3] អន្តរធាយាមីតិ ។ ហន្ទ ចរហិ មេ ត្វំ ព្រហ្មេ អន្តរធាយស្សុ សចេ វិសហសីតិ ។ អថខោ ភិក្ខវេ ពកោ ព្រហ្មា

១ ឱ. ម. ឯត្ថន្តរេ តន្តិ ទិស្សតិ ។ ២ ឱ. ម. ព្រហ្មានំ ។ ៣ ម. ឯត្ថន្តរេ បស្សាតិ ទិស្សតិ ។

អនិទស្សនៈ[១] ឈ្មោះអនន្តៈ[២] មានពន្លឺភ្លឺជាងធម្មជាតទាំងអស់ ដែលសត្វមិនធ្លាប់បានដល់ដោយសភាពនៃផែនដី មិនធ្លាប់បានដល់ដោយសភាពនៃទឹក មិនធ្លាប់បានដល់ដោយសភាពនៃភ្លើង មិនធ្លាប់បានដល់ដោយសភាពនៃខ្យល់ មិនធ្លាប់បានដល់ ដោយសភាពជាពួកសត្វ មិនធ្លាប់បានដល់ដោយសភាពជាទេវតា មិនធ្លាប់បានដល់ដោយសភាពជាបជាបតិទេវរាជ មិនធ្លាប់បានដល់ដោយសភាពជាព្រហ្ម មិនធ្លាប់បានដល់ដោយសភាពជាអាភស្សរព្រហ្ម មិនធ្លាប់បានដល់ដោយសភាពជាសុភកិណ្ហព្រហ្ម មិនធ្លាប់បានដល់ដោយសភាពជាវេហប្ផលព្រហ្ម មិនធ្លាប់បានដល់ដោយសភាពនៃព្រហ្មជាច្បង មិនធ្លាប់បានដល់ដោយសភាពនៃវត្ថុទាំងពួង ។ បពិត្រព្រះអង្គអ្នកនិទុក្ខ ណ្ហើយចុះ ខ្ញុំនឹងបំបាត់ខ្លួនអំពីព្រះអង្គឥឡូវនេះ ។ ម្នាលព្រហ្ម អើ បើអ្នកអាច ក៏ចូរបំបាត់ខ្លួន អំពីតថាគតឥឡូវនេះមើល ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ពកព្រហ្មគិត

---

១-២ វិញ្ញាណនេះជាឈ្មោះនៃព្រះនិព្វាន ជូនកាលហៅថា អនិទស្សនៈ ថា អនន្តៈ ។ ដែលឈ្មោះថាអនិទស្សនៈ ព្រោះមិនមានរូបារម្មណ៍មកកាន់រង្វង់ចក្ខុវិញ្ញាណ, ដែលឈ្មោះថាអនន្តៈ ព្រោះប្រាសចាកការកើតនិងវិនាសទៅវិញ ។ អដ្ឋកថា ។

អន្តរធាយិស្សាមិ សមណស្ស គោតមស្ស អន្តរធា-យិស្សាមិ សមណស្ស គោតមស្សាតិ នេវស្សុ មេ សក្ខោតិ អន្តរធាយិតុំ ។ ឯវំ វុត្តេ អហំ ភិក្ខវេ ពកំ ព្រហ្មានំ ឯតទវោចំ ហន្ទ ចរហិ តេ ព្រហ្មេ អន្តរធាយាមីតិ ។ ហន្ទ ចរហិ មេ ត្វំ មារិស អន្តរធាយស្សុ សចេ វិសហសីតិ ។ អថខ្វាហំ ភិក្ខវេ តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខារេសឹ[១] ឯត្តាវតា ព្រហ្មា ច ព្រហ្មបរិសា ច ព្រហ្មបា-រិសជ្ជា ច សទ្ទញ្ច មេ សុយ្យន្តិ[២] ន ច មំ ទក្ខន្តីតិ ។ អន្តរហិតោ ឥមំ គាថំ អភាសឹ

ភវេវាហំ ភយំ ទិស្វា
ភវញ្ច វិភវេសិនំ
ភវំ នាភិវទឹ កិញ្ចិ[៣]
នន្ទិញ្ច ន ឧបាទិយន្តិ ។

[១៩៤] អថខោ ភិក្ខវេ ព្រហ្មា ច ព្រហ្មបរិសា ច ព្រហ្មបារិសជ្ជា ច អច្ឆរិយព្ភូតចិត្តជាតា អហេសុំ

---

១ ឱ. អភិសង្ខាសឹ ។ ២ ឱ. សោស្សន្តិ ។ ៣ ឱ. កញ្ចិ ។

ថា អាត្មាអញនឹងបំបាត់ខ្លួនអំពីព្រះសមណគោតម អាត្មាអញនឹងបំបាត់ខ្លួនអំពីព្រះសមណគោតម ហើយក៏មិនអាចនឹងបំបាត់ខ្លួនអំពីតថាគតបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពកព្រហ្មពោលយ៉ាងនេះហើយ តថាគតក៏បានពោលនឹងពកព្រហ្មយ៉ាងនេះវិញថា ម្នាលព្រហ្ម បើដូច្នោះ តថាគតនឹងបំបាត់ខ្លួនអំពីអ្នកវិញ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ បើព្រះអង្គអាច ក៏ចូរបំបាត់ខ្លួនអំពីខ្ញុំទៅមើល ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯងតថាគតនិមិត្ត នូវឥទ្ធាភិសង្ខារមានសភាពដូច្នោះថា ព្រហ្មនិងព្រហ្មបរិស័ទ ព្រមទាំងព្រហ្មបារិសជ្ជា ឲ្យឮតែសំឡេងរបស់តថាគតប៉ុណ្ណោះ តែមិនបានឃើញតថាគតឡើយ ។ កាលតថាគតបំបាត់ខ្លួនទៅហើយ ក៏បានពោលនូវព្រះគាថានេះថា

តថាគតឃើញភ័យក្នុងភពផង ឃើញនូវពួកសត្វដែលកំពុង
ស្វែងរកនូវភពផង ហើយមិនបានពោលសរសើរគឺមិនស្វែង
រកភពណាមួយ ទាំងមិនប្រកាន់នូវសេចក្តីត្រេកអរ (ក្នុងភព)
ឡើយ ។

[១៩៥] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រហ្មនិងព្រហ្មបរិស័ទ ព្រមទាំងព្រហ្មបារិសជ្ជា ក៏កើតសេចក្តីអស្ចារ្យ ក្នុងចិត្តថា

អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សមណស្ស គោតមស្ស មហិទ្ធិកតា មហានុភាវតា ន ច[១] វត នោ ឥតោ បុព្វេ ទិដ្ឋោ វា អញ្ញោ សមណោ វា ព្រាហ្មណោ វា ឯវំមហិទ្ធិកោ ឯវំមហានុភាវោ យថាយំ[២] សមណោ គោតមោ សក្យកុលា បព្វជិតោ ភវរាមាយ វត ភោ បជាយ ភវរតាយ ភវសម្មុទិតាយ សមូលំ ភវំ ឧទព្វហីតិ ។

[១៩៦] អថខោ ភិក្ខវេ មារោ បាបិមា អញ្ញតរំ ព្រហ្មបារិសជ្ជំ អន្វាវិសិត្វា មំ ឯតទវោច សចេ ខោ ត្វំ មារិស ឯវំ បជានាសិ សចេ ត្វំ ឯវមនុពុទ្ធោ មា សាវកេ ឧបនេសិ មា បព្វជិតេ មា សាវកានំ ធម្មំ ទេសេសិ មា បព្វជិតានំ មា សាវកេសុ គេធិមកាសិ មា បព្វជិតេសុ ។ អហេសុំ ខោ ភិក្ខុ តយា បុព្វេ សមណព្រាហ្មណា លោកស្មឹ អរហន្តោ សម្មាសម្ពុទ្ធា

១ ឱ. ច សទ្ទោ ន ទិស្សតិ ។ ២ ឱ. ម. យំ ។

*អើ ហេតុនេះជាអស្ចារ្យណាស់ហ្ន៎ អើ ហេតុនេះមិនដែលមានទេហ្ន៎ ព្រះសមណគោតមពេញជាមានឫទ្ធិច្រើន ពេញជាមានអានុភាពច្រើនមែនមួយទៀត មុនអំពីកាលនេះ យើងទាំងឡាយមិនដែលបានឃើញ មិនដែលបានឮថា មានសមណៈឬព្រាហ្មណ៍ដទៃមានឫទ្ធិច្រើន មានអានុ-ភាពច្រើន ឲ្យដូចជាព្រះសមណគោតម ដែលចេញចាកសក្យត្រកូលមកបួសនេះឡើយ អើហ្ន៎ ព្រះសមណគោតមបេះផ្តិលផ្តាច់នូវភព ព្រមទាំងឫសគល់របស់ពួកសត្វ ដែលរីករាយក្នុងភព ត្រេកអរក្នុងភព ពេញចិត្តក្នុងភពបាន ។*

*[១៩៦] ម្នាលភិក្ខុទាំងឡាយ គ្រានោះ មារមានចិត្តបាបបានចូលជ្រែកសរីរៈ នៃព្រហ្មបារិសជ្ជាមួយរូប ហើយបានពោលនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ប្រសិនបើព្រះអង្គជ្រាបច្បាស់យ៉ាងនេះ ប្រសិនបើត្រាស់ដឹង (សច្ចៈ) យ៉ាងនេះហើយ សូមព្រះអង្គកុំពន្យល់ពួកសាវ័ក កុំពន្យល់ពួកបព្វជិត កុំសំដែងធម៌ដល់ពួកសាវ័ក កុំសំដែងធម៌ដល់ពួកបព្វជិតឡើយ កុំធ្វើសេចក្តីប្រាថ្នាក្នុងពួកសាវ័ក កុំធ្វើសេចក្តីប្រាថ្នាក្នុងពួកបព្វជិតឡើយ ។ ម្នាលភិក្ខុ ក្នុងកាលមុនខ្លួនលោក (ទៅទៀត) មានពួកសមណព្រាហ្មណ៍ ជាអរហន្តសម្មាសម្ពុទ្ធ*

បដិជានមានា តេ សាវកេ ឧបនេសុំ បព្វជិតេ សាវកានំ ធម្មំ ទេសេសុំ បព្វជិតានំ សាវកេសុ គេធិមកំសុ បព្វជិតេសុ សាវកេ ឧបនេត្វា បព្វជិតេ សាវកានំ ធម្មំ ទេសេត្វា បព្វជិតានំ សាវកេសុ គេធិកតចិត្តា បព្វជិតេសុ កាយស្ស ភេទា ចាណុបច្ឆេទា ហីនេ កាយេ បតិដ្ឋិតា ។ អហេសុំ ខោ[១] បន ភិក្ខុ[២] តយា បុព្វេ សមណព្រាហ្មណា លោកស្មឹ អរហន្តោ សម្មាសម្ពុទ្ធា បដិជានមានា តេ ន សាវកេ ឧបនេសុំ ន បព្វជិតេ ន សាវកានំ ធម្មំ ទេសេសុំ ន បព្វជិតានំ ន សាវកេសុ គេធិមកំសុ ន បព្វជិតេ តេ ន សាវកេ ឧបនេត្វា ន បព្វជិតេ ន សាវកានំ ធម្មំ ទេសេត្វា ន បព្វជិតានំ ន សាវកេសុ គេធិកតចិត្តា ន បព្វជិតេសុ កាយស្ស ភេទា ចាណុបច្ឆេទា បណីតេ កាយេ បតិដ្ឋិតា ។ តដ្តាហំ ភិក្ខុ ឯវំ វទាមិ ឥង្ឃ ត្វំ មារិស អប្បោស្សុក្កោ

១ ឱ. ខោសទ្ធោ ន ទិស្សតិ ។ ម. យេ ។ ២ ម. ភិក្ខូ ។

ជាអ្នកចេះដឹងក្នុងលោក ពួកសមណព្រាហ្មណ៍ទាំងនោះ បានពន្យល់ពួកសាវ័កនិងពួកបព្វជិត បានសំដែងធម៌ ដល់ពួកសាវ័កនិងពួកបព្វជិត បានធ្វើសេចក្ដីប្រាថ្នា ក្នុងពួកសាវ័កនិងពួកបព្វជិត លុះពន្យល់ពួកសាវ័កនិងពួកបព្វជិត សំដែងធម៌ដល់ពួកសាវ័កនិងពួកបព្វជិត មានចិត្តប្រាថ្នាក្នុងពួកសាវ័កនិងពួកបព្វជិតហើយ លុះទម្លាយកាយ ផ្ដាច់ជីវិតបាត់ទៅ កើតក្នុងពួកដ៏ថោកទាប (គឺអបាយភូមិទាំង ៤) ។ ម្នាលភិក្ខុ មួយទៀត ក្នុងកាលមុនខ្លួនលោក (ទៅទៀត) មានសមណព្រាហ្មណ៍ ជាអរហន្តសម្មាសម្ពុទ្ធ ជាអ្នកចេះដឹងក្នុងលោក ពួកសមណព្រាហ្មណ៍ទាំងនោះ មិនបានពន្យល់ពួកសាវ័ក មិនបានពន្យល់ ពួកបព្វជិត មិនសំដែងធម៌ ដល់ពួកសាវ័ក មិនសំដែងធម៌ដល់ពួកបព្វជិត មិនធ្វើសេចក្ដីប្រាថ្នាក្នុងពួកសាវ័ក មិនធ្វើសេចក្ដីប្រាថ្នា ក្នុងពួកបព្វជិត ពួកសមណព្រាហ្មណ៍ទាំងនោះ លុះមិនបានពន្យល់ ពួកសាវ័ក មិនបានពន្យល់ ពួកបព្វជិត មិនបានសំដែងធម៌ដល់ពួកសាវ័ក មិនបានសំដែងធម៌ដល់ពួកបព្វជិត មិនមានចិត្តប្រាថ្នាក្នុងពួកសាវ័ក មិនមានចិត្តប្រាថ្នា ក្នុងពួកបព្វជិតហើយ លុះទម្លាយកាយផ្ដាច់បង់ជីវិត ក៏បានមកកើតក្នុងទីដ៏ខ្ពង់ខ្ពស់ (ព្រហ្មលោក) ។ ម្នាលភិក្ខុ ព្រោះហេតុនោះបានជាខ្ញុំនិយាយនឹងលោកយ៉ាងនេះថា ម្នាលអ្នកនិទ៌ុក្ខ ខ្ញុំសូមរំលឹក កុំឲ្យលោកមានសេចក្ដីខ្វល់ខ្វាយ

ទិដ្ឋធម្មសុខវិហារំ អនុយុត្តោ វិហរស្សុ អនក្ខាតំ កុសលំ ហិ មារិស មា បរំ ឱវទាហីតិ ។ ឯវំ វុត្តេ អហំ ភិក្ខវេ មារំ បាបិមំ ឯតទវោចំ ជានាមិ ខោ តាហំ បាបិម មា ត្វំ មញ្ញិត្ថោ ន មំ ជានាតីតិ មារោ ត្វមសិ បាបិម ន មំ ត្វំ បាបិម ហិតានុកម្បី ឯវំ វទេសិ អហិតានុកម្បី មំ ត្វំ បាបិម ឯវំ វទេសិ ។ តុយ្ហំ ហិ បាបិម ឯវំ ហោតិ យេសំ សមណោ គោតមោ ធម្មំ ទេសេស្សតិ តេ មេ វិសយំ ឧបាតិវត្តិស្សន្តីតិ ។ អសម្មាសម្ពុទ្ធា ច បន តេ បាបិម សមណព្រាហ្មណា សមា-នា សម្មាសម្ពុទ្ធម្ហាតិ បដិជានឹសុ អហំ ខោ បន បាបិម សម្មាសម្ពុទ្ធោ វ សមានោ សម្មាសម្ពុទ្ធោ-ម្ហីតិ បដិជានាមិ ។ ទេសេន្តោបិ ហិ បាបិម តថាគតោ សាវកានំ ធម្មំ តាទិសោ វ អទេសេ-ន្តោបិ ហិ បាបិម តថាគតោ សាវកានំ ធម្មំ

ពេក សូមប្រកបរឿយ ៗ នូវធម៌ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នចុះ ព្រោះថាការដែលមិនសំដែង (ធម៌) ប្រាប់ជនដទៃ ជាការប្រពៃ ម្នាលអ្នកនិទ៌ុក្ខ សូមលោកកុំទូន្មានអ្នកដទៃឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើមារពោលយ៉ាងនេះហើយ ទើបតថាគតបានពោលពាក្យនេះនឹងមារមានចិត្តបាបវិញថា ម្នាលមារមានចិត្តបាប តថាគតស្គាល់អ្នកច្បាស់ហើយ អ្នកកុំមើលងាយថា ឥតអ្នកណាមួយស្គាល់អាត្មាអញដូច្នេះឡើយ ម្នាលមារមានចិត្តបាប អ្នកហ្នឹងហើយជាមារ ម្នាលមារមានចិត្តបាប អ្នកជាអ្នកមិនអនុគ្រោះតថាគតដោយប្រយោជន៍ទេ បានជានិយាយយ៉ាងនេះ ម្នាលមារមានចិត្តបាប អ្នកអនុគ្រោះតថាគត ដោយអំពើឥតប្រយោជន៍ បានជានិយាយយ៉ាងនេះ ។ ម្នាលមារមានចិត្តបាប ព្រោះអ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា សមណគោតមសំដែងធម៌ ដល់ពួកជនណា ពួកជននោះ នឹងកន្លងផុតវិស័យរបស់អាត្មាអញ ។ ម្នាលមារមានចិត្តបាប ឯពួកសមណព្រាហ្មណ៍ទាំងនោះ មិនមែនជាសម្មាសម្ពុទ្ធទេ តែប្តេជ្ញាថាយើងជាសម្មាសម្ពុទ្ធ ។ ម្នាលមារមានចិត្តបាប ទោះបីតថាគតសំដែងធម៌ដល់ពួកសាវ័កក្តី ក៏នៅជាតថាគតដដែល ម្នាលមារមានចិត្តបាប ទោះបីតថាគតមិនសំដែងធម៌ដល់ពួកសាវ័កក្តី ក៏នៅ

តាទិសោ វ ឧបទេដ្ឋាបិ ហិ បាបិម តថាគតោ សាវកេ តាទិសោ វ អនុបទេដ្ឋាបិ ហិ បាបិម តថាគតោ សាវកេ តាទិសោ វ តំ កិស្ស ហេតុ តថាគតស្ស បាបិម យេ អាសវា សង្កិលេសិកា បោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណីយា[១] បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា សេយ្យថាបិ បាបិម តាលោ មត្ថកច្ឆិន្នោ អភព្វោ បុន វិរូឡ្ហិយា ឯវមេវ ខោ បាបិម តថាគតស្ស យេ អាសវា សង្កិលេសិកា បោនោព្ភវិកា សទរា

១ ឱ. ម. ឯត្ថន្តរេ តេតិ ទិស្សតិ ។

ជាតថាគតដដែល ម្នាលមារមានចិត្តបាប ទោះបីតថាគតពន្យល់ពួក សាវ័កក្តី ក៏នៅជាតថាគតដដែល ម្នាលមារមានចិត្តបាប ទោះបីតថា-គតមិនពន្យល់ពួកសាវ័កក្តី ក៏នៅជាតថាគតដដែល ដំណើរនោះព្រោះហេតុអ្វី ម្នាលមារមានចិត្តបាប ព្រោះតថាគតបានលះបង់ នូវអាសវៈដែលជាសង្កិលេសធម៌ ជាធម៌តាក់តែងភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាផល មានជាតិជរានិងមរណៈ តទៅខាងមុខ បានទាំងផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីងដូចជាដើមត្នោត ដែលគេគាស់ក្របែលរំលើងឲ្យលែងដុះទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ ម្នាលមារមានចិត្តបាប ដូចជាដើមត្នោតដែលមានចុងកំបុតហើយ មិនគួរនឹងដុះឡើងវិញបាន យ៉ាងណា ម្នាលមារមានចិត្តបាប តថាគតបានលះបង់នូវអាសវៈទាំងឡាយ ជាសង្កិ-លេស ជាធម៌តាក់តែងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ

ទុក្ខវិចាកា អាយតឹ ជាតិជរាមរណីយា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មាតិ ។ ឥតិ ហិទំ មារស្ស ច អនាលបនតាយ ព្រហ្មុនោ ច អភិនិមន្តនតាយ តស្មា ឥមស្ស វេយ្យាករណស្ស ព្រហ្មនិមន្តនិកន្តេវ អធិវចនន្តិ ។

ព្រហ្មនិមន្តនិកសុត្តំ នវមំ និដ្ឋិតំ ។

មានទុក្ខជាផល មានជាតិជរានិងមរណៈតទៅខាងមុខ បានទាំងផ្តាច់ផ្តិល ឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីងដូចជាដើមត្នោត ដែលគេក្របែលគាស់រំលើងឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅទៀតហើយ ក៏យ៉ាងនោះដែរ ព្រោះការចរចាមិនកើតការនៃមារផង ព្រោះការនិមន្តចំពោះនៃព្រហ្មផង ហេតុដូច្នោះបានជាវេយ្យាករណ៍នេះមាននាមថា ព្រហ្មនិមន្តនិកៈ ដោយប្រការដូច្នេះឯង ។

ចប់ ព្រហ្មនិមន្តនិកសូត្រ ទី ៩ ។

# ទសមំ មារតជ្ជនីយសុត្តំ

[១៩៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា[១] ភគ្គេសុ វិហរតិ សុំសុមារគិរេ[២] ភេសកឡាវនេ មិគទាយេ ។ តេន ខោ បន សមយេន អាយស្មា មហាមោគ្គល្លានោ អព្ភោកាសេ ចង្កមិ[៣] ។ តេន ខោ បន សមយេន មារោ បាបិមា អាយស្មតោ មហាមោគ្គល្លានស្ស កុច្ឆិគតោ ហោតិ កោដ្ឋមនុ-បវិដ្ឋោ ។ អថខោ អាយស្មតោ មហាមោគ្គល្លានស្ស ឯតទហោសិ កិន្នុ[៤] ខោ មេ កុច្ឆិ គរុគរុតរោ វិយ[៥] មាសាចិតំ មញ្ញេតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ ចង្កមា ឱរោហិត្វា វិហារំ បវិសិត្វា បញ្ញត្តាសនេ[៦] និសីទិ ។ និសជ្ជ ខោ អាយស្មា មហាមោគ្គល្លានោ មារំ បាបិមន្តំ[៧] បច្ចត្តំ យោនិ-សោ មនសាកាសិ[៨] ។

---

១ ឱ. ម. អាយស្មា មហាមោគ្គល្លានោតិ ទិស្សតិ ។ ២ ម. សុសុមារគិរេ ។ ៣ ឱ. ម. ចង្កមតិ ។ ៤ ម. កឹ នុ ។ ៥ ឱ. គរុគរុ វិយ ។ ម. គរុតរោ វិយ ។ ៦ ឱ. ម. បញ្ញត្តេ អាសនេ ។ ៧ ឱ. ម. មារំ បាបិមន្តន្តិ ន ទិស្សតិ ។ ៨ ឱ. មនសិកាសិ ។

# មារតជ្ជនីយសូត្រ ទី ១០

[១៩៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ម្រឹគ ជិតក្រុងឈ្មោះសុំសុមារគិរៈ ក្នុងភគ្គជនបទ ។ គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុចង្រ្កមក្នុងទីវាល ។ សម័យនោះ មារមានចិត្តបាបចូលទៅនៅក្នុងផ្ទៃ សម្ងំក្នុងពោះវៀនរបស់ព្រះមហាមោគ្គល្លានមានអាយុ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា ដូចម្តេចហ្ន៎ បានជាផ្ទៃរបស់អាត្មាអញធ្ងន់ ៗ ហាក់ដូចជាសណ្តែករាជមាសទទឹកដូច្នេះ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានមានអាយុ ចុះមកអំពីចង្រ្កមចូលទៅកាន់វិហារហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលប្រគេន ។ លុះព្រះមហាមោគ្គល្លានមានអាយុអង្គុយហើយ ទើបពិចារណាឃើញនូវមារមានចិត្តបាប ដោយឧបាយចិត្តជារបស់ខ្លួន ។

[១៩៨] អទ្ទសា ខោ អាយស្មា មហាមោគ្គល្លានោ មារំ បាបិមន្តំ កុច្ឆិគតំ កោដ្ឋមនុបវិដ្ឋំ ទិស្វាន មារំ បាបិមន្តំ ឯតទវោច និក្ខម បាបិម និក្ខម បាបិម មា តថាគតំ វិហេសេសិ មា តថាគតស្សាវកំ មា តេ អហោសិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ អថខោ មារស្ស បាបិមតោ ឯតទហោសិ អជានមេវ[១] មំ អយំ សមណោ អបស្សំ ឯវមាហ និក្ខម បាបិម និក្ខម បាបិម មា តថាគតំ វិហេសេសិ មា តថាគតស្សាវកំ មា តេ អហោសិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ យោបិស្ស សោ សត្ថា សោបិ មំ នេវ ខិប្បំ ជានេយ្យ កុតោ ច[២] បន មំ អយំ សាវកោ ជានិស្សតីតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ មារំ បាបិមន្តំ ឯតទវោច ឯវម្បិ ខោ តាហំ បាបិម ជានាមិ មា ត្វំ មញ្ញិត្ថោ

---

១ ឱ. ម. អជានមេវ ខោ ។ ២ ឱ. ម. ចសទ្ទោ ន ទិស្សតិ ។

[១៩៨] ព្រះមហាមោគ្គល្លានមានអាយុ បានឃើញមារដែលមានចិត្តបាបនោះចូលក្នុងផ្ទៃ សម្ងំនៅក្នុងពោះវៀន លុះឃើញហើយ ក៏បាននិយាយនឹងមារមានចិត្តបាបដូច្នេះថា ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ អ្នកកុំបៀតបៀនព្រះតថាគត កុំបៀតបៀនសាវ័កព្រះតថាគតឡើយ ការបៀតបៀនដែលប្រព្រឹត្តទៅដើម្បីសេចក្តីមិនចម្រើន ដើម្បីសេចក្តីទុក្ខអស់កាលជាអង្វែង កុំមានដល់អ្នកឡើយ ។ គ្រានោះ មារមានចិត្តបាបមានសេចក្តីត្រិះរិះយ៉ាងនេះថា សមណៈនេះមិនដឹង មិនស្គាល់អញទេ បានជានិយាយយ៉ាងនេះថា ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ អ្នកកុំបៀតបៀនព្រះតថាគត កុំបៀតបៀនសាវ័កព្រះតថាគតឡើយ ការបៀតបៀនដែលប្រព្រឹត្តទៅដើម្បីសេចក្តីមិនចម្រើន ដើម្បីសេចក្តីទុក្ខអស់កាលជាអង្វែង កុំមានដល់អ្នកឡើយ សូម្បីគ្រូនៃសាវ័កនោះ ក៏មិនគប្បីស្គាល់អាត្មាអញបានដោយឆាប់រហ័ស ចំណង់បើសាវ័កនេះនឹងស្គាល់អាត្មាអញដូចម្តេចបាន ។ លំដាប់នោះ ព្រះមហាមោគ្គល្លានមានអាយុ បាននិយាយនឹងមារមានចិត្តបាប យ៉ាងនេះថា ម្នាលមារមានចិត្តបាប អាត្មាស្គាល់អ្នកច្បាស់ហើយ អ្នកកុំមើលងាយថា

ន មំ ជានាតីតិ មារោ ត្វមសិ ចាបិម តុយ្ហំ ហិ ចាបិម ឯវំ ហោតិ អជានមេវ មំ អយំ សមណោ អបស្សំ ឯវមាហ និក្ខម ចាបិម និក្ខម ចាបិម មា តថាគតំ វិហេសេសិ មា តថាគតស្សាវកំ មា តេ អហោសិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ យោបិស្ស សោ សត្ថា សោបិ មំ នេវ ឧប្បំ ជានេយ្យ កុតោ ច បន មំ អយំ សាវកោ ជានិស្សតីតិ ។ អថខោ មារស្ស ចាបិមតោ ឯតទ-ហោសិ ជានមេវ ខោ មំ អយំ សមណោ បស្សំ ឯវ-មាហ និក្ខម ចាបិម និក្ខម ចាបិម មា តថាគតំ វិហេសេសិ មា តថាគតស្សាវកំ មា តេ អហោសិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ អថខោ មារោ ចាបិមា អាយស្មតោ មហាមោគ្គល្លានស្ស មុខតោ ឧគ្គន្ត្វា បច្ចគ្គឡេ អដ្ឋាសិ ។

ឥតមានអ្នកណាស្គាល់អញ យ៉ាងនេះដូច្នេះ ម្នាលមារមានចិត្តបាប អ្នកហ្នឹងហើយជាមារ ម្នាលមារមានចិត្តបាប ឯអ្នកតែងមានសេចក្ដីត្រិះរិះយ៉ាងនេះថា សមណៈនេះមិនស្គាល់អញ មិនឃើញអញទេ បានជានិយាយយ៉ាងនេះថា ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ អ្នកកុំបៀតបៀនព្រះតថាគត កុំបៀតបៀនសាវ័កព្រះតថាគតឡើយ ការបៀតបៀនដែលប្រព្រឹត្តទៅ ដើម្បីសេចក្ដីមិនចម្រើន ដើម្បីសេចក្ដីទុក្ខ អស់កាលជាអង្វែង កុំមានដល់អ្នកឡើយ សូម្បីគ្រូនៃសាវ័កនេះ ក៏មិនគប្បីស្គាល់អាត្មាអញបានដោយឆាប់រហ័ស ចំណង់បើសាវ័កនេះ នឹងស្គាល់អាត្មាអញដូចម្ដេចបាន ។ លំដាប់នោះ មារមានចិត្តបាប មានសេចក្ដីត្រិះរិះយ៉ាងនេះថា សមណៈនេះស្គាល់ ឃើញអាត្មាអញមែន បានជានិយាយយ៉ាងនេះថា ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ អ្នកកុំបៀតបៀនព្រះតថាគត កុំបៀតបៀនសាវ័ករបស់ព្រះតថាគតឡើយ ការបៀតបៀនដែលប្រព្រឹត្តទៅ ដើម្បីសេចក្ដីមិនចម្រើន ដើម្បីសេចក្ដីទុក្ខ អស់កាលជាអង្វែង កុំមានដល់អ្នកឡើយ ។ គ្រានោះ មារមានចិត្តបាប ឡើងមកតាមមាត់ នៃព្រះមហាមោគ្គល្លានមានអាយុ មកឋិតនៅត្រង់សន្ទះទ្វារ ។

[១៩៩] អទ្ទសា ខោ អាយស្មា មហាមោគ្គល្លានោ មារំ បាបិមន្តំ បច្ចគ្គឡេ ឋិតំ ទិស្វាន មារំ បាបិមន្តំ ឯតទវោច ឯត្ថាបិ ខោ តាហំ បាបិម បស្សាមិ មា ត្វំ មញ្ញិត្ថោ ន មំ បស្សតីតិ ឯសោ ត្វំ បាបិម បច្ចគ្គឡេ ឋិតោ ។ ភូតបុព្វាហំ បាបិម ទូសី នាម មារោ អហោសឹ តស្ស មេ កាឡី នាម ភគិនី តស្សា ភគិនិយា[១] ត្វំ បុត្តោ សោ មេ ត្វំ ភាគិនេយ្យោ អហោសីតិ[២] ។ តេន ខោ បន[៣] សមយេន កកុសន្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧប្បន្នោ ហោតិ ។ កកុសន្ធស្ស ខោ បន បាបិម ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស វិធុរសញ្ជីវំ នាម មហាសាវកយុគំ អហោសិ អគ្គំ ភទ្ទយុគំ ។ យាវតា ខោ បន បាបិម កកុសន្ធស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សាវកា នាស្សុធ កោចិ អាយស្មតោ វិធុរេន សមសមោ ហោតិ

១ ឱ. ម. ភគិនិយាតិ ន ទិស្សតិ ។ ២ ឱ. ម. ឥតិសទ្ទោ ន ទិស្សតិ ។ ៣ ឱ. ម. ឯត្ថន្តរេ បាបិមាតិ ទិស្សតិ ។

[១៩៩] ព្រះមហាមោគ្គល្លានមានអាយុ បានឃើញមារមានចិត្តបាបនោះ មកបិតនៅត្រង់សន្ទះទ្វារ លុះឃើញហើយទើបនិយាយនឹងមារមានចិត្តបាប យ៉ាងនេះថា ម្នាលមារមានចិត្តបាប អាត្មាឃើញអ្នកក្នុងទីនេះដែរ អ្នកកុំមើលងាយថា មិនមានអ្នកណាឃើញអាត្មាអញដូច្នេះឡើយ ម្នាលមារមានចិត្តបាប អ្នកនុ៎ះបិតនៅត្រង់សន្ទះទ្វារ ។ ម្នាលមារមានចិត្តបាប កាលពីដើមមក អាត្មាបានកើតជាមារឈ្មោះទូសី ប្អូនស្រីរបស់អាត្មានោះ ឈ្មោះនាងកាឡី ខ្លួនអ្នកជាកូនប្រុសរបស់ប្អូនស្រីនោះ អ្នកនោះត្រូវជាក្មួយរបស់អាត្មា ។ ក៏សម័យនោះ ព្រះមានព្រះភាគទ្រង់ព្រះនាមកកុសន្ធៈ ជាអរហន្តសម្មាសម្ពុទ្ធ ត្រាស់ឡើងក្នុងលោក ។ ម្នាលមារមានចិត្តបាប ព្រះមានព្រះភាគទ្រង់ព្រះនាមកកុសន្ធៈជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់មានគូមហាសាវ័កឈ្មោះវិធុរៈ ១ ឈ្មោះសញ្ជីវៈ ១ ជាគូដ៏ប្រសើរដ៏ចម្រើន ។ ម្នាលមារមានចិត្តបាប ពួកសាវ័ករបស់ព្រះមានព្រះភាគ ទ្រង់ព្រះនាមកកុសន្ធៈ ជាអរហន្តសម្មាសម្ពុទ្ធក្នុងសាសនានេះ មិនមានសាវ័កណាមួយស្មើនឹងវិធុរៈ មានអាយុ

យថិទំ ធម្មទេសនាយ ។ ឥមិនា ខោ ឯតំ បាបិម បរិយាយេន អាយស្មតោ វិធុរស្ស វិធុរោ វិធុរោត្វេវ សមញ្ញា ឧទបាទិ ។ អាយស្មា បន បាបិម សញ្ជីវោ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ អប្ប-កសិរេនេវ សញ្ញាវេទយិតនិរោធំ សមាបជ្ជតិ ។ ភូត-បុព្វំ បាបិម អាយស្មា សញ្ជីវោ អញ្ញតរស្មឹ រុក្ខមូលេ សញ្ញាវេទយិតនិរោធំ សមាបន្នោ និសិន្នោ ហោតិ ។ អទ្ទសាសុំ ខោ បាបិម គោបាលកា បសុបាលកា កសកា បថាវិនោ អាយស្មន្តំ សញ្ជីវំ អញ្ញតរស្មឹ រុក្ខមូលេ សញ្ញាវេទយិតនិរោធំ សមាបន្នំ និសិន្នំ ទិស្វាន តេសំ[១] ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ អយំ សមណោ និសិន្នកោ[២] កាលកតោ ហន្ទ នំ ទហាមាតិ ។ អថខោ តេ បាបិម គោបាល-កា បសុបាលកា កសកា បថាវិនោ តិណញ្ច កដ្ឋញ្ច គោមយញ្ច សង្កឌ្ឍិត្វា អាយស្មតោ សញ្ជី-វស្ស កាយេ ឧបចិនិត្វា អគ្គឹ ទត្វា បក្កមឹសុ ។

១ ឱ. នេសំ ។ ២ ឱ. ម. និសិន្នកោ វ ។

ក្នុងការសំដែងធម៌ឡើយ ។ ម្នាលមារមានចិត្តបាប ដោយហេតុនេះ វិធុរៈមានអាយុ មានឈ្មោះថា វិធុរៈ វិធុរៈ ដូច្នេះ កើតប្រាកដឡើង ។ ម្នាលមារមានចិត្តបាប ចំណែកខាងសញ្ជីវៈមានអាយុ នៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងតែចូលសញ្ញាវេទយិតនិរោធ ដោយសេចក្តីលំបាកតិច ។ ម្នាលមារមានចិត្តបាប កាលពីដើមមក សញ្ជីវៈមានអាយុ អង្គុយចូលសញ្ញាវេទយិតនិរោធ ក្រោមម្លប់ឈើមួយដើម ។ ម្នាលមារមានចិត្តបាប ពួកអ្នករក្សាគោ ពួកអ្នករក្សាពពែ ពួកអ្នកភ្ជួររាស់ និងពួកអ្នកដំណើរ បានឃើញសញ្ជីវៈមានអាយុ កំពុងអង្គុយចូលសញ្ញាវេទយិតនិរោធក្រោមម្លប់ឈើមួយដើម លុះឃើញហើយ ពួកជនទាំងនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អើ នេះអស្ចារ្យណាស់ហ្ន៎ អើ មិនដែលមានទេហ្ន៎ សមណៈនេះ អង្គុយធ្វើមរណកាលទៅហើយ បើដូច្នោះយើងនឹងនាំគ្នាបូជាសពលោក ។ ម្នាលមារមានចិត្តបាប គ្រានោះ ពួកអ្នករក្សាគោ ពួកអ្នករក្សាពពែ ពួកអ្នកភ្ជួររាស់ និងពួកអ្នកដំណើរនោះ ប្រមូលនូវស្មៅ ឧស និងអាចម៍គោ មករុំកាយព្រះសញ្ជីវៈមានអាយុហើយ ក៏ដុតភ្លើងហើយចៀសចេញទៅ ។

អថខោ បាបិម អាយស្មា សញ្ជីវោ តស្សា រត្តិយា អច្ចយេន តាយ សមាបត្តិយា វុដ្ឋហិត្វា ចីវរានិ បប្ផោដេត្វា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ គាមំ បិណ្ឌាយ បាវិសិ ។ អទ្ទសាសុំ ខោ តេ បាបិម គោបាលកា បសុបាលកា កសកា បថាវិនោ អាយស្មន្តំ សញ្ជីវំ បិណ្ឌាយ ចរន្តំ ទិស្វាន នេសំ ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ អយំ សមណោ និសិន្នកោ កាលកតោ ស្វាយំ បដិសញ្ជីវិតោតិ ។ ឥមិនា ខោ ឯវំ បាបិម បរិយាយេន អាយស្មតោ សញ្ជីវស្ស សញ្ជីវោ សញ្ជីវោត្វេវ សមញ្ញា ឧទបាទិ ។

[២០០] អថខោ បាបិម ទូសិស្ស មារស្ស ឯតទហោសិ ឥមេសំ ខោ អហំ ភិក្ខូនំ សីលវន្តានំ កល្យាណធម្មានំ នេវ ជានាមិ អាគតឹ វា គតឹ វា យន្នូនាហំ ព្រាហ្មណគហបតិកេ អន្វាវិសេយ្យំ

ម្នាលមារមានចិត្តបាប គ្រានោះ ព្រះសញ្ជីវៈមានអាយុ លុះកន្លងរាត្រីនោះទៅ ទើបចេញអំពីសមាបត្តិនោះ ក៏រលាស់ចីវរ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ក្នុងវេលាព្រឹកព្រហាម ។ ម្នាលមារមានចិត្តបាប ពួកអ្នករក្សាគោ ពួកអ្នករក្សាពពែ ពួកអ្នកភ្ជួររាស់ និងពួកអ្នកដំណើរទាំងនោះ បានឃើញព្រះសញ្ជីវៈមានអាយុ កំពុងត្រាច់ទៅបិណ្ឌបាតហើយ ពួកជនទាំងនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អើ អស្ចារ្យណាស់ហ្ន៎ អើ មិនដែលមានទេហ្ន៎ សមណៈនេះអង្គុយធ្វើមរណកាលទៅហើយ ឥឡូវសមណៈនេះត្រឡប់មានសញ្ញាបិតនៅវិញ ។ ម្នាលមារមានចិត្តបាប ដោយហេតុនេះ ព្រះសញ្ជីវៈមានអាយុ មានឈ្មោះថា សញ្ជីវៈ សញ្ជីវៈ កើតឡើងយ៉ាងនេះឯង ។

[២០០] ម្នាលមារមានចិត្តបាប គ្រានោះ ទូសីមារមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញមិនបានដឹងដំណើរមក និងដំណើរទៅរបស់ពួកភិក្ខុដែលមានសីល មានកល្យាណធម៌ទាំងនេះសោះឡើយ បើដូច្នោះគួរតែអាត្មាអញ ចូលជ្រែកសរីរៈពួកព្រាហ្មណ៍និងគហបតីថា អ្នក

ឯថ តុម្ហេ ភិក្ខូ សីលវន្តេ កល្យាណធម្មេ អក្កោសថ បរិភាសថ រោសេថ វិហេសេថ អប្បេវ នាម តុម្ហេហិ អក្កោសិយមានានំ បរិភាសិយមានានំ រោសិយមា-នានំ វិហេសិយមានានំ សិយា ចិត្តស្ស អញ្ញថត្តំ យថា តំ ទូសី មារោ លភេថ ឱតារន្តិ ។ អថខោ[១] ចាបិម ទូសី មារោ ព្រាហ្មណគហបតិកេ អន្វាវិសិ ឯថ តុម្ហេ ភិក្ខូ សីលវន្តេ កល្យាណធម្មេ អក្កោសថ បរិភាសថ រោសេថ វិហេសេថ អប្បេវ នាម តុម្ហេហិ អក្កោសិយមានានំ បរិភាសិយមានានំ រោសិយមា-នានំ វិហេសិយមានានំ សិយា ចិត្តស្ស អញ្ញថត្តំ យថា តំ ទូសី មារោ លភេថ ឱតារន្តិ ។ អថខោ តេ ចាបិម ព្រាហ្មណគហបតិកា អន្វាវិសិដ្ឋា[២] ទូសិនា មារេន ភិក្ខូ សីលវន្តេ កល្យាណធម្មេ អក្កោសេន្តិ បរិភាសេន្តិ រោសេន្តិ វិហេសេន្តិ ឥមេ បន មុណ្ឌកា សមណកា ឥព្ភា កណ្ហា ពន្ធុបាទាបច្ចា ឈាយិ-នោស្មា ឈាយិនោស្មាតិ បត្តក្ខន្ធា អធោមុខា

១ ឱ. ម. ឯត្ថន្តរេ តេតិ បទំ ទិស្សតិ ។ ២ ឱ. អន្វាវិដ្ឋា ។

ចូឡយមកវគ្គ មារតជ្ជនីយសូត្រ សេចក្តីបរិវិតក្កនៃមារ

ទាំងឡាយ ចូរមក ចូរជេរ គម្រាម ប្រទូស្ត បៀតបៀនពួកភិក្ខុដែលមានសីល មានធម៌ជាកុសល គិតដូចម្តេច នឹងធ្វើចិត្តរបស់ពួកភិក្ខុដែលពួកអ្នកជេរ គម្រាម ប្រទូស្ត បៀតបៀនហើយនោះឲ្យរាយមាយ ល្មមឲ្យទូសីមារបានឱកាសនោះ ។ ម្នាលមារមានចិត្តបាប គ្រានោះ ទូសីមារ បានចូលជ្រែកសរីរៈពួកព្រាហ្មណ៍និងគហបតីថា អ្នកទាំងឡាយ ចូរមក ចូរជេរ គម្រាម ប្រទូស្ត បៀតបៀនពួកភិក្ខុដែលមានសីល មានធម៌ជាកុសល គិតដូចម្តេចនឹងធ្វើចិត្តរបស់ពួកភិក្ខុ ដែលពួកអ្នកជេរ គម្រាម ប្រទូស្ត បៀតបៀនហើយនោះ ឲ្យរាយមាយ ល្មមឲ្យទូសីមារ បានឱកាសនោះ ។ ម្នាលមារមានចិត្តបាប ពួកព្រាហ្មណ៍និងគហបតីនោះ ដែលទូសីមារ ចូលជ្រែកសរីរៈហើយ ទើបនាំគ្នាជេរ គម្រាម ប្រទូស្ត បៀតបៀនពួកភិក្ខុដែលមានសីល មានធម៌ជាកុសលថា ពួកសមណៈមានក្បាលរលីងទាំងនេះ ជាគហបតី ជាកណ្ហគោត្រ កើតអំពីបាទាព្រហ្ម មានកឱនចុះ មានមុខសំយុងចុះ មានអាការ

មធុរកជាតា ឈាយន្តិ បជ្ឈាយន្តិ និជ្ឈាយន្តិ អបជ្ឈាយន្តិ ។ សេយ្យថាបិ នាម ឧលូកោ រុក្ខ-សាខាយំ មូសិកំ មគ្គយមានោ ឈាយតិ បជ្ឈា-យតិ និជ្ឈាយតិ អបជ្ឈាយតិ ឯវមេវិមេ មុណ្ឌកា សមណកា ឥត្ថា កណ្ហា ពន្ធុបាទាបច្ចា ឈាយិ-នោស្មា ឈាយិនោស្មាតិ បត្តក្ខន្ធា អធោមុខា មធុរកជាតា ឈាយន្តិ បជ្ឈាយន្តិ និជ្ឈាយន្តិ អបជ្ឈាយន្តិ ។ សេយ្យថាបិ នាម កោដ្ឋោ[១] នទីតីរេ មច្ឆេ មគ្គយមានោ ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អបជ្ឈាយតិ ឯវមេវិមេ មុណ្ឌកា សមណកា ឥត្ថា កណ្ហា ពន្ធុបាទាបច្ចា ឈាយិនោស្មា ឈាយិនោស្មាតិ បត្តក្ខន្ធា អធោមុខា មធុរកជាតា ឈាយន្តិ បជ្ឈា-យន្តិ និជ្ឈាយន្តិ អបជ្ឈាយន្តិ ។ សេយ្យថាបិ នាម វិឡារោ សន្ធិសមលសង្កដីរេ មូសិកំ មគ្គយមានោ ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អបជ្ឈាយតិ ឯវមេវិមេ មុណ្ឌកា សមណកា ឥត្ថា កណ្ហា ពន្ធុបាទាបច្ចា

---

១ ឱ. ម. កោដ្ឋុ ។

ដូចជាមធុរកជាតិ គឺជាតិអ្នកខ្ជិលច្រអូស តែងសញ្ជប់សញ្ជឹង សំកុក ជ្រប់នៅដោយគិតថា យើងទាំងឡាយជាអ្នកមានឈាន យើងទាំងឡាយជាអ្នកមានឈាន ដូច្នេះ ។ ដូចជាសត្វមៀមស្វែងរកកណ្ដុរលើមែកឈើ តែងសញ្ជប់សញ្ជឹង សំកុក ជ្រប់នៅយ៉ាងណា ពួកសមណៈមានក្បាលរលីងជាគហបតី ជាកណ្ហគោត្រ ជាអ្នកកើតអំពីបាទាព្រហ្មនេះ មានកឱនចុះ មានមុខសំយុងចុះ មានអាការដូចមធុរកជាតិ តែងសញ្ជប់សញ្ជឹង សំកុក ជ្រប់នៅ ដោយគិតថា យើងទាំងឡាយជាអ្នកមានឈាន យើងទាំងឡាយជាអ្នកមានឈាន ដូច្នេះ ក៏យ៉ាងនោះ ។ ឬដូចជាសត្វចចក ស្វែងរកត្រីក្បែរឆ្នេរស្ទឹង តែងសញ្ជប់សញ្ជឹងសំកុកជ្រប់នៅយ៉ាងណា ពួកសមណៈមានក្បាលរលីងទាំងនេះ ជាគហបតី ជាកណ្ហគោត្រ ជាអ្នកកើតអំពីបាទាព្រហ្ម មានកឱនចុះ មានមុខសំយុងចុះ មានអាការដូចមធុរកជាតិ តែងសញ្ជប់សញ្ជឹង សំកុក ជ្រប់នៅដោយគិតថា យើងទាំងឡាយជាអ្នកមានឈាន យើងទាំងឡាយជាអ្នកមានឈានដូច្នេះ ក៏យ៉ាងនោះដែរ ។ ឬក៏ដូចជាសត្វឆ្មា ស្វែងរកកណ្ដុរទៀបជញ្ជាំងផ្ទះ និងទសម្រាប់បង្ហូរទឹកសំអុយ និងគំនរសម្រាម តែងសញ្ជប់សញ្ជឹង សំកុក ជ្រប់នៅយ៉ាងណា ពួកសមណៈមានក្បាលរលីងទាំងនេះ ជាគហបតី ជាកណ្ហគោត្រ កើតអំពីបាទាព្រហ្ម

៣៨៧

ចូឡយមករវគ្គស្ស មារតជ្ជនីយសុត្តេ គទ្រភោបមា

ឈាយិនោស្នា ឈាយិនោស្នាតិ បត្តក្ខន្ធា អធោមុខា មធុរកជាតា ឈាយន្តិ បជ្ឈាយន្តិ និជ្ឈាយន្តិ អ-បជ្ឈាយន្តិ ។ សេយ្យថាបិ នាម គទ្រភោ វហាច្ឆិន្នោ សន្ធិសមលសង្កដីរេ ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អបជ្ឈាយតិ ឯវមេវិមេ មុណ្ឌកា សមណកា ឥព្ភា កណ្ហា ពន្ធុបាទាបច្ចា ឈាយិនោស្នា ឈាយិនោស្នាតិ បត្តក្ខន្ធា អធោមុខា មធុរកជាតា ឈាយន្តិ បជ្ឈា-យន្តិ និជ្ឈាយន្តិ អបជ្ឈាយន្តីតិ ។ យេ ខោ បន ចាបិម តេន សមយេន មនុស្សា កាលំ ករោន្តិ យេភុយ្យេន កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។

មានកសំយុងចុះ មានមុខឱនចុះ មានអាការដូចមធុរកជាតិ តែងសញ្ចប់ សញ្ចឹង សំកុក ជ្រប់នៅដោយគិតថា យើងទាំងឡាយជាអ្នកមានឈាន យើងទាំងឡាយជាអ្នកមានឈានដូច្នេះ ក៏យ៉ាងនោះដែរ ។ ពុំនោះដូចជាសត្វលាដែលអស់សន្ទុះ (អស់ដើង) ហើយ តែងសញ្ចប់សញ្ចឹង សំកុក ជ្រប់នៅទៀបជញ្ជាំងផ្ទះ និងទីសម្រាប់បង្ហូរទឹកសំអុយ និងគំនរសម្រាម យ៉ាងណា ពួកសមណៈ មានក្បាលរលីងទាំងនេះ ជាគហបតី ជាកណ្ហគោត្រ ជាអ្នកកើតអំពីបាទាព្រហ្ម មានកឱនចុះ មានមុខសំយុងចុះ មានអាការដូចមធុរកជាតិ តែងសញ្ចប់សញ្ចឹង សំកុក ជ្រប់នៅដោយគិតថា យើងទាំងឡាយជាអ្នកមានឈាន យើងទាំងឡាយជាអ្នកមានឈានដូច្នេះ ក៏យ៉ាងនោះដែរ ។ ម្នាលមារមានចិត្តបាប ក៏ឯពួកមនុស្សណា ដែលធ្វើមរណកាលក្នុងសម័យនោះ ពួកមនុស្សទាំងនោះ លុះទម្លាយកាយបន្ទាប់អំពីមរណៈ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត-វិស័យ អសុរកាយ និងនរក ដោយច្រើន ។

[២០១] អថខោ ចាហំ ភិក្ខវេ កកចូបមំ ភគវា អរហំ សម្មាសម្ពុទ្ធោ ភិក្ខូ អាមន្តេសិ អឞ្ញាវិសិដ្ឋា ខោ ភិក្ខវេ ព្រាហ្មណគហបតិកា ឧសិជា មាវេដ ឯថ តុម្ហេ ភិក្ខូ សីលវន្តេ កល្យាណធម្មេ អក្កោសថ បរិភាសថ រោសេថ វិហេសេថ អប្បេវ នាម តុម្ហេហិ អក្កោសិយមានា បរិភាសិយមានា រោសិយមានា- នំ វិហេសិយមានានំ សិយា ចិត្តស្ស អញ្ញថត្តំ យថា នំ ឧសី មារោ លភេថ ឱតារន្តិ ឯថ តុម្ហេ ភិក្ខវេ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរថ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាស- ហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរថ ។ ករុណាស- ហគតេន ចេតសា... មុទិតាសហគតេន ចេតសា... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរថ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ

[២០១] ម្នាលមារមានចិត្តបាប គ្រានោះ ព្រះមានព្រះភាគទ្រង់ព្រះនាមកកុសន្ធៈ អរហន្តសម្មាសម្ពុទ្ធ បានត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍និងគហបតី ដែលទូសីមារចូលជ្រែកសរីរៈហើយថា អ្នកទាំងឡាយចូរមក ចូរជេរ គម្រាម ប្រទូស្ត បៀតបៀនភិក្ខុទាំងឡាយដែលមានសីល មានធម៌ជាកុសល គិតដូចម្តេចនឹងធ្វើចិត្តរបស់ពួកភិក្ខុ ដែលពួកអ្នកជេរ គម្រាម ប្រទូស្ត បៀតបៀនហើយនោះល្មមឲ្យរាយមាយ ឲ្យទូសីមារបានឱកាសនោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមក ចូរមានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ ជារូបាវចរនិងអរូបាវចរប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកដែលមានសត្វទាំងអស់ ដោយយកខ្លួនឯងប្រៀបនឹងសត្វទាំងអស់ ក្នុងទីទាំងពួង គឺទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសជុំវិញដោយប្រការដូច្នេះ ។ អ្នកទាំងឡាយចូរមានចិត្តប្រកបដោយករុណា... មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា... ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា

តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរថាតិ ។ អថខោ តេ ចាបិម ភិក្ខូ កកុសន្ធេន ភគវតា អរហតា សម្មាសម្ពុទ្ធេន ឯវំ ឱវទិយមានា ឯវំ អនុសាសិយមានា អរញ្ញគតាបិ រុក្ខមូលគតាបិ សុញ្ញាគារគតាបិ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរឹសុ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរឹសុ ។ ករុណាសហគតេន ចេតសា... មុទិតាសហគតេន ចេតសា... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរឹសុ តថា ទុតិយំ តថា តតិយំ

ចូរមានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ជារូបាវចរនិងអរូបាវចរ មានប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកដែលមានសត្វទាំងអស់ ដោយយកខ្លួនឯងប្រៀបនឹងសត្វទាំងអស់ ក្នុងទីទាំងពួង គឺទិសខាងលើ ទិសខាងក្រោមនិងទិសទទឹង គឺទិសជុំវិញ ដោយប្រការដូច្នេះ ។ ម្នាលមារមានចិត្តបាប កាលព្រះមានព្រះភាគទ្រង់ព្រះនាមកកុសន្ធៈ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះហើយ ទើបពួកភិក្ខុទាំងនោះទៅនៅក្នុងព្រៃខ្លះ ទៅនៅក្រោមម្លប់ឈើខ្លះ ទៅនៅក្នុងសុញ្ញាគារដ្ឋានខ្លះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ ជារូបាវចរនិងអរូបាវចរ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកដែលមានសត្វទាំងអស់ ដោយយកខ្លួនឯងប្រៀបនឹងសត្វទាំងអស់ ក្នុងទីទាំងពួង គឺទិសខាងលើ ទិសខាងក្រោម និងទិសទទឹងគឺទិសជុំវិញ ដោយប្រការដូច្នេះ ។ ពួកភិក្ខុទាំងនោះ មានចិត្តប្រ-កបដោយករុណា... មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា

តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរឹសុ ។

[២០២] អថខោ បាបិម ទូសិស្ស មារស្ស ឯតទហោសិ ឯវម្បិ ខោ អហំ ករោន្តោ ឥមេសំ ភិក្ខូនំ សីលវន្តានំ កល្យាណធម្មានំ នេវ ជានាមិ អាគតឹ វា គតឹ វា យន្នូនាហំ ព្រាហ្មណគហបតិកេ អន្វាវិសេយ្យំ ឯថ តុម្ហេ ភិក្ខូ សីលវន្តេ កល្យាណធម្មេ សក្ករោថ គរុករោថ មានេថ បូជេថ អប្បេវ នាម តុម្ហេហិ សក្ករិយមានានំ គរុករិយមានានំ មានិយមានានំ បូជិយមានានំ សិយា ចិត្តស្ស អញ្ញថត្តំ យថា នំ ទូសី មារោ លភេថ ឱតារន្តិ ។ អថខោ តេ បាបិម ទូសី មារោ ព្រាហ្មណគហបតិកេ អន្វាវិសិ ឯថ តុម្ហេ ភិក្ខូ សីលវន្តេ កល្យាណធម្មេ សក្ករោថ គរុករោថ មានេថ បូជេថ អប្បេវ នាម

ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ជារូបាវចរនិង អរូបាវចរ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយ ទៅកាន់លោកដែលមានសត្វទាំងអស់ ដោយយកខ្លួនឯងប្រៀបនឹងសត្វ ទាំងអស់ ក្នុងទីទាំងពួង គឺទិសខាងលើ ទិសខាងក្រោម និងទិស ទទឹងគឺទីជុំវិញ ដោយប្រការដូច្នេះ ។

[២០២] ម្នាលមារមានចិត្តបាប គ្រានោះ ទូសីមារមានសេចក្តី ត្រិះរិះយ៉ាងនេះថា កាលបើអាត្មាអញធ្វើយ៉ាងនេះ មិនបានដឹងដំណើរ មកនិងដំណើរទៅ របស់ពួកភិក្ខុដែលមានសីល មានធម៌ជាកុសលទាំង នេះឡើយ បើដូច្នោះ គួរតែអាត្មាអញចូលជ្រែកសរីរៈ ពួកព្រាហ្មណ៍និង គហបតីថា អ្នកទាំងឡាយ ចូរមកធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់-អាន បូជាពួកភិក្ខុដែលមានសីល មានធម៌ជាកុសល គិតដូចម្តេចនឹង ធ្វើចិត្តពួកភិក្ខុ ដែលពួកអ្នកធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជា ឲ្យរាយមាយ ល្មមឲ្យទូសីមារបានឱកាសនោះ ។ ម្នាលមារមានចិត្តបាប គ្រានោះ ទូសីមារចូលជ្រែកសរីរៈ ពួកព្រាហ្មណ៍និងគហបតីទាំងនោះថា អ្នកទាំងឡាយ ចូរមកធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជាពួក ភិក្ខុដែលមានសីល មានធម៌ជាកុសល គិតដូចម្តេច នឹងធ្វើចិត្តពួកភិក្ខុ

តុម្ហេហិ សក្ការិយមានានំ គរុការិយមានាំ មានិយមា-
នានំ បូជិយមានានំ សិយា ចិត្តស្ស អញ្ញថត្តំ យថា
នំ ទូសី មារោ លភេថ ឱតារន្តិ ។ អថខោ តេ បាបិម
ព្រាហ្មណគហបតិកា អន្វាវិសិដ្ឋា ទូសិនា មារេន
ភិក្ខូ សីលវន្តេ កល្យាណធម្មេ សក្ករោន្តិ គរុករោន្តិ
មានេន្តិ បូជេន្តិ ។ យេ ខោ បន បាបិម តេន
សមយេន មនុស្សា កាលំ ករោន្តិ យេភុយ្យេន
កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ
ឧបបជ្ជន្តិ ។

[២០៣] អថខោ បាបិម កកុសន្ធោ ភគវា
អរហំ សម្មាសម្ពុទ្ធោ ភិក្ខូ អាមន្តេសិ អន្វាវិសិដ្ឋា
ខោ ភិក្ខវេ ព្រាហ្មណគហបតិកា ទូសិនា មារេន
ឯថ តុម្ហេ ភិក្ខូ សីលវន្តេ កល្យាណធម្មេ សក្ក-
រោថ គរុករោថ មានេថ បូជេថ អប្បេវ នាម តុម្ហេ-
ហិ សក្ការិយមានានំ គរុការិយមានានំ មានិយមា-
នានំ បូជិយមានានំ សិយា ចិត្តស្ស អញ្ញថត្តំ យ-
ថា នំ ទូសី មារោ លភេថ ឱតារន្តិ ។ ឯថ

ដែលពួកអ្នកធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជា ឲ្យរាយមាយ ល្មមឲ្យទូសីមារបានឱកាសនោះ ។ ម្នាលមារមានចិត្តបាប ពួកព្រាហ្មណ៍ និងគហបតី ដែលទូសីមារចូលជ្រែកសរីរៈហើយនោះ ទើបនាំគ្នាធ្វើ សក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជាពួកភិក្ខុដែលមានសីល មាន ធម៌ជាកុសល ។ ម្នាលមារមានចិត្តបាប ក៏ពួកមនុស្សណា ធ្វើមរណៈ-កាលក្នុងសម័យនោះ ពួកមនុស្សទាំងនោះ លុះទម្លាយកាយខាងមុខ បន្ទាប់អំពីមរណៈ ក៏បានទៅកាន់សុគតិ សួគ៌ ទេវលោក ។

[២០៣] ម្នាលមារមានចិត្តបាប ព្រះមានព្រះភាគ ទ្រង់ព្រះ នាមកកុសន្ធៈអរហន្តសម្មាសម្ពុទ្ធ បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាល ភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍និងគហបតី ដែលទូសីមារ ចូលជ្រែក សរីរៈថា អ្នកទាំងឡាយ ចូរមកធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជាពួកភិក្ខុដែលមានសីល មានធម៌ជាកុសល គិតដូចម្តេច នឹងធ្វើចិត្ត របស់ពួកភិក្ខុដែលពួកអ្នកធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជា ឲ្យរាយមាយ ល្មមឲ្យទូសីមារ បានឱកាសនោះ ។ ម្នាលភិក្ខុទាំងឡាយ

តុម្ហេ ភិក្ខវេ អសុភានុបស្សី[១] កាយេ វិហរថ អាហារេ បដិក្កូលសញ្ញិនោ សព្វលោកេ អនភិរតសញ្ញិនោ សព្វសង្ខារេសុ អនិច្ចានុបស្សិនោតិ ។ អថខោ តេ ចាបិម ភិក្ខូ កកុសន្ធេន ភគវតា អរហតា សម្មាសម្ពុទ្ធេន ឯវំ ឱវទិយមានា ឯវំ អនុសាសិយមានា អរញ្ញគតាបិ រុក្ខមូលគតាបិ សុញ្ញាគារគតាបិ អសុភានុបស្សី កាយេ វិហរឹសុ អាហារេ បដិក្កូលសញ្ញិនោ សព្វលោកេ អនភិរតសញ្ញិនោ សព្វសង្ខារេសុ អនិច្ចានុបស្សិនោ ។

[២០៤] អថខោ ចាបិម កកុសន្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ អាយស្មតា វិធុរេន បច្ឆាសមណេន គាមំ បិណ្ឌាយ បាវិសិ ។ អថខោ ចាបិម ទូសី មារោ អញ្ញតរំ កុមារកំ[២] អន្វាវិសិត្វា សក្ខរំ គហេត្វា អាយស្មតោ វិធុរស្ស សីសេ បហារមទាសិ សីសំ ភេ[៣] ភិន្ទិ ។ អថខោ ចាបិម អាយស្មា វិធុរោ ភិន្នេន សីសេន លោហិតេន គឡន្តេន កកុសន្ធំ

១ ម. អសុភានុបស្សិនោ ។ ២ ឱ. កុមារំ ។ ៣ ម. តេ ។

អ្នកទាំងឡាយ ចូរមក ចូរពិចារណារឿយ ៗ នូវរបស់មិនស្អាតក្នុងកាយ មានសេចក្ដីសំគាល់គួរខ្ពើមរអើមក្នុងអាហារ មានសេចក្ដីសំគាល់នូវរបស់មិនជាទីត្រេកអរក្នុងលោកទាំងអស់ ពិចារណាឃើញថា មិនទៀង ក្នុងសង្ខារទាំងអស់ ។ ម្នាលមារមានចិត្តបាប គ្រានោះ ពួកភិក្ខុទាំងនោះ កាលបើព្រះមានព្រះភាគព្រះនាមកកុសន្ធៈ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះហើយ ទោះបីទៅនៅក្នុងព្រៃក្ដី ទៅនៅក្រោមម្លប់ឈើក្ដី ទៅនៅក្នុងផ្ទះស្ងាត់ក្ដី ជាអ្នកពិចារណាឃើញរឿយ ៗ នូវរបស់មិនស្អាតក្នុងកាយ មានសេចក្ដីសំគាល់ថា គួរខ្ពើមរអើមក្នុងអាហារ មានសេចក្ដីសំគាល់នូវរបស់មិនជាទីត្រេកអរ ក្នុងលោកទាំងអស់ ជាអ្នកពិចារណាថា មិនទៀងក្នុងសង្ខារទាំងអស់ ។

[២០៤] ម្នាលមារមានចិត្តបាប គ្រានោះ ព្រះមានព្រះភាគព្រះនាមកកុសន្ធៈ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរក្នុងវេលាបុព្វណ្ហសម័យ មានព្រះវិធុរៈមានអាយុជាបច្ឆាសមណៈ ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ម្នាលមារមានចិត្តបាប គ្រានោះ ទូសីមារបានចូលជ្រែកសរីរៈ កូនក្មេងម្នាក់ កាន់យកក្រួសចោលត្រង់សីសៈព្រះវិធុរៈមានអាយុ សីសៈរបស់លោកក៏បែក ។ ម្នាលមារមានចិត្តបាប គ្រានោះ ព្រះវិធុរៈមានអាយុ មានសីសៈបែកចេញឈាម ហូររហាម

យេវ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។ អថខោ បាបិម កកុសន្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ នាគាបលោកិតំ អបលោកេសិ ន វា[១] យំ ទូសី មារោ មត្តមញ្ញាសីតិ ។ សហាបលោកនាយ ច បន បាបិម ទូសី មារោ តម្ហា ច ឋានា ចវិ មហានិរយញ្ច ឧបបជ្ជិ ។

[២០៤] តស្ស ខោ បន បាបិម មហានិរយស្ស តយោ នាមធេយ្យា ហោន្តិ ឆផស្សាយតនិកោ ឥតិបិ សង្កុសមាហតោ ឥតិបិ បច្ចត្តវេទនិយោ ឥតិបិ ។ អថខោ មំ បាបិម និរយបាលា ឧបសង្កមិត្វា ឯតទវោចុំ យទា ខោ តេ មារិស សង្កុនា សង្កុំ ហទយេ សមាគច្ឆេយ្យ អថ នំ ត្វំ ជានេយ្យាសិ[២] វស្សសហស្សំ មេ និរយេ បច្ចមានស្សាតិ ។ សោ ខោ អហំ បាបិម ពហូនិ វស្សានិ ពហូនិ វស្សសតានិ ពហូនិ វស្សសហស្សានិ តស្មឹ មហានិរយេ អបច្ចឹ

---

១ ម. ចា ។ ២ ឱ. អថ នំ អាជានេយ្យាសីតិ ទិស្សតិ ។ ម. អថខោ ត្វំ ជានេយ្យាសីតិ ទិស្សតិ ។

ដើរតាមក្រោយ ៗ ព្រះមានព្រះភាគព្រះនាមកកុសន្ធៈ អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលមារមានចិត្តបាប គ្រានោះ ព្រះមានព្រះភាគព្រះនាមកកុសន្ធៈ អរហន្តសម្មាសម្ពុទ្ធទ្រង់ងាកមើល ដូចជាងាកមើលនៃដំរីថា ទូសីមារនេះ មិនបានដឹងប្រមាណទេ ។ ម្នាលមារមានចិត្តបាប ក៏ឯទូសីមារច្យុត ចាកទីនោះ ទៅកើតក្នុងមហានរក ព្រមដោយការងាកទត (របស់ព្រះកកុសន្ធៈ) ។

[២០៥] ម្នាលមារមានចិត្តបាប ក៏ឯមហានរកនោះឯង មានឈ្មោះ ៣ យ៉ាងគឺ ឆផស្សាយតនិកៈ[១] ១ សង្កុសមាហតៈ[២] ១ បច្ចត្តវេទនីយៈ[៣] ១ ។ ម្នាលមារមានចិត្តបាប គ្រានោះ ពួកនាយនិរយបាលបានចូលទៅរកអាត្មាហើយ និយាយយ៉ាងនេះថា បពិត្រលោកអ្នកនិរទុក្ខ កាលណាដែកស្រួចមកប្រជុំជាមួយនឹងដែកស្រួចត្រង់ហឫទ័យរបស់អ្នកហើយ ទើបអ្នកដឹងនូវហេតុនោះថា អាត្មាអញឆេះក្នុងនរកអស់មួយពាន់ឆ្នាំហើយ ។ ម្នាលមារមានចិត្តបាប អាត្មានោះបានឆេះក្នុងមហានរកនោះ អស់ឆ្នាំជាច្រើន អស់រយឆ្នាំជាច្រើន អស់ពាន់ឆ្នាំជាច្រើន

១ សត្វនរកមានវេទនាផ្សេងជាបច្ច័យ ក្នុងផស្សាយតនៈទាំង ៦ ។ ២ សត្វនរកដែលមានដែកស្រួចចាក់ ។ ៣ សត្វនរកកើតអំពីវេទនារបស់ខ្លួន ។ អដ្ឋកថា ។

ឧសសហស្សានិ[១] តស្សេវ មហានិរយស្ស ឧស្សទេ អបច្ចឹ វុដ្ឋានវេទនំ[២] វេទិយមានោ ។ តស្ស មយ្ហំ ចាបិម ឯវរូបោ កាយោ ហោតិ សេយ្យថាបិ មនុស្សស្ស ឯវរូបំ សីសំ ហោតិ សេយ្យថាបិ មច្ឆស្ស ។

[២០៦] កីទិសោ និរយោ អាសិ
យត្ថ ទុសី អបច្ចត្ថ
វិធុរំ សាវកមាសជ្ជ
កកុសន្ធញ្ច ព្រាហ្មណំ
សតំ អាសិ អយោសង្កុ
សព្វេ បច្ចត្តវេទនា
ឦទិសោ និរយោ អាសិ
យត្ថ ទុសី អបច្ចថ
វិធុរំ សាវកមាសជ្ជ
កកុសន្ធញ្ច ព្រាហ្មណំ
យោ ឯតមភិជានាតិ

១ ឱ. ម. ទសវស្សសហស្សានិ ។ ២ ឱ. ម. វុដ្ឋានិមំ នាម វេទនំ ។

បានឆេះក្នុងឧស្សុទនរក របស់មហានរកនោះឯង ទទួលទុក្ខវេទនាដែលកើតមកអំពីវិបាក អស់មួយហ្មឺនឆ្នាំ ។ ម្នាលមារមានចិត្តបាប ឯកាយរបស់អាត្មានោះ មានសភាពដូចជាក្បាលមនុស្ស ពុំនោះសោត មានសភាពដូចជាក្បាលត្រី ។

[២០៦] ទូសីមារ ដែលបៀតបៀនព្រះវិធុរសាវ័កនិងព្រះកកុសន្ធៈ ជាព្រាហ្មណជាត ហើយឆេះក្នុងនរកដូចម្ដេចទៅ ទូសីមារ ដែលបៀតបៀនព្រះវិធុរសាវ័កនិងព្រះកកុសន្ធៈជាព្រាហ្មណជាតហើយឆេះក្នុងនរក ដែលមានដែកស្រួចច្រើន មានសុទ្ធតែពួកសត្វទទួលទុក្ខវេទនាចំពោះខ្លួនឯង អ្នកឯង

៣៩៤

ចូឡយមកវគ្គស្ស មារតជ្ជនីយសុត្តេ អវសានគាថា

ភិក្ខុ ពុទ្ធស្ស សាវកោ
តាទិសំ ភិក្ខុមាសជ្ជ
កណ្ហាទុក្ខំ និគច្ឆសិ
មជ្ឈេ សរស្ស តិដ្ឋន្តិ
វិមានា កប្បដ្ឋាយិនោ
វេឡុរិយវណ្ណា រុចិរា
អច្ចិមន្តោ បភស្សរា
អច្ឆរា តត្ថ នច្ចន្តិ
បុថូ នានត្តវណ្ណិយោ
យោ ឯតមភិជានាតិ
ភិក្ខុ ពុទ្ធស្ស សាវកោ
តាទិសំ ភិក្ខុមាសជ្ជ

ចូឡយមកវគ្គ មារតជ្ជនីយសូត្រ គាថាជាទីបំផុត

បៀតបៀនភិក្ខុជាពុទ្ធសាវ័កដែលលោកដឹងច្បាស់នូវវិមានវត្ថុ

នុ៎ះហើយនឹងបាននូវសេចក្ដីទុក្ខដ៏ខ្លោ វិមានទាំងឡាយដែល

ឋិតនៅអស់មួយកប្ប មានពណ៌ដូចជាកែវពៃទូរ្យ ដ៏រុង

រឿង ហាក់ដូចជាអណ្ដាតភ្លើង មានពន្លឺភ្លឺផ្ទេកឋិតនៅត្រង់

កណ្ដាលសមុទ្រ មានទាំងពួកស្រីអប្សរជាច្រើន មានខ្លួន

និងសម្បុរផ្សេងគ្នា តែងរេរាំលើវិមាននោះ អ្នកឯងបៀតបៀន

ភិក្ខុជាពុទ្ធសាវ័កដែលលោកដឹងច្បាស់នូវវិមានវត្ថុនុ៎ះ ហើយ

កណ្ហាទុក្ខំ និគច្ឆសិ
យោ វេ ពុទ្ធេន ចុទិតោ
ភិក្ខុសង្ឃស្ស បេក្ខតោ
មិគារមាតុ បាសាទំ
បាទង្គុដ្ឋេន កម្បយិ
យោ ឯតមភិជានាតិ
ភិក្ខុ ពុទ្ធស្ស សាវកោ
តាទិសំ ភិក្ខុមាសជ្ជ
កណ្ហាទុក្ខំ និគច្ឆសិ
យោ វេជយន្តបាសាទំ
បាទង្គុដ្ឋេន កម្បយិ
ឥទ្ធិពលេន បត្ថទ្ធោ[១]
សំវេជេសិ ច ទេវតា
យោ ឯតមភិជានាតិ
ភិក្ខុ ពុទ្ធស្ស សាវកោ
តាទិសំ ភិក្ខុមាសជ្ជ

១ ឱ. ម. ឥទ្ធិពលេនុបត្ថទ្ធោ ។

រមែងបាននូវសេចក្តីទុក្ខដ៏ខ្មៅ ភិក្ខុណាមួយ ដែលព្រះពុទ្ធជាម្ចាស់ ដាស់តឿនហើយ ធ្វើមិគារមាតុប្រាសាទរបស់ភិក្ខុសង្ឃដែលកំពុងសំឡឹងមើល ឲ្យញាប់ញ័រ ដោយចុងម្រាមជើងបាន អ្នកឯងបៀតបៀនភិក្ខុជាពុទ្ធសាវ័កដែលលោកដឹងច្បាស់នូវវិមានវត្ថុនុ៎ះហើយ រមែងបាននូវសេចក្តីទុក្ខដ៏ខ្មៅ ភិក្ខុណាបានធ្វើវេជយន្តប្រាសាទ ឲ្យញាប់ញ័រដោយចុងម្រាមជើងបាន ជាអ្នកមាំមួនដោយកម្លាំងឫទ្ធិ អាចធ្វើទេវតាទាំងឡាយឲ្យសង្វេគបាន អ្នកឯងបៀតបៀនភិក្ខុជាពុទ្ធសាវ័កដែលលោកដឹងច្បាស់នូវវេជយន្តប្រាសាទនុ៎ះហើយ រមែងបាន

៣៩៧

ចូឡយមកវគ្គស្ស មារតជ្ជនីយសុត្តេ អវសានគាថា

កណ្ហាទុក្ខំ និកច្ឆសិ
យោ វេជយន្តចាសាទេ
សក្កំ សោ បរិបុច្ឆតិ
អបិ អាវុសោ ជានាសិ
តណ្ហាក្ខយវិមុត្តិយោ
តស្ស សក្កោ វិយាកាសិ
បញ្ហំ បុដ្ឋោ យថាកថំ
យោ ឯតមភិជានាតិ
ភិក្ខុ ពុទ្ធស្ស សាវកោ
តាទិសំ ភិក្ខុមាសជ្ជ
កណ្ហាទុក្ខំ និកច្ឆសិ
យោ ព្រហ្មានំ[១] បរិបុច្ឆតិ

១ ម. ព្រហ្មំ ។

នូវសេចក្តីទុក្ខដ៏ខ្មៅ ភិក្ខុណា សាកសួរប្រស្នានឹងព្រះឥន្ទ លើវេជយន្តប្រាសាទថា ម្នាលអាវុសោ អ្នកស្គាល់តណ្ហក្ខ-យវិមុត្តិឬទេ ព្រះឥន្ទដែលភិក្ខុនោះសួរប្រស្នាហើយ ក៏ដោះស្រាយតាមដំណើរពាក្យរបស់ភិក្ខុនោះ អ្នកឯងបៀតបៀននូវភិក្ខុជាពុទ្ធសាវ័ក ដែលដឹងច្បាស់នូវហេតុនុ៎ះហើយ រមែងបាននូវសេចក្តីទុក្ខដ៏ខ្មៅ ភិក្ខុណាសាកសួរប្រស្នានឹងព្រហ្ម

សុធម្មាយំ អភិតោសភំ
អជ្ជាបិ តេ អាវុសោ[១] ទិដ្ឋិ
យា តេ ទិដ្ឋិ បុរេ អហុ
បស្សសិ វីតិវត្តន្តំ
ព្រហ្មលោកេ បភស្សរំ
តស្ស ព្រហ្មា វិយាកាសិ
អនុបុព្វំ យថាកថំ
ន មេ មារិស សា ទិដ្ឋិ
យា មេ ទិដ្ឋិ បុរេ អហុ
បស្សាមិ វីតិវត្តន្តំ
ព្រហ្មលោកេ បភស្សរំ
សោហំ អជ្ជ កថំ វជ្ជំ
អហំ និច្ចោម្ហិ សស្សតោ
យោ ឯតមភិជានាតិ
ភិក្ខុ ពុទ្ធស្ស សាវកោ
តាទិសំ ភិក្ខុមាសជ្ជ

---

១ ម. ត្យាវុសោ ។

ជិតសាលាឈ្មោះសុធម្មា[១] ថា ម្នាលអាវុសោ សព្វថ្ងៃនេះ អ្នកឯងនៅមានទិដ្ឋិដូចជាពីថ្ងៃមុនដែរឬ អ្នកបានឃើញពន្លឺ (ព្រះមានព្រះភាគ) ដែលភ្លឺផ្ទេក កន្ទង់សត្វក្នុងព្រហ្មលោកដែរឬទេ ព្រហ្មក៏បានដោះស្រាយ តាមលំដាប់ពាក្យរបស់ភិក្ខុនោះថា បពិត្រលោកអ្នកនិរទុក្ខ ខ្ញុំមិនមានទិដ្ឋិដូចពីថ្ងៃមុនទេ ខ្ញុំបានឃើញពន្លឺ (ព្រះមានព្រះភាគ) ដែលភ្លឺផ្ទេក កន្ទង់សត្វក្នុងព្រហ្មលោកដែរ ថ្ងៃនេះខ្ញុំបានពោលពាក្យថា ខ្ញុំជាបុគ្គលទៀងទាត់ ឥតប្រែប្រួលឡើយ អ្នកឯងបៀតបៀននូវភិក្ខុជាពុទ្ធសាវ័ក ដែលលោកដឹងច្បាស់នូវ

---

១ សាលាសុធម្មាក្នុងព្រហ្មលោក មិនមែនសាលាសុធម្មាក្នុងជាន់តាវត្តិង្សទេ ។

៣៩៩

ចូឡយមកវគ្គស្ស មារតជ្ជនីយសុត្តេ អវសានគាថា

កណ្ហាទុក្ខំ និគច្ឆសិ
យោ មហានេរុនោ កូដំ
វិមោក្ខេន អផស្សយិ
វនំ បុព្វវិទេហានំ
យេ ច ភូមិសយា នរា
យោ ឯតមភិជានាតិ
ភិក្ខុ ពុទ្ធស្ស សាវកោ
តាទិសំ ភិក្ខុមាសជ្ជ
កណ្ហាទុក្ខំ និគច្ឆសិ
ន វេ អគ្គិ ចេតយតិ
អហំ ពាលំ ឌហាមិតិ
ពាលោ ច ជតិលំ[១] អគ្គឹ
អាសជ្ជន ស[២] ឌយ្ហតិ
ឯវមេវ តុវំ មារ
អាសជ្ជន តថាគតំ
សយំ ឌហិស្សសិ អត្តានំ

១ ឱ. ម. ជលិតំ ។ ២ ម. ឧ ។

ហេតុនុ៎ះ ហើយរមែងបាននូវសេចក្តីទុក្ខដ៏ខ្មៅ ភិក្ខុណា បានប៉ះពាល់កំពូលភ្នំមហាសិនេរុ ប៉ះពាល់នូវជម្ពូទ្វីប បុព្វវិទេហទ្វីប និងពួកជនដែលដេកលើផែនដី[១] ដោយឈានវិមោក្ខ អ្នកឯងបៀតបៀននូវភិក្ខុជាពុទ្ធសាវ័ក ដែលលោកដឹងច្បាស់នូវហេតុនុ៎ះ ហើយរមែងបាននូវសេចក្តីទុក្ខដ៏ខ្មៅប្រៀបដូចជាភ្លើងមិនដែលគិតថា អាត្មាអញនឹងឆេះមនុស្សពាលម្តងឡើយ តែមនុស្សពាលចេះតែមកប៉ះពាល់ភ្លើងដែលកំពុងឆេះសន្ធោ ភ្លើងនោះក៏ឆេះទៅ (យ៉ាងណា) ម្នាលមារ អ្នកឯងបៀតបៀនព្រះតថាគត គង់នឹងឆេះខ្លួនដោយខ្លួនឯង ដូចជា

---

១ ពួកជនដែលដេកលើផែនដីនោះ គឺពួកជនក្នុងអបរគោយានទ្វីប និងឧត្តរកុរុទ្វីប ។ អដ្ឋកថា។

ពាលោ អគ្គឹវ សម្ផុសំ
អបុញ្ញំ បសវិ មារោ
អាសជ្ជន តថាគតំ
កិន្នុ មញ្ញសិ បាបិម
ន មេ បាបំ វិបច្ចតិ
ករោតោ ចីយតិ បាបំ
ចិររត្តាយ កន្ទតិ(១)
មារ និព្វិន្ទ ពុទ្ធម្ហា
អាសម្មាកាសិ ភិក្ខុសុ
ឥតិ មារំ អត្តជ្ជេសិ(២)
ភិក្ខុ ភេសកឡាវនេ
តតោ សោ ទុម្មនោ យក្ខោ
តត្ថេវន្តរធាយថាតិ(៣) ។

មារតជ្ជនីយសុត្តំ ទសមំ និដ្ឋិតំ ។

ចូឡយមកវគ្គោ បញ្ចមោ ។

---

១ ឱ. ម. អន្តក ។ ២ ឱ. អយដ្ដេសិ ។ ម. អត្តេជ្ជសិ ។ ៣ ម. តត្ថេវន្តរធាយតីតិ ។

បុគ្គលពាលប៉ះពាល់ភ្លើង យ៉ាងនោះដែរ មារបើបៀតបៀនព្រះតថាគតហើយ គង់នឹងបានបាបពុំខាន ម្នាលមារមានចិត្តបាប អ្នកឯងស្មានថាបាបមិនឲ្យផលដល់អាត្មាអញឬដូចម្ដេច បាបពិតជាឲ្យផលដល់អ្នកធ្វើបាប ឯបុគ្គលបាប រមែងកន្ទក់កន្ទេញអស់កាលយូរអង្វែង ម្នាលមារ អ្នកឯងគេចចេញពីព្រះពុទ្ធទៅ កុំនៅបៀតបៀនពួកភិក្ខុឡើយ ភិក្ខុគឺមហាមោគ្គល្លាន បានគម្រាមមារក្នុងព្រៃភេសកឡាវ័ន ដូចបានរៀបរាប់មកនេះឯង លំដាប់នោះ យក្សគឺមារនោះឯង ក៏មានចិត្តអាក់អន់ហើយ ស្រាប់តែបាត់ពីទីនោះទៅមួយរំពេច ។

ចប់ មារតជ្ជនីយសូត្រ ទី ១០ ។

ចប់ ចូឡយមកវគ្គ ទី ៥ ។

ចូឡយមកវគ្គស្ស មារតជ្ជនីយសុត្តេ ឧទ្ទានគាថា

# តស្សុទ្ទានំ

# សាលេយ្យវេរញ្ជវេទល្ល

# ចូឡមហាធម្មសមាទានំ

# វីមំសកា ច ព្រហ្មា ទូសី ច

# មារោ បញ្ចមោ វវគ្គោ[១] ។

មូលបណ្ណាសកំ និដ្ឋិតំ ។

---

១ ឱរោបិយបោត្ថកេ

តស្សុទ្ទានំ

សាលេយ្យវេរញ្ជវេទល្ល ចូឡមហាធម្មសមាទានំ
វីមំសកា ច ព្រហ្មា ទូសី ច មារោ បញ្ចមោ វវគ្គោតិ ន ទិស្សតិ ។

មរម្មបោត្ថកេ

តស្ស វគ្គស្សុទ្ទានំ

សាលេយ្យវេរញ្ជទុវេចតុដ្ឋិ ចូឡមហាធម្មសមាទានំ ច
វីមំសកា កោសម្ពិ ច ព្រាហ្មណោ ទុស្សិ ច មារោ ទសមោ ច វគ្គោ
សាលេយ្យវគ្គោ បញ្ចមោ ។ ឥទំ វគ្គស្សុទ្ទានំ
មូលាបរិយាយោ ចេវ សីហនាទោ ច ឧត្តមោ
កតបោចេវ គោសិង្គោ សាលេយ្យោ ច ឥមេ បញ្ច
មូលបណ្ណាសកំ សមត្តន្តិ ទិស្សតិ ។

ចូឡយមកវគ្គ មារតជ្ជនីយសូត្រ ឧទ្ទានគាថា

*ឧទ្ទាន គឺបញ្ជីរឿងនៃចូឡយមកវគ្គនោះ ដូច្នេះគឺ សាលេយ្យកសូត្រ ១ វេរញ្ជកសូត្រ ១ ចូឡវេទល្លសូត្រ ១ មហាវេទល្លសូត្រ ១ ចូឡធម្មសមាទានសូត្រ ១ មហាធម្ម-សមាទានសូត្រ ១ វីមំសកសូត្រ ១ កោសម្ពិយសូត្រ ១ ព្រហ្មនិមន្តនិកសូត្រ ១ មារតជ្ជនីយសូត្រ ១ ចប់វវគ្គ ជាគម្រប់ ៥ ។*

ចប់ មូលបណ្ណាសកៈ ។

# សុត្តន្តបិដកេ មជ្ឈិមនិកាយស្ស

# មូលបណ្ណាសកំ

# តតិយោ ភាគោ

# មហាយមកវគ្គោ

## បឋមំ ចូឡគោសិង្គសាលសុត្តំ

អង្កេ


មហាយមកវគ្គស្ស ចូឡគោសិង្គសាលសុត្តេ *បដិសន្ថារវុត្តិ*........................ ៣

*អប្បមាទោ*........................... ៥

*ផាសុវិហារោ*........................ ៧

*ធម្មីកថាសន្ទស្សនំ*................ ១៣

*អនុរុទ្ធាទិកិត្តិ*........................ ១៥

*អនុរុទ្ធាទិប្បសំសា*................ ១៧


## ទុតិយំ មហាគោសិង្គសាលសុត្តំ


មហាយមកវគ្គស្ស មហាគោសិង្គសាលសុត្តេ *ពហុស្សុតប្បសំសា*.............. ២១

*ទិព្វចក្ខុប្បសំសា*.................. ២៣

*អភិធម្មកថាបសំសា*............ ២៥

*សមាបត្តិប្បសំសា*................ ២៧

# សុត្តន្តបិដក មជ្ឈិមនិកាយ

# មូលបណ្ណាសក

# តតិយភាគ

# មហាយមកវគ្គ

## *ចូឡគោសិង្គសាលសូត្រទី ១*

លេខទំព័រ


| | | | |
|---|---|---|---|
| មហាយមកវគ្គ | ចូឡគោសិង្គសាលសូត្រ | ការប្រព្រឹត្តនូវបដិសណ្ឋារៈ................ | ៣ |
| | | សេចក្តីមិនប្រមាទ .......................... | ៥ |
| | | ផាសុវិហារធម៌.................................. | ៧ |
| | | ការទ្រង់ពន្យល់ដោយធម្មីកថា........... | ១៣ |
| | | កិត្តិសព្ទនៃព្រះថេរៈមានព្រះអនុរុទ្ធជាដើម | ១៥ |
| | | ការទ្រង់សរសើរព្រះថេរៈមានព្រះអនុរុទ្ធជាដើម............................................ | ១៧ |


## *មហាគោសិង្គសាលសូត្រទី ២*


| | | | |
|---|---|---|---|
| មហាយមកវគ្គ | មហាគោសិង្គសាលសូត្រ | ការសរសើរភិក្ខុជាពហុស្សូត.............. | ២១ |
| | | ការសរសើរទិព្វចក្ខុ............................ | ២៣ |
| | | ការសរសើរអភិធម្មកថា..................... | ២៥ |
| | | ការសរសើរសមាបត្តិ.......................... | ២៧ |

# មាតិកាបត្តានិ

អង្កេ

មហាយមកវគ្គស្ស មហាគោសិង្គសាលសុត្តេ *ពហុស្សុតប្បសំសា*.................. ២៩

*បដិសល្លានារាមប្បសំសា*......... ៣១

*អារញ្ញកាទិប្បសំសា*................ ៣៣

*អភិធម្មកថាបសំសា*................ ៣៥

*សមាបត្តិប្បសំសា*..................... ៣៧

*អាសវក្ខយប្បសំសា*................. ៣៩

## តតិយំ មហាគោបាលសុត្តំ

មហាយមកវគ្គស្ស មហាគោបាលសុត្តេ *វជ្ជ្ជាភព្វតា*.............................. ៤១

*វជ្ជ្ជិភព្វតា*................................ ៤៧

*ភិក្ខុនោ ឯកាទសង្គានិ*............ ៤៩

## ចតុត្ថំ ចូឡគោបាលសុត្តំ

មហាយមកវគ្គស្ស ចូឡគោបាលសុត្តេ *ភូតបុព្វវត្ថុ* ............................... ៥៥

*បញ្ចគោណោបមា*.................. ៥៧

# សន្ទឹកាចង្អុលប្រាប់មាតិកា

លេខទំព័រ

មហាយមកវគ្គ មហាគោសិង្គសាលសូត្រ ការសរសើរភិក្ខុជាពហុស្សូត.............. ២៩
ការសរសើរភិក្ខុដែលរីករាយក្នុងការ
ពួនសម្ងំ.......................................... ៣១
ការសរសើរភិក្ខុអ្នកនៅក្នុងព្រៃជាដើម. ៣៣
ការសរសើរអភិធម្មកថា..................... ៣៥
ការសរសើរសមាបត្តិ......................... ៣៧
ការទ្រង់សរសើរធមិជាទីអស់ទៅ
នៃអាសវៈ........................................ ៣៩

## មហាគោបាលសូត្រ ទី ៣

មហាយមកវគ្គ មហាគោបាលសូត្រ ភាពនៃគង្វាលគោដែលមិនគួរដល់
សេចក្តីចម្រើន.................................. ៤១
ភាពនៃគង្វាលគោដែលគួរដល់សេចក្តីចម្រើន ៤៧
អង្គ ១១ របស់ភិក្ខុ........................... ៤៩

## ចូឡគោបាលសូត្រ ទី ៤

មហាយមកវគ្គ ចូឡគោបាលសូត្រ រឿងធ្លាប់មានមកហើយ.................... ៥៥
ឧបមាដោយគោ ៥ ពួក..................... ៥៧

# មាតិកាបត្តានិ

## បញ្ចមំ ចូឡសច្ចកសុត្តំ

អង្កេ

| | | | |
|---|---|---|---|
| មហាយមកវគ្គស្ស | ចូឡសច្ចកសុត្តេ | *សន្ធាគារេ លិច្ឆវីនំ សន្និបាតោ.* | ៦៣ |
| | | *សច្ចកស្ស ឧបមាវចនំ..............* | ៦៥ |
| | | *ពហុលប្បវត្តានុសាសនី............* | ៦៧ |
| | | *ឧបមាយ បដិបុច្ឆា ..................* | ៧១ |
| | | *តិលក្ខណព្យាករណំ................* | ៧៣ |
| | | *សារត្ថិកូបមា...........................* | ៧៧ |
| | | *ទុម្មុខស្ស ឧបមាវចនំ...............* | ៧៩ |
| | | *អនត្តានុបស្សនា........................* | ៨១ |
| | | *ស្វាតនាយាធិវាសនំ..................* | ៨៥ |
| | | *សុត្តបរិយោសានំ.......................* | ៨៧ |


## ឆដ្ឋំ មហាសច្ចកសុត្តំ

| | | | |
|---|---|---|---|
| មហាយមកវគ្គស្ស | មហាសច្ចកសុត្តេ | *កាយភាវនានុយុញ្ជនំ...............* | ៨៩ |
| | | *អចេលកវត្តានិ.........................* | ៩១ |
| | | *ចិត្តភាវនាកថា.........................* | ៩៣ |

# សង្ខឹកាចង្អុលប្រាប់មាតិកា

## ចូឡសច្ចកសូត្រ ទី ៥

លេខទំព័រ

មហាយមកវគ្គ ចូឡសច្ចកសូត្រ ពួកស្តេចលិច្ឆវីទ្រង់ប្រជុំគ្នាក្នុងសន្ថាគារស្ថាន...... ៦៣

ពាក្យប្រៀបរបស់សច្ចកនិគន្ថបុត្រ...................... ៦៥

ពាក្យប្រៀនប្រដៅដែលប្រព្រឹត្តទៅដោយច្រើន..... ៦៧

ការសាកសួរដោយពាក្យឧបមា.......................... ៧១

ការទ្រង់ព្យាករព្រះត្រៃលក្ខណ៍.......................... ៧៣

ឧបមាដោយអ្នកត្រូវការដោយខ្លឹមឈើ............... ៧៧

ពាក្យឧបមារបស់ទុម្មុខលិច្ឆវិបុត្រ....................... ៧៩

ការពិចារណាសង្ខារថាមិនមែនជាខ្លួន................ ៨១

ការទ្រង់ទទួលនិមន្តដើម្បីឆាន់ក្នុងថ្ងៃស្អែក ........ ៨៥

ទីបំផុតនៃសូត្រ................................................. ៨៧

## មហាសច្ចកសូត្រ ទី ៦

មហាយមកវគ្គ មហាសច្ចកសូត្រ ការប្រកបរឿយ ៗ នូវកាយភាវនា.................... ៨៩

អចេលកវគ្គ..................................................... ៩១

ពោលអំពីចិត្តភាវនា........................................ ៩៣

# មាតិកាបត្តានិ

អង្កេ

មហាយមកវគ្គស្ស មហាសច្ចកសុត្តេ *កាយចិត្តស្ស ភាវិតត្តា.................. ៩៥*

*ពោធិសត្តស្ស បរិវិតក្កនំ............... ៩៧*

*អាឡារូបសង្កមនំ.......................... ៩៩*

*ឧទ្ទកូបសង្កមនំ............................ ១០៣*

*តីសុ បឋមា ឧបមា..................... ១០៧*

*ទុតិយា ឧបមា............................ ១០៩*

*តតិយា ឧបមា............................ ១១១*

*ទុក្ករកិរិយាភេទោ.......................... ១១៣*

*សតានុសារិវិញ្ញាណំ..................... ១២៥*

*តីសុ បឋមា វិជ្ជា......................... ១២៧*

*តីសុ តតិយា វិជ្ជា........................ ១២៩*

*សម្មុឡ្ហាសម្មុឡ្ហតា.......................... ១៣១*

*ភគវតោ បសំសា ......................... ១៣៣*

# សង្ខិតកថជ្ពុលប្រាប់មាតិកា

លេខទំព័រ


| | | | |
|---|---|---|---|
| មហាយមកវគ្គ | មហាសច្ចកសូត្រ | ភារៈនៃកាយនិងចិត្តដែលបុគ្គលបានចម្រើន... | ៩៥ |
| | | សេចក្តីត្រិះរិះរបស់ព្រះពោធិសត្វ.............. | ៩៧ |
| | | ស្តេចចូលទៅរកអាឡារតាបស ............... | ៩៩ |
| | | ស្តេចចូលទៅរកឧទ្ទកតាបស.................... | ១០៣ |
| | | ឧបមាទាំង ៣ ឧបមា ទី ១.................... | ១០៧ |
| | | ឧបមា ទី ២ .......................................... | ១០៩ |
| | | ឧបមា ទី ៣........................................... | ១១១ |
| | | ប្រភេទនៃទុក្ករកិរិយា................................ | ១១៣ |
| | | វិញ្ញាណជាគ្រឿងរលឹកតាមនូវស្មារតី.......... | ១២៥ |
| | | បណ្តាវិជ្ជាទាំង ៣ វិជ្ជាទី ១...................... | ១២៧ |
| | | បណ្តាវិជ្ជាទាំង ៣ វិជ្ជា ទី ៣.................. | ១២៩ |
| | | ភារៈនៃបុគ្គលដែលវង្វេងនិងមិនវង្វេង......... | ១៣១ |
| | | ការពោលសរសើរព្រះមានព្រះភាគ........... | ១៣៣ |

# មាតិកាបត្តានិ

## សត្តមំ ចូឡតណ្ហាសង្ខយសុត្តំ

អង្កេ


| | | | |
|---|---|---|---|
| មហាយមកវគ្គស្ស | ចូឡតណ្ហាសង្ខយសុត្តេ | សង្ខិត្តេន វិមុត្តិកថា............. | ១៣៧ |
| | | សក្កោបសង្កមនំ.................. | ១៣៩ |
| | | វេជយន្តប្បសំសា................. | ១៤១ |
| | | វិមុត្តិកថា ............................ | ១៤៣ |


## អដ្ឋមំ មហាតណ្ហាសង្ខយសុត្តំ


| | | | |
|---|---|---|---|
| មហាយមកវគ្គស្ស | មហាតណ្ហាសង្ខយសុត្តេ | បាបទិដ្ឋិវិវេចនំ..................... | ១៥១ |
| | | តំ ទិដ្ឋាវេចនំ..................... | ១៥៣ |
| | | តំ ទិដ្ឋិបដិបុច្ឆា.................... | ១៥៥ |
| | | វិញ្ញាណុប្បត្តិ....................... | ១៥៩ |
| | | ភូតកថា.............................. | ១៦១ |
| | | ចតុរាហារា.......................... | ១៦៣ |
| | | សមុទយវារោ...................... | ១៦៥ |
| | | បច្ចយនយោ....................... | ១៦៧ |
| | | សមុទយនយោ ................... | ១៧១ |

# សន្ទឹកាចង្អុលប្រាប់មាតិកា

## *ចូឡតណ្ហាសង្ខយសូត្រ ទី ៧*


លេខទំព័រ

| | | | |
|---|---|---|---|
| មហាយមកវគ្គ | ចូឡតណ្ហាសង្ខយសូត្រ | វិមុត្តិកថាដោយសង្ខេប........................... | ១៣៧ |
| | | ការចូលទៅគាល់សក្កទេវរាជ.................. | ១៣៩ |
| | | ការពោលសរសើរវេជយន្តប្រាសាទ......... | ១៤១ |
| | | វិមុត្តិកថា............................................... | ១៤៣ |


## *មហាតណ្ហាសង្ខយសូត្រ ទី ៨*


| | | | |
|---|---|---|---|
| មហាយមកវគ្គ | មហាតណ្ហាសង្ខយសូត្រ | ការដោះទិដ្ឋិអាក្រក់............................... | ១៥១ |
| | | ការក្រាបបង្គំទូលអំពីទិដ្ឋិអាក្រក់របស់ សាតិភិក្ខុ............................................... | ១៥៣ |
| | | ការទ្រង់សួរអំពីទិដ្ឋិអាក្រក់របស់សាតិភិក្ខុ. | ១៥៥ |
| | | ទីកើតនៃវិញ្ញាណ.................................. | ១៥៩ |
| | | ពោលអំពីខន្ធបញ្ចកៈដែលកើតហើយ...... | ១៦១ |
| | | អំពីអាហារ ៤ យ៉ាង.............................. | ១៦៣ |
| | | សមុទយវារៈ.......................................... | ១៦៥ |
| | | បច្ចយន័យ ........................................... | ១៦៧ |
| | | សមុទយន័យ......................................... | ១៧១ |

# មាតិកាបត្តានិ

អង្កេ

មហាយមកវគ្គស្ស មហាតណ្ហាសង្ខយសុត្តេ *និរោធនយោ* ............................ ១៧៣

*ធម្មគុណកថា*........................... ១៧៧

*ទុក្ខក្ខន្ធសមុទយោ*..................... ១៨១

*ពុទ្ធគុណកថា*........................... ១៨៥

*សិក្ខាសាជីវសមាបន្នតា*............ ១៨៧

*ចិត្តបរិសោធនំ*.......................... ១៩១

*ទុក្ខក្ខន្ធនិរោធោ*....................... ១៩៣

## នវមំ មហាអស្សបុរសុត្តំ

មហាយមកវគ្គស្ស មហាអស្សបុរសុត្តេ *ទសសុ បឋមធម្មោ*................... ១៩៧

*ទសសុ តតិយធម្មោ*................. ១៩៩

*ទសសុ បញ្ចមធម្មោ*................ ២០១

*ទសសុ សត្តមធម្មោ*................. ២០៣

*ទសសុ នវមធម្មោ* ................... ២០៥

*បញ្ចូបមា*................................. ២០៩

*ចតូសុ ទុតិយជ្ឈានំ* ................. ២១៣

# សង្ខេបកូនសង្ខេបមាតិកា

លេខទំព័រ


មហាយមកវគ្គ មហាតណ្ហាសង្ខយសូត្រ និរោធន័យ ............................................ ១៧៣

ធម្មគុណកថា ........................................ ១៧៧

ហេតុជាទីកើតនៃកងទុក្ខ........................ ១៨១

ពុទ្ធគុណកថា ........................................ ១៨៥

ភារៈជាអ្នកប្រកបដោយសិក្ខានិងសាជីវៈ ១៨៧

ការជម្រះចិត្ត.......................................... ១៩១

សេចក្ដីរលត់នៃកងទុក្ខ............................ ១៩៣


## មហាអស្សបុរសូត្រ ទី ៩


មហាយមកវគ្គ មហាអស្សបុរសូត្រ បណ្ដាធម៌ទាំង ១០ ធម៌ទី ១ ................ ១៩៧

បណ្ដាធម៌ទាំង ១០ ធម៌ទី ៣................. ១៩៩

បណ្ដាធម៌ទាំង ១០ ធម៌ទី ៥ ................. ២០១

បណ្ដាធម៌ទាំង ១០ ធម៌ទី ៧.................. ២០៣

និយាយពីធម៌ទី ៩ ក្នុងពួកធម៌ ១០........ ២០៥

សេចក្ដីប្រៀបប្រាំយ៉ាង............................ ២០៩

និយាយពីឈានសុខទី ២ ក្នុងពួកឈាន ៤ ២១៣

# មាតិកាបត្តានិ

អង្កេ

មហាយមកវគ្គស្ស មហាអស្សបុរសុត្តេ *ចតូសុ តតិយជ្ឈានំ...................... ២១៥*

*តីសុ បឋមា វិជ្ជា.......................... ២១៧*

*តីសុ តតិយវិជ្ជា........................... ២១៩*

*សត្ត ខីណាសវនាមា .................. ២២១*

## ឧសមំ ចូឡអស្សបុរសុត្តំ

មហាយមកវគ្គស្ស ចូឡអស្សបុរសុត្តេ *សមណសាមីចិប្បដិបទា............... ២២៥*

*សមណទុប្បដិបទា ...................... ២២៧*

*សមណសាមីចិប្បដិបទា .............. ២៣៣*

## ចូឡយមកវគ្គោ

## បឋមំ សាលេយ្យកសុត្តំ

ចូឡយមកវគ្គស្ស សាលេយ្យកសុត្តេ *ពុទ្ធគុណកថា .............................. ២៣៩*

*ទស អកុសលកម្មបថា................. ២៤១*

*ទស កុសលកម្មបថា.................... ២៤៧*

*ធម្មចរិយាសមចរិយាផលំ............. ២៥១*

# សង្ខឹកាចង្អុលប្រាប់មាតិកា

លេខទំព័រ

មហាយមកវគ្គ មហាអស្សបុរសូត្រ និយាយពីឈានសុខទី ៣ ក្នុងពួកឈាន ៤... ២១៥
និយាយពីវិជ្ជាទី ១ ក្នុងពួកវិជ្ជា ៣.............. ២១៧
និយាយពីវិជ្ជាទី ៣ ក្នុងពួកវិជ្ជា ៣.............. ២១៩
ឈ្មោះរបស់ព្រះខីណាស្រព ៧ ប្រការ......... ២២១

## *ចូឡអស្សបុរសូត្រ ទី ១០*

មហាយមកវគ្គ ចូឡអស្សបុរសូត្រ បដិបទាដ៏សមគួរដល់សមណៈ..................... ២២៥
បដិបទាខុសរបស់សមណៈ.......................... ២២៧
បដិបទាដ៏សមគួរដល់សមណៈ..................... ២៣៣

# ចូឡយមកវគ្គ

## *សាលេយ្យកសូត្រ ទី ១*

ចូឡយមកវគ្គ សាលេយ្យកសូត្រ ពុទ្ធគុណកថា............................................. ២៣៩
អកុសលកម្មបថ ១០.................................. ២៤១
កុសលកម្មបថ ១០.................................... ២៤៧
ផលនៃកិរិយាប្រព្រឹត្តស្មើពោលគឺប្រព្រឹត្តតាមធម៌ ២៥១

# មាតិកាបត្តានិ

## ទុតិយំ វេរញ្ជកសុត្តំ

អង្កេ

ចូឡយមកវគ្គស្ស វេរញ្ជកសុត្តេ *ទស អកុសលកម្មបថា* ........................ ២៥៧
*ទស កុសលកម្មបថា* ........................ ២៦១
*ធម្មចរិយាសមចរិយាផលំ* ................. ២៦៣
*បាណាបេតសរណាគតតា* .................. ២៦៧

## តតិយំ មហាវេទល្លសុត្តំ

ចូឡយមកវគ្គស្ស មហាវេទល្លសុត្តេ *បញ្ញាវាទិប្បញ្ហា* ................................. ២៦៩
*វេទនាទិប្បញ្ហា* ................................. ២៧១
*ទ្វេ បច្ចយា* ....................................... ២៧៣
*បញ្ចង្គិកំ បឋមជ្ឈានំ* ........................ ២៧៥
*បញ្ចិន្ទ្រិយានិ* ................................... ២៧៧
*ទ្វេបុគ្គលប្បភេទោ* ............................ ២៧៩
*បច្ចយប្បញ្ហា* ................................... ២៨១
*ចតុចេតោវិមុត្តិយោ* ............................ ២៨៣

# សង្ខិកាចង្អុលប្រាប់មាតិកា

## *វេរញ្ជកសូត្រ ទី ២*

លេខទំព័រ


| | | | |
|---|---|---|---|
| ចូឡយមកវគ្គ | វេរញ្ជកសូត្រ | អកុសលកម្មបថ ១០ ................................ | ២៥៧ |
| | | កុសលកម្មបថ ១០...................................... | ២៦១ |
| | | ផលនៃកិរិយាប្រព្រឹត្តធម៌និងប្រព្រឹត្តស្មើ ........ | ២៦៣ |
| | | ភាវៈជាអ្នកដល់នូវសរណៈស្មើដោយជីវិត ..... | ២៦៧ |


## *មហាវេទល្លសូត្រ ទី ៣*


| | | | |
|---|---|---|---|
| ចូឡយមកវគ្គ | មហាវេទល្លសូត្រ | ប្រស្នាសួរអំពីបុគ្គលមានប្រាជ្ញាជាដើម.......... | ២៦៩ |
| | | ប្រស្នាសួរអំពីវេទនាជាដើម........................... | ២៧១ |
| | | បច្ច័យ ២ ប្រការ.......................................... | ២៧៣ |
| | | បឋមជ្ឈានប្រកបដោយអង្គ ៥...................... | ២៧៥ |
| | | ឥន្ទ្រិយ ៥ ប្រការ ....................................... | ២៧៧ |
| | | ដំណើរផ្សេងគ្នានៃបុគ្គលពីរពួក..................... | ២៧៩ |
| | | សួរពីបច្ច័យ................................................. | ២៨១ |
| | | និយាយពីចេតោវិមុត្តិ ៤............................... | ២៨៣ |

# មាតិកាបត្តានិ

អង្កេ

ចូឡយមកវគ្គស្ស មហាវេទល្លសុត្តេ *អាយស្មតោ សារីបុត្តស្ស*

*ភាសិតស្ស អភិនន្ទនំ*........................ ២៨៧

## ចតុត្ថំ ចូឡវេទល្លសុត្តំ

ចូឡយមកវគ្គស្ស ចូឡវេទល្លសុត្តេ *សក្កាយសមុទយប្បញ្ហា*.................... ២៨៩

*សក្កាយទិដ្ឋិប្បញ្ហា*........................... ២៩១

*មគ្គប្បញ្ហា*....................................... ២៩៣

*និរោធប្បញ្ហា*.................................. ២៩៥

*វេទនាបញ្ហា*.................................... ២៩៧

*អនុសយប្បញ្ហា*................................ ២៩៩

*បដិភាគប្បញ្ហា*................................ ៣០១

*ធម្មទិន្នាបសំសា*.............................. ៣០៣

## បញ្ចមំ ចូឡធម្មសមាទានសុត្តំ

ចូឡយមកវគ្គស្ស ចូឡធម្មសមាទានសុត្តេ *បឋមំ ធម្មសមាទានំ* ..................... ៣០៥

*ទុតិយំ ធម្មសមាទានំ*.................... ៣១១

*តតិយចតុត្ថធម្មសមាទានំ*............. ៣១៣

# សង្ខឹកាចង្អុលប្រាប់មាតិកា

លេខទំព័រ


| | | | |
|---|---|---|---|
| ចូឡយមកវគ្គ | មហាវេទល្លសូត្រ | សេចក្តីត្រេកអរចំពោះភាសិតរបស់ព្រះសារីបុត្រមានអាយុ................................ | ២៨៧ |

## ចូឡវេទល្លសូត្រ ទី ៤

| | | | |
|---|---|---|---|
| ចូឡយមកវគ្គ | ចូឡវេទល្លសូត្រ | សួរពីហេតុដែលនាំឲ្យកើតសក្កាយៈ......... | ២៨៩ |
| | | សួរពីសក្កាយទិដ្ឋិ.................................... | ២៩១ |
| | | សួរពីមគ្គ................................................ | ២៩៣ |
| | | សួរពីនិរោធ............................................ | ២៩៥ |
| | | វេទនាបញ្ហា............................................ | ២៩៧ |
| | | អនុសយប្បញ្ហា....................................... | ២៩៩ |
| | | បដិភាគប្បញ្ហា....................................... | ៣០១ |
| | | ការទ្រង់សរសើរធម្មទិន្នាភិក្ខុនី................. | ៣០៣ |

## ចូឡធម្មសមាទានសូត្រ ទី ៥

| | | | |
|---|---|---|---|
| ចូឡយមកវគ្គ | ចូឡធម្មសមាទានសូត្រ | ធម្មសមាទានទី ១................................. | ៣០៥ |
| | | ធម្មសមាទានទី ២................................. | ៣១១ |
| | | ធម្មសមាទានទី ៣ និងទី ៤................. | ៣១៣ |

# មាតិកាបត្តានិ

## ឆដ្ឋំ មហាធម្មសមាទានសុត្តំ

អង្កេ

ចូឡយមកវគ្គស្ស មហាធម្មសមាទានសុត្តេ *សេវិតព្វាសេវិតព្វធម្មា* ............. ៣១៧
*អវិជ្ជាគតគតិ*............................ ៣១៩
*វិជ្ជាគតគតិ*............................... ៣២៣
*បឋមំ ធម្មសមាទានំ* ............... ៣២៥
*ទុតិយំ ធម្មសមាទានំ*............... ៣២៧
*តតិយំ ធម្មសមាទានំ* .............. ៣២៩
*ចតុត្ថំ ធម្មសមាទានំ*................ ៣៣១
*ទុតិយោបមា* ............................៣៣៣
*បញ្ចមោបមា*............................ ៣៣៥

## សត្តមំ វីមំសកសុត្តំ

ចូឡយមកវគ្គស្ស វីមំសកសុត្តេ *ធម្មសមន្នេសនា*........................ ៣៣៩
*ឧត្តរឹ បដិបុច្ឆា*.......................... ៣៤៣
*តថាគតអចលសទ្ធា*................. ៣៤៥

# សន្លឹកចង្អុលប្រាប់មាតិកា

## *មហាធម្មសមាទានសូត្រ ទី ៦*


| | | | |
|---|---|---|---|
| ចូឡយមកវគ្គ | មហាធម្មសមាទានសូត្រ | ធម៌ដែលគួរសេពនិងមិនគួរសេព........ | ៣១៧ |
| | | គតិនៃអវិជ្ជា..................................... | ៣១៩ |
| | | គតិនៃវិជ្ជា......................................... | ៣២៣ |
| | | ធម្មសមាទានទី ១............................ | ៣២៥ |
| | | ធម្មសមាទានទី ២........................... | ៣២៧ |
| | | ធម្មសមាទានទី ៣........................... | ៣២៩ |
| | | ធម្មសមាទានទី ៤............................ | ៣៣១ |
| | | ឧបមាទី ២....................................... | ៣៣៣ |
| | | ឧបមាទី ៥...................................... | ៣៣៥ |


## *វីមំសកសូត្រ ទី ៧*


| | | | |
|---|---|---|---|
| ចូឡយមកវគ្គ | វីមំសកសូត្រ | ការស្វែងរកធម៌................................ | ៣៣៩ |
| | | ការសាកសួរតទៅទៀត ................... | ៣៤៣ |
| | | សេចក្ដីជឿមិនរំភើបក្នុងព្រះតថាគត... | ៣៤៥ |

# មាតិកាបត្ថានិ

## អដ្ឋមំ កោសម្ពិយសុត្តំ

អង្កេ

| | | | |
|---|---|---|---|
| ចូឡយមកវគ្គស្ស | កោសម្ពិយសុត្តេ | *កោសម្ពិកានំ បដិបុច្ឆា..............* | *៣៤៧* |
| | | *ឆ សារាណីយធម្មា ................* | *៣៤៩* |
| | | *សត្តង្គេសុ បឋមញ្ញាណំ..........* | *៣៥៣* |
| | | *សត្តង្គេសុ តតិយចតុត្ថ-ញ្ញាណំ....................................* | *៣៥៥* |
| | | *សត្តង្គេសុ បញ្ចមញ្ញាណំ.........* | *៣៥៧* |
| | | *សត្តង្គេសុ សត្តមញ្ញាណំ .........* | *៣៥៩* |

## នវមំ ព្រហ្មនិមន្តនិកសុត្តំ

| | | | |
|---|---|---|---|
| ចូឡយមកវគ្គស្ស | ព្រហ្មនិមន្តនិកសុត្តេ | *មារន្វាវិសនំ..............................* | *៣៦៣* |
| | | *ពកស្ស ទិដ្ឋិវិវេចនំ...................* | *៣៦៧* |
| | | *អច្ឆរិយព្ភុតំ..............................* | *៣៧៣* |
| | | *មារន្វាវិសនំ ............................* | *៣៧៥* |

# សន្លឹកចង្អុលប្រាប់មាតិកា

## កោសម្ពិយសូត្រ ទី ៨

លេខទំព័រ


| | | | |
|---|---|---|---|
| ចូឡយមកវគ្គ | កោសម្ពិយសូត្រ | ការទ្រង់សាកសួរពួកភិក្ខុនៅក្នុងកោសម្ពី... | ៣៤៧ |
| | | សារាណីយធម៌ ៦ ប្រការ...................... | ៣៤៩ |
| | | ញាណទី ១ ក្នុងអង្គ ៧......................... | ៣៥៣ |
| | | ញាណទី ៣ និងទី ៤ ក្នុងអង្គ ៧......... | ៣៥៥ |
| | | ញាណទី ៥ ក្នុងអង្គ ៧......................... | ៣៥៧ |
| | | ញាណទី ៧ ក្នុងអង្គ ៧......................... | ៣៥៩ |


## ព្រហ្មនិមន្តនិកសូត្រ ទី ៩


| | | | |
|---|---|---|---|
| ចូឡយមកវគ្គ | ព្រហ្មនិមន្តនិកសូត្រ | មារចូលជ្រៀតជ្រែក................................ | ៣៦៣ |
| | | ការទ្រង់ដោះទិដ្ឋិរបស់ពកព្រហ្ម................ | ៣៦៧ |
| | | សេចក្តីអស្ចារ្យមិនធ្លាប់មាន..................... | ៣៧៣ |
| | | មារចូលជ្រៀតជ្រែក................................ | ៣៧៥ |

# មាតិកាបត្តានិ

## ឧសមំ មារតជ្ជនីយសុត្តំ

អង្កេ

ចូឡយមកវគ្គស្ស មារតជ្ជនីយសុត្តេ *មារបរិវិតក្កោ................................ ៣៨១*

*ភូតបុព្វវត្ថុ..................................... ៣៨៣*

*មារបរិវិតក្កោ................................ ៣៨៥*

*គទ្រភោបមា................................. ៣៨៧*

*កកុសន្ធោវាទោ ............................ ៣៨៩*

*តយោ មហានិរយោ ...................... ៣៩៣*

*អវសានគាថា................................ ៣៩៥*

*ឧទ្ទានគាថា.................................. ៤០១*

# សង្ខេបចង្អុលប្រាប់មាតិកា

## *មារតជ្ជនីយសូត្រ ទី ១០*

លេខទំព័រ

| | | | |
|---|---|---|---|
| ចូឡយមកវគ្គ | មារតជ្ជនីយសូត្រ | សេចក្ដីបរិវិតក្កនៃមារ ............................ | ៣៨១ |
| | | រឿងធ្លាប់មានមកហើយ .......................... | ៣៨៣ |
| | | សេចក្ដីបរិវិតក្កនៃមារ.............................. | ៣៨៥ |
| | | ឧបមាដោយសត្វលា.............................. | ៣៨៧ |
| | | ឱវាទនៃព្រះកកុសន្ធៈជាម្ចាស់ ................ | ៣៨៩ |
| | | មហានរកទាំង ៣ ................................ | ៣៩៣ |
| | | គាថាជាទីបំផុត...................................... | ៣៩៥ |
| | | ឧទ្ទានគាថា........................................... | ៤០១ |

